# របត់នយោបាយ

## សីហនុ - លន់ នល់ - ប៉ុល ពត - ជា ស៊ីម - ហេង សំរិន - ហ៊ុន សែន






## ភាគ ៦




(ពីឆ្នាំ ១៩៦៨ ដល់ឆ្នាំ ១៩៧០)








# របត់នយោបាយ

សីហនុ - លន់ នល់ - ប៉ុល ពត - ជា ស៊ីម - ហេង សំរិន - ហ៊ុន សែន

ភាគ ៦

ហាមថតចម្លង

ស្នាដៃនេះត្រូវបានចុះបញ្ជីលេខ Ⓡ ៦៨៣/២១ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២១ នៅនាយកដ្ឋានសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល នៃក្រសួង វប្បធម៌ និងវិចិត្រសិល្បៈ។

**-សហការីពិនិត្យអក្ខរាវិរុទ្ធ៖**

ឯកឧត្ដម អេង វុទ្ធី អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ

វេជ្ជបណ្ឌិត អ៊ុន សុវណ្ណា

**-ការីកុំព្យូទ័រ**

ធូ កុសល ប្រធានក្រុម

ឈឹម មករា

ប៉ោ កុសល

ចាន់ ពិសុទ្ធ

ឈឹម ពុទ្ធី

រក្សាសិទ្ធិ©ឈឹម សេរីភ្នួន គ.ស.២០២៤

ISBN-13 : 978-9924-9698-4-6

# អារម្ភកថា

ចំពោះសៀវភៅឯកសារប្រវត្តិសាស្ត្ររបត់នយោបាយភាគទី៦នេះ ខ្ញុំបាទបានសិក្សាស្រាវជ្រាវពីមូលហេតុ ដែលនាំឲ្យមានព្រឹត្តិការណ៍រដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ និងលទ្ធផល ដែលមិននឹកស្មានដល់ នៃការធ្វើរដ្ឋប្រហារគួរឱ្យព្រឺខ្លាចមួយនេះផងដែរ ។

ក្រោយរដ្ឋប្រហារនោះ មេដឹកនាំខ្មែរទាំងសងខាងបានតាំងខ្លួនជាអ្នកស្នេហាជាតិ ប្រឆាំងនឹងពួកបរទេសឈ្លានពានតែរៀងៗខ្លួន។

ការពិត ម្ខាងទៅពឹងពួកវៀតកុង-វៀតណាមខាងជើង និងចិន ឯម្ខាងទៀតទៅពឹងពួកវៀតណាមខាងត្បូង និងសហរដ្ឋអាមេរិក។

លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្ដេចសីហនុ ពីអំណាចរាជានិយមផ្ដាច់ការ ដើម្បីបង្កើតរបបសាធារណរដ្ឋខ្មែរ មានសេរីភាព សមភាព ភាតរភាព វឌ្ឍនភាព និងសុភមង្គល តែអ្នកទទួលផលពិតប្រាកដ គឺមេដឹកនាំខ្មែរក្រហម ប៉ុល ពត មានឱកាសពង្រីកឥទ្ធិពលលទ្ធិកុម្មុយនិស្តរបស់ខ្លួនយ៉ាងឆាប់រហ័សក្នុងការធ្វើសង្គ្រាមបដិវត្ត នាំមកនូវរបបថ្មីមួយទៀត ដែលគ្មានការបែងចែកវណ្ណៈ, គ្មានអ្នកមាន គ្មានអ្នកក្រ, គ្មានអ្នកជិះជាន់ និងគ្មានអ្នកដែលត្រូវគេជិះជាន់...។

សង្គ្រាមមនោគមវិជ្ជា ធ្វើឱ្យខ្មែរវងទុក្ខវេទនាឈឺចាប់ខ្លោចផ្សា ស្គាល់តែវិនាសកម្ម ដែលគួរចងចាំដល់អ្នកនយោបាយខ្មែរជំនាន់ក្រោយៗ កុំបណ្ដែតបណ្ដោយឱ្យជ្រុលខ្លួនជាន់ដានប្រវត្តិសាស្ត្របែបនេះទៀត។

ឆ្លៀតឱកាសនេះដែរ ខ្ញុំបាទក៏សូមលំឱនកាយគោរពចំពោះឧត្តមគតិ និងមនសិការប្រវត្តិសាស្ត្រដ៏ថ្លៃថ្លារបស់សម្ដេចក្រឡាហោម ស ខេង ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ ដែលបានជួយឧបត្ថម្ភទាំងស្រុងដល់ការបោះពុម្ពសៀវភៅនេះ តាំងពីភាគទី១មក ដើម្បីកូនខ្មែរជំនាន់ក្រោយៗទៀតបានអានពិចារណា និងសិក្សារៀនសូត្រផងដែរ។

ជាទីបញ្ចប់នេះ ប្រសិនបើមានចំណុចខុសឆ្គងខ្វះខាត ឬលើសលស់ត្រង់ចំណុចណាមួយសូមសម្ដេច ទ្រង់ ឯកឧត្តម អស់លោក លោកស្រី និងប្រិយមិត្តអ្នកអានទាំងអស់ មេត្តាខន្តីអភ័យទោសដោយក្ដីអនុគ្រោះ។

ថ្ងៃចន្ទ ១១កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ពុទ្ធសករាជ២៥៦៨
រាជធានីភ្នំពេញ ត្រូវនឹងថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២៤

**ឈឹម សេរីឆ្នួន**

# មាតិកា

- ២៥២ វរសេនីយ៍ឯកសុស្តែន រាយការណ៍ពីទីតាំងវៀតកុងញ៉ឹក ជូឡុង ថាះ ហ្វែង ចង់ចូលគុកឬ? ........ ១
- ២៥៣ សម រង្ស៊ី និងសូម្ប៉ា ចាប់ផ្តើមស្នេហានៅទីក្រុងប៉ារីស ........ ១១
- ២៥៤ សម រង្ស៊ី ទម្លាយអាថ៌កំបាំងពីការបាត់ខ្លួន សម សារី ជាឪពុក ........ ២០
- ២៥៥ សម្តេចសីហនុ ថតភាពយន្ត និងបើកកាស៊ីណូ ........ ២៥
- ២៥៦ សម្តេចសីហនុ ចង់ភ្ជាប់ទំនាក់ទំនងការទូតជាមួយអាមេរិកឡើងវិញ ........ ៣០
- ២៥៧ សម្តេចសីហនុ បង្ហាញទីតាំង និងសកម្មភាពកងទ័ពវៀតកុងនៅក្នុងទឹកដីខ្មែរ ........ ៣៩
- ២៥៨ សម្តេចសីហនុ ប្រកាសទទួលស្គាល់រដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្នវៀតណាមខាងត្បូង ........ ៤៥
- ២៥៩ សម្តេចសីហនុ បណ្តោយឱ្យអាមេរិក មកទម្លាក់គ្រាប់បែកលើពួកវៀតកុងនៅក្នុងទឹកដីកម្ពុជា ........ ៥២
- ២៦០ ជីវភាពប្រជាព្រាស្តខ្មែរក្នុងសម័យទសវត្សរ៍ឆ្នាំ១៩៦០ ........ ៥៦
- ២៦១ សម្តេចសីហនុ បង្កើតរាជរដ្ឋាភិបាលស្រោចស្រង់ជាតិ ........ ៦២
- ២៦២ សម្តេចសីហនុ ធ្វើបុណ្យឧទ្ទិសកុសលដល់សព ហូ ជីមិញ លន់ នល់ និងទ្រង់សិរិមតៈ មិនចូលរួម ........ ៧១
- ២៦៣ សម្តេចសីហនុ ទៅចូលរួមបុណ្យសពហូ ជីមិញ ទ្រង់សិរិមតៈ ចាត់ទុកថាជាអំពើក្បត់ជាតិ ........ ៧៦
- ២៦៤ ទ្រង់សិរិមតៈ ចង់កាច់បំបាក់អំណាចសម្តេចសីហនុ ........ ៨៦
- ២៦៥ សម្តេចព្រះសង្ឃរាជជួន ណាត សោយទិវង្គត ........ ៩០
- ២៦៦ ការប្រយុទ្ធតស៊ូរបស់ពួកខ្មែរក្រហម ជាមួយទាហានរាជរដ្ឋាភិបាល ........ ៩៨
- ២៦៧ ទំនាស់រវាងសម្តេចសីហនុ និងទ្រង់សិរិមតៈ កាន់តែមុតស្រួចៗទៅ ........ ១០៣
- ២៦៨ សម្តេចសីហនុ យាងទៅប្រទេសបារាំង លន់ នល់ ប្រឈមមុខជាមួយ

កងទ័ពវៀតកុង ........ ១១១
- ២៦៩ បាតុកម្មវាយស្ថានទូតវៀតកុង-វៀតណាមខាងជើង ........ ១២០
- ២៧០ លន់ នល់ ឱ្យវៀតកុង ដកកងទ័ពទាំងអស់ ចេញពីទឹកដីកម្ពុជា ឱ្យបានមុនថ្ងៃទី១៥ មីនា ........ ១៣០
- ២៧១ បាតុកម្មនៅមុខរដ្ឋសភា ទាមទាររកមុខអ្នកលក់ដីឱ្យវៀតកុង ........ ១៤០
- ២៧២ តំណាងរាស្ត្រឡើងមានមតិរិះគន់ វាយប្រហារសម្តេចសីហនុ ........ ១៤៧
- ២៧៣ ថ្ងៃ១៨មីនា រដ្ឋប្រហារទម្លាក់សម្តេចសីហនុ ចេញពីអំណាច ........ ១៥៧
- ២៧៤ សហរដ្ឋអាមេរិក មានជាប់ពាក់ព័ន្ធនឹងរដ្ឋប្រហារថ្ងៃ១៨មីនា? ........ ១៦៥
- ២៧៥ លន់ ណុន ជាមនុស្សសំខាន់ម្នាក់ ក្នុងការធ្វើរដ្ឋប្រហារទម្លាក់សម្តេចសីហនុ ........ ១៧១
- ២៧៦ សុទ្ធ ប៉ូលីន ស្រក់ទឹកភ្នែក អាណិតសម្តេចសីហនុ ........ ១៧៩
- ២៧៧ ដូ អេនឡាយ និងផាំ វ៉ាន់ដុង ជំរុញឱ្យសីហនុ បង្កើតរណសិរ្សរួបរួមជាតិកម្ពុជា ........ ១៨៤
- ២៧៨ ប្រជាកសិករនាំគ្នាសម្លាប់តំណាងរាស្ត្រ២រូប និងប្អូនលន់ នល់ ទាមទារយកសម្តេចឪ មកវិញ ........ ១៩៣
- ២៧៩ អង្គការសហប្រជាជាតិ ទទួលស្គាល់រដ្ឋាភិបាល លន់ នល់ ........ ២០៤
- ២៨០ ឧត្តមសេនីយ៍លន់ នល់ សន្យាបង្កើតរបបសាធារណរដ្ឋខ្មែរ ........ ២១៣
- ២៨១ ប្រធានាធិបតី និចសុន បញ្ជាឱ្យកងទ័ពអាមេរិក និងវៀតណាមខាងត្បូងចូលទៅជួយទាហានលន់ នល់ ........ ២២២
- ២៨២ ទាហានលន់ នល់ សម្លាប់ និងបញ្ជូនអាណិកជនវៀតណាម ចេញពីទឹកដីកម្ពុជា ........ ២៣៤
- ២៨៣ សម្តេចសីហនុ បង្កើតរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ម៉ៅ សេទុង ថាព្រះអង្គស័ក្តិសមជនកុម្មុយនិស្ត ........ ២៤១
- ២៨៤ គោលជំហរមេដឹកនាំប្រទេសជាមិត្ត របស់សម្តេចសីហនុ ក្រោយរដ្ឋប្រហារ ........ ២៥៣

- ២៨៥ កងទ័ពអាមេរិក និងវៀតណាមខាងត្បូង ចូលមកវាយកម្ទាត់កងទ័ពវៀតកុង ក្នុងទឹកដីកម្ពុជា ..... ២៦២
- ២៨៦ លន់ នល់ ស្ដារទំនាក់ទំនងការទូត ជាមួយវៀតណាមខាងត្បូង ឡើងវិញ ..... ២៦៩
- ២៨៧ អតីតខ្មែរវៀតមិញ នៅហាណូយ ត្រលប់មកជួយធ្វើសង្គ្រាមផ្ដួលរម្លំរបប លន់ នល់ ..... ២៧៨
- ២៨៨ កាំង ហ្គេចអ៊ាវ រួចពីគុកព្រៃស រត់ទៅតស៊ូបន្តទៀត ..... ២៩០
- ២៨៩ សោ ភឹម សហការជាមួយពួកវៀតកុង ធ្វើសង្គ្រាមជាមួយទាហានអាមេរិក និងរដ្ឋការក្រុងព្រៃនគរ ..... ២៩៤

---

# ២៥២
# វរសេនីយ៍ឯកសុស្តែន រាយការណ៍ពីទីតាំងវៀតកុង ញ៉ឹក ជូឡុង ថាះ ហ្គេង ចង់ចូលកុកម្ម?



ឧត្តមសេនីយ៍ទោសុស្តែន ហ្វែរណង់ដេស នាយអគ្គសេនាធិការកងទ័ព
សាធារណរដ្ឋខ្មែរ

*សុស្តែន ហ្វែរណង់ដេស កើតនៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩២៣ មានស្រុកកំណើតនៅខេត្តពោធិ៍សាត់។ ឪពុក ឈ្មោះសាំសុង ហ្វែរណង់ដេស ធ្លាប់ជារដ្ឋមន្ត្រី ជាតំណាងរាស្ត្រ និងជាចាងហ្វាងទទួលពាក្យបណ្តឹងប្រជារាស្ត្រ នៅក្នុងព្រះបរមរាជវាំង និងម្តាយឈ្មោះម៉ារីយ៉ា សឹង។ ប្រពន្ធឈ្មោះខាំ ផង ជាអ្នកខេត្តបាត់ដំបង រៀបការនៅក្នុងឆ្នាំ១៩៥១។ មានកូន៧នាក់ (ស្រី៥ ប្រុស២) ។*

*សុស្តែន ហ្វែរណង់ដេស បានឱ្យដឹងថា ក្នុងខែសីហា ឆ្នាំ១៨៨៤ អគ្គទេសាភិបាលបារាំង ប្រចាំនៅដែនដីកូសាំងស៊ីន បានរៀបចំឲ្យព្រះមហាក្សត្រនរោត្តម ធ្វើដំណើរយាងទស្សនកិច្ចនៅទីក្រុងហុងកុង, ទីក្រុងម៉ានីល, ទីក្រុងម៉ាកាវ និងប្រទេសសិង្ហបុរី ដែលជាទឹកដីអាណានិគមរបស់ប្រទេសអង់គ្លេស ដើម្បីឲ្យ ព្រះអង្គទតឃើញពី*

ការលូតលាស់រីកចម្រើននៅតាមប្រទេសទាំងអស់នោះ។ នៅពេលយាងទៅដល់ក្រុងម៉ានីល ស្ដេចហ្វីលីពីន ក៏បានយកក្រុមភ្លេងព្រះរាជវាំង ដែលគេហៅថា ហ្វង់ហ្វារ៉ូយ៉ាល់ មកប្រគំទទួលស្វាគមន៍ព្រះអង្គ ។

បន្ទាប់មកទៀត ក្នុងពិធីជប់លៀងជាកិត្តិយសមួយថ្វាយព្រះអង្គ ក្រុមភ្លេងព្រះរាជវាំងហ្វង់ហ្វារ៉ូយ៉ាល់នោះក៏បានមកប្រគំបទចម្រៀង តាមលំនាំបទភ្លេងខ្មែរ ពីរោះខ្លាំងពេក ធ្វើឱ្យព្រះបាទនរោត្តម សព្វព្រះទ័យនឹងភ្លេងនោះកាន់តែខ្លាំងឡើង ព្រះអង្គក៏បានស្នើសុំស្ដេចហ្វីលីពីន យកតន្ត្រីករជាអ្នកប្រគំបទចម្រៀងនោះ ក្នុងនោះក៏មានឈ្មោះ ហ្វៀរណង់ដេស ជាជីតាទួតគាត់ម្នាក់ដែរ ឱ្យមករស់នៅក្នុងរាជធានីភ្នំពេញ ជួយបង្ហាត់បង្រៀនតន្ត្រីករខ្មែរបន្តទៀត ដើម្បីបង្កើតក្រុមភ្លេងហ្វង់ហ្វារ៉ូយ៉ាល់ នៅក្នុងព្រះបរមរាជវាំង ដូចស្ដេចហ្វីលីពីន ដែរ។ ជីតាទួត ជីតា និងឪពុកគាត់សុទ្ធតែជាអ្នកកាន់សាសនាកាតូលិកដូចគ្នា។ ពូជពង្សវង្សត្រកូលរបស់គាត់បានមករស់នៅប្រទេសខ្មែរ អស់៣-៤ជំនាន់មកហើយ ដូច្នេះមិនគួរចាំបាច់តម្រូវឱ្យគាត់ពន្យល់បំភ្លឺថា គាត់ជាខ្មែរ ឬមិនមែនខ្មែរទៀតនោះទេ ព្រោះមើលតែមុខទៅ នរណាក៏ដឹងថា គាត់ជាខ្មែរដែរ ។

សុស្តែន ហ្វៀរណង់ដេស បានរៀបរាប់ថា នៅក្នុងឆ្នាំ១៩៤៦ ពួកអាណានិគមបារាំង បានបញ្ជូនយុវសិស្សខ្មែរ ប្រមាណ១០នាក់ ក្នុងនោះមាន សក់ ស៊ុតសាខន, ហ៊ូ ហង់ស៊ីន, ស្រី សាម៉ន, អ៊ុយ សយ, ឋាប្បនា ងិន និងប៉ុក សំអាន ជាដើម ឱ្យទៅរៀនជាសិស្សនាយទាហានជំនាន់ទី១ នៅប្រទេសបារាំង ហើយរៀនតែក្នុងរយៈពេល៦ខែប៉ុណ្ណោះ ព្រោះត្រូវប្រញាប់វិលត្រលប់មកទទួលភារកិច្ចនៅតាមអង្គភាពកងទ័ពខ្មែរ ជំនួសនាយទាហានបារាំង នៅក្នុងប្រទេសកម្ពុជា វិញ ។

បន្ទាប់មកទៀត អំឡុងពាក់កណ្ដាលឆ្នាំ១៩៤៦ ដល់ពាក់កណ្ដាលឆ្នាំ១៩៤៧ គាត់ និងយុវជនខ្មែរចំនួនប្រមាណ ១០នាក់ទៀត ត្រូវបារាំង បញ្ជូនឱ្យទៅរៀនជាសិស្សនាយទាហានជំនាន់ទី២ នៅប្រទេសបារាំង រយៈពេល១ឆ្នាំ ។

សិស្សនាយទាហានជំនាន់ទី២ រួមមាន ក្រូច សំរេច, ពៅ លឹមវ៉ា, អ៊ុក ហ៊ូ និង អ៊ុំ ម៉ាន្នូរិន (បងថ្លៃ សម្ដេចសីហនុ) ជាមិត្តភក្តិជិតស្និទ្ធបំផុតរបស់គាត់ម្នាក់ផងដែរ។

ក្រោយបញ្ចប់ការសិក្សាពីសាលាយោធាបារាំង ពួកគាត់បានពាក់សក្តិ១ ហើយត្រូវបែងចែក ខ្លះឱ្យទៅបម្រើការងារជាមន្ត្រីយោធានៅក្រសួងការពារជាតិ, ខ្លះទៀតឱ្យទៅធ្វើការនៅអគ្គសេនាធិការដ្ឋានកងទ័ព ។

ចំណែករូបគាត់ចង់តែទៅបម្រើការងារនៅអង្គភាពណា ឬទីណា ដែលត្រូវចេញប្រយុទ្ធតតាំងជាមួយសត្រូវចូលមកឈ្លានពានតែប៉ុណ្ណោះ ពិសេសនៅខេត្តបាត់ដំបង ដែលជាសម្បុករបស់កងទ័ពយួនវៀតមិញ ដែលចូលមកសាបព្រោះ លទ្ធិកុម្មុយនិស្តនៅក្នុងប្រទេសកម្ពុជា។ តែយ៉ាងណា ពួកគាត់ជានាយទាហានខ្មែរទាំងជំនាន់ទី១ ទាំងជំនាន់ទី២ គ្មានបទពិសោធ និងមានសមត្ថភាពគ្រប់គ្រាន់ ដូចកងទ័ពយួនវៀតមិញ ដែលធ្វើសង្គ្រាមជាមួយទាហានបារាំង ជាយូរឆ្នាំមកហើយនោះដែរ ។

សុស្តែន ហ្វែរណង់ដេស បានបន្តថា មកដល់សម័យសង្គមរាស្ត្រនិយម មេដឹកនាំយើង មិនសូវគិតគូរពីរឿងការពារព្រំដែនទេ។ បែរជាយកពួកទាហានទៅឱ្យធ្វើផ្លូវ ទៅជួយសាងសង់ផ្ទះ ទៅជួយធ្វើស្រែចំការរបស់ប្រជារាស្ត្រទៅវិញ មិនទុកពេលវេលា ឱ្យពួកទាហានហ្វឹកហ្វឺនក្បួនយុទ្ធសាស្ត្រ ដើម្បីការពារខ្មាំងសត្រូវជាប្រទេសជិតខាងចូលមកឈ្លានពានទេ  ព្រោះថា ក្រោយពីសត្រូវយួនដណ្ដើមយកកូសាំងស៊ីន (ទឹកដីកម្ពុជាក្រោម) បានហើយ ពួកគេនៅតែលួចបង្ខិតព្រំដែនខាងកើត ដូចសត្រូវសៀម នៅខាងលិចដែរ។ តែយ៉ាងណា កាលសម័យសង្គមរាស្ត្រនិយម ដឹកនាំដោយសម្ដេចសីហនុ ព្រះអង្គមានកិត្តិយសកេរ្តិ៍ឈ្មោះល្បីល្បាញ អាចទប់ទល់តាមផ្លូវនយោបាយក្នុងការការពារ ព្រំដែន ពិសេសព្រះអង្គបានទាមទារតាមផ្លូវច្បាប់ យកប្រាសាទព្រះវិហារ បានពីសៀម មកវិញ។

សម័យសង្គមរាស្ត្រនិយមមានការរីកចម្រើនលើគ្រប់វិស័យ ដូចជាសាលារៀន មន្ទីរពេទ្យ សមិទ្ធិផ្សេងៗទៀតរីកចម្រើនព្រោងព្រាតដូចផ្សិតត្រូវទឹកភ្លៀង។ តែអកុសល

សម្ដេចឪយើង ព្រះអង្គទាក់ទងកសាងមិត្តភាពជាមួយចិនកុម្មុយនិស្ត។ ពេលព្រះអង្គយាងទៅប្រទេសចិនម្ដងៗ មានកូនសិស្ស និងប្រជាជនចិន រាប់លាននាក់ កាន់ទង់ជ័យបក់ទទួលស្វាគមន៍ ដោយស្រែកលាន់រំពងថា៖ ជយោ! សម្ដេចសីហនុៗៗៗ ...យ៉ាងអធិកអធមបំផុត ។

លុះពេលត្រលប់មកពីប្រជុំនៅសន្និសីទនាក្រុងបានឌុង( ប្រទេសឥណ្ឌូនេស៊ី) ខែមេសា ឆ្នាំ១៩៥៥ ព្រះអង្គលែងប្រកាន់យកមាគ៌ានយោបាយអព្យាក្រឹតទៀត ព្រះអង្គងាកទៅគាំទ្រចិន រួចហើយបើកទ្វារឱ្យយួនវៀតកុង-វៀតណាម ខាងជើង ចូលមកបោះទីតាំងកងទ័ពនៅក្នុងទឹកដីខ្មែរយើង ដើម្បីធ្វើសង្គ្រាមជាមួយអាមេរិក ដែលជាសម្ព័ន្ធមិត្តរបស់ ប្រទេសវៀតណាមខាងត្បូង ។

ពេលនោះ ព្រះអង្គជាសម្ដេចឪរបស់យើងទាំងអស់គ្នាទៅហើយ ចង់ព្រះអង្គដូរទិសនយោបាយទៅខាងណា គឺស្រេចនៅលើព្រះអង្គ។ យើងជាកូនចៅចាំតែទទួលប៉ុណ្ណោះ។ ដោយសារ សម្ដេចឪដូរទិសនយោបាយ ទើបសង្គ្រាមនៅ វៀតណាមខាងត្បូង ឆេះរាលដាលចូលមកក្នុងប្រទេសកម្ពុជា។

សុស្ដែន ហ្វែរណង់ដេស បានរៀបរាប់បញ្ជាក់ថា នៅថ្ងៃទី៣១ ខែមករា ឆ្នាំ១៩៦៨ ( ពេលនោះ គាត់មានឋានន្តរសក្តិ ជាវរសេនីយ៍ឯក) សម្ដេចសីហនុ បានតែងតាំងគាត់ ជារដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលបន្ទុកសន្តិសុខជាតិ។ ពេលចូលមកកាន់តំណែងដំបូង គាត់បានត្រិះរិះ ពិចារណាថា តើត្រូវធ្វើអ្វីខ្លះ និងធ្វើយ៉ាងណា ដើម្បីថែរក្សាសន្តិសុខ របស់ប្រទេសជាតិឱ្យបានល្អ?។

ពេលនោះគាត់គិតថា បញ្ហាយួនវៀតកុង-វៀតណាមខាងជើង ចូលមកបោះទីតាំងកងទ័ពនៅក្នុងទឹកដីខ្មែរយើង ជាបញ្ហាគ្រោះថ្នាក់របស់ប្រទេសជាតិធំណាស់ ដូច្នេះ គាត់ក៏បានបញ្ជាឱ្យមន្ត្រីក្រោមឱវាទនៅក្នុងទីក្រុងភ្នំពេញ និងនៅតាមបណ្ដាខេត្តមួយទៀត ឱ្យនាំគ្នាចុះទៅស៊ើបអង្កេត និងប្រមូលព័ត៌មានសម្ងាត់ផ្សេងៗ ដើម្បីឱ្យដឹងច្បាស់ថា តើកងទ័ព វៀតកុង-វៀតណាមខាងជើង បានចូលមកបោះទីតាំងនៅ

លើទឹកដីខ្មែរត្រង់កន្លែងណាខ្លះ? ហើយពួកគេកំពុងធ្វើអីខ្លះនៅក្នុងទឹកដីខ្មែរ? ។

ដោយមានការខិតខំប្រឹងប្រែងអស់រយៈពេលជាច្រើនខែក្រោយមក គាត់បានធ្វើរបាយការណ៍លម្អិតមួយ ស្តីពីសកម្មភាពរបស់កងទ័ពវៀតកុង-វៀតណាមខាងជើងសរុបទាំងអស់ មានប្រមាណ៦ម៉ឺននាក់ កំពុងបោះទីតាំងនៅលើ ទឹកដីខ្មែរ ពិសេសនៅខេត្តរតនគិរី, ខេត្តមណ្ឌលគិរី និងខេត្តស្ទឹងត្រែង មានទាំងឃ្លាំងដាក់អាវុធ, កន្លែងជួសជុលអាវុធគ្រប់ប្រភេទ, មន្ទីរពេទ្យ, ជម្រកសម្រាប់កងទ័ពឈប់សម្រាក, កន្លែងហ្វឹកហ្វឺនកងទ័ព ព្រមទាំងបានធ្វើផែនទីបង្ហាញទីតាំងនីមួយៗផង ដើម្បីយកទៅថ្វាយព្រះករុណា សម្តេចសីហនុ ជាព្រះប្រមុខរដ្ឋ ឱ្យទ្រង់ជ្រាប ។

ក្នុងរបាយការណ៍នោះដែរ គាត់បានរាយការណ៍អំពីខ្សែរយៈទាក់ទងរបស់កងទ័ពវៀតកុង-វៀតណាមខាងជើង ទាំងនៅ ទីក្រុងភ្នំពេញ និងនៅតំបន់ទន្លេសាបខេត្តកំពង់ឆ្នាំង ព្រមទាំងកន្លែងផ្សេងៗទៀត ដែលមានជនជាតិយួន រស់នៅប្រមូលផ្តុំគ្នាបង្កើតជាបណ្តាញទាក់ទងគ្នាយ៉ាងសកម្មជាមួយកងទ័ពវៀតកុង-វៀតណាមខាងជើង ផងដែរ។ ពិសេស គាត់បានវាយតម្លៃក្នុងរបាយការណ៍នោះដែរថា កងទ័ពវៀតកុង-វៀតណាមខាងជើង ដែលនៅខេត្តរតនគិរី ខេត្តមណ្ឌលគិរី និងខេត្តស្ទឹងត្រែង អាចវាយយកទីក្រុងភ្នំពេញ របស់យើងយ៉ាងយូរ តែក្នុងរយៈ២ឬ៣ថ្ងៃប៉ុណ្ណោះ ។

សុស្តែន ហ្វែរណាំងដេស បានរម្លឹកថា ពេលនោះ សម្តេចសីហនុ កំពុងយាងទៅបំពេញទស្សនកិច្ច និងសួរសុខទុក្ខ ប្រជារាស្ត្រជាកូនចៅរបស់ព្រះអង្គ នៅខេត្តរតនគិរី។ ដោយមិនរង់ចាំសម្តេចសីហនុ យាងវិលត្រលប់មកក្រុងភ្នំពេញ វិញ គាត់ក៏បានសម្រេចចិត្តឡើងយន្តហោះ ដើម្បីយករបាយការណ៍ និងផែនទីស្តីពីកងទ័ពវៀតកុង-វៀតណាមខាងជើង ចូលមកបោះទីតាំងនៅលើទឹកដីខ្មែរនោះ ទៅថ្វាយនៅក្រុងឡាបានសៀកខេត្តរតនគិរី ដើម្បីឱ្យព្រះអង្គឲ្យបានជ្រាបជាបន្ទាន់ ។

ពេលទៅដល់ព្រះរាជដំណាក់ នៅក្រុងឡាបានសៀក សម្តេចសីហនុ មិនទាន់យាងត្រលប់មកពីបំពេញទស្សនកិច្ចនៅតាមភូមិរបស់ប្រជារាស្ត្រវិញទេ គាត់ត្រូវ

រង់ចាំនៅមុខព្រះរាជដំណាក់នោះ ដើម្បីចូលគាល់ព្រះអង្គ ។

លុះព្រះអង្គយាងមកដល់ គាត់បានចូលទៅក្រាបថ្វាយបង្គំ ទូលថ្វាយព្រះអង្គពីរឿងកងទ័ពវៀតកុង-វៀតណាម ខាងជើង បានចូលមកបោះទីតាំងនៅលើទឹកដីខ្មែរ ហើយថ្វាយឯកសារជារបាយការណ៍ និងផែនទីផងដែរ ។

ក្រោយពីទតរបាយការណ៍ និងផែនទីរួច សម្តេចសីហនុ ប្រាប់គាត់ថា សហជីវិនកុំអាលត្រលប់ទៅភ្នំពេញវិញ ចាំដល់ព្រឹកស្អែក ទៅជួបឧត្តមសេនីយ៍ញឹក ជូឡុង អគ្គមេបញ្ជាការកងទ័ព ដែលកំពុងឋិតនៅក្រុងឡាបានសៀក នេះដែរ សិន។ គាត់ក៏ក្រាបថ្វាយបង្គំលាសម្តេចសីហនុ មករកកន្លែងសម្រាក ដើម្បីរង់ចាំជួបឧត្តមសេនីយ៍ ញឹក ជូឡុង នៅព្រឹកស្អែក ។

យប់នោះ គាត់មានអារម្មណ៍សប្បាយរីករាយខ្លាំងណាស់ ព្រោះគិតថា គាត់បានបំពេញភារកិច្ចដ៏ថ្លៃថ្លា និងមានប្រយោជន៍បំផុតចំពោះប្រទេសជាតិ ហើយបានមើលឃើញពីចំណុចខ្លាំង និងចំណុចខ្សោយរបស់ពួកយួនវៀតកុង រួមទាំងខ្សែរយៈទាក់ទងរបស់វានៅទីក្រុងភ្នំពេញ និងតាមបណ្តាខេត្តនានានៅគ្រប់ទីកន្លែង ។

គាត់សង្ឃឹមថា ដោយសារស្នាដៃដ៏ថ្លៃថ្លានេះ គាត់អាចនឹងឡើងឋានៈបុណ្យស័ក្តិជាមិនខាន ឬយ៉ាងហោចណាស់ ក៏ចៅហ្វាយនាយគាត់បំពាក់មេដាយ (គ្រឿងឥស្សរិយយស)ដល់គាត់ដែរ។ គាត់ដេកមិនលក់មួយយប់ ព្រោះសប្បាយចិត្តដោយបានបម្រើប្រទេសជាតិ និងមេដឹកនាំប្រទេសបានល្អ ។

ព្រឹកឡើង ប្រហែលម៉ោង៧ មាននាយទាហានរងម្នាក់បានបើករថយន្តហ្ស៊ីបមួយគ្រឿង មកគោរពអញ្ជើញគាត់ថា៖ ឯកឧត្តមអគ្គបញ្ជាការ ឲ្យមកអញ្ជើញតេជគុណទៅជួប។ គាត់ត្រេកអរណាស់ ព្រោះជឿជាក់ថា ចៅហ្វាយនាយគាត់នឹងលើកសរសើរគាត់ជាមិនខាន ។

ពេលចូលទៅដល់ក្នុងបន្ទប់ គាត់ឈរគោរពឧត្តមសេនីយ៍ញឹក ជូឡុង ត្រង់ជើងភ្លឹង។ តែញឹក ជូឡុង មិនប្រាប់ឲ្យគាត់អង្គុយនៅលើកៅអីក្បែរនោះទេ គឺឲ្យឈរ

នឹងថ្កល់ ហើយចង្អុលមុខ ដេរដៀលគាត់ថា៖ នែ! អាសុស្តែន គេឲ្យអ្ហែងធ្វើធំ តែហ្អែងគ្មានដឹងអីទាំងអស់។ អាពង់ក្ត... អ្ហែងធ្វើរបាយការណ៍រឿងទាំងហ្នឹង ហ្អែងដឹងទេថានេះជារឿងគោលនយោបាយជាន់ខ្ពស់របស់សម្តេច? ម៉េចក៏ហ្អែងហ៊ានសរសេររបាយការណ៍ផ្តេសផ្តាសអញ្ចឹង។ បើរឿងនេះបែកធ្លាយ ដឹងដល់នរណាម្នាក់ ហើយកាសែតចុះផ្សាយទៅ តើវាទៅជាយ៉ាងម៉េច? ហ្អែងចង់ចូលគុកឬ?

នៅពេលឧត្តមសេនីយ៍ ញ៉ឹក ជូឡុង ចង្អុលមុខដេរដៀលគាត់ដូច្នេះ គាត់ភ្ញាក់ព្រើត ហើយងឹតមុខឈឹងរកគិតអ្វីមិនយល់ គាត់នឹកថា ងាប់ហើយម្តងនេះ ។

នៅពេលរៀបរាប់មកដល់ត្រឹមនេះ សុស្តែន ហ្វ៊ែរណង់ដេស ស្រក់ទឹកភ្នែកបណ្តើរ និងបញ្ជាក់បន្ថែមទាំងតូចចិត្តថា ឧត្តមសេនីយ៍ញ៉ឹក ជូឡុង ឲ្យក្តគាត់...។

តាំងពីដើមមក គាត់ជាកូនចៅរបស់ឧត្តមសេនីយ៍ញ៉ឹក ជូឡុង។ គាត់មិនដែលមានជម្លោះ ឬគំនុំគុំក្ងួនអ្វីជាមួយគ្នាទេ ហើយឧត្តមសេនីយ៍ញ៉ឹក ជូឡុង តែងតែហៅគាត់ អា។ បែបនេះ ពោលគឺ មិនមែននៅពេលខឹងរឿងនេះ ទើបឧត្តមសេនីយ៍ញ៉ឹក ជូឡុង ហៅគាត់ថា អា។ នោះទេ ។



ញ៉ឹក ជូឡុង និងសាក់ ស៊ីស្បោង ពេលសម្តែងភាពយន្ត

សុស្តែន ហ្វ៊ែរណង់ដេស បន្តថា គាត់ធ្លាប់ធ្វើតែទាហាន ហើយធ្វើតាមបញ្ជារបស់ចៅហ្វាយនាយប៉ុណ្ណោះ តែបើ និយាយពីរឿងនយោបាយវិញ គាត់មិនដែលសោះ។

លុះពេលចាប់ផ្តើមធ្វើរដ្ឋមន្ត្រីមិនបានប៉ុន្មានខែផង ស្រាប់តែប៉ះចំរឿងធំសែនធំបែបនេះតែម្តង ។

ជាមួយគ្នានេះ គាត់ក៏បានលើកដៃសំពះសុំទោសដល់វិញ្ញាណក្ខន្ធរបស់ឧត្តមសេនីយ៍ញ៉ឹក ជូឡុង ដែលបានស្លាប់

ទៅហើយនោះផងដែរ ព្រោះគាត់និយាយនេះ មិនមែនមានបំណងចង់ឱ្យប៉ះពាល់ដល់កិត្តិយសរបស់ឧត្តមសេនីយ៍ញឹក ជូឡុង នោះទេ គឺគាត់គ្រាន់តែនិយាយរឿងនេះ ដើម្បីឲ្យបានធូរទ្រូងខ្លះប៉ុណ្ណោះ ។

សុស្តែន ហ្វែរណង់ដេស បន្តទៀតថា ពេលនោះ ទោះបីឧត្តមសេនីយ៍ញឹក ជូឡុង ជេរស្តីយ៉ាងណា ក៏គាត់នៅស្ងៀម មិនហ៊ានតបតអ្វីទាំងអស់។

បន្តិចក្រោយមក ឧត្តមសេនីយ៍ ញឹក ជូឡុង ក៏បញ្ជាមកគាត់ថាៈ អាសុស្តែន! ឥឡូវនេះ អញឱ្យគេរៀបចំយន្តហោះ មួយគ្រឿង ដើម្បីឲ្យអ្អែងឡើងទៅក្រុងភ្នំពេញភ្លាម ហើយពេលទៅដល់ទីស្តីការក្រសួងអ្អែង ( ក្រសួងសន្តិសុខជាតិ) អ្អែងត្រូវណែនាំកូនចៅអ្អែងទាំងអស់ ឱ្យប្រមូលឯកសារ និងរបាយការណ៍ ដែលសរសេរទាក់ទងពីរឿងកងទ័ពយួនវៀតកុង នៅក្នុងទឹកដីខ្មែរទាំងប៉ុន្មាន ដុតចោលទាំងអស់ ។

មុនពេលឡើងយន្តហោះចាកចេញពីក្រុងឡាបានសៀក វិលត្រលប់ទៅទីក្រុងភ្នំពេញវិញ គាត់បានវាយទូរលេខទៅប្រាប់មន្ត្រីក្រោមឱវាទគាត់ទាំងអស់ ទាំងនាយខុទ្ទកាល័យ ទាំងស្នងការ ព្រមទាំងនាយការិយាល័យទាំងអស់ កុំឲ្យទៅណាឲ្យសោះ ត្រូវមកជួបជុំគ្នានៅទីស្តីការក្រសួងសន្តិសុខជាតិ ជាបន្ទាន់ ។

ពេលយន្តហោះចុះចតនៅអាកាសយានដ្ឋានពោធិ៍ចិនតុង គាត់ឲ្យរថយន្តមកទទួលយកគាត់ តម្រង់ទៅទីស្តីការ ក្រសួងតែម្តង។ ទៅដល់ភ្លាម ពួកមន្ត្រីក្រោមឱវាទគាត់សំខាន់ៗទាំងអស់នៅជុំគ្នាជាស្រេច ។

គាត់បានបញ្ជាមន្ត្រីគាត់ទាំងអស់ឲ្យវិលទៅការិយាល័យរៀងៗខ្លួនវិញ ដើម្បីប្រមូលយកឯកសារទាំងអស់ ដែលនិយាយទាក់ទងអំពីទីតាំងវត្តមានកងទ័ពវៀតកុង-វៀតណាមខាងជើង ព្រមទាំងឯកសាររបស់ពួកបណ្តាញសម្ងាត់របស់វានៅក្នុងទីក្រុងភ្នំពេញ និងកន្លែងផ្សេងៗទៀត ឲ្យយកមកប្រគល់ឱ្យគាត់ទាំងអស់ ។

ពេលប្រមូលយកមកអស់ហើយ គាត់ក៏ចាប់ផ្តើមបញ្ជាឲ្យហែកឯកសារនោះរួចនាំគ្នាដុតបំផ្លាញចោលទាំងអស់ មិនឲ្យនៅសល់មួយសន្លឹកឡើយ ។

ក្រោយពេលដុតបំផ្លាញអស់ហើយ គាត់ថែមទាំងបានប្រាប់នាយខុទ្ទកាល័យ និងស្នងការ ព្រមទាំងនាយការិយាល័យទាំងអស់ថា៖ ខ្ញុំខុសហើយ ព្រោះខ្ញុំជាអ្នកបញ្ជាឲ្យអស់លោកធ្វើកិច្ចការនេះ ។ សូមអស់លោកទាំងអស់គ្នាជ្រាបថា យើងខុស ព្រោះយើងធ្វើឲ្យប៉ះពាល់ដល់គោលនយោបាយជាន់ខ្ពស់របស់សម្តេចឪ។ យើងលាតត្រដាងរឿងសម្ងាត់របស់ប្រទេសជាតិឲ្យគេឃើញទាំងអស់ ។

ចុងក្រោយ គាត់ផ្តាំមន្ត្រីគាត់ទាំងអស់នោះឲ្យបំភ្លេចចោលរឿងនេះនៅក្នុងចិត្តក្នុងសតិអារម្មណ៍របស់ខ្លួន កុំឱ្យមានតទៅទៀត ពោលគឺត្រូវបំបាត់រឿងសម្ងាត់នេះចោលទាំងស្រុង។ បន្ទាប់មក គាត់ក៏បានចេញពីទីស្តីការក្រសួងតាមទ្វារ ក្រោយ ដោយមិនចង់ឃើញមុខនរណាម្នាក់ឡើយ ។

ថ្ងៃនោះ គាត់មានការឈឺចាប់ក្នុងចិត្តខ្លាំងពេក ពេលចូលទៅដល់ផ្ទះ គាត់អត់និយាយស្តីរកប្រពន្ធកូនបន្តិចឡើយ។ គាត់ចូលក្នុងបន្ទប់ដេក ហើយបិទទ្វារជិត អង្គុយយំតែម្នាក់ឯង។ គាត់យំស្តាយ ពីព្រោះគាត់បានបម្រើប្រទេសជាតិ អស់ពីកម្លាំងកាយកម្លាំងចិត្ត តែមិនគួរណា មកខុសក្នុងរឿងនយោបាយ ដែលគាត់នៅខ្ចីពេក។ គេឲ្យគាត់ធ្វើធំ កាន់កាប់នយោបាយ តែគាត់មិនយល់ពីរឿងនយោបាយ។ កាលនោះ គាត់ក៏មិនមែននៅក្មេងនោះដែរ គឺគាត់មានអាយុជាង៥០ឆ្នាំហើយ ។

សុស្តែន ហ្វែរណង់ដេស យល់ឃើញថា រឿងរ៉ាវដេរស្តីឱ្យគាត់ដូចខាងលើនេះប្រហែលជាសម្តេចសីហនុ ជាអ្នកបញ្ជាទៅឧត្តមសេនីយ៍ញឹក ជូឡុង ឲ្យធ្វើការស្តីបន្ទោសគាត់ ដែលមិនយល់ពីរឿងនយោបាយ ព្រោះរឿងនេះ ជារឿងសម្ងាត់ ជារឿងនយោបាយជាន់ខ្ពស់របស់ព្រះអង្គ ដែលគ្មាននរណាត្រូវដឹងឮឡើយ ហើយហេតុអ្វីបានជារូបគាត់ជារដ្ឋមន្ត្រីក្រសួងសន្តិសុខជាតិ បែរជាធ្វើរបាយការណ៍ និងផែនទីបង្ហាញពីទីតាំងកងទ័ពវៀតកុង-វៀតណាមខាងជើង ចូលមកបោះទីតាំងនៅលើទឹកដីខ្មែរនោះ ធ្វើឲ្យខូចនយោបាយសម្ងាត់របស់សម្តេចសីហនុ ទៅវិញ?។

គាត់គិតថា រឿងនេះជារឿងប្រទេសជាតិធំណាស់ ដូច្នេះគាត់មិនជឿថា

ឧត្តមសេនីយ៍ញ៉ឹក ជូឡុង ហ៊ានហៅគាត់ទៅស្តីបន្ទោសទេ គឺមានតែសម្តេចសីហនុមួយអង្គគាត់ ដែលមានអំណាចបញ្ជាឱ្យឧត្តមសេនីយ៍ញ៉ឹក ជូឡុង ហៅ គាត់ទៅជួបដើម្បីធ្វើការអប់រំ និងស្តីបន្ទោសធ្ងន់ៗដូច្នេះ ។

ពេលនោះ គាត់ពិចារណាដែរថា ខ្លួនគាត់ជាទាហានខ្មែរស្នេហាជាតិមួយរូប ហ៊ានប្តូរជីវិតទៅ តតាំងជាមួយពួកខ្មាំងសត្រូវយួន ដែលចូលមកបោះទីតាំងលើទឹកដីខ្មែរដែរ។ តែគាត់ក៏ត្រូវតែបំពេញភារកិច្ចជាផ្លូវនយោបាយ គាត់ត្រូវតែប្រឹងប្រែងធ្វើការ ដើម្បីផ្គាប់ចិត្តចៅហ្វាយនាយរបស់គាត់ ដែលបានផ្តល់កិត្តិយសឱ្យគាត់ ធ្វើជារដ្ឋមន្ត្រីក្រសួងសន្តិសុខជាតិ ផងដែរ ។

# ២៥៣
# សម រង្ស៊ី និងសូមួរ៉ា ចាប់ផ្តើមស្នេហានៅទីក្រុងប៉ារីស



សម រង្ស៊ី និងជូឡុង សូមួរ៉ា

នៅចុងឆ្នាំ១៩៦៧ សម រង្ស៊ី បានជួប សូមួរ៉ា ម្តងទៀត នៅទីក្រុងប៉ារីស ។ លើកនេះ គាត់លួងលោមបបួលនាងឲ្យទៅដើរកម្សាន្តវិស្សមកាលជាមួយគាត់នៅប្រទេសអង់គ្លេស ។ គាត់ថែមទាំងបានកក់សំបុត្ររថភ្លើង និងសំបុត្រនាវារួចជាស្រេច ព្រមទាំងបានប្រាប់ជនជាតិអង់គ្លេសម្នាក់ ដែលស្រឡាញ់រាប់អានគាត់ជិតស្និទ្ធនៅក្រុងឡុងដ៍ ឱ្យរង់ចាំទទួលពួកគាត់ទៀតផង។ តែទីបំផុត នាងប្រាប់ថា នាងមិនអាចទៅដើរកម្សាន្តវិស្សមកាលជាមួយគាត់នៅប្រទេសអង់គ្លេស នោះបានទេ ។ តែគាត់ក៏ពេញចិត្តដែរ ដែលនាងប្រាប់រឿងនេះទៅឱ្យម្តាយគាត់បានដឹង ។

សម រង្ស៊ី បញ្ជាក់ថា សូមួរ៉ា បានសិក្សាភាសាអង់គ្លេស ពិតមែន តែនាងមិនដែលដាក់ជើងជាន់ប្រទេសនេះទេ។ ប្រទេសនេះមានតម្លៃណាស់នៅក្នុងបេះដូងគាត់ ហើយគាត់មានរឿងជាច្រើនដែលត្រូវរៀបរាប់ប្រាប់នាង ។

កាលនៅពីក្មេង ពេលឪពុកគាត់មកកាន់តំណែងជាឯកអគ្គរាជទូតនៅប្រទេសអង់គ្លេស គាត់ធ្លាប់សិក្សានៅប្រទេសនេះ អស់ជាច្រើនខែដែរ ហើយចាប់ពីពេលគាត់បានមករស់នៅជ្រកកោននៅប្រទេសបារាំង គាត់តែងតែធ្វើដំណើរទៅកម្សាន្តវិស្សម

កាលនៅប្រទេសអង់គ្លេសនេះ ជារៀងរាល់ឆ្នាំ ។

ពីឆ្នាំ១៩៤៦ដល់ឆ្នាំ១៩៥០ ឪពុកគាត់បានទៅសិក្សាផ្នែកវិទ្យាសាស្រ្តនយោបាយ នៅមហាវិទ្យាល័យ អូក្សហ្វដ ( oxford ) និងបានសិក្សាភាសាអង់គ្លេស នៅសាលាប៊េលីត្ស ( Berlitz ) ។

នៅទីនោះឪពុកគាត់បានជួបមនុស្សជាច្រើន ហើយគាត់បានផ្សារទំនាក់ទំនងមិត្តភាពជាមួយបុរសជាកម្មករម្នាក់ ឈ្មោះវីល្លៀម ហាំប្រេយ៍ ( William Humphreys ) ដែលមានវ័យចំណាស់ជាង រស់នៅអ៊ីស្លិនថុន( Islinton ) ជាសង្កាត់ក្រីក្រមួយរបស់ទីក្រុងឡុងដ៍។ ចំណងមិត្តភាពនេះបានកើតឡើងនៅពេលឪពុកគាត់វង្វេងផ្លូវ វីល្លៀមហាំប្រេយ៍ ក៏អញ្ជើញឪពុកគាត់ឲ្យចូលពិសាទឹកតែនៅក្នុងផ្ទះដ៏សាមញ្ញមួយរបស់ខ្លួនដោយរីករាយរាក់ទាក់បំផុត ។

ឪពុកគាត់រំភើបចិត្តខ្លាំងណាស់ចំពោះការស្វាគមន៍ដោយរីករាយរាក់ទាក់បំផុតនេះ។ បន្ទាប់មកទៀត ពួកគាត់ទាំងពីរនាក់ស្រលាញ់រាប់អានគ្នាកាន់តែជិតស្និទ្ធឡើងៗ តាមរយៈសរសេរសំបុត្រឆ្លើយឆ្លងគ្នាទៅវិញទៅមកជារឿយៗ ។

ក្រោយពីឪពុកគាត់ត្រូវបានតែងតាំងជាឯកអគ្គរាជទូតកម្ពុជា ប្រចាំប្រទេសអង់គ្លេស( ដើមឆ្នាំ១៩៥៨ ) ក្រុមគ្រួសារគាត់បានទៅរស់នៅក្នុងនិវេសនដ្ឋានរបស់ឯកអគ្គរាជទូតនៅអគារលេខ៦៤ ផ្លូវហ្វីលីម័រ ហ្គារដិន គឺនៅក្នុងសង្កាត់អ្នកមានមួយឈ្មោះកេនស៊ីនតោន ( Kensington )ឪពុកគាត់នៅតែទាក់ទងស្រលាញ់រាប់អានមិត្តភក្តិឈ្មោះវីល្លៀម ហាំប្រេយ៍ ( William Humphreys )នេះ ដូចមុនដដែល ហើយថែមទាំងបានអញ្ជើញមិត្តភក្តិកំសត់ម្នាក់នេះឱ្យមកលេងប្រទេសកម្ពុជា ទៀតផង ។

សម រង្ស៊ី បានបន្តថា តាំងពីថ្ងៃទៅសម្រាកវិស្សមកាលដំបូងនៅប្រទេសអង់គ្លេស វីល្លៀម ហាំប្រេយ៍( William Humphreys ) បានទទួលស្វាគមន៍គាត់ដោយរីករាយរាក់ទាក់ ដូចកាលទទួលស្វាគមន៍ឪពុកគាត់កាលពីឆ្នាំ ១៩៥៨ នោះដែរ ។

អនុស្សាវរីយ៍ទាំងអស់នេះបានឆ្លាក់ជាប់នៅក្នុងបេះដូងគាត់ជារៀងរហូត ។ តែ

នៅផ្ទះរបស់វីល្លៀមហាំប្រេយ៍( William Humphreys ) គ្មានបន្ទប់ទឹកទេ ។ យើងត្រូវទៅងូតទឹកជម្រះកាយនៅក្នុងបន្ទប់ទឹកសាធារណៈក្នុងមួយសប្ដាហ៍ម្ដង។ នៅថ្ងៃបុណ្យ ពួកគាត់ទៅទិញត្រីចៀន និងដំឡូងចៀនយកមកស្រោចទឹកខ្មេះ និងរោយអំបិលពីលើ ទទួលទាន ។

គាត់បានសរសេរប្រាប់សូមួរ៉ា ពីសារៈសំខាន់នេះ ចំពោះការមិនគិតពីឋានៈបុណ្យសក្ដិ ឬវណ្ណៈមានក្ររបស់បុគ្គលម្នាក់ៗក្នុងសង្គម ។ គាត់ក៏ដឹងដែរថា នៅពេលគាត់លើកឡើងពីការមិនប្រកាន់ឋានៈវណ្ណៈត្រង់ៗពេកបែបនេះ អាចធ្វើឱ្យបំណងដែលគាត់ប៉ងប្រាថ្នាចង់បានសូមួរ៉ា ជាគូវាសនានោះ ត្រូវបរាជ័យ ក៏អាចថាបាន ព្រោះគ្រួសារនាងមានឋានៈខ្ពង់ខ្ពស់។ ក្នុងអំឡុងពេលឪពុកនាងត្រូវបានតែងតាំងជាឯកអគ្គរាជទូតខ្មែរនៅទីក្រុងប្រាក( Prague ) ប្រទេសឆេកូស្លូវ៉ាគី គ្រួសារនាងមានរថយន្ត ៣គ្រឿង ចាំជូនដំណើរ និងមានអ្នកធ្វើនំជាជនជាតិអ៊ីតាលី ម្នាក់ទៀតផង ។

ពេលឪពុកនាងត្រូវបានតែងតាំងជាឯកអគ្គរាជទូតខ្មែរនៅទីក្រុងមូស្គូ សហភាពសូវៀត ពួកនាងចង់ទទួលទានម្ហូបអាហារអ្វី មានចុងភៅជាជនជាតិបារាំង ចាំបំពេញទំនើងចិត្តរបស់ពួកនាង ។

សម រង្ស៊ី បានបញ្ជាក់ថា ជីវិតរុងរឿងបែបនេះ គាត់ក៏ធ្លាប់ជួបកាលនៅស្ថានទូតខ្មែរនៅទីក្រុងឡុងដ៍ ពីឆ្នាំ១៩៥៨-៥៩ដែរ ពួកគាត់មានមេចុងភៅជាជនជាតិអេស្ប៉ាញ៉ុល មានអ្នកបម្រើមកពីប្រ៊ីតាញពីរនាក់ និងមានអ្នកបើកបររថយន្ត ជាជនជាតិអង់គ្លេសពីរនាក់ទៀតផង ។

ជាមួយគ្នានោះ ឪពុកម្ដាយគាត់ធ្លាប់ធ្វើដំណើរក្នុងព្រះរាជរថ ដើម្បីយកលិខិតសារតាំងជាឯកអគ្គរាជទូតថ្មីរបស់ប្រទេសកម្ពុជា ទៅថ្វាយព្រះមហាក្សត្រិយានីអេលីហ្សាបេត៍ទី២ របស់ចក្រភព អង់គ្លេស នៅវិមានប៊ែកឃីងហាំ( Buckingham )ផងដែរ ។ តែពេលនេះ គាត់ប្រាប់សូមួរ៉ា ជាញឹកញាប់ថា គាត់ញ៉ាំតែ ចេកមួយ ឬពីរផ្លែជាអាហារប៉ុណ្ណោះ។ គាត់គិតថា ដោយសារការពណ៌នាអំពីខ្សែជីវិតដ៏កំសត់នេះ សូមួរ៉ា ប្រហែល

ជាមានអារម្មណ៍ក្តុកក្តួល ហើយនាង ប្រហែលជាមានមនោសញ្ចេតនាស្នេហាមកលើ គាត់ ជាងបុត្រារបស់ព្រះអង្គម្ចាស់ ឬកូនកំលោះរបស់ពួកអ្នកមានឋានៈបុណ្យស័ក្តិខ្ពង់ខ្ពស់នៅទីក្រុងភ្នំពេញ ដែលក្រវែលចោមរោមសុំស្នេហ៍ពីនាង ។

សម រង្ស៊ី បានបន្តថា ក្នុងអំឡុងឆ្នាំ១៩៦៧ គាត់បានសរសេរសំបុត្រកាន់តែច្រើនឡើងៗពីទីក្រុងប៉ារីស ផ្ញើទៅសូមួរ៉ា ដែលនៅទីក្រុងភ្នំពេញ ហើយនាងតែងតែឆ្លើយតបមកវិញគ្រប់សំបុត្ររបស់គាត់ ។ សម័យនោះ ទីក្រុងប៉ារីស និងទីក្រុងភ្នំពេញ មានតែជើងយន្តហោះតែពីរ ឬបីជើងប៉ុណ្ណោះក្នុងមួយសប្តាហ៍ ។ តែទោះបីយ៉ាងណាក៏គាត់មិនហ៊ានសរសេរសារភាពពីមនោសញ្ចេតនាស្នេហារបស់គាត់ចំពោះនាងដែរ គឺហ៊ានត្រឹមតែសរសេរពីតម្លៃមិត្តភាពផ្សារភ្ជាប់រូបគាត់ជាមួយគ្រួសារនាងតែប៉ុណ្ណោះ ។

នៅដើមឆ្នាំ១៩៦៨ ក្រុមគ្រួសារសូមួរ៉ា បានធ្វើដំណើរមកលេងទីក្រុងប៉ារីស ម្តងទៀត។ ក្រោយពីស្នាក់នៅទីក្រុង ប៉ារីស បានមួយរយៈ ម្តាយនាងត្រូវត្រលប់មកទីក្រុងភ្នំពេញ វិញ ដោយទុកនាងឱ្យចាំធ្វើដំណើរនៅពេលក្រោយ ។ ឆ្លៀតឱកាសល្អនោះ គាត់ក៏បានបបួលនាងទៅចូលលេងនៅក្លឹបរាត្រីការឌីណាល់ ក្នុងសង្កាត់ឡាតាំង ។ នាងក៏ព្រមទៅជាមួយ គាត់ក៏បានបបួលមិត្តភក្តិជាជនជាតិបារាំងម្នាក់ឈ្មោះ មីស្សែល រៀននៅមហាវិទ្យាល័យជាមួយគ្នា ទៅជាមួយដែរ។ តែដោយសារខ្លាច មីស្សែល និយាយទាក់ទងស្នេហាជាមួយនាង គាត់ក៏ប្រាប់ មីស្សែល ថា សូមួរ៉ា ជាជនជាតិថៃ នាងមិនចេះនិយាយភាសាបារាំង ទេ ។

បន្ទាប់ពីចូលទៅដល់ក្នុងក្លឹបរាត្រី មីស្សែល ដែលជឿថា សូមួរ៉ា មិនចេះភាសាបារាំងនោះ ចេះតែនិយាយពាក្យអាសអាភាសចម្អេះចំអាសតែផ្តេសតែផ្តាសម្តងហើយម្តងទៀត ធ្វើឱ្យគាត់ព្រឺខ្លួន ព្រោះខ្លាចចិត្តសូមួរ៉ា មិនដឹងថា នាងវាយតម្លៃពួកគាត់ទាំងពីរនាក់ថាជាមនុស្សប្រភេទណា?។ តែពេលនោះ សំឡេងប្រគំតន្ត្រីលាន់ឮខ្លាំងៗ ឡើងហឹងត្រចៀក គាត់ក៏មិនដឹងថា សូមួរ៉ា ស្តាប់ឮពាក្យអាសអាភាសចម្អេះចំអាស

តែផ្តេសតែផ្តាស ដែលមិស្បែល បាននិយាយនោះ ឬអត់ទេ? ។

គាត់ចង់បបួលនាងឡើងរាំដែរ តែមិនហ៊ានទេ។ ពេលនោះ គាត់ចេះតែគិតថាគ្មានឱកាសណាល្អជាងពេលនេះ ឡើយ។ គាត់លូកម្រាមដៃគាត់ទៅចាប់ម្រាមដៃនាង ។ ជាមួយនឹងភាពអៀនខ្មាស ម្រាមដៃរបស់នាងនៅស្ងៀម គ្មានកម្រើកបន្តិចឡើយ ។

គាត់សារភាពដោយត្រង់ៗថា បងស្រលាញ់អូន! រួចឱនថើបថ្ពាសរបស់នាងថ្នមៗ។ បន្ទាប់មក គាត់បានបណ្តើរនាងចេញទៅឆ្ងាយពីសំឡេងតន្ត្រី ដើម្បីងាយស្រួលសាសងគ្នា ។

គាត់សួរនាងថា តើពេលណាទើបពួកយើងបានជួបគ្នាបែបនេះទៀត?

តែសូមួរ៉ា ឆ្លើយថា ពួកយើងមិនមែនជាគូនឹងគ្នាទេ! ។

គាត់គិតថា នាងនិយាយត្រូវ។ ទំនាក់ទំនងស្នេហារបស់ពួកគាត់ទាំងពីរនាក់ហាក់ដូចជាមិនអាចទៅរួចឡើយ ព្រោះគេ( សម្តេចសីហនុ) នៅតែហាមឃាត់គ្រួសារគាត់មិនឲ្យចូលទៅរស់នៅក្នុងប្រទេសកម្ពុជាវិញ ខណៈឧត្តមសេនីយ៍ញឹក ជូឡុងនៅតែជាមិត្តភក្តិជិតស្និទ្ធជាមួយសម្តេចសីហនុ ពួកគាត់មិនអាចមានវាសនារៀបការនឹងគ្នាបានឡើយ ។

ជាមួយគ្នានេះ គាត់បានគិតដល់ស្ថានភាពនៅប្រទេសកម្ពុជា គិតដល់ការលំបាករបស់សម្តេចសីហនុ ដែលកំពុងជាប់ ក្នុងមាត់ដង្កាប់របស់ពួកអាមេរិក និងពួកវៀតកុង-វៀតណាមខាងជើង ផងដែរ។ តែគាត់បាននិយាយទៅកាន់នាង ដោយជំនឿជឿជាក់ថាសម្រាប់ពួកយើងទាំងពីរគ្រប់យ៉ាងនឹងមានការផ្លាស់ប្តូរយ៉ាងឆាប់រហ័សជាមិនខាន ។

សម រង្ស៊ី ប្រាប់សូមួរ៉ា ថា នៅក្នុងឆ្នាំ១៩៦៨ គាត់ដឹងថា សម្តេចសីហនុ បានបណ្តោយឱ្យពួកកុម្មុយនិស្តវៀតណាមខាងជើង ប្រើប្រាស់ទឹកដីភាគខាងកើតនៃប្រទេសកម្ពុជា ដឹកអាវុធយុទ្ធភណ្ឌ និងកងទ័ពតាមអំពើចិត្ត។ ពួកវៀតកុង-វៀតណាមខាងជើង បានប្រើប្រាស់ទឹកដីកម្ពុជា ធ្វើជាមូលដ្ឋានសម្រាប់ការដកថយ និងវាយប្រហារកងទ័ពអាមេរិក និងវៀតណាមខាងត្បូង ។

គ្រឿងសព្វាវុធគ្រប់ប្រភេទជាជំនួយរបស់ចិន និងសូវៀត បានចូលយ៉ាងច្រើនតាមច្រកទ្វារកំពង់ផែក្រុងព្រះសីហនុ ។

គាត់មានសុទិដ្ឋិនិយមថា បញ្ហាដែលសម្តេចសីហនុ បិទភ្នែកសមគំនិតកងទ័ពវៀតកុង-វៀតណាមខាងជើង បើកការវាយប្រហារទៅលើរបបវៀតណាមខាងត្បូងនេះ អាមេរិក នឹងមិនអាចទ្រាំទ្រយូរទៀតបានទេ។ ចាំមើល ក្រោយពេល និចសុន ( Richard Nixon ) ឈ្នះឆ្នោតជាប្រធានាធិបតី គាត់មានគំនិតសុទិដ្ឋិនិយមថាអ្វីៗគ្រប់យ៉ាងនឹងល្អប្រសើរឡើងវិញ ហើយពួកយើងក៏អាចនឹងបានជួបគ្នាជាគូវាសនាដែរ ។ ប៉ុន្តែ នាងបានជំទាស់នឹងគំនិតសុទិដ្ឋិនិយមនេះ ។

បន្ទាប់ពីនាំនាងទៅលេងកម្សាន្តនៅក្លឹបការឌីណាមក សូម្ពួរ៉ា ក៏បានត្រលប់ទៅទីក្រុងភ្នំពេញ វិញ។ ពីរបីសប្តាហ៍ក្រោយមក នាងបានសរសេរសំបុត្រមួយច្បាប់ដោយប្រើពាក្យខឹងសម្បាយ៉ាងខ្លាំង ផ្ញើមកឱ្យគាត់ ហើយនៅចុងបញ្ចប់នៃសំបុត្រនោះ នាងបានបញ្ជាក់ប្រាប់ឲ្យគាត់ឈប់ផ្ញើសំបុត្រទៅឱ្យនាងទៀត ។

ក្រោយមក គាត់បានដឹងថា មូលហេតុដែលធ្វើឱ្យសូម្ពួរ៉ា មានការខឹងសម្បាខ្លាំងនោះ គឺដោយសារម្តាយគាត់( អ៊ុម អេម )បានសរសេរសំបុត្រខ្លីមួយទៅម្តាយសូម្ពួរ៉ា ជាមិត្តភក្តិចាស់របស់គាត់ ដោយគ្មានការស្ទាបស្ទង់ចិត្តជាមុន ដើម្បីសុំស្តីដណ្តឹងសូម្ពួរ៉ា ហើយម្តាយគាត់ក៏ពុំបានប្រាប់រឿងនេះឱ្យគាត់បានដឹងបន្តិចដែរ ។

គាត់យល់ថា ការផ្តើមគំនិតរបស់ម្តាយគាត់បែបនេះ មិនត្រឹមតែមិនត្រូវកាលៈទេសៈប៉ុណ្ណោះទេ គឺថែមទាំងជាមហន្តរាយទៀតផង ពីព្រោះនេះអាចចាត់ទុកថា ជាការមិនគោរពបែបបទប្រពៃណីខ្មែរ និងជាការប្រមាថមាក់ងាយមួយ បើទោះបីម្តាយគាត់ និងម្តាយសូម្ពួរ៉ា ជាមិត្តភក្តិនឹងគ្នាក៏ដោយ ។

ពេលនេះគឺច្បាស់ណាស់ ពួកគាត់ទាំងពីរនឹងមិនអាចបានជួបគ្នាជាគូអនាគតបានឡើយ។ គាត់ត្រូវបានគេចាត់ទុកថា ជាកូនជនក្បត់ជាតិ ជាកូនជនថោកទាបខណៈសូម្ពួរ៉ា ជាកូនស្រីរបស់មន្ត្រី ដែលមានភក្តីភាពបំផុតចំពោះសម្តេចសីហនុ ។

*សម រង្ស៊ី នៅចាំបានថា កាលសូម្ប៉ា មានអាយុ១៣ ឬ១៤ឆ្នាំ បន្ទាប់ពីបានបញ្ជូនអ្នកបែចូវមកស្តាបស្ទង់ពីរបី ដងមក គ្រួសារអភិជនមួយបាននាំកូនកំលោះរបស់ខ្លួនមកជួបម្តាយឪពុករបស់នាង ក្នុងបំណងចង់ផ្សារសាច់ឈាមនឹងគ្នា ។ ពេលកំពុងពិភាក្សាគ្នានោះ គេឃើញ សូម្ប៉ា ដែលជិះកង់លើផ្លូវដីហុយមួយចេញទៅក្រៅអស់រយៈពេល៣ម៉ោងហើយនោះ បានត្រលប់មកដល់ផ្ទះវិញ ដោយជើងនាងប្រឡាក់ដីស្រមក និងបែកញើសពេញខ្លួន ហើយក្បាលជង្គង់ និងកំភួនជើងនាងរលាត់ស្បែកដោយសារដួលកង់ទៀតផង ។*

*ដោយមិនដឹងថា មានភ្ញៀវនៅក្នុងផ្ទះ នាងសប្បាយរីករាយ ហើយស្រែកច្រៀងយ៉ាងរំភើយ។ ម្តាយកូនកំលោះសួរម្តាយឪពុកនាងថា នាងគឺសូម្ប៉ា ឬ? ឧត្តមសេនីយ៍ជូឡុង ឆ្លើយកុហកថា មិនមែនទេ នាងជាកូនពៅ! ។ ការពិត ឧត្តមសេនីយ៍ជូឡុង មានកូន៧នាក់ ហើយសុទ្ធតែស្រីទាំងអស់ គឺគ្មានប្រុសម្នាក់ទេ។ សូម្ប៉ា ជាកូនទី៤ ហើយនាងមានមុខមាត់ស្រដៀងគ្នានឹងកូនស្រីទី៧ ដែលជាកូនពៅនោះដែរ ។*

*សម រង្ស៊ី បានរម្លឹកថា តាមប្រពៃណីសម័យនោះ ជាទូទៅគេចង់ឲ្យកូនស្រីរៀបការនៅវ័យក្មេង។ តែចំពោះឧត្តមសេនីយ៍ជូឡុង និងភរិយា មិនចង់ឱ្យសូម្ប៉ា រៀបការនៅវ័យក្មេងពេកទេ ហើយអ្វីដែលពួកគាត់ឆ្លើយ កុហកថា នាងមិនមែនសូម្ប៉ា នោះក៏ព្រោះតែមិនចង់ឲ្យភ្ញៀវអាក់អន់ស្រពន់ចិត្តតែប៉ុណ្ណោះ ។*

*តាមពិតទៅ គ្រួសារអភិជនមួយនោះមានបំណងចង់ចងសម្ព័ន្ធមេត្រីភាពឱ្យកាន់តែជិតស្និទ្ធជាមួយឧត្តមសេនីយ៍ញឹក ជូឡុង ច្រើនជាងចង់បានសូម្ប៉ា ជាកូនប្រសា ។ ចុងក្រោយមានបុរសម្នាក់ជាកូនប្រុសរបស់ប្រធានក្រុមហ៊ុនជាតិដ៏ធំមួយរបស់ប្រទេសកម្ពុជាបានឃើញសូម្ប៉ា នៅក្នុងពិធីរៀបអាពាហ៍ពិពាហ៍បងស្រីរបស់នាង ( ជូឡុង កេតធី) ជាមួយបុត្រារបស់សម្តេចសីហនុ គឺព្រះអង្គម្ចាស់ចក្រពង្ស ក្នុងឆ្នាំ១៩៦៥។ បុរសអភិជនមានកិត្តិយសខ្ពង់ខ្ពស់នោះ មានអាយុ៤០ឆ្នាំទៅហើយនោះ បានបង្ហើបប្រាប់គ្រួសារញឹក ជូឡុង ថា គេចង់បានសូម្ប៉ា ដែលទើបមានអាយុ១៥ឆ្នាំនោះ ធ្វើជាគូអនាគត។*

ទោះបីឪពុកម្តាយរបស់សូមួរ៉ា ដឹងថា គម្លាតអាយុពួកគេទាំងពីរនាក់ខុសគ្នាឆ្ងាយពេក ក៏ដោយ ក៏ម្តាយនាងបានទៅ រកគ្រូហោរាទស្សន៍ទាយគុណគូរលេខមើល ដើម្បីចង់ដឹងថា ក្រោយពេលបានកូនស្រីគាត់បានក្លាយជាភរិយាហើយ តើបុរសនេះនៅតែមានស្រីញី និងប្រពន្ធចុងច្រើនថែមទៀតឬទេ? ចម្លើយគឺមិនចាំបាច់ទៅគ្រូហោរាណាទស្សន៍ទាយ ទេ ព្រោះសម័យនោះ បុរសជាអភិជនអ្នកមានឋានៈបុណ្យស័ក្តិខ្ពង់ខ្ពស់ ជាទូទៅតែងតែមានប្រពន្ធចុង និងប្រពន្ធលួចលាក់ច្រើនរាប់មិនអស់ ជារឿងធម្មតា ។

ទីបំផុត ដោយមិនចាំបាច់សួរចិត្តសូមួរ៉ា មួយម៉ាត់ ឪពុកម្តាយរបស់នាងក៏បានឆ្លើយយ៉ាងខ្លីថា ពេលនេះ កូនស្រីគាត់នៅក្មេងពេក រង់ចាំបីឆ្នាំទៀត គឺក្រោយពេលនាងប្រឡងជាប់បាក់ឌុបហើយសិន ។ពួកគាត់សង្ឃឹមថា បីឆ្នាំទៀត បុរសម្នាក់នេះនឹងមិនអាចរង់ចាំកូនស្រីពួកគាត់បានឡើយ។ ម្យ៉ាងពួកគាត់ចង់ឱ្យនាងបន្តការសិក្សាឱ្យបានវែងឆ្ងាយទៅមុខទៀតផងដែរ ។

ចុងឆ្នាំ១៩៦៨ នៅក្រុងភ្នំពេញ សូមួរ៉ា បានប្រឡងជាប់បាក់ឌុប សម រង្ស៊ី សង្ឃឹមថា នាងនឹងមកបន្តការសិក្សា នៅប្រទេសបារាំង ហើយពួកគាត់បានរស់នៅជិតគ្នាជាមិនខាន។ ប៉ុន្តែ ក្តីសង្ឃឹមរបស់គាត់ត្រូវរលាយអស់ ។ នាងមិនព្រមមកបន្តការសិក្សានៅទីក្រុងប៉ារីស ព្រោះនាងខ្លាចឃ្លាតឆ្ងាយពីម្តាយឪពុក នាងក៏ចុះឈ្មោះចូលរៀនឆ្នាំទី១ នៅមហាវិទ្យាល័យច្បាប់ ក្នុងទីក្រុងភ្នំពេញ ។

ជាមួយគ្នានោះ សម រង្ស៊ី ចេះតែព្រួយបារម្ភថា ថ្ងៃណាមួយ សូមួរ៉ា អាចនឹងសរសេរសំបុត្រមកប្រាប់គាត់ថា ឪពុកម្តាយនាងនឹងឱ្យនាងរៀបការយ៉ាងអធិកអធមបំផុត ជាមួយកំលោះជាកូនអភិជន ឬជាកូនមន្ត្រីជាន់ខ្ពស់ណាម្នាក់ជាមិនខាន ព្រោះជាច្រើនឆ្នាំមក នាងមានគ្រួសារអភិជន និងមន្ត្រីជាន់ខ្ពស់ជាច្រើនបានចូលមកចែចូវចង់ភ្ជាប់និស្ស័យជាមួយនាងជាបន្តបន្ទាប់ ។

នាសរទរដូវ( រដូវស្លឹកឈើជ្រុះ) ឆ្នាំ១៩៦៩ ពេលកំពុងអស់សង្ឃឹមថា មិនអាចមានវាសនាបានជួបសូមួរ៉ា ទៀតទេនោះ ស្រាប់តែមានដំណឹងថា ឧត្តមសេនីយ៍ញឹក ជូឡុង

ត្រូវចូលនិវត្តន៍ ដោយសារគាត់មានវ័យចាស់ជរាទៅហើយ។ ម្យ៉ាងទៀត ចៅពីរនាក់របស់គាត់ក៏បានកើតនៅទីក្រុងប៉ារីស ដែរ។ ដូច្នេះ ឧត្តមសេនីយ៍ញឹក ជូឡុងបានសម្រេចចិត្តនាំក្រុមគ្រួសារផ្លាស់ប្តូរទីលំនៅមកនៅទីក្រុងប៉ារីស។ ដំណឹងនេះធ្វើឱ្យគាត់មានការសប្បាយរីករាយ និងភ្ញាក់ផ្អើលជាខ្លាំង ។

ពេលបវេសនកាល សូមួរ៉ា ក៏បានចុះឈ្មោះចូលរៀនថ្នាក់ឆ្នាំទី២ ផ្នែកច្បាប់នៅមហាវិទ្យាល័យក្រុងសូសូ ( Soceaux )។ ពេលល្ងាចមួយ ម្តាយសូមួរ៉ា បានឲ្យនាងយកកន្ត្រកដាក់ម្ហូបអាហារខ្មែរមួយមកឲ្យម្តាយគាត់ ហើយបានផ្តាំផ្ញើថា កូនឯងមិនបាច់ឡើងទៅដាន់លើយកទៅឲ្យផ្ទាល់ទេ គឺកូនឯងទុកកន្ត្រកនេះ ផ្ញើនៅបុគ្គលិកសន្តិសុខយាមអាគារនោះបានហើយ ចាំម្ចាស់ផ្ទះគេចុះមកយក។ តែនាងភ្លេចបណ្តាំម្តាយ ក៏ឡើងទៅដល់ផ្ទះដែលនៅខាងលើ ។

ចៃដន្យ ពេលនោះគាត់ទើបត្រលប់មកពីហែលទឹកវិញ សក់គាត់នៅទទឹកនៅឡើយ ភ្នែកគាត់ឡើងក្រហម បើកទ្វារឡើង ឃើញនាងនៅពីមុខ ធ្វើឱ្យគាត់មានការភ្ញាក់ផ្អើលស្រឡាំងកាំងយ៉ាងខ្លាំង។ សូមួរ៉ា និយាយមកកាន់ គាត់ថា៖ ម៉ាក់ឲ្យខ្ញុំយកម្ហូបអាហារខ្មែរមួយកន្ត្រកនេះ មកជូនម៉ាក់លោក!។ គាត់នៅតែស្រឡាំងកាំងកាំងស្មារតី សម្លឹងមុខនាងមិនដាក់ភ្នែក ដោយទុកឲ្យនាងឈរយួរកន្ត្រកដ៏ធ្ងន់នោះនៅមាត់ទ្វារយ៉ាងយូរ ។ រហូតដល់នាងលាន់មាត់ និងអស់សំណើចចំពោះកាយវិការគាត់ថា ម៉េចលោកឯង មិនឱ្យខ្ញុំចូលទៅខាងក្នុងទេឬ? គាត់ក៏ប្រញាប់ទទួលកន្ត្រកពីដៃនាងហើយចូលក្នុងផ្ទះជជែកគ្នាលេងដោយរីករាយ ដូចកាលពីពេលជួបគ្នាមុនៗដែរ។ ចាប់ពីពេលនោះមកពួកគាត់ក៏មានឱកាសជួបសារសេងគ្នាជាបន្តបន្ទាប់ ដោយមិនឲ្យឪពុកម្តាយពួកគាត់ទាំងពីរដឹងឡើយ ។

ជាមួយគ្នានោះ គាត់បានជូននាងទៅមហាវិទ្យាល័យនៅក្រុងសូសូ( Soceaux ) ។ បន្ទាប់មកពួកគាត់ទាំងពីរបានរៀបចំត្រៀមមេរៀនជាមួយគ្នា។ ពួកគាត់ដើរកម្សាន្តជាមួយគ្នា ហើយសន្យាថាស្រឡាញ់គ្នាជារៀងរហូត ។

# ២៥៤
# សម រង្ស៊ី ទម្លាយអាថ៌កំបាំងពីការបាត់ខ្លួន សម សារី ជាឪពុក



សម សារី និងកញ្ញាអ៊ិន អេម ពេលរៀបមង្គលការ

*អាថ៌កំបាំងនៃការបាត់ខ្លួនរបស់សម សារី តាំងពីដើមទីមក ធ្វើឱ្យសម រង្ស៊ី ព្រមទាំងម្តាយ និងបងៗគាត់ចង់ដឹងការពិតខ្លាំងឡើងៗ។ នៅទីក្រុងប៉ារីស ក្រោយពីជីវភាពរស់នៅរបស់ពួកគាត់ធូរជារគ្រាន់បើបន្តិច បងប្រុសគាត់អេម៉្មារិទ្ធ បានចំណាយពេលវេលា និងថាមពលយ៉ាងច្រើន ដើម្បីធ្វើការស្រាវជ្រាវពីអាថ៌កំបាំងនៃការបាត់ខ្លួនរបស់ឪពុកគាត់ ។*

*សម រង្ស៊ី បានអះអាងថា ក្រោយពីបងប្រុសគាត់អេម៉្មារិទ្ធ បានប្រមូលឯកសារនិងសក្ខីកម្មថ្មីៗជាច្រើនមក ពួកគាត់ រកឃើញការពិតមួយដែលមានការខុសប្លែកពីឯកសារនិងសក្ខីកម្មពីពេលមុនៗ។ ពួកគាត់ឈប់យល់ច្រឡំដូចមុនទៀតថា សម្តេចសីហនុ បានឲ្យគេលួចធ្វើឃាតឪពុកពួកគាត់...។*

*នៅចុងឆ្នាំ១៩៦៥ ក្រោយពេលពួកគាត់មកដល់ទីក្រុងប៉ារីស ឡេអុង ស្ហេហ្ស៍ម៉ាតាំង ( Leon Chaisemartin ) ដែលឪពុកគាត់ស្រលាញ់គោរពចាត់ទុកជាឪពុកធម៌ តាំង*

ពីឪពុកពួកគាត់មកសិក្សាផ្នែកវិទ្យាសាស្ត្រនយោបាយ កាលពីចុងទសវត្សរ៍ឆ្នាំ១៩៤៩ នោះ បានប្រគល់សំបុត្រជាច្រើន ដែលលោកបានទទួលពីឪពុកពួកគាត់ ។

សំបុត្រទាំងអស់នោះត្រូវបានឪពុកពួកគាត់ផ្ញើមកឱ្យលោក ក្រោយពេលឪពុកគាត់បានរត់គេចខ្លួនចេញពីក្រុងភ្នំពេញ ក្នុងឆ្នាំ១៩៥៩ ទៅចូលរួមក្នុងចលនាខ្មែរសេរីរបស់ សឺង ង៉ុកថាញ់ ដើម្បីប្រឆាំងសម្តេចសីហនុ មកម្ល៉េះ ។

សំបុត្រទាំងអស់នោះ ក៏បានលាតត្រដាងពីអាថ៌កំបាំងនៃការបាត់ខ្លួនរបស់ឪពុកគាត់ ។ តាមពិត ឪពុកគាត់( សម សារី) ពិតជាបានគាំទ្រចលនាតស៊ូដឹកនាំដោយ សឺង ង៉ុកថាញ់ ពិតមែន។ ប៉ុន្តែឪពុកគាត់បានជំទាស់ មិនឱ្យធ្វើការតស៊ូដោយប្រើអាវុធ ។ មុននឹងរត់ចេញពីទីក្រុងភ្នំពេញ ឪពុកគាត់ក៏បានផ្ញើសំបុត្រមួយទៅជីតារបស់គាត់ឈ្មោះ សម ញាណ ដើម្បីសុំយោបល់ដែរ។

ក្រោយពីឪពុកគាត់រត់ចេញពីទីក្រុងភ្នំពេញ មិនបានប៉ុន្មានសប្តាហ៍ផង ក៏មានអំពើភេរវកម្មមួយបានកើតឡើងនៅក្នុងព្រះបរមរាជវាំង សំដៅទៅលើព្រះមហាក្សត្រ សុរាម្រិត។ អំពើភេរវកម្ម( បំផ្ទុះគ្រាប់បែក)នេះ ធ្វើឲ្យបងប្អូនជីដូនមួយរបស់ព្រះមហាក្សត្រមួយអង្គ( នរោត្តម វ៉ាគ្រីវ៉ាន់ នាយកពិធីការព្រះបរមរាជវាំង)ត្រូវសោយទិវង្គត ។

ក្រោមលេសនៃអំពើភេរវកម្មនេះ ម្តាយ និងសមាជិកគ្រួសារខាងឪពុកគាត់មួយចំនួនត្រូវចាប់ខ្លួន។ ពេលនោះ ទោះបី ឪពុកគាត់កំពុងដឹកនាំចលនាខ្មែរសេរីជាមួយសឺង ង៉ុកថាញ់ ពិតមែន តែឪពុកគាត់បានសរសេរលិខិតមួយផ្ញើមកថ្វាយសម្តេចសីហនុដើម្បីសម្តែងនូវការចូលរួមមរណទុក្ខចំពោះព្រះអង្គ ដោយមិនមានប្រើភាសាបង្កប់ន័យអ្វីផ្សេងនោះទេ។

សម រង្ស៊ី បានបញ្ជាក់បន្ថែមថា ចាប់តាំងពីរត់គេចខ្លួនចេញពីក្រុងភ្នំពេញ ក្នុងខែមេសា ឆ្នាំ១៩៥៩ បានតែ៣ខែប៉ុណ្ណោះ ឪពុកគាត់បានផ្ញើសំបុត្រជាច្រើនមកថ្វាយសម្តេចសីហនុ។ តែយ៉ាងណា គាត់( សម រង្ស៊ី) សុំមិនបង្ហាញឱ្យឃើញសំបុត្រនោះទេ បើទោះបីជាសំបុត្រនោះវាមានសារៈសំខាន់ពាក់ព័ន្ធក្នុងរឿងនយោបាយយ៉ាងណា ក៏

ដោយ ។

សម រង្ស៊ី បានបន្ថែមថា នៅក្នុងសំបុត្រនោះ គាត់ពិនិត្យឃើញមានការបែកបាក់នយោបាយនៅក្នុងក្រុមប្រឆាំងស្តាំនិយម ពិសេសបង្ហាញថា ទោះបីឪពុកគាត់រត់គេចខ្លួនចេញពីក្រុងភ្នំពេញ ទៅចូលរួមដឹកនាំចលនាខ្មែរសេរីជាមួយសឺង ង៉ុកថាញ់ ( នៅប្រទេសវៀតណាមខាងត្បូង)អស់រយៈពេលជាច្រើនខែមកហើយពិតមែន តែឪពុកគាត់នៅតែមានបំណងទាក់ទងជាមួយសម្តេចសីហនុ ទាំងផ្នែកនយោបាយ និងមិត្តភាពផងដែរ ។

ខ្លឹមសារក្នុងសំបុត្រទាំងនោះ ពីមួយបន្ទាត់ទៅមួយបន្ទាត់ ឪពុកគាត់ហាក់ដូចជាបានបង្ហាញឱ្យដឹងថា គាត់ជាបុរសអស់សង្ឃឹមម្នាក់កំពុងតែទាល់ច្រកក្នុងអន្ទាក់មួយដែលរឹតរួតរូបគាត់កាន់តែខ្លាំងឡើងៗ ហើយគាត់កំពុងព្យាយាមរកវិធីដោះខ្លួនចេញពីអន្ទាក់នោះ ដើម្បីវិលត្រលប់មកជួបជុំគ្រួសារនៅក្រុងភ្នំពេញ វិញ ។

ខុសពីអ្នកនយោបាយផ្សេងៗទៀត ឪពុកគាត់មិនចង់បំផ្លាញរបបរាជានិយមនៅកម្ពុជាទេ គឺគ្រាន់តែចង់កែទម្រង់ប៉ុណ្ណោះ។ ឪពុកគាត់ស្រមៃចង់បានរបបរាជាធិបតេយ្យអាស្រ័យសភា ដូចនៅប្រទេសអង់គ្លេស និងអញ្ញាក្រឹតពិតប្រាកដ មិនលំអៀងទៅរកពួកកុម្មុយនិស្ត ។ គ្មានអ្វីលើសពីហ្នឹងទេ ។

ដូច្នេះឪពុកគាត់បានស្នើសុំសម្តេចសីហនុ ឱ្យមានការព្រមព្រៀងគ្នាមួយ ដើម្បីឪពុកគាត់ចាកចេញពីចលនាខ្មែរសេរី ដែលប្រឆាំងនឹងព្រះអង្គ ។ តែសម្តេច សីហនុ មិនទទួលយកសំណើរនេះទេ ។

ចំណុចសំខាន់នៃការមិនចុះសម្រុងគ្នារវាងឪពុកគាត់ និងសឺង ង៉ុកថាញ់ គឺះ ទី១.ពាក់ព័ន្ធនឹងរាជានិយម និងសាធារណរដ្ឋនិយម ។ ទី២. ប្រសិនបើចលនាខ្មែរសេរីទទួលជោគជ័យ បានឡើងកាន់អំណាច គឺច្បាស់ជាត្រូវសងបំណុលទៅសម្ព័ន្ធមិត្តវៀតណាមខាងត្បូង និងថៃ ដោយប្រគល់ទឹកដីមួយផ្នែករបស់កម្ពុជា ទៅឲ្យពួកគេ ។ ឪពុកគាត់បដិសេធដាច់ខាតក្នុងការឡើងកាន់អំណាចបែបនេះ។ តែសឺង ង៉ុកថាញ់ មិនអត់ឱនឱ្យឪពុកគាត់ដកខ្លួនវិលទៅរកសម្តេចសីហនុ វិញឡើយ ។

នៅទីក្រុងបាងកក ឪពុកគាត់បានលួចផ្ញើសំបុត្រជាបន្តបន្ទាប់ទៅថ្វាយសម្ដេចសីហនុ ដោយប្រើវិធីបង្វែងដានយ៉ាងសម្ងាត់បំផុត។ ឪពុកគាត់បានឱ្យអ្នកបើករថយន្តរបស់គាត់ម្នាក់យកសំបុត្រដែលគាត់បន្ទំដាក់អាសយដ្ឋានក្លែងក្លាយ ផ្ញើទៅ វីល្លៀម ហាំប្រេយ៍ ( William Humphreys ) នៅទីក្រុងឡុង និងគ្រួសារឡេអុង ស្ហែហ្ស៍ម៉ាតាំង ( Leon Chaisemartin ) នៅទីក្រុងប៉ារីស ជាបន្តបន្ទាប់ ក្នុងបំណងចាកចេញពីក្រុមប្រឆាំងខ្មែរសេរី និងត្រៀមខ្លួនចូលមករស់នៅក្នុងសង្គមជាតិវិញ ក្រោមការការពាររបស់សម្ដេចសីហនុ ។ ប៉ុន្តែគ្មានលទ្ធផលអ្វីតបមកវិញសោះ ។ មិនតែប៉ុណ្ណោះ មិនយូរប៉ុន្មាន សំបុត្រមួយចំនួន ដែលគាត់ផ្ញើទៅថ្វាយសម្ដេចសីហនុ ត្រូវសឺង ង៉ុកថាញ់ ចាប់បានធ្វើឱ្យឪពុកគាត់ បានធ្លាក់ទៅក្នុងស្ថានភាពដ៏ស្មុគស្មាញគ្រោះថ្នាក់បំផុត ។

បងប្រុសរបស់គាត់ ឈ្មោះអេម៉្មារិទ្ធ បានចំណាយពេលវេលាស្រាវជ្រាវជាច្រើនឆ្នាំទម្រាំដឹងថា ឪពុករបស់គាត់បានបាត់បង់ជីវិត ដោយសារមេដឹកនាំខ្មែរសេរី មិនមែនដោយសារសម្ដេចសីហនុ នោះទេ ។

សម រង្ស៊ី បញ្ជាក់ថា នាចុងឆ្នាំ១៩៦២ ឬដើមឆ្នាំ១៩៦៣ ពេលឪពុកគាត់ដឹកនាំកងកម្លាំងមួយចំនួនទៅធ្វើសកម្មភាពនៅក្នុងខេត្តប៉ាក់សេ ភាគខាងត្បូងនៃប្រទេសឡាវ ត្រូវអង្គរក្សគាត់ម្នាក់ជាកម្លាំងបង្កប់របស់សឺង ង៉ុកថាញ់ ដកកាំភ្លើងបាញ់សម្លាប់ឪពុកគាត់ពីក្រោយខ្នងយ៉ាងកំសាកបំផុត។

សម រង្ស៊ី បញ្ជាក់បន្ថែមថា មានសក្ខីកម្មជាច្រើនបានបញ្ជាក់ពីហេតុការណ៍បាញ់សម្លាប់ឪពុកគាត់ដ៏កំសាកនេះ ។ នៅក្នុងឆ្នាំ១៩៦៥ សម្ដេចសីហនុ បានដឹងច្បាស់ថាសម សារី ជាឪពុកគាត់បានបាត់បង់ជីវិតទៅហើយ ដូច្នេះ ព្រះអង្គគ្មានហេតុផលអ្វីដែលត្រូវទុកពួកគាត់ជាប្រពន្ធកូនរបស់សម សារី ឲ្យបិតនៅក្រោមការឃ្លាំមើលតទៅទៀតឡើយ ។ ដូច្នេះ ព្រះអង្គក៏បាននិរទេសពួកគាត់ចេញពីមាតុប្រទេសឱ្យទៅប្រទេសវៀតណាមខាងត្បូង ។

មូលហេតុដែលសម្ដេចសីហនុ និរទេសពួកគាត់ឱ្យចេញពីមាតុប្រទេសនេះ ក៏

មិនខុសគ្នាពីក្រោយពេលពួកគាត់ទៅដល់ប្រទេសវៀតណាមខាងត្បូងហើយ សឺង ង៉ុកថាញ់ សុខចិត្តផ្តល់ប្រាក់ដុល្លារមួយចំនួន ដើម្បីឲ្យពួកគាត់ចាកចេញពីទីក្រុងព្រៃនគរ (សាយហ្គន) ទៅរស់នៅប្រទេសបារាំង បន្តទៀតនោះដែរ ។

ពាក់ព័ន្ធអាថ៌កំបាំងរឿងនរណាជាអ្នកសម្លាប់សម សារី នេះ អតីតសាស្ត្រាចារ្យម្នាក់នៅវិទ្យាល័យព្រះស៊ីសុវត្ថិ ឈ្មោះអ៊ុច គិរម្យ រស់នៅសហរដ្ឋអាមេរិក បានអះអាងថា គាត់បានសួរបញ្ជាក់ឡឹក សំអឿន ជាអតីតមេចលនាតស៊ូខ្មែរសេរីនៅប្រទេសថៃ ដែលក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ បានទៅរស់នៅសហរដ្ឋអាមេរិក ជាមួយគាត់ ពីរឿងអាថ៌កំបាំងនៃការបាត់ខ្លួនរបស់សម សារី នេះដែរ ។ តែឡឹក សំអឿន បញ្ជាក់ថា មិនមែនកម្លាំងរបស់សឺង ង៉ុកថាញ់ ជាអ្នកបាញ់សម្លាប់សម សារី ដូចដែលសម រង្ស៊ី បានលើកឡើងនោះទេ ។

ឡឹក សំអឿន ក៏ធ្លាប់បានបញ្ជាក់ថា គឺពួកសេអ៊ីអា (CIA) របស់អាមេរិក និងមេប៉ូលិសថៃ បានសហការគ្នាប្រើល្បិចនាំសម សារី យកទៅសម្លាប់ចោលនៅខេត្តចំប៉ាសាក់ប្រទេសឡាវ ។

ស្របគ្នានេះដែរ ក៏មានប្រភពព័ត៌មានបរទេសមួយ បានឱ្យដឹងថា ពួកសេអ៊ីអា (CIA) របស់អាមេរិក បាននាំសម សារី ជិះឧទ្ធម្ភាគចក្រចេញពីប្រទេសថៃ លុះមកដល់ត្រង់ព្រំដែនប្រទេសកម្ពុជា និងប្រទេសឡាវ ក៏បានជាក់ទម្លាក់សម សារី ពីលើឧទ្ធម្ភាគចក្រដើម្បីសម្លាប់តែម្តង ។ តែរហូតមកដល់សព្វថ្ងៃនេះ នៅតែគ្មានព័ស្តុតាង ឬសាក្សីណាម្នាក់ចេញ មុខមកបញ្ជាក់ថានេះ ជាការពិតដែរ ។

ពាក់ព័ន្ធករណីអាថ៌កំបាំងនរណាជាអ្នកសម្លាប់សម សារី នេះដែរប្រវត្តិវិទូដេវីដ ឆានល័រ (David Chandler) បានសរសេរខ្ញីថា សម សារី ត្រូវពួកចៅហ្វាយបរទេសរបស់គាត់ជាអ្នកសម្លាប់ ។ តែប្រវត្តិវិទូរូបនេះ មិនបានបង្ហាញ ព័ស្តុតាង និងថ្ងៃខែច្បាស់លាស់ទេ គ្រាន់តែសេសេរថា ការសម្លាប់នោះ គឺនៅក្នុងអំឡុង ឆ្នាំ១៩៦២ ។

# ២៥៥
# សម្តេចសីហនុ ថតភាពយន្ត និងបើកកាស៊ីណូ



សម្តេចសីហនុ ពេលដឹកនាំថតខ្សែភាពយន្ត

ចាប់ពីឆ្នាំ១៩៦៧មក ដោយសារអំពើពុករលួយកាន់តែរីករាលដាលខ្លាំងឡើងៗ ធ្វើឱ្យសេដ្ឋកិច្ចជាតិក៏កាន់តែស្រុតចុះ ហើយការរត់ពន្ធអង្ករទៅលក់ឱ្យកងទ័ពវៀតកុង-វៀតណាមខាងជើង កាន់តែកើនច្រើនឡើងៗ ធ្វើឱ្យប្រទេសជាតិ ជួបវិបត្តិសេដ្ឋកិច្ចកាន់ធ្ងន់ធ្ងរទៅៗ ។

ក្នុងគោលបំណងរកប្រាក់កាសមកបំពេញថវិការដ្ឋ ដែលកំពុងមានការខ្វះខាត សម្តេចសីហនុ ក៏បានឱ្យបើកបនល្បែងស៊ីសង(កាស៊ីណូរដ្ឋ)មួយកន្លែងនៅភ្នំពេញ នៅខាងក្រោយសណ្ឋាគារកាំបូឌីយ៉ាណា ជាប់មាត់ទន្លេចតុមុខ, នៅក្រុងព្រះសីហនុ និងនៅលើកំពូលភ្នំបូកគោ ។

ជនជាតិចិននៅទីក្រុងម៉ាការមួយក្រុមបានមកវិនិយោគទុនក្នុងការបើកកាស៊ីណូនោះ ត្រូវបង់ពន្ធចូលរដ្ឋក្នុងមួយថ្ងៃ ១.២៥០.០០០ រៀល( ស្មើនឹង២៥០០០ដុល្លារ)។ ប៉ុន្មានខែ

ក្រោយមក ដោយសារមានភ្ញៀវចូលលេងកាន់តែច្រើនឡើងៗពួកគេត្រូវបង់ប្រាក់ចូលរដ្ឋ ពី១៥០ ០០០ដុល្លារ ទៅ២០០ ០០០ដុល្លារក្នុងមួយថ្ងៃ ហើយក្រោយមកទៀត នៅថេរនៅត្រឹម ៨០ ០០០ដុល្លារក្នុងមួយថ្ងៃវិញ ។ ប៉ុន្តែថវិកាដែលបានមកពីការបើកកាស៊ីណូនេះ ត្រូវពួកមន្ត្រីពុករលួយបន្លំកិបកេងអស់មួយភាគធំ ។

ក្រោយពីបើកកាស៊ីណូ ឱ្យលេងជាផ្លូវការនោះ ល្បែងស៊ីសងទាំងឡាយនៅកន្លែងផ្សេងៗទៀតត្រូវហាមឃាត់ ។ បើនរណាហ៊ានលេងល្បែងស៊ីសងនៅកន្លែងហាមឃាត់នោះនឹងត្រូវកម្លាំងសមត្ថកិច្ចចាប់ខ្លួនយកមកផ្តន្ទាទោសតាមច្បាប់ ។ ប៉ុន្តែនៅក្នុងឱកាសបុណ្យចូលឆ្នាំប្រពៃណីខ្មែរនៅពាក់កណ្តាលខែមេសា ជារៀងរាល់ឆ្នាំ សម្តេចសីហនុបានបើកសិទ្ធិឱ្យប្រជារាស្ត្រជាកូនចៅព្រះអង្គនៅទូទាំងប្រទេស លេងល្បែងស៊ីសងគ្រប់ប្រភេទដោយសេរី រយៈពេល៣ថ្ងៃ ៣យប់ផងដែរ បើផុតកំណត់នេះទៅ ប្រជារាស្ត្រជាកូនចៅណាហ៊ានលេងល្បែងស៊ីសងបន្តទៀត នឹងត្រូវកម្លាំងសមត្ថកិច្ចចាប់ខ្លួន ។

មកដល់ឆ្នាំ១៩៦៩ ការបើកកាស៊ីណូនោះ បង្ហាញឱ្យឃើញនូវផលវិបាកជាច្រើន ព្រោះមិនថាតែពួកអ្នកមាន ពួកមន្ត្រីរាជការធំៗមួយចំនួននោះទេ សូម្បីប្រជាកសិករខ្មែរខ្លះនៅជនបទ ក៏នាំគ្នាចូលទៅលេងល្បែងស៊ីសងនៅកាស៊ីណូនោះ ភាគច្រើនចាញ់អស់ប្រាក់កាស លក់គោក្របី លែងហ៊ានវិលត្រលប់ទៅផ្ទះសម្បែងនៅឯស្រុកស្រែចម្ការវិញ ហើយមួយចំនួនគ្មានវិធីអ្វីដោះស្រាយ គឺមានតែធ្វើអត្តឃាតដោយចងក ឬលោតទឹកសម្លាប់ខ្លួន ។

ចំណែកអ្នកនៅទីក្រុងភ្នំពេញមួយចំនួន ក្រោយពីចាញ់អស់ប្រាក់កាស មាសប្រាក់ផ្ទះសម្បែង បានទៅលោតទឹកសម្លាប់ខ្លួនពីលើស្ពានជ្រោយចង្វា និងស្ពានក្បាលថ្នល់ (ស្ពានព្រះមុនីវង្ស) ជាបន្តបន្ទាប់ដែរ ។

ពេលនោះដែរ សម្តេចសីហនុ ក៏បានធ្វើការស្ទាបស្ទង់ជាសម្ងាត់ក្នុងបំណងផ្សារទំនាក់ទំនងការទូត ជាមួយសហរដ្ឋអាមេរិក ឱ្យបានល្អប្រសើរវិញ ហើយព្រះអង្គក៏បានស្នើសុំឱ្យប្រទេសកម្ពុជា បានចូលជាសមាជិកស្ថាប័នធនាគារពិភពលោក(World Bank),

ធនាគារអភិវឌ្ឍន៍អាស៊ី(ADB) និងមូលនិធិរូបិយវត្ថុអន្តរជាតិ(IMF) ដែលស្ថាប័នឥណទានទាំង៣នោះ សុទ្ធតែនៅក្រោមឥទ្ធិពលរបស់អាមេរិក ។

ឱនភាពថវិកាជាតិបានធ្លាក់ចុះពី ២០០លានរៀល ក្នុងឆ្នាំ១៩៦៨ ដល់ ២៦៥លានរៀលក្នុងឆ្នាំ១៩៦៩។ ផលិតផលកសិកម្ម គ្មានការរីកចម្រើន ហើយលទ្ធភាពនៃការនាំចេញនៅតែទាបជាងការគ្រោងទុក។ ការធ្វើកំណែទម្រង់សេដ្ឋកិច្ច ដែលរដ្ឋធ្វើជាតួបនីយកម្ម បានក្លាយទៅជាប្រភពនៃការរីករាលដាលអំពើពុករលួយ កាន់តែច្រើនឡើងៗ និងចំហឡើងៗ ពិសេសពួកមន្ត្រីនានា ដែលនៅអែបអបជុំវិញសម្ដេចសីហនុ ។

អ្នកជំនាញការខាងសេដ្ឋកិច្ចជាតិ និងអន្តរជាតិ បានព្រមានថា គេត្រូវតែចាត់ការជាបន្ទាន់ ដើម្បីរៀបចំសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាតិឡើងវិញទាំងស្រុង ដោយចាត់វិធានការណ៍កាត់បន្ថយការចំណាយសម្រាប់សកម្មភាពផ្សេងៗ ដែលមិនចាំបាច់ និងបញ្ចប់រាល់ការចំណាយទាំងឡាយដែលមិនមានគម្រោងទុកជាមុន, បញ្ឈប់ការចំណាយតាមទំនើងចិត្ត ដោយគ្រាន់តែយកមុខយកមាត់របស់បុគ្គលសំខាន់គឺត្រូវផ្ដោតការយកចិត្តទុកដាក់ទៅលើវិស័យកសិកម្ម។ ប៉ុន្តែ ដើម្បីរៀបចំស្ដារសេដ្ឋកិច្ចឡើងវិញ គឺចាំបាច់ត្រូវតែពឹងផ្អែកលើជំនួយ ឬប្រាក់កម្ចីពីបរទេស ដោយខានមិនបានឡើយ។

ចាប់ពីឆ្នាំ១៩៦៦មក សម្ដេចសីហនុ បានផ្ដោតព្រះទ័យយ៉ាងវក់វីទៅលើការថតខ្សែភាពយន្ត ដោយព្រះអង្គ និងព្រះជាយា (អ្នកម្នាងម៉ូនិក) ព្រមទាំងបុត្រាសីហមុនី ជាអ្នកសម្ដែងតួឯកផ្ទាល់ទៀតផង ។

ដំបូង ការដាក់បញ្ចាំងខ្សែភាពយន្តរបស់ព្រះអង្គ ទទួលបានជោគជ័យគួរឱ្យកោតសរសើរ និងទទួលបានប្រាក់ចំណូលយ៉ាងច្រើន ពីព្រោះប្រជារាស្ត្រស្រលាញ់ពេញចិត្ត និងចង់ដឹងចង់ឃើញព្រះភ័ក្ត្រ និងកាយវិការរបស់ព្រះអង្គ និងព្រះ ជាយា ព្រមទាំងបុត្រា សម្ដែងជាតួភាពយន្ត តើស័ក្តិសមយ៉ាងណា ទើបនាំគ្នាទៅទស្សនាយ៉ាងច្រើនកុះករ ។ លុះយូរៗ ទៅ ប្រជារាស្ត្រជាទស្សនិកជន និងប្រាក់ចំណូលក៏ចាប់ផ្ដើមធ្លាក់ចុះកាន់តែតិចទៅៗ ។




រឿងប្រជាកុមារ ស្នាព្រះហស្តរបស់សម្តេចសីហនុ ដាក់បញ្ចាំងនៅរោងភាពយន្តគិរីរម្យ

ឆ្នាំ១៩៦៦ សម្តេចសីហនុ ផលិតខ្សែភាពយន្តមានចំណងជើងថា "អប្សរា" ជាស្នាព្រះហស្តដំបូង សម្តែងជាតួឯក ដោយម្ចាស់ក្សត្រីនរោត្តម បុប្ផាទេវី និងរាជវង្ស ជាច្រើនអង្គទៀត ។ ខ្សែភាពយន្តរឿង «អប្សរា» នេះ ហ្វីលទំហំ៣៥មីលីម៉ែត្រ ត្រូវបើកពិធីសម្ពោធដាក់ឱ្យបញ្ចាំងថ្ងៃទី១៦ ខែឧសភា ឆ្នាំ១៩៦៦។

បន្ទាប់មក រឿងព្រះវិហារ ហ្វីលទំហំ៣៥មីលីម៉ែត្រ និងរឿងប្រជាកុមារ ហ្វីលទំហំ៣៥មីលីម៉ែត្រ សម្តែងជាតួឯកដោយបុត្រា នរោត្តម សីហមុនី ។

ឆ្នាំ១៩៦៧ រឿងព្រៃប្រសិទ្ធិ ហ្វីលទំហំ៣៥មីលីម៉ែត្រ និង រឿងឆាយាលើអង្គរ ហ្វីលទំហំ៣៥មីលីម៉ែត្រ ។ ចំណាយថវិកាផលិតអស់ប្រមាណ ២ម៉ឺនដុល្លារអាមេរិក ។

ឆ្នាំ១៩៦៨ រឿងវាសនាអកុសល ហ្វីលទំហំ៣៥មីលីម៉ែត្រ ។ ឆ្នាំ១៩៦៩ រឿងសន្ធិប្រកាស ហ្វីលទំហំ៣៥មីលីម៉ែត្រ, រឿងផ្កាកុលាបនៃភ្នំបូកគោ ហ្វីលទំហំ៣៥មីលីម៉ែត្រ និង រឿងសប្បាយក្នុងការរស់នៅ ហ្វីលទំហំ៣៥មីលីម៉ែត្រ ។

ឆ្នាំ១៩៧០ រឿងវាសនាអកុសល ហ្វីលទំហំ៣៥មីលីម៉ែត្រ បានថតចប់សព្វគ្រប់ និងរឿងផ្គរលាន់នៅកោះកុង ហ្វីលទំហំ៣៥មីលីម៉ែត្រ ថតពុំទាន់ចប់។ ដោយសារព្រឹត្តិការណ៍រដ្ឋប្រហារថ្ងៃ១៨ មីនា ឆ្នាំ១៩៧០ ភាពយន្តទាំងពីរនេះ ត្រូវអាក់ខានមិនបានបញ្ចាំងជាផ្លូវការទេ ។

# ២៥៦
# សម្តេចសីហនុ ចង់ភ្ជាប់ទំនាក់ទំនងការទូតជាមួយអាមេរិក ឡើងវិញ



បេសកជនពិសេស ឆេស្ទ័រ បូលីដ ជួបពិភាក្សាគ្នាជាមួយសម្តេចសីហនុ

*នៅថ្ងៃទី២១ ខែតុលា ឆ្នាំ១៩៦៧ មានប្រជាពលរដ្ឋអាមេរិក ប្រមាណ១០ម៉ឺននាក់ បាននាំគ្នាធ្វើបាតុកម្មដ៏ធំមួយនៅរដ្ឋធានីវ៉ាស៊ីនតោន ដើម្បីតវ៉ាប្រឆាំងនឹងសង្គ្រាមវៀតណាម ។ ក្នុងចំណោមនោះ មានបាតុករប្រមាណ៣ម៉ឺននាក់ បាននាំគ្នាដើរដង្ហែក្បួនទាំងយប់ ឆ្ពោះទៅកាន់មន្ទីរប៉ង់តាហ្គោន រហូតដល់មានការប៉ះទង្គិចគ្នាដោយហិង្សាជាមួយនឹងពួកទាហាន និងកងសន្តិសុខ ហើយបាតុករាប់រយនាក់ត្រូវបានចាប់ខ្លួន ។*

*បើតាមការស្ទាបស្ទង់មតិមួយ នៅដើមឆ្នាំ១៩៦៨ បានបង្ហាញថា ប្រជាពលរដ្ឋអាមេរិក ប្រមាណ៥០% បានបញ្ចេញមតិប្រឆាំងនឹងនយោបាយធ្វើសង្គ្រាមនៅវៀតណាម របស់ប្រធានាធិបតី លីនដុន ចនសុន(*Lyndon Johnson*) ហើយមានតែប្រជាពលរដ្ឋអាមេរិក ៣៥% ប៉ុណ្ណោះ ដែលគាំទ្រ ។*

ចលនាប្រជាពលរដ្ឋអាមេរិក ប្រឆាំងនឹងការធ្វើសង្គ្រាមនៅវៀតណាម ក៏បាន ក្លាយទៅជាបញ្ហានយោបាយផ្ទៃក្នុងអាមេរិក កាន់តែធ្ងន់ធ្ងរទៅៗ រហូតធ្វើឲ្យប្រធានាធិបតី លីនដុន ចនសុន ត្រូវបង្ខំចិត្តលែងឈរឈ្មោះជាបេក្ខជនប្រធានាធិបតី សម្រាប់អាណត្តិទី២។

នៅថ្ងៃទី៨ ខែមករា ឆ្នាំ១៩៦៨ ក្នុងឱកាសមកបំពេញទស្សនកិច្ចនៅទីក្រុងភ្នំពេញ ឆេស្ទ័រ បូលីដ ( Chester A. Bowled ) បេសកជនពិសេសរបស់ប្រធានាធិបតី លីនដុន ចនសុន( Lyndon Johnson ) បានចូលគាល់ និងពិភាក្សាជាមួយសម្ដេចសីហនុ ស្ដីពីបញ្ហាវត្តមានកងទ័ពវៀតកុង-វៀតណាមខាងជើង នៅក្នុងទឹកដីនៃប្រទេសកម្ពុជា ។

សម្ដេចសីហនុ បានបង្ហាញពីកង្វល់របស់ព្រះអង្គពីបញ្ហាអព្យាក្រឹតភាព និងពីបញ្ហាអធិបតេយ្យភាព បូរណភាពទឹកដីរបស់ប្រទេសកម្ពុជា ហើយព្រះអង្គក៏មានបំណងឱ្យកងទ័ពសហរដ្ឋអាមេរិក ធ្វើប្រតិបត្តិការយោធាជាទ្រង់ទ្រាយតូចៗវាយប្រហារកងទ័ពវៀតកុង-វៀតណាមខាងជើង ដែលបានចូលមកបោះទីតាំង នៅតំបន់ដាច់ស្រយាលនៃប្រទេសកម្ពុជា ផងដែរ ។ ជាមួយគ្នានោះ ព្រះអង្គក៏បានបង្ហើបពីបំណងរបស់ព្រះអង្គ ដែលចង់ស្ដារទំនាក់ទំនងការទូតជាមួយសហរដ្ឋអាមេរិក ឡើងវិញផងដែរ តែបានដាក់លក្ខខណ្ឌថា ការស្ដារទំនាក់ទំនងការទូតគ្នាឡើងវិញនេះបាន លុះត្រាតែសហរដ្ឋអាមេរិក ទទួលស្គាល់ព្រំដែនប្រទេសកម្ពុជាជាមុនសិន ។

បេសកជនពិសេស ឆេស្ទ័រ បូលីដ( Chester A. Bowled ) ក៏មានសុទិដ្ឋិនិយមថា ទនាក់ទំនងការទូតរវាងប្រទេសទាំងពីរនឹងត្រូវបានស្ដារឡើងវិញជាមិនខាន ។

ដោយសារតែវត្តមានកងទ័ពវៀតកុង-វៀតណាមខាងជើង នៅក្នុងប្រទេសកាន់តែកើនច្រើនឡើងៗ នៅក្នុងសមាជជាតិនាដើមខែមករា ឆ្នាំ១៩៦៩ សម្ដេចសីហនុ ក៏បានប្រកាសថា ប្រទេសកម្ពុជា ត្រូវតែសម្របខ្លួនទៅតាមចរន្តនៃសហប្រតិបត្តិការអន្តរជាតិ មានន័យថា ព្រះអង្គនឹងងាកទៅផ្សារទំនាក់ទំនងការទូតជាមួយ សហរដ្ឋអាមេរិកវិញ ។

ថ្ងៃទី២០ ខែមករា ឆ្នាំ១៩៦៩ រីឆាដ និចសុន ( Richard Nixon ) បានជាប់ឆ្នោតប្រធានា

ធិបតីទី៣៧ របស់សហរដ្ឋអាមេរិក គាត់បានសន្យាថា នឹងរកដំណោះស្រាយសន្តិភាព ប្រកបដោយកិត្តិយសមួយ ដើម្បីបញ្ចប់សង្គ្រាមនៅវៀតណាម ខណៈដែលវត្តមានកងទ័ព របស់សហរដ្ឋអាមេរិក នៅវៀតណាមខាងត្បូង បានកើនឡើងដល់ទៅ ៥៤១,០០០នាក់ ហើយក្នុងមួយសប្តាហ៍ៗ នៅសមរភូមិវៀតណាមនោះ ជាមធ្យម កងទ័ពអាមេរិក ត្រូវស្លាប់ និងរបួសប្រមាណ៣០០នាក់ ។

ដំបូង ប្រធានាធិបតីនិចសុន បានសម្រេចសាកល្បងដកទ័ពអាមេរិក ចំនួន២៥០០០ នាក់ ចេញពីប្រទេស វៀតណាមខាងត្បូង ហើយគ្រោងនឹងដកចំនួន១៥០ ០០០នាក់ទៀត ក្នុងពេលដ៏ខ្លីខាងមុខ ។ ប៉ុន្តែ ការដកទ័ពលើកដំបូង ចំនួន២៥០០០នាក់ នៅដើមឆ្នាំ ១៩៦៩នោះ ជាអំណោយផលដល់កងទ័ពវៀតកុង-វៀតណាមខាងជើង កាន់តែបង្កើន សកម្មភាពវាយប្រហារទៅលើទីក្រុងសាយហ្គន កាន់តែខ្លាំងក្លាឡើងៗ ។



ប្រធានាធិបតីនិចសុន និងឧត្តមសេនីយ៍ ក្រេកតុន អាប្រាម(Creighton Abrams)

ពេលនោះឧត្តមសេនីយ៍ក្រេកតុន អាប្រាម ( Creighton Abrams ) មេបញ្ជាការកងទ័ពអាមេរិក នៅសមរភូមិវៀតណាម បានព្រមានទៅ ប្រធានាធិបតីនិចសុន ថា មុននឹងដកទ័ពអាមេរិក ចំនួន១៥០០០០នាក់ទៀត ចេញពីប្រទេសវៀតណាមខាងត្បូង បន្តទៀត យើងត្រូវតែកម្ទេចមូលដ្ឋានកងទ័ពវៀតកុង-វៀតណាមខាងជើង នៅតាមព្រំដែនក្នុងប្រទេសកម្ពុជា ជាមុនសិន បើមិនដូច្នេះទេ យើងមិនអាចដោះស្រាយស្ថានភាពយោធាយើងបានទេ ។

ឧត្តមសេនីយ៍ក្រេកតុន អាប្រាម ( Creighton Abrams ) បានប្តូរយុទ្ធសាស្ត្រពីការបើកប្រតិបត្តិការជាទ្រង់ទ្រាយធំ ក្នុងការវាយកម្ទេចកងទ័ពវៀតកុង-វៀតណាមខាងជើង មកជាប្រតិបត្តិការទ្រង់ទ្រាយតូចៗ និងប្រើប្រាស់អាវុធទំនើបៗមានប្រសិទ្ធភាព ហើយសហការគ្នាជាមួយកងទ័ពរដ្ឋការក្រុងព្រៃនគរ ដោយផ្តោតទៅលើការកម្ទេច ទីតាំងភ័ស្តុភាររបស់ពួកវៀតកុង-វៀតណាមខាងជើង វិញម្តង ។

ដោយសារសាធារណមតិអាមេរិក និងអន្តរជាតិ ប្រឆាំងទាមទារឱ្យបញ្ចប់សង្គ្រាមនៅវៀតណាមកាន់តែខ្លាំងឡើងៗ ប្រធានាធិបតីអាមេរិក រីឆាដ និចសុន ( Richard Nixon ) ក៏ត្រូវបង្ខំចិត្តអនុវត្តផែនការដកកងទ័ពអាមេរិក ចេញពីវៀតណាមខាងត្បូង និងជួយកសាងកងទ័ពរដ្ឋការវៀតណាមខាងត្បូង ឱ្យបានខ្លាំងពូកែរឹងមាំជាបណ្តើរៗ ដើម្បីជានាំប់រង ធ្វើសង្គ្រាមទប់ទល់ជាមួយពួកវៀតកុង-វៀតណាមខាងជើង ដោយខ្លួនឯង ហើយផែនការនេះ ប្រធានាធិបតីអាមេរិក ឱ្យឈ្មោះថា វៀតណាមូបនីយកម្ម ( Vietnamisation ) ។

របាយការណ៍មួយបានឱ្យដឹងថា ពីឆ្នាំ១៩៦៦ ដល់ខែមេសា ឆ្នាំ១៩៦៩ មាននាវាដឹកទំនិញធំៗ ចំនួន៣៦គ្រឿង ក្នុងនោះមាននាវាសហភាពសូវៀត ២៥គ្រឿង និងនាវាចិន ១១ គ្រឿង បានដឹកអាវុធគ្រាប់រំសេវ ទម្ងន់ ១៨៣៦៧តោន ចូលមកកំពង់ផែក្រុងព្រះសីហនុ ។

រដ្ឋាភិបាលក្រុងវ៉ាស៊ីនតោន បានធ្វើការប៉ាន់ស្មានថា ក្នុងចំណោមអាវុធ និងគ្រាប់រំសេវទាំងអស់នោះ ប្រទេសកម្ពុជា ក៏បានទទួល ៤០០តោនដែរ ក្នុងមួយឆ្នាំៗ ។ រថយន្ត

ទាហានរាជរដ្ឋាភិបាលកម្ពុជា និងរថយន្តឈ្នួលរបស់ក្រុមហ៊ុន ហាក់ លី និងក្រុមហ៊ុនមជ្ឈិម បូព៌ា ជាច្រើនគ្រឿង បានដឹកជញ្ជូនគ្រឿងសព្វាវុធ គ្រាប់រំសេវ និងសម្ភារសឹកទាំងនោះ ទៅទុកក្នុងឃ្លាំងក្បែរៗក្រុងភ្នំពេញមួយរយៈខ្លី រួចដឹកបន្តជាលក្ខណៈលាក់បាំងទៅកាន់មូលដ្ឋានសំខាន់ៗរបស់ពួកវៀតកុង-វៀតណាមខាងជើង ចំនួន១១ទីតាំង ដែលនៅប៉ែកខាងកើតនៃទឹកដីកម្ពុជា ។

វរសេនីយ៍ឯក អ៊ុំ ម៉ាន្នូរិន រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលបន្ទុកការពារលើផ្ទៃប្រទេស និងជាបងថ្លៃរបស់សម្ដេចសីហនុ ព្រមទាំងនាយទាហានជាន់ខ្ពស់មួយចំនួនទៀតជាអ្នកចាត់ចែងការដឹកជញ្ជូននេះ ។

ទន្ទឹមនេះ អង្ករនៅក្នុងប្រទេសប្រមាណ ១០០,០០០តោន គឺស្មើនឹងពាក់កណ្ដាលនៃបរិមាណអង្ករនាំចេញទៅក្រៅប្រទេសប្រចាំឆ្នាំ ក៏ត្រូវបានដឹកយកទៅលក់ឱ្យពួកវៀតកុង-វៀតណាមខាងជើង ផងដែរ។ ការធ្វើពាណិជ្ជកម្មលក់អង្ករដោយលួចលាក់ទៅឱ្យពួកវៀតកុង-វៀតណាមខាងជើងនេះកាន់តែធ្វើឱ្យសេដ្ឋកិច្ចជាតិធ្លាក់ចុះថែមទៀត ។

នៅដើមខែកុម្ភៈ ឆ្នាំ ១៩៦៩ សម្ដេចសីហនុ បានប្រកាសថា ទោះបីសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម ( វៀតណាមខាងជើង) និងរណសិរ្សជាតិរំដោះវៀតណាមខាងត្បូង( វៀតកុង) បានប្រកាសទទួលស្គាល់ បូរណភាពទឹកដី និងខ្សែបន្ទាត់ព្រំដែនកម្ពុជា រួចហើយក៏ដោយ ក៏ពួកគេនៅតែបញ្ជូនកងទ័ពឱ្យចូលមកបោះទីតាំងនៅក្នុងទឹកដីរបស់ព្រះអង្គដដែល ។

នៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ១៩៦៩ ជាមួយនឹងផែនការរកសន្តិភាព ដើម្បីបញ្ចប់សង្គ្រាមនៅវៀតណាមខាងត្បូង ប្រធានាធិបតីអាមេរិក រីឆាដ និចសុន បានប្រកាសថា លោករីករាយនឹងការផ្សារទំនាក់ទំនងការទូតជាមួយប្រទេសកម្ពុជាឡើងវិញ បន្ទាប់ពីទំនាក់ទំនងការទូតនេះត្រូវកាត់ផ្ដាច់ទាំងស្រុងតាំងពីឆ្នាំ១៩៦៥ មក ។

ក្នុងសន្និសីទកាសែតមួយ នៅថ្ងៃ ទី០២ ខែមីនា ឆ្នាំ១៩៦៩ សម្ដេចសីហនុ បានបង្ហាញផែនទីឱ្យសាធារណមតិជាតិ និងអន្តរជាតិ បានដឹងពីទីតាំងទាំងឡាយរបស់កង

ទ័ពវៀតកុង-វៀតណាមខាងជើង នៅក្នុងទឹកដីខ្មែរ និងបញ្ជាក់ថា កងទ័ពទាំងនេះមានចំនួនលើសពី៤០០០០នាក់ កំពុងស្ថិតនៅលើទឹកដីកម្ពុជា ។

ប៉ុន្តែ ព្រះអង្គនៅតែធ្វើមិនដឹងមិនឮចំពោះបញ្ហាដឹកជញ្ជូនអង្ករទៅលក់ឱ្យកងទ័ពវៀតកុង-វៀតណាមខាងជើង ដដែល ដោយមិនគិតដល់ផលវិបាកផ្សេងៗ ដែលធ្វើឱ្យសេដ្ឋកិច្ចជាតិស្រុតចុះនោះឡើយ ហើយការលក់អង្ករនោះបានធ្វើឱ្យមន្ត្រីរាជរដ្ឋាភិបាល ដែលកាន់កាប់ការងារនោះ ឆ្លៀតឱកាសប្រព្រឹត្តអំពើពុករលួយ កិបកេងថវិការដ្ឋ មកធ្វើមានបានខ្លួនឯងតែប៉ុណ្ណោះ ។

ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៦៩ កងទ័ពសហរដ្ឋអាមេរិក ចាប់ផ្តើមបើកយុទ្ធនាការទម្លាក់គ្រាប់បែករយៈពេល១៤ខែ ដើម្បីកម្ទេចទីតាំងកងទ័ពវៀតកុង-វៀតណាមខាងជើងទាំងឡាយ ដែលស្ថិតនៅក្នុងទឹកដីកម្ពុជា ។

យុទ្ធនាការទម្លាក់គ្រាប់បែកយ៉ាងច្រើនសន្ធឹកសន្ធាប់ ដែលមិនធ្លាប់មានពីមុនមកនេះ គឺជាគំនិតផ្តួចផ្តើមរបស់ ហង់រី គីស៊ីងហ្គ័រ ( Henry Kissinger ) ជាទីប្រឹក្សាសន្តិសុខជាតិរបស់ប្រធានាធិបតីសហរដ្ឋអាមេរិក រីឆាដ និចសុន ( Richard Nixon ) ដោយពុំមានការសុំឯកភាពពីសភាសហរដ្ឋអាមេរិកឡើយ ហើយក៏ពុំមានការយល់ព្រម ១០០ ភាគរយ និងជាចំហពីប្រធានាធិបតីសហរដ្ឋអាមេរិក រីឆាដ និចសុន ( Richard Nixon ) ដែរ ។

យុទ្ធនាការទម្លាក់គ្រាប់នេះ មានឈ្មោះថា ប្រតិបត្តិការម៉ឺនុយ ( Menu= បញ្ជីរាយឈ្មោះមុខម្ហូប) ធ្វើឡើងដើម្បីកម្ទេចកងទ័ព វៀតកុង-វៀតណាមខាងជើង ឱ្យនៅសល់តិចបំផុត និងជួយពង្រឹងកងទ័ពវៀតណាមខាងត្បូង ឱ្យបានរឹងមាំ មុននឹងកងទ័ពសហរដ្ឋអាមេរិក ដកទៅប្រទេសរបស់ពួកគេវិញ ។

ក្នុងរយៈពេល១៤ ខែនៃយុទ្ធនាការនេះ យន្តហោះយក្សបេ៥២ របស់សហរដ្ឋអាមេរិកបានហោះមកទម្លាក់គ្រាប់បែកមកលើទឹកដីកម្ពុជា ចំនួន៣៦៣០លើក ។

អ្នកបើកយន្តហោះទាំងអស់នោះ ទម្លាក់គ្រាប់បែកពុំមានធ្វើការបែងចែកថា កន្លែង

ណាជាភូមិ ដែលប្រជារាស្ត្រខ្មែររស់នៅ ឬកន្លែងណាជាទីតាំងកងទ័ពវៀតកុង-វៀតណាមខាងជើងនោះទេ គឺពួកគេទម្លាក់គ្រាប់បែកមកលើស្រុក ភូមិខ្មែរជាច្រើនកន្លែងបណ្តាលឱ្យប្រជាកសិករខ្មែរ រាប់រយនាក់ត្រូវបាត់បង់ជីវិត និងរងរបួស ។

តែការដឹកជញ្ជូនអាវុធយុទ្ធភណ្ឌ និងស្បៀងអាហារទៅផ្គត់ផ្គង់ឱ្យកងទ័ពវៀតកុង-វៀតណាមខាងជើង ត្រូវអាក់ខាន ។ ជាមួយគ្នានោះ ដើម្បីគេចចេញពីការទម្លាក់គ្រាប់បែកដ៏សាហាវឃោរឃៅនោះ កងទ័ពវៀតកុង ដែលមានទីតាំងនៅក្បែរៗព្រំដែនក៏នាំគ្នារុលចូលមកក្នុងទឹកដីខ្មែរកាន់តែជ្រៅបន្ថែមទៀត ។

សម្តេចសីហនុ ក៏បានត្អូញត្អែរជាសាធារណៈពីរឿងយន្តហោះបេ៥២(B.52)របស់អាមេរិក មកទម្លាក់គ្រាប់បែកលើប្រជារាស្ត្ររបស់ព្រះអង្គ ហើយព្រះអង្គបានដាក់ផែនការឱ្យកងទ័ពព្រះអង្គបាញ់ទម្លាក់យន្តហោះ អាមេរិកទាំងអស់នោះតាមដែលអាចធ្វើបានផងដែរ។ ប៉ុន្តែការបាញ់យន្តហោះបេ៥២ របស់អាមេរិក ទាំងនោះពុំឃើញមានធ្លាក់មួយគ្រឿងណាឡើយ ។

ថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៦៩ សម្តេចសីហនុ បានបង្ហាញជាសាធារណៈនូវផែនទីដែលមានកំណត់បង្ហាញពីទីតាំងរបស់កងទ័ពវៀតកុង វៀតណាមខាងជើង នៅក្នុងទឹកដីប្រទេសកម្ពុជា ដើម្បីឱ្យសាធារណមតិជាតិ អន្តរជាតិបានដឹងឮដែរ។ តែទោះបីយ៉ាងនេះក៏ដោយ ក៏ព្រះអង្គបានប្រកាសថា ព្រះអង្គនឹងមិនផ្លាស់ប្តូរគោលនយោបាយជាមួយ នឹងពួកវៀតណាមកុម្មុយនិស្តនោះដែរ។ ប៉ុន្តែព្រះអង្គគ្រាន់តែងាកជំហរនយោបាយទៅរកសហរដ្ឋអាមេរិក បន្តិចតែប៉ុណ្ណោះ ។

ការចរចារកសន្តិភាពនៅវៀតណាមខាងត្បូង ត្រូវអូសបន្លាយ ដោយសារតែពួកវៀតកុង-វៀតណាមខាងជើង ប្រើយុទ្ធសាស្ត្រចរចាផង និងវាយផង។ ពិសេស គឺក្នុងឱកាសបុណ្យចូលឆ្នាំចិន-វៀតណាម ឆ្នាំ១៩៦៩ នោះ ពួកគេបានបើកការវាយប្រហារជាទ្រង់ទ្រាយធំ និងនៅគ្រប់ទីកន្លែងនៅវៀតណាមខាងត្បូង ក្នុងគោលបំណងយកជ័យជម្នះផ្តាច់ព្រ័ត្រ ដូចដែលពួកគេបានអនុវត្តកាលពីពេលបុណ្យចូលឆ្នាំចិន-វៀតណាម

ឆ្នាំ១៩៦៨ ដែរ ។ ប៉ុន្តែ ទាំងនៅក្នុងឆ្នាំ ១៩៦៨ និងទាំងនៅក្នុងឆ្នាំ១៩៦៩ នោះ ជ័យជម្នះផ្ដាច់ព្រ័ត្ររបស់ពួកគេនៅតែស្ថិតក្នុងការស្រមើស្រមៃដដែល ហើយទឹកដីនៃប្រទេសកម្ពុជា ក៏នៅតែជាជម្រកដែលមិនអាចអត់បានរបស់ពួកគេផងដែរ។ ប៉ុន្តែ ទោះជាយ៉ាងនេះ ក៏ដោយ ក៏សម្ដេច សីហនុ នៅតែជឿជាក់ថា នៅទីបំផុត កងទ័ពវៀតកុង-វៀតណាមខាងជើង នឹងទទួលបានជ័យជម្នះផ្ដាច់ព្រ័ត្រយ៉ាងពិតប្រាកដ ដូច្នេះ ព្រះអង្គនៅតែរក្សាចំណងមិត្តភាពជាមួយពួកវៀតកុង-វៀតណាមខាងជើង និងប្រទេសចិន ផងដែរ ។

ម្យ៉ាងទៀត ទោះបីដឹងច្បាស់ថា ប្រជារាស្ត្រខ្មែរមិនចូលចិត្តទាំងវៀតណាមខាងត្បូង ទាំងវៀតណាមខាងជើង ក៏ពិតមែន ប៉ុន្តែ ដើម្បីរក្សាអំណាចព្រះអង្គផង និងដើម្បីរក្សាស្ថិរភាពនយោបាយប្រទេសជាតិផង សម្ដេចសីហនុ ត្រូវតែបង្ខំព្រះទ័យចងសម្ព័ន្ធមិត្តជាមួយវៀតណាមខាងជើង ដែលព្រះអង្គជឿជាក់ថា ជាអ្នកទទួលជ័យជម្នះចុងក្រោយ ។

នៅថ្ងៃទី២ ខែមេសា ឆ្នាំ១៩៦៩ សហរដ្ឋអាមេរិក បានប្រកាសទទួលស្គាល់អធិបតេយ្យភាព ឯករាជ្យ អព្យាក្រឹតភាព និងបូរណភាពទឹកដីនៃប្រទេសកម្ពុជា ។

រដ្ឋាភិបាលសហរដ្ឋអាមេរិក និងក្រុមអធិការកិច្ចឯករាជ្យ បានបញ្ជាក់ថា ផ្ទៃដីចម្ការកៅស៊ូ និងព្រៃ ចំនួន ៦៩.២០០ហិកតារ នៃខេត្តកំពង់ចាម ត្រូវយន្តហោះចម្បាំងសហរដ្ឋអាមេរិក បាញ់ថ្នាំគីមីសម្លាប់ស្លឹកឈើ  ហើយដំណាំកៅស៊ូ ចំនួន ៩៨៨០ហិកតាត្រូវបានប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ធ្វើឱ្យខាតបង់ប្រាក់ចំណូលពីការនាំចេញរបស់ប្រទេស១២ភាគរយ។ តែយ៉ាងណា ក៏ការទម្លាក់គ្រាប់បែក ព្រមទាំងបាញ់ថ្នាំគីមីសម្លាប់ស្លឹកឈើព្រៃ  និងដំណាំកៅស៊ូនៅលើទឹកដីកម្ពុជានេះ ត្រូវបានគេសង្ស័យថា សម្ដេចសីហនុ ជាអ្នកបើកភ្លើងខៀវ ផងដែរ ។

ក្រោយពេលប្រធានាធិបតីនិចសុន ទទួលស្គាល់បូរណភាពទឹកដី និងខ្សែបន្ទាត់ព្រំដែនកម្ពុជា មក ថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៦៩ ប្រទេសកម្ពុជា និសហរដ្ឋអាមេរិក បានប្រកាសថានឹងភ្ជាប់ទំនាក់ទំនងការទូតជាមួយគ្នាឡើងវិញ ។



យន្តហោះអាមេរិក ទម្លាក់គ្រាប់បែកលើទឹកដីខ្មែរ

*ក្រោយភ្ជាប់ទំនាក់ទំនងការទូតឡើងវិញ នាថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៦៩នោះបាន តែ២ថ្ងៃប៉ុណ្ណោះ គឺចាប់ពីថ្ងៃទី១៤ ខែមេសា ចំពេលដែលប្រទេសកម្ពុជា ប្រារព្ធធ្វើពិធីបុណ្យចូលឆ្នាំថ្មីតាមប្រពៃណីតាំងពីបុរាណមក រហូតដល់ថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៦៩ យន្តហោះអាមេរិក ជាច្រើនគ្រឿង បានហោះមកបាញ់សារធាតុគីមីលើចម្ការកៅស៊ូ និងដំណាំផ្សេងៗទៀត ចំនួន៨៥០០០ហិកតា នៅក្នុងស្រុកមេមត់ និងពញាក្រែក ក្នុងខេត្តកំពង់ចាម( សព្វថ្ងៃជាខេត្តត្បូងឃ្មុំ) ដើម្បីឱ្យស្វិតដើមកៅស៊ូ និងស្វិតឈើផ្សេងៗទៀត ជ្រុះអស់ ងាយស្រួលនឹងតាមរុករកកងទ័ពវៀតកុង-វៀតណាមខាងជើង ដែលនាំគ្នាលាក់ខ្លួននៅទីនោះ ។*

*កាសែតញូវយ៉កថែម ( New York Time ) បានធ្វើការប៉ាន់ប្រមាណថា ការខូចខាតចម្ការកៅស៊ូ និងដំណាំកសិកម្មផ្សេងៗទៀត នៅក្នុងខេត្តកំពង់ចាម នោះមានតម្លៃប្រមាណ ១១ លានដុល្លារសហរដ្ឋអាមេរិក ។*

# ២៥៧
# សម្តេចសីហនុ បង្ហាញទីតាំង និងសកម្មភាពកងទ័ពវៀតកុង នៅក្នុងទឹកដីខ្មែរ



សម្តេចសីហនុ ធ្វើសន្និសីទកាសែត នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៦៩

នៅក្នុងខែមេសា ឆ្នាំ១៩៦៩ សម្តេចសីហនុ បានបញ្ជូនគណៈបេសកកម្មមួយទៅទីក្រុងមូស្គូ សហភាពសូវៀត ដើម្បីសុំជំនួយយោធា និងប្រាក់កម្ចីមួយចំនួនផងដែរ ។

ក្នុងភាពស្ទាក់ស្ទើរដែរនោះ មេដឹកនាំសហភាពសូវៀត បានផ្តល់ជំនួយជានាវាល្បាតតូចៗ ព្រមទាំងអាវុធ និងគ្រាប់រំសេវមួយចំនួនប៉ុណ្ណោះ ព្រោះមេដឹកនាំសូវៀតគិតថា សម្តេចសីហនុ នឹងយកអាវុធទាំងនោះទៅវាយបង្ក្រាបពួកខ្មែរក្រហម ដែលជាពួកតស៊ូកុម្មុយនិស្តដូចពួកគេដែរនោះ ជាមិនខាន ។

ចំណែកមេដឹកនាំចិន វិញ ក៏បានតាមដានសភាពការណ៍នយោបាយនៅកម្ពុជាដោយយកចិត្តទុកដាក់បំផុត ។ ពួកគេក៏មានការព្រួយបារម្ភពីបញ្ហាឱនភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅកម្ពុជា ព្រមទាំងគោលជំហរថ្មីនៃការតម្រង់ទិសនយោបាយអព្យាក្រឹតរបស់សម្តេចសីហនុ ផងដែរ ។

ពេលនោះដែរ ពួកជំនាញការ និងអ្នកបច្ចេកទេសនៅតាមរោងចក្រនានា ដែលជាជំនួយរបស់ចិន នៅក្នុងប្រទេសកម្ពុជា ក៏បានសាកល្បងជួយរៀបចំការផលិត និងការគ្រប់គ្រងនៅតាមរោងចក្រទាំងនោះឱ្យបានល្អប្រសើរដែរ។ ប៉ុន្តែ ដោយសារមន្ត្រីកម្ពុជា ជាប្រធានរោងចក្រ អសមត្ថភាពផង ហើយមិនព្រមស្ដាប់ពួកជំនាញការ និងអ្នកបច្ចេកទេសចិនផងនោះ នៅទីបំផុត ពួកគេគ្មានអ្វី ក្រៅពីនាំគ្នាវិលត្រលប់ទៅប្រទេសពួកគេវិញ ទាំងសោកស្ដាយនោះឡើយ ។

ទោះបីយ៉ាងនេះក៏ដោយ ក៏មេដឹកនាំចិន នៅតែអះអាងថា ខ្លួននឹងយល់ព្រមផ្ដល់ប្រាក់កម្ចីមួយចំនួនក្នុងរយៈពេលវែង ដោយមិនយកការប្រាក់ និងគ្មានលក្ខខណ្ឌអ្វីទាំងអស់ចំពោះប្រទេសកម្ពុជា។ ប៉ុន្តែ សម្ដេចសីហនុ ឈ្វេងយល់ថា ការធ្វើជាកូនបំណុលរបស់ប្រទេសចិនកុម្មុយនិស្ត អាចធ្វើឱ្យប្រទេសព្រះអង្គជួបគ្រោះថ្នាក់ ។

ពេលនោះ រដ្ឋាភិបាលបារាំង បានប្រកាសថា នឹងយល់ព្រមឱ្យប្រាក់កម្ចីចំនួន ១២៣លានហ្វ្រង់ ដោយយកការប្រាក់តិចតួចបំផុត ប្រសិនបើកម្ពុជា យកទៅអនុវត្តកម្មវិធីអភិវឌ្ឍន៍ជាក់លាក់ណាមួយ។ សម្ដេចសីហនុ ធ្វើជាមិនដឹងមិនឮចំពោះការប្រកាសរបស់រដ្ឋាភិបាលបារាំង ដូចខាងលើនេះ។ ប៉ុន្តែ ដល់ខែកុម្ភៈ ឆ្នាំ១៩៧០ ក៏មានគណៈប្រតិភូរាជរដ្ឋាភិបាលកម្ពុជាមួយក្រុម បានធ្វើដំណើរទៅទីក្រុងប៉ារីស ដើម្បីចរចាពីបញ្ហាប្រាក់កម្ចីនោះ ។

នៅដើមខែឧសភា ឆ្នាំ១៩៦៩ សម្ដេចសីហនុ បានធ្វើសន្និសីទកាសែត ដើម្បីបង្ហាញព័ស្ដុតាងជាក់ស្ដែងពីជំនួយរបស់ពួកវៀតកុង-វៀតណាមខាងជើង ចំពោះពួកឧទ្ទាមខ្មែរក្រហម ។

នៅថ្ងៃទី០៩ ខែឧសភា ឆ្នាំ១៩៦៩ កាសែតបារាំង អាអេហ្វប៉េ(AFP)បានចុះផ្សាយអត្ថបទមួយ មានចំណងជើងថា សីហនុ បង្ហាញព័ស្ដុតាងស្ដីពីជំនួយវៀតកុង-វៀតណាមខាងជើង ចំពោះពួកឧទ្ទាមខ្មែរក្រហម ។

អត្ថបទនេះ បានសរសេរថា កាលពីថ្ងៃសៅរ៍ សម្ដេចសីហនុ បានដាក់បង្ហាញជា

លើកទី១ ដល់អ្នកកាសែតជាតិ និងអន្តរជាតិនូវព័ស្តុតាងជាសម្ភារៈ និងការចូលរួមរបស់ពួកវៀតកុង-វៀតណាមខាងជើង ជាមួយពួកឧទ្ទាមខ្មែរលើ នៅក្នុងខេត្តរតនគិរី ដែលនៅជាប់ព្រំដែនប្រទេសលាវ និងវៀតណាមខាងត្បូង។ ជាមួយគ្នានោះ ព្រះអង្គក៏បានដាក់បង្ហាញ រូបថតមួយឈុត ស្តីពីទិដ្ឋភាពក្រោយការប្រយុទ្ធរបស់កងទ័ពព្រះអង្គជាមួយពួកឧទ្ទាមខ្មែរលើ ដែលនៅក្នុងខេត្តរតនគិរី នោះ ។

ក្នុងចំណោម សាកសពពួកឧទ្ទាមខ្មែរលើជាច្រើននៅក្នុងរូបថតទាំងនោះ ក៏មានសាកសពជនជាតិវៀតណាម២ នាក់ ដែលស្លៀកពាក់ពណ៌ត្រេអ៊ី និងពាក់ស្បែកជើងកង់ឡាន របស់ពួកវៀតកុង-វៀតណាមខាងជើង ផងដែរ។ ព្រះអង្គបានបង្ហាញកាំភ្លើងរបស់ពួកវៀតកុង-វៀតណាមខាងជើង ដែលផលិតនៅប្រទេសចិន និងកូនសៀវភៅកំណត់ហេតុផ្ទាល់ខ្លួន របស់វៀតកុង-វៀតណាមខាងជើង ម្នាក់ ដែលមានសរសេរអក្សរខ្មែរខ្លះៗនៅក្នុងនោះផងដែរ ។

ជាមួយគ្នានោះព្រះអង្គ ក៏បានធ្វើការតវ៉ាចំពោះកាសែតអាមេរិកមួយ ដែលបានចុះផ្សាយថា ព្រះអង្គបានបដិសេធចំពោះសេចក្តីប្រកាសទទួលស្គាល់បូរណភាពទឹកដី និងខ្សែបន្ទាត់ព្រំដែនខ្មែរ របស់ប្រធានាធិបតី រីឆាដ និចសុន កាលពីថ្ងៃទី១១ មេសា កន្លងមកនោះផងដែរ។

ព្រះអង្គបានឆ្លើយបំភ្លឺទៅកាសែតអាមេរិក នោះវិញថា ផ្ទុយទៅវិញ ព្រះអង្គមានព្រះទ័យរំភើបរីករាយអស់ពីដួងចិត្ត នៅពេលបានដឹងពីសេចក្តីប្រកាសទទួលស្គាល់ខ្សែបន្ទាត់ព្រំដែនកម្ពុជា របស់ប្រធានាធិបតី រីឆាដ និចសុន នេះ។ ប៉ុន្តែព្រះអង្គគ្រាន់តែសូមប្រកាសមោឃៈទុកជាមុនចំពោះលក្ខខណ្ឌទាំងឡាយណាដែលក្រសួងការបរទេសសហរដ្ឋអាមេរិក ដាក់មកឱ្យកម្ពុជា តែប៉ុណ្ណោះ។

ព្រះអង្គបញ្ជាក់បន្ថែមថា បើពិតជាមានបំណងធ្វើការសម្រុះសម្រួលជាមួយកម្ពុជា ពិតប្រាកដនោះ សហរដ្ឋអាមេរិក ត្រូវតែបញ្ជាក់ឱ្យបានច្បាស់ថា ព្រំដែនកម្ពុជាបច្ចុប្បន្នទាំងអស់ រាប់ទាំងបណ្តាកោះ និងភូមិខ្មែរមួយចំនួនទៀត ដែលមេដឹកនាំរដ្ឋការ

ក្រុងព្រៃនគរយកទៅកាន់កាប់ផងដែរ ។

នៅចុងខែឧសភា ឆ្នាំ១៩៦៩ រាជរដ្ឋាភិបាលកម្ពុជា បានសម្រេចចិត្តថា នឹងលែងឱ្យមានវត្តមានគណៈកម្មាធិការ ត្រួតពិនិត្យអន្តរជាតិនៅលើទឹកដីរបស់ខ្លួននៅពេលដ៏ខ្លីខាងមុខ ។ សំខាន់ គឺរាជរដ្ឋាភិបាលកម្ពុជា មិនចង់ឱ្យគណៈកម្មាធិការត្រួតពិនិត្យអន្តរជាតិនោះ រវីរវល់ជាមួយបញ្ហាជ្រៀតចូល និងបោះទីតាំងរបស់កងទ័ពវៀតកុង-វៀតណាមខាងជើង នៅលើទឹកដីខ្មែរតទៅទៀត ដើម្បីកុំឱ្យបញ្ហានេះកាន់តែមានការស្មុគស្មាញថែមទៀត ។

ទាក់ទងដល់បញ្ហាសម្តេចសីហនុ មានបំណងចង់ឱ្យគណៈកម្មាធិការត្រួតពិនិត្យអន្តរជាតិ ដកចេញពីប្រទេស កម្ពុជា នេះដែរ កាសែតអាអេហ្វប៉េ (AFP) របស់បារាំងក៏បានសរសេរ បន្ទោសទៅលើតំណាងប្រទេសកាណាដា និងប៉ូឡូញ ដែលជាសមាជិកគណៈកម្មាធិការត្រួតពិនិត្យអន្តរជាតិនោះថា ពួកនេះបម្រើតែផលប្រយោជន៍សហរដ្ឋអាមេរិក និងពួកវៀតណាមកុម្មុយនិស្ត តែប៉ុណ្ណោះ គឺពួកគេមិនខ្វាយខ្វល់អំពីជោគវាសនានៃ ឯករាជ្យភាព អព្យាក្រឹត និងពុទ្ធសាសនា របស់ប្រទេសកម្ពុជា ឡើយ ។

នៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ១៩៦៩ សម្តេចសីហនុ បានធ្វើសន្និសីទកាសែត ជាមួយអ្នកកាសែតបរទេស នៅព្រះរាជដំណាក់ចំការមន ក្នុងទីក្រុងភ្នំពេញ ព្រះអង្គបានបង្ហាញរូបថតកងទ័ពវៀតកុង-វៀតណាមខាងជើង ៣នាក់ ដែលកងទ័ពព្រះអង្គចាប់ខ្លួនបាននៅក្នុងខេត្តរតនគិរី កាលពីថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៦៩ ។

បន្ទាប់មកទៀត នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៦៩ ថ្ងៃទីនៅព្រះរាជដំណាក់លើភ្នំបូកគោ ជាមួយអ្នកកាសែត បរទេស សម្តេចសីហនុ បានបង្ហាញរូបថតកងទ័ពវៀតកុង-វៀតណាមខាងជើងជាច្រើននាក់ ដែលកងទ័ពព្រះអង្គ ចាប់ខ្លួនបាននៅក្នុងខេត្តរតនគិរី ផងដែរ ។

ក្នុងសន្និសីទសារព័ត៌មាន នៅថ្ងៃទី១១ ខែ មិថុនា ឆ្នាំ១៩៦៩ សម្តេចសីហនុ បានថ្លែងថា នៅក្នុងខេត្តរតនគិរី ក្បែរព្រំដែនយួនខាងត្បូង ពួកវៀតកុង-វៀតណាមខាងជើង បានចូលមកបោះទីតាំងនៅតាមភូមិទាំងឡាយ ដែលស្ថិត នៅឆ្ងាយៗពីផ្លូវគមនាគមន៍ ។



**សម្ដេចសីហនុ ធ្វើសន្និសីទសារព័ត៌មាន នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៦៩**

ពួកគេបានរៀបចំកងកម្លាំងខ្មែរ ប្រហែល៦០នាក់ ប្រដាប់ដោយកាំភ្លើងស្វ័យប្រវត្តិ និងគ្រាប់បែក ផលិតនៅប្រទេសចិន ឱ្យស្ថិតនៅក្រោមបញ្ជារបស់ពួកគេផ្ទាល់ ហើយកងកម្លាំងខ្មែរនេះតែងនាំគ្នា ដើរឆ្លងកាត់ពីភូមិមួយទៅភូមិមួយទៀត ដើម្បីឃោសនានយោបាយដល់អ្នកភូមិនៅទីនោះទៀតផង ។

ក្នុងឱកាសធ្វើសន្និសីទកាសែតនោះដែរ សម្ដេចសីហនុ បានបើកកកាយពីការសាបព្រោះអំពី ភេរវកម្មរបស់ពួកកុម្មុយនិស្តយួន និងខ្មែរជាភ្នាក់ងាររបស់គេដែលរស់នៅតាមតំបន់ព្រៃភ្នំនោះផងដែរ។ ដោយឡែក ចំពោះអ្នកភូមិ ទាំងឡាយណាដែលស្មោះត្រង់ជាមួយរាជរដ្ឋាភិបាលខ្មែរ ត្រូវបានពួកគេសម្លាប់ចោលយ៉ាងសាហាវឃោរឃៅបំផុត ។

ដើម្បីសម្លាប់អ្នកភូមិណាដែលស្មោះត្រង់ជាមួយរាជរដ្ឋាភិបាល មុនដំបូង គេយកខ្សែរចងរឹតដៃចងជើង រួចវាយនឹង ដំបងគល់ឫស្សី។ ជាមួយគ្នានោះ ព្រះអង្គបានសារភាពថា កងទ័ពរាជរដ្ឋាភិបាលគ្មានកម្លាំង និងគ្រឿងអាវុធគ្រប់គ្រាន់ ដើម្បីកម្ចាត់នូវអំពើឃ្លានពាននេះបានទេ ។

នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ១៩៦៩ ស្ថានទូតអាមេរិក បានចាប់បើកទ្វារនៅទីក្រុងភ្នំពេញ ឡើងវិញ ដោយមានតែភារធារីឈ្មោះឡូយដ៍ រ៉ៃវើស៍ ៉ាយ ( Lloyd M.Rives ) និងបុគ្គលិកចំនួន៨នាក់ប៉ុណ្ណោះ។ ប៉ុន្មានថ្ងៃក្រោយមក ដើម្បីបង្ហាញពីការប្ដេជ្ញាចិត្តថ្មីរបស់ក្រុងវ៉ាស៊ីនតោន ចំពោះប្រទេសកម្ពុជា សមាជិកព្រឹទ្ធសភា មេនហ្វីល ( Mansfield ) បានអញ្ជើញទៅបំពេញទស្សនកិច្ចជាលើកទី៣ នៅទីក្រុងភ្នំពេញ ។

សម្ដេចសីហនុ បានចាត់ទុកសមាជិកព្រឹទ្ធសភា មេនហ្វីល ( Mansfield ) ថាជាមិត្តភក្តិដ៏អស្ចារ្យ និងស្មោះត្រង់បំផុតរបស់កម្ពុជា ដែលបានរួមចំណែកជួយស្តារទំនាក់ទំនងកម្ពុជា និងសហរដ្ឋអាមេរិក ឡើងវិញ។ រហូតដល់ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៧០ គឺក្រោយរដ្ឋប្រហារថ្ងៃទី ១៨ ខែមីនា រយៈពេលជិត៧ខែ ទើបឃើញអ្នកការទូតម្នាក់ ឈ្មោះអេម៉ូរី ស្វង៍( Emory E Swank ) មកកាន់តំណែងឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ប្រចាំនៅទីក្រុងភ្នំពេញ ។

# ២៥៨
# សម្តេចសីហនុ ប្រកាសទទួលស្គាល់រដ្ឋាភិបាល បដិវត្តន៍បណ្តោះអាសន្នវៀតណាមខាងត្បូង



នាយករដ្ឋមន្ត្រីលន់ នល់ ទទួលស្វាគមន៍នាយករដ្ឋមន្ត្រីវៀតកុង ហ្វីញ តឹនផាត

ក្រោយពេលប្រធានាធិបតីអាមេរិក រីឆាដ និចសុន និចសុន( Richard Nixon ) មានផែនការដកកងទ័ពអាមេរិក ចេញពីវៀតណាមខាងត្បូង និងសន្យារកដំណោះស្រាយសន្តិភាពប្រកបដោយកិត្តិយសមួយ ដើម្បីបញ្ចប់សង្គ្រាមនៅឥណ្ឌូចិននោះ នៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ១៩៦៩ រណសិរ្សជាតិរំដោះវៀតណាមខាងត្បូង( វៀតកុង) ដែលវៀតណាមខាងជើង ជាស្ថាបនិក បានបង្កើតរដ្ឋាភិបាលមួយមានឈ្មោះថា រដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្ននៃសាធារណរដ្ឋវៀតណាមខាងត្បូង ដើម្បីបង្ហាញសាធារណមតិអន្តរជាតិថា ការតស៊ូរបស់ពួកគេកាន់តែបោះជំហានទៅមុខ ហើយពួកគេនឹងទទួលបានជ័យជម្នះក្នុងពេលខាងមុខនេះជាក់ជាមិនខាន ។

សមាសភាពរដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្ននៃសាធារណរដ្ឋវៀតណាមខាងត្បូងនោះ មានហ៊ុីញ តឹនផាត (Huỳnh Tấn Phát) ជានាយករដ្ឋមន្ត្រី និងឧបនាយករដ្ឋមន្ត្រី៣នាក់ ក្នុងនោះមានស្ត្រីម្នាក់ឈ្មោះង្វៀន ធីប៊ីញ ជាឧបនាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីក្រសួងការបរទេស និងរដ្ឋមន្ត្រីចំនួន៩នាក់ទៀត ។

នៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ១៩៦៩ សម្តេចសីហនុ ប្រកាសទទួលស្គាល់រដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្នវៀតណាមខាងត្បូង ដែលទើបបង្កើតថ្មីនោះ ។

ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៦៩ ង្វៀង វ៉ាន់ហៀវ ដែលត្រូវបានតែងតាំងជាឯកអគ្គរដ្ឋទូតរបស់រដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្នវៀតណាមខាងត្បូង ប្រចាំនៅប្រទេសកម្ពុជាបានមកប្រគល់សារតាំងថ្វាយសម្តេចសីហនុ និងបានសន្យាជាលាយលក្ខណ៍អក្សរថា នឹងយល់ព្រមដកកងទ័ពវៀតកុង-វៀតណាមខាងជើង ចេញពីប្រទេសកម្ពុជាវិញ នៅពេលចប់សង្គ្រាម ។

នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ១៩៦៩ ទីភ្នាក់ងារសារព័ត៌មានខ្មែរ(AKP)បានចុះផ្សាយថា ទោះបីរាជរដ្ឋាភិបាលកម្ពុជា ហាមឃាត់យ៉ាងណា ក៏ពួកវៀតកុង-វៀតណាមខាងជើងនៅតែបន្តចូលមកបោះទីតាំងនៅលើទឹកដីកម្ពុជា ដដែលៗ នេះកាន់តែបង្ហាញឱ្យឃើញនូវការប្រទូសរ៉ាយកាន់តែខ្លាំងថែមទៀតជាមួយអ្នកភូមិកម្ពុជា ទាំងឡាយដែលរស់នៅក្បែរៗទីតាំងនោះ ហើយថា ពួកវៀតកុង-វៀតណាមខាងជើងនោះ ក៏បានជួយដល់ពួកឧទ្ទាមខ្មែរក្រហម ផងដែរ ។

ប៉ុន្តែ ទីភ្នាក់ងារព័ត៌មានខ្មែរ (AKP) ក៏បានបញ្ជាក់ថា ការឈ្លានពានដ៏សាហាវព្រៃផ្សៃរបស់កងទ័ពអាមេរិក និង រដ្ឋការក្រុងព្រៃនគរ មកលើប្រទេសកម្ពុជា មិនសូវកើតមានញឹកញាប់ដូចពេលមុនៗទេ ។

ទន្ទឹមនោះដែរ កាសែតអាអេហ្វប៉េ(AFP) របស់បារាំង ក៏បានចុះផ្សាយថា បើតាមកម្លាំងស៊ើបការណ៍នៅ ក្រុងព្រៃនគរ បានឱ្យដឹងថា ពួកទាហានរាជរដ្ឋាភិបាលកម្ពុជា នៅខេត្តស្វាយរៀង បានធ្វើការរារាំងនៅតាមខ្សែបន្ទាត់ព្រំដែន មិនឱ្យកងទ័ពវៀតកុង ចូលទៅ

ក្នុងទឹកដីរបស់ពួកគេ ហើយថា ការវិវត្តនៃសភាពការណ៍នៅកម្ពុជា អាចប្រៀបប្រដូចទឹកមួយដំណក់នៅលើស្លឹកឈូក ហើយនៅទីបំផុត ដំណក់ទឹកមួយដំណក់នោះ នឹងធ្លាក់ទៅជាផល ប្រយោជន៍ដល់ពួកវៀតកុង ដែលកំពុងបង្កើនសកម្មភាពលើសមរភូមិប្រយុទ្ធ ដើម្បីយកប្រៀបនៅលើតុចរចានៅទីក្រុងប៉ារីស ។

នៅក្នុងខែមិថុនា នេះដែរ ដោយសារតែព្រះអង្គបានទទួលព័ត៌មានថា ពួកខ្មែរក្រហមដែលកំពុងតស៊ូនៅក្នុងព្រៃនោះ មានពួកវៀតកុង-វៀតណាមខាងជើងជាអ្នកត្រួតត្រា និងជាអ្នកបំពាក់អាវុធឱ្យ សម្តេចសីហនុ ក៏បានចាត់វិធានការកម្រិតការដឹកជញ្ជូនស្បៀង និងសម្ភារៈផ្សេងៗទៀតដែលឆ្លងកាត់តាមព្រំដែនកម្ពុជា យកទៅផ្គត់ផ្គង់កងទ័ពវៀតកុង-វៀតណាមខាងជើង ដែលនៅតំបន់រំដោះរបស់ពួកគេនៅលើទឹកដីវៀតណាមខាងត្បូង ។

នៅថ្ងៃទី៣០ ខែមិថុនា ដល់ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ១៩៦៩ ហ៊ុីញ តឹនផាត (Huỳnh Tấn Phát) នាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្នវៀតណាមខាងត្បូង (វៀតកុង) បានដឹកនាំគណៈប្រតិភូមួយក្រុម មកបំពេញទស្សនកិច្ចនៅទីក្រុងភ្នំពេញ ក្នុងគោលបំណងធ្វើការស្ទាបស្ទង់ពីគោលជំហររបស់សម្តេចសីហនុ ជាមួយពួកគេផង និងធ្វើការកែលម្អនូវភាពមិនច្បាស់លាស់ នៃទំនាក់ទំនងពីមុនមកឱ្យបានច្បាស់លាស់ល្អប្រសើរឡើងវិញផងដែរ ។

ហ៊ុីញ តឹនផាត (Huỳnh Tấn Phát) បានជួបពិភាក្សាគ្នាជាមួយសម្តេចសីហនុ ជាព្រះប្រមុខរដ្ឋកម្ពុជា រយៈពេលប្រហែល៣ម៉ោង ក្នុងបរិយាកាសរីករាយស្និទ្ធស្នាលបំផុត ដោយផ្តោតសំខាន់ទៅលើការគោរពអធិបតេយ្យភាព បូរណភាពទឹកដីកម្ពុជា ។

នៅថ្ងៃបញ្ចប់ដំណើរទស្សនកិច្ចនោះ សម្តេចសីហនុ បានរៀបចំពិធីជប់លៀងដ៏អធិកអធមមួយ ផ្តល់ជាកិត្តិយសចំពោះហ៊ុីញ តឹនផាត (Huỳnh Tấn Phát) ហើយព្រះអង្គចាត់ទុកថា រដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្នវៀតណាមខាងត្បូង គឺជារដ្ឋាភិបាលស្របច្បាប់របស់ប្រទេសវៀតណាមខាងត្បូង និងជាមហាមិត្តរបស់ព្រះអង្គទៀតផង ។

សម្តេចសីហនុ បានសម្តែងនូវការកោតសរសើរចំពោះប្រជាជនវៀតណាម

ដែលបានធ្វើការតស៊ូប្រឆាំងនឹងការឈ្លានពានរបស់អាមេរិក និងបានបញ្ជាក់ជាថ្មីម្តងទៀត នូវការគាំទ្រដោយឥតសំចៃចំពោះរដ្ឋាភិបាលបដិវត្តន៍នេះ ដែលបានស្នើសុំឱ្យមានការចរចានៅទីក្រុងប៉ារីស ដើម្បីរកដំណោះស្រាយបញ្ចប់សង្គ្រាមនៅវៀតណាម ។

សម្តេចសីហនុ និងហ៊្វីញ តឹនផាត (Huỳnh TấnPhát) បានថ្លែងសុន្ទរកថា កោតសរសើរគ្នាទៅវិញទៅមក និងបានបញ្ជាក់ថា ចំណងសាមគ្គីភាពរវាងប្រទេសកម្ពុជា និងវៀតណាម មិនអាចសាបសូន្យបានឡើយ ។

ប៉ុន្តែក្រោយពេល ហ៊្វីញ តឹនផាត (Huỳnh Tấn Phát) ចាកចេញពីប្រទេសកម្ពុជាបានតែ២-៣ថ្ងៃប៉ុណ្ណោះ សម្តេចសីហនុ បានមានបន្ទូលប្រាប់មន្ត្រីការទូតអាមេរិក ថា ពួកកុម្មុយនិស្តវៀតណាម នៅតែមានគំនិតអាក្រក់ ហើយព្រះអង្គគ្មានជឿទុកចិត្តពួកនេះបន្តិចណាទេ ។

ចំណែករដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្នវៀតណាមខាងត្បូងវិញ បានចេញសេចក្តីថ្លែងការណ៍ជាផ្លូវការមួយ ដោយចាត់ទុកថា ដំណើរទស្សនកិច្ចរបស់នាយករដ្ឋមន្ត្រី ហ៊្វីញ តឹនផាត (Huỳnh Tấn Phát) នៅប្រទេសកម្ពុជា នោះថា ជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រមួយ និងបានរឹតចំណងសាមគ្គីរបស់ប្រជាជនជាបងប្អូនទាំង២ ឱ្យកាន់តែរឹងមាំទៀតផង ។

ចាប់ពីពេលនោះមក សម្តេចសីហនុ ក៏ចាប់ផ្តើមប្រុងប្រយ័ត្នចំពោះការមានបន្ទូលរបស់ព្រះអង្គ ដោយចៀសវាង មិនមានបន្ទូលរិះគន់វាយប្រហារទៅលើប្រទេសចិន និងលទ្ធិកុម្មុយនិស្ត ដូចមុនៗទៀតដែរ ។

កាលអំឡុងពេលប្រទេសចិន ធ្វើបដិវត្តន៍វប្បធម៌នោះ ទំនាក់ទំនងការទូតរវាងកម្ពុជា និងចិន ដែលសម្តេចសីហនុ បម្រុងនឹងកាត់ផ្តាច់នៅក្នុងខែកញ្ញា ឆ្នាំ១៩៦៧ ទៅហើយនោះ ត្រូវបាននាយករដ្ឋមន្ត្រីចិន ជូ អេនឡាយ ធ្វើការសម្របសម្រួលទាន់ពេលវេលា ធ្វើឱ្យចំណងការទូតនោះមានជីវិតបន្តទៀត ក៏ពិតមែន តែជាចំណងការទូតមួយដែលស្ថិតនៅក្នុងភាពមិនសូវជឿទុកចិត្តគ្នាដូចមុនឡើយ ។

នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៦៩ កាសែតឡា ណាស្យុង (La Nation) របស់ប៉ារាំង បានចុះផ្សាយថា សម្តេចសីហនុ បានធ្វើការបរិហារថ្កោលទោសចំពោះការជ្រៀតចូលរបស់ពួកវៀតកុង-វៀតណាមខាងជើង មកក្នុងទឹកដីរបស់ព្រះអង្គ។ ប៉ុន្តែព្រះអង្គបែរជាលើកតម្កើងទំនាក់ទំនងការទូតរដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្នវៀតណាមខាងត្បូង នៅក្នុងទីក្រុងភ្នំពេញ ឱ្យទៅដល់ថ្នាក់ឯកអគ្គរដ្ឋទូត ព្រមទាំងបានទទួលស្វាគមន៍ដំណើរទស្សនកិច្ចរបស់ ហ៊្វីញ តឹនផាត (Huỳnh Tấn Phát) នាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្នវៀតណាមខាងត្បូងនោះ យ៉ាងអធិកអធមទៀតផង ។

អ្នកកាសែតបរទេស បានចោទសួរសម្តេចសីហនុ ថា តើក្រោយពេលប្រទេសវៀតណាម មានសុខសន្តិភាព ព្រះអង្គមានជំនឿថា កងទ័ពវៀតកុង នឹងឈប់ចូលមកជ្រៀតជ្រែកក្នុងទឹកដីរបស់ព្រះអង្គបន្តទៀតដែរឬទេ ហើយពួកនេះអាចនឹងឈប់ជួយឧបត្ថម្ភគាំទ្រចំពោះការតស៊ូរបស់ពួកឧទ្ទាមខ្មែរក្រហមដែរឬទេ?

សម្តេចសីហនុ ឆ្លើយថា៖ នេះជាសំណួរមួយដែលប្រជារាស្ត្រខ្មែរ កំពុងតែសួរខ្លួនឯងសព្វថ្ងៃនេះដែរ។ តែគួរឱ្យសោកស្តាយ ដោយសារពេលនេះខ្ញុំមិនអាចឆ្លើយប្រាប់ថា នៅពេលប្រទេសវៀតណាម ទទួលបានសុខសន្តិភាពនៅពេលខាងមុខនេះ ពួកគេនឹងបញ្ឈប់ការជ្រៀតចូលមកក្នុងទឹកដីកម្ពុជា តទៅទៀត ឬពួកគេនឹងឈប់ផ្តល់ជំនួយដល់ពួកឧទ្ទាមខ្មែរក្រហមយ៉ាងណានោះទេ?។ តែយើងបានទទួលការសន្យាពីពួកគេថា ពួកគេនឹងដកទ័ពថយចេញពីកម្ពុជា នៅពេលសង្គ្រាមត្រូវបានបញ្ចប់ ហើយយើងក៏បានទាមទារឱ្យពួកគេគោរពការសន្យានេះដែរ។ ដូច្នេះ មានតែអនាគតកាលប៉ុណ្ណោះ ដែលជាអ្នកបញ្ជាក់ថា អ្វីៗនឹងទៅជាការពិតនោះ។ ប៉ុន្តែ បើ សកម្មភាពរបស់ពួកឧទ្ទាមខ្មែរក្រហមចេះតែថយចុះក្នុងរយៈពេលប៉ុន្មានខែខាងមុខតទៅទៀតនោះ វាអាចជាសញ្ញានៃក្តីសង្ឃឹមរបស់យើង ។

អ្នកកាសែតបរទេសបានសួរសម្តេចសីហនុ បន្តថា បើសហរដ្ឋអាមេរិក ដកខ្លួនទាំងស្រុងពីប្រទេសវៀតណាម តើចិន អាចគាំទ្រពួកខ្មែរក្រហមបន្ថែមទៀតទេ ហើយចិន

អាចបន្តការវាតទីរបស់គេនៅអាស៊ីអាគ្នេយ៍ ឬយ៉ាងណាដែរ?

សម្តេចសីហនុ ឆ្លើយថា យើងមិនដឹងច្បាស់ថា អ្វីខ្លះទៅ ដែលចិន ចង់បានពិតប្រាកដ នៅពេលចប់សង្គ្រាមនៅវៀតណាម នោះទេ។ តែយើងមិនគិតថា ចិនមានផលប្រយោជន៍អ្វី ក្នុងការគាំទ្រពួកខ្មែរក្រហម ដែលគ្រាន់តែជាចំណែកតូចមួយ ខណៈដែលចលនាសង្គមរាស្ត្រនិយមរបស់យើង សម្តែងឱ្យឃើញនូវទំនាក់ទំនងមិត្តភាពដ៏ល្អជាមួយចិន នាពេលបច្ចុប្បន្ន ហើយយើងក៏មានបំណងថែរក្សាទំនាក់ទំនងមិត្តភាពនេះឱ្យបានស្ថិតស្ថេរគង់វង្ស នៅពេលអនាគតដែរ។ ប៉ុន្តែ តាមបែបផែនដ៏ទូលំទូលាយជាងនេះ ចិនអាចចាប់ផ្តើមអនុវត្តគំនិតវាតទីនិយមតាមរយៈ មនោគមវិជ្ជារបស់ខ្លួនទៅលើអាស៊ីអាគ្នេយ៍ ក្រោយពេលសហរដ្ឋអាមេរិក ចាកចេញទាំងស្រុងពីប្រទេសវៀតណាម។ ប៉ុន្តែគ្មាននរណាអាចប៉ាន់ស្មានបានថា អ្វីពិតប្រាកដដែលកើតមាន ឬមិនកើតមាននៅពេលនោះបានឡើយ។ ដូច្នេះប្រទេសនីមួយៗ នៅក្នុងតំបន់( តំបន់អាស៊ីអាគ្នេយ៍) មានភារកិច្ចធ្វើការតស៊ូប្រឆាំងនឹងការប៉ុនប៉ងជាយថាហេតុ នៃការឆ្លងរីករាលដាលលទ្ធិម៉ៅនិយមចូលក្នុងប្រទេសរៀងៗខ្លួន ពិសេសជំរុញឱ្យមានគំនិតជាតិនិយម និងធ្វើឱ្យប្រជាពលរដ្ឋខ្លួនមានសុខមាលភាព ដើម្បីជារនាំងដ៏ប្រសើរបំផុត ក្នុងការទប់ទល់នឹងការវាតទីរបស់កុម្មុយនិស្តចិន នោះ។

តែយ៉ាងណាក៏ដោយ ក៏នៅថ្ងៃទី៤ ខែកក្កដា ឆ្នាំ១៩៦៩ សម្តេចសីហនុ បានបញ្ជាឱ្យដោះលែងអ្នកទោសវៀតកុង-វៀតណាមខាងជើង ( ឈ្លើយសឹក) ចំនួន២០នាក់ ។ នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ១៩៦៩ អ្នកទោសជាកងទ័ពវៀតកុង-វៀតណាមខាងជើង ចំនួន៥៣នាក់ ដែលកងយោធពលខេមរភូមិន្ទចាប់បានតាំងពីខែវិច្ឆិកា ឆ្នាំ១៩៦៨ ត្រូវបានសម្តេចសីហនុ បានបញ្ជាឱ្យដោះលែងបន្តទៀត ។

អ្នកទោសជាកងទ័ពវៀតកុង-វៀតណាមខាងជើង ត្រូវបានសម្តេចសីហនុ ដោះលែង និងប្រគល់ទៅឲ្យរដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្នវៀតណាមខាងត្បូង វិញជាបន្តបន្ទាប់ទៀត គឺ ថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៦៩ ដោះលែងចំនួន ៩១នាក់( ក្នុងនោះមានស្រី ចំនួន៣៨នាក់) ។

ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៦៩ ដោះលែង ចំនួន២២នាក់ ។

ថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៦៩ ដោះលែង ចំនួន១១នាក់។ ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៦៩ ដោះលែង ចំនួន៤នាក់ និងថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៧០ ដោះលែង ចំនួន១៦នាក់ ។

ង្វៀង បាឌុង អនុប្រធានគណៈកម្មាធិការបេសកកម្មការទូតរដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្នវៀតណាម ខាងត្បូង និងសហសេវិករបស់គាត់ម្នាក់ឈ្មោះង្វៀង ហ្វាំងគិញ ជាអ្នកមកទទួលអ្នកទោសវៀតកុង-វៀតណាមខាងជើង ទាំងនោះ បានបញ្ជាក់ថាអ្នកទោសទាំងអស់មានសុខភាពល្អ និងបានសំដែងការដឹងគុណចំពោះទឹកព្រះទ័យសប្បុរសធម៌ និងការសន្តោសប្រណីរបស់សម្តេចសីហនុ ដែលបានដោះលែងពួកគេផងដែរ។

# ២៥៩
# សម្តេចសីហនុ បណ្តោយឱ្យអាមេរិក មកទម្លាក់គ្រាប់បែកលើពួកវៀតកុង នៅក្នុងទឹកដីកម្ពុជា



សឺន សាន ឧបនាយករដ្ឋមន្ត្រីទី១
ជួបពិភាក្សាគ្នាជាមួយ ឆេស្ទ័រ បូវឡេស

*នៅថ្ងៃទី១០ ខែមករា ឆ្នាំ១៩៦៨ ឆេស្ទ័របូវឡេស* ( Chester Bowles ) *ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ប្រចាំប្រទេសឥណ្ឌា មកបំពេញទស្សនកិច្ចនៅកម្ពុជា ក្នុងនាមជាបេសកជនពិសេសរបស់ប្រធានាធិបតីចនសុន* ( John Son ) ។

*ពេលនោះ ឆេស្ទ័រ បូវឡេស* ( Chester Bowles ) *បានជួបពិភាក្សាជាមួយ សឺន សាន ជាឧបនាយករដ្ឋមន្ត្រីទី១ ទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយផ្តោតការយកចិត្តទុកដាក់ពីបញ្ហាស្តារ ទំនាក់ទំនងការទូតរវាងប្រទេសកម្ពុជា និងសហរដ្ឋអាមេរិកឡើងវិញ។ ប៉ុន្តែ ខ្លឹមសារនៃកិច្ចពិភាក្សាគ្នានេះ មិនត្រូវបានផ្សព្វផ្សាយឱ្យដឹងជាសាធារណៈទេ ។*

*នៅថ្ងៃទី១១ ខែមករា ឆ្នាំ១៩៦៨ សម្តេចសីហនុ បានសព្វព្រះទ័យរួមសោយព្រះក្រយាថ្ងៃត្រង់ជាមួយឆេស្ទ័រ បូវឡេស ផងដែរ ។*

*ច្រើនឆ្នាំក្រោយមក សឺន សាន ដែលបានចូលរួមក្នុងពិធីពិសាភោជនាហារនោះដែរ បានបង្ហើបឱ្យដឹងថា ពេលសោយព្រះក្រយារួច សម្តេចសីហនុ ក៏បានប្រទានព្រះតម្រិះទៅបេសកជនពិសេសឆេស្ទ័រ បូវឡេស សុំឱ្យសហរដ្ឋអាមេរិក ប្រើយន្តហោះមកទម្លាក់គ្រាប់បែកលើកងទ័ពវៀតកុង-វៀតណាមខាងជើង ដែលកំពុងបោះទីតាំងនៅលើទឹកដី*

ខ្មែរហើយ ធ្វើចរិតជាម្ចាស់នៅលើទឹកដីខ្មែរទៀតផង ។

ការសម្ងាត់ស្តីពីរឿងសម្តេចសីហនុ បើកដៃឱ្យកងទ័ពអាមេរិក ទម្លាក់គ្រាប់បែក ទៅលើទីតាំងកងទ័ពវៀតកុង-វៀតណាមខាងជើង នៅក្នុងទឹកដីកម្ពុជានេះត្រូវបានគេ លាក់ការណ៍ជិតឈឹងតែម្តង ។

នៅពេលជួបពិភាក្សាគ្នានោះដែរ សម្តេចសីហនុ បានចៀសវាង មិនឱ្យមានចំណុច ខ្វែងគ្នាក្នុងការវិលត្រលប់ទៅរកទំនាក់ទំនងការទូតជាមួយគ្នាឡើងវិញទេ ។

ចំណែកភាគីអាមេរិក ក៏បានបង្ហាញនូវជំហរយោគយល់គ្នា ដោយបានគូសបញ្ជាក់ថា ចាប់ពីថ្ងៃនេះតទៅ អាមេរិក នឹងធ្វើឱ្យអស់លទ្ធភាព ដើម្បីកុំឱ្យកងទ័ពរបស់ពួកគេនៅ វៀតណាមខាងត្បូងរំលោភបំពានលើព្រំដែនកម្ពុជា បន្តទៀត ហើយថា ពួកគេនឹងបញ្ជូន ព័ត៌មានសម្ងាត់ស្តីពីការជ្រៀតចូលរបស់ពួកវៀតកុង-វៀតណាមខាងជើង ចូលមកក្នុង ទឹកដីកម្ពុជា មកឱ្យរាជរដ្ឋាភិបាលក្រុងភ្នំពេញ បានដឹងទៀតផង ។

នៅដើមឆ្នាំ១៩៦៩ កងទ័ពវៀតកុង-វៀតណាមខាងជើង បានចូលមកបោះទីតាំង ឈរជើង កាន់តែច្រើនឡើង និងកាន់តែជ្រៅទៅៗ មកក្នុងទឹកដីកម្ពុជា។ ពិសេសនៅ ក្នុងតំបន់ចំពុះទា នៅក្នុងខេត្តស្វាយរៀង ។

ក្នុងផែនទីមួយ ដែលរៀបចំឡើងដោយអគ្គសេនាធិការដ្ឋានកងយោធពលខេមរភូមិន្ទ បានបង្ហាញយ៉ាងច្បាស់ថា កងទ័ពវៀតកុង-វៀតណាមខាងជើង បានបោះទីតាំង និងត្រួតត្រាទាំងស្រុងនៅតាមបណ្តោយព្រំដែនខាងកើត និងខាងត្បូងប្រទេសកម្ពុជា ចាប់តាំងពីតំបន់ព្រៃភ្នំខេត្តរតនគិរី រហូតដល់ខេត្តកំពត ជាខេត្តជាប់សមុទ្រ មានបណ្តោយ ប្រមាណ៦០០គីឡូម៉ែត្រ និងទទឹងពី៥ ទៅ១០គីឡូម៉ែត្រជាមធ្យម ដោយមានបោះទីតាំង កងវរសេនាតូច, កងវរសេនាធំ,ប៉ុស្តិ៍បញ្ជាការ, ឃ្លាំងផ្ទុកអាវុធគ្រាប់រំសេវ និងបន្ទាយ សម្រាប់ឱ្យកងទ័ពសម្រាកទៀតផង ។

នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៦៩ នៅពេលយាងទៅទីប្រជុំជនលំផាត់ ខេត្តរតនគិរី សម្តេចសីហនុ បានប្រកាសជាសាធារណៈថា កងទ័ពវៀតកុង-វៀតណាមខាងជើងបាន

ចូលមកកាន់បោះទីតាំងនៅស្រុកបរកែវ និងនៅស្រុកអណ្ដូងពេជ្រ ហើយព្រះអង្គក៏បានបញ្ជាឱ្យកងយោធពលខេមរភូមិន្ទ រុញច្រានពួកនេះឱ្យចេញទៅវិញដែរ ។

នៅក្នុងខែឧសភា ឆ្នាំ១៩៦៩ ឧត្ដមសេនីយ៍លន់ នល់ ក៏បញ្ជាឱ្យបើកប្រតិបត្តិការសឹកមួយបណ្ដេញកងទ័ព វៀតកុង-វៀតណាមខាងជើងឱ្យចាកចេញពីស្រុកបរកែវ ដោយជោគជ័យ ។

នៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ១៩៦៩ សម្ដេចសីហនុ បានប្រកាសជាសាធារណៈថា កម្ពុជានឹងផ្សារទំនាក់ទំនងការទូតជាមួយសហរដ្ឋអាមេរិកវិញ ដោយជាដំបូង រាជរដ្ឋាភិបាលក៏បានស្នើទៅសហរដ្ឋអាមេរិក ធ្វើការផ្លាស់ប្ដូរភារធារី គ្នាទៅវិញទៅមកសិន ។

នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៦៩ ដោយមានការយល់ព្រមពីរាជរដ្ឋាភិបាលកម្ពុជា អ្នកជំនាញការអាមេរិក ៤នាក់ បានធ្វើដំណើរមកប្រទេសកម្ពុជា ដើម្បីធ្វើការស្រាវជ្រាវ និងស៊ើបអង្កេតពីពាក្យបណ្ដឹងរបស់កម្ពុជា ស្ដីពីបញ្ហាខូចខាត ដោយសារការសាយភាយនៃជាតិគីមី ដែលយន្ដហោះអាមេរិក បានបាញ់ឱ្យស្វិតឈើជ្រុះនៅក្នុងទឹកដីនៃខេត្តកំពង់ចាម កាលពីខែមេសា និងឧសភា ដើម្បីងាយស្រួលក្នុងការតាមរុករកកងទ័ពវៀតកុង-វៀតណាមខាងជើង ដែលលាក់ខ្លួននៅទីនោះ។ ពេលនោះ រាជរដ្ឋាភិបាលកម្ពុជា ក៏បានទាមសំណងពីអាមេរិក ចំនួន៨.៦៨៤.៤១០ ដុល្លារ ផងដែរ ។

នៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៦៩ សម្ដេចសីហនុ បានសម្រេចព្រះទ័យផ្ដាច់ទំនាក់ទំនងការទូត ជាមួយសហព័ន្ធ អាល្លឺម៉ង់(អាល្លឺម៉ង់ខាងលិច) ដោយសារតែព្រះអង្គបានផ្សារទំនាក់ទំនងការទូតជាមួយសាធារណរដ្ឋប្រជាធិបតេយ្យ អាល្លឺម៉ង់ (អាល្លឺម៉ង់កុម្មុយនិស្ដ ឬអាល្លឺម៉ង់ខាងកើត) ដែលជាសត្រូវរបស់អាល្លឺម៉ង់ខាងលិច ។

ពេលនោះ រដ្ឋមន្ត្រី ការបរទេសអាល្លឺម៉ង់ខាងលិច ចាត់ទុកការផ្សារទំនាក់ទំនងការទូតជាមួយអាល្លឺម៉ង់ខាងកើតនោះ គឺជាទង្វើអមិត្តមួយរបស់សម្ដេចសីហនុ ចំពោះប្រទេសខ្លួន ។

ថ្ងៃទី១១ ខែកក្កដា ឆ្នាំ១៩៦៩ មន្ត្រីជាន់ខ្ពស់ក្រសួងការបរទេសអាមេរិក ឈ្មោះ

អេលដេន អេរិកសុន ( Elden Erikson ) បានអញ្ជើញមកដល់ទីក្រុងភ្នំពេញ ដើម្បីរៀបចំបើកស្ថានទូតអាមេរិកឡើងវិញ មុនពេលមន្ត្រីការទូតអាមេរិក ឈ្មោះឡយដ៍ រ៉ែវើស៍ ( Lloyd M Rivers ) មកបំពេញតួនាទីជាភារធារីនៅកម្ពុជា ។

នៅចុងខែកក្កដា ឆ្នាំ១៩៦៩ សម្តេចសីហនុ ក្នុងនាមជាព្រះប្រមុខរដ្ឋនៃព្រះរាជាចក្រកម្ពុជា បានផ្ញើ ព្រះរាជសារជាផ្លូវការមួយទៅប្រធានាធិបតីអាមេរិក និចសុន ឱ្យមកបំពេញទស្សនកិច្ចនៅកម្ពុជា ។

ជាមួយគ្នានោះដែរ ព្រះអង្គក៏បានហាមប្រាមមិនឱ្យបណ្តាញសារព័ត៌មានកម្ពុជាទាំងអស់ សរសេររិះគន់អំពីនយោបាយរបស់អាមេរិក នៅអាស៊ី ជាដាច់ខាត និងមិនឱ្យសរសេរពីការទម្លាក់គ្រាប់បែករបស់កងទ័ពអាកាសអាមេរិក នៅតាមតំបន់ព្រំដែនកម្ពុជា ដូចមុនទៀតឡើយ ។

វាប្រាកដណាស់ដែលថា ពេលនោះ សម្តេចសីហនុ មានជំនឿជឿជាក់ថា កងទ័ពវៀតកុង-វៀតណាមខាងជើង នឹងមានជ័យជម្នះលើរដ្ឋាភិបាលវៀតណាមខាងត្បូង ដែលជាសម្ព័ន្ធមិត្តរបស់សហរដ្ឋអាមេរិក ។ ប៉ុន្តែព្រះអង្គក៏ព្រួយព្រះទ័យណាស់ដែរ ក្រោយពេលកងទ័ពអាមេរិក ដកចេញពីវៀតណាមខាងត្បូង ព្រោះពេលនោះ ប្រទេសព្រះអង្គនឹងស្ថិតនៅតែម្នាក់ឯង ប្រឈមមុខជាមួយប្រទេសវៀតណាម ដែលក្លាយជាប្រទេសកុម្មុយនិស្ត ប្រកបដោយថាមពល និងប្រឈមមុខជាមួយប្រទេសប្រទេសថៃ ដែលជាសត្រូវឈ្លានពានដណ្តើមទឹកដីតាំងពីបុរាណកាលមក ។

# ២៦០
# ជីវភាពប្រជារាស្ត្រខ្មែរក្នុងសម័យទសវត្សរ៍ឆ្នាំ១៩៦០



តារាចម្រៀងម៉ៅ សារ៉េត ក្នុងក្រុមតន្ត្រីយោធាតិរម្យ

*មិនថាសម័យអាណានិគមបារាំង នោះទេ ទោះបីមកដល់សម័យដើមទសវត្សរ៍ឆ្នាំ១៩៦០ទៅហើយ ក៏ដោយ ក៏ដីស្រែចម្ការ រថយន្ត កង់ ម៉ូតូ គោ ក្របី ទូក រទេះ រហូតដល់វិទ្យុ ក៏ត្រូវបង់ពន្ធឲ្យរាជការដែរ។ នៅតាមឃុំនីមួយៗ ស្មៀនឃុំជាអ្នកកាន់បញ្ជីដើរទារពន្ធ។ បើពលរដ្ឋណាយឺតយ៉ាវបង់ពន្ធរយៈពេល១ឆ្នាំ ត្រូវឡើងទៅបង់ពន្ធនៅស្នាក់ការពន្ធដារខេត្ត ហើយត្រូវបង់ប្រាក់ពិន័យទៀតផង។ ក្នុងមួយឆ្នាំៗ រាជការយកពន្ធ វិទ្យុមួយគ្រឿង ១រៀល, ទូកមួយគ្រឿង ១រៀល, គោឬក្របីទឹមប្រើបាន ១នឹម ១រៀល, មេគោនិងកូនស្ទាវមិនយកពន្ធទេ ។ ស្រែវស្សា ស្រែប្រាំង អំពក សាបសំណាប ក៏រាជការតម្រូវឱ្យបង់ពន្ធជូនរដ្ឋដែរ ។*

*នៅដើមទសវត្សរ៍ឆ្នាំ១៩៦០ ក្នុងមួយភូមិៗ ប្រជារាស្ត្រដែលមានវិទ្យុស្តាប់ មានតែ*

១គ្រួសារ ឬ២គ្រួសារប៉ុណ្ណោះ ហើយពួកគេសុទ្ធតែជាអ្នកមានជីវភាពធូរធារផងដែរ ។

វិទ្យុសម័យនោះ មានតែវិទ្យុម៉ាកហ្វីលីព(Philips) ផលិតនៅប្រទេសហុល្លង់ ដាក់ថ្មពិលដល់ទៅ៦០ដុំឯណោះ ហើយឮសំឡេងខ្លាំងណាស់។ ជារៀងរាល់ព្រលប់ថ្ងៃសៅរ៍ ស្ថានីយវិទ្យុនៅក្រុងភ្នំពេញ មានកម្មវិធីចាក់ផ្សាយសិល្បៈអាយ៉ៃ និងល្ខោនបាសាក់ ដើម្បីចែកជូនប្រជារាស្ត្រនៅទូទាំងប្រទេស ស្តាប់កម្សាន្ត ។

សិល្បៈអាយ៉ៃ មាន២ប្រភេទ គឺអាយ៉ៃឆ្លងឆ្លើយ និងអាយ៉ៃរឿង សម្តែងដោយ តាសាលួត, តាល្វៃ, ស្មៀនឈិន, សង្ហា ផន, អន្ទិតសក់ខ្លី, នាងសាព៉ាំ ប៉ាក់, នាងសាទុំផ្កាយព្រឹក, នាងសារី ឆែម ជាដើម...។

ចំណែកសិល្បៈល្ខោនបាសាក់វិញ មានវង់ល្ខោនបាសាក់រស្មីចន្ទ្រាទួលទំពូង សម្តែងជាតួឯកដោយសាំង សារុន, នាងចេកម៉ាច, នាងយ៉ាន់ រឿន(ប្រពន្ធសាំង សារុន), ជឹម ឆន, ឯម សុផុនហៅក្តី ។

ក្រៅពីនេះ ក៏មានវង់ល្ខោនបាសាក់ផ្សារស៊ីឡិប របស់អ្នកម្នាងយិន តាត និងវង់ល្ខោនបាសាក់គីឡូលេខ៦ របស់ថៅកែបាក់ ស្រេង-អ្នកស្រីអ៊ុន វ៉ាង ដោយមានឈ្មោះអេតាលី ហៅភ្ញី និងនាងម៉ក់ ឡែន ជាតួឯក ។

នៅពេលមានកម្មវិធីចាក់ផ្សាយសិល្បៈអាយ៉ៃ ឬល្ខោនបាសាក់ តាមវិទ្យុជារៀងរាល់ព្រលប់ថ្ងៃសៅរ៍នោះ អ្នកភូមិជាច្រើនគ្រួសារតែងតែនាំកូនចៅតូចធំមកអង្គុយជុំគ្នានៅផ្ទះអ្នកដែលមានវិទ្យុម៉ាកហ្វីលីព(Philips)នោះ ភូមិខ្លះនាំគ្នាក្រាលកន្ទេលស្លឹកត្នោត អ្នកខ្លះដេក អ្នកខ្លះអង្គុយស្តាប់ការសម្តែងសិល្បៈអាយ៉ៃ ឬល្ខោនបាសាក់នោះ រហូតយប់ជ្រៅចប់កម្មវិធីសម្តែង(ល្ខោនវ៉ាពេង) ទើបដាស់កូនចៅដើរទៅផ្ទះរៀងៗខ្លួនវិញ ។

ក្រោយមក ប្រជារាស្ត្រខ្មែរក៏ឈប់ប្រើវិទ្យុម៉ាកហ្វីលីព(Philips)នេះទៀត ព្រោះមានវិទ្យុម៉ាកស្តង់ដារ(STANDARD) ម៉ាកហ្សាប(SHARP) និងម៉ាកនីវីកូ(NIVICO)នាំចូលមកពីជប៉ុន ដាក់ថ្មពិលតែ៤ដុំប៉ុណ្ណោះ ។

កាលនោះ ក៏មានការរត់ពន្ធវិទ្យុម៉ាកតូហូ(TOHO)ពីប្រទេសថៃ ចូលមកតាម

ច្រកព្រំដែនអូរជ្រៅ ផងដែរ ដោយវិទ្យុ ម៉ាកតូហូនេះ ប្រើថ្មពិល៤ដុំដែរ និងមានតម្លៃតែជាង១០០០រៀល ។

ប្រជារាស្ត្រប្រុសៗមានអាយុចាប់ពី១៨ឆ្នាំឡើង ត្រូវទៅធ្វើអត្តសញ្ញាណប័ណ្ណហៅថាកាត៥ផ្នត់ នៅសាលាស្រុក ។

ប្រជារាស្ត្រដែលត្រូវទៅធ្វើអត្តសញ្ញាណប័ណ្ណនោះ ម្នាក់ៗត្រូវបង់ប្រាក់២៥រៀល ។ បើគ្មានអត្តសញ្ញាណប័ណ្ណទេ ត្រូវយករូបថត៤គុណ៦ ពីរសន្លឹកត្រូវទៅធ្វើលិខិតបញ្ជាក់កិរិយាមារយាទនៅសាលាឃុំ និងត្រូវបង់ប្រាក់ ១០រៀល ផងដែរ។ ពេលដើរទៅណាឆ្ងាយត្រូវដាក់អត្តសញ្ញាណប័ណ្ណ ឬលិខិតបញ្ជាក់កិរិយាមារយាទនោះ ជាប់ក្នុងហោប៉ៅដើម្បីបង្ហាញសមត្ថកិច្ចប៉ូលិស។ បើសមត្ថកិច្ចប៉ូលិសឃាត់សួរនាំ ហើយដឹងថាគ្មានអត្តសញ្ញាណប័ណ្ណ ឬលិខិតបញ្ជាក់កិរិយាមារយាទទេ នឹងត្រូវផាកពិន័យ ២៥រៀល ។

ដោយឡែក មានតែអ្នកប្រកបរបរឡើងត្នោតប៉ុណ្ណោះ ដែលគ្រប់អាយុ១៨ឆ្នាំហើយ រាជការអនុគ្រោះ មិនបាច់ឱ្យធ្វើកាត៥ផ្នត់ តែពេលធ្វើដំណើរទៅទីប្រជុំជនត្រូវក្រវាត់កាំបិតចិតត្នោតនៅចង្កេះជាសញ្ញាឱ្យដឹងថាពួកគេជាអ្នកឡើងត្នោត ។ តែបើពេលបុណ្យអុំទូក៣ថ្ងៃ នៅភ្នំពេញ ចំណុះទូកដែលគ្មានកាត៥ផ្នត់ ត្រូវកាន់ច្រវាអុំទូកជាសញ្ញា ដើម្បីកុំឱ្យសមត្ថកិច្ចចាប់ផាកពិន័យ ។

សម័យនោះ មេឃុំគ្មានសាលាឃុំសម្រាប់ធ្វើការឱ្យបានសមរម្យទេ គឺមេឃុំយកផ្ទះរបស់ខ្លួនធ្វើជាកន្លែងធ្វើការតែម្តង ។

ឆ្នាំ១៩៦៧-១៩៦៨ នៅស្រុកព្រៃឈរ ខេត្តកំពង់ចាម ក៏ដូចជានៅតាមបណ្តាខេត្តផ្សេងៗទៀតដែរ កសិករធ្លាប់លក់ស្រូវ១ថាំង(២៤គ.ក)បានតែតម្លៃ៦០រៀលប៉ុណ្ណោះ។ លុះចូលដល់ឆ្នាំ១៩៦៩ ស្រូវ១ថាំង បានឡើងថ្លៃដល់ ១០០រៀល ។

នៅរដូវចម្រូត ពួកឈ្មួញធំៗចាត់ឲ្យក្រុមអ្នកស្រុកដើរទិញស្រូវតាមផ្ទះឬដល់លានពោយស្រូវតែម្តង ។

ពួកគេដឹកស្រូវតាមរថយន្តទ្រុងឬត្រាក់ទ័រសណ្តោងរ៉ឺម៉ក គគ្រឹកគគ្រេងទាំងយប់

ទាំងថ្ងៃ។ ពួកឈ្មួញប្រមូលទិញស្រូវពីប្រជាកសិករ យកទៅចូលរោងម៉ាស៊ីនធំៗ កិនជាអង្ករដើម្បីយកទៅលក់ឱ្យកងទ័ពវៀតកុង-វៀតណាមខាងជើង ចំណេញបានប្រាក់យ៉ាងច្រើនសន្ធឹកសន្ធាប់ ។



**វិមានឯករាជ្យ នាដើមទសវត្សរ៍ឆ្នាំ១៩៦០**

ជារៀងរាល់ឆ្នាំ នៅទូទាំងប្រទេស សិស្សថ្នាក់ទី៧ទាំងអស់នៃសាលាបឋមសិក្សាត្រូវប្រលងចូលរៀនថ្នាក់ទី៦ ទំនើបជាតិនៅតាមអនុវិទ្យាល័យ ឬវិទ្យាល័យនានា ។ តែមុនពេលប្រលងសិស្សម្នាក់ៗត្រូវបំពេញបែបបទ និងសរសេរពាក្យសុំប្រលងដោយខ្លួនឯងផ្ទាល់ ។

បើសិស្សណាប្រលងជាប់ជាស្ថាពរ បានចូលរៀនថ្នាក់ទី៦ ទំនើបជាតិ ត្រូវបង់ប្រាក់២០០០រៀល តែបើសិស្សណាជាប់បម្រុង ត្រូវបង់ប្រាក់៣៥០០រៀល ។

សម័យឆ្នាំ១៩៦៧-៦៨នោះ មាស១ជី តម្លៃ៣០០រៀល ។

ចំពោះគ្រួសារមានជីវភាពសម្បូរធូរធារមិនជាបញ្ហាចោទប៉ុន្មានទេ តែសម្រាប់គ្រួសារកសិករក្រីក្រ ត្រូវយកដីស្រែចម្ការទៅបញ្ចាំឱ្យពួកអ្នកមាន ដើម្បីយកប្រាក់មក

បង់ថ្លៃចូលរៀនថ្នាក់ទី៦ទំនើបជាតិនោះ ។ បើសិស្សរៀនថ្នាក់ទី៣ណាម្នាក់ ប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ( ឌីប្លូម) អាចដាក់ពាក្យប្រលងធ្វើគ្រូបង្រៀនថ្នាក់បឋមសិក្សា បានតាមបំណងប្រាថ្នា ។

គ្រួសារអ្នកមានជីវភាពធូរធារខ្លះ គ្រាន់តែដឹងថា មានកំលោះណាម្នាក់ប្រឡងជាប់គ្រូភូមា ទោះបីមិនទាន់បានទៅចូលរៀននៅសាលាគរុកោសល្យផង ក៏អ្នកនោះចូលមកទាក់ទងចែចូវចង់លើកកូនក្រមុំឱ្យទៅហើយ ។

អំឡុងពេលនោះដែរ ស្រូវ១ថាំង( ២៤គ.ក) ថ្លៃ៦០រៀល តម្លៃមាស១ជី ថ្លៃតែ៣០០រៀលប៉ុណ្ណោះ។ ដល់លុះស្រូវ១ថាំងឡើងថ្លៃដល់១០០រៀល មាស១ជី ក៏ឡើងថ្លៃជាង៦០០រៀល ទៅជិត៧០០រៀលដែរ ។

នេះមិនមែនដោយសារក្រុមហ៊ុនជាតិសូណិចស៊ីម (SONEXIM) ប្រមូលទិញស្រូវពីកសិករដោយឱ្យតម្លៃខ្ពស់ នាំចេញទៅលក់នៅក្រៅប្រទេស ដើម្បីលើកកម្ពស់ជីវភាពប្រជាកសិករនោះទេ ផ្ទុយទៅវិញ បញ្ហាស្រូវឡើងថ្លៃនេះ គឺដោយសារពួកវៀតកុង-វៀតណាមខាងជើង បានលួចបោះពុម្ពប្រាក់ខ្មែរក្រដាស៥០០រៀល យ៉ាងច្រើនសន្ធឹកសន្ធាប់ យកមកទិញអង្ករខ្មែរ ដើម្បីយកទៅផ្គត់ផ្គង់ដល់កងទ័ពរបស់ពួកគេ ។

ចំណែកប្រជាកសិកខ្មែរ និងពួកឈ្មួញធំៗ ឃើញស្រូវអង្ករឡើងថ្លៃដូច្នេះ ក៏នាំគ្នារត់ពន្ធអង្ករទៅលក់ឱ្យពួកវៀតកុង-វៀតណាមខាងជើង ទាំងថ្ងៃទាំងយប់គ្មានឈប់ឈរ ។

ឯក្រុមហ៊ុនជាតិសូណិចស៊ីម (SONEXIM )វិញ ទិញស្រូវអង្ករក្នុងតម្លៃថោកៗគ្មានប្រជាកសិករខ្មែរណាដឹកស្រូវទៅលក់ឱ្យទេ ។

មិនយូរប៉ុន្មាន ស្រាប់តែវិទ្យុផ្សាយសំឡេងភ្នំពេញ បានប្រកាសផ្សព្វផ្សាយថា ពេលនេះ ក្រដាសប្រាក់៥០០រៀល ដែលមានរូបចម្លាក់អប្សរា២នាក់ និងចុះហត្ថលេខាដោយអគ្គទេសាភិបាល សឺន សាន ដែលបោះពុម្ពតាំងពីឆ្នាំ១៩៥៦ មកនោះ មានគេលួចបោះពុម្ពក្លែងក្លាយ និងកំពុងចរាចរចាយពេញផ្ទៃប្រទេស។ ហេតុនេះ សូមឲ្យប្រជារាស្ត្រ

ខ្មែរ នាំគ្នាយកលុយក្រដាសប្រាក់៥០០រៀល ដែលមានរូបអប្សរា២នាក់ និងចុះហត្ថលេខា ដោយអគ្គទេសាភិបាល សឺន សាន ទៅប្តូរយកលុយក្រដាសប្រាក់៥០០រៀលប្រភេទថ្មី ដែលមានរូបកសិករស្លៀកខោខ្លីពណ៌លឿង កំពុងកាន់យាមនង្គ័លភ្ជួរដីស្រែឬក្រដាសប្រាក់ ៥០០រៀលរូបគោ ចុះហត្ថលេខាដោយអគ្គទេសាភិបាលថ្មី មកចាយវាយជំនួសវិញ ។




ក្រដាសប្រាក់៥០០រៀល ប្រភេទថ្មី




ក្រដាសប្រាក់៥០០រៀល ប្រភេទចាស់ ត្រូវដូរចេញ

ប្រជារាស្ត្រខ្មែរខ្លះ បានអះអាងថា គាត់ឃើញកងទ័ពវៀតកុង នាំគ្នាចេញពីព្រៃ នៅក្បែរៗព្រំដែន ចូលមកដល់ ផ្សារខេត្តក្រចេះ អង្គុយស៊ីគុយទាវផឹកកាហ្វេ និងទិញទំនិញ ចាំបាច់ផ្សេងៗទៀត ដោយទូទាត់ជាលុយខ្មែរក្រដាស ៥០០រៀលរូបចម្លាក់អប្សរា២នាក់ ថ្មីៗបែស ទាំងបាច់ៗ ។

# ២៦១
# សម្ដេចសីហនុ បង្កើតរាជរដ្ឋាភិបាលស្រោចស្រង់ជាតិ




ឧត្ដមសេនីយ៍ឯកលន់ នល់ លុតជង្គង់ទទួលសម្ដេចសីហនុ

*ក្នុងគោលបំណងដោះស្រាយបញ្ហាសេដ្ឋកិច្ចជាតិដែលកាន់តែធ្លាក់ដុនដាបទៅៗផង ព្រមទាំងបញ្ហាវត្តមានកងទ័ព វៀតកុង-វៀតណាមខាងជើង ចូលមកបោះទីតាំងឈរជើង នៅក្នុងទឹកដីខ្មែរកាន់តែច្រើនឡើងៗផង និងបញ្ហាការបរទេសផងដែរនោះ នៅថ្ងៃទី០៤ ខែសីហា ឆ្នាំ១៩៦៩ សម្ដេចសីហនុ បានកោះប្រជុំសមាជពិសេសមួយនៅក្នុងព្រះបរមរាជវាំង ដោយអញ្ជើញតែសមាសភាពសមាជិកគណៈរដ្ឋមន្ត្រី, សមាជិករដ្ឋសភា, សមាជិកក្រុមប្រឹក្សាព្រះរាជាណាចក្រ ,សមាជិកបរៈរាជរដ្ឋាភិបាល, សមាជិកសភាយុវជន, តំណាងសារព័ត៌មានរដ្ឋ និងឯកជន សរុប ប្រមាណជាង៣០០នាក់ ចូលរួមតែប៉ុណ្ណោះ ។*

*ចំណែកក្រុមឥស្សរជនដែលមានគំនិតកណ្ដាលនិយម និងឆ្វេងនិយម ត្រូវបាន*

ព្រះអង្គបដិសេធ មិនឱ្យចូលប្រជុំក្នុងសមាជពិសេសនោះឡើយ ។

ក្នុងសមាជពិសេសនោះ សម្តេចសីហនុ បានជ្រើសតាំងឥស្សរជនចំនួន១០រូប ដាក់ជាបេក្ខជន ដើម្បីឱ្យអ្នកចូលរួមក្នុងសមាជពិសេសនោះ បោះឆ្នោតជ្រើសរើសយកម្នាក់ ឱ្យធ្វើជានាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលថ្មីមួយ ដែលព្រះអង្គ ឱ្យឈ្មោះថា រាជរដ្ឋាភិបាលស្រោចស្រង់ជាតិ ។

ក្រោយពីដំណើរការបោះឆ្នោត លទ្ធផលបានបង្ហាញថា ១.ឧត្តមសេនីយ៍ឯក លន់ នល់ ទទួលបានការគាំទ្រចំនួន ១១៥សំឡេង, ២.ព្រះអង្គម្ចាស់ស៊ីសុវត្ថិ សិរិមតៈ ទទួលបានការគាំទ្រចំនួន៩៩សំឡេង, ៣.ព្រះអង្គម្ចាស់នរោត្តម កន្តុល ទទួលបានការគាំទ្រចំនួន៩៦សំឡេង, ៤.ព្រះអង្គម្ចាស់នរោត្តម នរទីបោ( នរៈទីប៉ូ) ព្រះជន្ម ២៣វស្សា ជាបុត្រារបស់សម្តេចសីហនុ ទទួលបានការគាំទ្រចំនួន៩០សំឡេង, ៥.អ៊ុង ហុងសាធទទួលបានការគាំទ្រចំនួន ៨៨សំឡេង, ៦.យ៉ែម សំបូរ ទទួលបានការគាំទ្រចំនួន៨៧សំឡេង, ៧.ផ្វៃក គីន ទទួលបានការគាំទ្រចំនួន៨៥ សំឡេង, ៨.សាន យុន ទទួលបានការគាំទ្រចំនួន៧៧សំឡេង, ៩.ញឹក ជូឡុង ទទួលបានការគាំទ្រចំនួន៧៦សំឡេង និង១០.ឧប គឹមអាង ទទួលបានការគាំទ្រចំនួន៧០សំឡេង ។




តែទោះបីលទ្ធផលនៃការបោះឆ្នោត ឧត្តមសេនីយ៍ឯកលន់ នល់ ទទួលបានការគាំទ្រចំនួន១១៥សំឡេង ក៏ដោយ ក៏គាត់បានឡើងប្រកាសនៅក្នុងពិធីនោះថា រូបគាត់ពុំមានសមត្ថភាពក្នុងការបង្កើត និងដឹកនាំរាជរដ្ឋាភិបាលស្រោចស្រង់ជាតិនោះទេ គឺ

*សូមប្រគល់ភារកិច្ចនេះ ទៅព្រះអង្គម្ចាស់ស៊ីសុវត្ថិ សិរិមតៈ ដែលជាអ្នកជាប់ឆ្នោត លំដាប់ទី២ ( ទទួលបានការគាំទ្រចំនួន៩៩សំឡេង)វិញ។ បន្ទាប់មក ព្រះអង្គម្ចាស់ស៊ីសុវត្ថិ សិរិមតៈក៏បានឡើងប្រកាសថា ទ្រង់ក៏មិនមានសមត្ថភាពបង្កើត និងដឹកនាំរាជរដ្ឋាភិបាលនោះដែរ។*

*ពេលនោះ សម្តេចសីហនុ បានឡើងមានបន្ទូលស្នើសុំដល់អង្គសមាជទាំងមូលថា ទោះយ៉ាងណា សូមកុំជ្រើសតាំងបុត្រានរោត្តម នរទីបោ( នរៈទីប៉ូ) ដែលទទួលការគាំទ្រចំនួន៩០សំឡេងដែរនោះ ធ្វើជានាយករដ្ឋមន្ត្រីឱ្យសោះ។ តែព្រះអង្គមិនយល់ទាស់ទេ ប្រសិនបើឥស្សរជនណាត្រូវបានជ្រើសតាំងជានាយករដ្ឋមន្ត្រីរាជរដ្ឋាភិបាលស្រោចស្រង់ជាតិ ពេញចិត្តជ្រើសរើសបុត្រាអង្គនេះឱ្យធ្វើជាសមាជិករាជរដ្ឋាភិបាល ។*


ព្រះអង្គម្ចាស់ នរោត្តម នរទីបោ
HORS CONCOURS

[ក្នុងឱកាសសមាជពិសេស (៤-៨-៦៩) ព្រះអង្គម្ចាស់នរទីបោ ត្រូវបានសមាជិកសមាជពិសេស បោះឆ្នោតថ្វាយសេចក្តីទុកចិត្ត ឲ្យធ្វើជានាយករដ្ឋមន្ត្រីបានចំនួន ៩០សម្លេង ។ តាមព្រះរាជបន្ទូល នៃ សម្តេចឳ ជាអម្ចាស់ ព្រះអង្គសុំអនុញ្ញាតពីសមាជពិសេស ពុំជ្រើសរើសព្រះអង្គម្ចាស់ ព្រះរាជបុត្រជានាយករដ្ឋមន្ត្រីបានទេ ។ ប៉ុន្តែព្រះអង្គទ្រង់ពុំយល់ទាស់ឡើយ បើមានាយករដ្ឋមន្ត្រីណាពេញចិត្តថ្វាយព្រះអង្គម្ចាស់ នរទីបោ ធ្វើជាសមាជិករដ្ឋាភិបាល ។

បុត្រានរោត្តម នរទីបោ(នរៈទីប៉ូ) ឯកសារកាសែតក្នុងស្រុក ខែសីហា ឆ្នាំ១៩៦៩

ការដាក់បុត្រា នរទីបោ ( នរៈទីប៉ូ) ធ្វើជាបេក្ខជននាយករដ្ឋមន្ត្រីនោះ គឺសម្ដេច សីហនុ គ្រាន់តែជាការចង់ស្ទាបស្ទង់ប្រជាប្រិយភាពរបស់បុត្រាព្រះអង្គ សម្រាប់ពេល អនាគតតែប៉ុណ្ណោះ ។

ពេលនោះ កុំថាឡើយដល់ឱ្យធ្វើជានាយករដ្ឋមន្ត្រី សូម្បីតែឱ្យធ្វើជារដ្ឋមន្ត្រី ឬជា រដ្ឋលេខាធិការនៅក្នុងរាជរដ្ឋាភិបាល ស្រោចស្រង់ជាតិនោះ ក៏ទ្រង់នរទីបោ( នរៈទីប៉ូ) មិន បានធ្វើផង ព្រោះនេះ អាចមកពីវ័យនៅក្មេងខ្ចី ( ព្រះជន្ម ទើប២៣ឆ្នាំ) និងខ្វះបទពិសោធ ក្នុងការដឹកនាំផងដែរ ។

ដើម្បីដោះស្រាយបញ្ហាបង្កើតរាជរដ្ឋាភិបាលស្រោចស្រង់ជាតិនេះឱ្យខាងតែ បាន សម្តេចសីហនុ ក៏បានធ្វើការពិគ្រោះយោបល់ភ្លាមៗ ជាមួយព្រះអង្គម្ចាស់នរោត្តម កន្តុល ដែលជារាជវង្ស និងឥស្សរជនដ៏មានឥទ្ធិពលម្នាក់ដែរ ។

បន្ទាប់ពីពិគ្រោះយោបល់ជាមួយព្រះអង្គម្ចាស់នរោត្តម កន្តុល មក សម្តេចសីហនុ ក៏បានឡើងមានបន្ទូលប្រកាសរបៀបជាការដាក់បញ្ជាទៅលើឧត្តមសេនីយ៍លន់ នល់ ជា មនុស្សដែលព្រះអង្គជឿទុកចិត្តបំផុតនោះ ឱ្យទទួលយកតំណែងជានាយករដ្ឋមន្ត្រីនៃ រាជរដ្ឋាភិបាលស្រោចស្រង់ជាតិ ដោយមិនអាចប្រកែកតវ៉ាបានជាដាច់ខាត ។

បើតាមប្រភពពីមន្ត្រីជាន់ខ្ពស់ម្នាក់ បានបង្ហើបឱ្យដឹងថា មុនពេលបោះឆ្នោតនោះ សម្តេចសីហនុ និងឧត្តមសេនីយ៍ លន់ នល់ បានពិភាក្សាគ្នាជាសម្ងាត់ពីរឿងរៀបចំរាជរដ្ឋា ភិបាលស្រោចស្រង់ជាតិនេះជាមុនរួចទៅហើយ ទោះបីជាស្ត្រីដ៏មានឥទ្ធិពលបំផុតម្នាក់ ( អ្នកម្នាងម៉ូនិក? ) និងពួកមន្ត្រីអែបអបនៅជុំវិញព្រះអង្គបានចាក់រុក កុំឱ្យព្រះអង្គជ្រើស តាំងឧត្តមសេនីយ៍លន់ នល់ ធ្វើជានាយករដ្ឋមន្ត្រី ដើម្បីកុំឱ្យបាត់បង់ផលប្រយោជន៍ក្នុង មុខជំនួញរបស់ពួកគេយ៉ាងណា ក៏ដោយ ក៏ព្រះអង្គនៅតែជឿជាក់ថា នៅពេលនេះ មានតែ ឧត្តមសេនីយ៍លន់ នល់ ទេ ដែលអាចជួយព្រះអង្គក្នុងការស្រោចស្រង់ប្រទេសជាតិបាន។

ការពិត សម្តេចសីហនុ ក៏បានដឹងច្បាស់ដែរថា ឧត្តមសេនីយ៍លន់ នល់ ពុំមាន សមត្ថភាពក្នុងការដោះស្រាយបញ្ហានយោបាយ និងបញ្ហាសេដ្ឋកិច្ចនោះបានទេ។ ប៉ុន្តែ

ព្រះអង្គជ្រើសតាំងជានាយករដ្ឋមន្ត្រីនេះ គឺដើម្បីឱ្យ ឧត្តមសេនីយ៍លន់ នល់ ក្លាយជាស៊ូហារតូ នៅកម្ពុជា ដឹកនាំកងទ័ពចេញបង្ក្រាបពួកឧទ្ទាមខ្មែរក្រហម ដែលបង្កអសន្តិសុខដល់ប្រទេសជាតិតាំងពីឆ្នាំ១៩៦៧ មកនោះ។ ស៊ូហារតូ ជាអ្នកដឹកនាំកងទ័ពចេញបង្ក្រាបពួកកុម្មុយនិស្តនៅប្រទេសឥណ្ឌូណេស៊ី ឱ្យវិនាសសូន្យ កាលពីអំឡុងឆ្នាំ ១៩៦៥ និង១៩៦៦ ។

ជាមួយគ្នានោះ ព្រះអង្គជឿជាក់ថា ប្រសិនបើពួកឧទ្ទាមខ្មែរក្រហមធ្វើសកម្មភាពវិទ្ធង្សនាខ្លាំងក្លាបន្តទៀតនោះ ឧត្តមសេនីយ៍ជាសេនាដៃស្តាំរបស់ព្រះអង្គម្នាក់នេះ ក៏នឹងមិនរួញរាក្នុងការដឹកនាំប្រទេស ងាកទៅរកសហរដ្ឋអាមេរិក ដែរ ។

ឧត្តមសេនីយ៍លន់ នល់ ជាអ្នកជឿជាក់លើព្រះពុទ្ធសាសនា ពិសេសជឿលើមន្តអាគមផ្សេងៗហួសហេតុ ផងដែរ តែគាត់ជាមនុស្សស្អប់ខ្ពើមលទ្ធិកុម្មុយនិស្តជាទីបំផុត ។ បណ្តាប្រទេសសេរីប្រជាធិបតេយ្យនៅលើពិភពលោក ពិសេស សហរដ្ឋអាមេរិក ជឿទុកចិត្ត និងសង្ឃឹមលើគាត់ ។

មតិអន្តរជាតិខ្លះ យល់ឃើញថា គាត់ជាមនុស្សមិនសូវរួសរាយរាក់ទាក់ និងគ្មានមហិច្ឆតានយោបាយទេ តែបើគាត់មានគំនិតស្ទុងទៅរកអ្វីមួយ គាត់ត្រូវតែធ្វើ ទោះបីមានឧបសគ្គយ៉ាងណាក៏ដោយ ពោលគឺ គាត់ប្រៀបដូចជាត្រាក់ទ័រប៊ុលដូហ្ស៊័រ ( Bulldozer ) មួយគ្រឿងដែលកំពុងបើកកាត់ព្រៃភ្នំយ៉ាងដូច្នោះដែរ ។

នៅថ្ងៃទី១៤ ខែសីហា ឆ្នាំ១៩៦៩ ឧត្តមសេនីយ៍ឯក លន់ នល់ បានដឹកនាំសមាជិករាជរដ្ឋាភិបាលស្រោចស្រង់ជាតិ ទៅបង្ហាញខ្លួននៅក្នុងរដ្ឋសភា ដើម្បីសុំការអនុម័តយល់ព្រមពីពួកតំណាងរាស្ត្រ ។

សមាសភាពរាជរដ្ឋាភិបាលស្រោចស្រង់ជាតិនោះ រួមមាន៖ ឧត្តមសេនីយ៍ឯក លន់ នល់ ជា នាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការពារជាតិ, ព្រះអង្គម្ចាស់ស៊ីសុវត្ថិ សិរិមតៈ ជាឧបនាយករដ្ឋមន្ត្រីទី១ ទទួលបន្ទុកមហាផ្ទៃ អប់រំជាតិ សម្របសម្រួលកិច្ចការសាសនា សណ្តាប់ធ្នាប់ និងសន្តិសុខជាតិ, អ៊ឹង ហុងសាធ ជាឧបនាយករដ្ឋមន្ត្រីទី២ទទួលបន្ទុកសាធារណៈសុខាភិបាល សង្គមកិច្ច ការងារបង្កើនគុណភាពដីធ្លី អភិវឌ្ឍន៍សហ

គមន៍ លំនៅឋាន និងព័ត៌មាន, ឌប គឹមអាង ជាឧបនាយករដ្ឋមន្ត្រីទី៣ ទទួលបន្ទុកហិរញ្ញវត្ថុ ផែនការ និងសម្របសម្រួលកិច្ចការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, យ៉ែម សំបូរ ទេសរដ្ឋមន្ត្រីទទួលបន្ទុកយុត្តិធម៌ និងទំនាក់ទំនងសភា, ព្រះអង្គម្ចាស់នរោត្តម ភូរិស្សរ៉ាជារដ្ឋមន្ត្រីក្រសួងការបរទេស, ផ្ទៃក ភឺន ជារដ្ឋមន្ត្រីក្រសួងសាធារណការ និងទូរគមនាគមន៍, ជួន សៅឌី ជារដ្ឋមន្ត្រីក្រសួងកសិកម្ម, លោកស្រីអ៊ឹង មឹង រដ្ឋលេខាធិការក្រសួងទេសចរណ៍, វរសេនីយ៍ឯកអ៊ុំ ម៉ាន្នូរិន ជារដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលបន្ទុកក្រសួងការពារលើផ្ទៃប្រទេស, វរសេនីយ៍ឯកសុស្តែន ហ្វែរណង់ដេស ជារដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលបន្ទុកក្រសួងសន្តិសុខជាតិ, ស្រី ប៉ុង ជារដ្ឋលេខាធិការក្រសួងឧស្សាហកម្ម, ព្រំ ថុស ជារដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម, ទេព ឈីវខេង ជារដ្ឋលេខាធិការក្រសួងឃោសនាការ, ឌី ទូច ជារដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលបន្ទុកក្រសួងធម្មការ និងសាសនសិក្សា និង ឡុង បុត្តា ជារដ្ឋលេខាធិការក្រសួងអប់រំជាតិ ។

តែនៅក្នុងសមាសភាពរាជរដ្ឋាភិបាលស្រោចស្រង់ជាតិនេះ ក៏មានមួយចំនួនជាមនុស្សជំនិតរបស់សម្តេចសីហនុ ដែរ ដូចជា អ៊ឹង ហុងសាធ ជាឧបនាយករដ្ឋមន្ត្រីទី២, ព្រះអង្គម្ចាស់នរោត្តម ភូរិស្សរ៉ា ជារដ្ឋមន្ត្រីក្រសួងការបរទេស, វរសេនីយ៍ឯកអ៊ុំ ម៉ាន្នូរិន (បងថ្លៃសម្តេចសីហនុ) ជារដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលបន្ទុកក្រសួងការពារលើផ្ទៃប្រទេស, វរសេនីយ៍ឯកសុស្តែន ហ្វែរណង់ដេស ជារដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលបន្ទុកក្រសួងសន្តិសុខជាតិ, ជួន សៅឌី ជារដ្ឋមន្ត្រីក្រសួងកសិកម្ម និងទេព ឈីវខេង ជារដ្ឋលេខាធិការក្រសួងឃោសនាការ ។

មួយថ្ងៃក្រោយមក គឺនៅថ្ងៃទី១៤ ខែ សីហា ឆ្នាំ១៩៦៩ សម្តេចសីហនុ បានអនុញ្ញាតឱ្យគណៈរដ្ឋមន្ត្រីថ្មី ចូលគាល់ ដើម្បីសម្តែងការគួរសម និងទទួលការណែនាំពីព្រះអង្គផងដែរ។ ពេលនោះព្រះអង្គបានសម្តែងនូវទំនុកព្រះទ័យទាំងស្រុង ចំពោះរាជរដ្ឋាភិបាលស្រោចស្រង់ជាតិនេះ ដោយព្រះអង្គមានបន្ទូលថា ព្រះអង្គប្រគល់អំណាចពេញលេញដល់រាជរដ្ឋាភិបាលនេះធ្វើសកម្មភាព ដោយសេរីលើគ្រប់វិស័យ គឺព្រះអង្គមិន

រារាំងអ្វីទាំងអស់ ។

ព្រះអង្គមានបន្ទូលទៀតថា រាជរដ្ឋាភិបាលថ្មីនេះ មិនត្រូវរួញរាក្នុងការសើរើពិនិត្យនូវអ្វីៗដែលមានកន្លងមកនោះទេ តែត្រូវធ្វើដោយគិតទៅដល់សេចក្តីថ្លៃថ្នូររបស់ជាតិ និងមិនឱ្យប៉ះពាល់ដល់គោលនយោបាយមិនចូលបក្សសម្ព័ន្ធ ដែលត្រូវការពារឱ្យបានជាដាច់ខាត ។

បន្ទាប់មក ក្នុងជំនួបជាឯកជនជាមួយឧត្តមសេនីយ៍លន់ នល់ ដែលជានាយករដ្ឋមន្ត្រីទើបនឹងតែងតាំងថ្មីនោះ សម្តេចសីហនុ បានបញ្ជាក់ប្រាប់លន់ នល់ បន្ថែមថា ព្រះអង្គសម្លឹងឃើញអត្ថប្រយោជន៍ជាច្រើនក្នុងការពង្រឹងទំនាក់ទំនងការទូតជាមួយសហរដ្ឋអាមេរិក និងការទទួលជំនួយពីប្រទេសជាមហាអំណាចមួយនេះ ផងដែរ ។

នៅថ្ងៃទី២១ ខែសីហា ឆ្នាំ១៩៦៩ សម្តេចសីហនុ បានរាជានុញ្ញាតឱ្យសមាជិកព្រឹទ្ធសភាអាមេរិក ឈ្មោះ ម៉ៃ ម៉ាន់ហ្វៀល( Mike Mansfield ) ដែលមកបំពេញទស្សនកិច្ចនៅទីក្រុងភ្នំពេញ ចូលជួបពិភាក្សា ។

ជាមួយគ្នានោះ ព្រះអង្គបានឱ្យលន់ នល់ ស្នើសុំប្រទេសបារាំងធ្វើជាមេអណ្តើកដើម្បីជួយធ្វើការសម្របសម្រួល ជាមួយប្រទេសថៃ ដើម្បីស្តារទំនាក់ទំនងការទូតរវាងប្រទេសទាំង២ឡើងវិញ និងសុំជួយគាំពារឱ្យមានសេចក្តីថ្លែងការណ៍រួមមួយរវាងថៃ និងកម្ពុជា ស្តីពីការគោរពព្រំដែនគ្នាទៅវិញទៅមក ហើយព្រះអង្គនឹងបញ្ជូន ប៉ែន នុត ជាទីប្រឹក្សាផ្ទាល់របស់ព្រះអង្គឱ្យទៅធ្វើជាតំណាងរបស់ប្រទេសកម្ពុជា នៅក្នុងពិធីចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍រួមនោះ និងរៀបចំឱ្យមានទំនាក់ទំនងការទូត ជាមួយប្រទេសថៃវិញ ក្នុងពេលឆាប់ៗខាងមុខនេះ។ មិនតែប៉ុណ្ណោះ ព្រះអង្គបានមានបន្ទូលថា រយៈពេល៨ថ្ងៃទៀតព្រះអង្គនឹងយាងទៅ បំពេញទស្សនកិច្ចជាមិត្តភាពមួយនៅប្រទេសថៃ និងចូលគាល់ព្រះមហាក្សត្រថៃ ភូមិពុល អាប់ឌុលយ៉ាដេត ផងដែរ។ ប្រហែលជាង២សប្តាហ៍ក្រោយមក រាជរដ្ឋាភិបាលក្រុងបាងកក ក៏បានបង្ហើបឱ្យដឹងពីការយល់ព្រមរបស់ខ្លួន តាមសំណើរបស់កម្ពុជាដែរ។ ប៉ុន្តែសម្តេចសីហនុ ក៏បានដាក់លក្ខខណ្ឌ

ថា មុនអ្វីៗកើតឡើងដូចខាងលើនេះ រាជរដ្ឋាភិបាលក្រុងបាងកក ត្រូវតែប្រកាសទទួលស្គាល់ខ្សែបន្ទាត់ព្រំដែនរបស់កម្ពុជាជា មុនសិន។ តែប្រទេសថៃ មិនព្រមប្រកាសទទួលស្គាល់ខ្សែបន្ទាត់ព្រំដែនរបស់កម្ពុជាជាមុន តាមលក្ខខណ្ឌនោះ ក៏ធ្វើឱ្យបញ្ហាស្តារទំនាក់ទំនងការទូតរវាងប្រទេសទាំង២នេះ នៅជាប់គាំងដដែល ។

នៅថ្ងៃទី២៣ ខែសីហា ឆ្នាំ១៩៦៩ ភរិយារបស់នាយករដ្ឋមន្ត្រី លន់ នល់ ឈ្មោះ បៃ នាងនាង ហៅ ខេង បានទទួលមរណភាពដោយរោគាពាធ ។

សពត្រូវបានតម្កល់ទុករយៈពេល១៥ថ្ងៃ នៅភូមិគ្រឹះ ដែលនៅតាម បណ្តោយផ្លូវទំនប់ទឹក ពីក្បាលថ្នល់ ទៅមន្ទីរពេទ្យរុស្ស៊ី ដើម្បីធ្វើបុណ្យតាមប្រពៃណី ។



**ពិធីដង្ហែសព ជំទាវបៃ នាងនាង**



សម្ដេចសីហនុ និងអ្នកម្នាងម៉ូនិក ចូលរួមក្នុងពិធីបុណ្យសពភរិយារបស់ លន់ នល់

ពេលនោះ សម្ដេចសីហនុ និងអ្នកម្នាងម៉ូនិក ជាព្រះជាយា ក៏បានទៅចូលរួមក្នុងពិធីបុណ្យនៅភូមិគ្រឹះនោះដែរ ។

នៅវេលាព្រឹកម៉ោង ៨ នាថ្ងៃអាទិត្យ ទី៧ ខែកញ្ញា ឆ្នាំ១៩៦៩ សពភរិយារបស់ លន់ នល់ ដែលគេតែងហៅថា ជំទាវខេង។ នោះ ត្រូវបានដង្ហែចេញពីភូមិគ្រឹះនៃសពទៅធ្វើពិធីបូជានៅវត្តលង្កាព្រះកុសុមារាម យ៉ាងអធិកអធមបំផុត ។

# ២៦២
# សម្ដេចសីហនុ ធ្វើបុណ្យឧទ្ទិសកុសលដល់សព ហូ ជីមិញ លន់ នល់ និងទ្រង់សិរិមតៈ មិនចូលរួម



សម្ដេចសីហនុ ឱនព្រះកាយគោរពរូបថតហូ ជីមិញ

ក្រោយពេលឧត្តមសេនីយ៍ឯកលន់ នល់ ឡើងជានាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការពារប្រទេស នៅក្នុងរាជរដ្ឋាភិបាលស្រោចស្រង់ជាតិមក គាត់បានធ្វើការស្ទាបស្ទង់ជាសម្ងាត់ចំពោះគោលជំហរសហរដ្ឋអាមេរិក ក្នុងបំណងកែលម្អទំនាក់ទំនងការទូតរវាងប្រទេសទាំង២ឱ្យបានល្អប្រសើរឡើងវិញ ។

ចំណែកសម្ដេចសីហនុ ក៏បានប្រគល់សិទ្ធិអំណាចគ្រប់យ៉ាងទៅឱ្យលន់ នល់ ដើម្បីពិនិត្យសើរើរឿងអ្វីៗដោយគ្មានការរារាំង ដូចដែលព្រះអង្គបានមានបន្ទូលនៅថ្ងៃប្រកាសសមាសភាពរាជរដ្ឋាភិបាលស្រោចស្រង់ជាតិ នាថ្ងៃទី១៤ ខែសីហា នោះដែរ។ ប៉ុន្តែទោះបីយ៉ាងណា ក៏អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិបានធ្វើការកត់សម្គាល់ថា នៅក្នុងឆ្នាំ១៩៦៩នោះ នយោបាយការបរទេសរបស់ព្រះអង្គ បានលិច

លង់ទៅក្នុងភាពច្របូកច្របល់ត្រឡប់ត្រឡិន មិនដឹងថាផាកទៅរកខាងណាឱ្យពិតប្រាកដ ព្រោះគេសង្កេតឃើញថា ព្រះអង្គចង់ស្តារទំនាក់ទំនងការទូតជាមួយ សហរដ្ឋអាមេរិក ឡើងវិញ តែព្រះអង្គនៅតែអនុញ្ញាតឱ្យកងទ័ពវៀតកុង-វៀតណាមខាងជើង បោះទីតាំងនៅលើទឹកដីកម្ពុជា ពិសេសព្រះអង្គបានប្រកាសទទួលស្គាល់ និងភ្ជាប់ទំនាក់ទំនងការទូត ជាមួយរដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្ន វៀតណាមខាងត្បូង ដែលពួកមេដឹកនាំកុម្មុយនិស្តវៀតណាម នៅក្រុងហាណូយ ទើបបង្កើតឡើងកាលពីថ្ងៃទី៨ ខែមិថុនា ឆ្នាំ១៩៦៩នោះ ផងដែរ ។

នៅថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៦៩ ហូ ជីមិញ មេដឹកនាំកំពូលវៀតណាមកុម្មុយនិស្តបានទទួលមរណភាពក្នុង វ័យ៧៩ឆ្នាំ ដោយសារជំងឺគាំងបេះដូងនៅទីក្រុងហាណូយ ។ ទោះបីសម្តេចសីហនុ ដឹងថា ហូ ជីមិញ មិនដែលប្រកាន់ឥរិយាបថត្រឹមត្រូវចំពោះព្រះរាជាណាចក្រកម្ពុជា របស់ព្រះអង្គក៏ដោយ ក៏ព្រះអង្គបានកោតសរសើរចំពោះទឹកចិត្តស្នេហាជាតិ និងភាពអង់អាចក្លាហានរបស់គាត់ក្នុងការតស៊ូប្រឆាំងពួកអាណានិគមនិយម និងពួកចក្រពត្តិនិយមដែរ ។

សម្តេចសីហនុ បានបញ្ជាក់ថា ព្រះអង្គ និងហូ ជីមិញ មិនដែលបានជួបគ្នាម្តងណាទាល់តែសោះ ។ ប៉ុន្តែ កន្លងមក ហូ ជីមិញ ធ្លាប់បានសរសេរសំបុត្រ និងផ្ញើសារទូរលេខមកថ្វាយព្រះអង្គជាញឹកញាប់ ដើម្បីសម្តែងនូវការដឹងគុណ របស់គាត់ចំពោះការផ្តល់ជំនួយផ្សេងៗ ពិសេសគឺការផ្តល់ទឹកដីកម្ពុជា ឱ្យកងទ័ពវៀតកុង-វៀតណាមខាងជើង បោះទីតាំង និងកោតសរសើរពីការដឹកនាំរបស់ព្រះអង្គ ជាបន្តបន្ទាប់។ តែទោះបីព្រះអង្គធ្លាប់បានដឹកនាំការប្រយុទ្ធបណ្តេញកងទ័ពវៀតមិញរបស់ហូ ជីមិញ កាលពីអំឡុងឆ្នាំ១៩៤៧ ដល់ឆ្នាំ១៩៥៤ ក្តី ក៏ព្រះអង្គនៅតែមានបំណងចង់ជួបផ្ទាល់ជាមួយមេដឹកនាំដ៏ល្បីល្បាញម្នាក់នេះដែរ ។

កាលពីថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៦៧ ហូ ជីមិញ បានផ្ញើសារលិខិតមួយថ្វាយចំពោះសម្តេចសីហនុ ជាព្រះប្រមុខរដ្ឋកម្ពុជា ដោយបានគូសបញ្ជាក់យ៉ាងច្បាស់ថា៖

«ការភ្ជាប់ទំនាក់ទំនងការទូតរវាងប្រទេសយើងទាំងពីរ គឺជានិមិត្តរូបដ៏ត្រចះត្រចង់នៃចំណងទាក់ទងមិត្តភាពយុទ្ធសាមគ្គីភាពដ៏ស្អិតរមួត ហើយនេះគឺជាព្រឹត្តិការណ៍ ប្រវត្តិសាស្ត្រមួយដ៏សំខាន់រវាងវៀតណាម និងកម្ពុជា ព្រមទាំងជាកត្តាដ៏សកម្មមួយក្នុងការរក្សាសន្តិភាពនៅឥណ្ឌូចិន ក៏ដូចជានៅអាស៊ីអាគ្នេយ៍ ទាំងមូលផងដែរ» ។

មួយថ្ងៃក្រោយមក គឺថ្ងៃទី២៤ ខែមិថុនា ឆ្នាំ១៩៦៧ រាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋ ប្រជាធិបតេយ្យវៀតណាម បានប្រកាសភ្ជាប់ទំនាក់ទំនងការទូតជាផ្លូវការ ។

ក្នុងឱកាសខួបអនុស្សាវរីយ៍លើកទី១៥ ថ្ងៃបុណ្យឯករាជ្យជាតិកម្ពុជា ( ថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៦៨) ហូ ជីមិញ បានផ្ញើសារលិខិតមួយ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ១៩៦៨ ផ្ញើថ្វាយសម្ដេចសីហនុ ដោយបានសង្កត់ធ្ងន់ថា៖ «នៅថ្ងៃនេះ ក៏ដូចទៅថ្ងៃអនាគតដែរ ប្រទេសយើងទាំងពីរ នឹងក្លាយជាមិត្តភក្តិដ៏ស្និទ្ធស្នាលជរាបរៀងទៅ...» ។

សម្ដេចសីហនុ បានបញ្ជាក់បន្តថា នៅក្នុងឆ្នាំ១៩៦៨ ព្រះអង្គមានបំណងចង់យាងទៅ បំពេញទស្សនកិច្ចជាផ្លូវការនៅសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម( វៀតណាមខាងជើង) ដើម្បីបានជួបហូ ជីមិញ ដែរ។ ប៉ុន្តែ ហូ ជីមិញ បានផ្ញើលិខិតមួយឆ្លើយតបមកវិញ ដោយបានថ្លែងនូវទឹកចិត្តរំភើបរីករាយជាទីបំផុត ចំពោះ បំណងប្រាថ្នារបស់ព្រះអង្គក្នុងការចង់យាងទៅបំពេញទស្សនកិច្ចជាផ្លូវការនៅសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម និងមានបំណងជួបគាត់ផ្ទាល់នោះ។ ប៉ុន្តែ ហូ ជីមិញ បានសរសេរអង្វរក្នុងលិខិតដដែលនោះថា សូមព្រះអង្គកុំប្រថុយ ប្រថានក្នុងការចង់យាងទៅបំពេញទស្សនកិច្ចនៅប្រទេសយើងខ្ញុំធ្វើអ្វី ព្រោះខ្លាចក្រែងមានគ្រោះថ្នាក់ ដោយសារតែការទម្លាក់គ្រាប់បែកដាយថាហេតុពីសំណាក់យន្តហោះអាមេរិក លើទីក្រុងហាណូយ ហើយគាត់ក៏បានសូមឱ្យព្រះអង្គពន្យារពេលនៃការយាងទៅបំពេញទស្សនកិច្ចនោះមួយរយៈទៀតសិន ដើម្បីឱ្យរដ្ឋាភិបាលក្រុងហាណូយ និងប្រជាជនវៀតណាមខាងជើងមានឱកាសក្នុងការរៀបចំពិធីទទួលបដិសណ្ឋារកិច្ចទទួលព្រះអង្គឱ្យបានអធិកអធម ស័ក្តិសម

នឹងព្រះកិត្តិនាមរបស់ព្រះអង្គ។ ប៉ុន្តែ នៅក្នុងខែកក្កដា ឆ្នាំ១៩៦៩ ទស្សនាវដ្តីឡឺ សង្គម (Le Sangkum) របស់សម្តេច សីហនុ បានចុះផ្សាយរូបតុ្កកមួយ បង្ហាញពីព្រះទ័យព្រះអង្គ ដែលមិនចង់ឱ្យកងទ័ពវៀតកុង-វៀតណាមខាងជើង ចូលមកបោះទីតាំងនៅក្នុងទឹកដីខ្មែរ ផងដែរ ។




រូបតុ្កកសម្តេច សីហនុ និងហូ ជីមិញ ក្នុងទស្សនាវដ្តីឡឺសង្គម ចេញផ្សាយខែកក្កដា ឆ្នាំ១៩៦៩

ក្រោយពីទទួលដំណឹងមរណភាពនេះភ្លាម សម្តេចសីហនុ បានរៀបចំធ្វើពិធីបុណ្យតាមប្រពៃណីព្រះពុទ្ធសាសនា នៅក្នុងប្រាសាទទេវាវិនិច្ឆ័យ ដើម្បីឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធរបស់ហូ ជីមិញ ដោយមានវត្តមានរបស់ឯកអគ្គរដ្ឋទូត នៃសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម និងឯកអគ្គរដ្ឋទូតនៃរដ្ឋាភិបាលបដិវត្តន៍បណ្ដោះអាសន្នវៀតណាមខាងត្បូង ប្រចាំនៅទីក្រុងភ្នំពេញ បានចូលរួមអង្គុយបត់ជើងសំពះ និងស្តាប់ព្រះធម៌ជាមួយមន្ត្រីខ្មែរនោះដែរ ។

ក្នុងឱកាសប្រារព្ធពិធីបុណ្យឧទ្ទិសកុសលដល់សព ហូ ជីមិញនោះ លន់ នល់ ជានាយករដ្ឋមន្ត្រី និងទ្រង់ស៊ីសុវត្ថិ សិរិមតៈ ជាឧបនាយករដ្ឋមន្ត្រី មិនបានមកចូលរួមទេ តែពួកគាត់បានចាត់ឱ្យទ្រង់នរោត្តម ភូរិស្សារ៉ា ជារាជវង្ស និងជារដ្ឋមន្ត្រីក្រសួងការបរទេស ជាតំណាងមកចូលរួម ហើយអ្វីដែលធ្វើឱ្យសម្តេចសីហនុ កាន់តែចម្ងៃកក្នុងព្រះទ័យថែមទៀតនោះគឺ ព្រះអង្គមិនឃើញរដ្ឋមន្ត្រីក្រសួងឃោសនាការ ចាត់បញ្ជូនអ្នកថតរូប និងអ្នកថតភាពយន្តឯកសារមកថត និងយកព័ត៌មានស្តីពីពិធីបុណ្យនេះទេ ។

ជាធម្មតា នៅពេលព្រះអង្គជាព្រះប្រមុខរដ្ឋរៀបចំធ្វើពិធីអ្វីមួយជាផ្លូវការ ក្រសួងឃោសនាការ ត្រូវតែចាត់បញ្ជូនមន្ត្រីរបស់ខ្លួនឱ្យមកថតរូប ថតភាពយន្តទុកជាឯកសារ និងចាក់បញ្ចាំងឱ្យប្រជារាស្ត្រទស្សនា ។

តែទោះបីយ៉ាងនេះក៏ដោយ ក៏ភ្លាមៗនោះព្រះអង្គបានចាត់ចែងឱ្យអ្នកផ្សេងទៀតមកថតយករូបភាពពីទិដ្ឋភាពខ្លះៗ នៃពិធីបុណ្យនោះ ហើយក្រោយពិធីបុណ្យឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធរបស់ហូ ជីមិញ ល្ងាចនោះមក ព្រះអង្គបានឱ្យ អៀវ ប៉ុណ្ណា-ការ ជាអ្នកជំនាញខាងថតភាពយន្ត និងត្រូវជាបងថ្លៃរបស់អ្នកម្នាងម៉ូនិក លាងហ្វីល ដែលទើបតែថតហើយថ្មីៗនោះ ដើម្បីផ្ញើទៅរដ្ឋាភិបាលក្រុងហាណូយ ឱ្យទាន់ពេលនៅព្រឹកស្អែក ។

# ២៦៣
# សម្តេចសីហនុ ទៅចូលរួមបុណ្យសពហូ ជីមិញ ទ្រង់សិរិមត: ចាត់ទុកថា ជាអំពើក្បត់ជាតិ




សពហូ ជីមិញ

*ព្រឹកថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ១៩៦៩ សម្តេចសីហនុ អមដំណើរដោយអ្នកម្នាងម៉ូនិក ជាមហេសី និងព្រះអង្គម្ចាស់ នរោត្តម កូរិស្សារ៉ា រដ្ឋមន្ត្រីក្រសួងការបរទេស ព្រមទាំងសហការីប៉ុន្មាននាក់ទៀត បានឡើងយន្តហោះម៉ាស៊ីន៤ របស់កងអាកាសចរណ៍ភូមិន្ទកម្ពុជា ធ្វើដំណើរឆ្ពោះទៅអាកាសយានដ្ឋាននៅជាយទីក្រុងហាណូយ ដើម្បីចូលរួមពិធីបុណ្យសពហូ ជីមិញ ដែលប្រារព្ធធ្វើនៅថ្ងៃទី០៩ ខែកញ្ញា ។*

ប៉ុន្តែ ពេលព្រះអង្គយាងទៅដល់អាកាសយានដ្ឋានពោធិ៍ចិនតុង ឧត្តមសេនីយ៍ឯក លន់ នល់ នាយករដ្ឋមន្ត្រី មិនបានទៅជូនព្រះរាជដំណើរព្រះអង្គទេ គឺមានតែទ្រង់ សិរិមតៈ ជាឧបនាយករដ្ឋមន្ត្រីប៉ុណ្ណោះ ហើយពិធីជូនព្រះរាជដំណើរនោះ ពុំមានការរៀបចំឱ្យមានកងកិត្តិយសត្រៃទ័ព បន្ទឹបទភ្លេង និងវន្ទាអាវុធថ្វាយព្រះអង្គដូចមុនៗឡើយ ។

ក្រោយពីមានព្រឹត្តិការណ៍រដ្ឋប្រហារ ថ្ងៃ១៨ ខែមីនា ឆ្នាំ ១៩៧០ សម្តេចសីហនុ បានបញ្ជាក់ថា មូលហេតុ ដែលទ្រង់សិរិមតៈ និងបក្ខពួកមិនឱ្យមានការរៀបចំពិធីជូនព្រះរាជដំណើររបស់ព្រះអង្គ ឱ្យបានអធិកអធមដូចមុនៗ នោះ មកពីពួកគេយល់ថា ការយាងទៅចូលរួមក្នុងពិធីបុណ្យសពហូ ជីមិញ របស់ព្រះអង្គនៅពេលនោះ គឺជាអំពើក្បត់ជាតិ...។

ពេលព្រះអង្គនិងសមាជិកគណៈប្រតិភូយាងនិងអញ្ជើញទៅដល់អាកាសយានដ្ឋាននៅជាយទីក្រុងហាណូយ រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម បានរៀបចំធ្វើបដិសណ្ឋារកិច្ចថ្វាយចំពោះព្រះអង្គយ៉ាងរាក់ទាក់ និងកក់ក្តៅបំផុត ។

បើទោះបីពេលនោះ ប្រជាជនវៀតណាមខាងជើងទាំងមូលកំពុងមានទុក្ខសោកដ៏ធំធេង ដោយសារការបាត់បង់មេដឹកនាំដ៏ខ្លាំងពូកែរបស់ខ្លួន ក៏ពិតមែន ក៏មានប្រជាជនវៀតណាម ដ៏ច្រើនកុះករ មករង់ចាំទទួលព្រះអង្គយ៉ាងអធិកអធម ឱ្យស័ក្តិសមជាព្រះប្រមុខរដ្ឋនៃប្រទេសកម្ពុជា ដែលបានជួយឧបត្ថម្ភគាំទ្រដល់ការតស៊ូរបស់ពួកគេ ក្នុងប្រឆាំងនឹងពួកចក្រពត្តិអាមេរិក និងរបបរដ្ឋការវៀតណាមខាងត្បូង អស់រយៈពេលជិត ១០ឆ្នាំមកហើយនោះ ។

សម្តេចសីហនុ មានការភ្ញាក់ផ្អើល និងសប្បាយព្រះទ័យយ៉ាងខ្លាំង ព្រោះមិននឹកស្មានថា ប្រទេសកុម្មុយនិស្តដ៏ក្រីក្រ និងកំពុងត្រូវភ្លើងសង្គ្រាមឆាបឆេះមួយនេះ រៀបចំពិធីទទួលស្វាគមន៍ព្រះអង្គមានភាពអធិកអធមយ៉ាងដូច្នេះសោះ ។

មេដឹកនាំសំខាន់នៃសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម ដែលបានមឈរ

រង់ចាំស្វាគមន៍ព្រះអង្គនៅមាត់ជណ្ដើរយន្តហោះ គឺ តុង ឌឹកថាំង ជាប្រធានាធិបតីស្ដីទី ដែលមានវ័យជាង៨០ ឆ្នាំទៅហើយនោះ មានគេឈរបាំងឆត្រឱ្យនៅកណ្ដាលថ្ងៃក្ដៅហែង ជាមួយមេដឹកនាំជាន់ខ្ពស់វៀតណាមផ្សេងៗ ទៀត លើកលែងតែ ឡេ យន់ អគ្គលេខាបក្សកុម្មុយនិស្តវៀតណាមម្នាក់ប៉ុណ្ណោះ ដែលមិនបានមកទទួលស្វាគមន៍ព្រះអង្គនៅអាកាសយានដ្ឋាននោះ។ ពេលចុះផុតពីជណ្ដើរយន្តហោះ តុង ឌឹកថាំង បានឱបរឹតព្រះអង្គយ៉ាងស្និទ្ធស្នាលបំផុត ។

ក្នុងពេលព្រះអង្គស្នាក់នៅទីក្រុងហាណូយ ផាំ វ៉ាន់ដុង ដែលកាន់តំណែងនាយករដ្ឋមន្ត្រីតាំងពីឆ្នាំ១៩៥៥ មកនោះ បានតាមអមព្រះរាជដំណើរ និងកំដរព្រះអង្គជាប់ជានិច្ច ហើយពេលជួបព្រះអង្គម្ដងៗ ផាំ វ៉ាន់ដុង តែងតែលើកដៃសំពះតាមរបៀបប្រពៃណីខ្មែរយ៉ាងស័ក្ដិសមឥតខ្ចោះ មុននឹងឱបរឹតព្រះអង្គពេញណែនក្នុងរង្វង់ដៃរបស់គាត់ ។

សម្ដេចសីហនុ បានវាយតម្លៃថា ផាំ វ៉ាន់ដុង ជាមេដឹកនាំដែលមានលក្ខណៈរួសរាយរាក់ទាក់ ស្រស់ស្រាយ និងមានប្រាជ្ញាឈ្លាសវៃ ហើយព្រះអង្គនឹកក្នុងព្រះទ័យថា ថ្ងៃណាមួយ គាត់នឹងក្លាយទៅជាកល្យាណមិត្តរបស់ព្រះអង្គ ដូចនាយករដ្ឋមន្ត្រីចិន ជូ អេនឡាយ និងមេដឹកនាំកូរ៉េខាងជើង គីម អ៊ីលស៊ុង ដែរ ជាមិនខាន ។ ប៉ុន្តែព្រះអង្គក៏ឈ្វេងយល់ថា ពេលនេះមេដឹកនាំវៀតណាមកុម្មុយនិស្ត កំពុងតែត្រូវការឱ្យព្រះអង្គជួយឧបត្ថម្ភគាំទ្រពួកគេ ក្នុងការធ្វើសង្គ្រាមនៅវៀតណាមខាងត្បូង ហើយម្យ៉ាងទៀត ពេលនោះ ព្រះអង្គគឺជាប្រមុខរដ្ឋតែម្នាក់គត់នៅលើពិភពលោកនេះ ដែលបានយាងទៅចូលរួមជាកិត្តិយសនៅក្នុងពិធីបុណ្យសពហូ ជីមិញ ផងដែរ ទើបពួកគេយកចិត្តទុកដាក់ក្នុងការផ្គាប់ផ្គុនព្រះអង្គយ៉ាងអស់ពីចិត្តពីថ្លើមដូច្នេះ ។

ពេលនោះ ទ្រឿង ជិញ ប្រធានសភាប្រជាជនវៀតណាម ក៏បានលើកសរសើរពីរូបសម្ផស្សរបស់អ្នកម្នាងម៉ូនិក ដោយចិត្តស្មោះសបំផុត។ ឧត្តមសេនីយ៍ វ៉ូ ង្វៀនយ៉ាប់ ជាមេទ័ពកំពូល និងជាវីរបុរសដែលបានដឹកនាំកងទ័ព វាយបំបាក់កងទ័ពបារាំង នៅ

សមរភូមិឡៀន បៀនភូ កាលពីឆ្នាំ១៩៥៤ ព្រមទាំងកិរិយាដ៏តូចប្រឡឹង និងមានប្រាជ្ញាវាងវៃរបស់គាត់ បានដាក់ខ្លួនជាអ្នកផ្គាប់ផ្គុនអ្នកម្នាងម៉ូនិក ដោយមិនគិតពីបុណ្យស័ក្តិឋានៈដ៏ខ្ពង់ខ្ពស់របស់ពួកគាត់ឡើយ ។

ពួកមេដឹកនាំវៀតណាម និងភរិយារបស់ពួកគេទាំងអស់ បាននាំគ្នាប្តូរវេនគ្នាមកនៅកំដរព្រះអង្គ និងមហេសីជាប់ជាប្រចាំ លើកលែងតែភរិយារបស់នាយករដ្ឋមន្ត្រី ផាំវ៉ាន់ដុង ដែលកំពុងមានជំងឺធ្ងន់ មិនអាចមកចូលរួមកំដរព្រះអង្គ និងមហេសី បាន ។

សម្តេចសីហនុ មានបន្ទូលប្រាប់មេដឹកនាំវៀតណាមកុម្មុយនិស្តថាៈ ខ្ញុំសព្វព្រះទ័យដឹកនាំគណៈប្រតិភូកម្ពុជា មកលំឱនកាយគោរពចំពោះសពមេដឹកនាំវៀតណាមដែលប្រកបដោយកិត្យានុភាព ដោយក្តីរំជួលចិត្តជាទីបំផុត។ ជាមួយនឹងការមកដល់រដ្ឋធានីនៃសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម ដ៏អស្ចារ្យនេះ ខ្ញុំសូមពាំនាំមកនូវការកោតសរសើរពីសំណាក់រាជរដ្ឋាភិបាល និងប្រជាពលរដ្ឋខ្មែរ ចំពោះវីរភាពតស៊ូប្រកបដោយជោគជ័យរបស់អស់លោកក្នុងការប្រឆាំងនឹងពួកចក្រពត្តិនិយម និងចំពោះការកសាងប្រទេសជាតិអស់លោកឡើងវិញ ដែលមុននេះ ត្រូវរងការបំផ្លិចបំផ្លាញដោយសារការទម្លាក់គ្រាប់បែកដ៏ច្រើនសន្ធឹកសន្ធាប់របស់ពួកចក្រពត្តិអាមេរិក ។

សម្តេចសីហនុ មានបន្ទូលបន្តទៀតថាៈ ខ្ញុំសូមប្រកាសជាថ្មីម្តងទៀតនូវការគាំទ្រដោយឥតលក្ខខណ្ឌចំពោះការតស៊ូដ៏យុត្តិធម៌ និងស្របច្បាប់របស់សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម និងរដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្នវៀតណាមខាងត្បូង ដើម្បីនាំមកនូវសន្តិភាពត្រលប់មកវិញ ហើយចាប់ពីពេលនេះរហូតទៅអនាគត ការគាំទ្រនេះនឹងបន្តទៅទៀត ដោយមិនឈប់ឈរឡើយ ។

នៅក្នុងពិធីបុណ្យសពហូ ជីមិញ នៅទីក្រុងហាណូយនោះ អ្នករៀបចំពិធីបានចែកប៉ានដៃពណ៌ក្រហម ( ព៌ណតំណាងលទ្ធិកុម្មុយនិស្ត) ឱ្យដល់គណៈប្រតិភូបរទេសទាំងអស់ដែលបានចូលរួម។ ដោយឡែកតែគណៈប្រតិភូកម្ពុជា មានពាក់ប៉ានដៃពណ៌ខ្មៅ និងពណ៌សនៅជាប់នឹងប៉ែកខាងលើដៃអាវគ្រប់ៗគ្នា រួចជាស្រេច ។

សម្តេចសីហនុ បានបដិសេធដោយពាក្យសម្តីទន់ភ្លន់ថា គណៈប្រតិភូកម្ពុជា មិនចាំបាច់ប្រើប៉ាន់ដៃពណ៌ក្រហមនេះទេ ហើយព្រះអង្គបានពន្យល់ពួកគេវិញថា ប៉ាន់ដៃពណ៌ខ្មៅ និងពណ៌សនេះ គឺជាពណ៌តំណាងឱ្យការកាន់មរណទុក្ខរបស់ប្រជាជាតិកម្ពុជា រួចទៅហើយ ។

គណៈប្រតិភូបណ្តាប្រទេសផ្សេងៗទៀតដែលចូលមកក្នុងពិធី ដោយមិនមានពាក់ប៉ាន់អ្វីនៅជាប់នឹងប៉ែកខាងលើដៃអាវនោះ ត្រូវបានអ្នករៀបពិធីបុណ្យសព ជូនប៉ាន់ដៃពណ៌ក្រហមនោះគ្រប់ៗគ្នា ។

នៅលើសៀវភៅក្រាំងមាសចារសាររំលែកទុក្ខ សម្តេចសីហនុ បានសរសេរថា ព្រះអង្គសូមសម្តែងនូវគារវកិច្ចដ៏រំភើបបំផុត ចំពោះលោកប្រធានហូ ជីមិញ ដែលជាអ្នកស្នេហាជាតិប្រឆាំងនឹងពួកអាណានិគមនិយម និងពួកចក្រពត្តិនិយម ដើម្បីជាផលប្រយោជន៍របស់ប្រជាជាតិជាប្រទេសតតិយលោកទាំងអស់ ។

នៅក្នុងពិធីគោរពវិញ្ញាណក្ខន្ធហូ ជីមិញ មេដឹកនាំវៀតណាម បានរៀបចំឱ្យសម្តេចសីហនុ ជាព្រះប្រមុខរដ្ឋនៃប្រទេសកម្ពុជា ឈរនៅខាងមុខកូស៊ីហ្គីន ប្រធានគណៈប្រតិភូសហភាពសូវៀត និងឆឺ យ៉ុងកឺន ប្រធានគណៈប្រធានរដ្ឋនៃសាធារណរដ្ឋប្រជាធិបតេយ្យកូរ៉េ ដែលជាមេដឹកនាំលំដាប់ទី២ របស់កូរ៉េខាងជើង បន្ទាប់ពីសេនាប្រមុខ គីម អ៊ីលស៊ុង ជាមេដឹកនាំលំដាប់ទី១ ។

ចំណែកនាយករដ្ឋមន្ត្រីចិន ជូ អេនឡាយ ដោយមិនចង់ជួបមុខមេដឹកនាំសូវៀតជាគូទំនាស់របស់ខ្លួននោះ បានធ្វើដំណើរមកក្រុងហាណូយ ដើម្បីគោរពសពហូ ជីមិញ តាំងពីប៉ុន្មានថ្ងៃមុនមកម្ល៉េះ រួចបានវិលត្រលប់ទៅប្រទេសចិន វិញភ្លាមៗ ។

ហ្វីដែល កាស្ត្រូ មេដឹកនាំប្រទេសគុយបា ក៏ទៅចូលរួមនៅក្នុងពិធីគោរពវិញ្ញាណក្ខន្ធហូ ជីមិញ នោះដែរ។ តែគាត់ស្លៀកពាក់ឯកសណ្ឋានជាយោធា ដោយមានក្រវាត់កាំភ្លើងខ្លីនៅនឹងចង្កេះទៀតផង។



ហ្វីដែល កាស្ត្រូ មេដឹកនាំប្រទេសគុយបា ក្នុងពិធីដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធហូ ជីមិញ

នៅពេល ឡេ យន់ អគ្គលេខាធិការបក្សពលករវៀតណាម ឡើងសូត្រវិយោគកថានៃការបែកគ្នាជារៀងរហូតរបស់ហូ ជីមិញ ដ៏គួរឱ្យស្រងេះស្រងោចបំផុតនោះ ភ្ញៀវបរទេសជាអ្នកចូលរួមទាំងអស់ បានឮសូរសំឡេងយំខ្សឹកខ្សួលរបស់នាយករដ្ឋមន្ត្រី ផាំ វ៉ាន់ដុង ដែលកំពុងឈរសម្រក់ទឹកភ្នែករហាម ហើយប្រជាជនវៀតណាមក្មេងចាស់ប្រុសស្រីរាប់សែននាក់ទៀត ក៏នាំគ្នាទួញយំលាន់រងំពេញកន្លែងប្រារព្ធពិធីទាំងមូល ។

សម្តេចសីហនុ បានដឹកនាំគណៈប្រតិភូចូលទៅសម្តែងគារវកិច្ចចំពោះសព ហូ ជីមិញ និងដាក់កម្រងផ្កាមួយយ៉ាងធំ ដោយមានទង់ជាតិកម្ពុជា នៅជាប់កម្រងផ្កានោះផងដែរ។

នៅតាមរោងភាពយន្តធំៗ ក្នុងទីក្រុងហាណូយនោះដែរ គេបានរៀបចំឱ្យមានការចាក់បញ្ចាំងភាពយន្តឯកសារខ្នាតខ្លី ស្តីពីសម្តេចសីហនុ រៀបចំធ្វើពិធីបុណ្យឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធរបស់ហូ ជីមិញ នៅក្នុងប្រាសាទទេវាវិនិច្ឆ័យមុនពេល

ព្រះអង្គចេញដំណើរមកទីក្រុងហាណូយ មួយថ្ងៃនោះដែរ ។

តាមរយៈខ្សែភាពយន្តឯកសារនេះ ទស្សនិកជននៅក្រុងហាណូយ បានឃើញផ្ទាំងរូបថតហូ ជីមិញ ដ៏ធំមួយតម្កល់នៅមុខព្រះរាជបល្ល័ង្កនៃព្រះមហាក្សត្រខ្មែរ និងឃើញសម្ដេចសីហនុ អុជទៀនធូប និងឱនសិរសាគោរពវិញ្ញាណក្ខន្ធសព ព្រមទាំងបានឃើញវត្តមានរបស់ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម និងឯកអគ្គរដ្ឋទូតនៃរដ្ឋាភិបាលបដិវត្តន៍បណ្ដោះអាសន្នវៀតណាមខាងត្បូង ( វៀតកុង) ប្រចាំនៅទីក្រុងភ្នំពេញ និងមន្ត្រីនៅក្នុងព្រះបរមរាជវាំង ស្លៀកពាក់តាមរបៀបប្រពៃណីខ្មែរជាច្រើនរូប អង្គុយបត់ជើងសំពះ ព្រះសង្ឃព្រះពុទ្ធសាសនាជាច្រើន កំពុងសូធ្យធម៌ឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធសព ផងដែរ ។

នៅពេលនោះ មេដឹកនាំបក្សកុម្មុយនិស្តវៀតណាម ក៏បានសន្យាថា ពួកគេនៅតែបន្តគោរពអព្យាក្រឹតភាព បូរណភាពទឹកដីកម្ពុជា និងស្ថាប័នផ្សេងៗរបស់ព្រះរាជាណាចក្រកម្ពុជា ដូចមុនដដែល ។

ប៉ុន្តែ ជាមួយគ្នានោះ ពួកគេបានស្នើសុំឱ្យព្រះអង្គមានការបន្ធូរបន្ថយខ្លះចំពោះការរារាំង និងបន្ទប់បង្អាក់ផ្លូវដឹកជញ្ជូនស្បៀងអាហារ អាវុធ គ្រាប់រំសេវ ដែលឆ្លងកាត់ទឹកដីប្រទេសកម្ពុជា យកទៅផ្គត់ផ្គង់កងទ័ពរបស់ពួកគេ ដែលកំពុងធ្វើសង្គ្រាមនៅវៀតណាមខាងត្បូង ផងដែរ។ តែសម្ដេចសីហនុ បានទម្លាក់ការទទួលខុសត្រូវនៅក្នុងការរារាំងការបិទផ្លូវដឹកជញ្ជូននេះ ទៅលើឧត្តមសេនីយ៍ឯកលន់ នល់ ជានាយករដ្ឋមន្ត្រី និងពួកនាយទាហានជាន់ខ្ពស់របស់ព្រះអង្គផ្សេងៗទៀតទៅវិញ ។

ទោះបីយ៉ាងណា ព្រះអង្គបានបញ្ជាក់ប្រាប់មេដឹកនាំកុម្មុយនិស្តវៀតណាមថា ព្រះអង្គនឹងបញ្ជាទៅនាយករដ្ឋមន្ត្រី លន់ នល់ ឱ្យបញ្ឈប់ការរារាំង និងបន្ទប់បង្អាក់ការដឹកជញ្ជូននោះតទៅទៀត ។

តែនេះគ្រាន់តែភាសាការទូតរបស់ព្រះអង្គជាមួយពួកមេដឹកនាំកុម្មុយនិស្តវៀតណាម តែប៉ុណ្ណោះ ព្រោះក្រោយពីយាងមកមាតុប្រទេសវិញ ព្រះអង្គមិនបានបញ្ជា

ទៅនាយករដ្ឋមន្ត្រីលន់ នល់ ឱ្យឈប់រាំងការដឹកជញ្ជូនស្បៀងអាហារ អាវុធ គ្រាប់រំសេវ របស់ពួកវៀតកុង-វៀតណាមខាងជើង ឆ្លងកាត់ទឹកដីប្រទេសកម្ពុជា នោះឡើយ ។

ចំណែករដ្ឋាភិបាលបារាំងវិញ បានចាត់ឱ្យនាយឧត្តមសេនីយ៍ ហ្សង់ សាំតឺនី ( Jean Sainteny ) ដែលរដ្ឋាភិបាលបារាំង ធ្លាប់បញ្ជូនឱ្យមកចរចាជាមួយហូ ជីមិញ នៅក្នុងឆ្នាំ១៩៤៦ ដោយគ្មានបានលទ្ធផលអ្វីនោះ ធ្វើជាតំណាងរដ្ឋាភិបាលបារាំងមកចូលរួមក្នុងពិធីបុណ្យសពហូ ជីមិញ ដែរ ។

ក្រោយពេលពិធីបុណ្យសពត្រូវបានបញ្ចប់ ស្អែកឡើង សម្តេចសីហនុ បានយាងនិវត្តន៍ត្រលប់មកមាតុប្រទេសវិញ ដោយមានប្រធានាធិបតីស្តីទីតុង ឌឹកថាំងនិងមន្ត្រីជាន់ខ្ពស់វៀតណាម ជាច្រើនរូបទៀត ជូនដំណើរយ៉ាងអធិកអធម នៅអាកាសយានដ្ឋាន ដូចកាលពេលព្រះអង្គយាងទៅដល់ដែរ ។

នៅពេលនោះ ព្រះអង្គក៏បានអញ្ជើញនាយឧត្តមសេនីយ៍ ហ្សង់ សាំងតឺនី ( Jean Sainteny ) តំណាងប្រទេសបារាំង ឱ្យមកបំពេញទស្សនកិច្ចនៅកម្ពុជា ដោយធ្វើដំណើរតាមយន្តហោះអាកាសចរណ៍ភូមិន្ទកម្ពុជា ជាមួយព្រះអង្គ ផងដែរ។

ពេលស្នាក់នៅទីក្រុងហាណូយ នោះដែរ ពួកមេដឹកនាំវៀតណាមកុម្មុយនិស្ត បានដាក់ថ្វាយនូវពង្រាងកិច្ចព្រមព្រៀងពាណិជ្ជកម្មមួយ ដែលធ្លាប់បានពិភាក្សាគ្នាម្តងរួចមកហើយ កាលពេល ហ៊្វីញ តឹនផាត ( Huỳnh Tấn Phát ) នាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្នវៀតណាមខាងត្បូង ទៅបំពេញទស្សនកិច្ចនៅកម្ពុជា កាលពី ខែមុន តែព្រះអង្គមិនទាន់បានសម្រេចព្រះទ័យយ៉ាងណានៅឡើយ ។

សម្តេចសីហនុ បានរម្លឹកថា ក្នុងអំឡុងពេលឧត្តមសេនីយ៍ហ្សង់ ដឺគូ ( Jean Decoux ) មកធ្វើជាអគ្គទេសាភិបាលនៅឥណ្ឌូចិន កាលពីពាក់កណ្តាលទសវត្សរ៍ឆ្នាំ ១៩៤០ សម្តេចសីហនុ ក៏បានយាងទៅបំពេញទស្សនកិច្ចនៅទីក្រុងហាណូយ នេះម្តងរួចមកហើយ ប៉ុន្តែពេលព្រះអង្គយាងទៅចូលរួមបុណ្យសពហូ ជីមិញ នៅខែកញ្ញា ឆ្នាំ ១៩៦៩ នោះ ព្រះអង្គបានកត់សម្គាល់ថា រដ្ឋធានីមួយនេះ មានការរីកចម្រើនតែបន្តិច

បន្តួចនៅតាមសង្កាត់ពីរបីប៉ុណ្ណោះ ចំណែកសង្កាត់ផ្សេងៗទៀត មានមនុស្សរស់នៅណែន ណាន់តាន់តាប់ និងមានសភាពកខ្វក់ខ្លាំងណាស់ ។

ព្រះអង្គបានធ្វើការប្រៀបធៀបថា កាលពីសម័យអាណានិគមបារាំង នៅពេលដែលហាណូយ ក្លាយជារដ្ឋធានីមួយ ដ៏គួរឱ្យកោតសរសើរបំផុតនោះ រាជធានីភ្នំពេញគ្រាន់តែជាទីប្រជុំជនតូចមួយប៉ុណ្ណោះ។ ប៉ុន្តែ មកដល់ឆ្នាំ១៩៦៩ នោះ ទីក្រុងភ្នំពេញបានឈានដល់ចំណុចកំពូលរបស់ខ្លួន ដែលសូម្បីអ្នកកាសែតបរទេសដែលប្រឆាំងនឹងគោលជំហរអព្យាក្រឹតរបស់ព្រះអង្គ ក៏បានសរសេរសរសើរថា ភ្នំពេញ ជារាជធានីដ៏ទំនើប និងស្រស់បំព្រងមួយ...។

ក្រោយយាងត្រលប់មកពីក្រុងហាណូយ វិញ បាន២សប្តាហ៍ តាមព្រះរាជបញ្ជារបស់សម្តេចសីហនុ នៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ ១៩៦៩ ព្រំ ថុស រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មនោះ ជាមួយង្វៀន វ៉ាន់ហៀវ ឯកអគ្គរដ្ឋទូតនៃរដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្នវៀតណាមខាងត្បូង ដោយភាគីកម្ពុជា អនុញ្ញាតឱ្យផលិតផលផ្សេងៗរបស់វៀតណាម នាំចូលមកក្នុងប្រទេសរបស់ខ្លួនបាន ហើយកម្ពុជា ត្រូវនាំផលិតផលជាស្បៀងអាហារ និងផលិតផលចាំបាច់ផ្សេងៗទៀត ទៅផ្គត់ផ្គង់ឱ្យកងទ័ពវៀតកុងដែលបោះទីតាំងនៅលើទឹកដីកម្ពុជា និងនៅលើទឹកដីវៀតណាមខាងត្បូង ផងដែរ ។

នៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៦៩ កម្លាំងសមត្ថកិច្ចសន្តិសុខជាតិស្រាវជ្រាវ និងចាប់បានគ្រាប់បែកដៃចំនួន៤៦០០០គ្រាប់ និងរបាំងបិទមុខការពារឧស្ម័នពុលចំនួន១២០០ទៀត ដែលគេត្រៀមប្រគល់ឱ្យពួកខ្មែរក្រហម។ ពេលនោះ ជនជាតិចិន២នាក់ពាក់ព័ន្ធរឿងនេះ ក៏ត្រូវចាប់ខ្លួនដែរ ហើយក្នុងចំណោមជនជាតិចិន២នាក់នេះ មានម្នាក់ត្រូវបានគេស្គាល់ថា ជាភ្នាក់ងារសម្ងាត់របស់ពួកកុម្មុយនិស្ត ដែលមានទំនាក់ទំនងជាមួយនឹងស្ថានទូតចិន នៅទីក្រុងភ្នំពេញ ។

នៅក្នុងសន្និសីទកាសែតមួយ សម្តេចសីហនុ បានដាក់បង្ហាញរូបថត និងគ្រាប់

បែកដៃចំនួន ៤៦០០០ គ្រាប់នោះ ព្រមទាំងមានបន្ទូលថា៖ គ្រាប់បែកដៃទាំងនោះ គឺគេទុកសម្រាប់ឱ្យពួកខ្មែរក្រហម ធ្វើសកម្មភាពភេរវកម្មនៅក្នុងទីក្រុងភ្នំពេញ និងតាមបណ្ដាខេត្តផ្សេងៗ ទៀតនៅរដូវប្រាំងខាងមុខ ។

នៅក្នុងការចេញផ្សាយរបស់ទស្សនាវដ្តីឡឺសង្គម ប្រចាំខែធ្នូ ឆ្នាំ១៩៦៩ សម្ដេចសីហនុ បានសរសេរថា៖ វត្តមានរបស់កងទ័ពសហរដ្ឋអាមេរិកនៅក្នុងតំបន់របស់យើង (ឥណ្ឌូចិន) យ៉ាងហោចណាស់ ក៏អាចធ្វើឱ្យពួកកុម្មុយនិស្តនៅអឺរ៉ុប និងនៅអាស៊ីមានការគោរពយើងខ្លះៗដែរ ។

សម្ដេចសីហនុ បានសរសេរបន្តថា៖ វត្តមានកងទ័ពអាមេរិកនេះ ជាគ្រោះថ្នាក់អាក្រក់មួយចំពោះពួកអ្នកប្រឆាំងនឹងពួកចក្រពត្តិនិយម ក៏ពិតមែន តែវាមានសារៈសំខាន់ក្នុងទំនាក់ទំនងជាមិត្តភាព និងការផ្ដល់ជំនួយផ្សេងៗ ពីបណ្ដា ប្រទេសសង្គមនិយមជាមិត្តរបស់យើងផងដែរ ។

តែនៅពេលកងទ័ពអាមេរិក ត្រូវដកចេញពីតំបន់នេះ វាប្រាកដណាស់ ដែលថារបបសង្គមរាស្ត្រនិយមនៃប្រទេសកម្ពុជា នឹងក្លាយជាគោលដៅធំរបស់ពួកកុម្មុយនិស្តធ្វើសកម្មភាពអមិត្ត, ការធ្វើវិទ្ធង្សនា, ការរំលោភបំពាន, ការជ្រៀតចូល និងការកាន់កាប់ត្រួតត្រាប្រទេសកម្ពុជា ជាមិនខាន ។

តែព្រះអង្គមិនជឿថា អាមេរិក នឹងបោះបង់ចោលប្រទេសដែលមិនមែនកុម្មុយនិស្តនៅអាស៊ីអាគ្នេយ៍ ឬនៅឥណ្ឌូចិន នោះទេ ។

សម្ដេចសីហនុ បានសរសេរបញ្ជាក់ថា៖ វាប្រាកដហើយដែលថានយោបាយថ្មីរបស់ប្រធានាធិបតីនិចសុន មិនឱ្យធ្វើអន្តរាគមន៍ ឬមិនរក្សាទុកកងទ័ពអាមេរិក នៅតាមបណ្ដាប្រទេសនានានៅក្នុងនៅអាស៊ីអាគ្នេយ៍ ឬនៅឥណ្ឌូចិន ក៏ពិតមែន ប៉ុន្តែ ព្រះអង្គនៅតែមិនជឿថា អាមរិក មានបំណងដោះដៃចេញពីតំបន់នេះ ក្រោមហេតុផលផ្សេងៗទៀតបានឡើយ ។

# ២៦៤
# ទ្រង់សិរិមតៈ ចង់កាច់បំបាក់អំណាចសម្តេចសីហនុ



ព្រះអង្គម្ចាស់ស៊ីសុវត្ថិ សិរិមតៈ

នៅក្នុងពិធីប្រកាសតែងតាំងជានាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលស្រោចស្រង់ជាតិ នាថ្ងៃទី១៤ខែសីហា ឧត្តមសេនីយ៍ឯកលន់ នល់ បានឡើងអានកម្មវិធីនយោបាយស្តីពីការធ្វើឱ្យប្រសើរលើសដើមលើវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរបស់ប្រទេសជាតិ។ ចំណែកសម្តេចសីហនុក៏បានសន្យាថា ព្រះអង្គក៏មិនធ្វើការជ្រៀតជ្រែកក្នុងកិច្ចការរាជរដ្ឋាភិបាល ដែលរៀបចំធ្វើឱ្យប្រសើរឡើងវិញផ្នែករដ្ឋបាល សេដ្ឋកិច្ច ហិរញ្ញវត្ថុ ដែលព្រះអង្គបានឯកភាពយល់ព្រម ជាគោលការណ៍រួចមកហើយដែរ ប៉ុន្តែ ទោះបីជាយ៉ាងនេះក៏ដោយ ក៏មានមជ្ឈដ្ឋានខ្លះបានរិះគន់ថា ក្រៅពីព្រះអង្គ ពុំមានមន្ត្រីជាន់ខ្ពស់ណាម្នាក់មានសិទ្ធិសម្រេចកិច្ចការអ្វីមួយបានឡើយ បើទោះបីកិច្ចការនោះមិនសូវសំខាន់ប៉ុន្មាន ក៏ដោយ បើគ្មានការយល់ព្រមពីព្រះអង្គជាមុនសិនទេ ពុំអាចសម្រេចបានឡើយ គឺតាំងពីយូរឆ្នាំមកហើយ រដ្ឋមន្ត្រី និងអភិបាលខេត្តនានា មុននឹងសម្រេចធ្វើការងារសំខាន់ៗ ត្រូវតែដាក់ថ្វាយនូវសំណុំឯកសារការងារនោះ ដើម្បីស្នើសុំព្រះរាជតម្រិះដ៏ខ្ពង់ខ្ពស់របស់ព្រះអង្គជាមុនសិន ។

ពួកឥស្សរជនដែលមានគំនិតប្រឆាំងនឹងសម្តេចសីហនុ បានធ្វើការរិះគន់ថា ទោះយ៉ាងណា ក៏ព្រះអង្គគ្មានពេលវេលាគ្រប់គ្រាន់ក្នុងការពិនិត្យសំណុំរឿងទាំងអស់នោះដែរ ព្រោះព្រះអង្គបានចំណាយពេលវេលាមួយភាគធំក្នុងការពិនិត្យអត្ថបទសំខាន់ៗក្នុង

ទស្សនាវដ្ដីទាំង៤របស់ព្រះអង្គ និងថតខ្សែភាពយន្ត ផងដែរ។ ដូច្នេះ ព្រះអង្គគ្មានពេលវេលាគ្រប់គ្រាន់ដើម្បីពិនិត្យសំណុំឯកសារផ្សេងៗរបស់រដ្ឋមន្ត្រី និងពួកអភិបាលខេត្តទាំងអស់នោះទេ ។

មុនពេលបង្កើតរាជរដ្ឋាភិបាលស្រោចស្រង់ជាតិ ប្រធានអគ្គនាយកដ្ឋាន(PDG) នៃសហគ្រាសរដ្ឋ ដែលភាគច្រើនរកស៊ីខាត អស់ទាំងថវិការដ្ឋ បានបង្អើបឱ្យដឹងថា ខុទ្ទកាល័យព្រះប្រមុខរដ្ឋបានកំណត់ឱ្យបញ្ជូនប្រាក់កាសដ៏ច្រើនសន្ធឹកសន្ធាប់ទៅថ្វាយសម្ដេចសីហនុ ជាទៀងទាត់ ដោយមិនចាំបាច់ឆ្លងតាមរយៈក្រុមប្រឹក្សាភិបាលរបស់សហគ្រាសទាំងនោះ ។

ប្រាក់កាសដែលបញ្ជូនទៅថ្វាយសម្ដេចសីហនុ ទាំងប៉ុន្មាននោះ ត្រូវដាក់បញ្ចូលទៅជាកញ្ចប់ថវិកាសម្រាប់ការងារ ស្ថាបនាជាតិ និងសម្រាប់ការងារចលនាសង្គមរាស្ត្រនិយម ដែលព្រះអង្គបានបង្កើតឡើងតាំងឆ្នាំ១៩៥៥ ដើម្បីយកទៅកសាងសាលារៀន, គិលានដ្ឋាន, វត្តអារាម, ផ្លូវថ្នល់, ស្ពានជាដើម ទៅតាមព្រះទ័យព្រះអង្គ។ តែថវិកាមួយចំណែកទៀត ក៏ត្រូវចំណាយជាប្រាក់រង្វាន់លើកទឹកចិត្តដល់អភិបាលខេត្តនានា, កីឡាករ,សិស្សនិស្សិត, ប៉ូលិស, ទាហានណាដែលមានស្នាដៃល្អផងដែរ ។

តែក្រោយពីបង្កើតរាជរដ្ឋាភិបាលស្រោចស្រង់ជាតិមក ព្រះអង្គម្ចាស់ស៊ីសុវត្ថិ សិរិមតៈ ជាឧបនាយករដ្ឋមន្ត្រីទី១ បានប្រកាសហាមប្រាមទីស្ដីការក្រសួងទាំងអស់ និងស្ថាប័នផ្សេងៗទៀត មិនឱ្យបញ្ជូនឯកសារការងារនានា ទៅខុទ្ទកាល័យព្រះប្រមុខរដ្ឋ (សម្ដេចសីហនុ) ដោយផ្ទាល់ដូចមុនៗ ទៀតទេ គឺទីស្ដីការក្រសួងទាំងអស់ ត្រូវផ្ញើសំណុំឯកសារការងារផ្សេងៗមកឱ្យទីស្ដីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងសម្រេចវិញ ហើយបើក្រសួងណាមួយមិនអនុវត្តតាមការហាមប្រាមនេះទេ នឹងត្រូវដាក់ទណ្ឌកម្ម ។

សម្ដេចសីហនុ ចាត់ទុកទង្វើរបស់ទ្រង់សិរិមតៈ ដូចខាងលើនេះ ថា ជាការបំបាក់ព្រះកិត្តិយសព្រះអង្គធ្ងន់ធ្ងរណាស់។ ព្រះអង្គឈ្វេងយល់ថា ទ្រង់សិរិមតៈ មានចេតនាចង់កម្រិតព្រំដែនអំណាចរបស់ព្រះអង្គ ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ ទៀតផង។

ទោះបីយ៉ាងណា ក៏ដោយ ក៏នៅក្នុងរាជរដ្ឋាភិបាលស្រោចស្រង់ជាតិនោះ វរសេនីយ៍ឯកអ៊ុំ ម៉ាន់នូរិន រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលបន្ទុកក្រសួងការពារលើផ្ទៃប្រទេស ដែលជាបងថ្លៃរបស់ព្រះអង្គ និងវរសេនីយ៍ឯកសុស្តែន ហ្វែរណង់ដេស រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលបន្ទុកក្រសួងសន្តិសុខជាតិ ក៏ស្ថិតនៅក្រោមបញ្ជាផ្ទាល់របស់ព្រះអង្គ ហើយមធ្យោបាយទទួលព័ត៌មាន និងការឃោសនាផ្សេងៗគ្រប់យ៉ាង ក៏ស្ថិតនៅក្រោមការត្រួតត្រារបស់ព្រះអង្គដែរ ។

ជាមួយគ្នានោះ សម្តេចសីហនុ បានរៀបចំឱ្យមានការហ្វឹកហាត់ក្បួនយុទ្ធសាស្ត្រ ដែលហៅថា វិជ្ជាយោធាប្រតិព័ទ្ធដល់ពួកយុវជនយុវនារីជាសមាជិកសមាជិកាចលនាសង្គមរាស្ត្រនិយម( យុវ័ន )ដែលជាសិស្សនិស្សិតនៅតាមវិទ្យាល័យ និងមហាវិទ្យាល័យនានានៅទូទាំងប្រទេស ដើម្បីបង្ការទុកពេលប្រទេសជាតិមានសង្គ្រាមផងដែរ ។

ប្រភពព័ត៌មានមួយទៀត បានបង្ហើបឱ្យដឹងថា ក្រោយពីបានឡើងធ្វើជានាយរដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលស្រោចស្រង់ជាតិ មិនបានមួយខែផង ឧត្តមសេនីយ៍ឯកលន់នល់ បានលួចបញ្ជូនសហការីជំនិតរបស់គាត់ ឱ្យទៅទាក់ទងជាមួយសឺង ង៉ុកថាញ់ មេដឹកនាំចលនាតស៊ូខ្មែរសេរី នៅក្នុងប្រទេសវៀតណាមខាងត្បូង ។

មេដឹកនាំចលនាតស៊ូខ្មែរសេរី សឺង ង៉ុកថាញ់ ក៏ចង់ផ្តួលរម្លំសម្តេចសីហនុ ដូចមេដឹកនាំចលនាតស៊ូខ្មែរក្រហមដែរ តែសឺង ង៉ុកថាញ់ មានមហាអំណាចអាមេរិកជាខ្នងបង្អែក ។

ចំណែក មេដឹកនាំចលនាតស៊ូខ្មែរក្រហមមាន មហាអំណាចកុម្មុយនិស្ត ពិសេសគឺ មហាអំណាចចិន ជាខ្នងបង្អែក។ ពេលនោះ សឺង ង៉ុកថាញ់ បានយល់ព្រមសហការជាមួយឧត្តមសេនីយ៍លន់ នល់ ។

ឥស្សរជនដែលជិតស្និទ្ធនឹងព្រះអង្គមួយចំនួនតូច បានថ្វាយយោបល់ពីគ្រោះថ្នាក់ជាយថាហេតុ ដែលបង្កឡើងដោយពួកស្តាំនិយម ( នល់ លន់ )ដែលព្រះអង្គបានលើកឱ្យកាន់អំណាចនោះដែរ តែព្រះអង្គមិនមានប្រតិកម្មអ្វី ពីរឿងនេះទេ ។

ផ្ទុយទៅវិញ ព្រះអង្គមានបន្ទូលថា៖ ឧត្តមសេនីយ៍ឯកលន់ នល់ គឺជាដៃស្តាំរបស់ព្រះអង្គ ហើយថា បើមានហេតុការណ៍អាក្រក់ណាមួយកើតឡើងនោះ ឧត្តមសេនីយ៍រូបនេះ នឹងកម្ចាត់គូសត្រូវរបស់ព្រះអង្គ ដូចដែលគាត់ធ្លាប់បង្ក្រាបអំពើក្បត់របស់ដាប ឈួន នៅខេត្តសៀមរាប កាលពីខែកុម្ភៈ ឆ្នាំ១៩៥៩ កន្លងមកនោះ ជាមិនខាន។

# ២៦៥
# សម្តេចព្រះសង្ឃរាជជួន ណាត សោយទិវង្គត




នៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៦៩ សម្តេចព្រះមហាសុមេធាធិបតីជួន ណាត( ជោតញ្ញាណោ) សម្តេចព្រះសង្ឃរាជថ្នាក់ទី១ នៃគណៈមហានិកាយ សោយទិវង្គតគួរឱ្យសោកស្តាយបំផុត ។

ចាប់ពីថ្ងៃទី១០ ខែកញ្ញា មក សម្តេចព្រះសង្ឃរាជចាប់មានអាពាធ ប៉ុន្តែមិនមានអាការៈធ្ងន់ប៉ុន្មានទេ។ លុះមកដល់វេលាម៉ោង១៥ និង៤៥នាទីរសៀល ថ្ងៃទី២៣ ខែកញ្ញា ពេលព្រះសង្ឃដែលធ្លាប់ចូលគាល់បម្រើព្រះអង្គកំពុងនាំគ្នានៅក្រោបន្ទប់សម្តេច ស្រាប់តែឮសូរកណ្តឹងរោទ៍ប្លែកពីធម្មតា ក៏នាំគ្នាស្ទុះចូលទៅមើល ពេលនោះសម្តេចមានព្រះឱង្ការថា៖ "អាត្មាចុកទ្រូងណាស់!" ។

ភ្លាមៗនោះ ព្រះអង្គដែលនៅកំដរ ក៏ជំនុំពិគ្រោះគ្នាឱ្យព្រះសិរីវិសុទ្ធ មី យ៉ាំ ទូរស័ព្ទ

ទៅវេជ្ជ បណ្ឌិតហោ ប៉េងថុង និងទៅក្រសួងធម្មការ។ មិនយូរប៉ុន្មាន គ្រូពេទ្យជាច្រើននាក់ក្នុងនោះ មានវេជ្ជបណ្ឌិតហោ ប៉េងថុង, មី សាម៉ីឌី, យូ គឹមយាន, ព្រំ ភួន, រស់ សារី និងវេជ្ជបណ្ឌិតម៉ា ហ្វូ ជនជាតិបារាំង ក៏បានមកដល់ជាបន្ទាន់ និងនាំគ្នាពិនិត្យឃើញថា អាការរោគរបស់សម្ដេចមិនជាធ្ងន់ប៉ុន្មានទេ ។

ប៉ុន្តែទោះបីជាយ៉ាងណា ក្រសួងសុខាភិបាលក៏បានចាត់វេជ្ជបណ្ឌិតយូ គឹមយាន និងវេជ្ជបណ្ឌិតលី គឹមសាន ឱ្យមកនៅថែរក្សាព្យាបាលព្រះរោគជាប់ជាប្រចាំរហូតដល់ថ្ងៃព្រហស្បតិ៍ ទី២៥ កញ្ញា ឆ្នាំ១៩៦៩ វេលាម៉ោង២០និង២០នាទី ស្រាប់តែសម្ដេចទ្រង់សោយទិវង្គត ក្នុងព្រះជន្ម៨៦ព្រះវស្សា នៅលើព្រះទែនសយនា (គ្រែដែលព្រះអង្គសឹង) នាល្វែងធំក្នុងមហាកុដិរបស់សម្ដេចនៅវត្តឧណ្ណាលោម ដោយស្ងប់ស្ងៀមគ្មានពុស្រែកថ្ងូរ ឬកម្រើកព្រះកាយបន្តិចទាល់តែសោះ ។

បន្ទាប់ពីបានដំណឹងនៃការសោយព្រះទិវង្គត របស់សម្ដេចព្រះសង្ឃរាជភ្លាមក្នុងរាត្រីនោះ សម្ដេចសីហនុ ព្រះប្រមុខរដ្ឋ បានស្ដេចយាងមកកាន់មហាកុដិ វត្តឧណ្ណាលោម ដើម្បីក្រាបថ្វាយបង្គំព្រះបរមសព ។

ដំណាលគ្នានេះ សម្ដេចព្រះមហាក្សត្រិយានី កុសុមៈ ក៏ទ្រង់ចាត់អ្នកអង្គម្ចាស់នាយកក្រសួងនានា ក្នុងព្រះបរម រាជវាំង ជាព្រះរាជតំណាងមកថ្វាយបង្គំព្រះបរមសពដែរ ។

បន្ទាប់មក ឧត្តមសេនីយ៍ឯកលន់ នល់ នាយករដ្ឋមន្ត្រី, អង្គម្ចាស់ស៊ីសុវត្ថិ សិរិមតៈ ឧបនាយករដ្ឋមន្ត្រីទី១ ព្រមទាំងសមាជិកគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី, ឧកញ៉ាមហាមន្ត្រីកែមាស ចាងហ្វាងពិធីការព្រះបរមរាជវាំង និងមន្ត្រីនានាក្នុងព្រះបរមរាជវាំង, ឧត្តមសេនីយ៍ង៉ោ ហ៊ូ ទីប្រឹក្សាសម្ដេចព្រះប្រមុខរដ្ឋ, ឌី ទូច រដ្ឋលេខាធិការក្រសួងធម្មការ, អ៊ី ទុយ អភិបាលក្រុងភ្នំពេញ, ទឹម ដុង ប្រតិភូរាជរដ្ឋាភិបាលប្រចាំខេត្តកណ្ដាល ។

លាង ហាប់អាន នាយកវិទ្យាស្ថាន ពុទ្ធសាសនបណ្ឌិត្យក្រុមអភិបាលពុទ្ធិកសមាគមទាំងបី និងមន្ត្រីរាជការទាហានប៉ូលិសជាន់ខ្ពស់ទាំងអស់ សុទ្ធតែមានមុខស្រពោនក្រៀម

ក្រាំគ្រប់ៗគ្នា បានចូលមកលំឱនកាយគោរពសម្តែងមរណទុក្ខ សោកស្តាយ ក្រៀមក្រំ រំជួលចិត្តចំពោះព្រះបរមសពគ្រប់ៗគ្នា ។

បន្ទាប់មកព្រះពុទ្ធឃោសាចារ្យ ពាជ កឹង មេគណក្រុងភ្នំពេញ និងព្រះមុនីកោសល្យ សួរ ហាយ ចៅអធិការវត្តនិរោធរង្សី ព្រមទាំងព្រះរាជាគណៈ និងឋានានុក្រមជាច្រើនរយអង្គទៀត បាននិមន្តមកកកកុញ សុទ្ធតែមានទឹកមុខក្រៀមក្រំ ស្រងូត ស្រងាត់គ្រប់ៗអង្គ ។

ក្នុងពេលរាត្រីនោះ រហូតដល់ម៉ោង២២-២៣ ក៏នៅតែមានព្រះសង្ឃ និងពុទ្ធបរិស័ទនិមន្ត និងអញ្ជើញមកត្រៀបត្រា ពាសពេញបរិវេណវត្ត នាំគ្នាចូលក្រាបថ្វាយបង្គំព្រះបរមសពយ៉ាងកកកុញ ណែនណាន់តាន់តាប់ ។

ព្រះបរមសព នៃសម្តេចព្រះសង្ឃរាជជួន ណាត ត្រូវតម្កល់ក្នុងព្រះមហាមេរុ នៅកណ្តាលទីលានវាលព្រះមេរុ ខាងជើងព្រះបរមរាជវាំង ដើម្បីធ្វើទក្ខិណានុប្បទានជារៀងរាល់ថ្ងៃ រយៈពេលដល់ទៅ៦ខែ ដើម្បីជាការតបស្នងព្រះគុណូបការៈ ដ៏ឧត្តុង្គឧត្តមថ្លៃថ្លារបស់សម្តេច ។

សម្តេចព្រះសង្ឃរាជ ជួន ណាត ប្រសូតនៅ ថ្ងៃទី១១ ខែមីនា គ.ស ១៨៨៣ នៅភូមិកំរៀង ឃុំកាកោះ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។ មានមាតាឈ្មោះ យក់ បិតាឈ្មោះ ព្រហ្ម ជួន មុខរបរជាកសិករ។ ព្រះអង្គមានបងប្អូនបង្កើតពីរនាក់ គឺរូបព្រះអង្គ និងប្អូនប្រុសម្នាក់ឈ្មោះជួន នុត មានងារជាឧកញ៉ាសោភណ្ឌមន្ត្រី ។

នៅពេលមានជន្មាយុ ១២ឆ្នាំ មាតាបិតាបាននាំយកទៅផ្ញើផ្ញាក់ឲ្យរៀនសូត្រអក្សរសាស្ត្រក្នុងសំណាក់លោកគ្រូសូត្រស្តាំនាម កែវ ម៉ន នៅវត្តពោធិព្រឹក្ស ហៅវត្តពោល្យំ ក្នុងឃុំរលាំងកែន ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។

នៅក្នុងឆ្នាំ១៨៩៧ ចូលដល់វ័យ១៤ឆ្នាំ ព្រះអង្គក៏បានបួសជាសាមណេរនៅវត្តពោធិព្រឹក្សនោះ អស់រយៈកាលពីរឆ្នាំ ទើបចាកចេញទៅរៀនសូត្រព្រះបរិយត្តិធម៌ ឯវត្តឧណ្ណាលោម ទីក្រុងភ្នំពេញ ក្នុងសំណាក់ព្រះពុទ្ធគ្រូ ទេព សោ នៅកុដិថែវប្រុបកំពែងខាងជើង ។

លុះបានព្រះជន្មាយុគម្រប់២១ព្រះវស្សា ព្រះអង្គបាននិមន្តត្រលប់ទៅបំពេញឧបសម្បទាជាភិក្ខុ ក្នុងវត្តពោធិព្រឹក្ស វិញ ហើយបានទទួលព្រះនាមបញ្ញត្តិថា ជោតញ្ញាណោ។ បន្ទាប់ពីបំពេញឧបសម្បទាជាភិក្ខុភាពរួចហើយ ព្រះអង្គក៏និមន្តត្រលប់មកគង់នៅវត្តឧណ្ណាលោមវិញ ដើម្បីសិក្សាគន្ថធុរៈបន្តទៀត ។

ព្រះអង្គបានព្យាយាមសិក្សាទាំងផ្នែកទាំងផ្នែកភាសាបាលី ភាសាសំស្ក្រឹត និងភាសាបារាំង ដោយថាមពលដ៏ក្លៀវក្លាបំផុត រហូតបានចេះដឹងជ្រៅជ្រះច្បាស់លាស់ ។ ក្រៅពីនោះ ព្រះអង្គចេះភាសាអង់គ្លេស, ភាសាថៃ, ភាសាឡាវ, និងភាសាវៀតណាមអាចប្រាស្រ័យទាក់ទងគ្នាបានផងដែរ។



សម្ដេចព្រះសង្ឃរាជ ជួន ណាត និងសម្ដេចសីហនុ

ចាប់ពីឆ្នាំ១៩១០ ព្រះអង្គចាប់ផ្ដើមមានព្រះកិត្តិស័ព្ទល្បីថា ជាព្រះថេរៈស្ទាត់ជំនាញពូកែខាងភាសាបាលី ជាងភិក្ខុសាមណេរឯទៀតៗ ដែលរៀនជាមួយគ្នា ។

ឆ្នាំ១៩១៣ នៅចំពោះព្រះភ័ក្ត្រព្រះករុណាព្រះបាទសម្ដេចព្រះស៊ីសុវត្ថិ ព្រះអង្គបានចូលប្រលងដេញប្រយោគក្នុងព្រះឧបោសថរតនារាម វិហារព្រះកែវមរកត បាន ៤ប្រយោគ ដែលជាប្រយោគជាន់ខ្ពស់បំផុតក្នុងសម័យនោះ ។

ឆ្នាំ១៩១៥ ព្រះអង្គបានប្រលងជាប់លេខ២ និងបានទទួលការតែងតាំងជាសាស្ត្រាចារ្យនៅសាលាបាលីជាន់ខ្ពស់ ដែលសព្វថ្ងៃមានឈ្មោះថា ពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ។

ជាមួយគ្នានោះ ព្រះអង្គក៏បានបានសិក្សាស្រាវជ្រាវពីឫសគល់ភាសាបាលី រហូតអាចអាន ឬសន្ទនាតាមសំនៀងជាភាសាលង្កា ភាសាភូមា ភាសាមន ភាសាសៀម និងឡាវ ដោយគ្មានទើសទាក់ភ្ញាំងភ្ញាត់ រហូតបានទទួលការតែងតាំងជាព្រះគ្រូសង្ឃសត្ថា ។

ពីឆ្នាំ១៩២២ ដល់១៩២៣ ព្រះគ្រូសង្ឃសត្ថា ជួន ណាត និងព្រះគ្រូសង្ឃវិជ្ជា ហួត តាត ត្រូវបានចាងហ្វាងសាលាបារាំងសែហ្វចុងបូព៌ា ឈ្មោះ លូវី ហ្វីណូត៍ (L. Finot) ជនជាតិបារាំង និមន្តឱ្យទៅបំពេញវិជ្ជាខាងភាសាសំស្ក្រឹត និងអក្សរសិលាចារឹក នៅសាលាបារាំងចុងបូព៌ា នាក្រុងហាណូយ វៀតណាមខាងជើង ។

ឆ្នាំ១៩១៩ ដល់១៩៣០ ព្រះអង្គត្រូវបានតែងតាំងជាលេខាធិការនៃក្រុមតាក់តែងវចនានុក្រមខ្មែរ ដោយព្រះអង្គកាន់កិច្ចការនេះផ្ទាល់ រហូតដល់បានចប់ចុងចប់ដើម, ជាសមាជិកក្រុមពិនិត្យអក្ខរាវិរុទ្ធនៃសៀវភៅនានា ដែលសាលាបាលីជាន់ខ្ពស់ជាអ្នកបោះពុម្ពផ្សាយ, ជាមេប្រយោគក្នុងការប្រលងយកវិញ្ញាបនបត្របឋមសិក្សាខ្មែរ និងការប្រឡងយកសញ្ញាប័ត្របឋមសិក្សាជាន់ខ្ពស់ បារាំង-ខ្មែរ នៅក្រុងភ្នំពេញ, ជាសមាជិក នៃក្រុមជំនុំផ្ទៀងសម្រេចខាងវចនានុក្រមខ្មែរ ព្រមទាំងទទួលភារៈធ្វើវចនានុក្រម តែមួយព្រះអង្គឯង ដរាបដល់បានចប់សព្វគ្រប់ និងបានបោះពុម្ពផ្សាយទាំងភាគ១ភាគ២, ជាសមាជិកនៃក្រុមអភិបាលជំនុំផ្ដាច់ឆ្នាំ សម្រាប់បណ្ណាល័យកម្ពុជា ដែល

សព្វថ្ងៃហៅថា វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ, ជាចាងហ្វាងរង នៃសាលាបាលីជាន់ខ្ពស់, ជាសមាជិកជំនួយការក្រុមជំនុំព្រះត្រៃបិដក នៅវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ។

ពី១៩៣២ ដល់១៩៣៥ ព្រះអង្គត្រូវបានតែងតាំងជាសមាជិកនៃក្រុមជំនុំខាងការស្រាវជ្រាវជ្រើសរើសរកពាក្យពេចន៍ក្នុងផ្ទៃ នៃកវីនិពន្ធខ្មែរបុរាណ ដើម្បីប្រមូលបញ្ចូលពាក្យទាំងនេះដាក់ក្នុងវចនានុក្រមខ្មែរ, ជាសមាជិកក្រុមជំនុំពិនិត្យសៀវភៅដែលក្រសួងសិក្សាធិការជាតិបោះពុម្ពផ្សាយ, ជាសមាជិកនៃក្រុមជំនុំជ្រើសរើសពាក្យខ្មែរប្រៀបធៀបនឹងពាក្យបារាំង សម្រាប់ប្រើក្នុងកិច្ចការរាជការ និងជាសាស្ត្រាចារ្យបង្រៀនភាសាបាលី សំស្ក្រឹត ខ្មែរ និងឡាវ នៅថ្នាក់ទីបញ្ចប់នៅវិទ្យាល័យព្រះស៊ីសុវត្ថិ ។

ចាប់ពីឆ្នាំ១៩៣១មក សម្តេចព្រះសង្ឃរាជ ជួន ណាត បានដឹកនាំគណៈប្រតិភូមន្ត្រីសង្ឃ និមន្តទៅកាន់ប្រទេសលាវ ( ច្រើនលើក), ទឹកដីកូសាំងស៊ីន( កម្ពុជាក្រោម), ប្រទេសស្រីលង្កា, ប្រទេសភូមា, ប្រទេសឥណ្ឌា និងប្រទេស ឥណ្ឌូនេស៊ី ដើម្បីចូលរួមក្នុងពិធីផ្សេងៗដែលទាក់ទងដល់វិស័យព្រះពុទ្ធសាសនា ។

ជាមួយគ្នានោះ ព្រះអង្គបានទទួលគ្រឿងឥស្សរិយយសចំនួន១០គ្រឿង ។ ជាមួយគ្នានេះ ព្រះអង្គបានកសាងសមិទ្ធផលនិងបន្សល់ទុកស្នាព្រះហស្តជាច្រើនទៀត ។

ថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៤១ ព្រះអង្គបាននិពន្ធទំនុកចម្រៀងបទនគររាជសម្រាប់ច្រៀងគោរពជាតិខ្មែរ ។

ពីឆ្នាំ១៩៤២ ដល់ឆ្នាំ ១៩៤៨ ព្រះអង្គត្រូវបានតែងតាំងជាចាងហ្វាងសាលាបាលីជាន់ខ្ពស់ ដែលសព្វថ្ងៃមានឈ្មោះថា ពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ, ជាចៅអធិការវត្តឧណ្ណាលោម, ជាអធិបតីនៃថេរសភា គឺក្រុមជំនុំជាន់ខ្ពស់របស់សង្ឃ, ជាអនុប្រធានគណៈកម្មការវប្បធម៌នៃគណៈកម្មការជាតិខាងការសិក្សា, ជាប្រធានគណៈកម្មការធម្មវិន័យពិនិត្យការផ្សាយសៀវភៅសម្រាប់សាលាធម្មវិន័យក្នុងព្រះរាជាណាចក្រ ។

ដោយព្រះមហាវិរិយភាពទាំងផ្លូវព្រះពុទ្ធសាសនា ទាំងផ្លូវលោកដ៏ច្រើនមហិមា ព្រះអង្គបានឡើងសមណសក្តិជាលំដាប់លំដោយ គឺ ឆ្នាំ១៩១០ ជាព្រះបាឡាត់សាក្យ

បុត្តិយ៍ ( បាឡាត់របស់ព្រះសក្យវង្ស នុត វត្តឧណ្ណាលោម)។

ឆ្នាំ១៩១២ ជាព្រះគ្រូសង្ឃសត្ថា។ ឆ្នាំ១៩៣១ ជាព្រះសាសនសោភ័ណ ( រាជាគណៈកិត្តិយស)។

ឆ្នាំ១៩៤០ ជាព្រះពុទ្ធឃោសាចារ្យ ( រាជាគណៈថ្នាក់ទី២)។

ឆ្នាំ១៩៤៤ ជាសមណស័ក្តិជាព្រះពោធិវង្ស ( រាជាគណៈថ្នាក់ទី១) ។

ឆ្នាំ១៩៤៨ ជាព្រះមហាសុមេធាធិបតី សង្ឃនាយកគណៈមហានិកាយ ។

ឆ្នាំ១៩៥០ ព្រះមហាក្សត្រនរោត្តម សីហនុ បានប្រោសប្រទានប្រគេនព្រះឋានៈជាសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយ ។

ឆ្នាំ១៩៥៤ រដ្ឋាភិបាលសហភាពភូមា បានប្រគេនព្រះឋានៈសម្តេចជាព្រះអគ្គមហាបណ្ឌិតសហភាពភូមា ។

ឆ្នាំ១៩៥៧ រដ្ឋាភិបាលសហភាពភូមា បានសូមតម្កើងព្រះឋានៈព្រះអង្គជាព្រះអភិធជៈមហារដ្ឋគរុ នៃសហភាពភូមា ដែលជាសមណស័ក្តិដ៏ខ្ពស់បំផុត និងមានតែមួយអង្គក្នុងប្រទេសភូមា ។

ក្នុងឆ្នាំ១៩៥៧នោះដែរ ព្រះអង្គបាននិពន្ធទំនុកចម្រៀងបទបទសរភេញ្ញក្នុងឱកាសបុណ្យពាក់កណ្តាលសាសនា ( ពុទ្ធសករាជ២៥០០) ផងដែរ ។

ចាប់ពីឆ្នាំ១៩៦១ រហូតមក តាមការនិមន្តរបស់សមាគមអ្នកនិពន្ធខ្មែរ ព្រះអង្គបានសព្វព្រះទ័យមកគង់ជាវាគ្មិន ដើម្បីធ្វើអត្ថាធិប្បាយពន្យល់ណែនាំពីអត្ថន័យនៃការប្រើពាក្យនីមួយៗ និងពីឃ្លាឃ្លោងទាំងឡាយក្នុងកម្មវិធីអក្សរសាស្ត្រខ្មែរ ដែលចាក់ផ្សាយតាមវិទ្យុជាតិ ជារៀងរាល់ថ្ងៃសុក្រ ។

ឆ្នាំ១៩៦៣ សម្តេចព្រះប្រមុខរដ្ឋ នរោត្តម សីហនុ បានប្រោសប្រទានព្រះឋានៈសម្តេចជា សម្តេចព្រះសង្ឃរាជថ្នាក់ទី១ ។

ឆ្នាំ១៩៦៤ អ្នកនិពន្ធខ្មែរទាំងអស់បានឯកភាពគ្នាប្រគេនឋានៈព្រះអង្គជាព្រះអគ្គនិពន្ធអក្សរសាស្ត្រខ្មែរ និងជាប្រធានកិត្តិយសនៃសមាគមអ្នកនិពន្ធខ្មែរ ។

ថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៦៧ ព្រះអង្គបានទទួលសញ្ញាបត្របណ្ឌិតអក្សរសាស្ត្រពេញលក្ខណៈ ពីសម្តេចព្រះប្រមុខរដ្ឋ នរោត្តម សីហនុ នៅមហាវិទ្យាល័យអក្សរសាស្ត្រ និងមនុស្សសាស្ត្រ នៃសាកលវិទ្យាល័យសង្គមរាស្ត្រនិយម ។

ឆ្នាំ១៩៦៨ ព្រះអង្គទទួលឋានៈជាប្រធានគណៈកម្មការពិនិត្យអត្ថបទផ្សាយទាំងឡាយជារឿងប្រវត្តិសាស្ត្រខ្មែរ ។

ឆ្នាំ១៩៦៩ ព្រះអង្គទ្រង់ទទួលការតែងតាំងជាប្រធានគណៈកម្មការពិនិត្យ និងកំណត់អត្ថន័យរបស់ទង់ជាតិខ្មែរ ។

---

# ២៦៦
# ការប្រយុទ្ធតស៊ូរបស់ពួកខ្មែរក្រហម ជាមួយទាហានរាជរដ្ឋាភិបាល



សម្តេចសីហនុ ចុះសួរសុខទុក្ខទាហានរងរបួសដោយសារការវាយប្រយុទ្ធគ្នាជាមួយពួកខ្មែរក្រហម

តាមការអះអាងរបស់ប៉ុល ពត (សាឡុត ស) ក្រោយពេលបានឡើងកាន់អំណាចជានាយករដ្ឋមន្ត្រី នៃរបបកម្ពុជាប្រជាធិបតេយ្យ ពីឆ្នាំ១៩៧៥ ដល់១៩៧៩ បានឱ្យដឹងថា នៅក្នុងឆ្នាំ១៩៦៩ សភាពការណ៍នយោបាយក្នុង ប្រទេសកាន់តែមានសភាពតានតឹងឡើងៗ ។

ពួកមេដឹកនាំខ្មែរក្រហមបានក្តាប់សភាពការណ៍យ៉ាងណែន និងវាយតម្លៃថាសហរដ្ឋអាមេរិក និងលន់ នល់ មានគម្រោងធ្វើរដ្ឋប្រហារ ។

ពួកមេដឹកនាំខ្មែរក្រហមយល់ឃើញថា ប្រសិនបើលន់ នល់ ធ្វើរដ្ឋប្រហារមែន

នោះមុខជាជួយជំរុញឱ្យមានកម្លាំងថ្មីទៀត មកនៅខាងបដិវត្តន៍របស់ពួកគេមិនខាន ។ ដូច្នេះ ពួកគេចាំបាច់ត្រូវតែត្រៀមរៀបចំទទួលយកកម្លាំងថ្មីនោះ ហើយរដ្ឋប្រហារនោះ ប្រាកដជាផ្ដល់ផលជាវិជ្ជមានដល់ចលនាបដិវត្តន៍របស់ពួកគេ ។

ពេលនោះពួកមេដឹកនាំខ្មែរក្រហមបានតាក់តែងឯកសារមួយស្ដីពីមាគ៌ានយោបាយរណសិរ្សរួបរួមជាតិ ត្រៀមទុកមុនជាស្រេច ។

មាគ៌ានយោបាយរណសិរ្សរួបរួមជាតិរបស់ពួកមេដឹកនាំខ្មែរក្រហមនេះ គឺមិនអនុញ្ញាតឱ្យពួកបញ្ញវន្ត ដែលរត់ចូលព្រៃតស៊ូធ្វើបដិវត្តន៍ ធ្វើការរិះគន់វាយប្រហារទៅលើសម្ដេចសីហនុ ដូចមុនៗទៀតទេ ។

ពួកមេដឹកនាំខ្មែរក្រហមចាត់ទុកថា ការរិះគន់វាយប្រហារទៅលើសម្ដេចសីហនុ គឺជាការអនុវត្តផ្ទុយពីមាគ៌ារណសិរ្សរួបរួមជាតិរបស់បក្សៗ ដូច្នេះ គួរតែរិះគន់វាយប្រហារទៅលើសហរដ្ឋអាមេរិក និងពួកក្បត់លន់ នល់ តែប៉ុណ្ណោះ ។

តែការអះអាងរបស់ប៉ុល ពត ( សាឡុត ស) ដែលថា គាត់បានតាក់តែងមាគ៌ានយោបាយរណសិរ្សរួបរួមជាតិនេះ នៅក្នុងឆ្នាំ១៩៦៩នោះ ដូចជាមិនសូវទំនងប៉ុន្មានទេ ហើយក៏មិនប្រាកដថា គាត់បានដឹងជាមុនពីផែនការរបស់លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្ដេចសីហនុ នោះដែរៗ តែបើថា គាត់បានតាក់តែងគោលនយោបាយរណសិរ្សរួបរួមជាតិនោះ ក្រោយថ្ងៃរដ្ឋប្រហារទម្លាក់សម្ដេចសីហនុ ចេញពីអំណាច ថ្ងៃទី១៨ ខែមីនាឆ្នាំ១៩៧០វាដូចជាទំនងជាង ព្រោះរហូតដល់ ថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧០ គឺក្រោយធ្វើរដ្ឋប្រហារនោះតែ៥ថ្ងៃ សម្ដេចសីហនុ ដែលកំពុងស្នាក់នៅទីក្រុងប៉េកាំង បានប្រកាសបង្កើតរណសិរ្សរួបរួមជាតិកម្ពុជា ដោយរួមសហការគ្នាជាមួយពួកខ្មែរក្រហមប៉ុល ពត( សាឡុត ស) គឺបក្សកុម្មុយនិស្តកម្ពុជា នេះឯង ។

នៅក្នុងឯកសារសម្ងាត់ស្ដីពីប្រវត្តិបក្សកុម្មុយនិស្តកម្ពុជា ដែលមានអៀង សារី ជាអ្នកឧទ្ទេសនាមនៅក្នុងសម័យតស៊ូធ្វើសង្គ្រាមដណ្ដើមអំណាចពីមេដឹកនាំរបបសាធារណរដ្ឋខ្មែរ ក្នុងឆ្នាំ១៩៧១ បានសរសេរថា ចាប់ពីចុងឆ្នាំ១៩៦៧ ដល់ឆ្នាំ១៩៧០ ពួកខ្មាំង

( ពួកលន់ នល់ ) បានចាប់ផ្តើមធ្វើសង្គ្រាមស៊ីវិលបង្ក្រាបចលនាតស៊ូបដិវត្តន៍យើង ។ យុទ្ធមិត្តរបស់យើងត្រូវរស់នៅឆ្ងាយៗពីគ្នាពីកន្លែងមួយទីកន្លែងមួយទៀត ។

អៀង សារី បានបញ្ជាក់ថា ការធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយ មានការលំបាកខ្លាំងណាស់ ហើយរហូតដល់សព្វថ្ងៃ( ឆ្នាំ១៩៧១ ) ក៏យើងនៅតែមិនអាចធ្វើមហាសន្និបាតបក្សបានដែរ គឺមានតែការ ប្រជុំរបស់សមាជិកអចិន្ត្រៃយ៍របស់គណៈកម្មាធិការមជ្ឈិមបក្សប៉ុណ្ណោះ ។

អៀង សារី រម្ញឹកថា នៅក្នុងខែកក្កដាឆ្នាំ ១៩៦៩ អង្គប្រជុំសមាជិកអចិន្ត្រៃយ៍របស់គណៈកម្មាធិការមជ្ឈិមបក្ស បានចេញសេចក្តីសម្រេចមួយស្តីពីការធ្វើសង្គ្រាមប្រជាជនដើម្បីវាយសំពងទៅលើពួកខ្មាំង និងរារាំងមិនឱ្យមានការបាត់បង់សន្តិភាព និងអព្យាក្រឹតភាពរបស់ប្រទេសជាតិ ។

យើងត្រូវតែកសាងបក្សគ្រប់វិស័យឡើងវិញ កសាងយុទ្ធសាស្ត្រ និងយុទ្ធវិធីឡើងវិញ ព្រមទាំងរៀបចំផែនការវាយប្រហារទៅលើខ្មាំងវិញ។ តែយើងមិនប្រឆាំងនឹងសម្តេចសីហនុ ទេ ។

ប្រភពព័ត៌មានមួយបានឱ្យដឹងថា ចាប់ពីឆ្នាំ១៩៦៨ មក ខៀវ សំផន, ហ៊ូ យន់និងហ៊ូ នឹម ដែលបានគេចខ្លួនរត់ចូលព្រៃទៅរស់នៅជាមួយពួកខ្មែរក្រហមនោះ តែងតែដើរឃោសនារិះគន់វាយប្រហារទៅលើសម្តេចសីហនុ ដោយគ្មានសំចៃមាត់បន្តិចឡើយ ។ ប៉ុន្តែ មកដល់ខែវិច្ឆិកា ឆ្នាំ១៩៦៩ ដែលពេលនោះពួកគាត់ទាំង៣នាក់ កំពុងរស់នៅក្នុងព្រៃនៃតំបន់ភ្នំក្រវាញ ក៏បានចូលរៀនសូត្រពីមាគ៌ានយោបាយបដិវត្តន៍ថ្មីរបស់បក្ស ។ មាគ៌ានយោបាយ បដិវត្តន៍ថ្មីរបស់បក្សនោះ គឺមិនចាត់ទុកសម្តេចសីហនុ ជាមេដឹកនាំមាននិន្នាការទៅរកអាមេរិក ទេ ។

ពេលនោះ ពួកមេដឹកនាំខ្មែរក្រហម ចង់រួមដៃគ្នាជាមួយសម្តេចសីហនុ ជាចំហដើម្បីឆ្លៀតឱកាសយកចំណេញផ្នែកនយោបាយ ព្រោះពួកគេក៏ដឹងថាប្រជារាស្ត្រខ្មែរភាគច្រើនលើសលប់គោរពជឿជាក់ និងស្មោះត្រង់យ៉ាងប្តូរផ្តាច់បំផុតជាមួយសម្តេច

សីហនុ ។

តែទោះជាយ៉ាងនេះក៏ដោយ ក៏នៅក្នុងឆមាសទី១ ឆ្នាំ១៩៦៩ ពួកឧទ្ទាមខ្មែរក្រហម១៣០ នាក់ត្រូវអាជ្ញាធរបាញ់សម្លាប់, ប្រមាណ១០០នាក់ទៀតត្រូវរងរបួស និង ៦០នាក់ទៀតត្រូវចាប់ខ្លួន និងសារភាព។ ចំណែកពួកឧទ្ទាមខ្មែរក្រហមវិញ ក៏បានបាញ់សម្លាប់ទាហាន និងប៉ូលិស ព្រមទាំងប្រជាពលរដ្ឋមួយចំនួនដែរ ។

មកដល់ឆមាសទី២ ឆ្នាំ១៩៦៩ បើតាមរបាយការណ៍របស់រាជរដ្ឋាភិបាលស្រោចស្រង់ជាតិ ដឹកនាំដោយឧត្តមសេនីយ៍ឯកលន់ នល់ បានឱ្យដឹងថា ទាហានរាជរដ្ឋាភិបាល និងពួកឧទ្ទាមខ្មែរក្រហម មានការប្រយុទ្ធគ្នា ចំនួន២២លើក ក្នុងនោះមាន១៣លើក ជាការវាយប្រហាររបស់ពួកឧទ្ទាមខ្មែរក្រហមមកលើទាហានរាជរដ្ឋាភិបាល ហើយមានការបន្ថែមកម្លាំងរបស់ពួកឧទ្ទាមខ្មែរក្រហម នៅភូមិភាគនិរតី និងមានការងើបបះបោរជាថ្មីនៅបាត់ដំបង ភូមិភាគពាយ័ព្យ។ ប៉ុន្តែនៅភូមិភាគបូព៌ា ពួកឧទ្ទាមភាគច្រើនបាននាំគ្នាចូលទៅជ្រកកោននៅក្នុងទឹកដីវៀតណាមខាងត្បូង គឺនៅខាងក្រោយកងទ័ពវៀតកុង-វៀតណាមខាងជើង ដែលដាក់ពង្រាយនៅតាមបណ្តោយព្រំដែន នៅក្នុងខេត្តកំពង់ចាម, ខេត្តព្រៃវែង និងខេត្តស្វាយរៀង ហើយពួកនេះ មិនសូវបញ្ចេញសកម្មភាពប្រឆាំងរាជរដ្ឋាភិបាលគួរឱ្យកត់សម្គាល់ឡើយ ។

របាយការណ៍របស់រាជរដ្ឋាភិបាលស្រោចស្រង់ជាតិ ដដែលបានបញ្ជាក់ថាពួកឧទ្ទាមខ្មែរក្រហមមួយចំនួនទៀត កំពុងឈរជើងនៅតាមភូមិនានានៅក្នុងខេត្តកំពង់ចាម, នៅប៉ែកខាងជើងខេត្តព្រៃវែង និងនៅខាងជើងខេត្តស្វាយរៀង ដោយមានពួកអ្នកស្រុកជួយលាក់បំពួនពួកគេ ។

នៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៦៩ កាសែតឡឺ ម៉ុងដ៍ របស់បារាំង បានចេញផ្សាយអត្ថបទមួយថា នៅក្នុងឆ្នាំនេះ កាសែតផ្សាយជាភាសាខ្មែរបានចុះផ្សាយបង្ហាញជាសាធារណៈ ២លើកមកហើយ នូវរូបថតដែលមានក្បាលមនុស្សម្នាក់ (ក្បាលពួកខ្មែរក្រហម) គេទើបកាត់កថ្មីៗ ដាក់ក្បែរកាំភ្លើងវែងមួយដើមនៅលើកន្ទេលមួយ ។

*ករណីកាត់ក្បាលពួកខ្មែរក្រហមនេះ ក៏ធ្លាប់កើតមានកាលពីឆ្នាំ១៩៦៨ នៅក្នុងខេត្តកំពតដែរ គឺទាហានរបស់ឧត្តមសេនីយ៍ឯកលន់ នល់ បានកាត់ក្បាលពួកនេះមកដាក់នៅមុខផ្សារក្នុងទីរួមខេត្ត ដើម្បីបង្ហាញសាធារណជន ផងដែរ ។*



សពនាយទាហានដែលស្លាប់ដោយសារការវាយប្រយុទ្ធគ្នាជាមួយពួកខ្មែរក្រហម

# ២៦៧
# ទំនាស់រវាងសម្តេចសីហនុ និងទ្រង់សិរិមតៈ កាន់តែមុតស្រួចៗទៅ



ទ្រង់សិរិមតៈ

ថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៦៩ ឧត្តមសេនីយ៍ឯកលន់ នល់ នាយករដ្ឋមន្ត្រីរាជរដ្ឋាភិបាលស្រោចស្រង់ជាតិ ត្រូវចេញទៅព្យាបាលជំងឺនៅប្រទេសបារាំង ដោយមិនកំណត់រយៈពេលដែលត្រូវវិលត្រលប់មកវិញ។

ព្រះអង្គម្ចាស់ស៊ីសុវត្ថិ សិរិមតៈ ជាឧបនាយករដ្ឋមន្ត្រីទី១ ត្រូវឡើងជានាយករដ្ឋមន្ត្រីប្រតិភូ( នាយករដ្ឋមន្ត្រីស្តីទី) ដឹកនាំគណៈរដ្ឋមន្ត្រី ជំនួស។

កាលពីឆ្នាំ១៩៦៧ ឧត្តមសេនីយ៍ឯកលន់ នល់ រងរបួសដោយសារគ្រោះថ្នាក់ចរាចរណ៍ គាត់បានទៅព្យាបាលរបួសនោះ នៅប្រទេសបារាំង ម្តងរួចមកហើយ។

ក្រោយពីបានដឹងច្បាស់ថា រដ្ឋសភា និងរាជរដ្ឋាភិបាលស្រោចស្រង់ជាតិ បានពួតដៃគ្នារកវិធីកាត់បន្ថយអំណាចស្របតាមរដ្ឋធម្មនុញ្ញរបស់ព្រះអង្គមក នៅដើមខែធ្នូ ឆ្នាំ១៩៦៩ សម្តេចសីហនុ បានរៀបចំគម្រោងការឱ្យមន្ត្រីជំនិតរបស់ព្រះអង្គជាច្រើននាក់ ធ្វើដំណើរចុះទៅតំបន់នានា ដែលស្ថិតនៅក្បែរៗទីក្រុងភ្នំពេញ ដើម្បីឃោសនាប្រមែប្រមូលប្រជារាស្ត្រឱ្យនាំគ្នាមកជួបជុំនៅមុខព្រះបរមរាជវាំង គ្រោងធ្វើបាតុកម្មគាំទ្រព្រះអង្គ និងសម្តែងការប្រឆាំងចំពោះរដ្ឋសភា និងរាជរដ្ឋាភិបាល

ដែលចង់កាត់បន្ថយអំណាចព្រះអង្គនោះដែរ។ ប៉ុន្តែព្រះអង្គម្ចាស់ស៊ីសុវត្ថិ សិរិមតៈ ដែលបានឡើងកាន់តំណែងជានាយករដ្ឋមន្ត្រីស្តីទី បានដឹងរឿងនេះ ទ្រង់ក៏បានបញ្ជាទៅអភិបាលខេត្ត អភិបាលស្រុក ឱ្យចុះទៅអប់រំណែនាំអាជ្ញាធរភូមិ-ឃុំ និងប្រជារាស្ត្រ ឱ្យរក្សាភាពស្ងៀមស្ងាត់នៅតាមភូមិ-ឃុំនីមួយៗ និងមិនឱ្យនាំគ្នាទៅចូលរួមធ្វើបាតុកម្មគាំទ្រសម្តេចសីហនុ ដែលគ្រោងធ្វើនៅមុខព្រះបរមរាជវាំងនោះ ជាដាច់ខាត។

ជាមួយគ្នានោះ ព្រះអង្គម្ចាស់ស៊ីសុវត្ថិ សិរិមតៈ ក៏មានគោលការណ៍ធ្វើវិសោធនកម្មថវិកាជាតិផងដែរ ដោយសារកន្លងទៅថវិកាជាតិដ៏ច្រើនសន្ធឹកសន្ធាប់ត្រូវបានគេបញ្ចូលដោយខុសច្បាប់ ទៅក្នុងហិបប្រាក់ពិសេសរបស់ សម្តេចសីហនុ ជាព្រះប្រមុខរដ្ឋតែម្តង ដោយមិនបាច់ឆ្លងនាយករដ្ឋមន្ត្រី ។

លើសពីនេះទៅទៀតក្រសួងនីមួយៗត្រូវកាត់ថវិការបស់ខ្លួនមួយចំណែក ទៅដាក់ក្នុងហិបប្រាក់ពិសេសរបស់ព្រះប្រមុខរដ្ឋនោះផងដែរ ។

ព្រះអង្គម្ចាស់ស៊ីសុវត្ថិ សិរិមតៈ បានសម្រេចឱ្យលុបចោលការផ្ទេរថវិកាជាតិទៅដាក់ក្នុងហិបប្រាក់ពិសេសរបស់សម្តេចសីហនុ ជាព្រះប្រមុខរដ្ឋ នោះវិញ ព្រោះគ្មានច្បាប់ចែង និងផ្ទុយពីផលប្រយោជន៍ជាតិ។ ដូច្នេះ ឧប គឹមអាង ជាឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកក្រសួងសេដ្ឋកិច្ចជាតិ និងហិរញ្ញវត្ថុ បានចុះហត្ថលេខាលើសារាចរមួយផ្ញើទៅព្រះរាជខុទ្ទកាល័យនៃព្រះប្រមុខរដ្ឋ និងគ្រប់ក្រសួងនានា ដើម្បីឱ្យអនុវត្តការធ្វើវិសោធនកម្មថវិកាជាតិនេះ ឱ្យមានប្រសិទ្ធភាព ។

ជាមួយគ្នានោះ ក្រសួងសេដ្ឋកិច្ចជាតិ និងហិរញ្ញវត្ថុ ក៏មានគោលការណ៍ផ្គត់ផ្គង់ថវិកាទៅព្រះរាជខុទ្ទកាល័យព្រះប្រមុខរដ្ឋ តាមតម្រូវការរបស់សម្តេចសីហនុ ដែរ តែការផ្គត់ផ្គង់នោះត្រូវធ្វើឡើងនៅក្នុងក្របខណ្ឌថវិកាជាតិ មានច្បាប់ត្រឹមត្រូវ ។

បន្ទាប់មក ក្រសួងមហាផ្ទៃ ក៏មានចេញសារាចរមួយ ជូនដល់គ្រប់អភិបាលខេត្ត និងនាយកដ្ឋានរដ្ឋបាលសំខាន់ៗទាំងអស់នៅក្នុងព្រះរាជាណាចក្រ ហាមប្រាម មិនឲ្យមានការទាក់ទងរាល់ការងារពាក់ព័ន្ធនឹងកិច្ចការរដ្ឋបាលផ្សេងៗ ដោយផ្ទាល់ជាមួយ

ខុទ្ទកាល័យនៃព្រះប្រមុខរដ្ឋ ដូចមុនៗទៀតឡើយ។

សារាចរនេះគឺធ្វើឡើងនៅក្នុងគោលដៅដើម្បីកែទម្រង់កិច្ចការរដ្ឋ និងស្តារទំនាក់ទំនងការងាររដ្ឋបាល រវាងរាជរដ្ឋាភិបាលជាមួយរដ្ឋបាលខេត្តឱ្យមានប្រសិទ្ធភាពឡើងវិញ។

ចំពោះការប្រយុទ្ធប្រឆាំងនឹងអំពើភេរវកម្មសេដ្ឋកិច្ច ដែលវៀតណាមខាងជើងលួចបោះពុម្ពក្រដាសប្រាក់៥០០រៀលក្លែងក្លាយ ដើម្បីយកមកទិញអង្ករពីពួកឈ្មួញ និងពីប្រជាកសិករខ្មែរក្នុងតម្លៃខ្ពស់ ធ្វើឱ្យតម្លៃអង្ករឡើងថ្លៃខ្ពស់ជាអតិបរមានោះ រាជរដ្ឋាភិបាលស្រោចស្រង់ជាតិសម្រេចប្តូរក្រដាសប្រាក់៥០០រៀល ដោយបោះពុម្ពប្រាក់៥០០រៀលថ្មី មកជំនួសវិញ។

ចំណែកបញ្ហាកែទម្រង់សេដ្ឋកិច្ចវិញ ដោយមើលឃើញច្បាស់ថា ប្រទេសជាតិជួបគ្រោះវិបត្តិសេដ្ឋកិច្ចកាន់តែជ្រៅទៅៗ ហើយចាំបាច់ត្រូវមានកំណែទម្រង់ជាបន្ទាន់នោះ តំណាងរាស្ត្រភាគច្រើនដាច់ខាត ក៏បានគាំទ្រគម្រោងកំណែទម្រង់សេដ្ឋកិច្ចទីផ្សារសេរីរបស់រាជរដ្ឋាភិបាលស្រោចស្រង់ជាតិ ហើយបោះឆ្នោតអនុម័តយល់ព្រមឱ្យរាជរដ្ឋាភិបាល ដើម្បី អនុវត្តគោលការណ៍កំណែទម្រង់នោះ។ ប៉ុន្តែ កំណែទម្រង់សេដ្ឋកិច្ចទីផ្សារសេរីនេះធ្វើឱ្យសម្តេចសីហនុ មានការក្រេវក្រោធជាខ្លាំង ព្រោះនេះជាការប្រឆាំងនឹងគោលការណ៍ជាតូបនីយកម្មសេដ្ឋកិច្ច តាមបែបទ្រឹស្តីសង្គមនិយមរបស់ព្រះអង្គ។

ព្រះអង្គបានប្រកាសជាសាធារណៈថា តំណាងរាស្ត្រភាគច្រើន ជាអ្នកប្រឆាំងនឹងនយោបាយរបស់ព្រះអង្គ ហើយព្រះអង្គប្រកាសឈប់ទាក់ទងជាមួយពួកតំណាងរាស្ត្រទាំងនោះដូចមុនៗ ផងដែរ។ មិនតែប៉ុណ្ណោះ ព្រះអង្គបានប្រកាសហាមប្រាមមិនឱ្យពួកតំណាងរាស្ត្រទាំងនោះចូលរួមក្នុងសមាជជាតិ ដែលគ្រោងនឹងធ្វើនៅខែធ្នូខាងមុខទៀតផង។

ជាមួយគ្នានោះ ព្រះអង្គក៏មិនចង់ឱ្យរាជរដ្ឋាភិបាល ដែលមានព្រះអង្គម្ចាស់

សិរិមត: ជានាយករដ្ឋមន្ត្រីប្រតិភូ ចូលរួមក្នុងសមាជជាតិនោះដែរ។ដូច្នេះព្រះអង្គបានរកវិធីមួយក្នុងព្រះរាជបំណងធ្វើឲ្យរាជរដ្ឋាភិបាលស្រោចស្រង់ជាតិ លាលែងពីតំណែងមុនពេលបើកសមាជជាតិនោះ។

វិធីនោះ គឺព្រះអង្គឲ្យសមាជិករាជរដ្ឋាភិបាលស្រោចស្រង់ជាតិមួយចំនួន ជាមនុស្សជំនិតនឹងព្រះអង្គសុំលាលែងពីតំណែង ដើម្បីឱ្យមានវិបត្តិគណៈរដ្ឋមន្ត្រី ។

ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៦៩ មុនពេលបើកសមាជជាតិលើកទី២៨ មួយថ្ងៃ មានសមាជិករាជរដ្ឋាភិបាល ៤ រូប គឺៈ ទី១- អ៊ឹង ហុងសាធ ឧបនាយករដ្ឋមន្ត្រីទី២ ទទួលបន្ទុកសាធារណសុខាភិបាល សង្គមកិច្ច ការងារបង្កើនគុណភាពជីវិតអភិវឌ្ឍន៍សហគមន៍លំនៅឋាន និងព័ត៌មាន, ទី២- ជួន សៅឌី រដ្ឋមន្ត្រីក្រសួងកសិកម្ម, ៣- ទេព ឈីវខេង រដ្ឋមន្ត្រីក្រសួងឃោសនាការ និងទី៤- ស្រី ប៉ុង រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម ដែលជាតស្សូរជន ស្មោះត្រង់ជាមួយសម្តេចសីហនុ បានដាក់ពាក្យសុំលាលែងពីតំណែងក្នុងគោលបំណងធ្វើឱ្យមានវិបត្តិគណៈរដ្ឋមន្ត្រី ដើម្បីឱ្យមានការរៀបចំរាជរដ្ឋាភិបាលថ្មីមួយទៀត ជំនួសរាជរដ្ឋាភិបាលស្រោចស្រង់ជាតិ ដែលមានព្រះអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមត: ជានាយករដ្ឋមន្ត្រីប្រតិភូ ។

ចំណែកវរសេនីយ៍ឯកអ៊ុំ ម៉ាន់នូរិន រដ្ឋលេខាធិការក្រសួងការពារលើផ្ទៃប្រទេស និងវរសេនីយ៍ឯកសុស្តែន ហ្វែរណង់ដេស ជារដ្ឋលេខាធិការក្រសួងសន្តិសុខជាតិ ព្រះអង្គមិនឲ្យលាលែងពីតំណែងទេ គឺរក្សាទុកដើម្បីរក្សាសន្តិសុខផ្ទាល់របស់ព្រះអង្គ។

ពេលនោះ ព្រះអង្គម្ចាស់ស៊ីសុវត្ថិ សិរិមត: ក្នុងនាមជានាយករដ្ឋមន្ត្រីប្រតិភូក៏បានយល់ព្រមតាមពាក្យសុំលាលែងពីតំណែងរបស់សមាជិករាជរដ្ឋាភិបាលទាំង ៤នាក់នោះភ្លាមៗ ដោយគ្មានបង្អង់យូរឡើយ។

៣ថ្ងៃក្រោយមក សម្តេចសីហនុ ក្នុងនាមជាព្រះប្រមុខរដ្ឋ នៃព្រះរាជាណាចក្រកម្ពុជា បានស្នើសុំឱ្យលុបចោលការយល់ព្រមចំពោះពាក្យសុំលាឈប់ពីតំណែងរបស់

សមាជិករាជរដ្ឋាភិបាលទាំង៤នាក់នោះវិញដែរ តែត្រូវព្រះអង្គម្ចាស់ស៊ីសុវត្ថិ សិរិមតៈ បដិសេធ...។

នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៦៩ ជាថ្ងៃចាប់ផ្ដើមបើកសមាជជាតិលើកទី២៨ ថ្ងៃដំបូង សម្ដេចសីហនុ បានប្រមូលពួកអ្នកដែលមានស្វាមីភក្ដិជាមួយព្រះអង្គប្រមាណ ១៥០០នាក់ ដើម្បីបំផុសចលនាមហាជនទាមទារឱ្យរាជរដ្ឋាភិបាលស្រោចស្រង់ជាតិដឹកនាំដោយលន់ នល់ និងព្រះអង្គម្ចាស់សិរិមតៈ លាលែងពីតំណែង។ ប៉ុន្តែព្រះអង្គម្ចាស់សិរិមតៈ ដែលបានដឹងគម្រោងការនេះ ក៏បានរៀបចំត្រៀមកម្លាំងទាហានប្រមាណ ១០០០នាក់ ឱ្យស្លៀកពាក់ស៊ីវិលទៅចូលរួមក្នុងសមាជនោះ ដើម្បីត្រៀមធ្វើការទប់ទល់នឹងពួកអ្នកគាំទ្រសម្ដេចសីហនុ វិញ ។

មុនពេលអង្គសមាជចាប់ផ្ដើម មាននាយទាហាន២នាក់ ដែលស្មោះត្រង់នឹងសម្ដេចសីហនុ បានលួចផ្ដល់ព័ត៌មានពីរឿងព្រះអង្គម្ចាស់សិរិមតៈ ត្រៀមកម្លាំង១០០០នាក់នោះ ថ្វាយព្រះអង្គជ្រាប។ តែយ៉ាងណា ព្រះអង្គក៏មិនចង់ឱ្យមានការប៉ះទង្គិចជាមួយព្រះអង្គម្ចាស់សិរិមតៈ ជាចំហនោះឡើយ។ ដូច្នេះ ព្រះអង្គក៏ប្រែព្រះទ័យលែងឱ្យអ្នកស្មោះត្រង់នឹងព្រះអង្គអនុវត្តគម្រោងការបំផុសអង្គសមាជទាមទារឱ្យរាជរដ្ឋាភិបាលស្រោចស្រង់ជាតិ លាលែងពីតំណែងនោះ វិញ ។

ទោះបីព្រះអង្គមានព្រះទ័យមិនចង់ឱ្យមានការប៉ះទង្គិចជាមួយព្រះអង្គម្ចាស់សិរិមតៈ ជាចំហក៏ពិតមែន ក៏នៅថ្ងៃទី២៨ ខែធ្នូ ជាថ្ងៃទី២ នៃសមាជជាតិនោះ ព្រះអង្គម្ចាស់សិរិមតៈ បានបញ្ជូនកម្លាំងទាហានស្លៀកពាក់ស៊ីវិល ប្រមាណ ១០០០ នាក់ឱ្យបន្លំខ្លួនមកចូលរួមក្នុងសមាជនោះ ដូចដែលទ្រង់គ្រោងទុកដែរ។ តែយ៉ាងណា នៅថ្ងៃចុងក្រោយនៃអង្គសមាជនោះ គេពុំឃើញមានហេតុការណ៍អាក្រក់ណាមួយបានកើតឡើងឡើយ ហើយអ្នកការទូតបរទេសនានា ក៏សប្បាយចិត្តពីភាពស្ងប់ស្ងាត់នោះដែរ ។



សមាជជាតិនៅវាលព្រះមេរុ កាលចុងទសវត្សរ៍ឆ្នាំ១៩៦០

ជាច្រើនឆ្នាំក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ សម្ដេចសីហនុ បានរម្លឹកថា នៅក្នុងសមាជជាតិលើកទី២៨ នោះ ទ្រង់សិរិមត: ជានាយករដ្ឋមន្ត្រីស្ដីទី បានបញ្ជាឱ្យអនុសេនីយ៍ទោ លន់ ណុន ជាប្អូនប្រុសរបស់នាយករដ្ឋមន្ត្រី លន់ នល់ នាំកម្លាំងទាហាន និងពួកខ្មែរសេរី ដែលបានមកចុះចូលក្នុងសង្គមជាតិវិញ កាលពីប៉ុន្មានខែមុននោះ សរុបរាប់ពាននាក់ ឱ្យបន្ទំខ្លួនចូលប្រជុំនៅក្នុងអង្គសមាជ ក្នុងបំណងបន្ទច់បង្អាក់កុំឱ្យមានការកែទម្រង់ធ្វើជាតូបនីយកម្ម អាហរ័ណ នីហរ័ណ ដែលព្រះអង្គបានបង្កើតឡើងនោះតទៅទៀត និងបញ្ឈប់ការនាំចូលផ្ដាច់មុខរបស់រដ្ឋ នូវសុរា ថ្នាំពេទ្យ និង មុខទំនិញផ្សេងៗមួយចំនួនទៀត ព្រមទាំងត្រូវអនុញ្ញាតបើកឱ្យមានធនាគារឯកជនរបស់ខ្មែរ និងបរទេសផងដែរ ។

ប៉ុន្តែ ពេលនោះកម្លាំងបង្កប់របស់ពួកខ្មែរក្រហម ដែលបានប្រមូលគ្នីគ្នាមកឱ្យចូលរួមក្នុងអង្គសមាជនោះដែរ បានរួមគ្នាជាមួយសមាជិកអង្គសមាជផ្សេងៗទៀតមកពីបណ្ដាខេត្តនានា ដែលស្វាមីភក្ដិជាមួយព្រះអង្គ បាននាំគ្នាលើកដៃគាំទ្រគោលនយោ

បាយសេដ្ឋកិច្ចរបស់ព្រះអង្គច្រើនលើសលប់។

ពេលឃើញសមាជិកអង្គសមាជភាគច្រើនលើកដៃគាំទ្រព្រោងព្រាតដូច្នេះ ពួកទាហាន និងពួកខ្មែរសេរីចុះចូល ដែលវរសេនីយ៍ត្រីលន់ ណុន ឱ្យស្លៀកពាក់ស៊ីវិលមកបន្ទំខ្លួននៅក្នុងអង្គសមាជនោះ ក៏លើកដៃគាំទ្រគោលនយោបាយសេដ្ឋកិច្ចរបស់ព្រះអង្គ នឹងគេដែរ។



**សមាជជាតិនៅវាលព្រះមេរុ កាលចុងទសវត្សរ៍ឆ្នាំ១៩៦០**

ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ១៩៧០ ក្នុងនាមជានាយករដ្ឋមន្ត្រីស្តីទី ព្រះអង្គម្ចាស់ស៊ីសុវត្ថិ សិរិមតៈ បានបញ្ជាកម្លាំងសមត្ថកិច្ចឱ្យចាប់ថ្នាំពេទ្យទម្ងន់១៦តោន, មាសប្រមាណ ៥០០គីឡូក្រាម និងក្រដាសប្រាក់៥០០រៀលរូបគោក្លែងក្លាយជាច្រើនកេសទៀត នៅអាកាសយានដ្ឋានពោធិ៍ចិនតុង។

ថ្នាំពេទ្យ មាស និងប្រាក់រៀលក្លែងក្លាយដ៏ច្រើនសន្ធឹកសន្ធាប់ នេះ ត្រូវបានគេ

ផ្ញើពីក្រៅប្រទេសតាមយន្តហោះ ដើម្បីយកទៅផ្គត់ផ្គង់ដល់កងទ័ពវៀតកុង-វៀតណាមខាងជើង ដែលនៅប៉ែកខាងកើតប្រទេស ដូចកាលកន្លងមកដែរ ។

សម្តេចសីហនុ ដែលកំពុងសម្រាកព្យាបាលរោគនៅមន្ទីរពេទ្យឯកជនរបស់វេជ្ជបណ្ឌិតប៉ាតេ ឯប្រទេសបារាំង បានដឹងរឿងនេះ ព្រះអង្គក៏បានផ្ញើសារទូរលេខបញ្ជាឱ្យរាជរដ្ឋាភិបាលប្រគល់របស់របររត់ពន្ធទាំងអស់នោះ ទៅឱ្យតំណាងរដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្នវៀតណាមខាងត្បូង( ពួកវៀតកុង)នៅទីក្រុងភ្នំពេញ តាមការស្នើសុំរបស់ពួកគេវិញដែរ ប៉ុន្តែ ព្រះអង្គម្ចាស់ស៊ីសុវត្ថិ សិរិមតៈ មិនព្រមដាដាច់ខាត ព្រោះទ្រង់យល់ឃើញថា ការនាំចូលប្រាក់រៀលក្លែងក្លាយដ៏ច្រើនសន្ធឹកសន្ធាប់នោះ នឹងធ្វើឱ្យសេដ្ឋកិច្ចជាតិលិចលង់ជាមិនខាន ។

ពេលនោះដែរ សម្តេចសីហនុ មានការព្រួយបារម្ភពីផែនការចរចាបញ្ចប់សង្គ្រាមនៅវៀតណាមខាងត្បូង របស់និចសុន ប្រធានាធិបតីអាមេរិក ដែរ ព្រោះពេលនោះ និចសុន បម្រុងនឹងដកកងទ័ពអាមេរិកទាំងអស់ ចេញពីវៀតណាមខាងត្បូង ដើម្បីប្តូរយកទាយាទរបស់ខ្លួនជាច្រើន ដែលត្រូវកងទ័ពវៀតកុង-វៀតណាមខាងជើង ចាប់បានជាឈ្លើយសឹក ។

ទន្ទឹមនេះ ព្រះអង្គក៏មានការព្រួយបារម្ភដែរថា ក្រោយពេលកងទ័ពវៀតណាមកុម្មុយនិស្ត ដណ្តើមជ័យជម្នះលើរបបរដ្ឋការក្រុងព្រៃនគរមក តើពួកវៀតកុងព្រមទាំងមហាអំណាចចិន និងសហភាពសូវៀត ផងដែរ អាចជួយដល់ពួកខ្មែរក្រហម ដើម្បីផ្តួលរម្លំព្រះអង្គ និងផ្លាស់ប្តូរប្រទេសកម្ពុជា ឱ្យទៅជាប្រទេសកុម្មុយនិស្តដូចពួកគេដែរទេ?

# ២៦៨
# សម្តេចសីហនុ យាងទៅប្រទេសបារាំង
# លន់ នល់ ប្រឈមមុខជាមួយកងទ័ពវៀតកុង




រូបត្លុកនៅក្នុងទស្សនាវដ្តីឡឺ សង្គម របស់សម្តេចសីហនុ
ចេញផ្សាយលេខ៤៦ ខែខុសតា ឆ្នាំ១៩៦៩ បង្ហាញពីពួកវៀតកុង ចូលមកបោះទីតាំង
ក្នុងទឹកដីខ្មែរហើយ ដុតបំផ្លាញសាលារៀន មន្ទីរពេទ្យ និងផ្ទះខ្មែរទៀត

ក្រោយពីបញ្ចប់សមាជជាតិលើកទី២៨ នោះមក សម្តេចសីហនុ មានអាការៈញ័រក្នុងខ្លួន និងហត់នឿយយ៉ាងខ្លាំង។ ព្រះអង្គក៏បានសម្រេចព្រះទ័យយាងចូលសម្រាកនៅក្នុងមន្ទីរពេទ្យកាល់ម៉ែត ដើម្បីឱ្យក្រុមគ្រូពេទ្យជំនាញ ពិនិត្យព្រះរាជសុខភាព ។

គ្រូពេទ្យជំនាញបញ្ជាក់ថា ព្រះអង្គមានជំងឺទឹកនោមផ្អែម, លើសសារធាតុកូលេស្តេរ៉ូល, អន់ថ្លើម និងឡើងជាតិ អាស៊ីដ ទៀតផង ។

ដោយសារសហការីព្រះអង្គ ចេះតែនាំគ្នាមករំខានដោយសុំចូលគាល់ ដើម្បីសុំព្រះរាជតម្រិះពីបញ្ហាផ្សេងៗ រកពេលសម្រាកព្យាបាលព្រះរោគស្ទើរមិនបាននោះ នៅថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧០ សម្ដេចសីហនុ បានយាងចាកចេញពីប្រទេស ដើម្បីទៅសម្រាកព្យាបាលជំងឺនៅមន្ទីរពេទ្យឯកជនមួយ របស់វេជ្ជបណ្ឌិតបារាំង ម្នាក់ឈ្មោះ ហ្សុក ប៉ាតេ ដែលស្ថិតនៅក្នុងទីប្រជុំជនតូចមួយឈ្មោះហ្គ្រាស នាមាត់សមុទ្រអាហ្គៀរ (Agur) ប្រទេសបារាំង ។

វេជ្ជបណ្ឌិតហ្សុក ប៉ាតេ មិនត្រឹមតែជាគ្រូពេទ្យឯកទេសដ៏ចំណានម្នាក់ប៉ុណ្ណោះទេ គឺថែមទាំងជាមិត្តភក្ដិដ៏ជិតស្និទ្ធរបស់សម្ដេចសីហនុ ផងដែរ។ ជាទម្លាប់ ជារៀងរាល់២ឆ្នាំម្ដង ព្រះអង្គតែងតែយាងទៅសម្រាកនៅទីនោះរយៈពេល ២ខែ ។មុនពេលយាងឡើងយន្តហោះ ព្រះអង្គបានប្រកាសថា ព្រះអង្គនឹងចាកចេញទៅក្រៅប្រទេសរយៈពេលពី៣ទៅ៦ខែឯណោះ ទើបព្រះអង្គយាងនិវត្តត្រលប់មកមាតុប្រទេសវិញ ។

សម្ដេចសីហនុ បានសារភាពថា ការចាកចេញទៅសម្រាកនៅមន្ទីរពេទ្យក្រៅប្រទេសពេលនោះ មិនមែនដោយសារតែបញ្ហាសុខភាពរបស់ព្រះអង្គតែមួយមុខប៉ុណ្ណោះទេ គឺមកពីដោយសារការបាក់ទឹកព្រះទ័យយ៉ាងខ្លាំងផងដែរ ។

ការបាក់ព្រះទ័យនោះ ក៏ព្រោះតែពួកតំណាងរាស្ត្ររបស់ចលនាសង្គមរាស្ត្រនិយម ប្រកាន់ជំហរស្ដាំពេក និងធាប់ជឿតាមឧបាយកលដែលរៀបចំឡើងដោយទ្រង់សិរិមតៈ ដើម្បីបន្ទុះបង្អាប់ព្រះអង្គ ។

ជាមួយគ្នានោះ ព្រះអង្គក៏មានការអាក់អន់ព្រះទ័យជាមួយមេដឹកនាំពួកវៀតកុង-វៀតណាមខាងជើង ដែលព្រះអង្គអនុញ្ញាតឱ្យកងទ័ពពួកគេចូលបោះទីតាំងនៅលើទឹកដីព្រះអង្គនោះ បែរជាពួកគេជួយគាំទ្រដល់ពួកឧទ្ទាមខ្មែរក្រហមដែលជាសត្រូវរបស់ព្រះអង្គទៅវិញ ។

ពិសេស សូម្បីតែពួកមេដឹកនាំចិន ជាកល្យាណមិត្តរបស់ព្រះអង្គក៏បានជួយគាំពារយ៉ាងសកម្មដល់ពួកឧទ្ទាមខ្មែរក្រហម ឱ្យស្រមើស្រមៃធ្វើបដិវត្តន៍វប្បធម៌ ដូច

ខ្លួននោះដែរ ។

ពេលយាងទៅដល់ប្រទេសបារាំង ព្រះអង្គបានជួបជាមួយនាយករដ្ឋមន្ត្រីលន់ នល់ ដែលបានចាកចេញពីប្រទេសទៅព្យាបាលជំងឺ តាំងពីថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៦៩ នោះដែរ ។

ពេលនោះ ក្នុងនាមជានាយករដ្ឋមន្ត្រីរាជរដ្ឋាភិបាលស្រោចស្រង់ជាតិ លន់ នល់ ក៏បានសម្តែងពីទឹកចិត្តស្មោះត្រង់ និងស្វាមីភក្តិ ដែលមិនចេះសាបសូន្យចំពោះព្រះអង្គ និងសូមព្រះរាជតម្រិះពីព្រះអង្គក្នុងការដឹកនាំប្រទេសជាតិបន្តទៀត ។

ប្រភពព័ត៌មានមួយបានបង្ហើបឱ្យដឹងថា ពេលនោះ លន់ នល់ បានស្នើសុំឱ្យព្រះអង្គ មានព្រះរាជតម្រិះពីបញ្ហាវត្តមានកងទ័ពវៀតកុង-វៀតណាមខាងជើង នៅលើទឹកដីកម្ពុជា តើត្រូវធ្វើយ៉ាងណា ក្នុងនាមកម្ពុជា ជាប្រទេសឯករាជ្យ អព្យាក្រឹត មិនចូលបក្សសម្ព័ន្ធ? ។

ក្រោយពីធ្វើដំណើរមកដល់មាតុប្រទេសវិញ នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៧០ លន់ នល់ បានចាប់ផ្តើមចុះធ្វើការត្រួតពិនិត្យដោយផ្ទាល់ នៅតាមបណ្តាខេត្តមួយចំនួនដែលមានព្រំដែនជាប់ជាមួយប្រទេសវៀតណាមខាងត្បូង ពិសេសគឺ ខេត្តរតនគិរី ដែលជាព្រៃលាក់ខ្លួនរបស់ពួកមេឧទ្ទាមខ្មែរក្រហម និងទីតាំងកងទ័ពពួកវៀតកុង-វៀតណាមខាងជើងផងដែរ ។

លន់ នល់ បានប្រជុំនាយទាហាន និងពលទាហានរបស់គាត់នៅទីនោះថា ឱ្យប្រុងប្រៀបត្រៀមខ្លួនធ្វើការប្រយុទ្ធទប់ទល់ជាមួយពួកវៀតណាម ដែលគាត់បានចាត់ទុកថាជាសត្រូវសួពូជរបស់កម្ពុជា ។

ទស្សនាវដ្តីឡឺ សង្គម ( Le Sangkum ) ដែលសម្តេចសីហនុ ជាចាងហ្វាងផ្ទាល់នោះក្នុងច្បាប់ចេញផ្សាយខែមករា ឆ្នាំ១៩៧០ បានចុះផ្សាយបទវិចារណកថាមួយ ជាស្នាព្រះហស្តនិពន្ធដោយសម្តេចសីហនុ មានចំណងជើងថា៖ អនាគតរបស់ប្រទេសកម្ពុជា ក្រោយពេលបញ្ចប់សង្គ្រាមនៅវៀតណាម...។

បទវិចារណកថានេះមានខ្លឹមសារជាអាទិ៍ថា៖ បរាជ័យរបស់អាមេរិកនៅវៀតណាម នឹងបើកចំហផ្លូវឱ្យលទ្ធិកុម្មុយនិស្តចិន និងកុម្មុយនិស្តវៀតណាម ហូរហៀរទៅលើតំបន់អាស៊ីទាំងមូល ហើយប្រសិនបើអាមេរិក យកប្រទេសសៀម, សិង្ហបុរី និងម៉ាឡេស៊ី ធ្វើជារនាំងការពារលទ្ធិកុម្មុយនិស្តនៅអាស៊ីនោះ អាមេរិក ត្រូវដឹងថា បើប្រទេសកម្ពុជា និងឡាវ ក្លាយទៅជាប្រទេសកុម្មុយនិស្តដែរ ពេលនោះគ្រោះថ្នាក់នៃលទ្ធិកុម្មុយនិស្តវៀតណាម និងលទ្ធិកុម្មុយនិស្តម៉ៅនិយម នឹងចូលមកដល់មាត់ទ្វាររបស់ប្រទេសសៀម, សិង្ហបុរី និងម៉ាឡេស៊ី ជាមិនខាន ។

សម្តេចសីហនុ បានសរសេរបន្តថា ពេលកំពុងត្រៀមខ្លួនចាកចេញពីប្រទេសវៀតណាមខាងត្បូង អាមេរិក បានរៀបចំផែនការផ្តួលរម្លំមេដឹកនាំប្រទេសកម្ពុជា និងលាវដែរ ។

សម្តេចសីហនុ ក៏បានសរសេរដែរថា នយោបាយសហភាពសូវៀត នៅភូមិភាគអាស៊ីអាគ្នេយ៍ គឺចង់បង្កើតកម្លាំងម៉្យាង ដើម្បីទប់ទល់ឥទ្ធិពលរបស់ក្រុងប៉េកាំង។ ប៉ុន្តែសហភាពសូវៀត និងសហរដ្ឋអាមេរិក ទំនងជាមិនព្យាយាមរារាំងនយោបាយវៀតណាមូបនីយកម្មលើកម្ពុជា ទេ ពីព្រោះនេះជារង្វាន់តូចតាចមួយ ដែលប្រទេសទាំង២នេះ ត្រូវផ្តល់ទៅឱ្យពួកកុម្មុយនិស្ត ។

សម្តេចសីហនុ សរសេរបន្តទៀតថា ជំនួយយោធាសម្រាប់ប្រទេសព្រះអង្គត្រូវរីងស្ងួត ពេលនេះនៅសល់តែជំនួយរបស់បារាំងប៉ុណ្ណោះ។ ប៉ុន្តែទោះបីយ៉ាងណាយើងត្រូវតែតស៊ូរហូតដល់ដំណក់ឈាមចុងក្រោយ បើទោះបីជាត្រូវប្រើតែដំបង ធ្នូព្រួញ ដូចកាលពីឆ្នាំ១៩៥៣ ឬបាតដៃទទេ ក៏ដោយ ។

ទាក់ទងដល់ការចេញផ្សាយទស្សនាវដ្តី និងសារព័ត៌មានមួយចំនួន ដែលសម្តេចសីហនុ បានបង្កើតឡើងនោះ ព្រះអង្គបានយកជនជាតិបារាំង ពីរនាក់ គឺម្នាក់ឈ្មោះហ្សាល មីយ៉េរ ( Charles Meyer ) និងម្នាក់ទៀត ឈ្មោះហ្សង់ បារ៉េ ( Jean Barre ) មកធ្វើជាអ្នកគ្រប់គ្រងកាសែត និងទស្សនាវដ្តីរបស់ព្រះអង្គព្រមទាំងជាទីប្រឹក្សា ដើម្បីជួយ

ដល់ការងារសំខាន់ក្នុងការដឹកនាំប្រទេសរបស់ព្រះអង្គផងដែរ។



ហ្សាល ម៉ីយ៉េរ

ហ្សាល ម៉ីយ៉េរ (Charles Meyer) កើតនៅថ្ងៃទី១២ ខែមីនា ឆ្នាំ១៩២៣ នៅប្រទេសបារាំង ជាប្រវត្តិវិទូ និងជា អ្នកជំនាញខាងគូរផែនទី។

ដំបូង គាត់បានមកបម្រើការងារឱ្យពួកអាណានិគមបារាំង នៅទីក្រុងព្រៃនគរ។ ចាប់ពីឆ្នាំ១៩៤៦មក គាត់បានផ្លាស់មកបម្រើការងារនៅប្រទេសកម្ពុជា ក្នុងនាមជាជំនួយការដ៏ជិតស្និទ្ធរបស់សម្ដេចសីហនុ រហូតបានក្លាយជាទីប្រឹក្សាកិច្ចការបរទេសរបស់ព្រះអង្គទៀតផង ។

ក្នុងចំណោមមន្ត្រីបរទេសទាំងអស់ ហ្សាល ម៉ីយ៉េរ (Charles Meyer) មនុស្សសំខាន់ជាងគេរបស់ សម្ដេចសីហនុ។ មជ្ឈដ្ឋានខ្លះ ពិសេសពួកអាមេរិក យល់ឃើញថា ហ្សាល ម៉ីយ៉េរ មានទស្សនៈឆ្វេងនិយម និងបាន ជះឥទ្ធិពលអាក្រក់ទៅលើសម្ដេចសីហនុ ។

គេមិនដឹងច្បាស់ថា តើមានទំនាក់ទំនងអ្វី បានជាសម្ដេចសីហនុ ជឿទុកចិត្តយកគាត់មកធ្វើជាមនុស្សសំខាន់សម្រាប់ព្រះអង្គដូច្នេះទេ ។

តែអ្វីដែលច្បាស់ពិតប្រាកដគឺសម្ដេចសីហនុ ទទួលស្គាល់ថាគាត់ជាមនុស្សដែលមានប្រាជ្ញាឈ្លាសវៃ និងមានថាមពលបំផុត ហើយក៏ជាមនុស្សដែលមានគំនិតប្រឆាំងនឹងសហរដ្ឋអាមេរិកផងដែរ ។

ជាមួយតួនាទីជាទីប្រឹក្សាកិច្ចការបរទេស គាត់មានតួនាទីសំខាន់ៗជាច្រើនទៀតដូចជា សរសេរសុន្ទរកថាផ្សេងៗ ថ្វាយសម្ដេចសីហនុ និងកែសម្រួលខ្លឹមសារខ្លះៗនៃសុន្ទរកថាតាមការសព្វព្រះទ័យរបស់ព្រះអង្គ ។



ហ្សាល មីយ៉េរ (រូបក្នុងរង្វង់) ពេលសម្តេចសីហនុ ទៅជួបមេដឹកនាំចិន ខែតុលា ឆ្នាំ១៩៦៥

ជាមួយគ្នានោះ គាត់ក៏ជាអ្នកនិពន្ធអត្ថបទឲ្យកាសែតរ៉េអាលីតេកាំបូតហ្សៀន (réalité cambodgienne) និងរៀបចំ ឱ្យសម្តេចសីហនុ ធ្វើសន្និសីទកាសែតជាមួយអ្នកកាសែតបរទេសផងដែរ ។

គាត់មិនត្រឹមតែមានទំនាក់ទំនងនៅក្នុងសហគមន៍បារាំង និងពួកមន្ត្រីខ្មែរ ព្រមទាំងអ្នករកស៊ីឯកជនធំៗប៉ុណ្ណោះទេ គឺគាត់ថែមទាំងមានទំនាក់ទំនងជិតស្និទ្ធជាមួយពួកមន្ត្រីស្ថានទូតចិន, ស្ថានទូតវៀតណាមខាងជើង និងស្ថានទូតរដ្ឋាភិបាលបាលបណ្តោះអាសន្នវៀតណាមខាងត្បូង (វៀតកុង) នៅទីក្រុងភ្នំពេញ ទៀតផង ។

ហ្សាល មីយ៉េរ (Charles Meyer) មានប្រពន្ធជាជនជាតិចិនហុងកុង ។

ក្រៅពីគាត់ គ្មានជនបរទេសណាផ្សេងទៀត ដែលមានឱកាសបាននៅជិតសម្តេចសីហនុ ឡើយ ។

ក្នុងនាមជាទីប្រឹក្សាកិច្ចការបរទេស គាត់ធ្វើឲ្យសម្តេចសីហនុ អស់ជំនឿលើសហរដ្ឋ

អាមេរិក ហើយងាកទៅរកប្រទេសចិនកុម្មុយនិស្ត តែគាត់ធ្វើឲ្យសម្តេចសីហនុ នៅតែរក្សាទំនាក់ទំនងជិតស្និទ្ធជាមួយប្រទេសបារាំង ដដែល ។

ចំណែក ហ្សង់ បារ៉េ ( Jean Barre ) ជាទីប្រឹក្សារបស់សម្តេចសីហនុ ម្នាក់ដែរនោះ មានតួនាទីជាចាងហ្វាងកាសែតរ៉េអាលីតេកាំបូតហ្សែន ( réalité cambodgienne ) ក៏មានគំនិតឆ្វេងនិយមដូចហ្សាល ម៉ីយ៉េរ ( Charles Meyer ) ដែរ ។

នៅពេលសម្តេចសីហនុ ធ្វើសន្និសីទកាសែតជាមួយពួកបរទេសម្តងៗ គេឃើញហ្សង់ បារ៉េ ( Jean Barre ) នៅអង្គុយក្បែរជានិច្ច។ ពេលព្រះអង្គទ្រង់ស្វៀមរកនឹកមិនឃើញចំណុចសំខាន់អ្វីមួយ ដែលត្រូវឆ្លើយបំភ្លឺទៅនឹងសំណួរ អ្នកកាសែតបរទេស ព្រះអង្គគ្រាន់តែងាកមុខទៅរកហ្សង់ បារ៉េ ( Jean Barre ) ដែលអង្គុយក្បែរនោះតែបន្តិច គាត់នឹងជួយបង្កើបចំណុចសំខាន់នោះឱ្យព្រះអង្គនឹកឃើញភ្លាម ។

ក្នុងអំឡុងពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៦០ សម្តេចសីហនុ បានបង្កើតទស្សនាវដ្តីកាំប៊ុយហ្សា( Kambuja ) និង ទស្សនាវដ្តីឡឺសង្គម( Le Sangkum ) ដោយមានហ្សង់ បារ៉េ ( Jean Barre ) និងជនជាតិបារាំង មួយចំនួនទៀត ជាអ្នកចាត់ចែង និងនិពន្ធអត្ថបទ ។

ហ្សង់ បារ៉េ ( Jean Barre ) ចូលចិត្តទទួលទានអាហារឆ្ងាញ់ៗ។ នៅពេលសម្តេចសីហនុរៀបចំពិធីជប់លៀងជាផ្លូវការណាមួយ តែងតែមានវត្តមានគាត់ជានិច្ច។ ក្រៅពីនេះ គេតែតែងឃើញគាត់ចូលទៅផឹកស៊ីនៅតាមភោជនីយដ្ឋានធំៗនៅទីក្រុងភ្នំពេញ ហើយពេលចេញមកវិញគាត់តែងតែបណ្តើរប្រុសក្មេងខ្មែរមកជាមួយ ដោយគ្មានខ្វល់ខ្វាយពីការពេបជ្រាយគាត់ពើរឿងស្នេហាភេទដូចគ្នាបន្តិចទាល់តែសោះ ។

ក្រៅពី ហ្សាល ម៉ីយ៉េរ ( Charles Meyer ) និងហ្សង់ បារ៉េ ( Jean Barre )ជនជាតិបារាំង ជាទីប្រឹក្សា សម្តេចសីហនុ ក៏មានជំនួយការខាងភាសាអង់គ្លេស ឈ្មោះដូណាល់ឡង់កាស្ទ័រ ( Donald Lancaster ) និងអតីតមន្ត្រីក្រសួងការបរទេសអង់គ្លេស ម្នាក់ទៀត ព្រមទាំងអ្នកកាសែតបារាំង ឈ្មោះ ព្យែរ ហ្វិច្ស( Pierre Fuchs ) និងប៊ែរណា ហាម៉ែល ( Bernard Hamel ) ផងដែរ ។







ទស្សនាវដ្ដី LE SANGKUM និងទស្សនាវដ្ដី KAMBUJA របស់សម្ដេចសីហនុ

នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ១៩៧០ កាសែតវ៉ាស៊ីនតោនប៉ុស្ដិ៍របស់អាមេរិក បានដកស្រង់បន្ទូលរបស់សម្ដេចសីហនុ ដែលកំពុងគង់នៅប្រទេសបារាំង មកចុះផ្សាយថាសម្ដេចសីហនុ បានប្រកាសថា សហរដ្ឋអាមេរិក នឹងត្រូវបង្ខំចិត្តរក្សាវត្តមានកងទ័ពរបស់ខ្លួននៅវៀតណាមខាងត្បូង បន្តទៀត ទោះបីនៅអាត្លង់ទិក មានស្ថានការណ៍បែបណា ក៏ដោយ ។

នៅថ្ងៃដដែលនេះដែរ ទស្សនាវដ្ដីប្រចាំខែមួយរបស់បារាំង បានចុះផ្សាយថា សម្ដេចសីហនុ ប្រមុខរដ្ឋកម្ពុជា ដែលកំពុងស្នាក់នៅព្យាបាលរោគនៅប្រទេសបារាំងបានធ្វើការទស្សន៍ទាយទុកថា សហរដ្ឋអាមេរិក នឹងរក្សាកងទ័ពរបស់ខ្លួននៅក្នុងប្រទេសវៀតណាមខាងត្បូង បន្តទៀត ព្រោះថា ប្រសិនបើសហរដ្ឋអាមេរិក ដកកងទ័ពរបស់ខ្លួនទាំងស្រុង ចេញពីប្រទេសវៀតណាមនោះ គឺ៖ ទី១- វានឹងធ្វើឱ្យរដ្ឋាភិបាលក្រុងព្រៃនគរសព្វថ្ងៃត្រូវដួលរលំ និងមានការបង្ហូរឈាមគ្នា។ ទី២- វានឹងធ្វើឱ្យប្រទេសរបស់ព្រះអង្គ និងប្រទេសជិតខាង ក្លាយទៅជារណបរបស់ចិន ជាមិនខាន។ ទី៣-បណ្ដាប្រទេសនៅអាស៊ីទាំងអស់នឹងចាត់ទុកថា នេះជាបរាជ័យដ៏អាម៉ាស់បំផុតរបស់សហរដ្ឋអាមេរិក ។

សម្តេចសីហនុ បានបញ្ជាក់ថា ពេលកងទ័ពសហរដ្ឋអាមេរិក ដកខ្លួនទាំងស្រុង ចេញពីប្រទេសវៀតណាមនោះ ប្រជាពលរដ្ឋវៀតណាមខាងត្បូង នឹងបោះឆ្នោតគាំទ្រ ឱ្យពួកវៀតកុង ឡើងកាន់អំណាចនៅក្រុងព្រៃនគរ ព្រោះថ្មីៗនេះ ព្រះអង្គបានជួបអតីតមិត្តរួមថ្នាក់ជាច្រើនដែលជាអ្នកជំនួញធំៗ ធ្លាប់សិក្សានៅវិទ្យាល័យក្រុងព្រៃនគរ ជាមួយគ្នានោះ ពួកគេបានទូលព្រះអង្គថា បើមានការបោះឆ្នោតនៅវៀតណាមខាងត្បូង ពួកគេនឹងបោះឆ្នោតគាំទ្រពួកវៀតកុង...។

ទោះបីយ៉ាងណា ក៏សម្តេចសីហនុ យល់ថា សហរដ្ឋអាមេរិក នឹងមិនដកកងទ័ពរបស់ខ្លួនឱ្យអស់រលីង ពីតំបន់អាស៊ីអាគ្នេយ៍នោះទេ ព្រោះតុល្យភាពកម្លាំងនឹងត្រូវធ្លាក់ចុះ ហើយកម្ពុជា និងប្រទេសជិតខាងមួយចំនួនទៀត នឹងក្លាយទៅជារណបរបស់ប្រទេសចិន ។ ដូច្នេះអាមេរិក ត្រូវតែអនុវត្តគោលនយោបាយថ្មី ដោយផ្អែកលើឯករាជ្យជាតិ និងការអភិវឌ្ឍផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ចនៅតាមបណ្តាប្រទេសទាំងឡាយនៅអាស៊ីអាគ្នេយ៍នេះ ។

ពេលនោះ អ្នកធ្វើយធ្វងព័ត៌មានកាសែត ញូវយ៉កថៃម បានរាយការណ៍ទៅទីស្នាក់ការកាសែតរបស់ខ្លួននៅសហរដ្ឋអាមេរិកថា ក្រោយពីស្នាក់នៅក្នុងប្រទេសកម្ពុជា រយៈពេល ២សប្តាហ៍មក ទើបដឹងថា សម្តេចសីហនុ បានហាមប្រាម មន្ត្រីរាជរដ្ឋាភិបាលទាំងអស់ មិនឱ្យជួបធ្វើសម្ភាសជាមួយអ្នកកាសែតបរទេស ហើយថា សម្តេចសីហនុ ជឿជាក់ថា នៅពេលអនាគត ចិននឹងកាន់កាប់អាស៊ីអាគ្នេយ៍ ប៉ុន្តែបច្ចុប្បន្ន ប្រទេសរបស់ព្រះអង្គកំពុងរងនូវការគំរាមកំហែងពីប្រទេសវៀតណាម ។

ពេលសម្តេចសីហនុ យាងចេញទៅក្រៅប្រទេស រាជរដ្ឋាភិបាលស្រោចស្រង់ជាតិ ចាប់ផ្តើមប្រឈមមុខជាមួយកងទ័ពវៀតកុង-វៀតណាមខាងជើង ដែលបោះទីតាំងនៅលើទឹកដីកម្ពុជា និងរារាំងមិនឱ្យដឹកជញ្ជូនអាវុធ ស្បៀង ទៅឱ្យកងទ័ពនេះ ដូចមុនៗទៀត ។

# ២៦៩
# បាតុកម្មវាយស្ថានទូតវៀតកុង-វៀតណាមខាងជើង




បាតុកម្មវាយស្ថានទូតវៀតកុង-វៀតណាមខាងជើង ព្រឹកថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៧០

*ក្រោយពេលឧត្តមសេនីយ៍លន់ នល់ វិលត្រលប់មកដល់មាតុប្រទេសវិញបាន ៩ថ្ងៃ គឺនៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ១៩៧០ សម្តេចសីហនុ ក៏បានផ្ញើសារទូរលេខមួយមកប្រាប់ថា ព្រះអង្គនឹងបន្តដំណើរយាងទៅទីក្រុងមូស្គូ និងទីក្រុងប៉េកាំង ដើម្បីធ្វើការសម្របសម្រួលជាមួយមេដឹកនាំសហភាពសូវៀត និងចិនឱ្យជួយធ្វើអន្តរាគមន៍ឱ្យ កងទ័ពវៀតកុង-វៀតណាមខាងជើងដកចេញទឹកដីកម្ពុជា ។*

*នៅដើមខែមីនា ឆ្នាំ១៩៧០ ក៏មានពាក្យចចាមអារ៉ាមមួយថា មានសត្វក្រពើសមួយ*

ក្បាល បានបង្ហាញខ្លួន នៅទន្លេចតុមុខ ធ្វើឱ្យមានការ ភ្ញាក់ផ្អើល ហើយមានមនុស្សជាច្រើន បាននាំគ្នាមកឈរនៅសួនច្បារមាត់ទន្លេ ដើម្បីរង់ចាំមើលសត្វក្រពើនោះ ។

បន្ទាប់មកទៀត ក៏មានមនុស្សម្នាក់ បានឡើងទៅលើបង្គោលសសរព្រះអង្គដង្កើ ដែលនៅជាប់មាត់ទន្លេមុខព្រះបរមរាជវាំងទៀត ធ្វើឱ្យប្រជារាស្ត្រខ្មែរភាគច្រើនលើសលប់ ដែលជឿលើអបិយជំនឿ យល់ថា ស្រុកទេសជាតិនឹងមានហេតុការណ៍អាក្រក់ជាមិនខាន។

២ថ្ងៃជាប់ៗគ្នា គឺថ្ងៃទី០៨ និង០៩ ខែមីនា ឆ្នាំ១៩៧០ ដោយមានបញ្ជាពីរាជរដ្ឋាភិបាលផងដែរ អាជ្ញាធរខេត្តស្វាយរៀង បានបំផុសប្រជារាស្ត្រនៅតាមភូមិធំៗមួយចំនួននៅក្នុងស្រុករមាសហែក, ស្រុកចន្ទ្រា, ស្រុកកំពង់រោទិ៍ និងរំដួល ជាប់ព្រំដែនវៀតណាមខាងត្បូង ឱ្យនាំគ្នាបះបោរធ្វើបាតុកម្មប្រឆាំងនឹងវត្តមានកងទ័ពវៀតកុង-វៀតណាមខាងជើង ដែលបានបោះទីតាំងក្នុងភូមិទាំងនោះ ដោយនៅមួយកន្លែងៗមានប្រជារាស្ត្រចូលរួម ពី២០០ ទៅ៣០០នាក់ ។

ទោះបីកងទ័ពវៀតកុង-វៀតណាមខាងជើងនៅទីនោះ ព្យាយាមធ្វើអំពើល្អមកលើប្រជាកសិករខ្មែរនៅទីនោះយ៉ាងណាក៏ដោយ ក៏ពួកគាត់មិនសប្បាយចិត្តចំពោះកងទ័ពបរទេសនេះដែលហាមឃាត់ពួកគាត់មិនឱ្យដើរហើរសេរី នៅក្នុងកន្លែងមួយចំនួនក្នុងភូមិស្រុករបស់ពួកគាត់ និងមិនសប្បាយចិត្តពីរឿងកងទ័ពវៀតកុង-វៀតណាម ខាងជើងប្រមូលពួកគាត់ឱ្យបររទេះគោរទេះក្របី ទៅជួយលីសែង និងដឹកជញ្ជូនគ្រាប់រំសេវស្បៀងអាហារឱ្យពួកគេផងដែរ ។

នៅថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៧០ មុនពេលយាងចូលជួបប្រធានាធិបតីបារាំង ប៉ុមពីឌូ នៅក្នុងវិមានអេលីហ្សេ សម្តេចសីហនុ ក៏បានជ្រាបពីរឿងប្រជារាស្ត្រខ្មែរនៅខេត្តស្វាយរៀងធ្វើបាតុកម្មបណ្តេញកងទ័ពវៀតកុង-វៀតណាមខាងជើង ឱ្យចាកចេញពីខេត្តស្វាយរៀង នោះដែរ។ ព្រះអង្គបានថ្លែងប្រាប់ក្រុមអ្នកកាសែតបរទេសដែលចោមរោមធ្វើបទសម្ភាសថា ព្រះអង្គចាត់ទុកការធ្វើបាតុកម្មនោះ ជារឿងធម្មតា ។

ក្រោយពីបានឮសម្តេចសីហនុ មានបន្ទូលបែបនេះ សមាជិករាជរដ្ឋាភិបាលនៅភ្នំពេញខ្លះ បានអះអាងថា នេះជាការបង្ហាញឱ្យឃើញនូវការសព្វព្រះទ័យរបស់ព្រះអង្គចំពោះរាជរដ្ឋាភិបាល ដែលបានរៀបចំឱ្យមានបាតុកម្មដោយសន្តិវិធី បែបនេះ ។

នៅព្រឹកថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៧០ មានបាតុកម្មដ៏ធំមួយនៅទីក្រុងភ្នំពេញ ។ ប្រភពមួយបានអះអាងថា នល់ ណុន ប្អូនប្រុសរបស់ឧត្តមសេនីយ៍លន់ នល់ ជាអ្នករៀបចំឱ្យមានបាតុកម្មនេះ។ សិស្សនិស្សិតនៅតាមគ្រឹះស្ថានសិក្សា និងមន្ត្រីរាជការនៅតាមក្រសួងនានា ត្រូវបានគេប្រមូលឱ្យទៅចូលរួមធ្វើបាតុកម្មនៅមុខស្ថានទូត រដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្នវៀតណាមខាងត្បូង ដែលស្ថិតនៅតាមបណ្តោយផ្លូវលេខ ២១៨( ម្តុំខាងមុខស្ថានទូតកូរ៉េខាងត្បូង សព្វថ្ងៃ) ។

សិស្សវិទ្យាល័យព្រះស៊ីសុវត្ថិ និងវិទ្យាល័យព្រះយុគន្ធរ ដែលស្ថិតនៅមិនឆ្ងាយប៉ុន្មានពីស្ថានទូតនោះ បាននាំគ្នាហែក្បួនដោយថ្មើរជើងមកដល់មុខស្ថានទូតនេះមុនគេ ដោយមានសរសេរអក្សរនៅលើបដាធំៗថា “ វៀតកុង ត្រលប់ទៅផ្ទះឯងវិញទៅ!( Vietcong go home! ) ” និង “ កម្ពុជា មិនមែនជាទឹកដីរបស់ពួកវៀតកុង ទេ ” ...ជាដើម ។

ពួកមន្ត្រីរាជការ និងពួកទាហានស្លៀកពាក់ស៊ីវិលជាច្រើនក៏ត្រូវបានគេបញ្ជូនឱ្យទៅចូលរួម និងជួយលើកទឹកចិត្តដល់សិស្សនិស្សិតទាំងអស់នោះផងដែរ។ មិនតែប៉ុណ្ណោះ អ្នករៀបចំបង្កើតឱ្យមានបាតុកម្មនេះ ក៏បានបញ្ចូលពួកខ្មែរកម្ពុជាក្រោម ដែលមានកំហឹងឈឺចាប់ជាមួយវៀតណាម ជាយូរមកហើយនោះ ឱ្យចូលរួមជាច្រើនរយនាក់ផងដែរ ។

នៅទីបំផុត កំហឹងរបស់បាតុករកាន់តែពុះកញ្ជ្រោលខ្លាំងឡើងៗ អ្នករៀបចំធ្វើបាតុកម្មមិនអាចត្រួតត្រាសភាពការណ៍បាន ក្រុមបាតុករបានឈានដល់ការទម្លាយទ្វាររបងស្ថានទូតចូលទៅខាងក្នុងវាយកម្ទេចគ្រឿងសម្ភារៈ និងឯកសារផ្សេងៗទាំងប៉ុន្មាននៅក្នុងស្ថានទូតខ្ទេចខ្ទី អស់គ្មានសល់។ រថយន្តស្ថានទូត៣-៤គ្រឿង ត្រូវក្រុមបាតុករនាំគ្នារុញចេញមកកណ្តាលថ្នល់ផ្លូវ ហើយនាំគ្នាលើកបំបះឱ្យក្រឡាប់ផ្ងារជើងឡើងលើ

រួចដុតឱ្យឆាបឆេះសន្ធោសន្ធៅ ។

បាតុករផ្សេងៗទៀត បាននាំគ្នាជញ្ជូនសម្ភារៈរបស់របរ ដែលនៅក្នុងស្ថានទូតទាំងប៉ុន្មានយកមកបោះលើអណ្ដាតភ្លើងដែលកំពុងឆាបឆេះរថយន្តនោះ ធ្វើឱ្យអណ្ដាតភ្លើងកាន់តែឆេះខ្លួលខ្លាញ់ថែមទៀត ។

រថយន្តពន្លត់អគ្គិភ័យរបស់កម្លាំងសមត្ថកិច្ចប៉ូលិស ក៏បានបាញ់ទឹកស្រោចទៅលើគេហដ្ឋានទាំងឡាយ ដែលនៅក្បែរៗនោះ ដើម្បីការពារការឆេះរាលដាលផងដែរ ។

ពេលនោះ បុគ្គលិកស្ថានទូតស្ថានទូតរដ្ឋាភិបាលបដិវត្តន៍បណ្ដោះអាសន្នវៀតណាមខាងត្បូង ដែលគេចខ្លួនមិនទាន់ ត្រូវក្រុមបាតុករចាប់វាយធ្វើបាប ហើយខ្លះទៀតត្រូវបាតុករដកហូតយកនាឡិកាដៃ និងកាបូបដាក់លុយជាដើម ។

បន្តិចក្រោយមក ទើបមានកម្លាំងសមត្ថកិច្ចចូលទៅរំដោះបុគ្គលិកស្ថានទូតដែលខ្លះរងរបួសបែកក្បាល ហូរឈាមដោកអាវចេញពីហ្វូងបាតុករ មកដាក់ក្នុងរថយន្តរួចបើកនាំចេញទៅបាត់ ។





បាតុកម្មវាយស្ថានទូតវៀតកុង-វៀតណាមខាងជើង ព្រឹកថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៧០

ហ្វូងបាតុកររបស់សិស្សវិទ្យាល័យឥន្ទ្រទេវី និងវិទ្យាល័យសង្គមរាស្ត្រនិយម(បឹងកក់) ដែលស្ថិតនៅតំបន់ទួលគោក ឆ្ងាយពីស្ថានទូតនោះ ទម្រាំនឹងដើរហែក្បួនមកដល់ស្ថានទូតនេះត្រូវរងការវាយប្រហារ ដោយសារសិស្សនិស្សិតមកពីវិទ្យាល័យនានា និងមហាវិទ្យាល័យដែលនៅជិតៗនោះស្ទើរខ្ទេចខ្ទីអស់មុនបាត់ទៅហើយ ។

ក្រោយពីវាយកម្ទេចស្ថានទូតរដ្ឋាភិបាលបដិវត្តន៍បណ្ដោះអាសន្នវៀតណាមខាងត្បូង នៅផ្លូវលេខ ២១៤ ដុតបំផ្លាញរថយន្ត៣-៤គ្រឿង និងសម្ភារៈឯកសារផ្សេងៗទៀតនៅកណ្ដាលទ្រូងផ្លូវមិនទាន់ឆេះអស់ផង ក្រុមបាតុករបានដង្ហែក្បួនបន្តទៀតទៅតាមបណ្ដោយមហាវិថីព្រះមុនីវង្ស តម្រង់ទៅរកភ្លើងស្តុបបូកគោ ជាបន្តទៀត។

នៅប្រមាណ១០០ម៉ែត្រខាងជើងភ្លើងស្តុបបូកគោនោះ ក្រុមបាតុករបាននាំគ្នាសម្រុកចូលស្ថានទូតវៀតណាមខាងជើង (ក្រោយការបោះឆ្នោតឆ្នាំ១៩៩៣ ទីតាំងនិងអគារនេះ ត្រូវបានរាជរដ្ឋាភិបាល យកទៅធ្វើជាវិទ្យាស្ថានស្ថិតិ) ។

ពេលក្រុមបាតុករកំពុងសម្រុកចូលទៅក្នុងស្ថានទូតវៀតណាមខាងជើង យ៉ាងណែនណាន់តាន់តាប់នោះ ក៏នាំគ្នាភ្ញាក់ផ្អើលចោឡោ ព្រោះមានអ្នកខ្លះស្រែកថា៖“មានគ្រាប់បែកនៅខាងក្នុងៗ!” ក្រុមបាតុករក៏ប្រជ្រៀតគ្នារត់ចេញមកក្រៅវិញ ។

ក្រោយពេលដឹងថា គ្មានគ្រាប់បែកអ្វីនៅក្នុងអគារស្ថានទូតនោះ ពួកគេក៏នាំគ្នាសម្រុកចូលទៅវាយបំផ្លាញសម្ភារៈឯកសារ ផ្សេងៗ និងរុញរថយន្តចេញមកដុតបំផ្លាញ ហើយយកទង់ជាតិរបស់សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម (វៀតណាមខាងជើង)មកគ្របលើអណ្ដាតភ្លើងដែលកំពុងឆាបឆេះរថយន្តនោះទៀតផង ។

ក្រុមបាតុករបានប្រទះឃើញរូបចម្លាក់សម្ដេចសីហនុ (រូបចម្លាក់ពាក់កណ្ដាលខ្លួន)លាបពណ៌ទឹកមាស ដែលដាក់តាំងនៅក្នុងស្ថានទូត ក៏នាំគ្នាលើកកាន់ដង្ហែចេញមកក្រៅស្រែកហ៊ោកញ្ជ្រៀវជុំវិញអណ្ដាតភ្លើង ដែលកំពុងឆាបឆេះរថយន្ត នៅលើទ្រូងផ្លូវព្រះមុនីវង្ស ហើយនាំគ្នាស្រែកខ្លាំងៗថា៖“ជយោ! សម្ដេចឪៗ” ជាប់ជានិច្ច ។

បន្ទាប់មកទៀត ក្រុមបាតុករបាននាំគ្នាទៅវាយបំផ្លាញសម្ភារៈឯកសារ និង

សៀវភៅផ្សេងៗទៀតនៅបណ្ណាល័យរបស់ស្ថានទូតវៀតណាមខាងជើង ដែលស្ថិតនៅតាមបណ្តោយផ្លូវព្រះមុនីវង្ស ដែរ ។ តែស្ថិតនៅខាងត្បូងភ្លើងស្តុបបូកគោនោះប្រហែលជាង១០០ម៉ែត្រនោះ ។ តែនៅទីនោះ ក្រុមបាតុករមិនមានធ្វើសកម្មភាពដុតបំផ្លាញរថយន្តទៀតទេ។



បាតុករវាយបំផ្លាញសម្ភារៈឯកសារនៅបណ្ណាល័យស្ថានទូតវៀតណាមខាងជើង

ការវាយកម្ទេចស្ថានទូតទាំង២នេះ ធ្វើឱ្យមន្ត្រីទូតវៀតណាម ៣នាក់រងរបួសត្រូវកម្លាំងសមត្ថកិច្ចប៉ូលិសចូលទៅអន្តរាគមន៍យកទៅរក្សាទុកនៅស្នងការដ្ឋាននគរបាលក្រុងមួយរយៈ។ បន្ទាប់មកពួកគេក៏បានសុំទៅជ្រកកោននៅក្នុងស្ថានទូតប្រទេសជាមិត្តផ្សេងទៀត ។

ការវាយកម្ទេចស្ថានទូតវៀតកុង-វៀតណាមខាងជើង ត្រូវបានបញ្ចប់ក៏ពិតមែនតែក្រុមបាតុករក៏បានបន្តធ្វើសកម្មភាពវាយបំផ្លាញហាងលក់ទំនិញ និងផ្ទះសម្បែងរបស់ជនជាតិវៀតណាម ជាច្រើនកន្លែងបន្តទៀត ។

ចំណែករដ្ឋាភិបាលក្រុងព្រៃនគរ(វៀតណាមខាងត្បូង) វិញ បានបង្ហាញនូវទឹកចិត្តសោមនស្សរីករាយយ៉ាងខ្លាំង ចំពោះ ព្រឹត្តិការណ៍បាតុកម្មវាយកម្ទេចស្ថានទូតវៀតកុង-វៀតណាមខាងជើងនេះ ដោយរដ្ឋមន្ត្រីការបរទេសរដ្ឋាភិបាលក្រុងព្រៃនគរ បានផ្តល់បទសម្ភាសប្រាប់កាសែតអាអេហ្វប៉េ(AFP)របស់បារាំងថា បាតុកម្មរបស់ប្រជាពលរដ្ឋខ្មែរ វាយស្ថានទូតទាំង២នេះ ពិតជាត្រឹមត្រូវ ហើយថា ទង្វើរបស់ពួកវៀតណាមកុម្មុយនិស្ត យូរឬឆាប់ ត្រូវតែទទួលបាននូវប្រតិកម្មបែបនេះ ព្រោះពួកគេបានបំផ្លាញអព្យាក្រឹតភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ។

នៅថ្ងៃទី១២ ខែមីនា ឆ្នាំ១៩៧០ នៅចំពោះមុខក្រុមអ្នកកាសែតបារាំង និងអ្នកកាសែតអន្តរជាតិផ្សេងៗទៀត នៅក្រុងប៉ារីស សម្តេចសីហនុ បានមានបន្ទូលថា មុននឹងត្រលប់ទៅប្រទេសកម្ពុជាវិញ ព្រះអង្គនឹងយាងទៅកាន់ទីក្រុងមូស្គូ និងទីក្រុងប៉េកាំងដើម្បីស្នើសុំឱ្យមេដឹកនាំសហភាពសូវៀត និងចិន ជួយធ្វើអន្តរាគមន៍ យ៉ាងណាឱ្យកងទ័ពវៀតកុង-វៀតណាមខាងជើង ចាកចេញពីទឹកដីកម្ពុជា។ ព្រះអង្គបានបញ្ជាក់ប្រាប់ក្រុមអ្នកកាសែតថា មេដឹកនាំសហភាពសូវៀត និងចិន ត្រូវតែធ្វើការជ្រើសរើសរវាងពួកដែលធ្វើឱ្យប្រទេសកម្ពុជា ក្លាយទៅជាប្រទេសកុម្មុយនិស្ត និងពួកដែលជួយរក្សាប្រទេសកម្ពុជាឱ្យទៅជាអព្យាក្រឹត? ប្រសិនបើពួកគេបដិសេធ មិនជួយធ្វើអន្តរាគមន៍ឱ្យកងទ័ព វៀតកុង-វៀតណាមខាងជើង ដកចេញពីកម្ពុជាទេ ពេលប្រទេសកម្ពុជា ងាកទៅរកសហរដ្ឋអាមេរិក វិញនោះ ពួកគេកុំបន្ទោសព្រះអង្គឱ្យសោះ ។

នៅថ្ងៃសុក្រ ទី១៣ ខែមីនា ឆ្នាំ១៩៧០ កាសែតឡឺម៉ុងដ៍ របស់បារាំង បានចុះផ្សាយព័ត៌មានស្តីពីការធ្វើបាតុកម្មវាយកម្ទេចស្ថានទូតវៀតកុង-វៀតណាមខាងជើង កាលពីថ្ងៃពុធ ទី១១ ខែមីនា នោះដែរ និងបានដកស្រង់សម្តី អ្នកនាំពាក្យរបស់សម្តេចសីហនុថា តាមការគ្រោងទុក ព្រះអង្គត្រូវចាកចេញពីប្រទេសបារាំង យាងទៅបំពេញទស្សនកិច្ចនៅសហភាពសូវៀត រយៈពេល៥ថ្ងៃ(ពីថ្ងៃទី១៣ ដល់ថ្ងៃទី១៨ ខែមីនា) និងយាងទៅបំពេញទស្សនកិច្ចនៅប្រទេសចិន បន្តទៀត រយៈពេល៥ថ្ងៃ រហូតដល់ថ្ងៃទី២៤ ខែមីនា ទើបព្រះ

អន្តចាកចេញពីទីក្រុងសៀងហៃ វិលត្រលប់ទៅមាតុភូមិកម្ពុជា វិញ ។

នៅរសៀលថ្ងៃទី១៣ ខែមីនា នោះដែរ សម្តេចសីហនុ បានផ្ញើសារទូរលេខមួយមកថ្វាយព្រះមហាក្សត្រិយានី កុសុមៈ ជាព្រះមាតាដែលនៅទីក្រុងភ្នំពេញ មានខ្លឹមសារថា៖ ទូលបង្គំបានដឹងដំណឹងដ៏ក្រៀមក្រំពីការធ្វើបាតុកម្មហិង្សា វាយកម្ទេចស្ថានទូតនៃសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម( វៀតណាមខាងជើង) និងស្ថានទូតរដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្នវៀតណាមខាងត្បូង( វៀតកុង) ដែលបង្កឡើងដោយជនរួមជាតិយើងមួយចំនួន ហើយទូលបង្គំក៏បានដឹងច្បាស់ពីមូលហេតុ ដែលជំរុញឱ្យជនរួមជាតិយើងផ្ទុះកំហឹងបែបនេះដែរ។ ប៉ុន្តែ ទូលបង្គំស្ទើរតែមិនជឿថា ជនរួមជាតិយើងឈានដល់ការប្រព្រឹត្តអំពើជ្រុលហួសហេតុ ដែលផ្ទុយពីផលប្រយោជន៍ដ៏ឧត្តុង្គឧត្តម និងផ្ទុយពីកិត្តិនាមដ៏ល្អប្រពៃរបស់ប្រទេសជាតិយើង ។

ពិតហើយដែលថា ប្រទេសជាតិ ដែលយើងស្រឡាញ់ជាង ជីវិតយើងទៅទៀតនោះកំពុងស្ថិតនៅក្នុងគ្រោះថ្នាក់ ប៉ុន្តែអ្វីដែលយើងមិនអាចបញ្ចៀសគ្រោះថ្នាក់នោះបាន គឺដោយសារតែការវាយកម្ទេចស្ថានទូតគេ..។

ទូលបង្គំជឿជាក់ថា ព្រឹត្តិការណ៍ដ៏ធ្ងន់ធ្ងរនេះ ត្រូវបានក្រុមឥស្សរជនមួយចំនួនជាអ្នករៀបចំឡើង ដើម្បីបំផ្លាញជាស្ថាពរនូវចំណងមិត្តភាពរបស់ប្រទេសកម្ពុជា ជាមួយបណ្តាប្រទេសសង្គមនិយម និងរុញច្រានប្រទេសយើងឱ្យធ្លាក់ក្នុងកណ្តាប់ដៃរបស់ប្រទេសមហាអំណាចជាពួកចក្រពត្តិនិយម និងមូលធននិយម តែប៉ុណ្ណោះ ។

សារទូរលេខដដែលបានបន្តថា ពួកឥស្សរជនទាំងអស់នោះ គិតតែផលប្រយោជន៍ផ្ទាល់ខ្លួន និងបក្ខពួករបស់គេ ជាងផលប្រយោជន៍ប្រទេសជាតិ។ ពួកគេឆ្លៀតឱកាសពេលទូលបង្គំអវត្តមាននៅក្នុងប្រទេស ដើម្បីសម្រេចគោលបំណងរបស់ពួកគេ ។ ដូច្នេះទូលបង្គំនឹងវិលត្រលប់ទៅប្រទេសវិញ ដើម្បីពិភាក្សាជាមួយប្រជារាស្ត្រ និងកងទ័ព ដើម្បីស្នើសុំឱ្យមានការធ្វើប្រជាមតិជ្រើសរើសមួយ។ បើប្រជារាស្ត្រ និងកងទ័ពចង់ដើរតាមពួកឥស្សរជនទាំងនោះ ដើម្បីរុញច្រានប្រទេសកម្ពុជា ឱ្យក្លាយទៅជា

ប្រទេសលាវទី២ ត្រូវតែអនុញ្ញាតឱ្យទូលបង្គំលាឈប់ពីតំណែងជាមុនសិន ។

ពេលនោះ មេដឹកនាំរាជរដ្ឋាភិបាលនៅភ្នំពេញ មិនមានប្រតិកម្មឆ្លើយតបនឹងសារទូរលេខរបស់សម្តេចសីហនុ ដែលផ្ញើមកថ្វាយព្រះមាតារបស់ព្រះអង្គនោះទេ។

ខណៈនោះដែរ នាយករដ្ឋមន្ត្រីលន់ នល់ ក៏បានផ្ញើសារទូរលេខមួយរាយការណ៍ថ្វាយទៅសម្តេចសីហនុ ពីសភាពការណ៍នៃការធ្វើបាតុកម្មនោះ និងទូលបញ្ជាក់ប្រាប់ព្រះអង្គថា វាគ្មានអ្វីដែលគាត់ត្រូវដឹកនាំរាជរដ្ឋាភិបាលស្រោចស្រង់ជាតិ ទៅចូលជាមួយអង្គការសេអាតូ ឬមហាអំណាចណាមួយនោះទេ ព្រោះនេះ ជាទង្វើផ្ទុយនឹងមាគ៌ានយោបាយអព្យាក្រឹតរបស់ព្រះអង្គ ។

នៅថ្ងៃទី១២ ខែមីនា ព្រះអង្គម្ចាស់ស៊ីសុវត្ថិ សិរិមតៈ ឧបនាយករដ្ឋមន្ត្រី បានប្រកាសជាសាធារណៈថា រាជរដ្ឋាភិបាលកម្ពុជា ទាមទារឱ្យមេដឹកនាំវៀតកុង និងវៀតណាមខាងជើង គោរពខ្សែបន្ទាត់ព្រំដែនខ្មែរឱ្យបាន ត្រឹមត្រូវ ហើយកិច្ចព្រមព្រៀងពាណិជ្ជកម្ម ដែលសម្តេចសីហនុ បញ្ជាឱ្យ ព្រំ ថុស រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម និងឧស្សាហកម្ម ចុះហត្ថលេខាជាមួយង្វៀន វ៉ាន់ហៀវ ឯកអគ្គរដ្ឋទូតរដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្នវៀតណាមខាងត្បូង ប្រចាំក្រុងភ្នំពេញ កាលពីថ្ងៃទី២៥ ខែកញ្ញា ឆ្នាំមុននោះ ត្រូវព្យួរទុកសិន ។

ពេលនោះដែរ ដោយមានការគាំទ្រពីឧត្តមសេនីយ៍សក់ ស៊ុតសាខន ជានាយអគ្គសេនាធិការកងយោធពលខេមរភូមិន្ទ ព្រះអង្គម្ចាស់សិរិមតៈ ក៏បានប្រកាសថ្កោលទោសប្រឆាំងនឹងកងទ័ពវៀតកុង-វៀតណាមខាងជើង ដែលកំពុងបោះទីតាំងនៅលើទឹកដីកម្ពុជា ហើយថា កម្ពុជា កំពុងស្ថិតនៅក្នុងស្ថានភាពគ្រោះអាសន្ន និងស្នើសុំ ជ្រើសរើសទាហានថ្មី ចំនួន១ម៉ឺននាក់បន្ថែមទៀត ដើម្បីការពារព្រំដែនខាងកើត ។

ព្រះអង្គម្ចាស់សិរិមតៈ បញ្ជាក់ថា បាតុកម្មវាយកម្ទេចស្ថានទូតវៀតកុង-វៀតណាមខាងជើងនោះ គឺកើតចេញពីឆន្ទៈរបស់ជនរួមជាតិខ្មែរ ហើយទ្រង់ក៏មិនអាចឱបដៃនៅស្ងៀមចំពោះការហូរចូលរបស់កងទ័ពវៀតកុង-វៀតណាមខាងជើង មកក្នុង

ទឹកដីកម្ពុជា ទៀតបានដែរ ។

ទោះបីមានការវាយកម្ទេចស្ថានទូតវៀតកុង-វៀតណាមខាងជើង យ៉ាងនេះក៏ដោយ ក៏នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៧០ អ្នកនាំពាក្យគណៈប្រតិភូរដ្ឋាភិបាលបដិវត្តន៍បណ្ដោះអាសន្នវៀតណាមខាងត្បូង ដែលកំពុងបំពេញទស្សនកិច្ចនៅទីក្រុងបារីសនោះដែរ បានប្រកាសប្រាប់ក្រុមអ្នកកាសែតថា ទំនាក់ទំនងមិត្តភាព និងសាមគ្គីភាពរវាងព្រះរាជាណាចក្រកម្ពុជា និងវៀតណាម ក្នុងការប្រយុទ្ធប្រឆាំងនឹងចក្រពត្តិអាមេរិក នៅតែមានភាពល្អប្រសើរ ពុំមានអ្វីធ្វើឱ្យល្អក់កករឡើយ ។

# ២៧០
# លន់ នល់ ឱ្យវៀតកុង ដកកងទ័ពទាំងអស់ ចេញពីទឹកដីកម្ពុជា ឱ្យបានមុនថ្ងៃទី១៥ មីនា



**ឧត្តមសេនីយ៍ឯក លន់ នល់**

នៅថ្ងៃទី១២ ខែមីនា ឆ្នាំ១៩៧០ រាជរដ្ឋាភិបាលស្រោចស្រង់ជាតិ បានប្រកាសឱ្យកងទ័ពវៀតកុង-វៀតណាមខាងជើង ដកចេញពីទឹកដីកម្ពុជាឱ្យអស់នៅត្រឹមថ្ងៃទី១៥ ខែមីនា ពោលគឺទុករយៈពេលឱ្យតែ៣ថ្ងៃ ប៉ុណ្ណោះ និងបានបដិសេធ លែងទទួលស្គាល់កិច្ចព្រមព្រៀងស្តីពីការដឹកជញ្ជូនអាវុធទៅឱ្យកងទ័ពវៀតកុង-វៀតណាមខាងជើង តាមច្រកទ្វារកំពង់ផែក្រុងព្រះសីហនុ ទៀតផង ។

ក្រោយពីមានបាតុកម្មវាយស្ថានទូតរដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្នវៀតណាមខាងត្បូង និងសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម (វៀតណាមខាងជើង) ថ្ងៃទី១១ មីនា មក នៅថ្ងៃទី១២ និង១៣ មីនា ពួកយុវជនដែលមានគំនិតជ្រុលនិយមជាច្រើនក្រុម បានបន្តធ្វើសកម្មភាពវាយធ្វើបាប និងប្លន់ទ្រព្យសម្បត្តិនៅតាមផ្ទះជនជាតិវៀតណាម

រំលោភស្រ្តីវៀតណាម និងរំលោភបំពានទៅលើព្រះវិហារកៅដាយ ទៀតផង តែកម្លាំងសមត្ថកិច្ច នៅតែធ្វើមិនដឹង មិនឮពីបញ្ហានេះ បង្កឱ្យមានភាពអនាធិបតេយ្យយ៉ាងពេញទំហឹងនៅក្នុងទីក្រុងភ្នំពេញ ។

ថ្ងៃទី១២ មីនា ឆ្នាំ១៩៧០ នៅមិនឆ្ងាយប៉ុន្មានពីខាងលិចផ្សារធំថ្មី បណ្ណាគារឯកជនដ៏ធំមួយ ឈ្មោះ"ហុង យូ" ត្រូវបានពួកបាតុករ ដែលសុទ្ធសឹងជាយុវជនវាយកម្ទេច ដោយសារតែថៅកែហាងលក់សៀវភៅ និងប្រដាប់ប្រដាកីឡានេះជាជនជាតិវៀតណាម។

នៅថ្ងៃទី១៣ ខែមីនា សម្តេចសីហនុ បានផ្តល់បទសម្ភាសដោយឡែកមួយ ជាមួយអ្នកកាសែតអាមេរិក ថា ព្រះអង្គមានការខកព្រះទ័យយ៉ាងខ្លាំង បន្ទាប់ពីព្រះអង្គបានជួបតំណាងរបស់សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម ប្រចាំនៅប្រទេសបារាំង ឈ្មោះ ម៉ៃ វ៉ាន់បូ ព្រះអង្គបានស្នើសុំឱ្យគាត់ដកកងទ័ពវៀតកុង-វៀតណាមខាងជើងទាំងអស់ចេញពីកម្ពុជា នោះ ត្រូវបានតំណាងវៀតណាមកុម្មុយនិស្តរូបនេះ ឆ្លើយថា គាត់មិនអាចសម្រេចចិត្តពីបញ្ហានេះទេ។ ប៉ុន្តែគាត់នឹងផ្តល់ព័ត៌មាននេះ ទៅឱ្យរដ្ឋាភិបាលរបស់គាត់...។

នៅថ្ងៃទី១៣ មីនា ព្រះមហាក្សត្រិយានី កុសុមៈ បានកោះអញ្ជើញឧត្តមសេនីយ៍ លន់ នល់ ជានាយករដ្ឋមន្ត្រី ព្រមទាំងសមាជិករាជរដ្ឋាភិបាលមួយចំនួនទៀតឱ្យចូលគាល់ ដើម្បីស្នើសុំឱ្យចាត់វិធានការទប់ស្កាត់ កុំឱ្យមានចលនាបាតុកម្មអនាធិបតេយ្យនោះតទៅទៀត និងសុំឲ្យធ្វើតាមគោលនយោបាយរបស់សម្តេចសីហនុ ឡើងវិញ។

ជាមួយគ្នានោះ ព្រះមហាក្សត្រិយានីបានផ្ញើព្រះរាជសារមួយទៅចេង ហេង ដែលកំពុងកាន់តំណែងជាប្រមុខរដ្ឋស្តីទី គំរាមរំលាយសភាចោល ប្រសិនបើគាត់មិនបញ្ឈប់ការប្រកាសផ្សព្វផ្សាយសេចក្តីថ្លែងការណ៍ប្រឆាំងនឹងពួកវៀតកុង-វៀតណាមខាងជើង នោះទេ។

ការគំរាមរំលាយសភាចោលនេះ ធ្វើឱ្យឥស្សរជនមួយចំនួនមានការភ្ញាក់ផ្អើលដែរ ព្រោះព្រះមហាក្សត្រិយានី គ្រាន់តែជាតំណាងព្រះរាជបល្ល័ង្កប៉ុណ្ណោះ ពុំមានអំណាចជា

ផ្លូវការណាមួយក្នុងការរំលាយសភានោះទេ ចុះហេតុអ្វី បានជា ព្រះអង្គធ្វើដូចសម្តេច សីហនុជាព្រះប្រមុខរដ្ឋទៅវិញ? ។

នៅថ្ងៃសុក្រទី១៣ ខែមីនា នោះដែរ សម្តេចសីហនុ បានផ្ញើសារទូលេខមួយទៀតថ្វាយមកព្រះមាតារបស់ព្រះអង្គថា ២ថ្ងៃទៀត ព្រះអង្គនឹងយាងមកកាន់មាតុប្រទេសវិញ ។

នៅរសៀលថ្ងៃទី១៩ ខែមីនា ប្រជារាស្ត្រនៅទីក្រុងភ្នំពេញ ក្នុងសម្លៀកបំពាក់ស្អាតបាត និងសិស្សនិស្សិតក្នុងឯកសណ្ឋានជាយុវជនរាជសង្គមនិយមខ្មែរ( យុវ៉ន )រាប់ម៉ឺននាក់ ក្នុងទឹកចិត្តសប្បាយរីករាយ ត្រូវបានគេរៀបចំឱ្យឈរអមសងខាងផ្លូវពីអាកាសយានដ្ឋានពោធិ៍ចិនតុង មកព្រះរាជដំណាក់ចំការមន ដើម្បីទទួលស្វាគមន៍ព្រះរាជដំណើរ យាងនិវត្តរបស់សម្តេចសីហនុ មកកាន់មាតុប្រទេសវិញ ។

លុះដល់វេលាម៉ោង៦ព្រលប់ ស្រាប់តែមានការប្រកាស ដំណឹងថា ការយាងនិវត្តរបស់ព្រះអង្គត្រូវលើកពេលទៅថ្ងៃក្រោយវិញ ហើយប្រជារាស្ត្រ និងសិស្សនិស្សិត ដែលមករង់ទទួលស្វាគមន៍ព្រះរាជដំណើរទាំងអស់ ត្រូវរំសាយឱ្យវិលត្រលប់ទៅផ្ទះវិញរៀងៗខ្លួន ។

សម្តេចសីហនុ បានពន្យារពេលរហូតដល់ថ្ងៃទី២៤ ខែមីនា ទើបព្រះអង្គយាងនិវត្តមកមាតុភូមិវិញ ព្រោះព្រះអង្គត្រូវយាងទៅទីក្រុងមូស្គូ និងទីក្រុងប៉េកាំង បន្តទៀតដើម្បីជួបមេដឹកនាំសូវៀត និងមេដឹកនាំចិន សុំឱ្យជួយធ្វើអន្តរាគមន៍ឱ្យកងទ័ពវៀតកុង-វៀតណាមខាងជើង ដកចេញពីកម្ពុជា វិញ ។

នៅថ្ងៃទី១៣ ខែមីនា នាយករដ្ឋមន្ត្រីលន់ នល់ បានឱ្យសុស្តែន ហ្វែរណង់ដេសទៅទូលព្រះមហាក្សត្រិយានី កុសុមៈ ថា រាជរដ្ឋាភិបាលបានរៀបចំចាត់ចែងឱ្យ យ៉ែម សំបូរ ជាតំណាង ឱ្យធ្វើដំណើរទៅ ក្រុងប៉ារីស ប្រទេសបារាំង ដើម្បីចូលគាល់សម្តេចសីហនុ ដែលកំពុងបំពេញទស្សនកិច្ចនៅទីនោះ ដើម្បីរាយការណ៍ថ្វាយព្រះអង្គពីសភាពការណ៍ ដែលកំពុងកើតមាននៅក្នុងប្រទេស និងទូលព្រះអង្គពីវិធានការទាំងឡាយ ដែលរាជរដ្ឋាភិបាល កំពុងដោះស្រាយផងដែរ។

ពេលនោះ ព្រះមហាក្សត្រិយានី កុសុមៈ ក៏បានត្រាស់បង្គាប់ឱ្យព្រះអង្គម្ចាស់ នរោត្តម កន្តុល ជាតំណាងស្ថាប័ន ព្រះមហាក្សត្រ ធ្វើដំណើរជាមួយ យ៉ែម សំបូរ ជាតំណាងរាជរដ្ឋាភិបាល ទៅក្រុងប៉ារីស ជាមួយគ្នា ដើម្បីទៅគាល់សម្តេចសីហនុរាយការណ៍ថ្វាយព្រះអង្គពីសភាពការណ៍ ដែលកំពុងកើតមាននៅក្នុងប្រទេស ។

ប្រភពមួយ បានឱ្យដឹងថា ការដែលនាយករដ្ឋមន្ត្រីលន់ នល់ បញ្ជូនយ៉ែម សំបូរ ឱ្យទៅគាល់ព្រះអង្គនោះ គឺគ្រាន់តែដើម្បីបញ្ចុះបញ្ចូលព្រះអង្គ កុំឱ្យយាងត្រឡប់មកមាតុប្រទេសវិញ ធ្វើប្រជាមតិ ឬបើកសមាជជាតិឱ្យប្រជារាស្ត្រខ្មែរទាំងមូលសម្រេចចិត្តថា តើត្រូវគាំទ្រព្រះអង្គ ឬគាំទ្ររាជរដ្ឋាភិបាល ស្រោចស្រង់ជាតិ ឱ្យដឹកនាំប្រទេសបន្តទៀតតែប៉ុណ្ណោះ ។

ដោយសារសម្តេចសីហនុ ទទួលដំណឹងដូចខាងលើនេះ ទើបព្រះអង្គមិនអាចទទួលយកនូវឧបាយកលដ៏អាម៉ាស់បែបនេះបានទេ ។ ដូច្នេះ ព្រះអង្គបានផ្តាំផ្ញើទៅរាជរដ្ឋាភិបាលលន់ នល់ វិញថា មិនបាច់បញ្ជូន យ៉ែម សំបូរ មកទេ ព្រះអង្គមិនទទួលជួបជាដាច់ខាត ។

នៅថ្ងៃទី១៤ ខែមីនា ពេលមុនពេលធ្វើដំណើរទៅឡើងយន្តហោះនៅអាកាសយានដ្ឋានពោធិ៍ចិនតុង យ៉ែម សំបូរ និងព្រះអង្គម្ចាស់នរោត្តម កន្តុល នាំគ្នាទៅជួបនាយករដ្ឋមន្ត្រីលន់ នល់ នៅឯផ្ទះរបស់គាត់ដែលស្ថិតនៅក្បែរផ្សារដើមថ្កូវ តាមបណ្តោយផ្លូវទំនប់ទឹក( ពីក្បាលថ្នល់ ទៅមន្ទីរពេទ្យរុស្ស៊ី បច្ចុប្បន្នជាផ្លូវលេខ២៧១) ដើម្បីទទួលការណែនាំបន្ថែមទៀត។

ក្រោយពេលឥស្សរជនទាំង២នាក់ ចេញពីបន្ទប់ទទួលភ្ញៀវបានបន្តិច ស្រាប់តែឧត្តមសេនីយ៍លន់ នល់ បានបក់ដៃ ឱ្យត្រលប់មកជួបគាត់វិញ ហើយប្រាប់ថា មិនបាច់ទៅទេ ព្រោះសម្តេចមិនអនុញ្ញាតឱ្យពួកយើងទៅជួបជាដាច់ខាត ។

តាមប្រភពសម្ងាត់មួយទៀតបានឱ្យដឹងថា គឺអ្នកម្នាងម៉ូនិក ជាមហេសី និងឧត្តមសេនីយ៍ង៉ោ ហ៊ូ ជាអ្នកឱ្យយោបល់ថ្វាយទៅសម្តេចសីហនុ មិនឱ្យទទួលជួបឥស្សរជន

ទាំង២នេះ តាំងពីមុនពេលព្រះអង្គយាងចេញពីក្រុងប៉ារីស ទៅក្រុងមូស្គូ ថ្ងៃទី១៣ ខែមីនាមកម្ល៉េះ ។ ថ្ងៃនោះព្រះអង្គបានប្រជុំបិទទ្វារជិតជាមួយឥស្សរជនមួយចំនួន ដែលអមព្រះរាជដំណើរព្រះអង្គ ដោយព្រះអង្គមានបន្ទូលថា ពេលព្រះអង្គយាងត្រលប់ទៅដល់ក្រុងភ្នំពេញ វិញ ព្រះអង្គនឹងឱ្យតុលាការសឹកកាត់ទោសឥស្សរជនមួយចំនួន ដែលព្រះអង្គបានកំណត់ឈ្មោះរួចជាស្រេចហើយ ពិសេសគឺលន់ នល់ នាយករដ្ឋមន្ត្រី និងព្រះអង្គម្ចាស់ស៊ីសុវត្ថិ សិរិមតៈ ជាឧបនាយករដ្ឋមន្ត្រីទី១ ។

ប្រភពដដែលបានអះអាងថា ពេលប្រជុំបិទទ្វារបន្ទប់ជិតនោះ ព្រះអង្គម្ចាស់ស៊ីសុវត្ថិ ឥស្សរ៉ូ ជាបងប្អូនព្រះអង្គម្ចាស់ស៊ីសុវត្ថិ សិរិមតៈ ដែលជាតំណាងអចិន្ត្រៃយ៍របស់ព្រះរាជាណាចក្រកម្ពុជា ប្រចាំអង្គការយូណេស្កូ និងជាចាងហ្វាងគេហដ្ឋានខ្មែរ (Maison du Cambodge) នៅក្នុងបុរីសាកលវិទ្យាល័យអន្តរជាតិក្រុងប៉ារីស តាំងពីឆ្នាំ១៩៦៧មក ក៏មានវត្តមាននៅក្នុងអង្គប្រជុំនោះដែរ ទ្រង់បានលួចថតសំឡេងតាមខ្សែអាត់ ហើយបានបញ្ជូនមកឱ្យព្រះអង្គម្ចាស់សិរិមតៈ នៅក្រុងភ្នំពេញ ភ្លាមៗ ហើយព្រះអង្គម្ចាស់សិរិមតៈ ក៏បានយកខ្សែអាត់ថតសំឡេងនោះ ទៅចាក់ឱ្យនាយករដ្ឋមន្ត្រីលន់ នល់ ស្តាប់ ហើយប្រាប់លន់ នល់ ថា វិធីដោះស្រាយមានតែម្យ៉ាងគត់ គឺត្រូវតែទម្លាក់សម្តេចសីហនុ ចេញពីអំណាច បើពុំដូច្នេះប្រាកដជានឹងត្រូវស្លាប់ទាំងអស់គ្នាជាមិនខាន។ ប៉ុន្តែ លន់ នល់ បដិសេធ ដោយគាត់ចង់រកវិធីដោះស្រាយផ្សេងវិញ។ ប៉ុន្តែទោះបីយ៉ាងនេះក៏ដោយ ក៏លន់ នល់ នៅតែបន្តផ្ញើសារទូរលេខស្តីពី សភាពការណ៍នៅក្នុងប្រទេស ទៅថ្វាយព្រះអង្គជ្រាបជារៀងរាល់ថ្ងៃដែរ ។

នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ១៩៧០ ទស្សនាវដ្តីថែម (Time Magazine) របស់អាមេរិកបានចុះផ្សាយព័ត៌មានពីដំណើរទស្សនកិច្ចរបស់សម្តេចសីហនុ នៅសហភាពសូវៀតថា សម្តេចសីហនុ ប្រមុខរដ្ឋកម្ពុជា ដែលកំពុងភ័យខ្លាច ប្រទេសព្រះអង្គក្លាយទៅជាប្រទេសលាវទី២ ឬអាចទៅជាប្រទេសវៀតណាម ផងនោះ បានយាងទៅដល់ទីក្រុងមូស្គូ កាលពីម្សិលមិញ (ថ្ងៃទី១៣ មីនា) ក្នុងគោលបំណងពិភាក្សាជាមួយមេដឹកនាំ

សហភាពសូវៀត ឱ្យជួយបញ្ចុះបញ្ចូលមេដឹកនាំវៀតកុង-វៀតណាមខាងជើង ឱ្យដកកងទ័ពចេញពីទឹកដីកម្ពុជា។ ប៉ុន្តែ មុនពេលព្រះអង្គយាងមកដល់ក្រុងមូស្គូ ( ថ្ងៃទី១៣មីនា) នៅទីក្រុងភ្នំពេញ ឯណោះ មានដំណឹងថា លន់ នល់ បានដាក់ឱសានវាទឱ្យកងទ័ពវៀតកុង-វៀតណាមខាងជើង ដកចេញពីទឹកដីកម្ពុជា ឱ្យបានមុនថ្ងៃទី១៥ ខែមីនា ខណៈប្រជារាស្ត្រខ្មែរនៅទីក្រុងភ្នំពេញ កំពុងបន្តធ្វើការវាយកម្ទេចផ្ទះសម្បែង និងធ្វើបាបជនជាតិវៀតណាម នៅក្នុងសង្កាត់មួយចំនួន ។

ទស្សនាវដ្តីថែម បានសរសេរបន្តថា មុនពេលចាកចេញពីក្រុងបារីស ថ្ងៃទី១៣មីនា សម្តេចសីហនុ បានប្រាប់ក្រុម អ្នកកាសែតថា ព្រះអង្គនឹងស្នើឱ្យមេដឹកនាំចិន ធ្វើអន្តរាគមន៍ទៅមេដឹកនាំវៀតកុង-វៀតណាមខាងជើង ឱ្យដកកងទ័ពចេញពីកម្ពុជាហើយថា នយោបាយអព្យាក្រឹតរបស់ព្រះអង្គ គឺជាការចាំបាច់ណាស់សម្រាប់ឯករាជ្យភាព និងអធិបតេយ្យភាពរបស់កម្ពុជា។

បើមានការផ្លាស់ប្តូរនយោបាយ កម្ពុជា ច្បាស់ជាក្លាយទៅជាប្រទេសលាវទី២ ក៏អាចថាបាន។ មានបន្ទូលឆ្លើយតបចំពោះក្រុមអ្នកកាសែតដែលបានលើកជាឧទាហរណ៍ថា ប្រសិនបើមានការធ្វើរដ្ឋប្រហារទម្លាក់ព្រះអង្គចេញពីអំណាចដោយពួកស្តាំនិយមនៅទីក្រុងភ្នំពេញមែននោះតើព្រះអង្គមានតម្រិះយ៉ាងណា? សម្តេចសីហនុមានបន្ទូលបញ្ជាក់ថា ប្រសិនបើកងទ័ព និងប្រជារាស្ត្រស្រឡាញ់គាំទ្រពួកស្តាំនិយមមែននោះ ព្រះអង្គនឹងមិនតតាំងដណ្តើមយកអំណាចពីពួកនេះមកវិញទេ។ ប៉ុន្តែ អ្វីដែលព្រះអង្គព្រួយព្រះទ័យបំផុតនោះគឺខ្លាចកម្ពុជាក្លាយទៅជាប្រទេសលាវទី២។



ព្រះអង្គម្ចាស់ស៊ីសុវត្ថិ ឥស្សរ៉ៈ

ជាមួយគ្នានោះ ក្នុងបទសម្ភាសជាមួយអ្នកយកព័ត៌មានទូរទស្សន៍មួយ ព្រះអង្គបានមានបន្ទូលថា ពួកស្ដាំនិយមរបស់ព្រះអង្គអាចមានលទ្ធភាពធ្វើរដ្ឋប្រហារទម្លាក់ព្រះអង្គ ដើម្បីដឹកនាំប្រទេសឱ្យងាកទៅរកសហរដ្ឋអាមេរិក ។

ទស្សនាវដ្ដីថៃម ចុះផ្សាយបន្តថា ថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៧០ ពេលយាងដល់អាកាសយានដ្ឋានទីក្រុងមូស្គូ សម្ដេចសីហនុ ត្រូវបានប្រធានឧត្ដមក្រុមប្រឹក្សារដ្ឋសហភាពសូវៀត នីកូឡៃ ប៉ូដហ្គ័រនី( Nikolai Podgorny ) មកទទួលស្វាគមន៍ ។

ថ្ងៃទី១៤ ខែមីនា ឆ្នាំ១៩៧០ អ្នកឆ្លើយឆ្លងព័ត៌មានរបស់ទស្សនាវដ្ដីសូវៀតមួយបានរាយការណ៍ពីដំណើរទស្សនកិច្ចរបស់សម្ដេចសីហនុ ថា ថ្ងៃនេះ( ថ្ងៃទី១៤ ខែមីនា) ព្រះអង្គដែលកំពុងស្ថិតនៅទីក្រុងមូស្គូ និងបានចូលជួបពិភាក្សាជាមួយប្រធានឧត្ដមក្រុមប្រឹក្សារដ្ឋសហភាពសូវៀត  នីកូឡៃ ប៉ូដហ្គ័រនី( Nikolai Podgorny ) ស្ដីពីបញ្ហាបញ្ឈប់ឱ្យមានកងទ័ពវៀតកុង-វៀតណាមខាងជើង បោះទីតាំងនៅលើទឹកដីរបស់ព្រះអង្គ ហើយថា អ្នកការទូតបរទេសនៅទីក្រុងភ្នំពេញ ជឿជាក់ថា ការធ្វើបាតុកម្មប្រឆាំងនឹងវត្តមានរបស់កងទ័ពវៀតកុង-វៀតណាមខាងជើងប៉ុន្មានថ្ងៃមុននេះ គឺជាយុទ្ធសាស្ត្រដែលរៀបចំឡើងដោយសម្ដេចសីហនុ ផ្ទាល់តែម្ដង ហើយអ្វីដែលព្រះអង្គបានចោទប្រកាន់ថាពួកស្ដាំនិយមជាអ្នករៀបចំឱ្យមានបាតុកម្មវាយកម្ទេចស្ថានទូតវៀតកុង-វៀតណាមខាងជើង កាលពីថ្ងៃទី១១ ខែមីនា នោះ គឺពួកស្ដាំនិយមមានបំណងចង់អូសទាញប្រទេសទៅរកសហរដ្ឋអាមេរិក នោះ គឺគ្រាន់តែជាយុទ្ធសាស្ត្រលាងសម្អាតខ្លួនរបស់ព្រះអង្គ មិនឱ្យមានបញ្ហាល្អក់កករជាមួយពួកវៀតកុង-វៀតណាមខាងជើង តែប៉ុណ្ណោះ ។

អ្នកការទូតបរទេសយល់ឃើញទៀតថា ការព្រួយបារម្ភរបស់សម្ដេចសីហនុ ពីបញ្ហាវត្តមានកងទ័ពវៀតកុង-វៀតណាមខាងជើង ចូលមកបោះទីតាំងទៅលើទឹកដីកម្ពុជា បានកើតមានឡើងតាំងពី២-៣ឆ្នាំមុន មកម្ល៉េះ តែព្រះអង្គបានទទួលស្គាល់រដ្ឋាភិបាលបដិវត្តន៍បណ្ដោះអាសន្នវៀតណាមខាងត្បូងមុនគេ និងបានទៅចូលរួមក្នុងពិធីបុណ្យសពហូ ជីមិញ នៅទីក្រុងហាណូយ ទៀតផង។ ប៉ុន្តែ ទន្ទឹមនឹងនោះ ព្រះ

អង្គក៏បានផ្សារទំនាក់ទំនងបន្តិចម្តងៗ ជាមួយប្រទេសលោកខាងលិចផងដែរ ពិសេស ព្រះអង្គបានរៀបចំឱ្យមានទំនាក់ទំនងការទូតជាមួយសហរដ្ឋអាមេរិក ឡើងវិញ តាំងពីខែកក្កដា ឆ្នាំ១៩៦៩ មក។ ព្រះអង្គប្រហែលជាគិតថា ព្រះអង្គមិនអាចបណ្តេញកងទ័ពវៀតកុង-វៀតណាមខាងជើង ចេញពីប្រទេសរបស់ព្រះអង្គបានទេ ព្រោះប្រទេសកម្ពុជា គឺជាដង្ហើមស្លាប់រស់នៃយុទ្ធសាស្ត្រធ្វើសង្គ្រាមរបស់ពួកវៀតកុង-វៀតណាមខាងជើង ដើម្បីផ្តួលរម្លំរបបវៀតណាមខាងត្បូង ដែលសហរដ្ឋអាមេរិក ជាអ្នកគាំទ្រ ។

កងទ័ពវៀតណាមកុម្មុយនិស្តទាំងនោះបានទិញអង្ករ ស្បៀងអាហារ និងថ្នាំពេទ្យពីកម្ពុជា ហើយយកទឹកដីកម្ពុជា ធ្វើជាជម្រកសម្រាប់គេចខ្លួនពីការទម្លាក់គ្រាប់បែករបស់យន្តហោះបេ៥២ និងពីការដេញវាយប្រហាររបស់កងទ័ពអាមេរិក និងកងទ័ពរដ្ឋការវៀតណាមខាងត្បូង ចូលមកដល់ក្នុងទឹកដីកម្ពុជា ដែលធ្វើឱ្យប្រជាពស្ត្រកម្ពុជារងគ្រោះថ្នាក់ផងដែរ។ ប៉ុន្តែ សម្តេចសីហនុ ប្រាកដជាដឹងថា កងទ័ពរបស់ព្រះអង្គដែលមានចំនួនប្រមាណ៣ម៉ឺននាក់នោះ មិនអាចវាយកម្ចាត់ឱ្យកងទ័ពវៀតកុង-វៀតណាមខាងជើង ចេញពីទឹកដីរបស់ព្រះអង្គបានឡើយ។ ដូច្នេះ ព្រះអង្គមានមធ្យោបាយតែម្យ៉ាងគត់ គឺត្រូវរកដំណោះស្រាយតាមផ្លូវនយោបាយ និងការទូត ។

តែយ៉ាងណា នៅថ្ងៃទី១៤ ខែមីនាឆ្នាំ១៩៧០ ក្រសួងការបរទេសកម្ពុជា បានផ្ញើកំណត់ហេតុការទូតមួយទៅឱ្យមេដឹកនាំសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម (វៀតណាមខាងជើង) និងរដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្នវៀតណាមខាងត្បូងដើម្បីសម្តែងការសោកស្តាយចំពោះព្រឹត្តិការណ៍ធ្វើបាតុកម្មវាយប្រហារស្ថានទូតទាំង២នេះកាលថ្ងៃទី១១ ខែមីនា នោះដែរ ។

ទន្ទឹមនោះ រាជរដ្ឋាភិបាលកម្ពុជា ក៏បានបង្ខំឱ្យកងទ័ពវៀតកុង-វៀតណាមខាងជើងដកចេញពីកម្ពុជាឱ្យអស់មុនថ្ងៃទី១៥ ខែមីនា ដូចកាលប្រកាសថ្ងៃទី១២ ខែមីនា និងសូមឱ្យមានការគោរពច្បាប់អន្តរជាតិផងដែរ។ ប៉ុន្តែ ភាគីវៀតណាមកុម្មុយនិស្ត បានសុំពន្យារពេលនៃការដកកងទ័ពរបស់ខ្លួនចេញពីទឹកដីកម្ពុជា មួយរយៈសិន ។

ថ្ងៃទី១៩ ខែមីនា សម្ដេចសីហនុ បានជួបជាមួយប្រធានឧត្តមក្រុមប្រឹក្សារដ្ឋសហភាពសូវៀត នីកូឡៃ ប៉ូដហ្គ័រនី (Nikokai Podgorny) ម្ដងទៀត និងបានចូលជួបនាយករដ្ឋមន្ត្រី អាឡិចហ្សេ កូស៊ីហ្គីន(Alexei Kosigin)ផងដែរ ប៉ុន្តែ មិនបានពិភាក្សាគ្នាពីបញ្ហាអ្វីទេ គឺគ្រាន់តែជួបសម្ដែងការគួរសមគ្នាទៅវិញទៅមកប៉ុណ្ណោះ ហើយត្រូវបានមេដឹកនាំសូវៀត យាងព្រះអង្គឱ្យទៅតំបន់ជាយក្រុងមូស្គូមួយកន្លែង ដើម្បីទស្សនាបង្គោលអង់តែនវិទ្យុ និងទូរសទស្សន៍ ដែលមានកម្ពស់ខ្ពស់ជាងគេនៅលើពិភពលោកនេះ ទៅវិញៗ នៅទីក្រុងមូស្គូ សម្ដេចសីហនុ ក៏បានចូលជួបពិភាក្សាគ្នារយៈពេលយូរជាមួយ ឡេអូនីត ប្រេសណេវ(Leonid Brezhnev) អគ្គលេខាបក្សកុម្មុយនិស្តសូវៀត ផងដែរ។

អ្នកសង្កេតការណ៍អន្តរជាតិយល់ថា ពេលនោះ មេដឹកនាំសូវៀត មានជំហរទើសទាល់ចំពោះសម្ដេចសីហនុ ដែលមានចំណង់ចង់ឱ្យខ្លួនជួយធ្វើអន្តរាគមន៍ឱ្យកងទ័ពវៀតកុង-វៀតណាមខាងជើង ដកចេញពីទឹកដីកម្ពុជា។

នៅថ្ងៃទី១៩ ខែមីនា កាសែតញ៉ិនយ៉ឹន(កាសែត ប្រជាជន) របស់បក្សកុម្មុយនិស្តវៀតណាម ក៏បានធ្វើបទអត្ថាធិប្បាយថា ការវាយកម្ទេចស្ថានទូតវៀតណាមខាងជើង និងស្ថានទូតរដ្ឋាភិបាលបដិវត្តន៍បណ្ដោះអាសន្នវៀតណាមខាងត្បូង បានបង្កឱ្យមានការស្មុគស្មាញដល់ទំនាក់ទំនងការទូតរវាងកម្ពុជា និងរដ្ឋាភិបាលប្រទេសទាំង២នេះ ហើយថា បញ្ហានេះ បណ្ដាលមកពីការឈ្លានពានរបស់អាមេរិក មកលើវៀតណាមខាងត្បូង និងបណ្ដាលមកពីឧបាយកលបំផ្លាញឯករាជ្យភាព និងអព្យាក្រឹតភាពកម្ពុជារបស់អាមេរិកផងដែរ។

ដើម្បីដោះស្រាយបញ្ហាស្មុគស្មាញនេះ ប្រជាជនកម្ពុជា និងប្រជាជនវៀតណាម ត្រូវតែរួបរួមសាមគ្គីគ្នាឱ្យបានរឹងមាំ ដើម្បីតស៊ូប្រឆាំងនឹងការឈ្លានពាន និងល្បិចកលជ័ពិសពុលរបស់ចក្រពត្តិអាមេរិក។

ថ្ងៃទី១៦ ខែមីនា ទស្សនាវដ្ដីអិចប្រេស្ស (Express Magazine) បានសរសេរ

រៀបរាប់ពីព្រឹត្តិការណ៍វាយកម្ទេចស្ថានទូតសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមខាងជើង និងស្ថានទូតរដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្នវៀតណាមខាងត្បូង នៅទីក្រុងភ្នំពេញ កាលពី ថ្ងៃទី១១ ខែមីនា និងសរសេរថា កងទ័ពវៀតកុង-វៀតណាមខាងជើង ប្រមាណ៤០០០០នាក់ បានចូលមកបោះទីតាំងនៅក្នុងទឹកដីកម្ពុជា ដើម្បីធ្វើសង្គ្រាមប្រឆាំងនឹងកងទ័ពអាមេរិក និងផ្តួលរម្លំរបបរដ្ឋការវៀតណាមព្រៃនគរ ពិសេសនៅតំបន់បាធូ កងទ័ពវៀតកុងវៀតណាមខាងជើង បានជីករូងនៅក្រោមដីរាប់រយ សម្រាប់ជ្រកពួន និងលាក់អាវុធ។

ទស្សនាវដ្តីដដែលបានបន្តថា រដ្ឋាភិបាលសហរដ្ឋអាមេរិក បានផ្តល់សំណងដល់ប្រជាពលរដ្ឋខ្មែរ ដែលរងគ្រោះដោយសារគ្រាប់កាំភ្លើងផ្លោង និងការទម្លាក់គ្រាប់បែកពីលើ យន្តហោះរបស់ខ្លួន ក្នុងពេលដេញតាមកងទ័ពវៀតកុង-វៀតណាមខាងជើង ដែលរត់គេចខ្លួនចូលមកជ្រកពួននៅក្នុងទឹកដីកម្ពុជា នូវទឹកប្រាក់ ចំនួន២៤៨៥០ដុល្លារ ដោយអ្នកស្លាប់ម្នាក់ៗត្រូវទទួលសំណង៤០០ដុល្លារ និងអ្នករបួសម្នាក់ៗត្រូវទទួលសំណង ១៥០ដុល្លារ ប៉ុណ្ណោះ ។

---

# ២៧១
# បាតុកម្មនៅមុខរដ្ឋសភា ទាមទាររកមុខអ្នកលក់ដីឱ្យវៀតកុង


បាតុកម្មយុវនិស្សិត ប្រជារាស្ត្រ (លើកទី២)

សិស្សនិស្សិតបាតុកម្មនៅមុខរដ្ឋសភា ព្រឹកថ្ងៃទី១៦ ខែមីនា ឆ្នាំ១៩៧០

*សូមរម្លឹកថា នៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ១៩៧០ ក្រោយពីដឹងថា ក្រណាត់ចំនួន ៧កេស ដែលផ្ញើពីក្រុងហុងកុង មកឱ្យវរសេនីយ៍ឯកអ៊ុំ ម៉ាន្នូរិន រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលបន្ទុកក្រសួងការពារលើផ្ទៃប្រទេស ជាទំនិញបន្លំគេចពន្ធ ចូលមកតាមច្រកទ្វារអាកាសយានដ្ឋានពោធិ៍ចិនតុង ហើយវរសេនីយ៍ឯកសុស្តែន ហ្វែរណង់ដេស រដ្ឋលេខាធិការក្រសួងមហាផ្ទៃទទួលបន្ទុកសន្តិសុខជាតិ ជាមិត្តភក្តិជិតស្និទ្ធរបស់អ៊ុំ ម៉ាន្នូរិន មិនអើពើក្នុងការបង្ក្រាបសកម្មភាពរត់ពន្ធនេះ ព្រះអង្គម្ចាស់ស៊ីសុវត្ថិ សិរិមតៈ បានបញ្ជាឱ្យកម្លាំងពិសេសរបស់ទ្រង់ ទៅរឹបអូសក្រណាត់រត់ពន្ធចំនួន៧កេសនោះ ដោយគ្មានលើកលែង និងយោគយល់ ទោះបីដឹងថាវរសេនីយ៍ឯកអ៊ុំ ម៉ាន្នូរិន ជាបងថ្លៃរបស់សម្តេចសីហនុ ក៏ដោយ ។*

*ព្រឹកថ្ងៃទី១៦ ខែមីនា រដ្ឋសភា និងក្រុមប្រឹក្សាព្រះរាជាណាចក្រកម្ពុជា បានបើកសម័យប្រជុំពិសេស សួរដេញដោល វរសេនីយ៍ឯក អ៊ុំ ម៉ាន្នូរិន ពីរឿងជាប់ពាក់ព័ន្ធនឹង*

ការរត់ពន្ធក្រណាត់មកពីក្រុងហុងកុង មានតម្លៃប្រមាណ ៥០០ ០០០រៀល ដែលទ្រង់សិរិមត: បញ្ជាកម្លាំងសមត្ថកិច្ចពិសេសរបស់ទ្រង់ចាប់បាននៅអាកាសយានដ្ឋានពោធិ៍ចិនតុង កាលពីថ្ងៃទី០៣ ខែកុម្ភ: និងសួរដេញដោលវរសេនីយ៍ឯកសុស្តែន ហ្វៀរណង់ដេស រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលបន្ទុកក្រសួងសន្តិសុខជាតិ ដែលមិនបានបង្រ្កាបអំពើរត់ពន្ធនោះ ។

នៅព្រឹកថ្ងៃទី១៦ ខែមីនានោះដែរ សិស្សនិស្សិតនៅតាមវិទ្យាល័យ និងមហាវិទ្យាល័យក្នុងក្រុងភ្នំពេញ ត្រូវបានគេរៀបចំឱ្យដង្ហែក្បួនចេញពីវិទ្យាល័យ និងមហាវិទ្យាល័យរៀងៗខ្លួន ធ្វើដំណើរទៅចូលរួមធ្វើបាតុកម្មដ៏ធំមួយទៀតនៅមុខរដ្ឋសភា ដោយមានមន្ត្រីរាជការ និងប្រជារាស្ត្រជាច្រើនទៀត ចូលរួមផងដែរ ។

ហ្វូងបាតុករជាច្រើនពាន់នាក់ បាននាំគ្នាឈរនៅមុខអគាររដ្ឋសភាយ៉ាងកកកុញណែនណាន់តាន់តាប់ ហើយតំណាងសមាគមសិស្សវិទ្យាល័យ សមាគមនិស្សិតមកពីមហាវិទ្យាល័យមួយចំនួន បានឡើងអានញត្តិម្នាក់ម្តងៗ ជាបន្តបន្ទាប់ ថ្កោលទោសកងទ័ពវៀតកុង-វៀតណាមខាងជើង ដែលបានរំលោភបំពានចូលមកបោះទីតាំងនៅលើទឹកដីកម្ពុជា និងទាមទារឱ្យរាជរដ្ឋាភិបាលចាត់វិធានការបណ្តេញកងទ័ពវៀតកុង-វៀតណាមខាងជើងនេះ ចេញឱ្យអស់ពីលើទឹកដីកម្ពុជា ព្រមទាំងស្នើសុំឱ្យរដ្ឋសភា វែកមុខអ្នកលក់ដីឱ្យវៀតកុង-វៀតណាមខាងជើង ដោយមានសំឡេងស្រែកបន្ទរខ្លាំងៗថា៖ “ជយោ! សម្តេចឪៗ” និងសម្រែក “បរាជ័យ! ពួកយួនវៀតកុង” ផងដែរ ។

ពេលនោះ ស្រាប់តែមានមនុស្ស២នាក់ បានធ្វើសកម្មភាពបាចខិត្តប័ណ្ណជាច្រើនសន្ធឹកនៅចំកណ្តាលហ្វូងបាតុករនោះតែម្តង។ ពួកបាតុករ នាំគ្នារើសខិត្តប័ណ្ណនោះមកអាន ទើបដឹងថា ខិត្តប័ណ្ណនោះបានសរសេរថា៖“សីហនុ គឺជាជនក្បត់ជាតិ ដែលលក់ទឹកដីឱ្យពួកវៀតកុង”។ ក្រោយពីដឹងថាខិត្តប័ណ្ណនោះបានសរសេរប្រមាថព្រះចេស្តាសម្តេចឪ ដែលពួកបាតុករចាត់ទុកថា ជាព្រះបិតាជាតិ ជាសម្តេចឪរបស់ពួកគេមក

ភ្ជាមនោះ ពួកគេក៏នាំគ្នាចាប់អ្នកបាចខិត្តប័ណ្ណទាំង២នាក់នោះ វាយទាត់ដាក់ក្នុងបំណងសម្លាប់ចោលតែម្តង។ ប៉ុន្តែ ត្រូវកម្លាំងប៉ូលិសសម្ងាត់ស្លៀកពាក់ស៊ីវិល នាំគ្នាសម្រុកចូលទៅជួយធ្វើអន្តរាគមន៍រំដោះ អ្នកបាចខិត្តប័ណ្ណនោះចេញពីភ្លើងកំហឹងរបស់ហ្វូងបាតុករ ហើយរុញចូលក្នុងរថយន្ត បើកជម្លៀសយកទៅព្យាបាលមុខរបួសនៅក្រសួងសន្តិសុខជាតិ ។ ក្នុងចំណោមអ្នកបាចខិត្តប័ណ្ណ២នាក់នោះ មានម្នាក់ឈ្មោះហូហាវ ជាសាស្ត្រាចារ្យរូបវិទ្យានៅវិទ្យាល័យព្រះស៊ីសុវត្ថិ ជាមនុស្សរបស់ទ្រង់សិរិមតៈ និងទ្រិញ វ៉ាញ ។

ពេលនោះ វរសេនីយ៍ឯកប៊ូ ហ៊ែល ជាស្នងការនគរបាលរាជធានីភ្នំពេញ និងជាប់សាច់ឈាមជាខ្សែរាជវង្សានុវង្ស ព្រមទាំងជាមនុស្សមានភក្តីភាពស្មោះត្រង់ជាមួយសម្តេចសីហនុ យ៉ាងប្តូរផ្តាច់បំផុតនោះ បានទាមទារឲ្យនាំជនទាំងពីរនេះមកស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ដើម្បីឱ្យគាត់សួរចម្លើយវិញ ដោយលើកហេតុផលថា ករណីនេះ ឋិតនៅក្នុងដែនសមត្ថកិច្ចរបស់គាត់ ។

ដោយសារតែវរសេនីយ៍ឯកប៊ូ ហ៊ែល នៅតែមានះទទូចទាមទារឱ្យបញ្ជូនអ្នកបាចខិត្តប័ណ្ណទាំង២នាក់នេះយកទៅឱ្យគាត់សួរចម្លើយនោះ ទ្រង់ស៊ីសុវត្ថិ សិរិមតៈ ក្នុងនាមឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អប់រំជាតិ, សម្របសម្រួលកិច្ចការសាសនា និងសន្តិសុខជាតិ ក៏បានបញ្ជាឱ្យចាប់វរសេនីយ៍ឯកប៊ូ ហ៊ែល យកទៅឃុំទុកមួយកន្លែង។



រូបឯកសាររបស់កាសែតក្នុងស្រុក
ចេញផ្សាយល្ងាចថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០

ពេលនោះ វរសេនីយ៍ឯកប៊ូ ហ៊ែល បាននិយាយទូរស័ព្ទនៅលើតុទៅអគ្គស្នងការដ្ឋានកងរាជតម្រួតនៅទួលគោក ក្នុងបំណងសុំឲ្យអ៊ុំ ម៉ាន្នរិន ជាបងថ្លៃរបស់សម្តេចសីហនុ និងជារដ្ឋលេខាធិការក្រសួងការពារលើផ្ទៃប្រទេស ជួយធ្វើអន្តរាគមន៍ឱ្យគេដោះលែងគាត់វិញ ព្រមទាំងទទូចឲ្យអ៊ុំ ម៉ាន្នរិន បេញបញ្ជាដល់កងពលតូចកងរាជតម្រួតរាជធានីភ្នំពេញ ដែលជាកងកម្លាំងពិសេស មានភារកិច្ចការពារសន្តិសុខផ្ទាល់របស់សម្តេចសីហនុ ឲ្យចេញទៅចាប់ខ្លួនឥស្សរជននៅក្នុងជួររាជរដ្ឋាភិបាល មួយចំនួន ដែលគាត់ដឹងថាជាអ្នកកំពុងរៀបចំធ្វើរដ្ឋប្រហារទម្លាក់សម្តេចសីហនុ ។

ជាមួយគ្នានោះ វរសេនីយ៍ឯកប៊ូ ហ៊ែល ក៏មានបំណងសុំឲ្យអ៊ុំ ម៉ាន្នរិន បញ្ជាទៅកងរាជតម្រួតខេត្តគ្រប់ខេត្តទាំងអស់ នាំកម្លាំងចូលមករាជធានីភ្នំពេញ ជាបន្ទាន់ ដើម្បីទប់ស្កាត់កុំឲ្យមានរដ្ឋប្រហារផងដែរ។ តែការហៅទូរស័ព្ទនៅលើតុរបស់វរសេនីយ៍ ឯកប៊ូ ហ៊ែល នេះ ត្រូវបានក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ថតសំឡេងបាន ។

ពេលនោះដែរ នៅក្នុងអគាររដ្ឋសភា អ៊ិន តាំ ជាប្រធានរដ្ឋសភាស្តីទី កំពុងដឹកនាំកិច្ចប្រជុំសួរដេញដោលវរសេនីយ៍ឯក អ៊ុំ ម៉ាន្នរិន ជារដ្ឋលេខាធិការក្រសួងមហាផ្ទៃទទួលបន្ទុកក្រសួងការពារលើផ្ទៃប្រទេស ពីរឿងជាប់ពាក់ព័ន្ធនឹងការរត់ពន្ធក្រណាត់មកពីក្រុងហុងកុង មានតម្លៃប្រមាណ៥០០ ០០០រៀល និងវរសេនីយ៍ឯកសុស្តែនហ្វែរណាង់ដេស រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលបន្ទុកក្រសួងសន្តិសុខជាតិ ពីរឿងមិនមានសមត្ថភាពបង្ក្រាបអំពើរត់ពន្ធនោះ ហើយគាត់ និងតំណាងរាស្ត្រមួយចំនួនក៏បានចេញមកជួប និងទទួលញត្តិពីតំណាងបាតុករទាំងអស់ ហើយបានប្រកាសថា សភានឹងវែកមុខអ្នកលក់ដីឱ្យពួកវៀតកុង-វៀតណាមខាងជើង ឱ្យឃើញតាមការទាមទាររបស់ពួកបាតុករ ។

បន្ទាប់ពីទទួលញត្តិពីក្រុមបាតុករមក អ៊ិន តាំ ព្រមទាំងអ្នកតំណាងរាស្ត្រ និងសមាជិកក្រុមប្រឹក្សាព្រះរាជាណាចក្រ កម្ពុជា បានបន្តសម័យប្រជុំពិសេសនោះបន្តទៀត ។

សម័យប្រជុំពិសេសនេះត្រូវបានគេតខ្សែក្បាលមីក្រូ ដាក់ចេញមកក្រៅ ដើម្បីឱ្យពួកបាតុករ ដែលនៅកកកុញខាងមុខរដ្ឋសភានោះ បានស្តាប់ផងដែរ។ ប៉ុន្តែ ដល់វេលាថ្ងៃត្រង់ ពួកបាតុករភាគច្រើន បាននាំគ្នាត្រលប់ទៅផ្ទះសម្បែងវិញជាបន្តបន្ទាប់ នៅសល់តែពួកបាតុករមួយចំនួនប៉ុណ្ណោះ ដែលនៅចាំស្តាប់កិច្ចប្រជុំនោះបន្តទៀត ។

នៅក្នុងអង្គប្រជុំពិសេសនោះ ជាមួយនឹងការសួរដេញដោលអ៊ុំ ម៉ាន់វិន យ៉ាងតានតឹង ពួកតំណាងរាស្ត្រជាមនុស្សជំនិតរបស់ព្រះអង្គម្ចាស់សិរិមត: ពិសេសតំណាងរាស្ត្រទ្រិញ វ៉ាញ ក៏បានឡើងមានមតិវាយប្រហារដៀមដាមទៅលើសម្តេចសីហនុ ដោយមិនបញ្ចេញព្រះនាមព្រះអង្គឱ្យចំៗ ជុំវិញបញ្ហាពុករលួយ និងការពាក់ព័ន្ធជាមួយការរត់ពន្ធក្រណាត់មកពីក្រុងហុងកុង របស់អ៊ុំ ម៉ាន់វិន ជាបងថ្លៃរបស់ព្រះអង្គ ។

តំណាងរាស្ត្រទ្រិញ វ៉ាញ បានប្រកាសខ្លាំងៗថា៖ ការអនុញ្ញាតឱ្យពួកវៀតកុង-វៀតណាមខាងជើង ចូលមកបោះទីតាំងនៅលើទឹកដីកម្ពុជា គឺជាអំពើក្បត់ជាតិមួយ ។

សម័យប្រជុំត្រូវបានបន្តរហូតដល់វេលារសៀល។ ក្រោយពីតំណាងរាស្ត្រមួយចំនួនទៀត បានឡើងមានមតិរិះគន់ វាយប្រហារដោយប្រយោលទៅលើសម្តេចសីហនុ កាន់តែមានសភាពធ្ងន់ធ្ងរឡើងៗ ក្បាលមីក្រូដែលដាក់បំពងសំឡេង នៅខាងមុខរដ្ឋសភានោះ ត្រូវគេបិទលែងឱ្យឮសំឡេង ហើយសភាក៏បិទទ្វារប្រជុំពិភាក្សាដោយសម្ងាត់វិញ។ រហូតដល់ពេលព្រលប់ អង្គប្រជុំនៅតែមិនបានសម្រេចលទ្ធផលអ្វីជាផ្លូវការ ពីបញ្ហាវត្តមានកងទ័ពវៀតកុង-វៀតណាមខាងជើង នៅលើទឹកដីកម្ពុជា អ៊ិន តាំ ក៏បានសម្រេចលើកសម័យប្រជុំនោះទៅថ្ងៃទី១៨ មីនា បន្តទៀត ។

នៅថ្ងៃទី១៧ ខែមីនា ទស្សនាវដ្តីថៃម របស់អាមេរិក បានចុះផ្សាយថា មុនពេលបញ្ចប់ដំណើរទស្សនកិច្ច៤ថ្ងៃ នៅទី ក្រុងមូស្គូ សម្តេចសីហនុ បានជួបពិភាក្សាជាមួយឡេអូនីដ ប្រេសណេវ (Leonid Brezhnev) អគ្គលេខាបក្សកុម្មុយនិស្តសហភាពសូវៀត ។

ព្រះអង្គបានសម្តែងការកោតសរសើរ ចំពោះមេដឹកនាំសហភាពសូវៀត។ ប៉ុន្តែព្រះអង្គមិនបានបញ្ជាក់ថា តើមេដឹកនាំសូវៀតបានយល់ព្រមជួយធ្វើអន្តរាគមន៍ឱ្យ

កងទ័ពវៀតកុង-វៀតណាមខាងជើង ដកចេញពីទឹកដីកម្ពុជា ឬយ៉ាងណាទេ ។

ទស្សនាវដ្តីថៃម បានចុះផ្សាយបន្តថា នៅក្នុងអំឡុងពេលគង់នៅទីក្រុងមូស្គូ សម្តេចសីហនុ បានបដិសេធមិនជួបធ្វើសម្ភាសជាមួយអ្នកកាសែតលោកខាងលិចទេ ហើយឯកអគ្គរាជទូតរបស់កម្ពុជាប្រចាំនៅទីក្រុងមូស្គូ បានច្រានចោលរាល់ការសុំជួបធ្វើសម្ភាស។ ប៉ុន្តែ ថ្ងៃនេះ(ថ្ងៃ១៧ មីនា) ព្រះអង្គនឹងធ្វើសេចក្តីថ្លែងការណ៍មួយតាមរយៈសារព័ត៌មាន តាស្ស(TASS) របស់សហភាពសូវៀត ។

ចំណែកនៅទីក្រុងភ្នំពេញ វិញ តាំងពីព្រឹក រហូតដល់ថ្ងៃរសៀលនៅថ្ងៃទី១៧ ខែមីនា គេមិនឃើញមានសភាពការណ៍អ្វីប្លែក ក្រៅពីជនជាតិវៀតណាម នៅតែបន្តការប្រុងប្រយ័ត្នពីសុវត្ថិភាពរបស់ពួកគេ ដោយនាំគ្នាសំងំនៅតែក្នុងផ្ទះរៀងៗខ្លួនប៉ុណ្ណោះ ។

លុះមកដល់ពេលព្រលប់ គេឃើញមានការដាក់ពង្រាយកងទ័ពនៅតាមបណ្តោយមហាវិថីសំខាន់ៗ ហើយរថពាសដែក និងរថយន្តដឹកកងទ័ពបានបើកល្បាតខ្វាត់ខ្វែងតាមផ្លូវសំខាន់ជាប់ជាប្រចាំ ពិសេសក៏មានរថពាសដែក ជាច្រើនគ្រឿង បានធ្វើសកម្មភាពជាលក្ខណៈ ត្រៀមប្រយុទ្ធនៅក្បែររបងព្រះបរមរាជវាំង មួយចំនួន និងមួយចំនួនទៀត បានបង្ហាញខ្លួននៅជុំវិញដំណាក់ចំការមន និងរដ្ឋសភាផងដែរ ។

អាកាសយានដ្ឋានពោធិ៍ចិនតុង ត្រូវបិទទ្វារ លែងឱ្យមានយន្តហោះចុះឡើង ។ វរសេនីយ៍ឯក អ៊ុំ ម៉ាន្នូរិន ជារដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលបន្ទុកក្រសួងការពារលើផ្ទៃប្រទេស ដែលត្រូវជាប្អូនថ្លៃរបស់សម្តេចសីហនុ និងវរសេនីយ៍ ប៊ូ ហ៊ែល ព្រមទាំងនាយទាហានជាន់ខ្ពស់មួយចំនួនទៀត ដែលមានស្វាមីភក្តិជាមួយសម្តេចសីហនុ ត្រូវគេចាប់យកទៅឃុំទុកនៅស្នងការដ្ឋានប៉ូលិសក្រុងភ្នំពេញ។ តែ វរសេនីយ៍ឯកសុស្តែន ហ្វែរណាំងដេស រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលបន្ទុកសន្តិសុខជាតិ មិនត្រូវបានគេចាប់ខ្លួនទេ ។

ថ្ងៃនោះដែរ សមាជិករាជវង្ស និងមន្ត្រីដែលមានភក្តីភាពជាមួយសម្តេចសីហនុ ជាច្រើននាក់បាននាំគ្នារត់ទៅ ជ្រកជាមួយព្រះមហាក្សត្រិយានី កុសុមៈ នៅក្នុងព្រះបរមរាជ

រាំង ព្រោះភ័យខ្លាចពីសុវត្ថិភាពផ្ទាល់ខ្លួន ។

តែទោះបីយ៉ាងណាក៏ដោយ ក៏នៅថ្ងៃទី១៧ ខែមីនា នោះ ព្រះមហាក្សត្រិយានី កុសុមៈ បានមានបន្ទូលតាមវិទ្យុជាតិ ទៅកាន់ប្រជារាស្ត្ររបស់ព្រះអង្គថា៖ តាំងពីថ្ងៃទី០៨ ខែមីនា មក កូនចៅគ្រប់ស្រទាប់នៅក្នុងសង្គម និងយុវជនយើង បានសម្តែងឱ្យឃើញនូវមនោសញ្ចេតនាជាឯកច្ឆន្ទ ប្រឆាំងនឹងវត្តមានរបស់ពួកសត្រូវរំលោភបំពានមកលើទឹកដីមាតុភូមិ ដែលយើងស្រឡាញ់ជាងជីវិតយើងទៅទៀត ។

មហាបាតុកម្មរបស់ប្រជារាស្ត្រជាកូនចៅនេះ មិនត្រឹមតែបង្ហាញឱ្យឃើញពីគំនិតជាតិនិយមដ៏មោះមុតប៉ុណ្ណោះទេ គឺថែមទាំងបង្ហាញឱ្យឃើញនូវកំហឹងឈឺចាប់របស់ប្រជាជាតិយើងទាំងមូល ក្នុងការប្រឆាំងនឹងអំពើឈ្លានពានដោយចេតនារបស់ពួកសត្រូវយើងផងដែរ ។ ខ្ញុំសូមកត់ត្រាទុកនៅក្នុងព្រះទ័យ នូវកតវេទិតាយ៉ាងជ្រាលជ្រៅរបស់បងប្អូនកូនចៅចំពោះព្រះរាជបល្ល័ង្ក និងចំពោះរូបខ្ញុំផ្ទាល់ ដែលបងប្អូនកូនចៅនៅតែចាត់ទុកថា ជាព្រះមាតាជាតិ និងនៅតែចាត់ទុកសម្តេចព្រះឧបយោរាជ (សម្តេចសីហនុ) ជាព្រះប្រមុខរដ្ឋ ដែលបងប្អូនកូនចៅធ្លាប់សន្យាថា ដង្ហែតាមនយោបាយរបស់ព្រះអង្គ គឺឯករាជ្យ អព្យាក្រឹត បូរណភាពទឹកដី លទ្ធិជាតិនិយម និងសង្គមនិយមព្រះពុទ្ធសាសនារហូតអវសានជីវិតនោះ ។

# ២៧២
# តំណាងរាស្ត្រឡើងមានមតិរិះគន់ វាយប្រហារសម្ដេចសីហនុ




រដ្ឋសភាសម័យមុន១៩៧០

គួររម្លឹកថា នៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៦០ គឺក្រោយពីព្រះមហាក្សត្រព្រះបាទសុរាម្រឹត សោយទិវង្គតទៅបានប្រហែល២ខែ សភាជាតិក៏បានប្រជុំធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ជំពូក១២ ស្តីពីបទបញ្ញត្តិពិសេស បន្ថែមលើមាត្រា ១២២ ថា៖ ក្នុងករណីដែលកាលៈទេសៈពុំអនុញ្ញាតឲ្យចាត់តាំងទាំងព្រះមហាក្សត្រថ្មី ទាំងក្រុមប្រឹក្សារាជអនុសិទ្ធិ ដោយអនុលោមទៅតាមបទបញ្ញត្តិមាត្រា៣០ និងមាត្រា៣០ ស្ទួននៃរដ្ឋធម្មនុញ្ញនោះ សភាទាំងពីរត្រូវរួមប្រជុំគ្នាតាម សេចក្តីអញ្ជើញនៃប្រធានរដ្ឋសភា និងក្រោមអធិបតីភាពនៃប្រធាននេះ ដោយអនុលោមទៅតាមឆន្ទៈដែលប្រជារាស្ត្របានសម្តែង សភាអាចលើកអំណាច និងបុព្វសិទ្ធិទាំងឡាយរបស់ប្រមុខរដ្ឋប្រគល់ទៅ

ជូនឥស្សរជនណាមួយរូប ដែលប្រជារាស្ត្រស្រឡាញ់ទុកចិត្ត បានបញ្ចេញមតិចង្អុលបង្ហាញយ៉ាងជាក់ច្បាស់ ។

ប្រសិនបើប្រមុខរដ្ឋពុំបានស្ថិតនៅក្នុងកម្ពុជារដ្ឋមួយដងមួយគ្រា ឬពុំអាចទទួលភារកិច្ចបានមួយដងមួយគ្រា ប្រមុខរដ្ឋប្រគល់ភារកិច្ចនេះទៅឲ្យប្រធានរដ្ឋសភា ។ ប្រធានរដ្ឋសភាទទួលកាន់កាប់ភារៈទាំងនេះដោយទទួលខុសត្រូវផ្ទាល់ខ្លួន ។

នៅក្នុងឆ្នាំ១៩៦០នោះដែរ បន្ទាប់ពីប្រជារាស្ត្រនាំគ្នាធ្វើបាតុកម្មគាំទ្រឱ្យសម្តេចសីហនុ ឡើងកាន់តំណែងជា ព្រះប្រមុខរដ្ឋ ជួប ហែល ប្រធានរដ្ឋសភាបានកោះប្រជុំសមាជិករដ្ឋសភាប្រកាសសុំឱ្យតំណាងរាស្ត្រទាំងអស់អនុម័តគាំទ្រឱ្យសម្តេចសីហនុគង់នៅជាព្រះប្រមុខរដ្ឋអស់មួយជីវិតផងដែរ ។

នៅក្នុងការបោះឆ្នោតសភាថ្ងៃទី១១ ខែកញ្ញា ឆ្នាំ១៩៦៦ លទ្ធផលដែលបេក្ខជនជាប់ឆ្នោតជាតំណាងរាស្ត្រ រួមមាន៖ ១.តាន់អ៊ុក ណាំអៀង តំណាងរាស្ត្រមណ្ឌលសង្កាត់លេខ៣ ក្រុងភ្នំពេញ, ២.ញ៉ែម នាង តំណាងរាស្ត្រមណ្ឌលសង្កាត់លេខ៥ ក្រុងភ្នំពេញ, ៣.ស៊ឹម វ៉ា តំណាងរាស្ត្រមណ្ឌលសង្កាត់លេខ៦ ក្រុងភ្នំពេញ, ៤.ភី ធៀនឡាយ តំណាងរាស្ត្រមណ្ឌលស្វាយប៉ោ ខេត្តបាត់ដំបង, ៥.ឈរ សេងហាប់ តំណាងរាស្ត្រមណ្ឌលតាម៉ឺន ខេត្តបាត់ដំបង, ៦.ព្រំ សេង តំណាងរាស្ត្រមណ្ឌលគោកឃ្មុំ ខេត្តបាត់ដំបង, ៧.អ៊ុន ត្រមុចតំណាងរាស្ត្រមណ្ឌលបវេល ខេត្តបាត់ដំបង, ៨.ដាញ់ សាង តំណាងរាស្ត្រមណ្ឌល ( ? ) ខេត្តបាត់ដំបង, ៩.ឡុង ក្ងង តំណាងរាស្ត្រមណ្ឌលតាប៉ុន ខេត្តបាត់ដំបង, ១០.ហ៊ុលវង្ស អានុភាព តំណាងរាស្ត្រមណ្ឌលភ្នៀត ខេត្តបាត់ដំបង, ១១.ផ្ទេក ភីន តំណាងរាស្ត្រមណ្ឌលព្រះនេត្រព្រះ ខេត្តបាត់ដំបង, ១២.តាន់ ឈាងលីម តំណាងរាស្ត្រមណ្ឌលច្បារអំពៅ ខេត្តកណ្តាល, ១៣.យ៉ែម សំបូរ តំណាងរាស្ត្រមណ្ឌលសំពៅងធំ ខេត្តកណ្តាល, ១៤.ឆន បេង តំណាងរាស្ត្រមណ្ឌលព្រែកស្តី ខេត្តកណ្តាល, ១៥.ខៀវ សំផនតំណាងរាស្ត្រមណ្ឌលព្រែកអំបិល ស្រុកស្អាង ខេត្តកណ្តាល, ១៦.កែវ សាន តំណាងរាស្ត្រមណ្ឌលតាខ្មៅ ខេត្តកណ្តាល (អនុប្រធានរដ្ឋសភា), ១៧.លោកស្រីពុង ប៉េង

ចេង ( នាមដើម ស៊ីវ អេងគុង ) តំណាងរាស្ត្រមណ្ឌលគោកត្រប់ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល, ១៨.ង៉ូវ ទៀម តំណាងរាស្ត្រមណ្ឌលម្កាក់ ខេត្តកណ្ដាល, ១៩.ទេព ស៊ុនទី តំណាងរាស្ត្រមណ្ឌល ជ្រៃលាស់ ខេត្តកណ្ដាល, ២០.ព្រះអង្គម្ចាស់ស៊ីសុវត្ថិ សុវណ្ណារ៉េត តំណាងរាស្ត្រមណ្ឌលរកាកោង ខេត្តកណ្ដាល, ២១.ពិន យឿន តំណាងរាស្ត្រមណ្ឌលព្រែកតាមាក់ ខេត្តកណ្ដាល, ២២.កែម ផាត តំណាងរាស្ត្រមណ្ឌលសំពងជ័យ ខេត្តកំពង់ចាម, ២៣.ចៅសែន កុសលឈុំ តំណាងរាស្ត្រមណ្ឌលកំពង់ចាម ខេត្តកំពង់ចាម, ២៤.យក់ យីម តំណាងរាស្ត្រមណ្ឌលកោះសូទិន ខេត្តកំពង់ចាម, ២៥. អ៊ិន តាំ តំណាងរាស្ត្រមណ្ឌលប៉ុស ខេត្តកំពង់ចាម, ២៦.នៃ គឹមហុង តំណាងរាស្ត្រមណ្ឌល( ? ) ខេត្តកំពង់ចាម, ២៧.សេង យុយហួត តំណាងរាស្ត្រមណ្ឌលថ្មពេជ្រ ខេត្តកំពង់ចាម, ២៨.គួង លីហុង តំណាងរាស្ត្រមណ្ឌលកណ្ដាលជ្រំ ខេត្តកំពង់ចាម, ២៩.ហ៊ូ នឹម តំណាងរាស្ត្រមណ្ឌលជ្រៃវៀន ខេត្តកំពង់ចាម, ៣០.ជួន ប៉ុណ្ណារ៉ាហេង តំណាងរាស្ត្រមណ្ឌលព្រែកដំបូក ខេត្តកំពង់ចាម, ៣១.ហ៊ូ យន់ តំណាងរាស្ត្រមណ្ឌលសូគង់ ខេត្តកំពង់ចាម, ៣២.លោកស្រីអ៊ិន តាំ( ប្រពន្ធ អ៊ិន តាំ នាមដើម អ៊ិន តាត ) តំណាងរាស្ត្រមណ្ឌលស្ដី ខេត្តកំពង់ចាម, ៣៣.គុយពៅ តំណាងរាស្ត្រមណ្ឌលព្រែកកក់ ខេត្តកំពង់ចាម, ៣៤.តោ ឈុន តំណាងរាស្ត្រមណ្ឌលកំពង់លាវ ខេត្តព្រៃវែង, ៣៥.អ៊ាប លាងហ៊ិត តំណាងរាស្ត្រមណ្ឌលបឹងព្រះ ខេត្តព្រៃវែង, ៣៦.អឿ តូលុច តំណាងរាស្ត្រមណ្ឌលចាម ខេត្តព្រៃវែង, ៣៧.កែវ ស្រណោះ តំណាងរាស្ត្រមណ្ឌលពញាលឿង ខេត្តព្រៃវែង, ៣៨.ឧប គឹមអាង តំណាងរាស្ត្រមណ្ឌលរកា ខេត្តព្រៃវែង, ៣៩.លោកស្រីដៀបឱណារ តំណាងរាស្ត្រមណ្ឌលក្អៀងរាយ ខេត្តព្រៃវែង, ៤០.យី យ៉ាម៉ារ៉េត តំណាងរាស្ត្រមណ្ឌលស្មោង ខេត្តព្រៃវែង, ៤១.វ៉ា ជួន តំណាង រាស្ត្រមណ្ឌលស្វាយជ្រំ ខេត្តស្វាយរៀង, ៤២.ឌី បែលឡុង តំណាងរាស្ត្រមណ្ឌលច្រកម្ទេស ខេត្តស្វាយរៀង, ៤៣.អ៊ិន យ៉ុង តំណាងរាស្ត្រមណ្ឌលគគីរសោម ខេត្តស្វាយរៀង, ៤៤.សេក សាម៉ុំ តំណាងរាស្ត្រមណ្ឌលព្រៃស្វាយ ខេត្តស្វាយរៀង, ៤៥.តាន់ អ៊ិនថេង តំណាងរាស្ត្រមណ្ឌលកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង, ៤៦.ញឹក ញុញ តំណាងរាស្ត្រមណ្ឌល

ចោង ម៉ោង ខេត្តកំពង់ឆ្នាំង, ៤៧.ឱក វ៉ាស៊ី តំណាងរាស្ត្រមណ្ឌលពានី ខេត្តកំពង់ឆ្នាំង, ៤៨.ឡុង ផិន តំណាងរាស្ត្រមណ្ឌលព្រៃគ្រី ខេត្តកំពង់ឆ្នាំង, ៤៩.លោកស្រីទូ នៅ តំណាងរាស្ត្រមណ្ឌលព្រះម្លូ ខេត្តពោធិ៍សាត់, ៥០.ចេង តែម តំណាងរាស្ត្រមណ្ឌលផ្សារក្រោម ខេត្តពោធិ៍សាត់, ៥១.មាស យ៉ង់ តំណាងរាស្ត្រមណ្ឌលតាឡូ ខេត្តពោធិ៍សាត់, ៥២.លី ធៀងចេក តំណាងរាស្ត្រមណ្ឌលទ្រៀល ខេត្តកំពង់ធំ, ៥៣.នង ឈុំ តំណាងរាស្ត្រមណ្ឌលកំពង់ចិន ខេត្តកំពង់ធំ, ៥៤.ជះ ឆេង តំណាងរាស្ត្រមណ្ឌលស្រយ៉ូវ ខេត្តកំពង់ធំ, ៥៥.ញឹក ផុន (ប្អូនញឹក ជូឡុង) តំណាងរាស្ត្រមណ្ឌលតាំងក្រសាំង ខេត្តកំពង់ធំ, ៥៦. លឹម ស៊ា តំណាងរាស្ត្រមណ្ឌលក្រចេះ ខេត្តក្រចេះ, ៥៧. ហឿរ ឡាយអ៊ីន តំណាងរាស្ត្រមណ្ឌលស្នួល ខេត្តក្រចេះ, ៥៨.កែម ណាយ តំណាងរាស្ត្រមណ្ឌលអូររាំង ខេត្តមណ្ឌលគិរី, ៥៩.ជួន ស៊ុនួន តំណាងរាស្ត្រមណ្ឌលក្បាលរមាស ខេត្តកំពត, ៦០.កង សាផាន់ តំណាងរាស្ត្រមណ្ឌល... ខេត្តកំពត, ៦១.តូច ជីម តំណាងរាស្ត្រមណ្ឌលឈូក ខេត្តកំពត, ៦២.ឡោវ ផុន តំណាងរាស្ត្រ មណ្ឌលភ្នំកុង ខេត្តកំពត, ៦៣.ឯក យីអ៊ុន តំណាងរាស្ត្រមណ្ឌលញ៉ែងញ៉ង ខេត្តតាកែវ, ៦៤.មាន ចេង តំណាងរាស្ត្រមណ្ឌលបឹងត្រាញ់ ខេត្តតាកែវ, ៦៥.គីម ឡេ តំណាងរាស្ត្រមណ្ឌលត្រពាំងសាប ខេត្តតាកែវ, ៦៦.ឈុន ប៉ែន តំណាងរាស្ត្រមណ្ឌលបាពយណ៍ ខេត្តតាកែវ, ៦៧.ថាច់ ច័ន្ទ តំណាងរាស្ត្រមណ្ឌលគោកព្រេច ខេត្តតាកែវ, ៦៨.នេត្រ ប៊ិន តំណាងរាស្ត្រមណ្ឌលបាស្រែ ខេត្តតាកែវ, ៦៩. ម៉េច ប៊ុន តំណាងរាស្ត្រមណ្ឌលព្រះនិព្វាន ខេត្តកំពង់ស្ពឺ, ៧០.អ៊ុម ផុន តំណាងរាស្ត្រមណ្ឌលផុង ខេត្តកំពង់ស្ពឺ, ៧១.អ៊ុង ម៉ឹង តំណាងរាស្ត្រមណ្ឌលក្រាំងអំបិល ខេត្តកំពង់ស្ពឺ, ៧២.អ៊ូច ឯក តំណាងរាស្ត្រមណ្ឌលពាំងល្វា ខេត្តកំពង់ស្ពឺ, ៧៣.តុប ឃិន តំណាងរាស្ត្រមណ្ឌលវាលពន់ ខេត្តកំពង់ស្ពឺ, ៧៤.ឡុង បូរ៉េត តំណាងរាស្ត្រមណ្ឌលស្ទឹងត្រែង ខេត្តស្ទឹងត្រែង, ៧៥.ហង់ សារុន តំណាងរាស្ត្រមណ្ឌលកុកឡាក់ ខេត្តរតនគិរី, ៧៦.ថាន ស៊ិន តំណាងរាស្ត្រមណ្ឌលត្រពាំង ខេត្តកោះកុង, ៧៧.ទ្រិញ វ៉ាញ តំណាងរាស្ត្រមណ្ឌលសៀមរាប ខេត្តសៀមរាប, ៧៨.កើក គីលីម តំណាងរាស្ត្រមណ្ឌលសាងវើយ ខេត្តសៀមរាប,

៧៩.ឧត្តមស៊ិរិ នៃណារ៉ុង តំណាងរាស្ត្រមណ្ឌលត្រពាំងធំ ខេត្តសៀមរាប, ៨០.ហុង ទូហាយ តំណាងរាស្ត្រមណ្ឌលតាសោម ខេត្តសៀមរាប, ៨១.ឱក សឿម តំណាងរាស្ត្រមណ្ឌលសំរោង ខេត្តឧត្តរមានជ័យ, ៨២.តាន់ គឹមវុន តំណាងរាស្ត្រមណ្ឌលបាក់ក្តោង ខេត្តព្រះវិហារ ។

ឆ្នាំ១៩៦៧ ខៀវ សំផន តំណាងរាស្ត្រមណ្ឌលព្រែកអំបិល ខេត្តកណ្តាល, ហ៊ូយន់ តំណាងរាស្ត្រមណ្ឌលស្វាយគង់ ខេត្តកំពង់ចាម និងហ៊ូ នឹម តំណាងរាស្ត្រមណ្ឌលជ្រៃវៀន ខេត្តកំពង់ចាម នាំគ្នារត់ចូលព្រៃទៅតស៊ូជាមួយពួកខ្មែរក្រហម ។

ឆ្នាំ១៩៦៨ តំណាងរាស្ត្រមណ្ឌលសង្កាត់លេខ៥ ក្រុងភ្នំពេញ ឈ្មោះញ៉ែម នាង ទទួលមរណភាព ចេង ហេង បានឡើងជាតំណាងរាស្ត្រមណ្ឌលសង្កាត់លេខ៥ ជំនួស ។

នៅវេលាម៉ោង៩ព្រឹក ថ្ងៃពុធទី១៨ ខែមីនា ឆ្នាំ១៩៧០ នៅជុំវិញអគាររដ្ឋសភាមានការរាយបណ្តាក់កម្លាំងទាហាន និងមានរថពាសដែក ជាច្រើនគ្រឿងផងដែរ រដ្ឋសភាបានបើកអង្គប្រជុំវិសាមញ្ញមួយ ដើម្បីបោះឆ្នោតដកសេចក្តីទុកចិត្ត វរសេនីយ៍ឯកសុស្តែន ហ្វែរណង់ដេស រដ្ឋលេខាធិការក្រសួងមហាផ្ទៃទទួលបន្ទុកក្រសួងសន្តិសុខជាតិ ដែលរងការចោទប្រកាន់ថា បានស៊ុមគ្រលុំគប់គិតសមគំនិតជាមួយអំពើរត់ពន្ធរបស់វរសេនីយ៍ឯក អ៊ុំ ម៉ាន្នរិន ជារដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលបន្ទុកក្រសួងការពារលើផ្ទៃប្រទេស ។

បន្ទាប់មកទៀត ដោយសារមានការរំជើបរំជួលពេញទីក្រុងភ្នំពេញ តាំងពីថ្ងៃមានបាតុកម្មវាយស្ថានទូត វៀតកុង-វៀតណាមខាងជើង ថ្ងៃទី១១ ខែមីនាមក រដ្ឋសភា និងក្រុមប្រឹក្សាព្រះរាជាណាចក្រកម្ពុជា បានសម្រេចជាឯកច្ឆន្ទដាក់ប្រទេសជាតិឱ្យស្ថិតនៅក្នុងភាពប្រកាសអាសន្នរយៈពេល២ខែ និងបានប្រកាសប្រគល់អំណាចទៅឱ្យ រាជរដ្ឋាភិបាលកាន់តែធំជាងមុនទៅទៀត ដើម្បីឱ្យមានលទ្ធភាពដោះស្រាយស្ថានការណ៍ប្របូកប្របល់ ដែលបង្កឡើងដោយពួកវៀតកុង-វៀតណាមខាងជើង ព្រមទាំងសត្រូវនៅក្នុង និងក្រៅប្រទេសផងដែរ ។

ចាប់ពីម៉ោង១១ សមាជិករដ្ឋសភា និងក្រុមប្រឹក្សាព្រះរាជាណាចក្រកម្ពុជា បាន

លើកយកករណីសម្តេចសីហនុ មកធ្វើការពិភាក្សា ដោយបិទទ្វាររដ្ឋសភាជិត មិនឱ្យនរណាចេញចូលឡើយ។ ប៉ុន្តែ មុនការចាប់ផ្តើមយកករណីសម្តេចសីហនុ មកធ្វើការពិភាក្សា គេឃើញទ្រិញ វ៉ាញ ជាប្រធានគណៈកម្មការហិរញ្ញវត្ថុ និងរដ្ឋបាលរបស់រដ្ឋសភាដើរឆ្វាត់ឆ្វែងតាមចន្លោះជួរកៅអីមួយ ទៅជួរកៅអីមួយទៀត ខ្សឹបប្រាប់ពួកតំណាងរាស្ត្រទាំងអស់ ពីគ្រោងការសម្ងាត់របស់រាជរដ្ឋាភិបាល ដើម្បីទម្លាក់សម្តេចសីហនុ ហើយគាត់បានគំរាមថា រាជរដ្ឋាភិបាលនឹងបញ្ជាឱ្យសម្លាប់ចោលភ្លាមៗ នៅនឹងកន្លែង ចំពោះតំណាងរាស្ត្រណាដែលប្រឆាំងនឹងគម្រោងការសម្ងាត់នេះ ទៀតផង ។

ជាកិច្ចចាប់ផ្តើមតំណាងរាស្ត្រទ្រិញវ៉ាញ,ហឿ ឡែអ៊ីន.ព្រុំសេង,អ៊ួចឯក,ដាញ់សាងបានឡើងមានមតិរិះគន់ វាយប្រហារទៅលើសម្តេចសីហនុ ខ្លាំងៗជាបន្តបន្ទាប់ ដោយអ្នកខ្លះលើកឡើងថា សីហនុ ជាអ្នកបោកបញ្ឆោត ប្រជារាស្ត្រនិងបានជាន់ឈ្លីទៅលើគោលការណ៍ធំៗ ដែលមានចែងនៅក្នុងលក្ខន្តិកៈរបស់ចលនាសង្គមរាស្ត្រនិយម ។

តំណាងរាស្ត្រខ្លះថា ក្រោយពីបានឡើងកាន់អំណាចដោយសារតែប្រជារាស្ត្រជាសមាជិកចលនាសង្គមរាស្ត្រនិយម ដែលសង្ឃឹមថា សីហនុ នឹងធ្វើឱ្យប្រជារាស្ត្រមានអនាគតល្អប្រសើរជាងមុននោះ សីហនុ បែរជាធ្វើអ្វីៗស្រេចតែក្បាលចិត្ត ដោយគ្មានយកចិត្តទុកដាក់ពីសេចក្តីត្រូវការរបស់ប្រជារាស្ត្របន្តិចឡើយ។ សីហនុ គ្មានគិតអ្វីក្រៅតែពីបម្រើតែផលប្រយោជន៍សមាជិករាជវង្សានុវង្សរបស់ខ្លួនតែប៉ុណ្ណោះ ។



តំណាងរាស្ត្រ ទ្រិញ វ៉ាញ

នេះជាលើកទី១ហើយ ដែលពួកតំណាងរាស្ត្រទាំងនោះបានប្រើពាក្យថា សីហនុៗដោយមិនប្រើពាក្យថា សម្តេចឪ ឬព្រះករុណា ដូចពេលប្រជុំសភាកាលពីមុនៗ។ តំណាងរាស្ត្រខ្លះបានលើក

ឡើងថា អ្នកម្នាងម៉ូនិក ជាមហេសីរបស់សីហនុ ជាអ្នកធ្វើអន្តរាគមន៍ចំពោះការផ្តល់តំណែងនៅកន្ទែងខ្ពាញ់ៗ ដូចជាតំណែងអគ្គនាយកទីចាត់ការគយ និងរដ្ឋាករ ព្រមទាំងតំណែងអគ្គនាយកក្រុមហ៊ុនរដ្ឋផ្សេងៗទៀតដល់ពួកមន្ត្រីពុករលួយ ដែលមានទ្រព្យសម្បត្តិស្តុកស្តម្ភ ដើម្បីទាញយកផលប្រយោជន៍ពីពួកនោះវិញ។ ឯមន្ត្រីណាដែលស្អាតស្អំ គ្មានប្រាក់កាស ទោះបីអ្នកនោះមានសញ្ញាបត្រថ្នាក់បណ្ឌិតក៏ដោយ ក៏សីហនុ មិនឱ្យកាន់តំណែងទាំងនោះដែរ ។

តំណាងរាស្ត្រខ្លះបានលើកឡើងថា សីហនុ បានអនុញ្ញាតឱ្យគេបើកកាស៊ីណូលេងល្បែងស៊ីសង គឺដើម្បីបំផ្លិចបំផ្លាញបង្ហិនបង្ហោចប្រជារាស្ត្រខ្មែរ ។ សីហនុ ការពារតែមន្ត្រីពុករលួយ ដោយគ្មានការអៀនខ្មាស ដូចជាស្រី ប៉ុង( រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្ម) ឱ្យពួកឈ្មួញដឹកទំនិញផ្សេងៗ ឆ្លងកាត់ទឹកដីខ្មែរដោយគ្មានបង់ពន្ធចូលរដ្ឋ ។

សីហនុ ធ្វើឱ្យបាត់បង់កិត្យានុភាពរបស់ប្រទេសជាតិនៅលើឆាកអន្តរជាតិ និងបង្កើតបរិយាកាសមិនទុកចិត្តគ្នាចំពោះអ្នកវិនិយោគជាតិ និងអន្តរជាតិ ដែលជាហេតុធ្វើឱ្យរាំងស្ទះដល់ការលូតលាស់របស់សេដ្ឋកិច្ចជាតិ ។

សីហនុ ជាអ្នកធ្វើប្រជាភិថុត បោកបញ្ឆោតប្រជារាស្ត្រថា ខ្លួនបានផ្តល់អ្វីៗគ្រប់យ៉ាង ដូចជាកសាងមន្ទីរពេទ្យ សាលារៀន ផ្តល់ម៉ាស៊ីនបូមទឹកដល់ប្រជាកសិករ ជាដើម។ ប៉ុន្តែ សួរថា តើ សីហនុ បានប្រាក់កាសនេះមកពីណា យកទៅកសាងអគារ និងទិញសម្ភារៈទាំងអស់នោះ ទៅចែកជូនប្រជារាស្ត្រ? ប្រាក់កាសនោះ គឺប្រាក់កាសរបស់ប្រជារាស្ត្រ មិនមែនជាប្រាក់កាសរបស់សីហនុ ទេ ។

សីហនុ មិនគិតគូរដល់សុខមាលភាពរបស់ប្រជារាស្ត្រទេ នៅពេលប្រជារាស្ត្រជួបការលំបាកអត់ឃ្លាន សីហនុ បែរជារៀបចំពិធីមហោស្រពសិល្បៈផ្សេងៗ ដើម្បីជាការកម្សាន្តយ៉ាងអធិកអធមទៅវិញ ដោយបានអញ្ជើញបណ្តាគណៈប្រតិភូជាច្រើនប្រទេសឱ្យមកចូលរួម និងត្រូវចំណាយថវិការដ្ឋអស់រាប់សិបលានរៀល ។

ជាមួយគ្នានោះដែរ បើសីហនុ សព្វព្រះទ័យចំពោះកញ្ញាស្រស់ស្អាតណាម្នាក់ ហើយនោះ សីហនុ ហ៊ានផ្ដល់ប្រាក់ឱ្យយ៉ាងតិចបំផុត ក៏១០ម៉ឺនរៀលដែរ តែសម្រាប់ទាហានម្នាក់ ដែលបានពលីជីវិតនៅលើសមរភូមិ សីហនុ ផ្ដល់អំណោយ ត្រឹមតែ១ម៉ឺនរៀលប៉ុណ្ណោះ ។

តំណាងរាស្ត្រខ្លះទៀតបានលើកឡើងថា នយោបាយដឹកនាំប្រទេសរបស់សីហនុ គ្មានអ្វីក្រៅពីអនុញ្ញាតឱ្យកងទ័ពវៀតកុង-វៀតណាមខាងជើង បោះទីតាំងនៅលើទឹកដីកម្ពុជា ឡើយ។ សីហនុ បានរំលោភបំពានទៅលើរាជរដ្ឋាភិបាល បណ្ដាលឱ្យខូចផលប្រយោជន៍ប្រជារាស្ត្រតូចតាច។ សីហនុ អួតខ្លួនថា ស្រឡាញ់ប្រជារាស្ត្រ និងប្រទេសជាតិជាងអ្វីៗទាំងអស់។ ប៉ុន្តែ ការពិត ខ្លួនបានឱ្យគេដឹកជញ្ជូនគ្រឿងអាវុធទៅឱ្យពួកវៀតកុង-វៀតណាមខាងជើង ហើយបន្ទាប់មក ពួកវៀតកុង បានយកអាវុធទាំងអស់នោះ មកប្រឆាំងនឹងប្រជារាស្ត្រខ្មែរវិញ។ សីហនុ ចូលចិត្តធ្វើឱ្យមន្ត្រី ដែលមិនចេះអែបអបខ្លួនរងការអាម៉ាស់នៅចំពោះមុខមហាជន ។

សីហនុ អួតខ្លួនឯងថា ស្រឡាញ់ និងគោរពប្រជារាស្ត្រ តែខ្លួនបានប្រមាថមើលងាយទៅលើពួកតំណាងរាស្ត្រ ដែលជាតំណាងដ៏ត្រឹមត្រូវរបស់ប្រជារាស្ត្រ ដូចសត្វជាតុ ។

សីហនុ ចោទប្រកាន់តំណាងរាស្ត្រទាំងឡាយណា ដែលពុំមានទស្សនៈនយោបាយដូចខ្លួនថា សុទ្ធតែជាឧក្រិដ្ឋជនទាំងអស់ ។

សីហនុ ប៉ិនប្រសប់ប្រើល្បិចនយោបាយក្ដិចស្រមោចសង្គ្រារឱ្យជល់គ្នា ដោយប្រើល្បិចចាក់រុកឱ្យខ្មែរឈ្លោះជាមួយខ្មែរ ដើម្បីពង្រឹងពង្រីកអំណាចរបស់ខ្លួន ឱ្យកាន់តែខ្លាំងក្លារឹងមាំថែមទៀត ។

ចំណែកតំណាងរាស្ត្រស៊ឹម វ៉ា ដែលធ្លាប់សម្ដេចសីហនុ បញ្ជាឱ្យសមាជិកសភាភាគច្រើនបោះឆ្នោតដកអភ័យឯកសិទ្ធិសភារបស់គាត់នោះ បានឡើងមានមតិថា៖ ពីមុនខ្ញុំចេញមុខប្រឆាំងតិទៀនសម្ដេចសីហនុ តែម្នាក់ឯង គេនាំគ្នាស្អប់ខ្ញុំ...។

ឥឡូវនេះ គេនាំគ្នាចោមរោមស្រែកថ្កោលទោសសម្តេចសីហនុ ដូច្នេះ ខ្ញុំមិនចូលដៃជាមួយទេ គឺខ្ញុំដើរតួជាអ្នកការពារសម្តេចសីហនុ វិញ ។

ដោយឡែក ភួង សាន ជាសមាជិកក្រុមប្រឹក្សាព្រះរាជាណាចក្រ បានឡើងថ្លែងមតិការពារព្រះកិត្តិនាមសម្តេច សីហនុ និងបានព្រមានឱ្យសភាត្រៀមទប់ទល់ចំពោះការប្រឆាំងតបតនូវពាល់ពាក្យសម្តីវាយប្រហារប្រមាថសម្តេចសីហនុ ដែលគ្មានការត្រិះរិះពិចារណាទាំងអស់នេះផងដែរ ។

ពេល ភួង សាន កំពុងបញ្ចេញមតិ មិនទាន់ចប់ផង ត្រូវគេអូសទម្លាក់ពីវេទិកា ហើយនាំខ្លួនទៅឱ្យទ្រង់សិរិមតៈ ដែលនៅក្នុងអគាររដ្ឋសភានោះដែរ។ ទ្រង់សិរិមតៈក៏បានសម្លុតគំរាមកំហែងឱ្យ ភួង សាន ឱ្យឡើងប្រកាសបដិសេធនូវពាក្យសម្តីទាំងប៉ុន្មានដែលគាត់បានឡើងថ្លែងការពារព្រះកិត្តិនាមសម្តេចសីហនុ នោះវិញ ។

លុះដល់វេលាម៉ោង១រសៀល តំណាងរាស្ត្រនិងសមាជិកក្រុមប្រឹក្សាព្រះរាជាណាចក្រ ដែលមានវត្តមាននៅក្នុង អង្គប្រជុំនោះទាំងអស់ ត្រូវបានគេឱ្យចុះហត្ថលេខាលើសន្លឹកឆ្នោតដែលគេចែកឱ្យម្នាក់មួយសន្លឹកៗ មុននឹងយកទៅ បោះក្នុងហឹបឆ្នោត ដើម្បីដកសេចក្តីទុកចិត្តពីសម្តេចសីហនុ និងទម្លាក់ព្រះអង្គចេញពីអំណាចផងដែរ ។

នៅទីបំផុត សមាជិកសភាចំនួន៧៣នាក់ និងសមាជិកក្រុមប្រឹក្សាព្រះរាជាណាចក្រចំនួន១៩នាក់ ដែលមានវត្តមាននៅក្នុងអង្គប្រជុំ សរុប៩២នាក់ បានបោះឆ្នោតដកសេចក្តីទុកចិត្តពីសម្តេចសីហនុ ជាឯកច្ឆន្ទ ដោយមានសំឡេង៩២លើ៩២ ហើយអះអាងថា ការបោះឆ្នោតទម្លាក់សម្តេចសីហនុ នេះគឺស្របតាមជំពូក ១២ មាត្រា១២២ នៃច្បាប់រដ្ឋធម្មនុញ្ញ ។

តែបើតាមការអះអាងរបស់ស៊ឹម វ៉ា បានឱ្យដឹងថា ពេលនោះមានតំណាងរាស្ត្រ ២រូប គឺ គឹម ផុន និងសុះ សាអ៊ុន បានសម្រេចចិត្តបោះឆ្នោតអនុបវាទ។ ប៉ុន្តែ ដើម្បីបង្ហាញឱ្យឃើញថា តំណាងរាស្ត្រទាំងអស់(គ្មានសល់ម្នាក់) បានបោះឆ្នោតដកសេចក្តីទុកចិត្តពីសម្តេចសីហនុ សភាក៏ប្រកាសថា សភាបានបោះឆ្នោតដកសេចក្តីទុកចិត្តពីសម្តេចសីហនុ

ជាឯកច្ឆន្ទ ដោយសំឡេងគាំទ្រ១០០ភាគរយ ។



លទ្ធផលបោះឆ្នោតទម្លាក់សម្តេចសីហនុ ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០

# ២៧៣
# ថ្ងៃ១៨មីនា រដ្ឋប្រហារទម្លាក់សម្ដេចសីហនុ ចេញពីអំណាច



**អ៊ិន តាំ ប្រធានរដ្ឋសភាស្ដីទី**

នៅទីបំផុត រដ្ឋសភាបានចេញសេចក្ដីថ្លែងការណ៍ថ្កោលទោសកំហុស៥ចំណុច របស់សម្ដេចសីហនុ ដើម្បីឱ្យប្រជារាស្ត្រទូទៅបានដឹងផងដែរ។ កំហុសទាំង៥ចំណុច របស់សម្ដេចសីហនុ គឺ៖

ទី១-កម្ពុជា បានប្រកាន់យកអព្យាក្រឹតភាពជាខ្សែបន្ទាត់នយោបាយក្នុងការដឹកនាំប្រទេស។ ប៉ុន្តែ សីហនុ បានដឹកនាំប្រទេសចេញពីមាគ៌ានេះ គឺធ្វើអ្វីៗបង្កឱ្យប្រជារាស្ត្រ មានការព្រួយបារម្ភ និងខ្វល់ខ្វាយពីអនាគតរបស់ខ្លួន ។

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ សីហនុ បានគប់គិតជាមួយចិនកុម្មុយនិស្ត បង្វែរអព្យាក្រឹតភាពទៅទិសខាងឆ្វេង រហូតដល់អនុញ្ញាតឱ្យបង្កើតសមាគមមួយ ហៅថា សមាគមមិត្តភាពកម្ពុជា-ចិន ដែលមានសីហនុ ខ្លួនឯងជាប្រធានកិត្តិយស ។

ដោយមានវត្តមានសីហនុជាប្រធានកិត្តិយសរបស់សមាគមនេះ យុវជន សាស្ត្រាចារ្យ

កសិករ និងមន្ត្រីផ្សេងៗទៀតជាច្រើនត្រូវបានគេបង្ខិតបង្ខំឱ្យចូលជាសមាជិកសមាគមនេះ។

ជាមួយគ្នានេះ ជនមួយចំនួននៅសំឡូត ខេត្តបាត់ដំបង នៅព្រៃទទឹង ខេត្តកំពង់ចាម នៅខេត្តរតនគិរី នៅខេត្តមណ្ឌលគិរី បាននាំគ្នាចុះឈ្មោះចូលជាសមាជិកសមាគមនេះ ដោយមិនបានដឹងថា ថ្ងៃណាមួយ ការចុះឈ្មោះចូលជាសមាជិកនេះ អាចក្លាយជាឧបករណ៍សម្រាប់សម្លាប់ខ្លួនឯងឡើយ។ បន្តិចក្រោយមក ទើបសីហនុ ដឹងថាសកម្មភាពធ្វើវិទ្ធង្សនាទាំងឡាយរបស់ពួកខ្មែរក្រហមនោះ គឺដឹកនាំដោយពួកចិនកុម្មុយនិស្ត ដែលនៅពីក្រោយរាំងននសមាគមនេះ សីហនុ ក៏សម្រេចរំលាយសមាគមមិត្តភាពកម្ពុជា-ចិននោះចោលវិញ ហើយបានបញ្ជូនទៅបងថ្លៃ ឈ្មោះអ៊ុំ ម៉ាន្នូរិន ជារដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលបន្ទុកក្រសួងការពារលើផ្ទៃប្រទេស ឱ្យសម្លាប់សិស្សនិស្សិត សាស្ត្រាចារ្យ កសិករ រាប់ពាន់នាក់ ពិសេសក៏បានសម្លាប់តំណាងរាស្ត្រអាណត្តិទី៦ នេះជាច្រើននាក់ផងដែរ ។

អ្នកភូមិនៅសំឡូត ខេត្តបាត់ដំបង និងនៅខេត្តរតនគិរី ជាច្រើនពាន់នាក់ក៏ត្រូវគេសម្លាប់ដូចគ្នានេះដែរ ព្រោះតែពួកគេដើរតាមនយោបាយគាំទ្រកុម្មុយនិស្តរបស់សីហនុ ដោយមិនដឹងខ្លួន ហើយនៅពេលដែលទឹកភ្នែករបស់ក្រុមគ្រួសារជនរងគ្រោះមិនទាន់បាត់ស្ងួតនៅឡើយ ហើយសក់របស់ស្រីមេម៉ាយ ដែលកោរដើម្បីកាន់ទុក្ខស្វាមីដែលត្រូវគេយកទៅសម្លាប់ចោលនោះ មិនទាន់ដុះវែងដូចដើមវិញផង សីហនុ ដែលត្រលប់ទៅគាំទ្រចិនកុម្មុយនិស្ត ជាថ្មីទៀតនោះ បានអំពាវនាវឱ្យប្រជារាស្ត្រចូលរួមជាមួយខ្លួនម្តងទៀត ដើម្បីដើរឆ្ពោះទៅរកផ្លូវមួយដែលធ្វើឱ្យប្រជារាស្ត្ររងនូវសេចក្តីវិនាសទៅវិញ ។

ដូច្នេះ រដ្ឋសភាយល់ឃើញថា មេដឹកនាំម្នាក់ ដែលគ្មានបន្ទាត់នយោបាយច្បាស់លាស់បន្តិចទាល់តែសោះបែបនេះ ពុំអាចដឹកនាំប្រទេសឱ្យរួចផុតពីគ្រោះថ្នាក់ និងឈានទៅរកវឌ្ឍនភាពបានឡើយ ។

ទី២-ដោយសារនយោបាយគាំទ្រពួកកុម្មុយនិស្ត សីហនុ បានសម្រេចឱ្យមានកិច្ចព្រមព្រៀងសម្ងាត់ជាច្រើន ជាមួយកងទ័ពវៀតកុង និងយួនខាងជើង ដោយអនុញ្ញាតឱ្យ

ពួកនេះរាប់ម៉ឺននាក់ ចូលមកបោះទីតាំងនៅក្នុងទឹកដីខ្មែរ។ លើសពីនេះទៅទៀត សីហនុ បានផ្តល់គ្រឿងអាវុធ និងស្បៀងអាហារដល់ពួកនេះទៀតផង ដែលធ្វើឱ្យបាត់បង់ឯករាជ្យភាព និងអព្យាក្រឹតភាពរបស់ប្រទេសទាំងស្រុង ។

ទី៣-ពីថ្ងៃទី០៨ ដល់ថ្ងៃទី១៦ ខែមីនា ឆ្នាំ១៩៧០ ប្រជារាស្ត្រខ្មែរនៅតាមបណ្តាខេត្ត និងរាជធានីភ្នំពេញ បានសម្តែងនូវការក្តៅក្រហាយ ខឹងសម្បាចំពោះកងទ័ពវៀតកុង-យួនខាងជើង ដែលបានចូលមកកាន់កាប់ទឹកដី និងសម្លាប់ប្រជារាស្ត្រយើង បាននាំគ្នាធ្វើបាតុកម្មទាមទារឱ្យរដ្ឋសភា និងរាជរដ្ឋាភិបាលវែកមុខពួកក្បត់អ្នកគប់គិតលក់ទឹកដីឱ្យពួកកុម្មុយនិស្តវៀតកុង-យួនខាងជើង ដើម្បីយកមកផ្តន្ទាទោសឱ្យធ្ងន់បំផុត។ ពួកក្បត់ទាំងអស់នោះ គឺគ្មាននរណាក្រៅពីសីហនុ និងក្រុមគ្រួសារទេ ដែលបានអនុញ្ញាតឱ្យសត្រូវចូលមកបោះទីតាំងនៅលើទឹកដីរបស់យើង និងបានលក់អង្ករឱ្យពួកនេះទៀតផងហើយ ពួកគេបានទទួលលាភសក្ការៈសម្បូរហូរហៀរពីពួកកុម្មុយនិស្តវៀតកុង-យួនខាងជើងផងដែរ ។

ក្នុងកាលៈទេសៈដ៏ចាំបាច់នេះប្រជារាស្ត្រទាំងមូលបានសម្តែងនូវកំហឹងឈឺចាប់ចំពោះសត្រូវរបស់ខ្លួន គឺពួកយួនកុម្មុយនិស្តយ៉ាងពុះកញ្ជ្រោល បែរជាសីហនុ ចោទប្រកាន់ប្រជារាស្ត្រខ្លួនឯងថា ជាពួកក្បត់ទៅវិញ។ មិនតែប៉ុណ្ណោះ សីហនុ បានធ្វើការសម្របសម្រួលជាមួយសត្រូវទៀតផង ។

ទី៤-សីហនុ រំលោភរដ្ឋធម្មនុញ្ញក្នុងសំណុំរឿងមុខជំនួញទឹកប្រៃមួយនៅក្រុងកំពង់សោម ដែលគិតជាទឹកប្រាក់មានចំនួន៦៧លានរៀល។ សីហនុ អនុញ្ញាតឱ្យភួង ម៉ាហ្គាំង ជាជនជាតិបារាំង មកពីប្រទេសឥណ្ឌា ចូលសញ្ជាតិខ្មែរ មានឋានៈត្រឹមតែប្រធានអគ្គនាយកក្រុមហ៊ុនសុរាគារខ្មែរ ចុះកិច្ចព្រមព្រៀងដោយផ្ទាល់ជាមួយក្រុមហ៊ុនបរទេស ដោយមិនប្រកាសដាក់ឱ្យដេញថ្លៃ ហើយ គាត ឈន់ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្ម និងប៉ែន នុត នាយករដ្ឋមន្ត្រី ជាអ្នកទទួលខុសត្រូវពីបញ្ហានេះ មិនដែលបានគិតគូរពីភាពមិនប្រក្រតី ដែលបានកើតឡើងរំលងលើតួនាទីគ្រប់គ្រងរបស់ខ្លួននេះឡើយ ។

នៅពេលដែលតំណាងរាស្ត្រ២នាក់ ស្នើសុំកោះហៅគាត ឈន់ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្ម មកសួរដេញដោលពីបញ្ហានេះនៅក្នុងរដ្ឋសភា តាមមាត្រាទី១០០ នៃរដ្ឋធម្មនុញ្ញ សីហនុ បានជំទាស់រារាំង មិនឱ្យគាត ឈន់ ចូលមកឆ្លើយបំភ្លឺនៅក្នុងរដ្ឋសភាទេ បែរជាបញ្ជូន ភួង ម៉ាហ្គាំង និងរឿម សុផុន ដែលមិនមែនជារដ្ឋមន្ត្រី ឱ្យចូលមកឆ្លើយបំភ្លឺនៅក្នុងរដ្ឋសភាទៅវិញ ។

ភួង ម៉ាហ្គាំង និងរឿម សុផុន ទាំង២នាក់នេះ មិនត្រឹមតែមិនឆ្លើយសំណួររបស់សមាជិកសភាប៉ុណ្ណោះទេ គឺពួកគេប្រើវេទិកាសភាជេរប្រមាថដល់សមាជិកសភាគ្មានញញើតអ្វីបន្តិចឡើយ ព្រោះពួកគេមានការគាំទ្រពីសីហនុ ។

ពេលនោះ សមាជិកសភា បានយករឿងជេរប្រមាថនេះទៅប្រាប់សីហនុ ដែរតែសីហនុ នៅតែកាន់ជើង ភួង ម៉ាហ្គាំង និងរឿម សុផុន ហើយសីហនុ សម្រេចចិត្តយកបញ្ហានេះទៅដាក់នៅក្នុងសមាជជាតិ ដើម្បីឱ្យសមាជជាតិជាអ្នកដោះស្រាយទៅវិញ។ ប៉ុន្តែសមាជិកសភាបានបដិសេធ មិនចូលខ្លួនទៅដោះស្រាយបញ្ហានេះនៅក្នុងសមាជជាតិតាមគំនិតរបស់សីហនុ ទេ ព្រោះការដោះស្រាយបែបនេះពុំមានចែងនៅក្នុង រដ្ឋធម្មនុញ្ញឡើយ ។

ទី៥-សីហនុ ហាមឃាត់តំណាងរាស្ត្រទាំងអស់មិនឱ្យចូលរួមក្នុងពិធីបុណ្យ ជាតិផ្សេងៗ ព្រោះតែ តំណាងរាស្ត្រទាំងអស់នោះមិនព្រមស្តាប់តាមបង្គាប់របស់ខ្លួន ។

សីហនុ បានបញ្ជាឱ្យនាយកខុទ្ទកាល័យរបស់ខ្លួន បញ្ជូនលិខិតលេខ១៦៣៩ SPU/II ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ ១៩៦៩ និងលិខិតមួយទៀត លេខ 704 SPU/I ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ១៩៦៩ ហាមឃាត់តំណាងរាស្ត្រទាំងអស់ជាសមាជិករដ្ឋសភាមិនឱ្យចូលរួមក្នុងពិធីបុណ្យ ឯករាជ្យជាតិ បុណ្យអុំទូក និងពិធីបុណ្យជាតិផ្សេងៗទៀតជាដាច់ខាត នៅពេលណាខ្លួននៅមានជីវិត ។

នេះជាការរំលោភបំពានទៅលើសិទ្ធិរបស់តំណាងរាស្ត្រ រំលោភរដ្ឋធម្មនុញ្ញ និងច្បាប់ផ្សេងៗរបស់ប្រទេស ហើយជាការបង្ហាញថា នេះជាអំពើផ្តាច់ការរបស់

សីហនុ។

ដោយផ្អែកលើកំហុសធំៗដូចខាងលើនេះ សភាជាតិ និងក្រុមប្រឹក្សាព្រះរាជាណាចក្រ បានបោះឆ្នោតជាឯកច្ឆន្ទ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ទម្លាក់នរោត្តម សីហនុ ពីតំណែងប្រមុខរដ្ឋរបស់ប្រទេសកម្ពុជា ចាប់ពីពេល នេះតទៅ...។

ពេលនោះដែរ ចេង ហេង ជាប្រមុខរដ្ឋស្តីទី ត្រូវបានតែងតាំងជាប្រមុខរដ្ឋពេញសិទ្ធិ ហើយសមាសភាពរដ្ឋាភិបាល ស្រោចស្រង់ជាតិ ក៏ធ្វើការរុះរើផ្លាស់ប្តូរសមាសភាពមួយចំនួនដែរ ដោយឧត្តមសេនីយ៍ឯកលន់ នល់ នៅតែជានាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការពារជាតិ ដដែល, ព្រះអង្គម្ចាស់ស៊ីសុវត្ថិ សិរិមតៈ ជាឧបនាយករដ្ឋមន្ត្រីទី១ ទទួលបន្ទុកមហាផ្ទៃ សម្របសម្រួលកិច្ចការសាសនា សណ្តាប់ធ្នាប់ សន្តិសុខ និងអប់រំជាតិ, យ៉ែម សំបូរ ជា ឧបនាយករដ្ឋមន្ត្រីទី២ ទទួលបន្ទុកយុត្តិធម៌ សម្របសម្រួលខាងសាធារណសុខាភិបាល កិច្ចការសង្គម ការងារការបង្កើនគុណភាពជីវភាព អភិវឌ្ឍន៍សហគមន៍ លំនៅឋានជនបទ ទំនាក់ទំនងជាមួយសភា និងជារដ្ឋមន្ត្រីក្រសួង ការបរទេស, ឧប គឹមអាង ឧបនាយករដ្ឋមន្ត្រីទី៣ទទួលបន្ទុកហិរញ្ញវត្ថុ ផែនការ និងសម្របសម្រួលខាងសេដ្ឋកិច្ច, ផ្លែក ភឺន ជារដ្ឋមន្ត្រីសាធារណការ និងទូរគមនាគមន៍, ទ្រិញ វ៉ាញ ( មនុស្សជំនិតរបស់ទ្រង់សិរិមតៈ) ជារដ្ឋមន្ត្រីព័ត៌មាន, លោកស្រី អ៊ឹង មឹង ( ប្រពន្ធ អ៊ឹង ម៉ឹង)ជារដ្ឋលេខាធិការទេសចរណ៍, ព្រំ ផុស ជារដ្ឋមន្ត្រីពាណិជ្ជកម្ម និងឧស្សាហកម្ម, ឌី ទូច ជារដ្ឋលេខាធិការមហាផ្ទៃ ទទួលបន្ទុកធម្មការ និងពុទ្ធិកសិក្សា, ឆន សុខុម ជារដ្ឋលេខាធិការ អប់រំជាតិ, អ៊ុន ត្រមុច ជារដ្ឋលេខាធិការអមទីស្តីការគណៈរដ្ឋមន្ត្រីទទួលបន្ទុកការងារពិសេស, ចៅ សេងអ៊ួ ជារដ្ឋលេខាធិការសង្គមកិច្ចការងារបង្កើនគុណភាពជីវភាព អភិវឌ្ឍសហគមន៍ និងលំនៅឋានជនបទ, ទួន ឡាង ជារដ្ឋលេខាធិការកសិកម្ម, ហ៊ូ ហុង រដ្ឋលេខាធិការសាធារណសុខាភិបាល, គង់ ធុច ជារដ្ឋលេខាធិការមហាផ្ទៃ ទទួលបន្ទុកសន្តិសុខជាតិ, ឈឹម ខែត ជាអនុរដ្ឋលេខាធិការ ហិរញ្ញវត្ថុ ទទួលបន្ទុកថវិកា, អ៊ុង ហៀម អនុរដ្ឋលេខាធិការព័ត៌មាន, អ៊ឹង ប៊ុនហេង ជាអនុរដ្ឋលេខាធិការអមទីស្តីការគណៈរដ្ឋមន្ត្រី និងសាវ៉ាត ហ៊ិម ជាអនុរដ្ឋលេខាធិការមហាផ្ទៃ។ ចំណែកសមាសភាព

ដែលត្រូវដកចេញពីសមាជិកគណៈរដ្ឋមន្ត្រីថ្មីនោះ ភាគច្រើនជាមនុស្សជំនិតរបស់សម្តេចសីហនុ រួមមាន៖ ១.អ៊ឹង ហុងសាធ ឧបនាយករដ្ឋមន្ត្រីទី២ , ២.ព្រះអង្គម្ចាស់នរោត្តម ភូរិស្សារ៉ា រដ្ឋមន្ត្រីការបរទេស, ៣. ជួន សោឌី រដ្ឋមន្ត្រីកសិកម្ម ជំនួសដោយទួន ឡាង, ៤.អ៊ុំម៉ាន្នូរិន រដ្ឋលេខាធិការមហាផ្ទៃ ទទួលបន្ទុកការពារលើផ្ទៃប្រទេស ត្រូវដកចេញ ហើយស្ថាប័នកងរាជតម្រួត ដែលគ្រប់គ្រងដោយក្រសួងការពារលើផ្ទៃប្រទេសនេះ ក៏ត្រូវរំលាយចោលដែរ, ៥.សុស្តែន ហ្វែរណង់ដេស រដ្ឋលេខាធិការមហាផ្ទៃ ទទួលបន្ទុកក្រសួងសន្តិសុខជាតិ, ៦,ស្រី ប៉ុង រដ្ឋលេខាធិការឧស្សាហកម្ម, ៧.ទេព ឈីវខេង រដ្ឋលេខាធិការឃោសនាការ និង៨.ឡុង បុត្តា រដ្ឋលេខាធិការក្រសួងអប់រំ ។

នៅរសៀលថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ វិទ្យុជាតិបានប្រកាសព័ត៌មានស្តីពីរដ្ឋសភាសម្រេចទម្លាក់សម្តេចសីហនុ ចេញពីតំណែងប្រមុខរដ្ឋរបស់ប្រទេសកម្ពុជា ធ្វើឱ្យសិស្សនិស្សិត និងប្រជារាស្ត្រគ្រប់មជ្ឈដ្ឋាននៅទូទាំងប្រទេស ភ្ញាក់ផ្អើលស្រឡាំងកាំង និងប្រាប់ដំណឹងនេះពីមាត់មួយទៅមាត់មួយ ដោយក្តីជឿងឆ្ងល់បំផុត ។ ពិសេសអ្នកដែល បានចូលរួមធ្វើបាតុកម្មនៅថ្ងៃទី១៦ ខែមីនា នៅមុខរដ្ឋសភា ទាមទារឱ្យតំណាងរាស្ត្រវែកមុខអ្នកលក់ទឹកដីឱ្យពួកវៀតកុង-វៀតណាមខាងជើង ហើយស្រែកថា “ជយោ! សម្តេចឪៗ” នោះនាំគ្នាហួសចិត្តគ្រប់ៗគ្នា ព្រោះមិននឹកស្មានថា សម្តេចឪជាទីគោរពស្រឡាញ់របស់ពួកគេ ជាអ្នកលក់ទឹកដីឱ្យពួកវៀតកុង-វៀតណាមខាងជើងទៅវិញ ។

ប្រជារាស្ត្រខ្មែរនៅទូទាំងប្រទេស មានការភ្ញាក់ផ្អើលជ្រួលច្របល់ ហើយភាគច្រើនមានកំហឹងឈឺចាប់ ចំពោះលន់ នល់ និងព្រះអង្គម្ចាស់សិរិមតៈ ដែលជាមេដឹកនាំធ្វើរដ្ឋប្រហារទម្លាក់សម្តេចឪរបស់ពួកគេ ដោយអយុត្តិធម៌បំផុតយ៉ាងដូច្នេះ ។



សម្តេចសីហនុ កំពុងនៅក្រៅប្រទេស នៅថ្ងៃមានរដ្ឋប្រហារទម្លាក់ព្រះអង្គ

ចំណែកសម្តេចសីហនុ ដែលកំពុងបំពេញទស្សនកិច្ចរយៈពេល៥ថ្ងៃ នៅទីក្រុងមូស្គូ នោះព្រះអង្គមិនបានដឹងថា មានការធ្វើរដ្ឋប្រហារទម្លាក់ព្រះអង្គចេញពីអំណាចទេ ។

ក្រោយពេលធ្វើរដ្ឋប្រហារនៅថ្ងៃទី១៨ ខែមីនានោះ រយៈពេលប្រមាណតែ៤ម៉ោង ប៉ុណ្ណោះ សម្តេចសីហនុ ដែលនៅតែគិតថា ព្រះអង្គជាប្រមុខរដ្ឋនៃប្រទេសកម្ពុជា និងអ្នកម្នាងម៉ូនិក ជាមហេសី ព្រមទាំងមន្ត្រីហែហមមួយចំនួនទៀត កំពុងរៀបចំឡើងយន្តហោះពិសេសរបស់ក្រុមហ៊ុនអាអេរ៉ូហ្វ្លូត (Aeroflot) ម៉ាកអាយអិល-១៨ (IL-18) ទៅកាន់រដ្ឋធានីប៉េកាំង ប្រទេសចិន ដោយមាននាយករដ្ឋមន្ត្រីសហភាពសូវៀត អាឡិចហ្សេ កូស៊ីហ្គីន (Alekxei Kosygin) មកជូនដំណើរផងដែរ ។

មុនពេលឡើងជណ្តើរយន្តហោះ សម្តេចសីហនុ បានសំពះ និងចាប់ដៃលាមន្ត្រីសហភាពសូវៀត និងអ្នកការទូតបរទេសជាច្រើនទៀត ព្រមទាំងមានបន្ទូលសំណេះសំណាលជាមួយជនជាតិខ្មែរមួយក្រុម មានគ្នាប្រមាណ៣០នាក់ ក្នុងនោះភាគច្រើនជានិស្សិត ។

ចុងក្រោយ ពេលព្រះអង្គចាប់ដៃលាមេដឹកនាំកំពូលៗរបស់សហភាពសូវៀ ស្រាប់តែនាយករដ្ឋមន្ត្រីអាឡិចហ្សេ កូស៊ីហ្គីន (Alekxei Kosygin) បានទូលសម្តេច

*សីហនុ ថា តើព្រះអង្គបានដឹងពីរឿងគេធ្វើរដ្ឋប្រហារទម្លាក់ព្រះអង្គនៅរាជធានីភ្នំពេញ ប្រហែល២ម៉ោងមុននេះឬទេ? សម្តេចសីហនុ មានបន្ទូលថា ព្រះអង្គមិនបានដឹងរឿងធ្វើរដ្ឋប្រហារនៅរាជធានីភ្នំពេញ នោះទេ។នាយករដ្ឋមន្ត្រីសហភាពសូវៀត សួរថា តើព្រះអង្គគិតយ៉ាងណាចំពោះការធ្វើរដ្ឋប្រហារនេះ? សម្តេចសីហនុ តបវិញថា ត្រូវតែប្រឆាំងតបតវិញ...។*

*ក្រោយពីសម្តេចសីហនុ អមដំណើរដោយអ្នកម្នាងម៉ូនិក ជាមហេសី និងប៉ែន នុត ព្រមទាំងអ្នកហែហមមួយចំនួនទៀត ទៅដល់ទីក្រុងប៉េកាំង ព្រះអង្គបានថ្លែងប្រាប់អ្នកកាសែតថា ការទម្លាក់ព្រះអង្គចេញពីតំណែងនេះ គឺខុសពីច្បាប់រដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជាទាំងស្រុង ហើយព្រះអង្គបានបញ្ជាក់ថា មានតែការធ្វើប្រជាមតិទេ ទើបគេអាចទម្លាក់ព្រះអង្គចេញពីអំណាចដោយស្របច្បាប់បាន។ ព្រះអង្គចាត់ទុកថានេះជារដ្ឋប្រហារពេញទី ហើយព្រះអង្គក៏បានបញ្ជាក់ដែរថា ក្រុមសេអ៊ីអា របស់អាមេរិក គឺជាមេគំនិតផ្ទាល់នៅក្នុងការធ្វើរដ្ឋប្រហារនោះ ។*

# ២៧៤
# សហរដ្ឋអាមេរិក មានជាប់ពាក់ព័ន្ធនឹងរដ្ឋប្រហារថ្ងៃ១៨មីនា?



ប្រធានាធិបតី និចសុន និងហង់រី គីស្ស៊ីងហ្ស៊ែរ

ថ្ងៃទី១៩ ខែមីនា គឺក្រោយទម្លាក់សម្តេចសីហនុ ចេញពីតំណែងមួយថ្ងៃ លន់ នល់ បានប្រកាសដាក់ប្រទេសជាតិឱ្យស្ថិតក្នុងភាពមានអាសន្ន។ ថ្ងៃទី១៩ ខែមីនា នោះដែរ រដ្ឋាភិបាលសហរដ្ឋអាមេរិក ក៏បានប្រកាសទទួលស្គាល់ថា ការទម្លាក់សម្តេចសីហនុ គឺស្របតាមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា មិនមែនជារដ្ឋប្រហារនោះទេ។ ចំណែកនាយករដ្ឋមន្ត្រីវៀតណាម ផាំ វ៉ាន់ដុង បានប្រកាសគាំទ្រ និងទទួលស្គាល់ថា សម្តេចសីហនុ នៅតែជាមេដឹកនាំប្រទេសកម្ពុជា ដដែល ។

សម្តេចសីហនុ បានធ្វើការវាយតម្លៃពីរដ្ឋប្រហារនោះថា ការពិត លន់ នល់ មានបំណងចង់ទម្លាក់ព្រះអង្គចេញពីអំណាចតាំងពីឆ្នាំ១៩៦៩ មកម៉្លេះ។ ព្រះអង្គបានរំឭកថា នៅក្នុងខែកញ្ញា ឆ្នាំ១៩៦៩ នៅពេលព្រះអង្គដឹកនាំគណៈប្រតិភូមួយ

ក្រុមធ្វើដំណើរទៅចូលរួមបុណ្យសព ហូ ជីមិញ នៅសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម ។ ពេលនោះ យន្តហោះមិនទាន់ឡើងផុតពីអាកាសយានដ្ឋានពោធិ៍ចិនតុង ផង ព្រះអង្គម្ចាស់ស៊ីសុវត្ថិ សិរិមតៈ ដែលបានជូនព្រះរាជដំណើរព្រះអង្គនៅអាកាសយានដ្ឋាននោះ បានងាកទៅរកមន្ត្រីជំនិតម្នាក់របស់ទ្រង់ ប្រាប់ថា នេះជាឱកាសល្អ ដើម្បីទម្លាក់ព្រះអង្គចេញពីអំណាចហើយ ព្រោះពេលនោះ ទ្រង់សិរិមតៈបានរិះគន់ថា នៅពេលកងទ័ពវៀតកុង-វៀតណាមខាងជើង កំពុងរំលោភបំពានកាន់កាប់ដោយខុសច្បាប់ទឹកដីមួយផ្នែករបស់កម្ពុជា បែរជាព្រះអង្គយាងទៅចូលរួមពិធីបុណ្យសពហូ ជីមិញ នៅក្រុងហាណូយ បែបនេះ ជាទង្វើមួយមិនអាចទទួលយកបានឡើយ ។

ប៉ុន្តែ ឧត្តមសេនីយ៍ឯកលន់ នល់ ជានាយករដ្ឋមន្ត្រី ដែលកំពុងមានទុក្ខសោកដោយសារភរិយារបស់គាត់ទទួលមរណភាពដោយជំងឺ និងមិនទាន់ឱ្យគ្រូហោរាសាស្ត្រដែលគាត់មានជំនឿបំផុតនោះ គន់គូរជើងលេខមើលថា តើអាចទម្លាក់សម្តេចសីហនុបានឬមិនបាននោះ ប្រាប់ទៅទ្រង់សិរិមតៈ វិញថា ត្រូវរង់ចាំពេលវេលាណាមួយ ដែលអនុគ្រោះជាងនេះសិន ។

សម្តេចសីហនុ ក៏បានមានបន្ទូលឱ្យដឹងបន្តថា ពេលលន់ នល់ ទៅព្យាបាលរបួសត្រង់ស្មាដោយសារគ្រោះថ្នាក់ចរាចរណ៍ នៅប្រទេសបារាំងនោះ គាត់បានចូលសម្រាកពេទ្យឯកជនរបស់អាមេរិកមួយ ក្នុងក្រុងណឺយី សៀសែន ( Neuilly sur seine ) ក៏មានពួកជំនាញខាងរៀបចំធ្វើរដ្ឋប្រហាររបស់អាមេរិក បានក្លែងខ្លួនធ្វើជាអ្នកជំងឺចូលទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យនោះដែរ ដើម្បីមានឱកាសជួបពិភាក្សាគ្នាជាសម្ងាត់ពីគម្រោងធ្វើរដ្ឋប្រហារក្បត់នោះ ។

ក្រោយពីពិភាក្សាផ្លាស់ប្តូរយោបល់គ្នាជាមួយពួកជំនាញការធ្វើរដ្ឋប្រហាររបស់អាមេរិកមក លន់ នល់ ក៏បានវាយសារទូរលេខមកប្រាប់ព្រះអង្គម្ចាស់សិរិមតៈនៅឯភ្នំពេញ ឱ្យបានដឹងប្រាប់ពីគម្រោងការធ្វើរដ្ឋប្រហារនោះផងដែរ ។

តែមុននឹងចាប់ផ្តើមអនុវត្តគម្រោងការធ្វើរដ្ឋប្រហារ លន់ នល់ ចង់ឱ្យមានការសន្យាពីមេដឹកនាំអាមេរិក ជាមុនសិន ។

សម្តេចសីហនុ មានបន្ទូលបន្តទៀតថា នៅក្នុងឆ្នាំ១៩៦៩ ពួកគេបានរៀបចំឧបាយកលមួយ ដោយឱ្យទាហានខ្មែរសេរីរបស់សឺង ង៉ុកថាញ់ ធ្វើជាមកចុះចូលជាមួយព្រះអង្គក្នុងសង្គមជាតិវិញ តែតាមការពិត ពួកទាហានខ្មែរសេរីទាំងអស់នោះ គឺជាទាហានស៊ីឈ្នួលរបស់ពួកសេស៊ីអា ដែលទទួលបានប្រាក់ខែដ៏ច្រើនសន្ធឹកសន្ធាប់នោះ ចូលមកជាធ្វើជាកម្លាំងបង្កប់ ដើម្បីផ្តួលរម្លំព្រះអង្គតែប៉ុណ្ណោះ ។

សម្តេចសីហនុ មានបន្ទូលបញ្ជាក់ថា នៅក្នុងពិធីបើកសមាជជាតិខែធ្នូ ឆ្នាំ១៩៦៩ (សមាជលើកទី២៨) លន់ នល់ ដែលកំពុងស្ថិតនៅឯប្រទេសបារាំង បានទាក់ទងមកព្រះអង្គម្ចាស់សិរិមត: ឱ្យរៀបចំផែនការឱ្យពួកទាហានខ្មែរសេរី ដែលប្រើល្បិចកលឱ្យមកចុះចូលក្នុងសង្គមជាតិ កាលពីប៉ុន្មានខែមុននោះ ឱ្យទៅចូលរួមក្នុងសមាជជាតិនោះទាំងអស់គ្នាដោយឱ្យស្លៀកពាក់ជាស៊ីវិលដូចអ្នកចូលរួមផ្សេងៗទៀតដែរ ដើម្បីបន្ទប់បង្អាក់ផែនការសេដ្ឋកិច្ចរបស់ចលនាសង្គមរាស្ត្រនិយម ដោយទាមទារឱ្យក្រុមហ៊ុនអាហារ័ណនីហរ័ណរបស់រដ្ឋ ឈប់នាំចូលផ្តាច់មុខលើមុខទំនិញមួយចំនួនដូចជាៈ សុរា និងថ្នាំពេទ្យជាដើម ហើយអនុញ្ញាតឱ្យក្រុមហ៊ុនឯកជនផ្សេងទៀតមានសិទ្ធិនាំចូលដែរ និងអនុញ្ញាតឱ្យបង្កើតធនាគារឯកជនរបស់បរទេសឡើងវិញ ផងដែរ ។

ប៉ុន្តែ សមាជិកអង្គសមាជជាច្រើនទៀត ដែលពួកខ្មែរក្រហមជាអ្នកកៀងគរឱ្យមកចូលរួមក្នុងសមាជនោះ ព្រមទាំងតំណាងប្រជារាស្ត្រមកពីគ្រប់ខេត្តផ្សេងៗទៀតដ៏ច្រើនសន្ធឹកសន្ធាប់បានលើកដៃគាំទ្រគោលនយោបាយសេដ្ឋកិច្ចនៃការធ្វើជាតូបនីយកម្មឱ្យក្រុមហ៊ុនអាហារ័ណនីហរ័ណរបស់រដ្ឋ នាំចូលផ្តាច់មុខលើទំនិញមួយចំនួនដូចជាៈ សុរា និងថ្នាំពេទ្យ... ដូចមុនដដែល ពួកខ្មែរសេរីបង្កប់ខ្លួនទាំងអស់ បែរជានាំគ្នាលើកដៃគាំទ្រតាមមតិភាគច្រើននោះទៅវិញ ។

២សប្តាហ៍ ក្រោយថ្ងៃរដ្ឋប្រហារថ្ងៃទី១៨មីនានោះ វីល្លៀម រ៉ូជឺរ្ស៍ (William Rogers)

មន្ត្រីជាន់ខ្ពស់របស់សេតវិមាន សហរដ្ឋអាមេរិក បានប្រកាសជាសាធារណៈថា ទោះបីដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី រដ្ឋាភិបាលអាមេរិក មិនជាប់ពាក់ព័ន្ធពីរឿងធ្វើបាតុកម្មវាយកម្ទេចស្ថានទូតវៀតកុង-វៀតណាមខាងជើង នៅទីក្រុងភ្នំពេញ និងការធ្វើរដ្ឋប្រហារទម្លាក់សម្តេចសីហនុ នោះទេ ។

ជាមួយគ្នានោះដែរ ហង់រី គីស៊ីងហ្គ័រ ( Henry Kissinger ) ទីប្រឹក្សាផ្នែកសន្តិសុខជាតិរបស់ប្រធានាធិបតី និចសុន ( Nixon ) បានថ្លែងថា រដ្ឋប្រហារថ្ងៃទី១៨ ខែមីនានោះ ធ្វើឱ្យគាត់មានការភ្ញាក់ផ្អើលខ្លាំងណាស់ ។

ប្រភពមួយទៀតបានអះអាងថា តាមពិតទៅ ពុំមានព័ស្តុតាងណាមួយ ដែលបញ្ជាក់ថា ពួកសេអ៊ីអា មានជាប់ពាក់ព័ន្ធក្នុងការធ្វើរដ្ឋប្រហារថ្ងៃទី១៨ខែមីនា នោះទេ ប៉ុន្តែប្រភពមួយបានបង្ហាញថា អង្គភាពស៊ើបការណ៍សម្ងាត់របស់កងទ័ព អាមេរិក ប្រចាំការនៅទីក្រុងព្រៃនគរ មានជាប់ពាក់ព័ន្ធក្នុងការធ្វើរដ្ឋប្រហារនេះ...។

សាមុយអែល អ័រ ថរតុន ( Samuel R Thorton ) ដែលបម្រើការងារជាអ្នកឯកទេសខាងស៊ើបការណ៍សម្ងាត់នៅទីបញ្ជាការកងនាវាចរណ៍សហរដ្ឋអាមេរិក នៅទីក្រុងព្រៃនគរ ប្រទេសវៀតណាមខាងត្បូង ពីខែឧសភា ឆ្នាំ១៩៦៨ ដល់ខែឧសភា ឆ្នាំ១៩៦៩ នោះ បានប្រាប់អ្នកកាសែតសីមួរ ហឺស្ហ ( Seymour Hersh ) ថា គាត់បានទទួលព័ត៌មានពីគម្រោងរៀបចំធ្វើរដ្ឋប្រហារទម្លាក់សម្តេចសីហនុ តាំងពីដើមឆ្នាំ១៩៦៩មកម្ល៉េះ ។

សាមុយអែល អ័រ ថរតុន ( Samuel R Thorton ) បានបង្ហើបឱ្យដឹងថា លន់ នល់ បានទាក់ទងសហការជាមួយ ភ្នាក់ងារស៊ើបការណ៍សម្ងាត់របស់កងទ័ពអាមេរិក នៅទីក្រុងព្រៃនគរ ដើម្បីធ្វើរដ្ឋប្រហារនោះ និងស្នើសុំឱ្យសហរដ្ឋអាមេរិក ជួយឧបត្ថម្ភគាំទ្រគាត់ទាំងខាងយោធា នយោបាយ និងសេដ្ឋកិច្ច ក្រោយពេលគាត់ធ្វើទម្លាក់សម្តេចសីហនុរួចៗ តែអាមេរិក បានត្រៀមលក្ខណៈជួយឧបត្ថម្ភគាំទ្រច្រើនជាងការស្នើសុំរបស់គាត់ទៅទៀត ។

ក្រុមអ្នកឯកទេសខាងស៊ើបការណ៍នោះ បានរៀបចំផែនការឱ្យក្រុមអត្ត

ឃាតរបស់ទាហានពិសេស ខ្មែរកម្ពុជាក្រោម ( special forces ) ដែលអាមេរិកជាអ្នកបង្ហាត់បង្រៀន មកបន្លំខ្លួនធ្វើជាពួកវៀតកុង-វៀតណាមខាងជើង ទៅបង្កប់ខ្លួននៅទីក្រុងភ្នំពេញ ដើម្បីសម្លាប់សម្តេចសីហនុ ហើយយកលេសនេះទម្លាក់កំហុសទៅលើពួកកុម្មុយនិស្តវៀតកុង-វៀតណាមខាងជើង ។

ផែនការធ្វើឃាតសម្តេចសីហនុ នេះ ត្រូវបានគេឱ្យឈ្មោះថា ព្រះអាទិត្យរះលើសួនឧទ្យាន( Sunshine Park ) ហើយមន្ត្រីជាន់ខ្ពស់បំផុតរបស់រដ្ឋាភិបាលក្រុងវ៉ាស៊ីនតោន ក៏បានយល់ព្រមឱ្យក្រុមអ្នកឯកទេសខាងស៊ើបការណ៍នៅទីក្រុងព្រៃនគរ អនុវត្តផែនការធ្វើឃាតសម្តេចសីហនុ នៅក្នុងខែកុម្ភៈ ឬខែមីនា ឆ្នាំ១៩៦៩ ដែរ។ ប៉ុន្តែ លន់ នល់ បានបដិសេធមិនឱ្យអនុវត្តផែនការសម្លាប់សម្តេចសីហនុ នោះជាដាច់ខាត ដោយគាត់បានហៅផែនការនេះថា ជាឧក្រិដ្ឋកម្មដ៏អាក្រក់បំផុត ហើយគាត់បានស្នើសុំទៅអាមេរិក គ្រាន់តែជួយគាំទ្រខាងយោធាបានហើយ នៅពេលណាមានរដ្ឋប្រហារទម្លាក់សម្តេចសីហនុ។ អាមេរិកក៏យល់ព្រមតាមការស្នើសុំរបស់លន់ នល់ នោះដែរ។

សាមុយអែល អ័រ ថរតុន បានអះអាងថា បន្ទាប់មក ក៏មានកិច្ចព្រមព្រៀងមួយជាមួយលន់ នល់ ស្តីពីការបញ្ជូនកងទ័ពខ្មែរកម្ពុជាក្រោម( ខ្មែរសេរី)របស់សឺង ង៉ុកថាញ់ ចំនួន៦៤០នាក់ ឱ្យទៅចុះចូលជាមួយរដ្ឋាភិបាលកម្ពុជា រូបគាត់ផ្ទាល់ ក៏បានជួយរៀបចំឯកសារ ដែលទាក់ទងដល់ការធ្វើរដ្ឋប្រហារនោះទៀតផង ។

គួររម្លឹកថា កាលក្នុងឆ្នាំ១៩៦៩ កងទ័ពខ្មែរសេរីរបស់សឺង ង៉ុកថាញ់ ចំនួន៦៤០នាក់ បាននាំគ្នាចុះចូលជាមួយរដ្ឋាភិបាលភ្នំពេញ ហើយមេបញ្ជាការជាអ្នកដឹកនាំកម្លាំងទៅចុះចូលនោះ ត្រូវបានទទួលឋានន្តរសក្តិ ជាអនុសេនីយ៍ឯក និងមេបញ្ជាការរងទទួលបានឋានន្តរសក្តិជាអនុសេនីយ៍ទោ និងអនុសេនីយ៍ត្រី ។

ប្រភពមួយទៀត បានឱ្យដឹងថា ក្រោយពីលន់ នល់ បានឡើងជានាយករដ្ឋមន្ត្រីរាជរដ្ឋាភិបាលស្រោចស្រង់ជាតិ ក្នុងខែសីហា ឆ្នាំ១៩៦៩ បានរយៈពេលតែមួយខែ សឺង ង៉ុកថាញ់ មេខ្មែរសេរី បានទាក់ទងគ្នាជាសម្ងាត់ពីរឿងធ្វើរដ្ឋប្រហារទម្លាក់សម្តេច

សីហនុ ។

លុះមកដល់ខែកុម្ភៈ ឆ្នាំ១៩៧០ សឺង ង៉ុកថាញ់ បានធានាថា នៅពេលណាមានរដ្ឋប្រហារកើតឡើង គាត់នឹងបញ្ជូនកងទ័ពខ្មែរកម្ពុជាក្រោម ដែលអាមេរិក ជួយបង្កើតឱ្យគាត់នៅក្នុងប្រទេសវៀតណាមខាងត្បូងនោះ ឱ្យមកជួយលន់ នល់ ។

អនុសេនីយ៍ឯក ហ្វ័រវ៉េស្ត ប៊ី លីនលី ( Forest B Lindly ) ជានាយទាហានមួកបៃតង ( ទាហានអង្គការសហប្រជាជាតិ ) ប្រចាំការនៅក្នុងទឹកដីវៀតណាមខាងត្បូង ក្បែរព្រំប្រទល់ប្រទេសកម្ពុជា បានអះអាងថា នៅដើម ឆ្នាំ១៩៦៩ មេបញ្ជាការជាន់ខ្ពស់អាមេរិកម្នាក់ បានប្រាប់គាត់ថា នៅពេលខាងមុខនេះ នឹងមានការផ្លាស់ប្តូររដ្ឋាភិបាលនៅកម្ពុជា ។

អនុសេនីយ៍ឯក ហ្វ័រវ៉េស្ត ប៊ី លីនលី ( Forest B Lindly ) បានឱ្យដឹងថា នៅពេលមានបាតុកម្មវាយកម្ទេចស្ថានទូត វៀតកុង-វៀតណាមខាងជើង នៅទីក្រុងភ្នំពេញ ថ្ងៃទី ១១ ខែមីនា ឆ្នាំ១៩៧០ ទាហានខ្មែរសេរីជាច្រើនដែលបានមកចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជានោះ នាំគ្នាស្លៀកពាក់ស៊ីវិល ទៅចូលរួមវាយស្ថានទូតនោះដែរ ។

# ២៧៥
# លន់ ណុន ជាមនុស្សសំខាន់ម្នាក់ ក្នុងការធ្វើរដ្ឋប្រហារទម្លាក់សម្តេចសីហនុ



លន់ ណុន ពេលឡើងឋានន្តរស័ក្តិជា វរសេនីយ៍ត្រី

បើតាមសាស្ត្រាចារ្យ រស់ ចន្ទ្រាបុត្រ បានឱ្យដឹងថា លន់ ណុន ប្អូនប្រុសរបស់នាយករដ្ឋមន្ត្រីលន់ នល់ ក៏ជាតួអង្គសំខាន់ម្នាក់ក្នុងការដឹកនាំធ្វើរដ្ឋប្រហារនេះដែរ។

លន់ ណុន ជាសិស្សនាយទាហានជំនាន់ទី១៣។ ក្រោយបញ្ចប់ការសិក្សានៅសាលានាយទាហានភ្នំម គាត់បានទទួលឋានន្តរស័ក្តិជាអនុសេនីយ៍ត្រី( ស័ក្តិ១) ខណៈដែលមិត្តរួមជំនាន់គាត់ទាំងអស់ទទួលបានឋានន្តរស័ក្តិ ត្រឹមតែនាយចំណង់ប៉ុណ្ណោះ។

ក្រោយមក គាត់ឡើងស័ក្តិ២ និងជាមេបញ្ជាការកងរាជអាវុធហត្ថ រហូតដល់រដ្ឋប្រហារឆ្នាំ១៩៧០។ ដោយសារអំណាចបុណ្យសក្តិរបស់បងប្រុសគាត់ជាឧត្តមសេនីយ៍ឯក និងជានាយករដ្ឋមន្ត្រីកាលពីឆ្នាំ១៩៦៧ មកនោះ ទោះបីគាត់មានបុណ្យសក្តិមិនធំដុំអ្វីប៉ុន្មាន ក៏ពិតមែន តែគាត់បានក្លាយទៅជាមនុស្សដ៏មានឥទ្ធិពលម្នាក់ ។

តាំងពីឆ្នាំ១៩៦៨មក គាត់បានប្រមែប្រមូលនិស្សិតបញ្ញវន្ត ដែលមានគំនិតប្រឆាំងនឹងរបបរាជានិយម មកធ្វើជាកម្លាំងរបស់គាត់។ គាត់បានបើកអង្គប្រជុំសម្ងាត់តូចៗ ដែលមានគ្នា៨-១០នាក់ប៉ុណ្ណោះ នៅក្នុងផ្ទះសម្រាប់លំហែកាយចុងសប្តាហ៍របស់គាត់នៅភូមិបារគូ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ដែលមានចម្ងាយប្រមាណ២០គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ ។

រាល់ពេលប្រជុំសម្ងាត់នោះម្តងៗ គាត់ និងអ្នកចូលរួមបានលើកយកបញ្ហាប្រទេសជាតិមកធ្វើការពិភាក្សាគ្នា និងបានលើកឡើងពីគំនិតស្នេហាជាតិស្នេហាទឹកដី, ពីបញ្ហាវៀតកុង-វៀតណាមខាងជើង, ពីការប្រើអំណាចផ្តាច់ការ និងពីអំពើពុករលួយរបស់សម្តេចសីហនុ ដោយគាត់យល់ថា មានអ្នកម្នាងម៉ូនិក ជាអ្នកទាញខ្សែញាក់ផងដែរ ។

លន់ ណុន មានមិត្តភក្តិជិតស្និទ្ធមួយចំនួន ដូចជា៖ វរសេនីយ៍ត្រី ឈឹម ឈួន, លឿង វ៉ែន និងថោង លឹមហួង ជាដើម។ ជាមួយគ្នានោះ គាត់បានឱ្យសហការីជិតស្និទ្ធគាត់ម្នាក់ ឈ្មោះហូត ហៀម ទៅទាក់ទងនិស្សិតបញ្ញវន្តមួយចំនួន ដើម្បីឱ្យចូលរួមក្នុងក្រុមរបស់គាត់ដែរ ក្នុងនោះ រួមមាន ម៉ាន់ តេងសុង, វ៉ាន់ ឌីកាអុន និងរស់ ចន្ទ្រាបុត្រ ជាដើម។ បញ្ញវន្តទាំងនេះ ក៏ធ្លាប់បានទៅចូលរួមប្រជុំនៅផ្ទះលំហែកាយរបស់លន់ ណុន នៅភូមិបារគូ នោះដែរ ។

ប្រភពព័ត៌មានមួយ ក៏បានបង្ហើបឱ្យដឹងថា មុនរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា លន់ ណុន បានចាត់តាំងមន្ត្រីកងរាជអាវុធហត្ថ ដែលនៅក្រោមបញ្ជាគាត់២ នាក់ជាអ្នករត់ការចុះឡើងពីក្រុងភ្នំពេញ ទៅខេត្តស្វាយរៀង ដើម្បីលួចទាក់ទងគ្នាជាសម្ងាត់ជាមួយ

ចលនាតស៊ូខ្មែរសេរី របស់សឺង ង៉ុកថាញ់ ដែលស្ថិតនៅក្នុងទឹកដីវៀតណាមខាងត្បូង ។

ជាមួយគ្នានេះ គាត់ជាអ្នកឧបត្ថម្ភដល់កាសែតប្រយោជន៍ខ្មែរ ដែលមាន លឿង វ៉ែន ជាចាងហ្វាង និងកាសែតសុវណ្ណភូមិ ដែលមានឃួន ថៃ ជានិពន្ធនាយក ផងដែរ ។ ក្រោយពេលលន់ នល់ បានឡើងជានាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលស្រោចស្រង់ជាតិ ពីខែសីហា ឆ្នាំ១៩៦៩ មក កាសែតប្រយោជន៍ខ្មែរ របស់លឿង វ៉ែន ក៏បានចាប់ផ្តើមសរសេររិះគន់របបសង្គមរាស្ត្រនិយមរបស់សម្តេចសីហនុ ហើយកាសែតនគរធំ ដែលមានសុទ្ធ ប៉ូលីន ជាចាងហ្វាង និងត្រូវជាមិត្តភក្តិរបស់លន់ ណុន ដែរនោះ ក៏បានចាប់ផ្តើមសរសេរជៀមជាមខ្វះៗទៅលើសម្តេចសីហនុ ដូចកាសែតប្រយោជន៍ខ្មែរ ដែរ ។

ការសរសេររិះគន់វាយប្រហាររបស់កាសែតប្រយោជន៍ខ្មែរនោះ ធ្វើឱ្យសម្តេចសីហនុ ពិរោធយ៉ាងខ្លាំង ហើយនៅក្នុងឱកាសសមាជជាតិ នៅចុងខែធ្នូ ឆ្នាំ១៩៦៩ ព្រះអង្គឱ្យលឿង វ៉ែន ចូលមកឆ្លើយបំភ្លឺនៅចំពោះមុខអង្គសមាជទាំងមូល និងបង្ហាញព័ស្តុតាងជាក់ស្តែងនូវរាល់អ្វីៗ ដែលគាត់បានសរសេររិះគន់ព្រះអង្គនៅក្នុងអត្ថបទកាសែតនោះ ។

ក្រោយពីសមាជជាតិត្រូវបញ្ចប់ លឿង វ៉ែន ក៏ត្រូវគេចាប់យកទៅសួរចម្លើយ និងដាក់ពន្ធនាគារ ហើយកាសែតប្រយោជន៍ខ្មែរ ក៏ត្រូវបិទលែងឱ្យចេញផ្សាយបន្តទៀតដែរ ។ ពេលនោះ លន់ ណុន ក៏បានទាក់ទងឱ្យកាសែតផ្សេងៗទៀតសរសេរអត្ថបទប្រឆាំងតវ៉ាចំពោះការចាប់ខ្លួនលឿង វ៉ែន យកទៅដាក់ពន្ធនាគារ ក៏ដូចជាតវ៉ាចំពោះសេរីភាពសារព័ត៌មាន ផងដែរ ។

បន្ទាប់មកទៀត ហួត ហៀម បានប្រាប់ រស់ ចន្ទ្រាបុត្រ និងបញ្ញវន្តផ្សេងៗទៀត ដែលគាត់បានភ្ជាប់ទំនាក់ទំនងជាមួយគ្នាថា អ៊ុំ ម៉ាន្នូរិន រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលបន្ទុកការពារលើផ្ទៃប្រទេស និងសុស្តែន ហ្វែរណង់ដេស រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលបន្ទុកសន្តិសុខជាតិ បានបញ្ជាឱ្យកម្លាំងប៉ូលិសតាមចាប់ខ្លួនពួកបញ្ញវន្តសាស្ត្រាចារ្យ គ្រូបង្រៀន មន្ត្រីរាជការ និងទាហាន សរុបប្រមាណ៥០០នាក់ ។

រស់ ចន្ទ្រាបុត្រ ក៏មិនដឹងច្បាស់ថា ហួត ហៀម និយាយនេះពិត ឬយ៉ាងណាដែរ ។

ក្រោយពីប្រាប់ដំណឹងនេះមក ហួត ហៀម បានប្រគល់កាំភ្លើងខ្លីឱ្យរស់ ចន្ទ្រាបុត្រ និង មិត្តភក្តិផ្សេងទៀតម្នាក់មួយដើម ដើម្បីទុកការពារខ្លួនទៀតផង ។

ពេលនោះ ថោង លីមហួង បានគេចពីការតាមរករបស់សមត្ថកិច្ចប៉ូលិស ទៅសំងំលាក់ខ្លួននៅខាងជើងបឹងបាយ៉ាប ជាយក្រុងភ្នំពេញ។ ឯលន់ ណុន ប្រើល្បិចដោះដៃ ទៅសំងំលាក់ខ្លួននៅខេត្តកំពង់ស្ពឺ ។

សាស្ត្រាចារ្យ រស់ ចន្ទ្រាបុត្រ បានបញ្ជាក់ថា ពេលនោះគាត់មិនដឹងគោលបំណងពិតប្រាកដរបស់លន់ ណុន ចង់បានអ្វី ហើយក៏មិនដឹងថា រដ្ឋប្រហារថ្ងៃ១៨ មីនា ឆ្នាំ ១៩៧០ កើតឡើងដោយនរណាពិតប្រាកដដែរ ។

រហូតដល់ឆ្នាំ១៩៧៤ គឺក្រោយពេលធ្វើរដ្ឋប្រហារនោះ៤ឆ្នាំ ពេលលន់ ណុន រស់នៅជាលក្ខណៈនិរទេសខ្លួននៅប្រទេសបារាំង នៅក្នុងខែមិថុនា ក្នុងឱកាសដើរកម្សាន្តតែ២នាក់ជាមួយលន់ ណុន នៅឧទ្យានប៊ូឡូញ (Boulogne) លន់ ណុន បានបង្ហើបពីអាថ៌កំបាំងនៃការធ្វើរដ្ឋប្រហារនោះប្រាប់គាត់ថា រហូតពាក់កណ្តាលអធ្រាត្រថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៧០ លន់ នល់ និងទ្រង់ស៊ីសុវត្ថិ សិរិមត: មិនទាន់ឯកភាពគ្នាថាត្រូវធ្វើយ៉ាងម៉េចទេ ។

លន់ ណុន បានស្នើសុំឱ្យទ្រង់ធ្វើការសម្រេចចិត្តទម្លាក់សម្តេចសីហនុ ប៉ុន្តែព្រះអង្គម្ចាស់សិរិមត: មិនហ៊ានសម្រេចទេ ដោយរង់ចាំលន់ នល់ ជាអ្នកចាប់ផ្តើមមុន។ ឯកលន់ នល់ ក៏រង់ចាំមើលទ្រង់សិរិមត: ចាប់ផ្តើមមុនដែរ។ ប្រហែលម៉ោង៣ទៀបភ្លឺ ឈានចូលដល់ថ្ងៃទី១៨ ខែមីនា លន់ ណុន បានចូលទៅជួបលន់ នល់ នៅគេហដ្ឋាន( នៅក្បែរផ្សារដើមថ្កូវ) ដោយមាន ហង្ស ធុនហាក់, ឆន សុខុម និងគង់ អ៊ិន អមដំណើរជាមួយផង ។ ពេលនោះ លន់ នល់ កំពុងដេកលង់លក់ក្នុងអង្រឹង ។

តែគ្មាននរណាហ៊ានចូលទៅដាស់គាត់ទេ។ រហូតដល់ភ្លឺស្រាង១ លន់ ណុន ក៏សម្រេចចិត្ត ចូលទៅដាស់ ហើយប្រាប់ថា៖ លោកបង។! ព្រះអង្គម្ចាស់សិរិមត: បានយល់ព្រមទម្លាក់សម្តេច សីហនុ ហើយ។ ទ្រង់រង់ចាំតែការសម្រេចចិត្តពីលោកបងតែប៉ុណ្ណោះ ។

ពេលនោះលន់ នល់ នៅទ្រឹងបន្តិច ក៏ប្រាប់លន់ ណុន ថាៈ អើ! បើ ត: ( សិរិមត: ) ព្រម ព្រៀងធ្វើហើយ យើងមានតែសម្រេចធ្វើអ៊ីចឹងទាំងអស់គ្នាទៅ ។

ភ្លាមៗនោះ លន់ ណុន ដោយមានទាហានមួយក្រុមអមការពារផង បាន ធ្វើដំណើរតាមរថយន្តយ៉ាងប្រញាប់ប្រញាល់ឆ្ពោះទៅកាន់ភូមិគ្រឹះរបស់ទ្រង់សិរិ មត:។ ពេលឃើញលន់ ណុន និងក្រុមទាហានចូលទៅដល់ ទ្រង់សិរិមត: ក៏មានការ ភិតភ័យដែរ។ លន់ ណុន ប្រាប់ថា បងប្រុសគាត់( លន់ នល់) បានសម្រេចឱ្យចាត់ការក្នុង រឿងនេះហើយ។ ពេលនោះទ្រង់សិរិមត: ក៏បានយល់ព្រមឱ្យលន់ ណុន ចាប់ផ្តើមអនុវត្ត ផែនការទម្លាក់សម្តេចសីហនុ តែម្តង ។

តាមពិត លន់ ណុន បានប្រើល្បិចភូតកុហកលន់ នល់ ជាបងរបស់គាត់ផងនិង ភូតកុហកព្រះអង្គម្ចាស់សិរិមត:ផងដែរ។ រស់ ចន្ទ្រាបុត្រ ក៏បានសួរលន់ ណុន ថា ឧបមាថា នៅពេលនោះ លន់ នល់ បដិសេធ មិនឱ្យទម្លាក់សម្តេចសីហនុ តើគិតយ៉ាងណា? លន់ ណុន បានឆ្លើយភ្លាមថា គាត់មានផែនការទុកជាមុនរួចស្រេចហើយ បើបងរបស់គាត់មិន យល់ព្រម... គាត់នឹងចាប់បងរបស់គាត់ទុកមួយរយ:សិន ដើម្បីអនុវត្តផែនការនេះ ឱ្យ បានសម្រេច ។

ទីបញ្ជាការសម្រាប់ការអនុវត្តផែនការទម្លាក់សម្តេចសីហនុ នៅថ្ងៃទី១៨ ខែមីនា នោះ គឺនៅក្នុងផ្ទះរបស់ឧត្តមសេនីយ៍ឯកលន់ នល់ ដែលនៅជាប់ទំនប់ទឹក ក្បែរផ្សារ ដើមថ្កូវ នោះតែម្តង ។

ឧត្តមសេនីយ៍ឯកលន់ នល់ ជានាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការពារជាតិ មាន ឥទ្ធិពលទៅលើពលទាហាន និងនាយទាហានយ៉ាងណាក៏ដោយ ក៏គាត់បានបញ្ជាឱ្យ វរសេនីយ៍ឯកសេង ស៊ុនថៃ រៀបចំកងកម្លាំងពិសេសមួយ ដើម្បីត្រៀមលក្ខណ:ទប់ទល់ បង្ក្រាបការងើបបះបោរប្រឆាំងពីសំណាក់ក្រុមទាហានណាមួយផ្សេងទៀត ដែលមិន សប្បាយចិត្តនឹងការទម្លាក់សម្តេចសីហនុ នេះផងដែរ ។

គួរបញ្ជាក់ដែរថា តាំងពីសម័យអាណានិគមនិយមបារាំង មក សិស្សនាយទាហាន

ខ្មែរជំនាន់ទី១ រួមមានៈ ស្រី សាម៉ន, អ៊ុយ សយ, ហ៊ុល ឃុន ( កូនរបស់ស័ក្តិ៣ ប៊ូ ហ៊ុល ដែលគេតែងតែឃើញដើរអមការពារសម្តេចសីហនុ ជាប់ជានិច្ច) ផេង ផាន់អ៊ុ, ឋាប្បនា ងិន, ឆាយ ឡាយ, ហ៊ួ ទ្រូត, សក់ ស៊ុតសាខន និងប៉ុក សំអាន ... ។

ចំណែកនាយទាហានខ្មែរជំនាន់ទី២ រួមមានៈ សេង ស៊ុនថៃ, ពៅ លឹមរ៉ាំ, គ្រូច សំរេច, សុស្តែន ហ្វែរណាង់ដេស និងអ៊ុំ ម៉ាន្នូរិន ...ជាដើម ។

រហូតមកដល់ឆ្នាំ១៩៧០ នោះអតីតសិស្សនាយទាហានខ្មែរជំនាន់ទី១ និង ទី២ខ្លះ បានឡើងឋានន្តរសក្តិជា វរសេនីយ៍ត្រី, ជាវរសេនីយ៍ទោ, វរសេនីយ៍ឯក និង ខ្លះទៀត បានឡើងឋានន្តរស័ក្តិដល់ឧត្តមសេនីយ៍ ។

ប្រភពព័ត៌មានមួយបានអះអាងថា ពេលនោះ ក្រុមនាយទាហានជាន់ខ្ពស់ ដូចជា វរសេនីយ៍ហ៊ុល ឃុន, វរសេនីយ៍ផេង ផាន់អ៊ុ និងវរសេនីយ៍គ្រូច សំរេច មិន សប្បាយចិត្តនឹងការទម្លាក់សម្តេច សីហនុ នោះឡើយ ហើយគ្រូច សំរេច ក៏មានបំណង ចង់យកកាំភ្លើងធំបាញ់ផ្លោងទៅលើផ្ទះលន់ នល់ ទៀតផង ។

ប៉ុន្តែ បាន៣ថ្ងៃក្រោយមក វរសេនីយ៍ហ៊ុល ឃុន នេះ មិនដឹងជាចាញ់ឧបាយកល របស់ លន់ ណុន យ៉ាងដូចម្តេច ក៏បានរួមគ្នាជាមួយមន្ត្រីកងរាជអាវុធហត្ថដៃឆ្វេង៤នាក់ ជាកូនចៅជំនិតរបស់លន់ ណុន ដែលពេលនោះ មានឋានន្តរស័ក្តិត្រឹមតែវរសេនីយ៍ត្រី ទៅធ្វើឃាតវរសេនីយ៍ឯកសេង ស៊ុនថៃ ទៅវិញ ។

ប្រភពព័ត៌មាននោះ បានអះអាងថា នៅយប់ថ្ងៃទី២១ ខែមីនា ហ៊ុល ឃុន និង មន្ត្រីកងរាជអាវុធហត្ថដៃឆ្វេង ទាំង៤នាក់នោះបាននាំគ្នាជិះរថយន្តទៅបាញ់សម្លាប់ មិត្តភក្តិរបស់វរសេនីយ៍ឯកសេង ស៊ុនថៃ ម្នាក់ឈ្មោះប៊ូ កាបូ នៅនឹងផ្ទះរបស់ជនរងគ្រោះ ដែលនៅតាមបណ្តោយមហាវិថីកម្ពុជាក្រោម នោះតែម្តង។ លុះបាញ់សម្លាប់រួចហើយ ពួកគេក៏បានលើកសាកសពមកដាក់ក្នុងឃ្លុបខាងក្រោយរថយន្តជនរងគ្រោះ ហើយ ចេញដំណើរសំដៅទៅរកវរសេនីយ៍ឯកសេង ស៊ុនថៃ ដែលកំពុងនៅផ្ទះលន់ នល់ ជា ទីបញ្ជាការ នៃប្រតិបត្តិការធ្វើរដ្ឋប្រហារនោះ ។

ពេលចូលទៅដល់ មន្ត្រីកងរាជអាវុធហត្ថដៃឆៅម្នាក់ក្នុងចំណោមទាំង៤នាក់នោះ ក៏បានចុះទៅគំនាប់ វរសេនីយ៍ឯកសេង ស៊ុនថៃ រួចនិយាយថា៖ លោកកាបូ ឱ្យពួកខ្ញុំមកទទួលតេជគុណទៅជួប សូមអញ្ជើញតេជគុណ ឡើងរថយន្ត... ។

ដោយសារ ប៊ូ កាបូ ជាមិត្តភក្តិជិតស្និទ្ធបំផុត តែងតែដើរផឹកស៊ីជាមួយគ្នាស្ទើររាល់ថ្ងៃនោះ ពេលឃើញរថយន្តរបស់ឈ្មោះប៊ូ កាបូ មកទទួលដូច្នេះ វរសេនីយ៍ឯកសេង ស៊ុនថៃ ពុំមានអ្វីគួរឱ្យសង្ស័យអ្វីបន្តិចឡើយ គាត់បានចូលទៅក្នុងរថយន្តនោះ ដើម្បីទៅជួបមិត្តភក្តិផឹកស៊ីជាមួយគ្នា ដើម្បីឱ្យធូរអារម្មណ៍បន្តិច ។

ពេលទៅដល់ពាក់កណ្តាលផ្លូវ ក៏ត្រូវពួកកងរាជអាវុធហត្ថដាដៃជើងរបស់ លន់ ណុន ទាំង៤នាក់ នាំគ្នាក្រៀករឹតកវរសេនីយ៍សេង ស៊ុនថៃ សម្លាប់ចោលនៅលើរថយន្តនោះតែម្តង រួចហើយបើករថយន្តដឹកសាកសពយកទៅដាក់ ក្នុងផ្ទះថ្មដែលគេទុកចោលមួយ នៅតាមបណ្តោយមហាវិថីកម្ពុជាក្រោម និងនៅទល់មុខផ្ទះរបស់ជនរងគ្រោះ ឈ្មោះប៊ូ កាបូ។

ផ្ទះដែលគេទុកចោលនោះ ជាកម្មសិទ្ធិរបស់ឈ្មោះសេង ស៊ុនថេង ជាបងបង្កើតរបស់វរសេនីយ៍ឯកសេង ស៊ុនថៃ ដែលបានទទួលមរណភាពដោយសារគ្រោះថ្នាក់ចរាចរណ៍កាល៣ឆ្នាំមុន ហើយសេង ស៊ុនថៃ ជាអ្នកកាន់កាប់ថែរក្សាផ្ទះនេះ និងឧស្សាហ៍ជុំគ្នាផឹកស៊ីជាមួយមិត្តភក្តិឈ្មោះប៊ូ កាបូ នៅក្នុងផ្ទះនេះផងដែរ ។

ប្រភពដដែលបានអះអាងថា ពេលចូលទៅដល់ខាងក្នុង មន្ត្រីកងរាជអាវុធហត្ថដៃឆៅទាំង៤នាក់ បានយកសាកសព វរសេនីយ៍ឯកសេង ស៊ុនថៃ និងប៊ូ កាបូ ទៅដាក់ក្នុងបន្ទប់មួយជុំគ្នា ហើយបានរៀបចំដាក់ដបស្រា កែវស្រា សាច់ក្រៀម និងបបរ ដាក់ចាននៅពេញលើតុមួយ រួចវរសេនីយ៍ហ៊ុល ឃុន បានយកកាំភ្លើងខ្លីទៅបាញ់ផ្ទឹបត្រង់ថ្ពាល់ខាងស្តាំរបស់សាកសពវរសេនីយ៍ឯកសេង ស៊ុនថៃ មួយគ្រាប់ ធ្លាយចេញទៅចំហៀងខាងក្រោយក្បាល រួចហើយក៏យកកាំភ្លើងខ្លីនោះ មកដាក់នៅលើដៃសពរបស់ប៊ូ កាបូ ។ ក្រោយពីមានការភ្ញាក់ផ្អើលពីរឿងឃាតកម្មនេះ ពួកគេនាំគ្នាប្រតិដ្ឋហេតុការណ៍នោះថា

វរសេនីយ៍ឯកសេង ស៊ុនថៃ និងប៊ូ កាបូ ជាមិត្តភក្តិជិតស្និទ្ធនឹងគ្នានោះ បានផឹកស៊ីស្រវឹង ហើយឈ្លោះប្រកែកគ្នា រហូតដល់ទាញកាំភ្លើងខ្លីបាញ់សម្លាប់គ្នាទៅវិញទៅមក ។

ប្រភពដដែលបានរម្លឹកថា កាល សឺង ង៉ុកថាញ់ រត់ចូលព្រៃ នៅថ្ងៃទី០៩ ខែមីនា ឆ្នាំ១៩៥២ បង្កើតចលនាតស៊ូប្រឆាំងបារាំង នៅភ្នំដងរែក អនុសេនីយ៍ទោ ដួងច័ន្ទ សារ៉ាត ក៏បាននាំពលទាហាន នឹងកាំភ្លើងជាច្រើនរត់ចោលជួរកងទ័ពបារាំង ទៅចូលរួមតស៊ូជាមួយសឺង ង៉ុកថាញ់ ។

ពេលនោះសេង ស៊ុនថៃ ក៏បាននាំកូនទាហានមួយចំនួន រត់ទៅចូលរួមតស៊ូជាមួយសឺង ង៉ុកថាញ់ ដែរ។ តែត្រូវពួកទាហានបារាំង តាមទៅទាន់នៅត្រង់ភ្នំត្បែងមានជ័យ ក៏ចាប់ពួកគាត់យកត្រលប់មកវិញ ហើយបារាំង ក៏បានដកតំណែងជាមេបញ្ជាការរបស់គាត់តាំងពីពេលនោះមក ។

មជ្ឈដ្ឋានមួយចំនួនបានសន្និដ្ឋានថា មូលហេតុដែលលន់ ណុន បញ្ជាឱ្យគេសម្លាប់វរសេនីយ៍ឯកសេង ស៊ុនថៃ នេះ គឺដោយសារមិនទុកចិត្តសេង ស៊ុនថៃ ព្រោះខ្លាចទៅថ្ងៃក្រោយ សេង ស៊ុនថៃ ទៅចូលរួមជាមួយសឺង ង៉ុកថាញ់ ជាមេចលនាតស៊ូខ្មែរសេរី ដែលមានសហរដ្ឋអាមេរិក គាំទ្រជាយូរឆ្នាំមកហើយនោះ កម្ចាត់លន់ នល់ ជាបងប្រុសគាត់ចេញពីអំណាចវិញ។ តែទោះបីជាយ៉ាងណា នេះគ្រាន់តែជាការអះអាងពីប្រភពមិនផ្លូវការមួយប៉ុណ្ណោះ ។

# ២៧៦
# សុទ្ធ ប៉ូលីន ស្រក់ទឹកភ្នែក អាណិតសម្តេចសីហនុ







សុទ្ធ ប៉ូលីន ចាងហ្វាងកាសែតនគរធំ

ថ្ងៃទី១៩ ខែមីនា ឧត្តមសេនីយ៍លន់ នល់ នាយករដ្ឋមន្ត្រីរាជរដ្ឋាភិបាលស្រោចស្រង់ជាតិ ចេញមុខប្រកាសតាមវិទ្យុជាតិ ស្តីពីខ្លឹមសារនៃសេចក្តីសម្រេចរបស់រដ្ឋសភាក្នុងការទម្លាក់សម្តេចសីហនុ ចេញពីតំណែងប្រមុខរដ្ឋ និងប្រកាសអំពាវនាវឲ្យប្រជាពលរដ្ឋរក្សាភាពស្ងប់ស្ងៀម។

រសៀលថ្ងៃទី១៩ ខែមីនា ដដែលនោះដែរ តាមរយៈការចាក់ផ្សាយបន្តផ្ទាល់របស់ឧគ្ឃោសនសព្ទដ៏ធំមួយ នៅមុខទីធ្លាទីស្តីការក្រសួងឃោសនាការ មានប្រជាពលរដ្ឋ មន្ត្រីរាជការ អ្នកកាសែតជាច្រើនឈរចាំស្តាប់ត្រៀបត្រា ក្នុងនោះមាន សុទ្ធ ប៉ូលីន ជាចាងហ្វាងកាសែតនគរធំ ម្នាក់ដែរ នាយករដ្ឋមន្ត្រីលន់ នល់ បានប្រកាសពន្យល់ពី

ហេតុផលនៃការទម្លាក់សម្តេចសីហនុ ចេញពីតំណែងប្រមុខរដ្ឋជាលើកទី២ ។ ពេលនោះ សុទ្ធ ប៉ូលីន ហាក់ដូចជាមានចិត្តអាណិតអាសូរចំពោះសម្តេចសីហនុ រហូតដល់ស្រក់ទឹកភ្នែក ដោយមិនដឹងខ្លួន ។

សុទ្ធ ប៉ូលីន បញ្ជាក់ថា នេះជាលើកទី២ក្នុងជីវិតគាត់ ដែលទប់ទឹកភ្នែកមិនបាន ដោយសារមានមនោសញ្ចេតនាជាមួយសម្តេចសីហនុ។ លើកទី១ គាត់ស្រក់ទឹកភ្នែក ដោយសារសម្តេចសីហនុ ប្រកាសដាក់រាជ្យសម្បត្តិក្នុងឆ្នាំ ១៩៥៥។ តាំងពីយុវវ័យមក គាត់រស់នៅបានសុខសប្បាយក្រោមការដឹកនាំរបស់សម្តេចឪ គាត់ស្រឡាញ់សម្តេចឪ ដូចជាឪពុកបង្កើត ។

នៅក្បែរគាត់ អ្នកខ្លះបានខ្សឹបគ្នាថា ធ្វើគុណ១០០សំពៅ ទោសមួយចូលទៅរលាយអស់ ។ សម្តេចជាព្រះបិតា ជាតិ ជាវីរជនស្នេហាជាតិ គេមិនត្រូវវិនិច្ឆ័យទោសព្រះអង្គ ដោយគ្រាន់តែមានទោសកំហុសមួយប៉ុណ្ណោះ បានទេ ។

បន្ទាប់មក គាត់ក៏បើករថយន្ត( ម៉ាក Simca-Aronde ) ចេញពីមុខទីស្តីក្រសួងឃោសនាការ ដោយមិនដឹងថា ទៅទីណាពិតប្រាកដ?។ លុះព្រលប់បន្តិច គាត់បានសម្រេចចិត្តកាច់ចង្កូតរថយន្តតាមផ្លូវទៅចម្ការដូង ក្នុងបំណងទៅភូមិគ្រឹះលំហែកាយរបស់លន់ ណុន នៅក្នុងភូមិបារគូ ឃុំបារគូ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។

គាត់សង្ឃឹមថា នឹងបានជួបលន់ ណុន នៅភូមិគ្រឹះនោះ ដើម្បីស្ទាបស្ទង់ចង់ដឹងពីចិត្តលន់ នល់ ជាបងប្រុសគាត់ក្នុងរឿងទម្លាក់សម្តេចសីហនុ នេះ។ តែចៃដន្យ ពេលទៅដល់ម្តុំស្ទឹងមានជ័យ មានសត្វពស់មួយធំកំពុងដេកឆ្វាយរង្វេលនៅចំកណ្តាលថ្នល់ផ្លូវ ។ គាត់ប្រញាប់ជាន់ហ្វ្រាំងរថយន្តទាំងគំហុក ហើយរវៃកញ្ចក់រថយន្តមើលបន្តិច ក៏ជាន់ហ្គារ បើកទៅកិនលើសត្វពស់នោះ លាន់ឮសំឡេងឃឹក! ទំនងដូចជាកិន ចំកន្ទុយពស់ ឬមួយកិនលើដុំថ្មអ្វីមួយផង ក៏មិនដឹង? រួចហើយគាត់កាច់ចង្កូតរថយន្តត្រលប់ក្រោយវិញ ដើម្បីរកមើលសត្វពស់នោះ តែមិនឃើញមានអ្វីបន្តិចសោះ ។

គាត់ភិតភ័យជាខ្លាំង និងគិតក្នុងចិត្តថា ប្រហែលជាពស់នោះលូនមកនៅក្រោម

រថយន្តទេដឹង?។ ហេតុការណ៍នេះ ធ្វើឱ្យគាត់មានអារម្មណ៍គិតថា ប្រហែលជាសម្ដេចសីហនុ ត្រលប់ចូលមកប្រទេសខ្មែរវិញ តាមអាកាសយានដ្ឋានខេត្តសៀមរាប ទេដឹង? ។

ពេលវិលត្រលប់មកផ្ទះវិញ គាត់នៅតែមានអារម្មណ៍រវើរវាយថា ខាងលន់ នល់ និងរាជរដ្ឋាភិបាល ព្រមទាំងរូបគាត់ផងដែរ មិនអាចយកជ័យជម្នះទៅលើសម្ដេចសីហនុ បានទេ ។

ថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧០ អ្នកនិពន្ធដ៏សំខាន់ពីររូបនៅក្នុងអង្គភាពសារព័ត៌មាននគរធំ គឺ នួន ឃឿន និងខាំម ពូនគឹមនី មកជួបគាត់នៅក្នុងការិយាល័យ ហើយនិយាយថា គោលជំហរក្នុងការសរសេរអត្ថបទនយោបាយរបស់ពួកគេ គឺដើម្បីប្រឆាំងនឹងយួន មិនមែនដើម្បីទម្លាក់សម្ដេចសីហនុ ទេ។ ដូច្នេះ ពួកគេមិនអាចនៅធ្វើជាអ្នកនិពន្ធឲ្យកាសែតនគរធំ របស់គាត់ តទៅទៀតបានទេ ។

បន្ទាប់មកទៀត គឹម សែត ជានិពន្ធនាយកសារព័ត៌មាននគរធំ របស់គាត់ ក៏ត្រូវជូ ថានី ចាងហ្វាងកាសែតកោះសន្តិភាព អូសទាញឲ្យទៅធ្វើជានិពន្ធនាយករបស់កាសែតកោះសន្តិភាព បាត់ទៀត ។

សុទ្ធ ប៉ូលីន បានរម្លឹកថា ពេលនោះដែរ គាត់ខំប្រឹងស្ដាបស្ទង់ប្រតិកម្មដំបូងរបស់ពួកកាសែតបរទេស ជាពិសេស អ្នកនិពន្ធកាសែតរបស់សម្ដេចសីហនុ ២នាក់ ដែលជាមនុស្សជិតស្និទ្ធជាមួយព្រះអង្គ គឺ ប៊ែរណា ហាមែល ( Bernard Hamel ) និង ហ្សាល ម៉ីយ័រ ( Charles Meyer )។ គាត់បានជួប ប៊ែរណា ហាមែល( Bernard Hamel ) មួយភ្លែតនៅក្រសួងឃោសនាការ និងបានសួរអំពីព្រឹត្តិការណ៍ទម្លាក់សម្ដេចសីហនុ នេះ។ តាមរយៈស៊ឹម វ៉ា ជាអ៊ំរបស់គាត់ គឺអ្នកកាសែតបរទេសដែលជាមនុស្សជិតស្និទ្ធនឹងសម្ដេចសីហនុ ទាំងពីរនាក់នេះ បែរជាយល់ថា លន់ នល់ មានថ្វីដៃអស្ចារ្យណាស់ ដែលបានធ្វើបដិវត្តន៍មួយដោយមិនមានការបង្ហូរឈាមទៅវិញ ។

សុទ្ធ ប៉ូលីន បញ្ជាក់ថា តាមពិតទៅ គេពិបាកយល់ចិត្ត ហ្សាល ម៉ីយ័រ ( Charles Meyer ) ណាស់ ព្រោះអាថ៌កំបាំងអ្វីៗ គាត់មិនបញ្ចេញមកខាងក្រៅឲ្យអ្នកណាដឹងទេ។

តែក្រោយមក ប្រវត្តិវិទូដេវីត ឆាដល័រ ( David Chandler ) បានប្រាប់គាត់ ថា ហ្សាល ម៉ីយ័រ ( Charles Meyer ) ជាភ្នាក់ងារសម្ងាត់របស់រដ្ឋាភិបាលបារាំង ។ ប៉ុន្តែនៅក្នុងព្រឹត្តិការណ៍រដ្ឋប្រហារថ្ងៃ១៨ ខែមីនា ហ្សាល ម៉ីយ័រ ( Charles Meyer ) បានចេញមុខគាំទ្រទ្រង់ស៊ីសុវត្ថិ សិរិមតៈ ជាចំហតែម្តង។ ចំណែក ប៊ែរណា ហាមែល ( Bernard Hamel ) គាំទ្រលន់ នល់ ។

សុទ្ធ ប៉ូលីន បន្តទៀតថា នៅព្រឹកថ្ងៃទី២១ ខែមីនា លន់ ណុន បានហៅគាត់ឲ្យទៅប្រជុំជាមួយមិត្តភក្តិគាត់ម្នាក់ឈ្មោះថោង លឹមហួង ។

លន់ ណុន ចង់ឱ្យគាត់ទៅជួយគ្រប់គ្រងទីភ្នាក់ងារសារព័ត៌មានខ្មែរ ( AKP ) តែគាត់មិនស្រឡាញ់កិច្ចការនេះ គាត់ក៏បង្វិលទៅឲ្យ ថោង លឹមហួង ជាមិត្តភក្តិគាត់ឱ្យទៅគ្រប់គ្រងវិញ ។

ថ្ងៃទី២១ ខែមីនានោះដែរ នៅផ្ទះលន់ នល់ គេឃើញពួកមេទាហាន និងមន្ត្រីជាន់ខ្ពស់ជាច្រើនដូចជា ឡេស កាសេម, ថាច់ ប៉ូច, ថាច់ រ៉េង, កេង វ៉ាន់សាក់, គឹង តុន និងហង្ស ធុនហាក់ ជាដើម បានមកជុំគ្នានិយាយសរសើរពីជោគជ័យនៃការធ្វើរដ្ឋប្រហារថ្ងៃទី១៨ ខែមីនានោះ ដោយទឹកចិត្តសប្បាយរីករាយបំផុត ។

នៅពេលធ្វើរដ្ឋប្រហារនោះ លន់ នល់ បានបញ្ជាឲ្យគេចាប់ ប៊ូ ហ៊ែល, អ៊ឹង ហុងសាធ, ទេព ឈីខេង ... ផងដែរ។ តែមិនយូរប៉ុន្មាន គាត់បានបញ្ជាឱ្យដោះលែងពួកនេះវិញ។ ចំណែក សុស្តែន ហ្វែរណង់ដេស ត្រូវបានតែងតាំងជាមេបញ្ជាការយោធភូមិភាគទី២។

នៅថ្ងៃទី២១ ខែមីនា នេះដែរ ចេង ហេង បានឡើងធ្វើសច្ចាប្រណិធាននៅចំពោះមុខសមាជិករដ្ឋសភា សមាជិកក្រុមប្រឹក្សាព្រះរាជាណាចក្រ និងសមាជិករដ្ឋាភិបាល ដើម្បីចូលកាន់តំណែងប្រមុខរដ្ឋជំនួសសម្តេចសីហនុ ។

ការពិតទៅ ចេង ហេង ពុំមែនជាអ្នកចូលរួមផ្តួចផ្តើមគំនិតផ្ទាល់ក្នុងការរៀបចំផែនការផ្តួលរម្លំសម្តេចសីហនុ ទេ។ ប៉ុន្តែ ដោយសារសម្តេចសីហនុ យាងចេញទៅក្រៅ

ប្រទេស តាមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា គាត់ជាប្រធានរដ្ឋសភាត្រូវទទួលឋានៈជាប្រមុខរដ្ឋស្តីទី។ ដូច្នេះ ដើម្បីបង្ហាញថា ការទម្លាក់សម្តេចសីហនុ គឺស្របច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា លន់ នល់ និងទ្រង់សិរិមតៈ ត្រូវតែឱ្យគាត់ដើរតួជាអ្នកមានឋានៈកំពូលនេះតែម្តងទៅ ។

នៅយប់ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ក្រោយទម្លាក់សម្តេចសីហនុ បានប៉ុន្មានម៉ោង លន់ ណុនក៏បានស្នើសុំឱ្យឧត្តមសេនីយ៍ឯកលន់ នល់ ជាបងប្រុសគាត់ឱ្យប្រកាសបង្កើតរបបសាធារណរដ្ឋ ដើម្បីជំនួសរបបរាជានិយម ភ្លាមៗដែរ។ ប៉ុន្តែ ក្រោយពីបានដឹងរឿងនេះ ទ្រង់សិរិមតៈ ក៏បានស្នើសុំកុំទាន់ឱ្យប្រកាស បង្កើតរបបសាធារណរដ្ឋ សិន ។

# ២៧៧
# ជូ អេនឡាយ និងផាំ វ៉ាន់ដុង ជំរុញឱ្យសីហនុ បង្កើតរណសិរ្សរួបរួមជាតិកម្ពុជា



នាយករដ្ឋមន្ត្រីចិន ជូ អេនឡាយ

*នៅទីក្រុងប៉េកាំង នាយករដ្ឋមន្ត្រីចិន ជូ អេនឡាយ មានការខ្វល់ខ្វាយយ៉ាងខ្លាំង ចំពោះព្រឹត្តិការណ៍ធ្វើរដ្ឋប្រហារទម្លាក់សម្តេចសីហនុ នៅទីក្រុងភ្នំពេញនោះ។ គាត់បាន ជួបពិភាក្សាជាមួយ អេ ផេនម៉ាណាស ឯកអគ្គរដ្ឋទូតបារាំង ប្រចាំក្រុងប៉េកាំង ពីបញ្ហា ដែលថា តើប្រទេសចិន ត្រូវទទួលស្គាល់សម្តេចសីហនុ ជាប្រមុខរដ្ឋរបស់ប្រទេសកម្ពុជា តាមវិធីណា ដើម្បីកុំឱ្យប៉ះពាល់ដល់ទំនាក់ទំនងការទូត និងយុទ្ធសាស្ត្ររបស់ចិន នៅលើ ឆាកអន្តរជាតិ ។*

*ចំណែក នាយករដ្ឋមន្ត្រីប្រទេសវៀតណាមខាងជើង ផាំ វ៉ាន់ដុង កាន់តែមានការ ខ្វល់ខ្វាយជាង ជូ អេនឡាយ ទៅទៀត។ ភ្លាមៗនោះ គាត់បានធ្វើដំណើរទៅទីក្រុងប៉េកាំង*

ដើម្បីជួបពិភាក្សាគ្នាជាមួយមេដឹកនាំចិន ជុំវិញបញ្ហាទម្លាក់សម្ដេចសីហនុ នេះ ។

នៅរសៀលថ្ងៃទី២១ ខែមីនា ឆ្នាំ១៩៧០ នាយករដ្ឋមន្ត្រី នៃប្រទេសកុម្មុយនិស្ដទាំង២ បានជួបពិភាក្សាគ្នាយ៉ាងយូរ ។

ជាកិច្ចចាប់ផ្ដើមនៃការពិភាក្សាគ្នានោះ ជូ អេនឡាយ ប្រាប់ទៅផាំ វ៉ាន់ដុង ថា ប្រទេសបារាំង មានការព្រួយបារម្ភណាស់ ប្រសិនបើសម្ដេចសីហនុ ងាកមកខាងយើង ( ចិន និងវៀតណាមខាងជើង) ប្រទេសកម្ពុជា នឹងក្លាយទៅជាទីលានសមរភូមិមួយទៀត ហើយក៏មានការប៉ះពាល់ដល់ផលប្រយោជន៍ប្រទេសបារាំង ផងដែរ ។ ដូច្នេះ បារាំង ចង់ដណ្ដើមយកសមានចិត្តរបស់សម្ដេចសីហនុ ផង និងសហភាពសូវៀត ផង ។

បារាំង ប្រហែលជាអាចពន្យល់ទៅ សហភាពសូវៀត ថា ពួកលន់ នល់ មិនមែនងាកទៅរកអាមេរិក ទាំងស្រុងនោះទេ គឺពួកគាត់អាចងាកទៅខាងបារាំង ដើម្បីប្រកាន់ជំហរនយោបាយអព្យាក្រឹតបន្តទៀតដែរ។ ដូច្នេះ រដ្ឋាភិបាលលន់ នល់ អាចត្រូវគេទទួលស្គាល់ ហើយ បារាំង ប្រហែលជាសន្យាថា នឹងជួយឱ្យយោបល់ទៅរដ្ឋាភិបាលលន់ នល់ ពីបញ្ហាវាយប្រហារទៅលើកងទ័ពវៀតកុង-វៀតណាមខាងជើង ។

ចំណែករដ្ឋាភិបាលលន់ នល់ បាន សន្យាដែរថា ពួកគេនឹងបន្តគោលនយោបាយអព្យាក្រឹត និងគោរពកិច្ចព្រមព្រៀង ដែលបានចុះហត្ថលេខាពីមុនៗមក ពិសេសគេបានបញ្ជាឱ្យចាត់វិធានការការពារសន្តិសុខចំពោះស្ថានទូតចិន និងស្ថានទូតសហភាពសូវៀត នៅទីក្រុងភ្នំពេញ ទៀតផង ។

ជូ អេនឡាយ បានបញ្ជាក់ប្រាប់ផាំ វ៉ាន់ដុង ថា ពេលនេះ យើងគួរតែគាំទ្រសម្ដេចសីហនុ ហើយយើងចាំមើលថា តើព្រះអង្គមានសកម្មភាពយ៉ាងណា។ យើងគួរតែគាំទ្រ ពីព្រោះព្រះអង្គបានគាំទ្រការតស៊ូរបស់យើងក្នុងការប្រឆាំងនឹងសហរដ្ឋអាមេរិក នៅវៀតណាមខាងត្បូង។ ព្រះអង្គគាំទ្រដល់ប្រជាជាតិនៅតណ្ហចិន ក្នុងការប្រឆាំងជប៉ុន និង បារាំង កាលពីអតីតកាល ហើយព្រះអង្គក៏បានចូលរួមក្នុងសន្និសីទរបស់

ប្រទេសមិនចូលបក្សសម្ព័ន្ធនៅទីក្រុងបានឌុង ឆ្នាំ១៩៥៥ ដែរ ។

យើងនឹងរង់ចាំមើលថា មុនពេលយើងប្រកាសគាំទ្រព្រះអង្គ តើព្រះអង្គប្រាកដជាចង់បង្កើតរណសិរ្សរួបរួមជាតិមួយ ដើម្បីប្រឆាំងនឹងអាមេរិក ដែរឬទេ? ព្រោះព្រះអង្គអាចផ្លាស់ប្ដូរជំហរទៅតាមកាលៈទេសៈ។ តែទោះជាយ៉ាងណា យើងត្រូវដណ្ដើមសមានចិត្តរបស់ព្រះអង្គឱ្យមករកយើងកាន់តែច្រើនគឺកាន់តែប្រសើរ។ នេះគឺជាអ្វីដែលយើងត្រូវគិតទុកតាំងពីដំបូងទីមក ។

ខ្ញុំគិតថា រដ្ឋប្រហារទម្លាក់សម្ដេចសីហនុ របស់លន់ នល់ ទទួលការឯកភាពគ្នាពីបារាំង និងអាមេរិក។ ដូច្នេះ បារាំង លែងមានជំនឿលើសម្ដេចសីហនុ ទៀតហើយ ។

ជូ អេនឡាយ បាននិយាយទៅកាន់ ផាំ វ៉ាន់ដុង បន្តថា បើនិយាយពីសមត្ថភាពប្រយុទ្ធរបស់គាត់គឺសម្ដេចសីហនុ ប្រាកដជាមិនអាចប្រៀបផ្ទឹមជាមួយសមមិត្តបានឡើយ ។ តែបើព្រះអង្គយល់ព្រមបង្កើតរណសិរ្សរួបរួមជាតិ មួយនោះ កម្លាំងតស៊ូកម្ពុជា អាចឡើងខ្លាំងជាងមុន។ ប៉ុន្តែកន្លងមក បារាំងបានឱ្យយោបល់ទៅព្រះអង្គថា កុំធ្វើដូច្នេះ ព្រោះបើព្រះអង្គអនុញ្ញាតឱ្យកងទ័ពវៀតណាម ( វៀតកុង) ចូលមកក្នុងទឹកដីរបស់ព្រះអង្គហើយនោះ កងទ័ពវៀតណាម នោះ ប្រាកដជាមិនចេញទៅវិញឡើយ។ បារាំង ក៏ដឹងថា សម្ដេចសីហនុ មិនជឿបារាំង ទាំងស្រុងទេ ដូច្នេះហើយ បានជាបារាំង ចង់ឱ្យលន់ នល់ ឡើងដឹកនាំប្រទេសជំនួសព្រះអង្គវិញ ។

ជូ អេនឡាយ បន្តថា សម្ដេចសីហនុ ទោរទន់ទៅរកសហភាពសូវៀត និងចិន ហើយលន់ នល់ ក៏មិនចង់ធ្វើឱ្យសហភាពសូវៀត និងចិន មិនសប្បាយចិត្តដែរ ។ ក្រោយរដ្ឋប្រហារ លន់ នល់ មិនបានឱ្យទាហានគាត់បើកការវាយប្រហារភ្លាមៗទៅលើកងទ័ពសមមិត្ត( ផាំ វ៉ាន់ដុង) ដែលកំពុងបោះទីតាំងនៅតាមបណ្ដោយព្រំដែនដែរ ហើយគាត់ក៏មិនបង្ខំឱ្យយើងដោះស្រាយបញ្ហានេះដែរ ។ ប៉ុន្តែ ពួកគាត់បានបំផ្លិចបំផ្លាញផ្ទះរបស់ជនជាតិចិន និងវៀតណាម ជាច្រើន នៅខេត្តស្វាយរៀង។ មួយថ្ងៃក្រោយមក( ថ្ងៃ១៩មីនា) លន់ នល់ បានចេញបទបញ្ជាមួយ មិនឱ្យមានការប៉ះពាល់ដល់ស្ថានទូតចិន

និងស្ថានទូតសហភាពសូវៀត នៅទីក្រុងភ្នំពេញ ។

ម្យ៉ាងទៀត លន់ នល់ ក៏ញញើតដែរ បើគាត់ហ៊ានបើកការវាយប្រហារទៅលើកងទ័ពសមមិត្ត( ផាំ វ៉ាន់ដុង) គាត់ក៏ខ្លាចកងទ័ពសមមិត្តវាយបកវិញ ហើយចិន នឹងគាំទ្រវៀតណាម ។ ពេលនោះ សង្គ្រាមនៅឥណ្ឌូចិន នឹងកាន់តែរីករាលដាលដូចកាលមុនមានកិច្ចព្រមព្រៀងក្រុងហ្សឺណែវ ឆ្នាំ១៩៥៤ ទៀតជាមិនខាន ។



**នាយករដ្ឋមន្ត្រីប្រទេសវៀតណាមខាងជើង ផាំ វ៉ាន់ដុង**

ជូ អេនឡាយ បានរម្ងឹក ផាំ វ៉ាន់ដុង ថា សមមិត្តនឹងចាំបានននូវអ្វី ដែលសមមិត្តប្រធានម៉ៅ ធ្លាប់បាននិយាយទៅ កាន់សមមិត្តប្រធានហូ ជីមិញ ថា ឥណ្ឌូចិន ត្រូវតែរួបរួមគ្នាឱ្យដូចជាប្លុកតែមួយ ។

ទាក់ទងដល់លទ្ធភាពនៃកិច្ចសហប្រតិបត្តិការរវាងពួកខ្មែរក្រហមជាមួយសម្តេចសីហនុ និងពួកវៀតកុង-វៀតណាមខាងជើង ជូ អនឡាយ បានប្រាប់ទៅផាំ វ៉ាន់ដុង ថា យើងមានអារម្មណ៍ថា សម្តេចសីហនុ ចង់ឱ្យយើងជួយអំពីគោលការណ៍មិនលូកដៃចូល

ក្នុងកិច្ចការផ្ទៃក្នុងរបស់កម្ពុជា ផងដែរ ។

ផាំ វ៉ាន់ដុង បានតបវិញថា វានឹងពុំមានអ្វីលំបាកទេ ប្រសិនបើយើងយល់ព្រម លើគោលការណ៍ដឹកនាំមួយចំនួន។ ក្នុងស្ថានភាពបែបនេះ យើងសូមឱ្យទាំងសងខាង សហការគ្នា។ តើសម្តេចសីហនុ កំពុងរង់ចាំចម្លើយរបស់សមមិត្ត ( ជូ អេនឡាយ)មែន ទេ?

ជូ អេនឡាយ ឆ្លើយថា មែនហើយ! ពីព្រោះខ្ញុំបានប្រាប់ព្រះអង្គថា ខ្ញុំនឹងឆ្លើយ តបទៅព្រះអង្គវិញ បន្ទាប់ពីបានពិភាក្សាជាមួយសមមិត្តរួច។ ខ្ញុំដឹងថា មុនដំបូង ពួក លន់ នល់ និងសិរិមតៈ ចង់ចរចាជាមួយវៀតណាមខាងជើងផង និងវៀតណាមខាងត្បូង ផង។ ប្រសិនដូច្នេះមែន តើសមមិត្តដោះស្រាយបញ្ហានេះដោយវិធីណា? ។

ផាំ វ៉ាន់ដុង តបទៅវិញថា មុននឹងមកទីនេះ យើងបានពិភាក្សាគ្នាពីរឿងហ្នឹង ដែរ។ យើងយល់ថា ការចរចារបៀបនេះ នឹងមិននាំមកនូវលទ្ធផលអ្វីទេ ហើយពួកគេ អាចធ្វើការវាយប្រឆាំងយើងវិញដាយថាហេតុ តែយើងមិនចាញ់ ជាដាច់ខាត។ ដូច្នេះ ការចរចានោះគ្មានបានប្រយោជន៍អ្វីឡើយ។ តែទោះបីយ៉ាងណាក្តី ពេលនេះយើងមក ពិភាក្សាជាមួយសមមិត្ត( ជូ អេនឡាយ) និងសម្តេចសីហនុ ដើម្បីចង់ដឹងច្បាស់ថា តើ ស្ថានការណ៍វានឹងវិវត្តទៅជាយ៉ាងណា យើងសូមឱ្យសមមិត្តរង់ចាំបន្តិចសិន ។ តែឥរិយា បថរបស់យើងចំពោះសម្តេចសីហនុ គឺវិជ្ជមាន ។

ពេលសម្តេចស្នាក់នៅទីក្រុងប៉េកាំង បើទោះបីមេដឹកនាំចិន នៅតែចាត់ទុកថា ព្រះអង្គជាប្រមុខរដ្ឋរបស់ប្រទេសកម្ពុជា ក៏ពិតមែន ប៉ុន្តែការទទួលស្វាគមន៍ព្រះអង្គ មិន មានភាពអធិកអធមប៉ុន្មានទេ ។

នាយករដ្ឋមន្ត្រីចិន ជូ អេន ឡាយ ក៏បានទទួលជួបព្រះអង្គ ហើយសួរបញ្ជាក់ថា តើព្រះអង្គមានបំណងចង់ចាប់ផ្តើមធ្វើការតស៊ូ ដើម្បីប្រឆាំងនឹងពួកលន់ នល់ វិញដែរឬ ទេ?។ តែមេដឹកនាំចិនរូបនេះ ក៏បានទុកពេលឱ្យព្រះអង្គធ្វើការពិចារណាដែរ មុននឹងឆ្លើយ សំណួរនេះ ។



**សម្តេចសីហនុ និងផាំ វ៉ាន់ដុង**

*នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧០ សម្តេចសីហនុ បានប្រកាសបង្កើតរណសិរ្សមួយហៅថា រណសិរ្សរួបរួមជាតិកម្ពុជា ។*

*ប៉ែន នុត ត្រូវបានតែងតាំងជាប្រធានការិយាល័យនយោបាយនៃគណៈកម្មាធិការមជ្ឈិមរណសិរ្សរួបរួមជាតិកម្ពុជា និងសមាជិកការិយាល័យនយោបាយ ១០រូបទៀត រួមមាន ៖ ខៀវ សំផន, ហ៊ូ នឹម, ហ៊ូ យន់, ចៅ សេង, ដួង សំអុល, ហួត សម្បត្តិ, ចាន់ យូរ៉ាន់, ជា សាន, សារិន ឆាក និងជួន មុម្ម ។*

*ជាមួយគ្នានោះ សម្តេច សីហនុ បានប្រកាសនូវគោលការណ៍៥ ចំណុចដែលមានខ្លឹមសារថា៖ ១-ក្នុងឋានៈខ្ញុំជាប្រមុខរដ្ឋស្របច្បាប់របស់ប្រទេសកម្ពុជា ជាឋានៈខ្ពស់បំផុតដែលផ្តល់ឱ្យខ្ញុំជាឯកច្ឆន្ទដោយប្រជារាស្ត្រខ្មែរ ខ្ញុំសូមប្រកាសរំលាយជាស្ថាពរនូវរាជរដ្ឋាភិបាលលន់ នល់ និងសភាទាំង២ (រដ្ឋសភា និងក្រុមប្រឹក្សាព្រះរាជាណាចក្រ) ដែលមិនគោរពសម្បថរបស់ខ្លួន និងបំពានរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា ។*

*នៅថ្ងៃទី២៣ ខែមីនានោះដែរ យន្តហោះចម្បាំងរបស់អាមេរិក បានចូលមក*

បាញ់រះ និងទម្លាក់គ្រាប់បែកទៅលើទីតាំងកងទ័ពវៀតកុង-វៀតណាមខាងជើង ដែលស្ថិតនៅក្នុងទឹកដីខ្មែរជាច្រើនកន្លែងទៀត ។

ដើម្បីសហការគ្នាឱ្យបានរលូនក្នុងការបង្កើតចលនាតស៊ូនោះ នាយករដ្ឋមន្ត្រីចិន ជូ អេនឡាយ ក៏មានគម្រោងឱ្យមានជំនួបរវាងសីហនុ និងសាឡុត ស ( ប៉ុលពត) ដែលកំពុងធ្វើទស្សនកិច្ចសម្ងាត់នៅទីក្រុងប៉េកាំង នោះដែរ។ ប៉ុន្តែ គម្រោងជំនួបនេះត្រូវលុបចោលទៅវិញ។ លុះដល់ថ្ងៃទី២៦ ខែមីនា ខៀវ សំផន, ហ៊ូ យន់ និងហ៊ូ នឹមក្នុងនាមជាមេដឹកនាំផ្លូវការនៃចលនាខ្មែរក្រហម ដែលមានមូលដ្ឋានតស៊ូនៅក្នុងប្រទេសកម្ពុជា បានចុះហត្ថលេខារួមគ្នាមួយលើសារលិខិតមួយថ្វាយទៅសម្តេចសីហនុ ដើម្បីគាំទ្រការបង្កើតរណសិរ្សរួបរួមជាតិកម្ពុជា នោះ ។

ថ្ងៃទី២៨ ខែមីនា តាមរលកធាតុអាកាសវិទ្យុក្រុងប៉េកាំង ផ្សាយជាភាសាខ្មែរ សម្តេចសីហនុ ប្រកាសអំពាវនាវឱ្យយុវជន សិស្សនិស្សិត មន្ត្រីរាជការ និងប្រជារាស្ត្រដែលមានស្នាមីកក្តិនឹងព្រះអង្គ រត់ចូលព្រៃម៉ាគី ដើម្បីធ្វើការតស៊ូ ប្រឆាំងនឹងពួកក្បត់ លន់ នល់ និងសិរិមត: ។



អ្នកតស៊ូនៅក្នុងប្រទេស នាំគ្នាស្តាប់ការអំពាវនាវរបស់សម្តេចសីហនុ តាមវិទ្យុក្រុងប៉េកាំង

ថ្ងៃទី២៥ ខែមីនា រដ្ឋាភិបាលក្រុងហាណូយ ប្រកាសជាផ្លូវការគាំទ្រដល់បុព្វហេតុតស៊ូរបស់ប្រជាជនកម្ពុជា ដែលដឹកនាំដោយសម្តេចសីហនុ ដើម្បីការប្រឆាំងបនក្បត់លន់ នល់ និងចក្រពត្តិអាមេរិក ជាមេខ្លោង ។

មួយថ្ងៃក្រោយមក គឺនៅថ្ងៃទី២៦ ខែមីនា រដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្នវៀតណាមខាងត្បូង(វៀតកុង) ក៏បានប្រកាសគាំទ្រដល់បុព្វហេតុតស៊ូរបស់សម្តេចសីហនុ ក្នុងការប្រឆាំងនឹងពួកចក្រពត្តិអាមេរិក និងបរិវារ ព្រមទាំងបានសម្តែងការគាំទ្រដោយឥតលក្ខខណ្ឌចំពោះការអំពាវនាវជាប្រវត្តិសាស្ត្ររបស់សម្តេចសីហនុ ថ្ងៃទី២៣ ខែ មីនា នោះផងដែរ ។

ថ្ងៃទី២៧ ខែមីនា ព្រះអង្គម្ចាស់ សុផានុវង្ស មេដឹកនាំចលនាតស៊ូប៉ាថេតលាវ (លាវកុម្មុយនិស្ត) ក៏បានប្រកាសគាំទ្របុព្វហេតុតស៊ូរបស់សម្តេចសីហនុ ដែរ ។

នៅយប់ថ្ងៃទី២៨ ខែមីនា នៅទីក្រុងប៉េកាំង សម្តេចសីហនុ និងនាយករដ្ឋមន្ត្រីចិន ជូ អេនឡាយ បានជួបពិភាក្សាគ្នាម្តងទៀត ។

ជូ អេនឡាយ ប្រាប់សម្តេចសីហនុ ថា ប្រទេសកូរ៉េខាងជើង គាំទ្រព្រះអង្គហើយ ប្រទេសខ្លះនៅអារ៉ាប់ នឹងគាំទ្រព្រះអង្គ ។ ជាមួយគ្នានោះ ប្រទេសភាគច្រើននៅអាហ្វ្រិក ក៏ដូចគ្នានេះដែរ។ នៅពេលខាងមុខនឹងមានប្រទេសកាន់តែច្រើនឡើងៗ គាំទ្រដល់បុព្វហេតុតស៊ូដ៏ត្រឹមត្រូវរបស់ព្រះអង្គ ។ ប៉ុន្តែសម្តេចសីហនុ បានប្រាប់ទៅនាយករដ្ឋមន្ត្រីចិន វិញថា មានបញ្ហាមួយ ដែលធ្វើឱ្យ ព្រះអង្គមានអារម្មណ៍មិននឹងនរសោះនោះ គឺជា សាន (ឯកអគ្គរដ្ឋទូតខ្មែរប្រចាំក្រុងមូស្គូ) បានទូលព្រះអង្គថាគោលជំហររបស់សហភាពសូវៀតនៅពេលនេះ ស្ថិតនៅក្នុងការប្រយ័ត្នប្រយែងក្នុងការគាំទ្រដល់ការបង្កើតចលនាតស៊ូរបស់ព្រះអង្គនៅឡើយ ហើយបណ្តាប្រទេសសង្គមនិយមមួយចំនួននៅអឺរ៉ុប ក៏កំពុងតែមានគោលជំហរដូចសហភាពសូវៀត ដែរ ។

ជូ អេនឡាយ បញ្ជាក់ប្រាប់ សម្តេចសីហនុ វិញថា សហភាពសូវៀត តែងតែមានជំហរបែបនេះ មិនមែនតែលើបញ្ហាប្រទេសកម្ពុជា ប៉ុណ្ណោះទេ គឺបញ្ហានៅវៀតណាម

ក៏ដូច្នេះដែរ ។ ប៉ុន្តែ នៅពេលដែលភាគីទាំង៣ (កម្ពុជា វៀតណាម លាវ) ចេញសេចក្តីប្រកាសរួមនាពេលខាងមុខនេះ សហភាពសូវៀត ប្រាកដជាទទួលការអាម៉ាស់ និងធ្វើការពិចារណាគោលពីជំហររបស់ខ្លួនឡើងវិញ ជាមិនខាន ។

# ២៧៨
# ប្រជាកសិករសម្លាប់តំណាងរាស្ត្រ២រូប និងប្អូនលន់ នល់ ទាមទារយកសម្ដេចឪមកវិញ



រថក្រោះរបស់ទាហានលន់ នល់ ត្រៀមនៅគល់ស្ពានជ្រោយចង្វា

ក្រោយថ្ងៃរដ្ឋប្រហារភ្លាម លន់ នល់ បានចែកប្រាក់កាសដល់ពួកតំណាងរាស្ត្រ និងបានបង្កើតក្រុមឃោសនាសង្គ្រាមនយោបាយជាច្រើនក្រុម ឱ្យចុះទៅតាមភូមិ ឃុំ និងតាមគ្រឹះស្ថានសិក្សានានា ដើម្បីពន្យល់ប្រជារាស្ត្រ និង សិស្សានុសិស្ស និស្សិតឱ្យបានយល់ពីមូលហេតុនៃការទម្លាក់សម្ដេចសីហនុ ។

ជាមួយគ្នានោះ មន្ត្រីសង្ឃជាព្រះមេគណ និងព្រះអនុគណនៅតាមខេត្តស្រុកនានា ក៏រដ្ឋាភិបាលលន់ នល់ ឱ្យចុះទៅជួយទេសនាពន្យល់ប្រជារាស្ត្រជាពុទ្ធបរិស័ទពីបញ្ហានេះដែរ ។

ពេលនោះ ញៀន ធៀង ចៅហ្វាយខេត្តកំពង់ចាម បានស្នើសុំឲ្យរដ្ឋសភាដែលប្រជារាស្ត្រចោទប្រកាន់ថាជាអ្នកទម្លាក់សម្ដេចសីហនុ ចេញពីអំណាចដោយខុសច្បាប់នោះ ទៅពន្យល់ប្រាប់ប្រជារាស្ត្រនៅទីរួមខេត្តកំពង់ចាម ។

អ៊ិន តាំ ក្នុងនាមប្រធានរដ្ឋសភា ក៏បានសុំឱ្យតំណាងរាស្ត្រនៅខេត្តកំពង់ចាមទាំងអស់ ទៅចូលរួមជួយបំភ្លឺបកស្រាយតាមការស្នើសុំនោះ ។

ថ្ងៃទី២៧ ខែមីនា ញៀន ធៀង ចៅហ្វាយខេត្តកំពង់ចាម ចុះទៅមើលសភាពការណ៍នៅទីប្រជុំជនជីហែ ក្នុងស្រុកកោះសូទិន។ នៅពេលគាត់វិលត្រលប់មកវិញស្រាប់តែមានប្រជារាស្ត្រប្រមាណ៣០០នាក់ នាំគ្នាដង្ហែក្បួនតាមក្រោយរថយន្តរបស់គាត់មកក្រុងកំពង់ចាម ដើម្បីទាមទារឲ្យយកសម្ដេចឪមកវិញ។ ភ្លាមៗនោះរដ្ឋាភិបាលនៅភ្នំពេញ ក៏បានដកញៀន ធៀង ចេញ ហើយដាក់ ចាន់ គឹមអ៊ាង ជាចៅហ្វាយខេត្តកំពង់ចាម ជំនួសវិញ ។

ថ្ងៃទី២៨ ខែមីនា នៅចំការកៅស៊ូជប់ សកម្មភាពបាតុកម្មកាន់តែរីកធំទៅៗ តែចៅហ្វាយខេត្តថ្មី ចាន់ គឹមអ៊ាង ចេះប្រើវិធីយាបថទន់ភ្លន់ ធ្វើឱ្យសកម្មភាពបាតុកម្មស្ងប់ស្ងាត់បានមួយរយៈ ។

រដ្ឋាភិបាលបាននិមន្តព្រះគ្រូប៉ាង ខាត់ ឲ្យចេញទៅជួយទេសនាពន្យល់បាតុករដោយមានអ៊ិន តាំ ប្រធានសភា និងឆន សុខុម រដ្ឋមន្ត្រីក្រសួងអប់រំ ទៅជាមួយ ព្រោះក្នុងចំណោមបាតុករទាំងនោះ មានសិស្សសាលាជាច្រើនផងដែរ ។

ព្រះគ្រូប៉ាង ខាត់, អ៊ិន តាំ និងឆន សុខុម ធ្វើដំណើរចេញពីក្រុងភ្នំពេញ តាមយន្តហោះដាកូតា មួយគ្រឿង ហើយ អ៊ិន តាំ ចាំបានយកកងរក្សាខេត្ត ៦នាក់ទៅជាមួយដើម្បីជួយការពារសន្តិសុខផងដែរ។ ពេលយន្តហោះដាកូតា ចុះចតនៅ ទីលានមួយក្បែរភ្នំប្រុស វរសេនីយ៍ទោដាញ់ ម៉ែន មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងខេត្ត បានជិះរថយន្តហ្ស៊ីបមួយគ្រឿង ជាមួយទាហានមួយក្រុមមកទទួលពួកគាត់ ។

ពេលនោះ ចាន់ គឹមអ៊ាង ជាចៅហ្វាយខេត្ត មិនបានទៅទទួលគាត់ទេ ព្រោះរវល់

ទៅឃាត់ហ្វូងបាតុករនៅម្តុំវត្តជីដុះ។ ពេលទៅដល់សាលាខេត្ត ស្ងាត់ឈឹង ពួកគាត់នាំគ្នាទៅសម្រាកនៅសណ្ឋាគារខេត្ត រង់ចាំចៅហ្វាយខេត្តមកជួប។ មួយសន្ទុះ ក្រោយមក ចៅហ្វាយខេត្តក៏មកដល់ ហើយនិយាយក្អេងក្អាងថា ខ្លួនបានធ្វើឱ្យសភាពការណ៍ស្រួលបួលវិញអស់ហើយ សូមកុំបញ្ចេញពួកទាហានឲ្យទប់ទល់ជាមួយពួកបាតុករឱ្យសោះបើមានបញ្ហាអ្វី ទុកឱ្យគាត់ប្រើថ្វីមាត់គាត់ទៅទប់ទល់ជាមួយបាតុករ បានហើយ ។

ពេលនោះ និយាយគ្នាមិនទាន់ចប់ផង ស្រាប់តែមានឧទ្ធម្ភាគចក្រមួយគ្រឿង ដឹកឧត្តមសេនីយ៍ថោងវ៉ាន់ ហ្វាន់មឿង ពីខេត្តព្រៃវែង មកចុះនៅមុខបន្ទាយទាហានសឹករងខេត្ត ។ ពេលឮសូរសំឡេង ស្រាប់តែមានពួកបាតុករច្រើនរយនាក់នាំគ្នារត់មកឡោមព័ទ្ធឧទ្ធម្ភាគចក្រនោះ ។

ព្រះគ្រូប៉ាង ខាត់ បាននិមន្តទៅគង់លើជណ្តើរឡើងសណ្ឋាគារខេត្ត ក្នុងបំណងមានសង្ឃដីកាពន្យល់ក្រុមបាតុករដែរ តែគ្មានបាតុករណាម្នាក់រវីរវល់នឹងព្រះអង្គទេ ។ សូម្បីតែយាយតាចាស់ៗ មានកាន់អង្កត់អុសនៅដៃ ក៏គិតតែនាំគ្នារត់សម្រុកទៅរកឧទ្ធម្ភាគចក្រ ដែលកំពុងចុះចតនោះដែរ ។

ព្រះគ្រូប៉ាង ខាត់ មានសង្ឃដីកាប្រាប់អ៊ិន តាំ និងឆន សុខុម ថា សភាពការណ៍ដល់ថ្នាក់នេះហើយ អាត្មាមិនដឹងបានធម៌អីយកមកទេសនាទេ ព្រោះពួកគេមិនឈប់ស្តាប់យើងផង ។

ដោយសារហ្វូងបាតុករនាំគ្នាមកឡោមព័ទ្ធឧទ្ធម្ភាគចក្រកាន់តែច្រើននោះ វរសេនីយ៍ទោដាញ់ ម៉ែន ក៏បានដកទាហាន ដែលឱ្យមកការពារព្រះគ្រូប៉ាង ខាត់, អ៊ិន តាំ និងឆន សុខុម ទាំងអស់ យកទៅឲ្យការពារឧទ្ធម្ភាគចក្រវិញ ហើយទុកពួកគាត់ចោលនៅមុខសណ្ឋាគារខេត្ត ។

ពេលនោះ ចាន់ គឹមអ៊ាង ជាចៅហ្វាយខេត្តកំពង់ចាម ធានាថា គាត់អាចធ្វើឲ្យសភាពការណ៍ស្ងប់ស្ងាត់វិញបាន រួចហើយគាត់ក៏ដើរសំដៅទៅរកហ្វូងបាតុករ ដែលកំពុងនាំគ្នាមកឡោមព័ទ្ធឧទ្ធម្ភាគចក្រនោះ។ ចំណែក អ៊ិន តាំ ក៏ប្រញាប់នាំព្រះគ្រូប៉ាង

ខាត់ និងធន សុខុម ធ្វើដំណើរតាមរថយន្ត វិលត្រលប់ទៅឡើងយន្តហោះ ដែលនៅឯភ្នំប្រុស វិញ ។

ពេលធ្វើដំណើរពីមុខការិយាល័យពេទ្យសត្វ (ផ្លូវចុះទៅទន្លេអុំ) ទៅដល់វត្តនគរ ក៏មានបាតុករដាកម្មកររោងចក្រតម្បាញ និងអ្នកភូមិនៅណែនណាន់តាន់តាប់ពេញផ្លូវ។ តែបានកងរក្សាខេត្ត៦នាក់ ដែលគាត់យកទៅឱ្យជួយការពារសន្តិសុខនោះ បើករថយន្តហ្ស៊ីប នាំមុខបើកផ្លូវ ក៏អាចឆ្លងកាត់ហ្វូងបាតុករបាន។ លុះទៅដល់មុខរោងចក្រតម្បាញ បាតុករបានយករថយន្តធំមួយដាក់ទទឹងផ្លូវ ។

ពួកគាត់ត្រូវបើករថយន្តវាងចុះទៅតាមផ្លូវរទេះ ទើបអាចទៅដល់យន្តហោះដាកូតា ដែលកំពុងរង់ចាំនៅទីលានចុះចត ភ្នំប្រុសនោះ ។

អ៊ិន តាំ បានរម្លឹកថា អំឡុងពេលនោះ ពេលប្រពន្ធកូន និងបងប្អូនគាត់កំពុងធ្វើបុណ្យឧទ្ទិសកុសលដល់សពម្តាយគាត់នៅភូមិព្រៃកកក់ (ស្រុកស្ទឹងត្រង់) ជាស្រុកកំណើតរបស់គាត់ ស្រាប់តែមាបពួកបាតុករមួយក្រុមធំ បាននាំគ្នាមកវាយកម្ទេច បំផ្លាញសពម្តាយគាត់ដែលតម្កល់ទុកក្នុងចេតិយនៅជើងភ្នំក្បែរផ្ទះកំណើតគាត់នោះនិងតាមរកសម្លាប់ប្រពន្ធកូនគាត់ទៀតផង ។

តែប្រពន្ធកូនគាត់បានគេចផុតពីហ្វូងបាតុករដោយសារមានបងប្អូននៅ ទីនោះ ជួយបណ្តោះចេញទាន់ពេលវេលា ។

អ៊ិន តាំ បានបញ្ជាក់ថា ម្តាយគាត់ឈ្មោះម៉ុក ម៉ម អាយុ៧០ឆ្នាំ បានធ្វើមរណកាលពីថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៦៧។ តែឪពុកគាត់មិនទាន់ឲ្យបញ្ចុះសពម្តាយគាត់នៅក្នុងដីទេ គឺឱ្យរក្សាទុកសពនៅក្នុងចេតិយសិន រង់ចាំរហូតដល់ពេលឪពុកគាត់ស្លាប់ដែរ ទើបយកទៅបញ្ចុះក្នុងដីជាមួយគ្នាតែម្តង។ ដូច្នេះ សពម្តាយគាត់ត្រូវតម្កល់ទុកក្នុងចេតិយនោះ តាំងពីឆ្នាំ១៩៦៧ មក ។

ក្រោយពីពួកបាតុករវាយកម្ទេចចេតិយនោះមក បងប្អូនគាត់បានទៅប្រមែប្រមូលធាតុម្តាយរបស់គាត់បានបន្តិចបន្តួចយកទៅរក្សាទុក ។

ចំណែកតំណាងរាស្ត្រ២នាក់ គឺ គឹម ផុន និងសុះ សាអ៊ិន ដែលមានស្វាមីភក្តិចំពោះសម្តេចសីហនុ អវត្តមាន មិនបានបោះឆ្នោតទម្លាក់ព្រះអង្គ នៅថ្ងៃទី១៨ ខែមីនានោះ ក៏បានចុះទៅឃោសនាប្រាប់ប្រជារាស្ត្រនៅទីរួមខេត្តកំពង់ចាម ដើម្បីពន្យល់ហេតុផលពីរឿងរដ្ឋសភាបោះឆ្នោតទម្លាក់សម្តេចសីហនុ ដែរ ប៉ុន្តែ ត្រូវក្រុមបាតុករនាំគ្នាចោមរោមជុំជិត បើទោះបីតំណាងរាស្ត្រទាំង២នាក់នេះ ព្យាយាមពន្យល់ហេតុផលយ៉ាងណា ក៏ពួកបាតុករមិនស្តាប់ដែរ ហើយនាំគ្នាចាប់ចង និងកាប់សម្លាប់ដាច់សាកសពតំណាងរាស្ត្រ២នាក់នេះជាច្រើនកំណាត់ ។

បើតាម អ៊ិន តាំ បានឱ្យដឹងថា សុះ សាអ៊ិន ជាអតីតយោក្ប័ត្រ( មន្ត្រីកាន់បញ្ជីស្នាម និងឯកសារផ្សេងៗ) ធ្វើការនៅសាលាស្រុកកំពង់សៀម ជាប់ឆ្នោតជាតំណាងរាស្ត្រនីតិកាលទី៦ ពេលបោះឆ្នោតជំនួសកៅអីចៅសែន កុសល ហៅឈុំ ដែលបានលាឈប់ពីតំណែងតំណាងរាស្ត្រ ក្នុងឆ្នាំ១៩៦៧ ។

ចំណែកគឹម ផុន ជាភ្នាក់ងារក្រសួងប្រៃសណីយ៍នៅខេត្តកំពង់ចាម បានឈរឈ្មោះជាតំណាងរាស្ត្រនៅមណ្ឌលប៉ុស ( ខេត្តកំពង់ចាម) កាលពីថ្ងៃទី១១ ខែកញ្ញា ឆ្នាំ១៩៦៦ ជាមួយបេក្ខជនម្នាក់ទៀត ឈ្មោះសេង ង៉ួនអ៊ូ ប្រជែងជាមួយអ៊ិន តាំ ដែរ តែចាញ់ឆ្នោតអ៊ិន តាំ ទាំង២នាក់។ ប្រហែល៨ខែក្រោយមក សម្តេចសីហនុ បានតែងតាំងអ៊ិន តាំ ឱ្យទៅធ្វើជាចៅហ្វាយខេត្តបាត់ដំបង ។

នៅថ្ងៃទី១ ខែឧសភា ឆ្នាំ១៩៦៧ គឹម ផុន ក៏បានទៅឈរឈ្មោះនៅមណ្ឌលប៉ុស ( ខេត្តកំពង់ចាម) ម្តងទៀត ក៏បានជាប់ឆ្នោតជាតំណាងរាស្ត្រជំនួសអ៊ិន តាំ ចាប់ពីពេលនោះមក ។

នៅថ្ងៃប្រជុំសភា បោះឆ្នោតទម្លាក់សម្តេចសីហនុ នៅថ្ងៃទី១៨ ខែមីនា គឹម ផុន មិនបានចូលប្រជុំទេ ព្រោះគាត់ត្រូវទៅ បំពេញបេសកកម្មទៅខេត្តតាកែវ ។

ក្រោយពីប្រជារាស្ត្រនៅខេត្តកំពង់ចាម នាំបាតុកម្មទាមទារយកសម្តេចសីហនុមកវិញ លន់ នល់ មេដឹកនាំរដ្ឋប្រហារ ក៏បានឱ្យតំណាងរាស្ត្រទាំងអស់នៅខេត្តកំពង់

ចាម ចុះទៅឃោសនាពន្យល់ប្រជារាស្ត្រ ដើម្បីឱ្យយល់ពីហេតុផលពីរឿងរដ្ឋសភាទម្លាក់សម្តេចសីហនុ ។

ពេលនោះ តំណាងរាស្ត្រសុះ សាអ៊ុន និងគឹម ផុន យល់ថា ពួកគាត់ធ្លាប់រស់នៅខេត្តកំពង់ចាម យូរឆ្នាំមកហើយ និងមានប្រជារាស្ត្រភាគច្រើនស្រឡាញ់គាំទ្រ ពិសេសកន្លងមក ពួកគាត់ក៏ជាមន្ត្រីស្មោះស្ម័គ្រប្តូរផ្តាច់ ជាមួយសម្តេចសីហនុ ទៀតផង ក៏នាំគ្នាចុះទៅពន្យល់ប្រជារាស្ត្រនៅទីនោះ ពីមូលហេតុពិតប្រាកដ នៃការទម្លាក់សម្តេចសីហនុ ថ្ងៃទី១៨ ខែមីនា ដោយមិនបានគិតថាជួបហេតុការណ៍សាហាវ ឃោរឃៅដូច្នេះទាល់តែសោះ ។

សុះ សាអ៊ុន និងគឹម ផុន បានធ្វើដំណើរពីក្រុងភ្នំពេញ ក្នុងបំណងសម្រាកនៅទីរួមខេត្តកំពង់ចាម មួយយប់។ ព្រឹកស្អែក ទើបបន្តដំណើរទៅទីប្រជុំជនសួង ដើម្បីឃោសនាប្រាប់ប្រជារាស្ត្រឱ្យបានយល់ហេតុផលពីរឿងរដ្ឋសភាទម្លាក់សម្តេចសីហនុ ។ តែពេលមកដល់ទីរួមខេត្តកំពង់ចាម ក៏ត្រូវពួកបាតុករចាប់បណ្តើរទៅជាមួយ ។

លុះទៅដល់ទន្លេអំ ពួកបាតុករក៏បាននាំគ្នាកាប់សម្លាប់តំណាងរាស្ត្រទាំងពីរនាក់នេះ យ៉ាងសាហាវឃោរឃៅបំផុត ។

នៅកំពង់ចម្លងទន្លេបិទ រដ្ឋាភិបាលបានបញ្ជាប់ លែងឲ្យស្រឡាងឆ្លងទៅមកទៀតបណ្តាលឱ្យបាតុករនៅកកកុញ ណែនណាន់តាន់តាប់នៅត្រើយខាងកើត។ បន្តិចក្រោយមក ស្រាប់តែលេចមុខមេប៉ូលិសស្រុកត្បូងឃ្មុំម្នាក់ ឈ្មោះលន់ និល ដែលពួកបាតុករស្គាល់ច្បាស់ជាប្អូនប្រុសរបស់លន់ នល់។ ដោយសារភ្លើងកំហឹងពុះកញ្ជ្រោល ពួកបាតុករបាននាំគ្នាកាប់សម្លាប់លន់ និល រួចវះយកថ្លើមយកទៅឆាស៊ី ។

នៅថ្ងៃទី២៧ ខែមីនា ពួកបាតុករគាំទ្រសម្តេចសីហនុ មកពីស្រុកចំការលើ និងស្រុកព្រៃឈរ ជាច្រើនរយនាក់ ដោយមានលោកតាធ្វឹម នៅវត្តទេប ជាអ្នកនាំមុខ បាននាំគ្នាចាប់រថយន្តឈ្នួល ជិះដង្ហែក្បួនតាមផ្លូវជាតិលេខ៦អា ឡើងមកទីក្រុងភ្នំពេញយ៉ាងគគ្រឹកគគ្រេង ។



**កំពង់ចម្លងពីក្រុងកំពង់ចាម ទៅទន្លេបិទ**

*ពេលទៅដល់ខាងកើតគល់ស្ពានជ្រោយចង្វា ពួកទាហានលន់ នល់ បានមករាំងដំណើរ និងឱ្យវិលត្រលប់ទៅ ក្រោយវិញដែរ។ ប៉ុន្តែ ក្រុមបាតុករនៅតែសម្រុកឆ្លងស្ពានបន្តដំណើរទៅមុខទៀត។ ពេលនោះពួកទាហានលន់ នល់ ក៏បង្ខំចិត្តដកថយមកនៅពាក់កណ្តាលស្ពានជ្រោយចង្វា ហើយស្រែកបញ្ជាឱ្យពួកបាតុករថយក្រោយវិញ តែពួកបាតុករនៅតែចចេសរឹងរូស ពួកទាហានលន់ នល់ ក៏ចាប់ផ្តើមបាញ់រះទៅលើហ្វូងបាតុករដោយគ្មានត្រាប្រណី បណ្តាលឱ្យស្លាប់ប្រមាណ ៣០នាក់ និងរងរបួសជាច្រើននាក់ទៀត ទើបក្រុមបាតុករបង្ខំចិត្តនាំគ្នារត់ថយក្រោយវិញ ។*

*ក្នុងចំណោមបាតុករទាំងអស់នោះ មានកម្មករចម្ការកៅស៊ូប្រមាណ២០០នាក់ បាននាំគ្នាជិះរថយន្ត១២បាំង ៣គ្រឿង ត្រលប់ទៅក្រោយវិញ ។ ប៉ុន្តែទៅដល់ព្រៃទទឹង និងត្រើង ឃើញពួកទាហានលន់ នល់ ត្រៀមនៅទីនោះទៀត ក៏នាំគ្នាចុះពីលើរថយន្ត រត់រប៉ាត់រប៉ាយបែកខ្ញែកគ្នា យកតែព្រះអាយុសតែរៀងៗខ្លួន ។*

ថ្ងៃទី២៧ ខែមីនានោះដែរ បុគ្គលិកស្ថានទូតវៀតកុង-វៀតណាមខាងជើង ដែលរងការវាយប្រហារកាលពីថ្ងៃទី១១ មីនា បានចាកចេញពីទីក្រុងភ្នំពេញទាំងអស់ហើយ ទំនាក់ទំនងការទូតរវាងប្រទេសកម្ពុជា និងប្រទេសវៀតណាមកុម្មុយនិស្ត ក៏ត្រូវកាត់ផ្ដាច់ត្រឹមនោះដែរ ។

នៅថ្ងៃទី២៨ ខែមីនា ក្រុមបាតុករគាំទ្រសម្ដេចសីហនុ នៅខេត្តកំពត និងខេត្តតាកែវ បានជិះរថយន្តហែក្បួន តាមផ្លូវជាតិលេខ៣ មកដល់ទីប្រជុំជនអង្គតាសោម ក៏នាំគ្នាឡោមព័ទ្ធសាលាស្រុកត្រាំកក់ ក្នុងបំណងវាយកម្ទេចសាលាស្រុកនោះចោល ។

វរសេនីយ៍ទោហ៊ុន នឹម មេបញ្ជាការតំបន់សឹករងខេត្តតាកែវ បានដឹកនាំកម្លាំងទាហានមករារាំង មិនឱ្យបន្តដំណើរទៅទីក្រុងភ្នំពេញ ទៀត។ តែក្រុមបាតុករដែលមានតែកាំបិតពូថៅ និងដំបងនៅដៃ នាំគ្នាសម្រុកទៅមុខទៀត ជាមួយសម្រែកខ្លាំងៗ និងព្រមៗគ្នាថា៖ "ជយោ! សម្ដេចឪ ៗ ៗ" ដោយទឹកចិត្តស្វាមីភក្តិបំផុត ។

ពេលនោះដោយមានអន្តរាគមន៍ពីរថពាសដែកផង ពួកទាហានលន់ នល់ ក៏បានបាញ់រះទៅលើក្រុមបាតុករ បណ្ដាលឱ្យបាតុកររាប់សិបនាក់ បាត់បង់ជីវិត និងរងរបួស ក៏នាំគ្នារត់ខ្ចាត់ខ្ចាយអស់ ។




រថពាសដែកប្រើសម្រាប់បង្ក្រាបបាតុករ និងប្រយុទ្ធជាមួយកងទ័ពវៀតកុង

ចំណែកក្រុមបាតុករមកពីខេត្តព្រៃវែង និងស្វាយរៀង ក៏បានហែក្បួនរថយន្ត តាមផ្លូវជាតិលេខ១ មកដល់ពេជចក្រក្តារបន្ទះដីឥដ្ឋដែរ តែត្រូវពួកទាហានស្ទាក់រង់ចាំ ផ្លូវនៅទីនោះ បាញ់ឱ្យស្លាប់ និងរបួសរត់ខ្ចាត់ខ្ចាយទៅក្រោយអស់វិញ ។

ក្រោយពីសម្តេចសីហនុ ប្រកាសបង្កើតរណសិរ្សរួបរួមជាតិកម្ពុជា និងអំពាវនាវឱ្យប្រជារាស្ត្រខ្មែរ ចូលព្រៃម៉ាគី ធ្វើសង្គ្រាមតស៊ូប្រឆាំងនឹងពួកក្បត់លន់ នល់ មក ខៀវ សំផន ហ៊ូ នឹម និង ហ៊ូ យន់ ដែលមជ្ឈដ្ឋានភាគច្រើនយល់ថា សម្តេចសីហនុ បានឱ្យគេយកទៅសម្លាប់ចោល តាំងពីឆ្នាំ១៩៦៧នោះ បានចេញសេចក្តីប្រកាសតាមវិទ្យុក្រុងប៉េកាំង សម្តែងនូវការគាំទ្រចំពោះការអំពាវនាវរបស់សម្តេចសីហនុ និងបំផុសឱ្យប្រជារាស្ត្រខ្មែរងើបឡើងតស៊ូប្រឆាំងនឹងពួកក្បត់លន់ នល់ សិរិមតៈ ។

តែក្រោយពីបានឮខៀវ សំផន ហ៊ូ នឹម និងហ៊ូ យន់ ប្រកាសគាំទ្រចំពោះការអំពាវនាវរបស់សម្តេចសីហនុ ពួកមេដឹកនាំរដ្ឋប្រហារនៅទីក្រុងភ្នំពេញ បានបដិសេធថា គ្មាន ខៀវ សំផន, ហ៊ូ យន់ និងហ៊ូ នឹម ណានៅរស់ទៀតទេ ព្រោះសម្តេចសីហនុ បានយកពួកនេះទៅសម្លាប់ចោលអស់ តាំងពីឆ្នាំ១៩៦៧ មកម្ល៉េះ ។

ជាមួយគ្នានោះដែរ រដ្ឋាភិបាលលន់ នល់ បានឱ្យគេចាក់ផ្សាយនូវបទសម្ភាសរបស់ខៀវ សេងគីម ជាប្អូនប្រុសរបស់ខៀវ សំផន ដែលបានចេញមុខអះអាងថា ខៀវ សំផន ជាបងប្រុសគាត់ត្រូវសម្តេចសីហនុ ឱ្យគេយកទៅសម្លាប់ចោលនៅឯខេត្តកំពង់ស្ពឺ តាំងពី៣ឆ្នាំមុននោះទៀតផង ។

ក្រោយរដ្ឋប្រហារ ថ្ងៃ១៨ ខែមីនា តែ២ ថ្ងៃប៉ុណ្ណោះ ដោយមានទីប្រឹក្សាយោធាអាមេរិក ជាអ្នករៀបចំប្រតិបត្តិការសឹក ផងដែរកងទ័ពរដ្ឋការវៀតណាមខាងត្បូង (កងទ័ពធីវគី) ក៏បានចាប់ផ្តើមចូលមកក្នុងទឹកដីខ្មែរ ដើម្បីបើកការវាយប្រហារជាទ្រង់ទ្រាយធំទៅលើកងទ័ពវៀតកុង-វៀតណាមខាងជើង ។

កងទ័ពរដ្ឋការវៀតណាមខាងត្បូង បានបើកការវាយប្រហារកងទ័ពវៀតកុង-វៀតណាមខាងជើង នៅក្នុងខេត្តស្វាយរៀង ។ ចំណែកនៅខេត្តកណ្តាល យន្តហោះ

ចម្បាំងរបស់កងទ័ពរដ្ឋការវៀតណាមខាងត្បូង បានហោះមកទម្លាក់គ្រាប់បែកទៅលើទីតាំងកងទ័ពវៀតកុង - វៀតណាមខាងជើង នៅតាមបណ្តោយព្រំដែនដែរ ។ តែកងទ័ពវៀតកុង-វៀតណាមខាងជើង មួយកងអនុសេនាធំ ក៏បានបើកការវាយប្រហារទៅលើបន្ទាយទាហានលន់ នល់ នៅក្បែរព្រំដែននោះ ហើយមេទាហានខ្មែរនៅបន្ទាយនោះ ក៏បានសុំជំនួយតាមវិទ្យុទាក់ទងទៅកងទ័ពរដ្ឋការវៀតណាមខាងត្បូង ឱ្យជួយធ្វើអន្តរាគមន៍ ។

បន្តិចក្រោយមក កងកាំភ្លើងធំរបស់កងទ័ពរដ្ឋការវៀតណាមខាងត្បូង ក៏ចាប់ផ្តើមបាញ់ផ្លោងមកលើកងទ័ពវៀតកុង-វៀតណាមខាងជើង ឱ្យបង្ខំចិត្តដកថយវិញអស់។ ប៉ុន្តែ មិនយូរប៉ុន្មានកងទ័ពវៀតកុង-វៀតណាមខាងជើង ក៏បានសាកល្បងវាយប្រហារមកលើប៉ុស្តិ៍ទាហានខ្មែរ ដែលនៅក្នុងខេត្តកណ្តាលនោះជាថ្មីម្តងទៀត ដោយប្រើកម្លាំងច្រើនជាងមុន ។

មេទាហានលន់ នល់នៅទីនោះ ក៏សុំជំនួយតាមវិទ្យុទាក់ទងជាថ្មីម្តងទៀតឱ្យយន្តហោះចម្បាំងអាមេរិក មកទម្លាក់គ្រាប់បែកទើបពួកវៀតកុង-វៀតណាមខាងជើងដកថយវិញអស់ ។

នៅថ្ងៃទី២៧ ខែមីនា កងទ័ពរដ្ឋការវៀតណាមខាងត្បូង មួយកងវរសេនាតូចដោយមានការគាំទ្រពី កងឧទ្ធម្ភាគចក្រអាមេរិក ផង បានបើកការវាយប្រហារទៅលើកងទ័ពវៀតកុង-វៀតណាមខាងជើង ដែលនៅក្នុងទឹកដីខ្មែរចម្ងាយជាង៣គីឡូម៉ែត្រ និងបានសម្លាប់ខ្មាំងសត្រូវរបស់គេ៥៣នាក់ ។

មួយថ្ងៃក្រោយមកទៀត ទីប្រឹក្សាយោធាអាមេរិក វរសេនីយ៍ អ៊ីណេស ធើរ៉ែល ( Eanest Terrell ) បានជួបពិភាក្សាគ្នាជាមួយមេទាហានលន់ នល់ នៅក្បែរតំបន់ព្រំដែនពីបញ្ហាបើកប្រតិបត្តិការសឹករួមគ្នាមួយ។ ប៉ុន្តែ កងទ័ពវៀតកុង-វៀតណាមខាងជើងបានបង្កើនការវាយប្រហារព្រមៗគ្នាទៅលើពួកទាហានលន់ នល់ នៅទូទាំងប្រទេសពិសេសគឺនៅក្នុងបណ្តាខេត្តទាំងឡាយនៅប៉ែកខាងត្បូង និងខាងកើតប្រទេស ។

នៅខេត្តព្រៃវែង កងទ័ពវៀតកុង-វៀតណាមខាងជើង បានឆ្លងពីក្នុងទឹកដីប្រទេសវៀតណាមខាងត្បូង ចូលមកស្រុកកំពង់ត្របែក និងស្រុកព្រះស្ដេច វាយយកទីតាំងទាហានលន់ នល់ ផង និងសហការគ្នាជាមួយពួកខ្មែរក្រហម បង្កើតកងទ័ពតស៊ូផង ។

តាមការអំពាវនាវរបស់សម្ដេចសីហនុ តាមវិទ្យុនៅប៉េកាំង មានអ្នកស្ម័គ្រចិត្តចំនួន៧០០នាក់ បាននាំគ្នារត់ចូលព្រៃម៉ាគី ដែលមានមូលដ្ឋានតស៊ូនៅក្នុងឃុំពាមមន្ទារ ស្រុកកំពង់ត្របែក បង្កើតបានជាកងទ័ពមួយវរសេនាតូច ដោយមានកងទ័ពវៀតកុង-វៀតណាមខាងជើង ជាអ្នកជួយបង្ហាត់បង្រៀនក្បួនយុទ្ធសាស្ត្រ ។

នៅតាមបណ្ដាខេត្តផ្សេងៗទៀត ក៏មានយុវជនជាច្រើនបាននាំគ្នារត់ចូលព្រៃម៉ាគី ចូលរួមជាមួយកងទ័ពវៀតកុង-វៀតណាមខាងជើង ប្រយុទ្ធតស៊ូ ដើម្បីយកសម្ដេចសីហនុ មកកាន់អំណាចវិញដែរ ។

---

# ២៧៩
# អង្គការសហប្រជាជាតិ ទទួលស្គាល់រដ្ឋាភិបាល លន់ នល់



លន់ នល់ និងហាង់រី គីស្ស៊ីងហ្គ័រ

នៅពាក់កណ្តាលឆ្នាំ១៩៦៩ សាឡុត ស អគ្គលេខាធិការបក្សកុម្មុយនិស្តកម្ពុជា បានធ្វើដំណើរចេញពីប្រទេស ទៅកាន់ទីក្រុងហាណូយ។ នៅក្នុងខែសីហា ឆ្នាំ១៩៦៩មុនពេលចេញដំណើរពីក្រុងហាណូយ ទៅក្រុងប៉េកាំង សាឡុត ស បានចាត់តាំងកែវ មាស ជាសមាជិកគណៈកម្មាធិការមជ្ឈិមបក្ស និងជាជំនួយការរបស់សឺង ង៉ុកមិញ ដែលកំពុងរស់នៅក្នុងក្រុងហាណូយ នោះផងដែរ ។

សឺង ង៉ុកមិញ ជាអតីតអគ្គលេខាបក្សប្រជាជនបដិវត្តន៍ខ្មែរ ដែលបង្កើតឡើងកាលពីថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៥១។ ចំណែក កែវ មាស ជាមេដឹកនាំគណបក្សប្រជាជនជាចលនាតស៊ូចំហរបស់ពួកកុម្មុយនិស្តកម្ពុជា ពីឆ្នាំ១៩៥៥ មក ។

ប៉ុន្តែ ការស្នាក់នៅរបស់សាឡុត ស នៅទីក្រុងប៉េកាំង ពីចុងឆ្នាំ១៩៦៩ រហូតដល់មានព្រឹត្តិការណ៍រដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០នោះ ជារឿងលាក់ការណ៍

សម្ងាត់ មិនឱ្យដឹងជាសាធារណៈឡើយ ។

ក្រោយពីបានឡើងកាន់អំណាច ឆ្នាំ១៩៧៥ សាឡុត ស បានសរសេរនៅក្នុងសៀវភៅខ្មៅថា នៅថ្ងៃទី២១ ខែមីនា ឆ្នាំ១៩៧០ គាត់បានស្នើសុំឱ្យនាយករដ្ឋមន្ត្រីចិន ជូ អេនឡាយ ជួយបញ្ចុះបញ្ចូលសម្តេចសីហនុ ឱ្យរួបរួមគ្នាបង្កើតរណសិរ្សមួយ ដើម្បីប្រយុទ្ធតស៊ូប្រឆាំងនឹងបនក្បត់លន់ នល់, សិរិមតៈ និងសូមឱ្យសម្តេចសីហនុ ប្រកាន់យកជំហរវាយលុក ដោយមិនធ្វើការចរចាអ្វីទាំងអស់ជាមួយជនក្បត់លន់ នល់ សិរិមតៈ ។

ពេលនោះ ផាំ វ៉ាន់ដុង នាយករដ្ឋមន្ត្រីវៀតណាមខាងជើង ក៏បានចេញដំណើរពីក្រុងហាណូយ ទៅកាន់ទីក្រុងប៉េកាំង ដើម្បីជួបពិភាក្សាជាមួយសម្តេចសីហនុ និងនាយករដ្ឋមន្ត្រីចិន ជូ អេនឡាយ ពីរឿងបង្កើតរណសិរ្សនេះដែរ ។

សាឡុត ស បានអះអាងទៀតថា គាត់បានពិនិត្យលើឯកសារពង្រាងកម្មវិធីនយោបាយរណសិរ្សរួបរួមជាតិកម្ពុជា របស់សម្តេចសីហនុ ដើម្បីប្រឆាំងនឹងបនក្បត់លន់ នល់ សិរិមតៈនោះដែរ ហើយគាត់បានទាំងលុបពាក្យថា កសាងសង្គមនិយម និងកុម្មុយនិស្តនិយមនៅលើពង្រាងឯកសារនោះទៀតផង ព្រោះគាត់យល់ថា ការប្រើពាក្យទាំងពីរនោះ វាហាក់ដូចជានិយាយត្រង់ៗពេកពីរឿងតស៊ូធ្វើសង្គ្រាមដើម្បីឱ្យប្រទេសក្លាយជាកុម្មុយនិស្ត ។ ចំណែក សម្តេចសីហនុ វិញ មិនដឹងថា គាត់ជាអ្នកចូលរួមគំនិតបង្កើតរណសិរ្សរួបរួមជាតិកម្ពុជា នោះទេ ។

ថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៧០ កងទ័ពវៀតកុង-វៀតណាមខាងជើង ប្រមាណ៥កងពលតូច បានចាប់ផ្តើមវាយសម្រុកទៅលើទីតាំងបន្ទាយទាហានលន់ នល់ និងទីរួមខេត្ត ទីរួមស្រុក ដែលនៅតំបន់ឆ្ងាយៗ ។

កងទ័ពវៀតកុង- វៀតណាម ខាងជើងទាំងអស់នោះ សុទ្ធតែមានពាក់ព្រះឆាយាលក្ខណ៍សម្តេចសីហនុ និងបានឃោសនាប្រាប់ប្រជាជនខ្មែរថា ពួកគេនឹងវាយដណ្តើមយកអំណាចប្រគល់ឱ្យសម្តេចសីហនុ វិញ តែក្នុងរយៈពេល៤៨ម៉ោងប៉ុណ្ណោះ ។

ពេលនោះ ទាហានរដ្ឋាភិបាលលន់ នល់ សរុបនៅទូទាំងប្រទេស មានប្រមាណ

៣ម៉ឺននាក់ប៉ុណ្ណោះ ហើយមិនមានអាវុធទំនើបៗផងនោះ បានដកថយ និងបោះបង់ចោលទីតាំងរបស់ខ្លួនជាបន្តបន្ទាប់ ។

រយៈពេលតែប៉ុន្មានថ្ងៃប៉ុណ្ណោះ កងទ័ពវៀតកុង-វៀតណាមខាងជើង វាយដណ្ដើមបានខេត្តរតនគិរី, ខេត្តមណ្ឌលគិរី, ខេត្តស្ទឹងត្រែង និងខេត្តក្រចេះ ទាំងស្រុង ។ នៅទីក្រុងភ្នំពេញ ពួកសិស្សវិទ្យាល័យនានា និងយុវជនផ្សេងៗទៀតជាច្រើនបានស្ម័គ្រចិត្តចូលបម្រើក្នុងជួរទាហានរដ្ឋាភិបាល ដើម្បីចេញទៅទប់ទល់ជាមួយពួកវៀតកុង-វៀតណាមខាងជើង ដែលពួកគេចាត់ទុកថា ជាសត្រូវសួពូជនោះបាននាំគ្នាដោះសម្លៀកបំពាក់សិស្សចេញ ហើយស្លៀកពាក់ឯកសណ្ឋានកងទ័ព និងបំពាក់អាវុធភ្លាមៗនៅក្នុងបរិវេណបុរីកីឡា រួចហើយឡើងរថយន្តចេញទៅសមរភូមិតែម្ដង ដោយមិនបានហ្វឹកហ្វឺនក្បួនយុទ្ធសាស្ត្រអ្វីបន្តិចឡើយ ។

ជាមួយគ្នានោះ រដ្ឋាភិបាលលន់ នល់ បានធ្វើការឃោសនាថា សម្ដេចសីហនុ ជាអ្នកលក់ទឹកដីឱ្យយួនវៀតកុង, សម្ដេចសីហនុ មិនខុសពីស្ដេចជ័យជេដ្ឋាទី២ ដែលយកប្រពន្ធយួន ហើយកាត់ទឹកដីទៅឱ្យយួន និងឃោសនាពីប្រវត្តិដាំតែអុង កាលយួន ជីកព្រែកវិញតេ ឆ្នាំ១៨១៩ ដើម្បីបំផុសកំហឹងឈឺចាប់ជាមួយវៀតណាម និងលែងឱ្យប្រជាពលរដ្ឋខ្មែរឈប់ជឿជាក់លើសម្ដេចសីហនុ ទៀត។ មិនតែប៉ុណ្ណោះ សូម្បីតែនៅក្នុងសិល្បៈចម្រៀង ក៏ពួកគេបាន តែងបទថ្មីមកច្រៀង ដើម្បីឃោសនារឿងស្ដេចលក់ដីឱ្យវៀតកុងដែរ ។

ស៊ីន ស៊ីសាមុត អ្នកចម្រៀងសំឡេង មាស បានច្រៀងបទមួយ ដើម្បីជួយបំផុសយុវជនឱ្យចូលបម្រើក្នុងជួរកងទ័ព មានចំណងជើងថា៖“លាម៉ែ ចេញច្បាំង មានខ្លឹមសារទាំងស្រុងថា ៖

ម៉ែឱ្យអាវយ័ន្តកូនពាក់បន់ព្រះ ដែលមានតេជៈនៅក្នុងភពត្រើយ ព្រះគ្រូជាសង្ឃប្រទានពរជ័យ ស្អែកលាម្ដាយថ្លៃ ចេញធ្វើទាហាន ។

ពូជខ្មែរឈាមខ្មែរ ឈាមម៉ែចែកឱ្យ ឈាមច្បាំងពុំថយ ឈាមជាតិក្លាហាន បើ

ខ្មាំងមានះ កូនស៊ូប្តូរប្រាណ ពិតពុំវិលថ្កាន បកក្រោយឡើយណា។ ពេលល្ងាចរៃយំ ក្នុំពពាលខែ ស្រណោះដីខ្មែរ កេរពីដូនតា ស្តេចលក់ឱ្យយៀកកុង ក្បត់ជាតិសាសនា កូនសូមប្តេជ្ញា ធ្វើសឹកទាញជ័យ ។

ជាមួយគ្នានេះ ស៊ីន ស៊ីសាមុត ក៏បានច្រៀងបទមួយទៀត ដែលរម្លឹកគំនុំឈឺចាប់ពីជំនាន់វៀតមិញ ថា៖" ជំនាន់វៀតមិញវាទិញវាចាប់ វាបានសម្លាប់ ឪពុកម្តាយខ្ញុំ ខ្ញុំរស់កំព្រា ជីវិតទូលក្នុំ ខ្ញុំចងគំនុំ ជាងម្ភៃឆ្នាំហើយ ។

ពេលយល់ភូមិឋាន លំអានពុកម៉ែ ស្រណោះខ្ទមស្រែ ម៉ែឱ្យភ្ញៅកើយ ឥឡូវផ្នូរលោក នៅខ្ពស់នៅឡើយ អ្នកមានគុណអើយ កូនសូមសងឈាម..." ។

ក្រោយថ្ងៃទី១៨ មីនា ១៩៧០ ស៊ីន ស៊ីសាមុត បានចូលជាតារាចម្រៀងនៅក្នុងវង់តន្ត្រីនៃការិយាល័យទី៥ របស់ក្រសួងការពារជាតិ និងទទួលបានឋានន្តរស័ក្តិជាអនុសេនីយ៍ទោ( សក្តិ២) ហើយប៉ុន្មានឆ្នាំក្រោយមកទៀត គាត់បានឡើងឋានន្តរស័ក្តិជាអនុសេនីយ៍ឯក( ស័ក្តិ៣) ។

នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧០ នៅក្នុងបរិវេណផ្ទះឧត្តមសេនីយ៍ឯកលន់ នល់ មានបើកសន្និសីទកាសែតមួយ ដោយមានអ្នកកាសែតជាតិ និងអន្តរជាតិជាច្រើនចូលរួម ។ នៅពេលនោះ លន់ នល់ នាយករដ្ឋមន្ត្រី, ទ្រង់សិរិមត: ឧបនាយករដ្ឋមន្ត្រីទី១, អ៊ិន តាំ ប្រធានរដ្ឋសភា និងយ៉ែម សំបូរ ឧបនាយករដ្ឋមន្ត្រីទី២ និងជារដ្ឋមន្ត្រីក្រសួង ការបរទេស បានចំណាយពេលជាងមួយម៉ោង ដើម្បីឆ្លើយនឹងសំណួររបស់ក្រុមអ្នកកាសែត ។

លន់ នល់ បានថ្លែងថា ប្រសិនស្ថានការណ៍នៅកម្ពុជា កាន់តែធ្ងាក់ដុនដាបទៅៗ នោះ យើងនឹងសុំជំនួយប្រទេសជាមិត្ត ហើយយើងនឹងទិញអាវុធផងដែរ ប្រសិនបើមានលទ្ធភាព ។

អ្នកកាសែតសួរគាត់ថា ក្រែងរដ្ឋាភិបាលលោកឧត្តមសេនីយ៍ ទទួលបានអាវុធពីបណ្តាប្រទេសប្រឆាំងនឹងពួកកុម្មុយនិស្ត ដូចជា សហរដ្ឋអាមេរិក, វៀតណាមខាងត្បូង និងសៀម រួចហើយទេតើ?

លន់ នល់ ឆ្លើយថា យើងនឹងទទួលជំនួយពីគ្រប់បណ្ដាប្រទេសជាមិត្តទាំងអស់ ។ ប៉ុន្តែ ពេលនេះ ស្ថានការណ៍នៅកម្ពុជា ពុំមានអ្វីធ្ងន់ធ្ងរ រហូតដល់ធ្វើការអំពាវនាវរកអាវុធពីបរទេសទេ ហើយយើងក៏មិនត្រូវការកងទ័ពបរទេសឱ្យមកជួយវាយកម្ចាត់ពួកកុម្មុយនិស្តនៅប្រទេសយើងដែរ ។

លន់ នល់ ក៏បានបង្ហើបឱ្យដឹងពីការផ្សារទំនាក់ទំនងការទូតជាមួយប្រទេសវៀតណាមខាងត្បូង និងថៃ ដែរ តែគាត់បានបញ្ជាក់ថា ពេលនេះមិនទាន់ទេ គឺត្រូវទុកពេលមើលស្ថានការណ៍បន្តិចបន្តិចទៀតសិន ។

នៅពេលនោះដែរ អ្នកនាំពាក្យក្រសួងការបរទេសសហរដ្ឋអាមេរិក ក៏បានថ្លែងប្រាប់ក្រុមអ្នកកាសែត នៅក្រុងវ៉ាស៊ីនតោន ថា រដ្ឋាភិបាលកម្ពុជា ពុំបានស្នើសុំ ឬពន្យល់ពាក្យអ្វីបន្តិចពីរឿងសុំជំនួយយោធាពីសហរដ្ឋអាមេរិក ទេ ។

ថ្ងៃទី៣១ ខែមីនា ឆ្នាំ១៩៧០ រដ្ឋាភិបាលលន់ នល់ បានផ្ញើកំណត់ការទូតមួយទៅស្ថានទូតសហភាពសូវៀត និង អង់គ្លេស ព្រមទាំងលិខិតតវ៉ាមួយទៀត ទៅក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ដើម្បីប្រឆាំងតវ៉ាចំពោះកងទ័ព វៀតកុង-វៀតណាមខាងជើង ដែលបានបើកការវាយប្រហារមកលើទាហានរបស់ខ្លួន ដោយចេញមុខជាចំហតែម្ដង ។

អ្នកការទូតបរទេសមួយចំនួនយល់ថា កងទ័ពវៀតណាមកុម្មុយនិស្តដែលបោះទីតាំងនៅលើទឹកដីកម្ពុជា បើកការវាយប្រហារនេះ ក៏ដោយសារពួកគេភ័យខ្លាចកងទ័ពអាមេរិក និងកងទ័ពវៀតណាមខាងត្បូង ព្រមទាំងទាហានរដ្ឋាភិបាលលន់ នល់ រួមសហការគ្នាវាយប្រហារទៅលើទីតាំងឈរជើងរបស់ពួកគេ ដូច្នេះ ពួកគេត្រូវតែបើកការវាយប្រហារឱ្យបានមុន ដើម្បីរកខ្យល់ដកដង្ហើម ។

ចំណែករដ្ឋាភិបាលក្រុងហាណូយ បានប្រកាសច្រានចោលការចោទប្រកាន់របស់រដ្ឋាភិបាលលន់ នល់ ដែលថា កងទ័ពវៀតកុង-វៀតណាមខាងជើង បានបើកការវាយប្រហារមកលើទាហានរបស់ខ្លួននោះ គឺជាការមិនពិតទេ។ រដ្ឋាភិបាលក្រុង

ហាណូយ បញ្ជាក់ថា ការវាយប្រហារនោះ មានតែកងទ័ពដែលគាំទ្រស្រឡាញ់ស្មោះស្ម័គ្រ នឹងសីហនុ តែប៉ុណ្ណោះ ។

បើទោះបីឧត្តមសេនីយ៍លន់ នល់ បានប្រកាសជាញឹកញាប់ថា ទាហានគាត់ នឹងវាយកម្ទេចសត្រូវឱ្យវិនាសសាបសូន្យក្នុងពេលដ៏ខ្លីខាងមុខក៏ដោយ ក៏ទាហានគាត់នៅទូទាំងប្រទេសត្រូវបាក់ទ័ពបង្វិចិត្តរត់ចោលទីតាំងរបស់ខ្លួនជាបន្តបន្ទាប់ ។

នៅថ្ងៃទី០១ ខែមេសា ឆ្នាំ១៩៧០ កាសែតបរទេសមួយបានចុះផ្សាយថា រដ្ឋាភិបាលលន់ នល់ ចេញសេចក្តីប្រកាសទាត់ចោលកិច្ចព្រមព្រៀងស្តីពីសិទ្ធិក្នុងការដេញតាមកម្ទេចកងទ័ពវៀតកុង-វៀតណាមខាងជើង ដែលសម្តេចសីហនុ បានធ្វើឡើងយ៉ាងសម្ងាត់បំផុតជាមួយមន្ត្រីទូតអាមេរិក តាំងពីខែមេសា ឆ្នាំ ១៩៦៨ មកនោះ ។

សេចក្តីប្រកាសនេះ បានចាក់ផ្សាយតាមវិទ្យុភ្នំពេញ ថា កម្ពុជាប្រឆាំងដាច់ខាតចំពោះការរំលោភព្រំដែនពីសំណាក់កងទ័ពបរទេសទាំងអស់ ទោះបីកងទ័ពប្រទេសណាក៏ដោយ ។

ដើម្បីបង្ហាញឱ្យសាធារណមតិជាតិ និងអន្តរជាតិឃើញថា ខ្លួនជាអ្នកប្រជាធិបតេយ្យ និងគោរពសិទ្ធិមនុស្ស ថ្ងៃទី០២ ខែមេសា ឆ្នាំ១៩៧០ នៅមុខអគាររដ្ឋសភា រដ្ឋាភិបាល លន់ នល់ បានប្រកាសដោះលែងអ្នកទោសនយោបាយចំនួន ៤៨៦នាក់ ក្នុងនោះភាគច្រើនលើសលប់ គឺជាពួកខ្មែរក្រហម ក្នុងនោះមាន កាំង ហ្កេចអ៊ាវ ហៅឌុច និងនង់ សួន អតីតមេដឹកនាំគណបក្សប្រជាជន ដែលត្រូវតុលាការសឹកកាត់ទោសប្រហារជីវិតក្នុងខែឧសភា ឆ្នាំ១៩៦២ តែក្រោយមកត្រូវសម្តេចសីហនុ បន្ធូរបន្ថយទោសឱ្យមកនៅត្រឹម ជាប់គុកអស់មួយជីវិតវិញ ។

ចំណែក សាឡុត ឆាយ ( បង ប្រុសសាឡុត ស) មិនមែនជាពួកខ្មែរក្រហម តែជាអ្នកនិពន្ធអត្ថបទនយោបាយឱ្យកាសែតមួយចំនួន ក៏ត្រូវបានដោះលែងនៅពេលនោះដែរ ។ ក្រោយពីបានរួចទោស សាឡុត ឆាយ មិនបានរត់ចូលព្រៃទៅតស៊ូជាមួយពួកខ្មែរក្រហម ដូចកាំង ហ្កិចអ៊ាវ ហៅឌុច និងនង់ សួន ទេ គឺគាត់បានបន្តអាជីពជាអ្នកកាសែតបន្តទៀត

និងបានក្លាយជានិពន្ធនាយករបស់កាសែតប្រយោជន៍ខ្មែរ ( កាសែតរបស់រដ្ឋ) នៅក្នុងរបបសាធារណរដ្ឋខ្មែរ ។

ថ្ងៃទី០៤ ខែមេសា ឆ្នាំ១៩៧០ កាសែត អ៊ីខូណូមីក ( Economic ) បានចុះផ្សាយថា សង្គ្រាមនៅកម្ពុជា បានចាប់ផ្តើមហើយ ។ ជនរងគ្រោះដំបូងគេ នៅក្នុងសង្គ្រាមបង្ហូរឈាមនេះ គឺពួកអ្នកបះបោរជាង១០០នាក់ ដែលត្រូវកងទ័ពរដ្ឋាភិបាលបាញ់សម្លាប់នៅតាមផ្លូវទៅស្នួល( ខេត្តក្រចេះ ) នឹងនៅខេត្តកំពង់ចាម និងតំណាងរាស្ត្រ២នាក់ ត្រូវអ្នកបះបោរព័ទ្ធចាប់ និងនាំគ្នាកាប់ចិញ្ច្រាំ។ ពួកអ្នកបះបោរ ដែលមានពាក់ព្រះឆាយាលក្ខណ៍សម្តេចសីហនុ បានស្រែកទាមទារឱ្យយកសម្តេចឪ របស់ពួកគេមកវិញ។ ប៉ុន្តែសម្តេចសីហនុ ពុំមែនជាមេដឹកនាំពួកគេពិតប្រាកដទេ ។

កាសែតដដែលបានបន្តថា ខ្មែរកំពុងតែបង្ហូរឈាមខ្មែរគ្នាឯង ប៉ុន្តែគេមានការលំបាកក្នុងការសន្មតថា នេះជាសង្គ្រាមស៊ីវិល ព្រោះសកម្មភាពបះបោរភាគច្រើន គឺពួកវៀតកុង ជាអ្នកចាត់ចែង និងដឹកនាំ ហើយពួកនេះភាគច្រើនជាសមាសភាព ចេញពីសហគមន៍អាណិកជនវៀតណាម នៅក្នុងប្រទេសកម្ពុជា ។

ពួកវៀតកុង ជាអ្នកផ្តល់ខ្សែអាត់សំឡេងអំពាវនាវរបស់សម្តេចសីហនុ ទៅឱ្យពួកអ្នកបះបោរ ។ ជាការពិតហើយ ដែលថាប្រជាកសិករខ្មែរនៅតែស្មោះត្រង់ជាមួយសម្តេចសីហនុ ។ ប៉ុន្តែ ពួកវៀតណាមកុម្មុយនិស្ត ក៏កំពុងតែលេងល្បែងបោកប្រាស់មួយ។ ប្រជាកសិករស្មោះត្រង់នឹងសម្តេចសីហនុ ទាំងអស់នោះសង្ឃឹមថា ពួកវៀតណាមកុម្មុយនិស្ត នឹងជួយវាយផ្តួលរម្លំរដ្ឋាភិបាលភ្នំពេញ ដើម្បីយកអំណាចមកថ្វាយសម្តេចសីហនុ វិញ ។ តែអ្វីៗដែលកើតមានឡើងរយៈ ពេលពី២សប្តាហ៍កន្លងមកនេះ អាចចាត់ទុកថា គ្រាន់តែជាការចាប់ផ្តើមសាកល្បងប៉ុណ្ណោះ ។

ឥឡូវបញ្ហាសំខាន់ សួរថា តើពួកវៀតណាមកុម្មុយនិស្ត គ្រាន់តែជាអ្នកបង្កឱ្យមានចលនាបះបោរនៅតាមបណ្តាខេត្តនានា ឬក៏ត្រូវប្រើកម្លាំងកងទ័ពពួកគេវាយតម្រង់ទៅរកទីក្រុងភ្នំពេញ តែម្តង? ។

កាសែតដដែល សរសេរបន្តទៀតថា នេះគ្រាន់តែជាការភ្ញាក់រសជាតិជាលើកដំបូង របស់ពួកអ្នកដណ្តើមអំណាចពីសម្តេចសីហនុ ប៉ុណ្ណោះ ។ ឧត្តមសេនីយ៍លន់ នល់ និងទ្រង់ សិរិមតៈ បានសន្យាថា ពួកគាត់នឹងវាយកម្ចាត់ពួកវៀតណាមកុម្មុយនិស្ត ឱ្យចេញអស់ពីកម្ពុជា។ តែពួកវៀតណាមកុម្មុយនិស្ត ក៏បានតាំងចិត្តរួចហើយដែរថា កងទ័ពរបស់ពួកគេនឹងស្ថិតនៅលើទឹកដីកម្ពុជា រហូតដល់ចប់សង្គ្រាមនៅវៀតណាមខាងត្បូង ហើយពេលណាសម្តេចសីហនុ សម្រេចចិត្តឱ្យពួកគេវាយផ្តួលរម្លំពួកមេដឹកនាំរដ្ឋប្រហារជាអាយ៉ងអាមេរិក នៅភ្នំពេញ ពេលនោះទីតាំងកងទ័ពរបស់ពួកគេនៅលើទឹកដីកម្ពុជា ក៏មិនមានបញ្ហាអ្វីទៀតដែរ ។

នៅថ្ងៃទី០៦ ខែមេសា ឆ្នាំ១៩៧០ នៅក្នុងបទសម្ភាសជាមួយអ្នកឆ្លងឆ្លើយកាសែតអាមេរិក ឧត្តមសេនីយ៍លន់ នល់ ក្នុងនាមនាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាលកម្ពុជា បានថ្លែងថា យើងនឹងទទួលជំនួយជាគ្រឿងអាវុធក្នុងករណីចាំបាច់ ដើម្បីការពារប្រទេសតាមកិច្ចព្រមព្រៀងក្រុងហ្សឺណែវ ឆ្នាំ១៩៥៤ ។ ប៉ុន្តែ យើងមិនត្រូវការកងទ័ពពីប្រទេសផ្សេងទេ ពីព្រោះយើងមានធនធានមនុស្សគ្រប់គ្រាន់សម្រាប់ការពារប្រទេសរបស់យើង ។

ទាក់ទងដល់បញ្ហាទំនាក់ទំនងការទូតជាមួយសហរដ្ឋអាមេរិក លន់ នល់ បានបញ្ជាក់ថា ទំនាក់ទំនងការទូតរវាងកម្ពុជា និងសហរដ្ឋអាមេរិក ជាទំនាក់ទំនងមិត្តភាពប៉ុណ្ណោះ ហើយរដ្ឋាភិបាលកម្ពុជា កំពុងត្រៀមខ្លួនភ្ជាប់ទំនាក់ទំនងថ្នាក់ឯកអគ្គរដ្ឋទូតជាមួយសហរដ្ឋអាមេរិក ឡើងវិញ ។

នៅថ្ងៃដដែលនោះ ទ្រង់សិរិមតៈ ក៏បានជួបសន្ទនាដាច់ដោយឡែកជាមួយឯកអគ្គរដ្ឋទូតសហភាពសូវៀត, អង់គ្លេស និងបារាំង ប្រចាំប្រទេសកម្ពុជា ដើម្បីបញ្ជាក់ពីសភាពការណ៍នយោបាយនៅកម្ពុជា ផងដែរ ។

ចំណែកអ្នកនាំពាក្យក្រសួងការបរទេសសហរដ្ឋអាមេរិក ក៏បានប្រកាសថា សហរដ្ឋអាមេរិក បានត្រៀមខ្លួនជាស្រេច ក្នុងការឆ្លើយតបនឹងការស្នើសុំរបស់រដ្ឋាភិបាលកម្ពុជា ដែលសុំឱ្យបញ្ជូនអ្នកសង្កេតការណ៍របស់អង្គការសហប្រជាជាតិ ឱ្យទៅពិនិត្យស្ថាន

ការណ៍ជាក់ស្តែងនៅតំបន់ព្រំដែនកម្ពុជា និងវៀតណាមខាងត្បូង ។

ចំណែកសម្តេចសីហនុ បានធ្វើលិខិតជាលាយលក្ខណ៍អក្សរ និងចុះព្រះហស្តលេខា តវ៉ាសុំឱ្យអង្គការសហប្រជាជាតិរក្សាទុកអាសនៈកម្ពុជា នៅក្នុងអង្គការអន្តរជាតិកំពូលនេះ នៅទំនេររហូតដល់ទីបញ្ចប់នៃការតស៊ូរបស់ប្រជារាស្ត្រខ្មែរប្រឆាំងនឹងរបបរដ្ឋប្រហាររបស់ពួកក្បត់ លន់ នល់ សិរិមតៈ។

ប៉ុន្តែ ក្រោយពីរដ្ឋមន្ត្រីក្រសួងការបរទេសរបស់រដ្ឋាភិបាលលន់ នល់ នៅភ្នំពេញជូនដំណឹងស្តីពីការតែងតាំងឃឹម ទិត ឱ្យធ្វើជាតំណាងប្រទេសកម្ពុជា ប្រចាំនៅអង្គការសហប្រជាជាតិ ជំនួសហួត សម្បត្តិ ដែលទៅគាំទ្រសម្តេចសីហនុ នៅទីក្រុងប៉េកាំង មក អ៊ូ ថាន់ អគ្គលេខាធិការអង្គការសហប្រជាជាតិ ក៏បានសម្រេចប្រកាសទទួលស្គាល់រដ្ឋាភិបាលភ្នំពេញ  ជារដ្ឋាភិបាលស្របច្បាប់របស់ប្រទេសកម្ពុជា ។

# ២៨០
# ឧត្តមសេនីយ៍លន់ នល់ បង្កើតរបបសាធារណរដ្ឋខ្មែរ



លន់ នល់ និងសិរិមតៈ ក្នុងពិធីព្យុហយាត្រា
ថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៧០ នៅពហុកីឡដ្ឋានជាតិអូឡាំពិក

*នៅចុងខែមីនា ឆ្នាំ១៩៧០ វរសេនីយ៍ឯកថោង វ៉ាន់ហ្វាន់មឿង មេបញ្ជាការយោធភូមិភាគទី១ បានថ្លែងប្រាប់អ្នកធ្វើយធ្វងកាសែត ដឺហ្គារឌាន ស្តីពីស្ថានការណ៍សឹក នៅប៉ែកខាងកើតប្រទេសថា កងទ័ពជាតិកម្ពុជា កំពុងត្រៀមខ្លួនវាយបោសសម្អាតកងទ័ពវៀតកុង-វៀតណាមខាងជើង ឱ្យចេញពីទឹកដីខេត្តស្វាយរៀង ។*

*ចាប់ពីក្រោយព្រឹត្តិការណ៍ថ្ងៃ១៨ ខែមីនា មក ពួកងទ័ពវៀតកុង-វៀតណាមខាងជើង បានសម្លាប់ប្រជាពលរដ្ឋខ្មែរចំនួន ៥១នាក់ និងរបួស៧៨នាក់ និងនាំយកទៅជាមួយពួកវាចំនួន១០៨នាក់ ក្នុងនោះ មានទាហានរដ្ឋាភិបាល ៦៨នាក់ ផងដែរ ។*

*ឥឡូវនេះ ក្នុងរយៈពេលតែ១០ថ្ងៃប៉ុណ្ណោះ កងទ័ពរដ្ឋាភិបាលបានបើកប្រតិបត្តិ*

ការបោសសម្អាតពួកវានៅទីប្រជុំជនជីកូ ដែលរងការវាយប្រហារ២លើកមកហើយ និងនៅទីតាំងបាវិត ជាប់ព្រំដែនវៀតណាមខាងត្បូង មួយកន្លែងទៀត ។

វរសេនីយ៍ឯកថោង វ៉ាន់ហ្វាន់មឿង បានថ្លែងបន្តថា ក្រោយពេលកងទ័ពវៀតកុង មកស្ទាក់ផ្លូវជាតិលេខ១ ពីទីរួមខេត្តស្វាយរៀង ទៅព្រំដែនបាវិត ចាប់អ្នកធ្វើដំណើរយ៉ាងតិច៩នាក់យកទៅបាត់មក កងទ័ពរដ្ឋាភិបាលបានបើកប្រតិបត្តិការសឹកបោសសម្អាត និងបើកឱ្យធ្វើចរាចរណ៍ដូចធម្មតាវិញហើយ។ ចំណែកនៅតាមតំបន់ជាប់ព្រំដែនវៀតណាមខាងត្បូង អ្នកថតរូប និងអ្នកកាសែត៦នាក់ត្រូវពួក វៀតកុង ចាប់ខ្លួន។ បន្ទាប់មកទៀត ក៏មានអ្នកកាសែតជប៉ុន ម្នាក់ និងបារាំង ម្នាក់ទៀត ក៏ត្រូវពួកវាចាប់ខ្លួនដែរ ។

ថ្ងៃទី០៤ ខែមេសា ឆ្នាំ១៩៧០ មន្ត្រីរាជការ សាស្ត្រាចារ្យ គ្រូបង្រៀន សិស្ស និស្សិតបញ្ញវន្ត ជាច្រើន បានផ្ញើញត្តិ ទៅជូនរដ្ឋាភិបាល សម្តែងនូវបំណងប្រាថ្នារបស់គេ ដើម្បីឱ្យប្រទេសកម្ពុជា ដែលប្រកាន់យករបបរាជានិយមផ្តាច់ការ ជាង ២០០០ ឆ្នាំមកហើយនោះ ក្លាយមកជាប្រទេស ដែលប្រកាន់យករបបសាធារណរដ្ឋនិយម វិញ ក្នុងពេលឆាប់ៗខាងមុខនេះ ។

មិនមែនមានតែឥស្សរជន មន្ត្រីរាជការ សាស្ត្រាចារ្យ គ្រូបង្រៀន សិស្ស និស្សិតបញ្ញវន្តប៉ុណ្ណោះទេ ដែលចង់ឱ្យបង្កើតរបបសាធារណរដ្ឋនិយម សូម្បីពួករាជវង្សមួយចំនួន ដែលជាសែព្រះស៊ីសុវត្ថិ ដូចជាព្រះអង្គម្ចាស់ស៊ីសុវត្ថិ មុនីរ៉េត ជាអនុជ របស់មហាក្សត្រិយានីកុសុមៈ និងជារាជទាយាទ ត្រូវឡើងសោយរាជ្យបន្តពីព្រះមហាក្សត្រស៊ីសុវត្ថិ មុនីវង្ស ជាព្រះបិតាដែលបានសោយទិវង្គត កាលពីថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៤១ តែត្រូវខកខានវិញនោះ ក៏មិនចង់ឱ្យមានរបបរាជានិយមបន្តទៀតដែរ ។

ចំណែករាជវង្សជាសែនរោត្តម មួយចំនួន ត្រូវគេដកហូតពីតំណែងសំខាន់ៗ ខណៈសែ នរោត្តម មួយចំនួនទៀត ក៏បានព្យាយាមសម្របខ្លួនជាមួយនឹងរដ្ឋាភិបាល លន់ នល់ ដែរ។ ប៉ុន្តែទោះបីជាយ៉ាងនេះក៏ដោយ ក៏ព្រះអង្គម្ចាស់ស៊ីសុវត្ថិ មេថាវី ជា

ប្អូនប្រុសបង្កើតរបស់ព្រះអង្គម្ចាស់ស៊ីសុវត្ថិ សិរិមតៈ បានសម្រេចចូលរួមតស៊ូជាមួយសម្តេចសីហនុ នៅទីក្រុងប៉េកាំង និងបានទទួលតំណែងជាចាងហ្វាងខុទ្ទកាល័យរបស់សម្តេចសីហនុ នៅទីនោះផងដែរ ។

ចាប់ពី ឆ្នាំ១៩៧៣ មក ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ មេថាវី ត្រូវបានតែងតាំងជាឯកអគ្គរាជទូតរាជរដ្ឋាភិបាលរួបរួមជាតិ ប្រចាំនៅសាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់ ( អាល្លឺម៉ង់ខាងកើត) ។

ព្រះអង្គម្ចាស់ស៊ីសុវត្ថិ មេថាវី មានមហេសី ឈ្មោះអ្នកម្នាងណាណែត ស៊ីសុវត្ថិ ឈ្មោះដើម អាន ម៉ារី អ៊ីហ្ស៊ី (Anne Marie Izzi) ជាបងស្រីបង្កើតរបស់អ្នកម្នាងម៉ូនិក ឈ្មោះដើម ប៉ូល ម៉ូនិក អ៊ីហ្ស៊ី ( Paule Monique Izzi គឺសម្តេចម៉ែ សម្តេចយាយ សព្វថ្ងៃនេះ) ។

ដូច្នេះព្រះអង្គម្ចាស់ស៊ីសុវត្ថិ មេថាវី និងសម្តេចសីហនុ មិនត្រឹមតែជាបងប្អូនជីដូនមួយនឹងគ្នាទេ គឺត្រូវជាបងប្អូនសាច់ថ្លៃនឹងគ្នាទៀតផង ( មហេសី និងមហេសីជាបងប្អូនបង្កើត) ។

ព្រះអង្គម្ចាស់ស៊ីសុវត្ថិ មេថាវី មានបុត្រ ៦អង្គ ក្នុងនោះ ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ធម្មិកោ ជាបុត្រច្បង កើតនៅក្នុងឆ្នាំ ១៩៥២ ។ ប៉ុន្តែ ក្រោយពីមានរដ្ឋប្រហារ ថ្ងៃ១៨ មីនា ព្រះអង្គម្ចាស់ធម្មិកោ មិនបានទៅរស់នៅជាមួយព្រះបិតាមាតា ដែលនៅក្រុងប៉េកាំង ទេ គឺទ្រង់នៅខាងព្រះអង្គម្ចាស់ស៊ីសុវត្ថិ សិរិមតៈ ជាឪពុកធំនៅទីក្រុងភ្នំពេញ ដែលកំពុងប្រឆាំងនឹងសម្តេចសីហនុ និងព្រះបិតាព្រះមាតារបស់ទ្រង់ផងដែរ។

នៅថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៧០ រដ្ឋាភិបាលលន់ នល់ បានសម្រេចលុបចោលកិច្ចព្រមព្រៀងជាមួយចិន ស្តីពីការនាំអង្ករចំនួន១៣០០០តោន ដើម្បីយកទៅផ្គត់ផ្គង់កងទ័ពវៀតកុង ។

ថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៧០ នៅពហុកីឡដ្ឋានជាតិអូឡាំពិក លន់ នល់ បាប្រារព្វធ្វើក្បួនព្យុហយាត្រា មហាសាមគ្គីជាតិដ៏ធំមួយ ដោយមានយុវជនយុវនារី ជា

សិស្សនិស្សិត ជាង១ម៉ឺននាក់ បានចូលរួមដើរក្បួន ព្រមទាំងមានប្រជាពលរដ្ឋ និងយុវជនផ្សេងៗទៀតប្រមាណ៤ម៉ឺននាក់ បានចូលរួមទស្សនាក្បួនព្យុហយាត្រានោះ ។

ពិធីដើរក្បួនព្យុហយាត្រាមហាសាមគ្គីជាតិនេះ ធ្វើឡើងដើម្បីសម្តែងឱ្យឃើញពីការរួបរួមសាមគ្គីគ្នាជាធ្លុងមួយរបស់ប្រជាជាតិខ្មែរ ក្នុងការការពារទឹកដី ប្រឆាំងនឹងវៀតណាម ជាសត្រូវឈ្លានពាន និងមានការសម្តែងសិល្បៈ បង្ហាញពីការវាយផ្តួលរម្លំរបបស្តេចសក្តិភូមិ ដោយលើកយកតួអង្គសម្តេចសីហនុ ដែលពួកមេដឹកនាំរដ្ឋប្រហារចោទថា ជាអ្នកលក់ទឹកដីឱ្យយួនវៀតកុង និងជាស្តេចសក្តិភូមិជិះជាន់សង្កត់សង្កិនប្រជារាស្ត្រខ្មែរនោះ មកសម្តែងផងដែរ ។

ពិសេស តំណាងក្បួនព្យុហយាត្រាមហាសាមគ្គីជាតិ ក៏បានស្នើសុំឱ្យលន់ នល់ រៀបចំប្រកាសផ្លាស់ប្តូររបបគ្រប់គ្រងរបស់ប្រទេស ពីរបបរាជានិយម( ព្រះរាជាណាចក្រកម្ពុជា) ឱ្យទៅជារបបសាធារណរដ្ឋខ្មែរ វិញ ។

ថ្ងៃនៅក្នុងពិធីនោះ ឧត្តមសេនីយ៍លន់ នល់ ក៏បានប្រកាសសន្យាថា គាត់នឹងបង្កើតរបបសាធារណរដ្ឋខ្មែរ ក្នុងពេលឆាប់ៗខាងមុខ ។

នៅថ្ងៃទី១៥ ខែមេសា នៅទីក្រុងប៉េកាំង សម្តេចសីហនុ បានប្រកាសប្រាប់ក្រុមអ្នកកាសែតបរទេសថា បញ្ហាបង្កើត រណសិរ្សរួបរួមជាតិនៅកម្ពុជា ក្រោយរដ្ឋប្រហារថ្ងៃ១៨មីនា ១៩៧០ នោះ មិនមែនដើម្បីដណ្តើមអំណាចមកឱ្យខ្ញុំវិញ នៅពេលអនាគតនោះទេ។ ប៉ុន្តែ ប្រសិនបើបណ្តោយឱ្យលន់ នល់ ដឹកនាំប្រទេសតទៅទៀត វាគ្មានអ្វីក្រៅពីធ្វើឱ្យ ប្រទេសជាតិឆ្ពោះទៅរកភាពទាល់ច្រក ដែលបណ្តាលមកពីទំនាស់រវាងពួកសង្គមនិយម និងពួកមូលធននិយម ព្រមទាំងភាពទាល់ច្រក ដែលបណ្តាលមកពីទំនាស់រវាងពួកជឿនលឿន និងពួកប្រតិកិរិយានោះឡើយ ហើយភាពទាល់ច្រកនេះ មានតែពួកអ្នកតស៊ូសីហនុនិយម នៅក្នុងព្រៃម៉ាគីទេ ដែលអាចដោះស្រាយបាន ។






**សម្ដេចសីហនុ** **ឧត្ដមសេនីយ៍លន់ នល់**

*សម្ដេចសីហនុ មានបន្ទូលបញ្ជាក់ថា ពិតណាស់ ខ្ញុំត្រូវតែដឹកនាំការតស៊ូរហូតដល់ទីបញ្ចប់ ។ ប៉ុន្ដែ ពុំមែនដើម្បីស្វែងរកអំណាចមកវិញ ក្នុងនាមរូបខ្ញុំជាអ្នកកាន់ព្រះពុទ្ធសាសនាម្នាក់ដែលកំពុងឈានទៅរកភាពជរា ព្យាធិ និងមរណៈនោះទេ ។*

*រូបខ្ញុំត្រូវពួកស្ដាំនិយមបំផុតរបស់ខ្ញុំ មូលបង្កាច់យ៉ាងឃោរឃៅយ៉ាងថោកទាប និងយ៉ាងកំសាកបំផុត ។ ខ្ញុំមិនអាចទទួលយកនូវអំពើអយុត្តិធម៌នេះបានទេខ្ញុំត្រូវតែតស៊ូដោយឥតថយក្រោយ ប្រឆាំងនឹងបនក្បត់លន់ នល់ ដើម្បីស្វែងរកយុត្តិធម៌តែប៉ុណ្ណោះ ។*

*ខ្ញុំនឹងដឹកនាំការតស៊ូប្រយុទ្ធជាមួយអ្នកដែលស្មោះត្រង់នឹងខ្ញុំក៏ដូចជាយុវជនជឿនលឿននិយមរបស់យើង ដើម្បីឱ្យយុវជនទាំងនេះបានឡើងកាន់អំណាច ហើយក៏ដើម្បីឱ្យពួកគេបានសម្រេចនូវក្ដីស្រមៃរបស់ពួកគេ ដែលមានបំណងឆ្ពោះទៅរកយុត្តិធម៌សង្គម និងសង្គមនិយម ។*

*បើអ្នកស្មោះត្រង់ជាមួយខ្ញុំក្ដី ឬជនរួមជាតិណាម្នាក់ ត្រូវពលីជីវិតនៅក្នុងសមរភូមិប្រយុទ្ធនៅថ្ងៃណាមួយនោះ គឺពួកគេពុំមែនបូជាជីវិត ដើម្បីយកអំណាច ឬកិត្តិយស មកឱ្យសីហនុ វិញទេ គឺពួកគេបានបូជាជីវិតដ៏ថ្លៃថ្លាបំផុត ដើម្បីប្រជាជនខ្មែរទាំងមូល ។*

*សម្ដេចសីហនុ មានបន្ទូលបន្តទៀតថា កាសែតលោកខាងលិចមួយចំនួន បានគ្រើនរម្លឹកខ្ញុំថា ក្រោយការតស៊ូ ប្រឆាំងនឹងបនក្បត់ លន់ នល់ បានទទួលជ័យជម្នះហើយ ខ្ញុំនឹងត្រូវបង់ថ្លៃ ក្នុងតម្លៃណាមួយ ដើម្បីជាកិច្ចតបស្នងដល់សម្ព័ន្ធមិត្តកុម្មុយនិស្តរបស់ខ្ញុំ ដែលបាន*

ជួយដល់គាំទ្រដល់ការតស៊ូនោះជាមិនខាន ។ ប៉ុន្តែ ការគ្រើនរម្មឹកនេះ វាគ្មានប្រយោជន៍អ្វីទេ ហើយខ្ញុំមិនដែលគិតពីបញ្ហានេះដែរ ព្រោះការប្រយុទ្ធតស៊ូនេះ មានគោលដៅតែមួយ គឺនាំយករបបសង្គមនិយម របបប្រជាមានិតថ្មីមួយមកជូនប្រទេសជាតិប៉ុណ្ណោះ ហើយមេដឹកនាំរបបថ្មីនេះ គឺពួកយុវជនជឿនលឿននិយម និងពួកកុម្មុយនិស្តនិយមដែលមិនខ្វាចរអែងប្រទេសជិតខាងនោះម្តងណាឡើយ ។

នៅថ្ងៃទី១៦ ខែមេសា ទស្សនាវដ្ដីថៃម បានចុះផ្សាយថា កងទ័ពវៀតកុង-វៀតណាមខាងជើង បានបើកការវាយប្រហារលើផ្ទៃដី១ភាគ៣នៅកម្ពុជា ហើយកងទ័ពនេះបានហៅខ្លួនឯងថា ជាកងទ័ពថ្មីរបស់សម្ដេចសីហនុ ដែលទើបនឹងត្រូវគេទម្លាក់ពីអំណាច។ ពួកគេនឹងបង្កើនការវាយលុកបន្ថែមទៀត ដើម្បីផ្ដួលរម្លំរដ្ឋាភិបាលភ្នំពេញ នៅពេលខាងមុខឆាប់ៗនេះ ។

ពេលនោះដែរ វិទ្យុក្រុងប៉េកាំង ផ្សាយសំឡេងជាភាសាខ្មែរ បានប្រកាសប្រាប់អ្នកស្ដាប់ថា សម្ដេចសីហនុ នឹងត្រលប់ទៅប្រទេសកម្ពុជាវិញ នៅចុងខែមេសា នេះ។ ទស្សនាវដ្ដីថៃម ចុះផ្សាយបន្តថា កងទ័ពវៀតកុង បានចូលមកបោះទីតាំងលាតសន្ធឹងចាប់ពីតំបន់ចម្ការកៅស៊ូ នៅស្រុកស្នួល ខេត្តក្រចេះ រហូតដល់ឃុំកំពង់ត្រាច ស្រុករមាសហែក ខេត្តស្វាយរៀង និងជុំវិញទីរួមខេត្តស្វាយរៀង ព្រមទាំងនៅតាមដងទន្លេមេគង្គ ហើយតំបន់ចំពុះទា កំពុងស្ថិតនៅក្រោមការកាន់កាប់របស់កងទ័ពវៀតកុង ស្ទើរតែទាំងស្រុងទៅហើយ ។

ពេលនេះ ទីរួមខេត្តស្វាយរៀង ក៏កំពុងស្ថិតនៅក្រោមការគំរាមកំហែងរបស់កងទ័ពវៀតកុងដែរ។ កងទ័ពវៀតកុង បានបែងចែកគ្នាជា៣មុខព្រួញ ដើម្បីវាយដណ្ដើមយកទីរួមខេត្តស្វាយរៀង នេះ ។

ជាមួយគ្នានោះ កងទ័ពវៀតកុង ក៏មានបំណងវាយដណ្ដើមតំបន់កំពង់ចម្លងអ្នកលឿង ដើម្បីកាត់ផ្ដាច់ផ្លូវ គមនាគមន៍ពីខេត្តស្វាយរៀង ទៅកាន់ទីក្រុងភ្នំពេញដែរ ។

ចំណែកនៅប៉ែកនិរតី ទីក្រុងភ្នំពេញ កងទ័ពវៀតកុង កំពុងបើកការវាយប្រហារ

សំដៅទៅទីរួមខេត្តតាកែវ ។

តាមប្រភពពីមេបញ្ជាការទាហានលន់ នល់ បានឱ្យដឹងថា កងទ័ពវៀតកុង បានវាយសម្រុកទៅភ្នំដំរីរមៀល ដែលស្ថិតនៅភាគខាងត្បូងនៃទីរួមខេត្តតាកែវ ។ ទស្សនាវដ្ដីថៃម បានបញ្ជាក់ជាចុងក្រោយថា ទាហានរដ្ឋាភិបាលសរុបមានតែប្រមាណ៣៥០០០នាក់នោះ ពេលនេះបានកើនឡើងជិតទ្វេជាពីរ ដោយសារពួកយុវជននាំគ្នាចូលបម្រើដោយចិត្តស្មោះស្ម័គ្រ។ ប៉ុន្តែពួកគេពុំមានបទពិសោធក្នុងការប្រយុទ្ធ និងពុំមានការហ្វឹកហ្វឺនឱ្យបានល្អដូចកងទ័ពវៀតកុង ឡើយ ។

ថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧០ សម្ដេចសីហនុ ប្រកាសថា កំហុសធ្ងន់របស់ព្រះអង្គ ដែលបណ្ដាលឱ្យមានរដ្ឋប្រហារ ថ្ងៃ១៨ មីនា នោះ គឺដោយសារព្រះអង្គបានផ្ដល់អំណាចបុណ្យសក្ដិដល់លន់ នល់ និងសិរិមតៈ ច្រើនពេក ហើយក៏ដោយសារព្រះអង្គជឿទុកចិត្តពួកនេះ ដោយខ្វះការពិចារណាថា ពួកបញ្ញវន្តចម្រើននិយម និងសង្គមនិយមសុទ្ធតែពួកក្បត់ប្រទេសជាតិ ពួកបំផ្លាញផលប្រយោជន៍ប្រជារាស្ត្រ។ ប៉ុន្តែទោះជាយ៉ាងនេះ ក៏ដោយ ក៏ពេលនេះ ពួកយុវជន ពួកបញ្ញវន្តជាអ្នកស្នេហាជាតិ ជាអ្នកចម្រើននិយម និងជាអ្នកសង្គមនិយមទាំងអស់ បានយល់ព្រមអភ័យទោសឱ្យព្រះអង្គជាឯកច្ឆន្ទចំពោះកង្វះនៃការពិចារណានោះហើយ ។

នៅថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧០ សម្ដេច សីហនុ បានផ្ញើលិខិតមួយទៅកាសែតអាអេហ្វប៉េ ( AFP ) កាសែតឡឺ ហ្វីហ្គារ៉ូ ( Le Figaro ) និងកាសែតឡឺ ម៉ុងដ៍ ( Le Monde ) របស់បារាំង ដើម្បីបញ្ជាក់ប្រាប់សាធារណមតិជាតិ និងអន្តរជាតិថា ក្រៅពីការសន្យាមិនត្រលប់មកកាន់អំណាចវិញ ព្រះអង្គក៏ត្រូវតែបង្ខំចិត្តទទួលស្គាល់ពីបរាជ័យនៃការដឹកនាំរបស់ព្រះអង្គតាមបែបរបបសង្គមនិយមព្រះពុទ្ធសាសនា និងលទ្ធិសីហនុនិយម ដែលព្រះអង្គបានដឹកនាំតាំងពីឆ្នាំ១៩៥៥ ដល់ឆ្នាំ១៩៧០នោះមកដែរ ។

នៅថ្ងៃទី១៨ ខែមេសា កាសែតឡឺ ម៉ុងដ៍ របស់បារាំង បានចុះផ្សាយថា នៅក្នុងដំណើរទស្សនកិច្ចនៅទីក្រុងបាងកក យ៉ែម សំបូរ រដ្ឋមន្ត្រីការបរទេសនៅភ្នំពេញ បាន

ថ្ងៃផ្ប្រាប់អ្នកកាសែតថា គេមិនត្រូវការកាន់ប្រទ្បំពីការប្តេជ្ញាចិត្តដ៏មោះមុតរបស់រដ្ឋាភិបាលកម្ពុជា ក្នុងការបណ្តេញកងទ័ពបរទេស ដែលចូលមកធ្វើសកម្មភាពនៅក្នុងទឹកដីរបស់ខ្លួន ឱ្យចេញទៅវិញនោះទេ។ អ្វីដែលយើងត្រូវការ គឺឱ្យពួកគេគោរពឱ្យបានត្រឹមត្រូវនោះ គឺឯករាជ្យ បូរណភាពទឹកដីបច្ចុប្បន្នរបស់យើង ហើយយើងក៏ចៀសវាងដាច់ខាតមិនចូលរួមក្នុងប្លុក ឬក្នុងកតិកាសញ្ញាយោធាណាមួយដែរ ។

មួយថ្ងៃក្រោយមក គឺនៅថ្ងៃ១៩ ខែមេសា កាសែតឡឺម៉ុងដ៍ ដដែល បានចុះផ្សាយថា ស្ថានការណ៍នៅប្រទេសកម្ពុជា បានវិវត្តយ៉ាងឆាប់រហ័សជាងការរំពឹងទុក ដោយសារសង្គ្រាម និងចលនាបដិវត្តន៍ ។ សម្តេចសីហនុ បានបង្កើតរណសិរ្សរួបរួមជាតិមួយ ដើម្បីប្រឆាំងនឹងសហរដ្ឋអាមេរិក និងរកជ័យជម្នះឱ្យកងទ័ពកុម្មុយនិស្តកម្ពុជា ។ ឥឡូវនេះកងទ័ពវៀតកុង បានជួយជ្រោមជ្រែងដល់ពួកខ្មែរក្រហម ដោយចេញមុខតែម្តង ខណៈកាលពីប៉ុន្មានឆ្នាំចុងក្រោយនេះ (មុនរដ្ឋប្រហារថ្ងៃ១៨មីនា) រដ្ឋាភិបាលភ្នំពេញ បានកាត់បន្ថយសកម្មភាពពួកខ្មែរក្រហមនេះ ឱ្យនៅយ៉ាងតិច បំផុតទៅហើយ។ ដោយសារចលនាតស៊ូខ្មែរក្រហម មានមេដឹកនាំស្អាតស្អំ ហើយឥឡូវនេះ មានប្រជាកសិករ គាំទ្រមួយផ្នែកធំផង។ ដូច្នេះ គេមិនអាចចាត់ទុកចលនាតស៊ូនេះថា ជាខ្នែងតូចមួយរបស់ពួកវៀតកុង-វៀតណាមខាងជើង ដូចរដ្ឋាភិបាលក្រុងវ៉ាស៊ីនតោន បានលើកឡើងនោះឡើយ ។

កាសែតឡឺម៉ុងដ៍ ដដែល បានចុះផ្សាយបន្តថា នៅវៀតណាមខាងត្បូង និងប្រទេសលាវ គឺជាសមរភូមិប្រយុទ្ធគ្នា រវាងពួកកុម្មុយនិស្ត និងពួកប្រឆាំងនឹងកុម្មុយនិស្ត ។

ចំណែកនៅប្រទេសកម្ពុជា សម្តេចសីហនុ បានបោះបង់គោលជំហរអព្យាក្រឹតរបស់ព្រះអង្គ ដើម្បីសម្របខ្លួនជាមួយពួកកុម្មុយនិស្តទៅវិញ ។ ទីលានប្រយុទ្ធបានលាតសន្ធឹងពាសពេញឧបទ្វីបឥណ្ឌូចិន ទាំងមូល ។ អាមេរិក មិនអាចវាយឈ្នះលើពួកវៀតកុង-វៀតណាមខាងជើង បានទេ ។

ពួកកុម្មុយនិស្ត កំពុងពង្រីកតំបន់រំដោះរបស់ពួកគេ និងចាត់តាំងរដ្ឋអំណាចបដិវត្តន៍នៅកម្ពុជា ហើយរាជរដ្ឋាភិបាលរួបរួមជាតិ ដែលសម្តេចសីហនុ គ្រោងនឹង

បង្កើតនៅពេលខាងមុខនេះ មិនមែនមានតែឥស្សរជន ដែលកំពុងជ្រកកោន នៅទីក្រុងប៉េកាំង នោះទេ។ ប៉ុន្តែក៏មានអតីតៈតំណាងរាស្ត្រ៣រូប ( ខៀវ សំផន, ហ៊ូ យន់, ហ៊ូ នឹម) ដែលបានរត់ចូលព្រៃតស៊ូតាំងពី៣ឆ្នាំមុន ក៏មានឈ្មោះនៅក្នុងជួររាជរដ្ឋាភិបាលនោះដែរ ។

នៅទីបំផុត ដោយសារស្ថានការណ៍សឹកកាន់តែធ្ងាក់ដុនដាបទៅៗ នៅថ្ងៃទី២០ ខែមេសា ឧត្តមសេនីយ៍លន់ នល់ បានប្រកាសសុំជំនួយពីសហរដ្ឋអាម៉េរិក ដើម្បីទប់ទល់នឹងការវាយលុកយ៉ាងគំហុករបស់កងទ័ពវៀតកុង-វៀតណាមខាងជើង ។

# ២៨១
# ប្រធានាធិបតី និចសុន បញ្ជាឱ្យកងទ័ពអាមេរិក និងវៀតណាមខាងត្បូង ចូលទៅជួយទាហានលន់ នល់



កងរថក្រោះអាមេរិក ចូលដល់ទីប្រជុំស្នួល ខេត្តក្រចេះ

តាមការផ្ដួចផ្ដើមរបស់សម្ដេចសីហនុ ប្រធានរណសិរ្សរួបរួមជាតិកម្ពុជា និង នាយករដ្ឋមន្ត្រីចិន ជូ អេនឡាយ សន្និសីទកំពូលរបស់ប្រជាជននៅឥណ្ឌូចិន បាន ប្រារព្ធធ្វើឡើងរយៈពេល២ថ្ងៃ គឺថ្ងៃទី២៤ និង២៥ ខែមេសា ឆ្នាំ១៩៧០ នៅតំបន់កង់ទុង ក្បែរព្រំដែនប្រទេសចិន, វៀតណាម និងឡាវ ។

គណៈប្រតិភូចំនួន៤ រួមមាន៖ សម្ដេច សីហនុ តំណាងឱ្យប្រទេសកម្ពុជា, ព្រះអង្គម្ចាស់សុផាន់វង្ស តំណាងឱ្យប្រទេសលាវ , ផាំ វ៉ាន់ដុង តំណាងឱ្យប្រទេស វៀតណាមខាងជើង និងង្វៀន ហ៊ុយថ តំណាងឱ្យរដ្ឋាភិបាលបដិវត្តន៍បណ្ដោះអាសន្ន វៀតណាមខាងត្បូង( វៀតកុង) បានចូលរួមក្នុងសន្និសីទនោះដែរ ។

ក្រៅពីសម្ដេចសីហនុ ជាប្រធានគណៈប្រតិភូ ក៏មាន ប៉ែន នុត, ហួត សម្បត្តិ,

សារិន ឆាក, ចៅ សេង, ជួន មុម្ម និងរឿង ម៉ាច ជាសមាជិកគណៈប្រតិភូរណសិរ្សរួបរួមជាតិកម្ពុជា ផងដែរ ។

អង្គសន្និសីទបានធ្វើការវាយតម្លៃលើសភាពការណ៍រួមនៅឥណ្ឌូចិន និងការតស៊ូរបស់ប្រជាជនទាំង៣ ( វៀតណាម, កម្ពុជា និងលាវ) ក្នុងការតស៊ូប្រឆាំងនឹងពួកចក្រពត្តិអាមេរិក និងបរិវារ ហើយបានចេញសេចក្តីថ្លែងការណ៍រួមមួយ មានខ្លឹមសារជាអាទិ៍ថា៖ ប្រជាជនទាំង៣ប្រទេស គឺវៀតណាម កម្ពុជា លាវ បានរួមរស់ជាមួយគ្នានៅលើឧបទ្វីបឥណ្ឌូចិន ក្នុងរយៈពេល ជាង១៥ឆ្នាំកន្លងមកនេះ ត្រូវបានពួកចក្រពត្តិអាមេរិក ប៉ុនប៉ងកែប្រែឱ្យក្លាយទៅជាអាណានិគមបែបថ្មី និងជាមូលដ្ឋាន យោធារបស់ពួកវា ក្នុងគោលបំណងបំផ្លាញចលនាតស៊ូរំដោះជាតិនៅឥណ្ឌូចិន ក៏ដូចនៅអាស៊ីភាគអាគ្នេយ៍ និងបណ្តាប្រទេសឯករាជ្យផ្សេងៗទៀតនៅទ្វីបអាស៊ី ផងដែរ ។

ចក្រពត្តិអាមេរិក គឺជាពួកហ្វាស៊ីស្តបែបថ្មី ជាខ្មាំងសត្រូវដ៏សាហាវយង់ឃ្នង និងផ្តល់ទុក្ខលំបាកដ៏ធ្ងន់ធ្ងរបំផុតដល់ប្រជាជនឥណ្ឌូចិន និងដល់មនុស្សជាតិទាំងមូល ។ ប្រឈមមុខនឹងសត្រូវរួមនេះ ប្រជាជនឥណ្ឌូចិន ប្តេជ្ញាប្រយុទ្ធកៀកស្មាគ្នា ដើម្បីការពារសិទ្ធិដ៏ពិសិដ្ឋរបស់ប្រជាជាតិខ្លួន ។

ក្រោមការដឹកនាំរបស់សម្តេចព្រះនរោត្តម សីហនុ ប្រជាជនខ្មែរបានកម្ចាត់រាល់ឧបាយកលហ៊ុមព័ទ្ធ, ការបង្កហេតុ និងអំពើវិទ្ធង្សនាផ្សេងៗរបស់ចក្រពត្តិអាមេរិកនិងបានវាយបំបែកផែនការបង្កើតប្រព័ន្ធមូលដ្ឋានយោធារបស់ពួកវាពីប្រទេសវៀតណាមខាងត្បូង ទៅប្រទេសថៃ ដើម្បីក្រសោបយកកម្ពុជា និងលាវ ។

រយៈពេល១៥ឆ្នាំកន្លងមកនេះ ប្រជាជនកម្ពុជា អាចរក្សាបាននូវឯករាជ្យភាព,សន្តិភាព និងអព្យាក្រឹតភាពរបស់ខ្លួនបានគង់វង្ស ហើយកិត្យានុភាពរបស់ប្រទេសកម្ពុជាបានអណ្តែតឡើងឥតឈប់ឈរនៅលើផ្ទៃរាបអន្តរជាតិ ។

អង្គសន្និសីទបានសម្តែងការគាំទ្រពេញទំហឹងដល់ការតស៊ូប្រកបដោយវីរភាពរបស់ប្រជាជនខ្មែរ តាមការអំពាវនាវរបស់សម្តេចព្រះនរោត្តម សីហនុ ក្នុងការវាយកម្ចាត់

បនក្បត់លន់ នល់ សិរិមតៈ និងវាយបំបាក់សកម្មភាពឈ្លានពានរបស់ពួកចក្រពត្តិអាមេរិក ។

អង្គសន្និសីទ ក៏បានសម្តែងការគាំទ្រទាំងស្រុងនូវសេចក្តីប្រកាសទាំង៥ចំណុច របស់សម្តេចព្រះនរោត្តម សីហនុ នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧០ ហើយធ្វើការថ្កោលទោសចំពោះការប៉ុនប៉ងរបស់ចក្រពត្តិអាមេរិក និងបរិវារ ព្រមទាំងពួកប្រតិកិរិយាផ្សេងៗទៀតនៅអាស៊ី ដែលប្រើល្បិចយកឈ្មោះអង្គការសហប្រជាជាតិ ឬប្រើល្បិចតាមរយៈសន្និសីទណាមួយផ្សេងទៀត ប្រគល់អាសនៈរបស់ប្រទេសកម្ពុជា នៅក្នុងអង្គការសហប្រជាជាតិទៅឱ្យរបបប្រតិកិរិយាលន់ នល់ និងសិរិមតៈ ដែលជារបបខុសច្បាប់ ដើម្បីជ្រៀតចូលកិច្ចការផ្ទៃក្នុងរបស់កម្ពុជា ។



សម្តេចសីហនុ, ផ្សៀន ហ៊ុយថ (វៀតកុង),ផាំ វ៉ាន់ដុង និងសុផានវង្ស (លាវ)

អង្គសន្និសីទមានជំនឿយ៉ាងមុតមាំថា ការតស៊ូរបស់ប្រជាជនខ្មែរ នឹងនាំមកនូវជ័យជម្នះដ៏ត្រចះត្រចង់ជាមិនខាន ហើយក៏បានធ្វើការវាយតម្លៃថា ស្ថានការណ៍បច្ចុប្បន្នបានផ្តល់ឱកាសដ៏ប្រសើរជាងពេលណាៗទាំងអស់ សម្រាប់ប្រជាជនឥណ្ឌូចិន ក្នុងការតស៊ូប្រឆាំងនឹងពួកឈ្លានពានអាមេរិក ដើម្បីសង្គ្រោះជាតិ ។

ពួកចក្រពត្តិអាមេរិក មិនដែលធ្លាក់ចុះខ្សោយ និងឯកោខ្លាំង ដូចពេលនេះឡើយ ។ ប្រជាជនឥណ្ឌូចិន តស៊ូដើម្បីបុព្វហេតុដ៏ត្រឹមត្រូវ មានមាគ៌ាដឹកនាំច្បាស់លាស់ មានទឹកចិត្តពុះពោរ មានសាមគ្គីភាពរឹងមាំ គ្មានអ្វីមកបំបែកបាន និងមានការគាំទ្រពីប្រជាជននៅលើពិភពលោក ។

ប្រជាជននៃប្រទេសទាំង៣ នៅឥណ្ឌូចិន នឹងបង្កើនការប្រយុទ្ធតស៊ូលើគ្រប់វិស័យ ដើម្បីដណ្តើមនូវជ័យជម្នះទាំងស្រុង នៅពេលខាងមុខ ។

នៅក្នុងសន្និសីទនេះ នាយករដ្ឋមន្ត្រីចិន ជូ អេនឡាយ ក៏បានចូលរួមជាភ្ញៀវកិត្តិយសផងដែរ។ ដោយសារ មិនបាន១ខែផង សភាពការណ៍យោធាកាន់តែធ្លាក់ដុនដាបទៅៗ រដ្ឋាភិបាលលន់ នល់ បានស្នើសុំឱ្យកងទ័ពសហរដ្ឋអាមេរិក ជួយធ្វើអន្តរាគមន៍ ដោយប្រើយន្តហោះបេ៥២ ដើម្បីជួយកម្ចាត់កងទ័ពវៀតកុង-វៀតណាមខាងជើង ដែលកំពុងលុកលុយពេញផ្ទៃប្រទេសកម្ពុជា ។

ប្រទេសកូរ៉េខាងត្បូង បានត្រៀមខ្លួនជាស្រេចក្នុងការផ្តល់ជំនួយយោធាទៅឱ្យទាហានរដ្ឋាភិបាលលន់ នល់ ខណៈរាជរដ្ឋាភិបាលក្រុងបាងកក ក៏បង្ហាញពីគោលជំហរដូចប្រទេសកូរ៉េខាងត្បូង ដែរ នៅពេលណាដែលប្រទេសទាំង២នេះបានរៀបចំផ្សារទំនាក់ទំនងការទូតជាមួយកម្ពុជា ឡើងវិញ ។

បើតាមការផ្សាយរបស់កាសែតបារាំង អាអេហ្វប៉េ(AFP) បានឱ្យដឹងថា ប្រសិនបើមានសន្និសីទប្រជាជនអាស៊ី ប្រជុំសម្រេចផ្តន្ទាទោសអំពើឈ្លានពានរបស់ពួកកុម្មុយនិស្តវៀតណាម នៅកម្ពុជានោះ រដ្ឋាភិបាលប្រទេសឥណ្ឌូនេស៊ី នឹងត្រៀមកងទ័ពរបស់ខ្លួនចំនួន១៦០០នាក់ ដើម្បីឱ្យទៅធ្វើអន្តរាគមន៍នៅប្រទេសកម្ពុជា ដែរ ។

សន្និសីទប្រជាជនអាស៊ីនេះ បម្រុងនឹងបង្កើតឡើងដោយមានការជ្រោមជ្រែងពីមន្ទីរបញ្ចកោណរបស់សហរដ្ឋអាមេរិក ដើម្បីប្រឆាំងតបតទៅសន្និសីទប្រជាជនឥណ្ឌូចិន ដែលបានប្រព្រឹត្តឡើង កាលពីថ្ងៃទី២៤ និង២៥ ខែមេសា កន្លងមកនោះ ប៉ុន្តែក្រោយមក គម្រោងបង្កើតសន្និសីទប្រជាជនអាស៊ីនេះ ក៏ស្ងប់ស្ងាត់ទៅវិញ ។

ពេលនោះដែរ មេដឹកនាំពួកវៀតកុង-វៀតណាមខាងជើង ក៏បានធ្វើការបរិហារអំពីការគប់គិតគ្នារបស់រដ្ឋាភិបាលក្រុងវ៉ាស៊ីនតោន, ក្រុងព្រៃនគរ និងក្រុងភ្នំពេញដើម្បីបញ្ឆេះសង្គ្រាមនៅកម្ពុជា ហើយវិទ្យុផ្សាយសំឡេងរបស់រណសិរ្សរំដោះជាតិវៀតណាមខាងត្បូង( ពួកវៀតកុង ) ក៏បានជួយផ្សព្វផ្សាយគោលនយោបាយរបស់រណសិរ្សរួបរួមជាតិកម្ពុជា និងជួយបំផុសឱ្យប្រជាជនខ្មែររត់ចូលព្រៃម៉ាគី ដើម្បីតស៊ូប្រឆាំងបនក្បត់លន់ នល់ សិរិមត: ផងដែរ ។

នៅពេលកងទ័ពសហរដ្ឋអាមេរិក និងកងទ័ពរដ្ឋការវៀតណាមខាងត្បូង ជាច្រើនពាន់នាក់ កំពុងបើកការវាយប្រហារទៅលើទីតាំងបញ្ជាការដ្ឋានកងទ័ពវៀតកុង-វៀតណាមខាងជើង នៅតំបន់ផ្លែសន្ទូច ដែលជាតំបន់ព្រំប្រទល់ស្រុកស្នួលខេត្តក្រចេះ និងស្រុកពញាក្រែក, ស្រុកមេមត់ ខេត្តកំពង់ចាម តាមការស្នើសុំរបស់ឧត្តមសេនីយ៍លន់ នល់ នោះ នៅថ្ងៃទី៣០ ខែមេសា ប្រធានាធិបតីអាមេរិក រីឆាដ និចសុន ( Richart Nixon ) បានថ្លែងតាមកញ្ចក់ទូរទស្សន៍ទៅកាន់ប្រជាពលរដ្ឋអាមេរិក ថា ការវាយប្រហាររបស់កងទ័ពសហរដ្ឋអាមេរិក នៅតំបន់ផ្លែសន្ទូច ក្នុងទឹកដីកម្ពុជា នោះ មិនមែនជាការឈ្លានពានទេ គឺគ្រាន់តែជាការវាយបណ្តេញកងទ័ពវៀតកុង-វៀតណាមខាងជើង ដែលកំពុងកាន់កាប់ត្រួតត្រាតំបន់នោះតែប៉ុណ្ណោះ ហើយកងទ័ពអាមេរិក ក៏មិនមានបំណងកាន់កាប់តំបន់នេះដែរ ។ ពេលណា យើងវាយកម្ទាត់ និងបំផ្លាញគ្រឿងផ្គត់ផ្គង់របស់កងទ័ពវៀតកុង-វៀតណាមខាងខាងជើង អស់ហើយ យើងនឹងដក កងទ័ពថយវិញ។ ប្រតិបត្តិការវាយប្រហារនេះ ធ្វើឡើងគ្រាន់តែដើម្បីការពារកងទ័ពរបស់យើង ដែលបោះទីតាំងនៅក្នុង ទឹកដីវៀតណាមខាងត្បូង និងដើម្បីធានាដល់ជោគជ័យនៃការដកកងទ័ពយើងចេញពីវៀតណាមខាងត្បូង តែប៉ុណ្ណោះ។

ប្រធានាធិបតីនិចសុន បានថ្លែងបញ្ជាក់ថា កាលពី១០ថ្ងៃមុន ខ្ញុំបានសម្រេចចិត្តប្រកាសដកកងទ័ពអាមេរិក ចេញពីប្រទេសវៀតណាមខាងត្បូងចំនួន១៥០.០០០នាក់បន្ថែមទៀត នៅឆ្នាំខាងមុខ បើទោះបីខ្ញុំមានការព្រួយបារម្ភពីការកើនឡើងសកម្ម

ភាពរបស់ពួកកុម្មុយនិស្តនៅវៀតណាមត្បូង, នៅកម្ពុជា និងនៅលាវ ក៏ដោយ ។

ដូច្នេះខ្ញុំសូមរម្លឹកថា ពេលនេះ បើពួកកុម្មុយនិស្តបង្កើនសកម្មភាពនៅតំបន់ណាមួយ ដែលអាចបង្កគ្រោះថ្នាក់ដល់កងទ័ពយើង នៅវៀតណាមខាងត្បូង នោះ ខ្ញុំនឹងមិនរួញរាក្នុងការចាត់វិធានការបើកប្រតិបត្តិការសឹកបន្តទៀតឡើយ ហើយបើយើងគ្រាន់តែធ្វើការព្រមានតែមាត់ទទេនោះ ក៏ពួកវៀតកុង-វៀតណាមខាងជើង នៅតែបង្កើនសកម្មភាពឈ្លានពានទៅលើតំបន់ទាំងនោះ ពិសេសគឺនៅកម្ពុជា តែម្តង ។

ប្រធានាធិបតី និចសុន បានថ្លែងបន្តថា យប់នេះ ខ្ញុំនឹងរៀបរាប់ពីសកម្មភាពរបស់កងទ័ពវៀតកុង-វៀតណាមខាងជើង និងការបញ្ជាឱ្យដោះស្រាយស្ថានការណ៍ព្រមទាំងពីមូលហេតុនៃការសម្រេចចិត្តរបស់ខ្ញុំផងដែរ ។

កម្ពុជា ជាប្រទេសតូច មានប្រជាជន ៧លាននាក់។ ប្រទេសនេះជាប្រទេសអព្យាក្រឹតតាំងពីមានកិច្ចព្រមព្រៀងនៅហ្សឺណែវ ឆ្នាំ១៩៥៤ មក គឺកិច្ចព្រមព្រៀង ដែលចុះហត្ថលេខាដោយរដ្ឋាភិបាលវៀតណាមខាងជើង ។ តាំងពីពេលនោះមក យើងបានគោរពយ៉ាងត្រឹមត្រូវចំពោះអព្យាក្រឹតភាពរបស់ប្រទេសកម្ពុជា ។

គិតត្រឹមពីខែសីហា ឆ្នាំមុន (១៩៦៩) យើងបានដាក់មន្ត្រីគណៈបេសកកម្មការទូត មិនដល់១៥នាក់ផង នៅទីក្រុងភ្នំពេញ ។

ក្នុងរយៈពេល៤ឆ្នាំ គិតពីឆ្នាំ១៩៦៥ ដល់ឆ្នាំ១៩៦៩ យើងពុំមានមន្ត្រីគណៈ បេសកកម្មការទូតណាម្នាក់នៅកម្ពុជាទេ ហើយក្នុងរយៈពេល៥ឆ្នាំមុន ក៏យើងពុំបានផ្តល់ជំនួយយោធា និងជំនួយសេដ្ឋកិច្ចណាមួយដល់កម្ពុជា ដែរ ។

តែទោះបីយ៉ាងនេះក៏ដោយ ក៏ពួកវៀតណាមខាងជើង មិនបានគោរពអព្យាក្រឹតភាពរបស់កម្ពុជា ឡើយ ។

ក្នុងអំឡុង៤ឆ្នាំមុន ដូចការចង្អុលបង្ហាញតាមផែនទីនេះ កងទ័ពវៀតកុង-វៀតណាមខាងជើង បានបោះទីតាំងយោធាជាច្រើនកន្លែងនៅតាមបណ្តោយព្រំដែនខាងកើតរបស់កម្ពុជា ដែលនៅជាប់ជាមួយវៀតណាមខាងត្បូង ។




**ប្រធានាធិបតីនិចសុន ចង្អុលផែនទីប្រទេសកម្ពុជា**

*កងទ័ពវៀតកុង-វៀតណាមខាងជើង បានកាន់កាប់ និងយកទឹកដីកម្ពុជា ធ្វើជាទីតាំងមូលដ្ឋានហ្វឹកហ្វឺន, ឃ្លាំងដាក់សម្ភារភ័ស្តុភារ, ឃ្លាំងដាក់អាវុធគ្រាប់រំសេវ, កន្លែងសម្រាក និងកន្លែងឃុំឃាំងពួកឈ្លើយសឹក ។*

*អស់រយៈពេល៥ឆ្នាំមកហើយ ទាំងកងទ័ពអាមេរិក ទាំងកងទ័ពវៀតណាមខាងត្បូង មិនដែលបានធ្វើសកម្មភាពវាយប្រហារទៅលើទីតាំងទាំងអស់នោះឡើយ ។*

*សូម្បីក្រោយពួកកុម្មុយនិស្តចាប់ផ្តើមពង្រីកទីតាំងទាំងនេះបន្ថែមទៀត កាលពី៤សប្តាហ៍មុនក៏ដោយ ក៏យើងនៅតែឱ្យកងទ័ពសម្ព័ន្ធមិត្តវៀតណាមខាងត្បូង អត់ធ្មត់ និងមិនឱ្យកងទ័ពយើងធ្វើអ្វីពួកគេដែរ ។ ប៉ុន្តែក្នុងរយៈពេល២សប្តាហ៍ កន្លងមកនេះ កងទ័ពវៀតកុង-វៀតណាមខាងជើង បានពង្រីកសកម្មភាពទ័ពព្រៃរបស់ពួកគេ ហើយកំពុងប្រមូលផ្តុំកងទ័ពពិសេសរបស់ពួកគេ នៅតាមទីតាំងទាំងអស់នេះបន្ថែមទៀត ដូចជនរួមជាតិយើងបានឃើញនៅក្នុងផែនទីនេះស្រាប់ គឺពួកគេកំពុងបង្កើតកម្លាំង ដើម្បីបើកការវាយប្រហារជាទ្រង់ទ្រាយធំមកលើកងទ័ពរបស់យើង និងវៀតណាមខាងត្បូង ។*

ប្រធានាធិបតី និចសុន បានបញ្ជាក់ថា ២សប្តាហ៍កន្លងមកនេះ កងទ័ពវៀតកុង-វៀតណាមខាងជើង មិនលាក់ពុតត្បុតធ្វើជាគោរពអធិបតេយ្យភាព និងអព្យាក្រឹតភាពរបស់កម្ពុជា ដូចមុនៗទៀតទេ គឺកងទ័ពពួកគេរាប់ម៉ឺននាក់កំពុងតែឈ្លានពានប្រទេសកម្ពុជា និងឡោមព័ទ្ធទីក្រុងភ្នំពេញ ជាចំហទៀតផង។ ដូច្នេះហើយ បានជារដ្ឋាភិបាលក្រុងភ្នំពេញ បានប្រកាសអំពាវនាវមកសហរដ្ឋអាមេរិក និងបណ្តាប្រទេសផ្សេងៗទៀត ដើម្បីរកជំនួយ ព្រោះថាបើពួកវៀតកុង ទទួលជ័យជម្នះនោះកម្ពុជា នឹងក្លាយជាសម្បុកមួយយ៉ាងធំរបស់ពួកគេ សម្រាប់ឈានទៅវាយប្រហារប្រទេសវៀតណាមខាងត្បូង និងក្លាយជាជម្រកដែលពួកគេអាចដកថយពីការប្រយុទ្ធដោយគ្មានភ័យខ្លាចការវាយបករបស់យើងវិញ ។

ជាមួយគ្នានេះ កងទ័ព និងគ្រឿងសម្ភារបរិក្ខារផ្សេងៗ របស់វៀតណាមខាងជើង ក៏អាចហូរស្រោចទៅក្នុងប្រទេសវៀតណាមខាងត្បូង ដែលអាចបង្កគ្រោះថ្នាក់ មិនត្រឹមតែមកលើជីវិតកងទ័ពអាមេរិក យើងប៉ុណ្ណោះទេ គឺថែមទាំងបង្កគ្រោះថ្នាក់លើប្រជាជនវៀតណាមខាងត្បូង ទៀតផង ។

ប្រឈមមុខនឹងបញ្ហានេះយើងមានជម្រើស៣ គឺ៖

ទី១.បើយើងមិនធ្វើអ្វីសោះ បន្ទាប់ពីយើងដកកងទ័ពលើកក្រោយចំនួន ១៥០.០០០នាក់ទៀត ចេញពីវៀតណាមខាងត្បូងនោះ ជីវិតកងទ័ពរបស់យើង ដែលមិនទាន់ដកចេញ នឹងត្រូវរងនូវការគំរាមកំហែងជាមិនខាន ។

ប្រធានាធិបតី និចសុន បានបន្ថែមថា សូមក្រឡេកមើលផែនទីម្តងទៀត! នេះជាប្រទេសវៀតណាមខាងត្បូង ហើយនេះគឺវៀតណាមខាងជើង ។ កងទ័ពវៀតណាមខាងជើង បានកាន់កាប់ផ្នែកមួយនេះ នៅក្នុងប្រទេសឡាវ រួចទៅហើយ ។ ដូច្នេះ បើវៀតណាមខាងជើង បានកាន់កាប់ប្រទេសកម្ពុជា ផ្នែកមួយទៀត ឬបានកាន់កាប់ប្រទេសកម្ពុជា ទាំងមូលនោះ មានន័យថា វៀតណាមខាងត្បូង ត្រូវហ៊ុមព័ទ្ធជិតទាំងស្រុង នឹងត្រូវរងការវាយបកពីក្រោយ ហើយកងទ័ពអាមេរិក ក៏ដូចជាកងទ័ពវៀតណាមខាង

ត្បូង ដែរ ត្រូវស្ថិតនៅក្នុងស្ថានភាពមួយ ដែលមិនអាចទប់ទល់បាន ។

ទី២. យើងត្រូវតែផ្តល់ជំនួយយោធាឱ្យបានច្រើនដល់ប្រទេសកម្ពុជា ដោយផ្ទាល់ ។ តែឥឡូវនេះ នៅពេលយើងមានមនោសញ្ចេតនាដ៏ជ្រាលជ្រៅចំពោះការផ្តល់ជំនួយដល់ប្រជាជនកម្ពុជា ៧លាននាក់ ដែលកំពុងរងនូវការឈ្លានពាន របស់វៀតណាមខាងជើងនោះ បែរជាជំនួយយោធាដ៏ច្រើនសន្ធឹកសន្ធាប់នោះមិនអាចយកទៅប្រើប្រាស់បានរហ័សទាន់ចិត្ត និងមានប្រសិទ្ធភាពភ្លាមៗទៅវិញ ។

យើងនឹងខិតខំប្រឹងប្រែងឱ្យអស់ពីសមត្ថភាព ដើម្បីផ្តល់អាវុធធុនស្រាល និងសម្ភារសឹកផ្សេងៗទៀតដល់កងទ័ពកម្ពុជា ២០០០០នាក់ សម្រាប់ការពារខ្លួន ។ ប៉ុន្តែជំនួយនេះ គ្រាន់តែសម្រាប់ឱ្យកម្ពុជា មានសមត្ថភាពការពារ អព្យាក្រឹតភាពរបស់ខ្លួនប៉ុណ្ណោះ មិនមែនដើម្បីគោលបំណងយកទៅបង្ករឿងនោះទេ ។

ទី៣. យើងត្រូវចូលជ្រៅទៅក្នុងបញ្ហា មានន័យថា យើងត្រូវតែបោសសម្អាតទឹកដី ដែលកាន់កាប់ដោយកងទ័ព វៀតកុង-វៀតណាមខាងជើង ដែលជាមូលដ្ឋានសម្រាប់ការវាយប្រហារទៅលើកងទ័ពកម្ពុជា និងកងទ័ពអាមេរិក ព្រមទាំងកងទ័ពវៀតណាមខាងត្បូង ផងដែរ ។ ទីតាំងកងទ័ពវៀតកុង-វៀតណាមខាងជើងទាំងនោះ គឺស្ថិតនៅជិតក្រុងសាយហ្គន( ក្រុងព្រៃនគរ) តែម្តង ។ ឧទាហរណ៍ទីតាំងមួយមានឈ្មោះថាតំបន់ចំពុះទា( ខេត្តស្វាយរៀង) គឺស្ថិតចម្ងាយប្រមាណតែ៣០ម៉ៃល៍ប៉ុណ្ណោះពីទីក្រុងសាយហ្គន ។

ប្រធានាធិបតីនិចសុន បន្ថែមទៀតថា ឥឡូវនេះ ខ្ញុំសម្រេចចិត្តយកជម្រើសទាំង៣នេះ។ កងទ័ពយើងសហការជាមួយកងទ័ពវៀតណាមខាងត្បូង ចាប់ផ្តើមបើកការវាយប្រហារនៅក្នុងដើមសប្តាហ៍នេះ ដើម្បីបោសសម្អាតពួកកុម្មុយនិស្តនៅតាមបណ្តោយព្រំដែនកម្ពុជា-វៀតណាម ។

កងទ័ពវៀតណាមខាងត្បូង ត្រូវទទួលខុសត្រូវមួយផ្នែកធំសម្រាប់ប្រតិបត្តិការផ្នែកជើងគោក។ ចំណែក កងទ័ព អាមេរិក ជាអ្នកគាំទ្រផ្នែកជើងអាកាស និងភ័ស្តុភារ ។

ទោះយ៉ាងណា តំបន់មួយស្ថិតនៅខាងលើតំបន់ចំពុះទា គឺតំបន់ផ្ទៃសន្ទូច ( នៅក្នុងទឹកដីកម្ពុជា) ដែលកងទ័ពអាមេរិក និងកងទ័ពវៀតណាមខាងត្បូង បើកប្រតិបត្តិការ រួមគ្នានោះ វាមានសារៈសំខាន់ណាស់ ហើយយប់នេះ កងទ័ពអាមេរិក និងវៀតណាមខាងត្បូង នឹងបើកការវាយប្រហារ ទៅលើបញ្ជាការដ្ឋានពួកវៀតណាមកុម្មុយនិស្តទាំងអស់ ដែលស្ថិតនៅក្នុងទឹកដីវៀតណាមខាងត្បូង អស់រយៈពេល៥ឆ្នាំមកហើយ ផងដែរ ។ ជាការពិតហើយ ដែលប្រជាពលរដ្ឋអាមេរិកភាគច្រើនចង់ឱ្យដកកងទ័ពអាមេរិក ចេញពីប្រទេសវៀតណាមខាងត្បូង តែជម្រើសរបស់ខ្ញុំយប់នេះ ក៏ជាការចាំបាច់មួយសម្រាប់កម្មវិធីដកកងទ័ពយើង ចេញពីវៀតណាមខាងត្បូង ប្រកបដោយជោគជ័យ ។

ប្រជាពលរដ្ឋអាមេរិកភាគច្រើន ចង់បញ្ចប់សង្គ្រាមនៅវៀតណាម ជាជាងបន្តទុកឱ្យនៅរ៉ាំរ៉ៃ។ យ៉ាងណាមិញ ក៏ការសម្រេចរបស់ខ្ញុំនៅយប់នេះ ក៏ដើម្បីសម្រេចគោលបំណងនេះដែរ ។

នៅយប់ថ្ងៃទី០១ ខែឧសភា ឆ្នាំ១៩៧០ កងទ័ពពិសេសរបស់ខ្មែរកម្ពុជាក្រោម ជាង៦០០០នាក់ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់សហរដ្ឋអាមេរិក នៅក្នុងប្រទេសវៀតណាមខាងត្បូង ត្រូវបានដឹកជញ្ជូនតាមយន្តហោះជាច្រើនគ្រឿង ពីខេត្តបៀងហ័រ មកទីក្រុងភ្នំពេញ ដើម្បីជួយធ្វើអន្តរាគមន៍ទាហានរដ្ឋាភិបាលលន់ នល់ ដែលកំពុងបាក់ទ័ពនៅគ្រប់សមរភូមិ ។

កងទ័ពពិសេសនេះ អ្នកខ្លះហៅថា កងទ័ពម៉ៃហ្គក ឬកងទ័ពកន្សែងស ខ្លះថាកងទ័ពរបស់សឺង ង៉ុកថាញ់ ស្លៀកពាក់ឯកសណ្ឋាន កាន់អាវុធទំនើបៗ និងសម្បូរស្បៀងអាហារ ដូចកងទ័ពអាមេរិក ដែរ ។

នៅថ្ងៃ០២ ខែឧសភា ឆ្នាំ១៩៧០ រដ្ឋាភិបាលវៀតណាមខាងជើង ក៏បានចេញសេចក្តីប្រកាសមួយប្រឆាំងនឹងសេចក្តីថ្លែងការណ៍របស់ប្រធានាធិបតីនិច សុន កាលពីថ្ងៃទី៣០ ខែមេសា ដែលបានបញ្ជាឱ្យកងទ័ពអាមេរិក ចូលមកវាយប្រហារប្រទេសកម្ពុជានោះថា ជាទង្វើឥតអៀនខ្មាស ។

សេចក្ដីប្រកាសនោះបានបញ្ជាក់ថា នៅថ្ងៃទី២៩ និង៣០ ខែមេសា ពួកចក្រពត្តិអាមេរិក បានប្រមូលផ្ដុំកងទ័ពខ្លួន និងកងទ័ពអាយ៉ងធីវ គី ដ៏ច្រើនសន្ធឹកសន្ធាប់ មានទាំងកងទ័ពជើងគោក កងរថក្រោះ និងយន្តហោះបេ៥២(B-52) បើកការវាយប្រហារជាទ្រង់ទ្រាយធំចូលជ្រៅមកក្នុងទឹកដីកម្ពុជា ។

នេះជាការឈ្លានពានយ៉ាងចេញមុខ និងកំរោលបំផុតរបស់ពួកចក្រពត្តិអាមេរិកទៅលើឯករាជ្យ និងអព្យាក្រឹតភាពរបស់កម្ពុជា និងបានជាន់ឈ្លីទៅលើកិច្ចព្រមព្រៀងក្រុងហ្សឺណែវ ឆ្នាំ១៩៥៤ ស្ដីពីបញ្ហាឥណ្ឌូចិន ។

សេចក្ដីប្រកាសនោះបានបញ្ជាក់ថា នេះជាការដំឡើងថ្នាក់សង្គ្រាមប្រកបដោយគ្រោះថ្នាក់បំផុត នៅពេញឥណ្ឌូចិនទាំងមូល ដែលជាការគំរាមកំហែងដ៏ធ្ងន់មួយចំពោះសន្តិភាពនៅអាស៊ីអាគ្នេយ៍ និងចំពោះសន្តិភាពពិភពលោកទាំងមូល ហើយនេះជាការប្រមាថដោយឥតកោតក្រែងទៅលើបណ្ដាប្រទេស ដែលស្នេហាសន្តិភាព និងយុត្តិធម៌ ហើយក៏ជាការមានះដោយគ្មានការអៀនខ្មាសចំពោះពលរដ្ឋសហរដ្ឋអាមេរិក ដែលកំពុងទាមទារឱ្យរដ្ឋការនិចសុន បញ្ឈប់អំពើឈ្លានពានរបស់ខ្លួន និងដកកងទ័ពចេញឱ្យអស់ពីឥណ្ឌូចិន ផងដែរ ។

ដើម្បីបំភាន់មតិសាធារណៈនៅលើពិភពលោក ក៏ដូចជាប្រជាពលរដ្ឋអាមេរិក និងដើម្បីបិទបាំងអំពើឈ្លានពាន និងការពង្រីកសង្គ្រាមរបស់ខ្លួន ប្រធានាធិបតីនិចសុនបានបង្កើនការមួលបង្កាច់ទៅលើសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម គ្រប់បែបយ៉ាង ។ មិនតែប៉ុណ្ណោះ ប្រធានាធិបតីនិចសុន បានយកលេសថា ការវាយប្រហារមកលើប្រទេសកម្ពុជា នេះ គឺដើម្បីការពារអាយុជីវិតកងទ័ពអាមេរិក និងដើម្បីបញ្ចប់សង្គ្រាមនៅវៀតណាមខាងត្បូង ក្នុងពេលឆាប់ៗ ទៅវិញ ។

សេចក្ដីប្រកាសដដែល បានបន្តថា នរណាក៏ដឹងដែរថា រយៈពេល១៥ឆ្នាំកន្លងមកនេះ ចក្រពត្តិអាមេរិក បានធ្វើវិច្ឆេទកម្មទៅលើឯករាជ្យ សន្តិភាព អព្យាក្រឹតភាពរបស់ប្រទេសកម្ពុជា ក្នុងបំណងប្រែក្លាយប្រទេសនេះ ឱ្យទៅជាប្រទេសអាណានិគមបែបថ្មី

និងទៅជាមូលដ្ឋានយោធារបស់ខ្លួន ។

ក្រោយរដ្ឋប្រហារ ដែលដឹកនាំដោយចក្រពត្តិអាមេរិក ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ មក កងទ័ពអាមេរិក បានចាប់ផ្តើមបើកការវាយប្រហារទៅលើប្រទេសកម្ពុជា ដើម្បីសម្រេចមហិច្ឆតារបស់ខ្លួនដូចខាងលើ ។

ជាការឆ្លើយតបចំពោះការអំពាវនាវជាប្រវត្តិសាស្ត្ររបស់សន្និសីទកំពូលប្រជាជនឥណ្ឌូចិន ក្នុងការប្រឆាំងចំពោះការឈ្លានពានរបស់ចក្រពត្តិអាមេរិក ប្រជាជនទាំង៣ វៀតណាម កម្ពុជា និងលាវ ប្តេជ្ញាពង្រឹងសាមគ្គីភាព និងបង្កើនការប្រយុទ្ធកម្ចាត់ពួកឈ្លានពានអាមេរិក ឱ្យកាន់តែខ្លាំងក្លាបន្ថែមទៀត រហូតដណ្តើមបានជ័យជម្នះទាំងស្រុង ។

ចុងក្រោយនៃសេចក្តីប្រកាសនោះ បានលើកឡើងថា ដើម្បីសម្រេចនូវបណ្តាំដ៏ថ្លៃថ្លារបស់លោកប្រធានហូ ( ហូ ជីមិញ) ប្រជាជនវៀតណាម សូមប្តេជ្ញាដាច់ខាតបង្កើនការតស៊ូប្រឆាំងនឹងពួកឈ្លានពានអាមេរិក ដើម្បីសង្គ្រោះជាតិ និងគាំទ្រយ៉ាងពេញទំហឹងចំពោះបុព្វហេតុតស៊ូដ៏ត្រឹមត្រូវរបស់ប្រជាជនកម្ពុជា និង ប្រជាជនឡាវ ជាបងប្អូនផងដែរ ។

# ២៨២
# ទាហានលន់ នល់ សម្លាប់ និងបញ្ជូនអាណិកជនវៀតណាម ចេញពីទឹកដីកម្ពុជា




ទាហានលន់ នល់ ដើរប្រមូលអាណិកជនវៀតណាម យកទៅទុកមួយកន្លែង

ចាប់ពីដើមខែមេសា ឆ្នាំ១៩៧០មក ដោយយល់ឃើញថា អាណិកជនវៀតណាម ទាំងអស់ ដែលរស់នៅក្នុងប្រទេសកម្ពុជា សុទ្ធតែជាកម្លាំងបង្កប់របស់ពួកវៀតកុង-វៀតណាមខាងជើង និងជនជាតិវៀតណាម ទាំងអស់ជាសត្រូវស្បូពូជដូចគ្នានោះ រដ្ឋាភិបាលរបស់លន់ នល់ ក៏បានចាប់ផ្តើមសម្លាប់រង្គាលទៅលើអាណិកជនវៀតណាម នៅទូទាំងប្រទេស ។ បើតាមអ្នកសង្កេតការណ៍អន្តរជាតិ បានប៉ាន់ស្មានថា ក្នុងអំឡុងខែមីនា ឆ្នាំ១៩៧០នោះ ជនជាតិវៀតណាម ក្នុងប្រទេសកម្ពុជា មានប្រមាណ៤០០,០០០នាក់ ។

ជាមួយគ្នានោះដែរ លន់ នល់ សង្ឃឹមថា នឹងអាចយកប្រជាជនវៀតណាម ដែលកំពុងរស់នៅក្នុងប្រទេសកម្ពុជា ធ្វើជាចំណាប់ខ្មាំង ដើម្បីប្រឆាំងនឹងពួកវៀតកុង-វៀតណាមខាងជើង ផងដែរ។ នៅគ្រប់ខេត្តក្រុងទូទាំងប្រទេសកម្ពុជា ទាហានរដ្ឋាភិបាល

នាំគ្នាដើរប្រមូលជនជាតិវៀតណាម ឱ្យមកនៅជុំគ្នាតាមជំរំប្រមូលផ្តុំរៀងៗខ្លួន ។

នៅខេត្តតាកែវ និងស្វាយរៀង ជនជាតិវៀតណាមជាច្រើនរយនាក់ ត្រូវបានពួកទាហានរដ្ឋាភិបាល ប្រមូលយកមកបង្ខាំងទុកនៅក្នុងទីធ្លាស្រឡះមួយ ដែលមានរបងបន្លាលួសហ៊ុមព័ទ្ធជុំវិញ។ បន្ទាប់មក ពួកគេក៏ត្រូវទាហានរដ្ឋាភិបាល យកទៅបាញ់សម្លាប់អស់មួយចំនួន ។



ជំរំឃុំឃាំងជនជាតិវៀតណាមនៅប្រសូត
ខេត្តស្វាយរៀង ខែមេសា ១៩៧០

ពួកអ្នកកាសែតបរទេស ពិសេសពួកកាសែតអាមេរិក ដែលបានឃើញហេតុការណ៍ផ្ទាល់ភ្នែក បានផ្ញើព័ត៌មាននេះ ទៅចុះផ្សាយនៅពាសពេញពិភពលោក ។

ប៉ុន្តែសាធារណមតិអន្តរជាតិខ្លះចាត់ទុកថា ការសម្លាប់នេះជាបាតុភូតធម្មតា សម្រាប់សង្គ្រាមនៅទ្វីបអាស៊ីប៉ុណ្ណោះ ។

នៅទីក្រុងភ្នំពេញ ដោយសារការសែតក្នុងស្រុកភាគច្រើនចុះផ្សាយអត្ថបទញុះញង់ និងវិទ្យុជាតិបានផ្សព្វផ្សាយពីប្រវត្តិបាត់បង់ទឹកដីកម្ពុជាក្រោម, ប្រវត្តិកំពប់តែអុង...ជាដើម ប្រជាជនខ្មែរភាគច្រើនបានសម្តែងការអបអរសាទរ និងលើកទឹកចិត្តឱ្យពួកទាហានរដ្ឋាភិបាលសម្លាប់ជនជាតិវៀតណាមទាំងនោះ ថែមទៀត ។

កងទាហានជើងទឹក ដែលមានមូលដ្ឋាននៅជ្រោយចង្វារ ក៏បានចាប់ផ្តើមសម្លាប់បុរសជាជនជាតិវៀតណាម ម្តុំវិហារកាតូលិក នៅក្បែរផ្សារតូច ។

នៅថ្ងៃទី១៥ ខែមេសា កាសែតជាតិ និងអន្តរជាតិមួយចំនួន ក៏បានចុះផ្សាយអត្ថបទ និងរូបថតសាកសពជនជាតិវៀតណាម សរុបប្រមាណ៨០០នាក់ ដែលសាកសពខ្លះត្រូវកាត់ក្បាល និងដៃជាប់ចំណង អណ្តែតត្រៀបត្រានៅតាមដងទន្លេសាប

និងនៅតាមដងទន្លេមេគង្គ ពិសេសនៅតំបន់អ្នកលឿង ធ្វើឱ្យប្រជាពលរដ្ឋនៅទីនោះ ជួបការលំបាកក្នុងការប្រើប្រាស់ទឹកទន្លេផងដែរ។ អង្គការ និងសមាគមអន្តរជាតិជាច្រើន ក៏បានធ្វើដំណើរមកប្រទេសកម្ពុជា ដើម្បីស្រាវជ្រាវពីបញ្ហាសម្លាប់រង្គាលនេះ។





សាកសពជនជាតិវៀតណាម អណ្តែតទឹកទន្លេនៅកំពង់ចម្លងអ្នកលឿង

មន្ត្រីស្ថានទូតបណ្តាប្រទេសផ្សេងៗនៅទីក្រុងភ្នំពេញ ក៏បានធ្វើរបាយការណ៍ទៅឱ្យរដ្ឋាភិបាលពួកគេ ឱ្យបានដឹងពីបញ្ហានេះដែរ ពិសេសបុរីវ៉ាទីកង់ ដែលជាកន្លែងសម្តេចប៉ាប បិតាសាសនាគ្រិស្តគង់នៅនោះ ក៏បានសម្តែងនូវការរំជួលចិត្តបំផុត ចំពោះការសម្លាប់រង្គាលជនជាតិវៀតណាម ដែលជាអ្នកកាន់សាសនាគ្រិស្តនៅកម្ពុជា នេះដែរ។

រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម( វៀតណាមខាងជើង) បានប្រកាសថ្កោលទោសការសម្លាប់រង្គាលនោះថា នេះជាអំពើហ្វាស៊ីស្តនិយមរបស់ពួកក្បត់លន់ នល់ សិរិមតៈ។

ដោយឡែក រដ្ឋាភិបាលសាធារណរដ្ឋវៀតណាម ( វៀតណាមខាងត្បូង) ដែលជាគូសត្រូវវៀតណាមខាងជើង មិនសូវមានប្រតិកម្មអ្វីខ្លាំងក្លាប៉ុន្មានទេ ព្រោះរដ្ឋាភិបាលវៀតណាម ដែលគាំទ្រដោយសហរដ្ឋអាមេរិក មួយនេះ កំពុងរៀបចំផ្សារទំនាក់ទំនង

ការទូតជាមួយរដ្ឋាភិបាលលន់ នល់ ដើម្បីក្លាយជាសម្ព័ន្ធមិត្រនឹងគ្នា។ ប៉ុន្តែ ពួកអ្នកជាតិនិយមនៅក្នុងប្រទេសវៀតណាមខាងត្បូង បានចេញមុខប្រឆាំងនឹងរដ្ឋាភិបាលលន់ នល់ យ៉ាងគគ្រឹកគគ្រេង ហើយថែមទាំងបានប្រកាសដោយកំហឹងថា ពេលវេលាក្នុងការជម្រះបញ្ជីជាមួយកម្ពុជា ក្នុងការសម្លាប់រង្គាលនេះបានមកដល់ហើយ។ ជាមួយគ្នានោះ ពួកគេក៏បាននាំគ្នាធ្វើបាតុកម្ម និងកាន់កាប់អតីតស្ថានទូតកម្ពុជា នៅទីក្រុងព្រៃនគរ ដែលបានបិទទ្វារអស់រយៈពេល៦ឆ្នាំមកហើយនោះ ផងដែរ ។

លន់ នល់ បានថ្លែងបញ្ជាក់ទៅរដ្ឋាភិបាលក្រុងសាយហ្គន (វៀតណាមខាងត្បូង) ថា៖ វាគឺជារឿងពិបាកណាស់ ក្នុងការបែងចែករវាងជនជាតិវៀតណាម ពិតប្រាកដជាមួយនឹងជនជាតិវៀតណាម ជាកម្លាំងបង្កប់របស់ពួកវៀតកុង-វៀតណាមខាងជើង ។ ដូច្នេះ ពួកជនជាតិវៀតណាម ដែលត្រូវទាហានគាត់សម្លាប់នោះ សុទ្ធតែជាកម្លាំងបង្កប់របស់ពួកវៀតកុង-វៀតណាមខាងជើង ពិតប្រាកដ ដោយមានអាវុធកាន់នៅក្នុងដៃទៀតផង ។

រដ្ឋាភិបាលលន់ នល់ បានបដិសេធថា ពុំមានការសម្លាប់រង្គាលណាមួយទៅលើអាណិកជនវៀតណាម ដូចការចុះផ្សាយរបស់ពួកអ្នកការសែតមួយចំនួន ដែលមានចេតនាមួលបង្កាច់សភាពការណ៍នៅកម្ពុជា នោះឡើយ។ រដ្ឋាភិបាលលន់ នល់ បានធ្វើការបកស្រាយបំភ្លឺថា ពួកអាណិកជនវៀតណាម ដែលស្លាប់អណ្តែតត្រៀបត្រា លើផ្ទៃទឹកទន្លេសាប និងទន្លេមេគង្គនោះ គឺជាហេតុការណ៍គ្រោះថ្នាក់លិចកាណូត ដោយសារឧបាយកលរបស់ពួកវៀតកុង-វៀតណាមខាងជើង... ។

ដោយសារមានប្រតិកម្មជាបន្តបន្ទាប់ពីសាធារណមតិអន្តរជាតិ ឧត្តមសេនីយ៍ លន់ នល់ ក៏បានបញ្ជាឱ្យបញ្ឈប់សកម្មភាពសម្លាប់រង្គាលនោះ។ ប៉ុន្តែ គាត់បានបញ្ជាឱ្យបង្កើតកន្លែងប្រមូលផ្តុំជនជាតិវៀតណាម នៅក្នុងខេត្តមួយចំនួន ពិសេស នៅក្នុងទីក្រុងភ្នំពេញ គាត់បានបញ្ជាឱ្យបង្កើតជំរំប្រមូលផ្តុំដ៏ធំមួយ នៅក្នុងបរិវេណវិហារកាតូលិក ក្បែរគល់ស្ពានជ្រោយចង្វាត្រើយខាងលិច ( ត្រង់វិទ្យាល័យវត្តភ្នំ សព្វថ្ងៃ)

ដើម្បីបញ្ជូនពួកគេឱ្យធ្វើមាតុភូមិនិវត្តន៍ ទៅប្រទេសវៀតណាមខាងត្បូង វិញ ។

ជនជាតិវៀតណាមទាំងអស់ ត្រូវបង្ខំចិត្តលក់ផ្ទះសម្បែង រថយន្ត ម៉ូតូ កង់ និង គ្រឿងសង្ហារិមផ្សេងៗ ក្នុងតម្លៃថោកៗ និងចាកចេញទៅជាមួយបង្វេចសម្លៀកបំពាក់ វត្ថុមានតម្លៃ ( មាស ប្រាក់ )និងវត្ថុប្រើប្រាស់ចាំបាច់បន្តិចបន្តួចប៉ុណ្ណោះ ទៅស្នាក់នៅ ក្នុងជំរំ ប្រមូលផ្តុំបណ្តោះអាសន្នមួយរយៈ ដើម្បីរង់ចាំនាវាធំៗមកដឹកជញ្ជូនយកទៅ ឱ្យរស់នៅវៀតណាមខាងត្បូង វិញ ។

នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៧០ ប្រធានាធិបតីវៀតណាមខាងត្បូង ង្វៀន វ៉ាន់ធីវ បានចាត់ឱ្យរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ត្រាន់ ង៉ុកកៀវ ដឹកនាំគណៈប្រតូភូមួយ ក្រុម ធ្វើដំណើរមកក្រុងភ្នំពេញ ដើម្បីចរចាជាមួយរដ្ឋាភិបាលលន់ នល់ ពីបញ្ហា បញ្ជូនអាណិកជនវៀតណាម ដែលកំពុងប្រមូលផ្តុំនៅតាមជំរំនានា ឱ្យវិលត្រលប់ទៅ រស់នៅប្រទេសវៀតណាមខាងត្បូង និងរៀបចំភ្ជាប់ទំនាក់ទំនងការទូតជាមួយគ្នាវិញ ផងដែរ ។

គណៈប្រតិភូវៀតណាមខាងត្បូង ក៏បានចុះទៅសួរសុខទុក្ខនៅជំរំប្រមូលផ្តុំជន ជាតិវៀតណាម នៅវិហារ កាតូលិក ក្បែរគល់ស្ពានជ្រោយចង្វាត្រើយខាង លិចនោះដែរ ។



រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចវៀតណាមខាងត្បូង ចុះទៅសួរសុខទុក្ខជនជាតិវៀតណាម

រដ្ឋាភិបាលលន់នល់ក៏បានយល់ ព្រមជាមួយគណៈប្រតិភូវៀតណាម ខាងត្បូងឱ្យកងនាវាចរណ៍របស់វៀត ណាមខាងត្បូង និងអាមេរិក ជាច្រើន គ្រឿង ចូលមកតាមទន្លេមេគង្គ ដើម្បី ដឹកជញ្ជូនជនជាតិវៀតណាមទាំងអស់ ដែលនៅក្នុងជំរំប្រមូលផ្តុំនៅទីក្រុង

ភ្នំពេញ និងនៅខេត្តកំពង់ចាម យកទៅប្រទេសវៀតណាមខាងត្បូង វិញ ។

គណៈប្រតិភូវៀតណាមខាងត្បូង ដែលដឹកនាំដោយរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ត្រាន់ ង៉ុកកៀវ នេះ ក៏បានបើកផ្លូវឱ្យមានជំនួបរវាងនាយករដ្ឋមន្ត្រី លន់ នល់ និងអនុប្រធានាធិបតីវៀតណាមខាងត្បូង ង្វៀន ការគី ដើម្បីពិភាក្សាគ្នា ពីបញ្ហាបញ្ជូនកងទ័ពវៀតណាមខាងត្បូង ឱ្យចូលជួយធ្វើអន្តរាគមន៍បើកប្រត្តិការសឹកវាយកម្ចាត់កងទ័ពវៀតកុង-វៀតណាមខាងជើង នៅលើទឹកដីកម្ពុជា ផងដែរ ។

នៅពាក់កណ្ដាលខែឧសភា ឆ្នាំ១៩៧០ នាវាចម្បាំងធំៗរបស់សហរដ្ឋអាមេរិក និងវៀតណាមខាងត្បូង អមការពារដោយនាវាចម្បាំងតូចៗជាច្រើនគ្រឿងបានធ្វើដំណើរចូលមកប្រទេសកម្ពុជា តាមច្រកទ្វារទន្លេមេគង្គ ក្អមសំណ ឆ្ពោះមកទីក្រុងភ្នំពេញ ដើម្បីមកដឹកជញ្ជូនជនជាតិវៀតណាម យកទៅប្រទេសកំណើតរបស់ពួកគេវិញ ។

នៅតាមដងទន្លេមេគង្គ ក្បួននាវាចម្បាំងនោះ ត្រូវរងការបាញ់រះខ្ទះៗដែរ ពីសំណាក់កងទ័ពវៀតកុង-វៀតណាមខាងជើង ប៉ុន្តែកងទ័ពវៀតណាមខាងត្បូង បានធ្វើការបាញ់តបតវិញ ព្រមទាំងបានដុតផ្ទះសម្បែង និងលួចប្លន់ទ្រព្យសម្បត្តិប្រជាជនខ្មែរដែលរស់នៅតាមដងទន្លេមេគង្គនោះ ផងដែរ ។

តែទោះបីយ៉ាងនេះក៏ដោយ ក៏ការដឹកជញ្ជូនជនជាតិវៀតណាម ដើម្បីធ្វើមាតុភូមិនិវត្តន៍ទាំងអស់នោះគ្មានអ្វីមករាំងស្ទះដែរ ។ ពេលទៅដល់ប្រទេសវៀតណាមភ្លាម យុវជនវៀតណាមជាច្រើនបានស្ម័គ្រចិត្តចូលបម្រើក្នុងជួរកងទ័ព រដ្ឋវៀតណាមខាងត្បូង ជាថ្នូរនឹងការសន្យារបស់រដ្ឋការក្រុងព្រៃនគរ ថានឹងបញ្ជូនពួកគេឱ្យចូលមកធ្វើសង្គ្រាមជាមួយពួកវៀតកុងនៅក្នុងទឹកដីខ្មែរវិញ ដើម្បីពួកគេមានឱកាសបានសងសឹកចំពោះជនជាតិខ្មែរ ដែលបានធ្វើបាប និងកាប់សម្លាប់ក្រុមគ្រួសារ និងសាច់ញាតិពួកគេនោះវិញ ។




រូបនាវាចម្បាំងនាវាវៀតណាម និងអាមេរិក
ចូលមកដឹកជញ្ជូនជនជាតិវៀតណាម យកទៅវៀតណាមខាងត្បូងវិញ

# ២៨៣
# សម្តេចសីហនុ បង្កើតរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ម៉ៅ សេទុង ថា ព្រះអង្គស័ក្តិសមជនកុម្មុយនិស្ត



សម្តេចសីហនុ និងម៉ៅ សេទុង

*បន្ទាប់ពីបង្កើតរណសិរ្សរួបរួមជាតិកម្ពុជា កាលពីនៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧០ មក នៅទីក្រុងប៉េកាំង ថ្ងៃទី០៥ ខែឧសភា ឆ្នាំ១៩៧០ សម្តេចសីហនុ បានព្រមព្រៀងគ្នា ជាមួយពួកមេដឹកនាំខ្មែរក្រហម បង្កើតរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា* ( GRUNK = Government Royal of the National Union of Kampuchea ) ។

*ដើម្បីកុំឱ្យសាធារណមតិអន្តរជាតិហៅរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ថា រាជរដ្ឋាភិបាលនិរទេស មេដឹកនាំចិន បានស្នើសុំបញ្ចូលឈ្មោះអ្នកតស៊ូនៅក្នុងប្រទេសកម្ពុជា ជាសមាជិកគណៈរដ្ឋមន្ត្រីចំនួនពាក់កណ្តាល និងអ្នកតស៊ូនៅក្រៅប្រទេសចំនួនប្រហាក់ប្រហែលគ្នាដែរ ។*

រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជានេះ រួមមាន ប៉ែន នុត ( នៅក្រុងប៉េកាំង)ជានាយករដ្ឋមន្ត្រី, ខៀវ សំផន ( នៅក្នុងប្រទេស)ជាឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការពារជាតិ, សុន សេន ( នៅក្នុងប្រទេស) ជាអនុរដ្ឋមន្ត្រីការពារជាតិ, គាត ឈន់( នៅក្រុងប៉េកាំង) ជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី, សារិន ឆាក ( នៅក្រុង ប៉េកាំង) ជារដ្ឋមន្ត្រីការបរទេស, រ៉ាន់ ពិនី ( នៅក្រុងប៉េកាំង) ជាអនុរដ្ឋមន្ត្រីការបរទេស ក្រោយមកដូរដាក់អៀង សារី ( នៅក្នុងប្រទេស)ជាអនុរដ្ឋមន្ត្រីការបរទេស, ហ៊ូ យន់ ( នៅក្នុងប្រទេស) ជារដ្ឋមន្ត្រីមហាផ្ទៃ សហករណ៍ និងកំណែ ទម្រង់សហគមន៍, ហ៊ូ នឹម ( នៅក្នុងប្រទេស) ជារដ្ឋមន្ត្រីក្រសួងឃោសនាការ, ទីវ អុល ( នៅក្នុងប្រទេស) ជាអនុរដ្ឋមន្ត្រីក្រសួងឃោសនាការ, ជួន មុម្ម ( នៅក្រុងប៉េកាំង)ជារដ្ឋមន្ត្រីសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, កុយ ធួន ( នៅក្នុងប្រទេស)ជាអនុរដ្ឋមន្ត្រីសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឧត្តមសេនីយ៍ ដួង សំអុល ជារដ្ឋមន្ត្រីសម្ភារបរិក្ខារ និងសាស្ត្រាវុធ ( ពេលនោះ ដួង សំអុល កំពុងសម្រាកព្យាបាលរោគនៅក្នុងមន្ទីរពេទ្យមួយ ក្នុងក្រុងប៉េកាំង) តែ ក្រោយមក ដូរដាក់ ម៉ែន សាន ហៅនៃ សាវ៉ាន់ ហៅយ៉ា ( នៅក្នុងប្រទេស) ជារដ្ឋមន្ត្រីសម្ភារបរិក្ខារ និងសាស្ត្រាវុធ វិញ , ជា សាន ( នៅក្រុងប៉េកាំង) អតីតឯកអគ្គរាជទូតប្រចាំសហភាពសូវៀត និងជាអ្នកកាន់សាសនាកាតូលិក ជារដ្ឋមន្ត្រីយុត្តិធម៌ តែក្រោយមក ដូរដាក់អ្នកអង្គម្ចាស់នរោត្តម ភូរិស្សារ៉ា ( នៅក្នុងប្រទេស)ជារដ្ឋមន្ត្រីយុត្តិធម៌ វិញ, ថៅ សេង ( នៅក្រុងប៉េកាំង) ជារដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស, ជួន ប្រាសិទ្ធ ( នៅក្រុងប៉េកាំង) រដ្ឋមន្ត្រីសម្របសម្រួល, តូច កឿន ( នៅក្នុងប្រទេស)ជារដ្ឋមន្ត្រីសាធារណការ និងទូរគមនាគមន៍, ជួន ជឿន ( នៅក្នុងប្រទេស) ជារដ្ឋមន្ត្រីសុខាភិបាល, ចាន់ យូរ៉ាន់ ( នៅក្រុងប៉េកាំង)ជារដ្ឋមន្ត្រីអប់រំ និងយុវជន, អៀង ធារិទ្ធ ( នៅក្នុងប្រទេស) ជាអនុរដ្ឋមន្ត្រីអប់រំ និងយុវជន, ង៉ោ ហ៊ូ នៅក្រុងប៉េកាំងអតីតឧត្តមសេនីយ៍កងទ័ពជើងអាកាស។ ជារដ្ឋមន្ត្រី សង្គមកិច្ច តែក្រោយមក ដូរដាក់ជូ ជេត ( នៅក្នុងប្រទេស)ជារដ្ឋមន្ត្រីសង្គមកិច្ច និងសាសនា, សុក ធួក ( វន វ៉េត)( នៅក្នុងប្រទេស) អនុរដ្ឋមន្ត្រីសន្តិសុខជាតិ ។

រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា មានទីស្នាក់ការកណ្ដាលនៅក្នុងសណ្ឋាគារមិត្តភាព ក្រុងប៉េកាំង ដែលបានសាងសង់ក្នុងទសវត្សរ៍ឆ្នាំ១៩៥០ ដើម្បីឱ្យទីប្រឹក្សាសូវៀត ស្នាក់នៅ ។

នៅថ្ងៃទី០៥ ឧសភា នោះដែរ រដ្ឋាភិបាលចិន ក៏បានប្រកាសផ្ដាច់ទំនាក់ទំនងការទូតជាមួយរដ្ឋាភិបាលលន់ នល់ ដែរ ។

ក្រោយពីបង្កើតរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាមក រដ្ឋាភិបាលលន់ នល់ ក៏ដូចជាមន្ត្រីស្ថានទូតអាមេរិកដែរ បានប្រកាសថា ខៀវ សំផន, ហ៊ូ យន់ និងហ៊ូ នឹម ត្រូវបានសម្ដេចសីហនុ បញ្ជាឱ្យគេយកទៅសម្លាប់នៅខេត្តកំពង់ស្ពឺ តាំងពីឆ្នាំ១៩៦៧ មកម្ល៉េះដូច្នេះពួកគេចាត់ទុកថានេះជាការបង្កើតរដ្ឋាភិបាលខ្មោច ដើម្បីបោកបញ្ឆោតពលរដ្ឋខ្មែរតែប៉ុណ្ណោះ ។

អ្នកខ្លះបានហៅខៀវ សំផន, ហ៊ូ យន់ និងហ៊ូ នឹម ថា ជាពួកបិសាចឬខ្មោចទាំងបី ព្រោះស្លាប់បាត់ទៅហើយ អាចមកធ្វើជាសមាជិករាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា របស់សម្ដេចសីហនុ បានទៀត ។

ក្រោយពីប្រកាសសមាសភាពរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា បានមួយថ្ងៃ សម្ដេចសីហនុ បានប្រកាសប្រាប់ក្រុមអ្នកសារព័ត៌មានថា រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ហៅកាត់ថាហ្រ្គុង (Grunk) នេះ ស្ថិតនៅក្រៅប្រទេស ក៏ពិតមែន តែបានចាក់ឫសទៅដល់ក្នុងប្រទេសកម្ពុជា ។ ទីបញ្ជាការកងទ័ពរបស់រាជរដ្ឋាភិបាលនេះ គឺស្ថិតនៅព្រៃម៉ាគី ក្នុងប្រទេសកម្ពុជា ។ តែយើងត្រូវបំពេញភារកិច្ចមួយចំនួននៅក្រៅប្រទេស ពិសេសប្រទេសចិន និងបណ្ដាប្រទេសមួយចំនួនទៀត ដែលគាំទ្រយើង ។ ពេលណាកម្លាំងតស៊ូនៅព្រៃម៉ាគី ស្នើឱ្យយើងត្រលប់ទៅមាតុប្រទេសវិញ យើងនឹងត្រលប់ទៅវិញ ។ ប៉ុន្តែពេលនេះ យើងពន្យារពេលវិលត្រលប់ទៅវិញ ដោយសារត្រូវបែងចែកភារកិច្ចគ្នា ។

យើងត្រូវគោរពវិន័យដោយធ្វើអ្វីតាមគោលការណ៍របស់រណសិរ្ស ។ ខ្ញុំមិនអាចនិយាយបានថា នឹងត្រូវទៅពេលណាបាននោះទេ ព្រោះវាជាការចាំបាច់ ដើម្បី

លាក់ការណ៍ខ្លះ ។ ខ្ញុំប្រហែលជាត្រូវទៅមូស្គូសិន តែមិនទាន់ច្បាស់ទេ ។ ក្រៅពីប្រទេសចិន ខ្ញុំនឹងទៅប្រទេសណា ដែលទទួលស្គាល់ខ្ញុំជាប្រមុខរដ្ឋរបស់ប្រទេសកម្ពុជា តែប៉ុណ្ណោះ ។

ទាក់ទងដល់បញ្ហាកងទ័ពវៀតកុង-វៀតណាមខាងជើង កំពុងបើកការវាយប្រហារពាសពេញប្រទេសកម្ពុជា ដើម្បីផ្តួលរម្លំមេដឹកនាំរដ្ឋប្រហារនៅភ្នំពេញ សម្តេចសីហនុ បានបដិសេធថា យើងមិនចង់ធ្វើជារណបរបស់ប្រទេសណាមួយទេ។ ជាការពិតហើយ យើងជាមិត្តរួមអាវុធរបស់វៀតណាម, ចិន និងកូរ៉េ។ យើងបានទទួលជំនួយពីមិត្តភក្តិ និងបងប្អូនទាំងនេះ ។ ជួនកាលកងទ័ពតស៊ូរបស់យើងទទួលការហ្វឹកហ្វឺននៅក្នុងជំរំទាំងឡាយ ដែលមិនស្ថិតនៅក្នុងប្រទេស ។

ពីសម័យមុន យើងត្រូវការគ្រូបារាំងនៅក្រុងភ្នំពេញ មកបង្ហាត់កងទ័ពរបស់យើង តែពេលនេះ គ្រូបង្ហាត់សុទ្ធតែមកពីប្រទេសជាមិត្ត( វៀតណាមខាងជើង)។ ពេលណាកងទ័ពយើងហ្វឹកហ្វឺនរួច ពួកគេនឹងចេញទៅប្រយុទ្ធ។ យើងសង្ឃឹមលើបណ្តាប្រទេសជាមិត្ត ដូចជាប្រទេសចិន ជាដើម ដែលផ្តល់ជំនួយសម្ភារៈចាំបាច់ ពិសេសគឺអាវុធ និងភ័ស្តុភារ ។

សម្តេចសីហនុ បានបញ្ជាក់ថា ខ្ញុំបានជំពាក់ចិត្តលើលទ្ធិកុម្មុយនិស្ត ប៉ុន្តែខ្ញុំមិនមែនជាជនកុម្មុយនិស្ត ហើយខ្ញុំក៏មិនមែនជាប្រមុខខ្មែរក្រហមដែរ ។ ខ្ញុំជាកូនសិស្សក្រហម ប៉ុន្តែពួកកុម្មុយនិស្តផ្ទិនផ្តៅ មិនអាចទទួលយកខ្ញុំបានទេ ខ្ញុំជាសិស្សក្រហមដែលខ្សោយបំផុត ព្រោះខ្ញុំមិនយល់ច្បាស់ពីអ្វីទៅដែលហៅថាកុម្មុយនិស្តទេ ។

សម្តេចសីហនុ បញ្ជាក់បន្ថែមថា ការពិត ខ្ញុំជាអ្នកជាតិនិយមប៉ុណ្ណោះ ខ្ញុំជាខ្មែរម្នាក់ដូចដូនតារបស់ខ្ញុំដែរ ។ បច្ចុប្បន្ននេះ ខ្ញុំជាមេដឹកនាំប្រជារាស្ត្ររបស់ខ្ញុំ ដូចប្រធានាធិបតីបារាំង ហ្សាលដឺហ្គោល ដឹកនាំប្រជាពលរដ្ឋបារាំង ដូចកាលក្នុង សង្គ្រាមលោកលើកទី២ដែរ ។ បន្ទាប់ពីលោកប្រធានម៉ៅ ( ម៉ៅ សេទុង) គឺ មានតែហ្សាល ដឺហ្គោល ទេ ដែលខ្ញុំចាត់ទុកថា ជាវីរបុរសដែលគួរឱ្យកោតសរសើរបំផុត ។

សម្តេចសីហនុ បានរម្លឹកថា កាលពីពេលថ្មីៗកន្លងនេះ ខ្ញុំបានជួបពិភាក្សាជាមួយលោកប្រធានម៉ៅ។ លោកប្រធាន ម៉ៅ បានថ្លែងថា គាត់សប្បាយរីករាយណាស់ ដែលបានខ្ញុំធ្វើជាមិត្តរបស់គាត់។ គាត់ថា ទោះបីខ្ញុំជាស្តេចក្តី ក៏ខ្ញុំមានភក្តីភាពចំពោះប្រជាជនរបស់ខ្ញុំដែរ ហើយគាត់ថា ខ្ញុំស័ក្តិសមជាជនកុម្មុយនិស្ត ព្រោះខ្ញុំជាមេដឹកនាំខ្លាំងម្នាក់។

នៅថ្ងៃទី០៦ ខែឧសភា រដ្ឋាភិបាលសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម( វៀតណាមខាងជើង), សាធារណរដ្ឋ ប្រជាធិបតេយ្យប្រជាមានិតកូរ៉េ ( កូរ៉េខាងជើង) និងសាធារណរដ្ឋប្រជាមានិតចិន ក៏បានប្រកាសព្រមៗ គ្នាទទួលស្គាល់ រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាថា ជារាជរដ្ឋាភិបាលស្របច្បាប់តែមួយគត់របស់ប្រទេសកម្ពុជា ។

ជាមួយគ្នានោះ រដ្ឋាភិបាលវៀតណាមខាងជើង ក៏មានគម្រោងយាងសម្តេចសីហនុ ក្នុងនាមជាប្រមុខរដ្ឋនៃប្រទេសកម្ពុជា ឱ្យទៅបំពេញទស្សនកិច្ចជាផ្លូវការមួយនៅទីក្រុងហាណូយ ផងដែរ ។ ប៉ុន្តែសហភាពសូវៀត ដែលជាមហាអំណាចកុម្មុយនិស្តមួយដែរនោះ ស្ថិតនៅក្នុងភាពស្ងាត់ស្ងៀម មិនមានប្រតិកម្មអ្វីចំពោះការបង្កើតរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា នោះទេ ព្រោះមន្ត្រីការទូតរបស់ខ្លួនកំពុងបំពេញការងារជាធម្មតានៅក្នុងទីក្រុងភ្នំពេញ នៅឡើយ ។

ថ្ងៃទី១១ ខែឧសភា ម៉ៅសេទុង បានជួបពិភាក្សាគ្នាជាមួយឡេ យន់ អគ្គលេខាធិការបក្សកុម្មុយនិស្តវៀតណាម ។ ឡេ យន់ បានប្រាប់មេដឹកនាំកំពូលចិនថា យើងខ្ញុំបានខិតខំប្រឹងប្រែងគ្រប់លទ្ធភាពដើម្បីប្រយុទ្ធតស៊ូ ហើយយើងមានលទ្ធភាពប្រយុទ្ធតស៊ូបានល្អដូចសព្វថ្ងៃនេះ ក៏ដោយសារយើងខ្ញុំអនុវត្តតាមការណែនាំរបស់សមមិត្តប្រធាន ( ប្រធានម៉ៅ) ដែលណែនាំដល់យើងខ្ញុំពីមុនមក គឺទី១-មិនឱ្យមានការខ្លាចញញើតចំពោះសត្រូវរបស់យើង។ ទី២-ត្រូវបំបែកបំបាក់សត្រូវឱ្យទៅជាដុំៗ និងទី៣-ត្រូវប្រយុទ្ធតស៊ូក្នុងសង្គ្រាមយូរអង្វែង ។

ម៉ៅ សេទុង បានតបទៅឡេ យន់ វិញថា មែនហើយ ដែលថាត្រូវធ្វើសង្គ្រាមយូរអង្វែងនោះ ប៉ុន្តែវាមិនប្រសើរទេឬ ប្រសិនបើសង្គ្រាមនោះ វាមានរយៈពេលខ្លី? តើន

រណាខ្ញាចនរណា? តើប្រជាជនវៀតណាមក្តី ប្រជាជនកម្ពុជាក្តី និងប្រជាជនផ្សេងៗទៀតនៅអាស៊ីក្តី ជាអ្នកខ្លាចពួកចក្រពត្តិអាមេរិក ឬពួកចក្រពត្តិអាមេរិក ជាអ្នកខ្លាចសមមិត្ត?។ នេះជាសំណួរដែលសមមិត្តគួរយកទៅសិក្សាពិចារណា ។

គឺមហាអំណាចទៅវិញទេ ដែលខ្លាចប្រទេសតូចតាច។ ពិតហើយដែលថាកាលក្នុងអំឡុងឧប្បត្តិហេតុនៅសមុទ្រតុងកឹង ក្នុងឆ្នាំ១៩៦៤ សមមិត្តមិនមានបំណងចេញមុខធ្វើការប្រយុទ្ធជាមួយកងនាវាអាមេរិក ទេ ប៉ុន្តែ គ្រាន់តែឮព័ត៌មានមិនច្បាស់ការណ៍មកថា កងនាវារបស់វៀតណាម បានចេញដំណើរមកប្រយុទ្ធទប់ទល់ស្រាប់តែកងនាវាអាមេរិកនោះ ភ័យស្ទន់ស្ទោ ដកថយទៅវិញអស់ ។

តាំងពីសង្គ្រាមចាប់ផ្តើមមក មិនដែលមានជម្រើសណាផ្សេង ក្រៅពីការប្រយុទ្ធឡើយ។ ពួកផលិតអាវុធ និងគ្រាប់រំសេវ ព្រមទាំងពួកឈ្មួញ កំពុងទទួលផលចំណេញយ៉ាងច្រើនពីសង្គ្រាម ហើយតាំងពីពេលមានសង្គ្រាមមក ប្រធានាធិបតីអាមេរិក ដេកយប់បានតិចបំផុត ។

ម៉ៅ សេទុង បន្តថា ឥឡូវនេះ មានមនុស្សម្នាក់ទៀត គឺសម្តេចសីហនុ ។ ព្រះអង្គមិនមែនជាមនុស្សដែលងាយស្រួលនឹងធ្វើការជាមួយនោះទេ ។ ពេលណាសមមិត្តហ៊ានបំពានទៅលើព្រះអង្គ ព្រះអង្គនឹងតបតវិញភ្លាមៗតែម្តង ។

ឡេ យន់ តបទៅម៉ៅ សេទុង ថា ប្រជាជនវៀតណាម នៅតែគោរពតាមដំបូន្មានល្អៗ របស់សមមិត្តប្រធានជានិច្ច ។ កាលអំឡុង៩ឆ្នាំនៃការធ្វើសង្គ្រាមប្រឆាំងនឹងបារាំងប្រសិនបើគ្មានការឧបត្ថម្ភគាំទ្រពីបក្សកុម្មុយនិស្តចិន និងសមមិត្តប្រធានទេ ប្រាកដជាយើងខ្ញុំមិនអាចដណ្តើមជ័យជម្នះបានឡើយ ហើយរហូតមកដល់ពេលនេះ យើងអាចបន្តការតស៊ូប្រយុទ្ធក្នុងសង្គ្រាមយូរអង្វែងនៅវៀតណាមខាងត្បូង បាននោះ ក៏ព្រោះតែយើងខ្ញុំបានពឹងពាក់សមមិត្តប្រធានដែរ។ ដូច្នេះ យើងចាំបាច់ត្រូវតែយកការណែនាំរបស់សមមិត្តប្រធានទៅច្នៃប្រតិដ្ឋ និងអនុវត្តតាមភាពជាក់ស្តែងរបស់ ប្រទេសយើងខ្ញុំ ។

ម៉ៅ សេទុង បានសរសើរថា សមមិត្តមានការច្នៃប្រតិដ្ឋខ្ពស់។ តើនរណាម្នាក់ដែល

ហ៊ាននិយាយថា សមមិត្តគ្មានការប្ដេជ្ញាប្រតិជ្ញ និងគ្មានបទពិសោធនោះ? ។

ង៉ូ ឌិញយៀម (អតីតៈប្រធានាធិបតីវៀតណាមខាងត្បូង) បានសម្លាប់ ប្រជាជនរបស់សមមិត្ត១៦០.០០០នាក់។ រឿងនេះគេបានរាយការណ៍មកឱ្យខ្ញុំ តែខ្ញុំដឹងថា មានត្រឹមតែ ១០០.០០០នាក់ ប៉ុណ្ណោះ ដែលត្រូវង៉ូ ឌិញយៀម សម្លាប់... ។

ឡេ យន់ ឆ្លើយបញ្ជាក់ទៅម៉ៅ សេទុង ថា ប្រជាជនយើងខ្ញុំ១៦០.០០០នាក់ ត្រូវបានពួកវាសម្លាប់ពិតមែន ហើយនៅមានច្រើនទៀត ត្រូវបានពួកវាចាប់ដាក់គុក ។

ម៉ៅ សេទុង ឆ្លើយទៅវិញថា ខ្ញុំគិតថា អ៊ីចឹងល្អហើយ ពួកគេអាចសម្លាប់ប្រជាជនយើងបាន ចុះហេតុអ្វី បានជាយើងមិនអាចសម្លាប់ពួកគេវិញបាន?

ឡេ យន់ ឆ្លើយភ្លាមថា មែនហើយ គ្រាន់តែនៅក្នុងឆ្នាំ១៩៦៩ យើងសម្លាប់ និងធ្វើឱ្យពួកវារបួស ៦១០.០០០នាក់ ក្នុងនោះ មានពួកអាមេរិក ២៣០.០០០នាក់ ។

ម៉ៅ សេទុង បន្តថា ពួកអាមេរិក មិនមានកម្លាំងមនុស្សគ្រប់គ្រាន់សម្រាប់បែងចែកពាសពេញពិភពលោកទេ ខណៈដែលពួកគេបានចំណាយលើសលប់រួចទៅហើយ ។

នៅពេលពួកគេស្លាប់ច្រើន ពួកគេប្រាកដជាបាក់ទឹកចិត្ត ព្រោះការស្លាប់ពួកគេរាប់សិបពាន់នាក់ ជារឿងអាម៉ាស់បំផុតសម្រាប់ពួកគេ ហើយទាំងប្រជាជនវៀតណាមខាងជើង ទាំងប្រជាជនវៀតណាមខាងត្បូង មិនអាចចៀសផុតពីការសម្លាប់បានទេ ។ អាស៊ីអាគ្នេយ៍ ប្រៀបដូចជាសម្បុកឪម៉ាល់មួយ ប្រជាជនអាស៊ីអាគ្នេយ៍កំពុងតែភ្ញាក់រលឹក ។

អ្នកសន្តិភាពនិយមខ្លះ យល់ថា មាន់ឈ្មោលចូលចិត្តជល់ជាងមាន់ញី ។ ចុះហេតុអ្វី បានជាមានមាន់ឈ្មោលចូលចិត្តជល់ច្រើនម្ល៉េះ? ប៉ុន្តែឥឡូវនេះ មាន់ញីក៏ចូលចិត្តជល់ដែរ។ ឡេ យន់ ឆ្លើយទៅម៉ៅ សេទុង ថា បើគេមិនប្រយុទ្ធ គឺគ្មានច្រកចេញទេ ។

ម៉ៅ សេទុង ពោលបន្ទរថា ពិតហើយ បើគេមិនប្រយុទ្ធ គឺគ្មានច្រកចេញទេ ។ អ្នកឯង (អាមេរិក) បង្ខំអ្នកដទៃឱ្យប្រយុទ្ធ តែមិនទុកច្រកឱ្យគេចេញផងទេ។ អ្នកឯងកំពុងតែធ្វើបាបគេ ។

ឡេ យន់ បន្ថែមថា ប្រជាជននៅកម្ពុជា និងនៅលាវ ជាអ្នកជឿជាក់លើព្រះពុទ្ធសាសនា ពួកគេមិនចូលចិត្តការប្រយុទ្ធទេ តែឥឡូវពួកគេបានក្លាយទៅជាអ្នកប្រយុទ្ធដែរហើយ ។

ម៉ៅ សេទុង ប្រាប់ទៅឡេ យន់ វិញថា នេះជាការពិត តែសមមិត្តមិនអាចនិយាយថា ពួកគេមិនចូលចិត្តការប្រយុទ្ធ ដោយសារតែពួកគេជឿលើព្រះពុទ្ធសាសនានោះបានទេ។ ប្រជាជនចិន ក៏ជឿលើព្រះពុទ្ធសាសនាដែរ។ ប៉ុន្តែ បដិវត្តន៍ ឆ្នាំ១៩១១ ការប្រយុទ្ធត្រូវបន្តរហូតដល់១៧ឆ្នាំ។ ក្រោយមក ក៏បានក្លាយទៅជាការប្រយុទ្ធរវាងភាគីអ្នកធ្វើបដិវត្តន៍ និងអ្នកធ្វើបដិវត្តន៍ដូចគ្នា (បក្សកុម្មុយនិស្ត និងបក្សគួកមីនតាំង) ។

សង្គ្រាមមហាដំណើរឆ្ពោះទៅទិសខាងជើង ក៏ចាប់ផ្តើមឡើង។ បន្ទាប់មក កងទ័ពក្រហមក៏ត្រូវបង្កើតឡើងដែរ ហើយបន្តមកទៀត កងទ័ពជប៉ុន ក៏បានចូលលុកលុយប្រទេសចិន។ ប៉ុន្តែ ក្រោយពេលកងទ័ពជប៉ុន ចុះចាញ់ ជៀង កៃជៀក ក៏បានធ្វើសង្គ្រាមប្រឆាំងនឹងយើង ។

ម៉ៅ សេទុង បញ្ជាក់ថា ពេលនោះ សង្គ្រាមបានស៊ីពេល អស់ជិត៤ឆ្នាំ។ ជៀងកៃជៀក មិនអាចស៊ូទ្រាំបានតទៅទៀត ក៏រត់ភៀសខ្លួនទៅកោះតៃវ៉ាន់ ។ ឥឡូវនេះ គាត់និយាយនៅអង្គការសហប្រជាជាតិថា គាត់ជាតំណាងប្រទេសចិន ទាំងមូល។ ជៀង កៃជៀក ធ្លាប់មានទំនាក់ទំនងជិតស្និទ្ធជាមួយពួកយើង ។ ខ្ញុំបានជួបជៀង កៃជៀក ច្រើនដងមកហើយដែរ ។

ពេលបក្សគួកមីនតាំង ធ្វើសន្និបាតនៅក្វាងចូវ ខ្ញុំបានទៅជួប ជៀង កៃជៀក នៅទីនោះ។ ខ្ញុំក៏ធ្លាប់ជាសមាជិកម្នាក់របស់បក្សគួកមីនតាំងដែរ។ ខ្ញុំតែម្នាក់មានសមាជិកភាពនៅក្នុងគណបក្សពីរ គឺនៅក្នុងបក្សកុម្មុយនិស្តផង និងនៅក្នុងបក្សគួកមីនតាំងផង។ នៅក្នុងបក្សកុម្មុយនិស្ត ខ្ញុំជាសមាជិកគណៈកម្មាធិការមជ្ឈិមបក្ស ចំណែកនៅក្នុងបក្សគួកមីនតាំង ខ្ញុំជាសមាជិកបម្រុងគណៈកម្មាធិការមជ្ឈិមបក្សដែរ ។

ពេលនោះ ពួកយើង(បក្សកុម្មុយនិស្ត)មួយចំនួនក៏បាននាំគ្នាចូលបក្សគួកមីន

តាំង។ នាយករដ្ឋមន្ត្រី ផ្ទ អេនឡាយ របស់យើង ក៏ធ្លាប់ធ្វើជាប្រធាននាយកដ្ឋានកិច្ចការនយោបាយនៅបណ្ឌិត្យសភាយោធាហ្វងពូ របស់ជៀង កៃជៀក និងជាអនុប្រធានបក្សនៅក្នុងកងទ័ពដំបូង របស់ជៀង កៃជៀក ដែរ ។ ខ្ញុំមិនចាំបាច់និយាយពីសមមិត្តលីន ពៀវ ទេ។ លីន ពៀវ ជាសិស្សរបស់ជៀង កៃជៀក បានទៅរៀននៅហ្វងពូ នោះ រយៈពេល៩ខែ។ និយាយរួម ពេលនោះ នៅប្រទេសចិន មានមនុស្សតិចណាស់ ដែលមិនមានការទាក់ទងជាមួយជៀង កៃជៀក ។

សេនាប្រមុខលីន ពៀវ ដែលមានវត្តមាននៅក្នុងកិច្ចពិភាក្សាគ្នានេះដែរ បានបញ្ជាក់ថា គាត់ក៏ជាសមាជិកបក្សទាំង២នោះ ដែរ ។

ម៉ៅ សេទុង បន្តទៀតថា សូម្បីតែសាខាបក្សគួកមីនតាំង ទាំងអស់ ក៏យើងជាអ្នកជួយរៀបចំដែរ។ បើគ្មានជំនួយពីខាងបក្សកុម្មុយនិស្តទេ បក្សគួកមីនតាំង ក៏មិនអាចសម្រេចបានយុទ្ធសាស្ត្រសង្គ្រាមមហាដំណើរឆ្ពោះទៅទិសខាងជើងនោះ បានដែរ។ ប៉ុន្តែពេលនោះ បក្សគួកមីនតាំង ពុំមានអង្គការចាត់តាំងបក្ស ពុំមានសាខាបក្សនៅតំបន់ដងទន្លេលឿង និងនៅភាគខាងជើងទេ គឺពួកគេពឹងបក្សកុម្មុយនិស្តឱ្យជួយរៀបចំ ។

ម៉ៅ សេទុង បញ្ជាក់ប្រាប់ ឡេ យន់ ថា បើកងទ័ពអាមេរិក មិនមកក្បែរព្រំដែនចិន ទេ ហើយបើសមមិត្តមិនស្នើសុំទេ យើងក៏ប្រហែលជាមិនបញ្ជូនកងទ័ពរបស់យើងឱ្យទៅប្រឡូកក្នុងសង្គ្រាមនោះដែរ ។

ឡេ យន់ តបវិញថា នេះក៏ជាអ្វី ដែលយើងបានគិតឃើញដែរ ។ ពេលណាយើងមានលទ្ធភាពបន្តការប្រយុទ្ធ យើងសង្ឃឹមថា យើងនឹងធ្វើឱ្យមហាសមរភូមិក្រោយរបស់យើង មានស្ថិរភាពបន្តិច។ ពេលយើងកំពុងប្រយុទ្ធតស៊ូជាមួយពួកអាមេរិក យើងចាត់ទុកប្រទេសចិន ជាមហាសមរភូមិក្រោយរបស់យើងដែរ ។

ហេតុនេះហើយ បានជាមានពេលមួយនោះ យើងបានចេញសេចក្តីណែនាំមួយថា បើទោះបីយន្តហោះរបស់យើង ទទួលរងនូវការវាយប្រហារយ៉ាងណា ក៏

យន្តហោះទាំងអស់នោះមិនត្រូវទៅចុះចតនៅអាកាសយានដ្ឋានរបស់ចិន ដែរ ។

ម៉ៅ សេទុង ឆ្លើយកាត់ថា យន្តហោះសមមិត្តអាចទៅចុះចតនៅអាកាសយានដ្ឋានរបស់យើងបាន យើងមិនខ្លាចទេ។ បើយន្តហោះចម្បាំងអាមេរិក ហ៊ានមកវាយប្រហារលើមូលដ្ឋានកងទ័ពអាកាសរបស់យើង ឱ្យពួកគេមកសាកមើលទៅ! ។

ឡូ យន់ តបវិញថា បើទោះបីយើងបានចេញសេចក្ដីណែនាំដូច្នេះក៏ដោយ ក៏យើងនៅតែពឹងផ្អែកលើការជួយឧបត្ថម្ភគាំទ្ររបស់សមមិត្តប្រធានដែរ ។

ម៉ៅ សេទុង ប្រាប់ថា ពួកអាមេរិក ភ័យខ្លាចចាញ់ណាស់ ពួកគេគ្មានសេចក្ដីក្លាហានទេ ។ សមមិត្តប្រហែលជាអាចធ្វើការចរចាជាមួយអាមេរិក បាន។ តែថាមពលចម្បងរបស់សមមិត្ត គួរតែធ្វើឡើងនៅទីលានសមរភូមិ ។

តើនរណាជាអ្នកធ្វើវិទ្ធង្សនានៅសន្និសីទក្រុងហ្សឺណែវ ទាំង២លើក? ទាំងសមមិត្ត ទាំងយើងខ្ញុំធ្វើតាមសេចក្ដីសម្រេចរបស់សន្និសីទនោះដោយស្មោះត្រង់។ តែអាមេរិក អត់ធ្វើតាមទេ។ ហេតុនេះហើយ បានជានាយករដ្ឋមន្ត្រីសហភាពសូវៀត កូស៊ីហ្គីន នៅពេលថ្មីៗកន្លងមកនេះ ពេលគាត់ធ្វើសុន្ទរកថាជាសាធារណៈមួយទាក់ទងជាមួយនឹងការកោះប្រជុំសន្និសីទកំពូលរបស់ប្រជាជននៅឥណ្ឌូចិន( ថ្ងៃ២៤-២៥ ខែមេសា ឆ្នាំ១៩៧០) គាត់បានលើកឡើងថា ត្រូវតែធ្វើការពិគ្រោះគ្នាជាមុនសិន។ ខ្ញុំធ្លាប់ស្គាល់កូស៊ីហ្គីន និងធ្លាប់បានជួបពិភាក្សាគ្នាជាច្រើនដងទៀតផង តែពួកមេដឹកនាំ សូវៀត សព្វថ្ងៃនេះ ខ្ញុំមិនដែលស្គាល់ទេ ។

កាសែតលោកខាងលិចជាច្រើន បានបង្កើតពាក្យចចាមអារ៉ាម អំពីការបាក់បែកក្នុងជួរមេដឹកនាំរបស់សូវៀត។ ខ្ញុំក៏មិនដឹងរឿងនេះច្បាស់ដែរ ឮគេថា ប្រជាជនសូវៀតសាមញ្ញ ចាត់ទុកថាកូស៊ីហ្គីន ជាមេដឹកនាំដ៏ល្អម្នាក់ ។

ឡូ យន់ បន្តថា យើងខ្ញុំក៏ឮដូច្នេះ។ ម៉ៅ សេទុង បញ្ជាក់បន្ថែមថា សមមិត្តបានឮដូច្នេះដែរ? ។

តាមយោបល់ខ្ញុំ ស្តាលីន បានរស់ឡើងវិញជាថ្មីហើយ។ និន្នាការសំខាន់ក្នុង

ពិភពលោកសព្វថ្ងៃ គឺធ្វើបដិវត្តន៍រួមក្នុងពិភពលោកទាំងមូលតែម្តង។ ដូច្នេះ មហាអំណាចអាចចាប់ផ្តើមបង្កសង្គ្រាមលោកមួយទៀត។ ប៉ុន្តែ ដោយសារគ្រាប់បែក នុយក្លេអ៊ែរ មានតិចតួច ពុំទាន់មានមហាអំណាចណាមួយហ៊ានចាប់ផ្តើមបង្កសង្គ្រាមនោះទេ ។

រឿងនេះ វាពាក់ព័ន្ធដល់ប្រទេសជាមហាអំណាចពីរ (អាមេរិក និងសូវៀត) តែពេលនេះ មានមជ្ឈដ្ឋានជាច្រើននិយាយថា រឿងនេះពាក់ព័ន្ធប្រទេសជាមហាអំណាចដល់ទៅ៣ឯណោះ ។

តែគេមិនត្រូវបញ្ចូលប្រទេសចិន ទៅក្នុងរឿងនេះទេ ព្រោះការសិក្សាស្រាវជ្រាវរបស់ចិន ក្នុងការធ្វើអាវុធនុយក្លេអ៊ែរនោះ គឺគ្រាន់តែជាការពិសោធប៉ុណ្ណោះ។ យើងកំពុងស្ថិតនៅក្នុងដំណាក់កាលស្រាវជ្រាវនៅឡើយទេ ហេតុអ្វី បានជាគេត្រូវខ្លាចប្រទេសចិន? តើមកពីប្រទេសចិន មានប្រជាជនច្រើន បានជាធ្វើឱ្យគេខ្លាច? យើងក៏មានការព្រួយបារម្ភពីកំណើនប្រជាជនយើងខ្ញុំដែរ។ តែយើងចាំបាច់ ត្រូវតែចិញ្ចឹម និងផ្តល់សម្លៀកបំពាក់ដល់ប្រជាជនយើង។ ដូច្នេះហើយ បានជាឥឡូវនេះ យើងចាប់ផ្តើមធ្វើការសិក្សាអំពីការគ្រប់គ្រងកំណើត ដើម្បីធ្វើឱ្យអត្រាកំណើនប្រជាជនយើងថយចុះបន្តិចមកវិញ ។

ឡេ យន់ ប្រាប់ម៉ៅ សេទុង ថា យើងខ្ញុំមានលទ្ធភាពប្រយុទ្ធបន្តទៅទៀត ក៏ដោយសារសមមិត្តប្រធានបានមានប្រសាសន៍ថា ប្រជាជនចិន ទាំង៧០០លាននាក់ផ្តល់ការគាំទ្រពេញទំហឹងដល់ការតស៊ូរបស់ប្រជាជនវៀតណាម ហើយពួកអាមេរិកខ្លាចរឿងនេះណាស់ ។

ម៉ៅ សេទុង តបវិញថា ហេតុអ្វី បានជាអាមេរិកខ្លាច? នៅពេលអាមេរិក ឈ្លានពានប្រទេសណាមួយ តើវាជាកំហុសឬ ដែលយើងគាំទ្រប្រទេសមួយ ដែលត្រូវគេឈ្លានពាននោះ? អាមេរិក បញ្ជូនកងទ័ពជើងទឹក ជើងអាកាស និងជើងគោក រាប់រយពាន់នាក់ទៅសម្លុតគំរាមកំហែងប្រទេសវៀតណាម តើនរណាមកហាមឃាត់ចិន មិនឱ្យគាំទ្រប្រជាជនវៀតណាម? តើមានច្បាប់ណាមួយមកហាមឃាត់បែបនេះ?។

*ឡៅ យន់ បន្ថែមថា ពួកអាមេរិក និយាយថា ពួកគេអាចកែនកង់ទ័ព១២លាននាក់ តែពួកគេបញ្ជូនកងទ័ពតែកន្លះលាននាក់ប៉ុណ្ណោះ មកវៀតណាម ។ ប៉ុន្តែបើពួកគេបញ្ជូនមកច្រើនជាងនេះ ក៏ពួកគេមានការលំបាកដែរ ។*

*នាយករដ្ឋមន្ត្រីចិន ជូ អេនឡាយ ដែលមានវត្តមាននៅក្នុងពេលពិភាក្សាគ្នានោះដែរ បានលើកឡើងថា ដោយសារចិន មានប្រជាជនច្រើន ទើបធ្វើឱ្យគេមានការព្រួយបារម្ភ ។*

*ម៉ៅ សេទុង បន្ថែមថា ដោយសារយើងមានប្រជាជនច្រើន ពេលខ្លះយើងក៏មិនខ្លាចដែរ។ អាមេរិក កាន់កាប់កោះតៃវ៉ាន់របស់យើង តែយើងមិនបានកាន់កាប់កោះឡុង*( Long Island )*របស់អាមេរិក ទេ ។*

---

# ២៨៤
# គោលជំហរមេដឹកនាំប្រទេសជាមិត្ត
# របស់សម្តេចសីហនុ ក្រោយរដ្ឋប្រហារ



ប្រធានាធិបតីបារាំង ហ្សាលេ ដឺហ្គោល មកបំពេញទស្សនកិច្ចនៅកម្ពុជា

*ទោះបី ពេលនោះប្រទេសកម្ពុជា ត្រូវពិភពលោកចាត់ទុកថា ជាប្រទេសដ៏ក្រីក្រមួយក៏ពិតមែន ក៏នៅក្នុង ឆ្នាំ១៩៦៩ សម្តេចសីហនុ បានរៀបចំពិធីទទួលបដិសណ្ឋារកិច្ចយ៉ាងអធិកអធមបំផុតចំពោះប្រធានាធិបតី នៃប្រទេស នីហ្សេ ឈ្មោះហាម៉ានី ឌីយ៉ូរី* ( Hamani Diori ) *នោះដែរ ។*

*ព្រះអង្គមិនត្រឹមតែចំណាយថវិការដ្ឋដ៏ច្រើនសន្ធឹកសន្ធាប់ ចំពោះទស្សនកិច្ចរបស់មេដឹកនាំជនជាតិស្បែកខ្មៅមួយនេះទេ គឺព្រះអង្គបានទាំងផ្តល់នូវជំនួយសេដ្ឋកិច្ចដល់ប្រទេសនីហ្សេ នេះទៀតផង ។*

ជាមួយគ្នានោះ ព្រះអង្គបានបញ្ជូនអ្នកបច្ចេកទេសខ្មែរ២នាក់ ទៅទីក្រុងនីញ៉ាម៉េ (Niamey) ជារដ្ឋធានីនៃប្រទេសនីហ្សេ ដើម្បីទៅសិក្សាអំពីតម្រូវការផ្សេងៗរបស់ប្រទេសនេះទៀតផង ។

មិនតែប៉ុណ្ណោះ ព្រះអង្គបានបញ្ជូនអ្នកជំនាញខាងស្រាវជ្រាវផ្នែកក្សេត្រសាស្ត្រដ៏ល្បីល្បាញម្នាក់ឈ្មោះហូ តុងលីប ឱ្យទៅជួយអភិវឌ្ឍវិស័យកសិកម្ម ដល់ប្រទេសនីហ្សេ ផងដែរ ខណៈដែលវិស័យកសិកម្មរបស់ប្រទេសព្រះអង្គមិនទាន់មានការរីកចម្រើននៅឡើយ ហើយបញ្ហានេះព្រះអង្គក៏បានរងនូវការរិះគន់ពីមជ្ឈដ្ឋានឥស្សរជនមួយចំនួនដែរ ។

នៅពេលប្រធានាធិបតីហាម៉ានី ឌីយ៉ូរី (Hamani Diori) និងភរិយា មកបំពេញទស្សនកិច្ចនៅប្រទេសកម្ពុជានោះ ប្រជាពលរដ្ឋខ្មែរ ពិសេសគឺក្មេងៗជាសិស្សសាលានាំគ្នាទះដៃស្វាគមន៍យ៉ាងកងរំពង និងភ្ញាក់ផ្អើលយ៉ាងខ្លាំងចំពោះស្បែកដ៏ខ្មៅរលោងរបស់ប្រធានាធិបតីអាហ្វ្រិករូបនេះ ដោយនាំគ្នាលាន់មាត់ស្រែកថា ខ្មៅអីក៏ខ្មៅម្ល៉េះ? ស្ទើរគ្រប់ៗគ្នា ។

ពេលនោះ ភរិយារបស់ប្រធានាធិបតីហាម៉ានី ឌីយ៉ូរី (Hamani Diori) មានការងឿងឆ្ងល់ ក៏បានជជីកសួរទៅអ្នកម្នាងម៉ូនិក ជាមហេសីរបស់សម្តេចសីហនុ ដែលកំពុងអមដំណើរដែរនោះថា តើក្មេងៗសិស្សសាលាទាំងអស់នោះ គេស្រែកថាម៉េច? អ្នកម្នាងម៉ូនិក ក៏បកប្រែរបៀបកែលម្អសម្រែកនោះ ប្រាប់ទៅភរិយារបស់ប្រធានាធិបតីហាម៉ានី ឌីយ៉ូរី ថាពួកក្មេងៗសិស្សសាលាទាំងអស់នោះនាំគ្នាសរសើរថា ប្រធានាធិបតីហាម៉ានី ឌីយ៉ូរី (Hamani Diori) ប្រៀបដូចលោកម្ចាស់ដ៏ឧត្តុង្គឧត្តមម្នាក់ ។

ក្រោយពីត្រលប់ទៅដល់ប្រទេសនីហ្សេ វិញ ប្រធានាធិបតីហាម៉ានី ឌីយ៉ូរី (Hamani Diori) នៅតែជាប់ចិត្តចំពោះការធ្វើបដិសណ្ឋារកិច្ចដ៏អធិកអធមរបស់សម្តេចសីហនុ ជានិច្ច ។

ក្រោយរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ ១៩៧០ បាន២ឆ្នាំ គឺនៅក្នុងឆ្នាំ១៩៧២

បន្ទាប់ពីមានគោលជំហរស្ទាក់ស្ទើរ បន្តិចប្រធានាធិបតីប្រទេសនីហ្សេរូបនេះ ក៏បានប្រកាសទទួលស្គាល់រាជរដ្ឋាភិបាលរួបរួមជាតិរបស់សម្ដេចសីហនុ ថាជារាជរដ្ឋាភិបាលស្របច្បាប់ ដោយមិនខ្វាយខ្វល់ពីការប្រឆាំងជំទាស់របស់ប្រទេសលោកខាងលិចជាមិត្តភក្ដិរបស់លោកឡើយ ។

ចាប់ពីឆ្នាំ១៩៦០ មក សម្ដេចសីហនុ ក្នុងនាមជាព្រះប្រមុខរដ្ឋនៃព្រះរាជាណាចក្រកម្ពុជា បានរៀបចំពិធីទទួលដំណើរមកបំពេញទស្សនកិច្ចជាផ្លូវការរបស់មេដឹកនាំប្រទេសផ្សេងៗទៀតជាច្រើន ដូចជា អង់តូនី ណូវ៉ូតនី( Antoni Novotny )ប្រធានាធិបតីប្រទេសឆេកូស្លូវ៉ាគី និងភរិយា, ឧត្ដមសេនីយ៍ហ្សាល ដឺហ្គោល ប្រធានាធិបតីនៃប្រទេសបារាំង និងភរិយា, ហ្សូស៊ីព ប្រូសទីតូ ប្រធានាធិបតីនៃប្រទេសយូហ្គោស្លាវី និងភរិយា, ម៉ុកតា អ៊ូលដាដា ប្រធានាធិបតីនៃ ប្រទេសម៉ូរីតានី, ព្រះចៅអធិរាជ ហៃឡេ សេឡាស្សេ នៃប្រទេសអេត្យូពី, រ៉ាជិនដ្រា ប្រាសាដ ប្រធានាធិបតី នៃប្រទេសឥណ្ឌា, ស៊ូការណូ ប្រធានាធិបតី នៃប្រទេសឥណ្ឌូនេស៊ី ( មកបំពេញទស្សនកិច្ច៣ដងនៅកម្ពុជា), លីវ ចាវជី ប្រធានាធិបតីនៃសាធារណរដ្ឋប្រជាមានិតចិន, ឆឺ យ៉ុងកឺន ប្រធានគណៈប្រធានរដ្ឋនៃសាធារណរដ្ឋប្រជាធិបតេយ្យ ប្រជាមានិតកូរ៉េ, ដ្យូសដាដូ ម៉ាកាប៉ាហ្កាល់ ប្រធានាធិបតីនៃប្រទេសហ្វីលីពីន, ជូ អេនឡាយ នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតចិន, ទុងគូ អាប់ឌុលរ៉ាម៉ាន់ នាយករដ្ឋមន្ត្រីនៃប្រទេសម៉ាឡេស៊ី, លី ក្វាន់យូ នាយករដ្ឋមន្ត្រីនៃប្រទេសសិង្ហបុរី ( អញ្ជើញមកទស្សនកិច្ចនៅកម្ពុជា ច្រើនលើក), ហារ៉ូលដ៍ ហូលត៍ នាយករដ្ឋមន្ត្រីនៃប្រទេស អូស្ត្រាលី, ព្រះមហាក្សត្រឡេអូ ម៉ូលដ៍ និងអគ្គមហេសីនៃប្រទេសបែលហ្ស៊ិក, លោកស្រីហ្សាក្លីន កេណ្ណឺឌី ភរិយាសពប្រធានាធិបតីអាមេរិក ចន កេណ្ណឺឌី ជាដើម ។

ក្រោយរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ ១៩៧០ ព្រះចៅអធិរាជ ហៃឡេ សេឡាស្សេ នៃប្រទេសអេត្យូពី បានធ្វើដំណើរទៅទីក្រុងប៉េកាំង ប្រទេសចិន ជាទីដែលសម្ដេចសីហនុ បង្កើតរាជរដ្ឋាភិបាលនិរទេសមួយ ដើម្បីធ្វើសង្គ្រាមប្រឆាំងនឹងរបប

សាធារណរដ្ឋខ្មែររបស់លន់ នល់ នោះ ព្រះចៅអធិរាជអង្គនេះ បានទូលសម្ដេចសីហនុ ដែលធ្លាប់ជាមិត្តភក្តិជិតស្និទ្ធថា ខ្លួនមិនអាចទទួលស្គាល់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា របស់ព្រះអង្គ បានទេ គឺមានតែព្រះជាម្ចាស់ទេ ទើបអាចជួយព្រះអង្គ បានខ្លះ...។ ចំណែក ស៊ូហារតូ ប្រធានាធិបតី នៃប្រទេសឥណ្ឌូនេស៊ី ជាមិត្តភក្តិជិតស្និទ្ធរបស់សម្ដេចសីហនុ ដែរនោះ ក្រោយរដ្ឋប្រហារថ្ងៃទី ១៨ ខែមីនា ឆ្នាំ១៩៧០ បានប្រកាសទទួលស្គាល់រដ្ឋាភិបាលនៃសាធារណរដ្ឋខ្មែររបស់លន់ នល់ ទៅវិញ ។

ក្រោយពេលបំពេញទស្សនកិច្ចនៅកម្ពុជាមក ឌី យ៉ុងកឹន ប្រធានគណៈប្រធានរដ្ឋនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតកូរ៉េ បានរាយការណ៍ជូនសេនាប្រមុខ គីម អ៊ីលស៊ុង អគ្គលេខាគណៈកម្មាធិការបក្សពលករកូរ៉េ ថា ក្រោមការដឹកនាំរបស់សម្ដេចសីហនុ ប្រជាជនកម្ពុជា មានកម្រិតជីវភាពខ្ពស់ជាងគេ ក្នុងចំណោមប្រទេសតតិយលោកជាច្រើន ។

ប្រធានាធិបតីនៃប្រទេសហ្វីលីពីន ដ្យូសដាដូ ម៉ាកាប៉ាហ្គាល់ (Dios dado Macapagal) មានក្តីរំភើបរីករាយយ៉ាងខ្លាំងចំពោះការទទួលបដិសណ្ឋារកិច្ចរបស់សម្ដេចសីហនុ នៅក្រុងភ្នំពេញ កាលពីឆ្នាំ១៩៦៤ នោះ។ ប៉ុន្តែ លោកមានទឹកមុខស្រងូតស្រងាត់ ដោយសារលោកមិនអាចធ្វើការសម្របសម្រួលឱ្យសម្ដេចសីហនុ និងសហរដ្ឋអាមេរិក ជាមិត្តភក្តិរបស់លោកមានទំនាក់ទំនងល្អនឹងគ្នាវិញបាន ។

នៅក្នុងរាត្រីសមោសរ ដែលសម្ដេចសីហនុ រៀបចំជូនជាកិត្តិយសនោះ ប្រធានាធិបតីនៃប្រទេសហ្វីលីពីន រូបនោះ បានឡើងរាំជាមួយអ្នកម្នាងម៉ូនិក ជាមហេសីសម្ដេចសីហនុ តែមួយបទប៉ុណ្ណោះ ព្រោះអារម្មណ៍របស់លោកហាក់ដូចជាមិនស្ថិតនៅក្នុងរាត្រីសមោសរនោះ ដោយសារមិនអាចបញ្ចុះបញ្ចូលសម្ដេចសីហនុ ឱ្យមានទំនាក់ទំនងល្អជាមួយអាមេរិក វិញបាន ។

ចំណែក ទុងគូ អាប់ឌុលរ៉ាម៉ាន់ នាយករដ្ឋមន្ត្រីនៃប្រទេសម៉ាឡេស៊ី បានផ្តល់កិត្តិយសថ្វាយសម្ដេចសីហនុ ដោយទទួលយល់ព្រមជួបចរចាជាមួយដ្យូសដាដូ ម៉ា

កាប៉ាហ្កាល់ ប្រធានាធិបតីនៃប្រទេសហ្វីលីពីន ដើម្បីដោះស្រាយភាពតានតឹងរវាងប្រទេសទាំង២ តាមសំណើរបស់សម្ដេចសីហនុ ពេលលោកបំពេញទស្សនកិច្ចនៅខេត្តសៀមរាប ដែលជាទីក្រុងប្រាង្គប្រាសាទខ្មែរ ដ៏ល្បីល្បាញ ។

ក្នុងចំណោមឥស្សរជន និងមេដឹកនាំទាំងអស់របស់បណ្ដាប្រទេសនានានៅលើពិភពលោក ដែលធ្វើដំណើរមកទស្សនកិច្ចនៅកម្ពុជា មានតែដំណើរទស្សនកិច្ចរបស់អ្នកស្រីហ្សាក្គីលីន កេណ្ណឺឌី និងដំណើរទស្សនកិច្ចរបស់ប្រធានាធិបតីបារាំងហ្សាល ដឺហ្គោល ប៉ុណ្ណោះ ដែលល្បីរន្ទឺខ្លាំងជាងគេ។ រយៈពេល២សប្ដាហ៍ប៉ុណ្ណោះមុនពេលទទួលមរណភាព( ថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ១៩៧០) អតីតប្រធានាធិបតីបារាំងរូបនេះ បានសរសេរសារណាមួយមានចំណងជើងថា៖ "ស្មារតីនៃក្ដីសង្ឃឹម" ដោយគាត់ក៏បានសរសេរឧទ្ទិសស្នាដៃនោះ ថ្វាយចំពោះសម្ដេចសីហនុ ផងដែរ។




លោកស្រីហ្សាក្គីលីន កេណ្ណីឌី ពេលមកបំពេញទស្សនកិច្ចនៅកម្ពុជា

ទាក់ទងដល់ដំណើរទស្សនកិច្ចនៅកម្ពុជា របស់លោកស្រី ហ្សាក្គីលីន កេណ្ណឺឌី នៅដើមខែវិច្ឆិកា ឆ្នាំ១៩៦៧ សម្ដេចសីហនុ មានបន្ទូលថា ផ្ទុយពីអ្វីៗ ដែលមនុស្សជាច្រើនបាននឹកស្មាន នៅពេលនោះលោកស្រីហ្សាក្គីលីន កេណ្ណឺឌី មិនបានប្រគល់

សារលិខិតអ្វីមួយរបស់មេដឹកនាំអាមេរិក មកថ្វាយព្រះអង្គនៅក្នុងពេលមកបំពេញទស្សនកិច្ចនោះទេ ហើយលោកស្រីក៏មិនបាននិយាយអ្វីមួយម៉ាត់ អំពីបញ្ហាទំនាក់ទំនងផ្សេងៗ រវាងអាមេរិក និងកម្ពុជា ដែរ ។

លោកស្រី បានអះអាងប្រាប់ពិភពលោកថា លោកស្រីមកទស្សនកិច្ចនៅកម្ពុជា គឺមានបំណងតែម្យ៉ាងគត់ គឺទស្សនាប្រាសាទអង្គរវត្តតែប៉ុណ្ណោះ ហើយបើទោះបីព្រះអង្គបានរៀបចំធ្វើពិធីទទួលស្វាគមន៍លោកស្រីនៅរាជធានីភ្នំពេញ មានភាពអធិកអធមយ៉ាងណា ក៏លោកស្រីមិនសូវចាប់អារម្មណ៍ខ្លាំង ដូចនៅពេលទៅទស្សនាប្រាង្គប្រាសាទបុរាណខ្មែរ នៅខេត្តសៀមរាប នោះដែរ។ សម្តេចសីហនុ មានបន្ទូលបន្តថា លោកស្រីហ្សាក្លីលីន កេណ្ណឺឌី ជាស្ត្រីមានចរិតទន់ភ្លន់ ប្រកបដោយប្រាជ្ញាឈ្លាសវៃ និងមានឧត្តមគតិខ្ពង់ខ្ពស់ ។

ថ្ងៃមួយ ពេលធ្វើដំណើរបំពេញទស្សនកិច្ចនៅប្រទេសកម្ពុជា សម្តេចសីហនុ ដែលអមដំណើរជាមួយដែរនោះ បានមានបន្ទូលប្រាប់ទៅលោកស្រីថា មនុស្សម្នាប្រុសស្រីនាំគ្នាទះដៃអបអរសាទរយ៉ាងកក់ក្តៅចំពោះលោកស្រី ។

ពេលនោះ លោកស្រីហ្សាក់ក្លីលីន កេណ្ណឌី បានទូលព្រះអង្គវិញថា៖ “ការពិតពួកគេមិនមែនទះដៃអបអរសាទរចំពោះខ្ញុំទេ គឺពួកគេអបអរសាទរព្រះអង្គ ព្រោះពួកគេនាំគ្នាស្រែកជាប់ជានិច្ចថា៖ ជយោ! សម្តេចឪ, ជយោ! សម្តេចឪ... មិនមែនស្រែកឈ្មោះខ្ញុំឯណា? ។

ក្រោយរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ រហូតដល់ឆ្នាំ១៩៧៥ ទោះបីមេដឹកនាំសហរដ្ឋអាមេរិក បានចេញមុខជួយឧបត្ថម្ភគាំទ្ររបបសាធារណរដ្ឋខ្មែររបស់លន់ នល់ យ៉ាងពេញទំហឹង និងប្រឆាំងសម្តេចសីហនុ យ៉ាងណាក្តី ក៏ជារៀងរាល់ឆ្នាំ ឱ្យតែដល់ថ្ងៃទី៣១ ខែតុលា ជាថ្ងៃខួបកំណើតរបស់សម្តេចសីហនុ លោកស្រីហ្សាក់ក្លីលីន កេណ្ណឺឌី តែងតែផ្ញើសារមកថ្វាយព្រះពរព្រះអង្គជារៀងរាល់ឆ្នាំ មិនដែលខកខានមួយឆ្នាំណាឡើយ ។

ដោយឡែក នៅពេលប្រធានាធិបតីឥណ្ឌូនេស៊ី ស៊ូការណូ មកបំពេញទស្សនកិច្ចនៅប្រទេសកម្ពុជា ជាមួយករិយា ដែលមានរូបសម្រស់ស្រស់ស្អាតបំផុត ឈ្មោះពីហារទីនីពី ថ្ងៃទី១១ ដល់ ថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៦៤ លោកស្រី ពីហារទីនី បានទម្លាយអាថ៌កំបាំងរបស់ហូ ជីមិញ ជាមេដឹកនាំកំពូលរបស់សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម( វៀតណាមកុម្មុយនិស្ត) ដែលល្បីថា មិនរវល់ពីរឿងស្រីញីនោះ ប្រាប់សម្តេចសីហនុ ថាពេលលោកស្រីទៅបំពេញទស្សកិច្ចនៅទីក្រុងហាណូយ លោកស្រីបានសម្រេចជោគជ័យមួយក្នុងការធ្វើឱ្យហូ ជីមិញ ទទួលសារភាពថា គាត់មិនមែនជាព្រះទេ គឺគាត់ក៏បានផ្សងព្រេងក្នុងរឿងស្នេហាខ្លះៗដែរ ។



ប្រធានាធិបតីឥណ្ឌូនេស៊ី ស៊ូការណូ មកបំពេញទស្សនកិច្ចនៅប្រទេសកម្ពុជា

សម្តេចសីហនុ បានធ្វើការកត់សម្គាល់ថា ស៊ូការណូ ដែលជាវីរបុរសនៃឯករាជ្យជាតិរបស់ប្រទេសឥណ្ឌូនេស៊ី ជាមនុស្សចូលចិត្តសោភ័ណភាព ចូលចិត្តលេងខ្លួនស៊ីហា និងស្រលាញ់ឯកសណ្ឋានជាអគ្គបញ្ជាការកងទ័ពដ៏សង្ហា ជាមួយនឹងគ្រឿងឥស្សរិយយសជាច្រើន ពាក់រណោងរណោងពេញដើមទ្រូង។ តែគាត់ពាក់មួកកាតឹបខ្មៅ ជាប្រពៃណី

អ៊ិស្លាមជាប់ជានិច្ច មិនដែលហ៊ានបង្ហាញជាសាធារណៈឱ្យឃើញនូវក្បាលរាងពកបន្តិចរបស់គាត់ម្តងណាឡើយ ។

សម្តេចសីហនុ បានធ្វើការកត់សម្គាល់ទៀតថា ស៊ូការណូ ជាវាគ្មិនដ៏ពូកែម្នាក់ដែលអាចទាក់ទាញការគាំទ្រពីប្រជាពលរដ្ឋឥណ្ឌូនេស៊ី ដ៏ច្រើនកុះករ ហើយបើទោះបីគាត់មានវ័យចំណាស់ទៅហើយ ក៏គាត់នៅតែចូលចិត្តរឿងស្នេហាដែរ។ ចុងក្រោយស៊ូការណូ រស់នៅជាមួយភរិយា៤នាក់ គឺ ទី១-ឈ្មោះហ្វាត់ម៉ាវតី, ទី២-ឈ្មោះហារទីនី, ទី៣-ឈ្មោះទេវី (ជនជាតិជប៉ុន) និង ទី៤- លោកស្រីអារ្យាទី ដែលមានវ័យក្មេងជាងគេ តែមិនសូវស្អាតដូចភរិយាទី១ ទី២ និង ទី៣ ទេ ។

បើតាមសម្តេចសីហនុ បានឱ្យដឹងដែរថា ពេលមកបំពេញទស្សនកិច្ចនៅកម្ពុជានោះ ស៊ូ ការណូ ចូលចិត្តមកជិតអ្នកម្នាងម៉ូនិក ជាមហេសីព្រះអង្គ ធ្វើមើលតែអ្នកម្នាងជារាជនីរបស់គាត់អ៊ីចឹង តែគាត់ក៏បានបណ្តោយឱ្យព្រះអង្គនៅកំដរភរិយាទី២របស់គាត់ គឺលោកស្រីហារទីនី ដែលមានសម្បុរដូចជនជាតិខ្មែរបេះបិទនោះស្ងាត់ៗតែ២នាក់យ៉ាងសែនមនោរម្យ ហើយលោកស្រីហារទីនី ចាត់ទុកព្រះអង្គជាមិត្តភក្តិដែលមិនគួរឱ្យទុកចិត្តប៉ុន្មានឡើយ ។

បន្ទាប់មក ស៊ូការណូ បានរៀបចំឱ្យព្រះអង្គបានជួបជាមួយភរិយាទី៣ ឈ្មោះទេវី (ជនជាតិជប៉ុន) នៅក្នុងពិធីសោយភោជនាហារពេលល្ងាច និងបានឱ្យព្រះអង្គនាំភរិយាទី៤ វ័យក្មេងឈ្មោះអារ្យាទី ទៅជាមួយនៅក្នុងនាវាមួយផងដែរ ។

ក្រោយធ្លាក់ពីអំណាចក្នុងថ្ងៃទី១២ ខែមីនា ឆ្នាំ១៩៦៧ មក ស៊ូការណូ ត្រូវគេឃុំខ្លួនក្នុងភូមិគ្រឹះមួយ និងធ្លាក់ខ្លួនមានជំងឺទៀតផង។ ទោះបីយ៉ាងនេះក៏ដោយ ក៏លោកនៅតែឆ្លៀតឱកាសរៀបការជាមួយយុវតីម្នាក់ជាសិស្សរៀននៅអនុវិទ្យាល័យដែលមានអាយុត្រឹម១៦ ឆ្នាំប៉ុណ្ណោះ ។

នៅពេលព្រះចៅឡេអូប៉ូលដ៏ នៃប្រទេសបែលហ្ស៊ិក និងម្ចាស់ក្សត្រីយ៍លីល្យាណា ជាមហេសីយាងមកទស្សនកិច្ចនៅកម្ពុជា សម្តេចសីហនុ បានសង្កេតឃើញថា

ព្រះចៅឡេអូប៉ូលដ៏ និងមហេសី ជារាជវង្ស ដែលមានចរិតសាមញ្ញ និងមានវប្បធម៌ដ៏ខ្ពង់ខ្ពស់បំផុត ព្រមទាំងមានទស្សនៈត្រឹមត្រូវចំពោះស្ថានការណ៍នយោបាយក្នុងសាកលលោក ពិសេសគឺក្នុងទ្វីបអាស៊ី ។

ចំណែក លី ក្វាន់យូ នាយករដ្ឋមន្ត្រី នៃប្រទេសសិង្ហបុរីវិញ សម្តេចសីហនុ មានទំនាក់ទំនងយ៉ាងល្អប្រពៃ។ ព្រះអង្គចាត់ទុកមេដឹកនាំដែលមានដើមកំណើតជាជនជាតិចិនម្នាក់នេះ ជាមនុស្សមានប្រាជ្ញាឈ្លាសវៃ និងមានមហិច្ឆតា ដើម្បីឱ្យប្រទេសដ៏តូចរបស់គាត់ក្លាយទៅជាគំរូខាងសណ្តាប់ធ្នាប់ និងវិបុលភាព ។

លី ក្វាន់យូ ក៏បានសម្តែងការកោតសរសើរពីគោលនយោបាយអព្យាក្រឹត និងមិនចូលបក្សសម្ព័ន្ធរបស់សម្តេចសីហនុ ដែរ ។



**សម្តេចសីហនុ និងមហេសី ពេលយាងទៅបំពេញទស្សនកិច្ចនៅប្រទេសសិង្ហបុរី ក្នុងខែធ្នូ ឆ្នាំ១៩៦២**

# ២៨៥
# កងទ័ពអាមេរិក និងវៀតណាមខាងត្បូង ចូលមកវាយកម្ចាត់កងទ័ពវៀតកុង ក្នុងទឹកដីកម្ពុជា



ក្រោយពេលប្រយុទ្ធគ្នា ទីរួមស្រុកស្នួល ខេត្តក្រចេះ ស្ទើរក្លាយជាផេះ

*នៅពេលកងទ័ពអាមេរិក ចូលមកវាយកម្ចាត់កងទ័ពវៀតកុង-វៀតណាមខាងជើង នៅទីរួមស្រុកស្នួល ខេត្តក្រចេះ និងតំបន់ចម្ការកៅស៊ូក្រែក ស្រុកមេមត់ ខេត្តកំពង់ចាម រយៈពេល ២ខែ ទាហានរដ្ឋការក្រុងព្រៃនគរ ក៏បានបើកប្រតិបត្តិការសឹកចូលមកបោសសម្អាតកងទ័ពវៀតកុង-វៀតណាមខាងជើង នៅតំបន់ចំពុះទា ខេត្តស្វាយរៀង ដោយគ្មានកំណត់រយៈពេលនៃការបើកប្រតិបត្តិការសឹកនោះដែរ ។*




កងទ័ពវៀតណាមខាងត្បូង ចូលទីប្រជុំជនប្រសូត ខេត្តស្វាយរៀង (ថ្ងៃ១ឧសភា ១៩៧០)

កងពលធំលេខ៩ ដែលល្បីថាខ្លាំងពូកែបំផុតរបស់របបក្រុងព្រៃនគរ ដែលមានឧត្តមសេនីយ៍ ដូ កាវទ្រី ជាមេបញ្ជាការនោះ បានបើកយុទ្ធនាការបោសសម្អាតកងទ័ពវៀតកុង-វៀតណាមខាងជើង ដោយប្រើកងទ័ពថ្មើរជើងរាប់ពាន់នាក់ និងរថគ្រោះអឹម ១១៣(M.113)ចំនួន ៦២គ្រឿង ព្រមទាំងឧទ្ធម្ភាគចក្ររាប់សិបគ្រឿង ផ្សេងទៀតជួយគាំទ្រផង ។

ទាហានរដ្ឋការក្រុងព្រៃនគរ ឬទាហានរបបសារណរដ្ឋវៀតណាម ( វៀតណាមខាងត្បូង) ដែលប្រជាកសិករខ្មែរយើង ហៅថាទាហានធីវ-គី គឺជាឈ្មោះរបស់ប្រធានាធិបតីវៀតណាមខាងត្បូង ង្វៀន វ៉ាន់ធីវ បូកនឹង ឈ្មោះអនុប្រធានាធិបតី ង្វៀន កាវគី ។

ក្នុងចំណោមទាហានធីវ-គី ទាំងអស់នោះ មានមួយចំនួនជាជាអតីតអាណិកវៀតណាម ធ្លាប់រស់នៅក្នុងប្រទេសកម្ពុជា ហើយត្រូវពួកទាហានលន់ នល់ វាយធ្វើបាប និងសម្លាប់រង្គាលក្រុមគ្រួសារពួកគេ ក្រោយថ្ងៃធ្វើរដ្ឋប្រហារ ថ្ងៃទី១៨ ខែមីនានោះដែរ ។

ក្រោយពេលត្រូវបង្ខំឱ្យធ្វើមាតុភូមិនិវត្តន៍ទៅរស់នៅប្រទេសវៀតណាមខាងត្បូង វិញ ពួកគេក៏បានស្ម័គ្រចិត្តចូលបម្រើក្នុងជួរទាហានធីវ-គី ។ លុះបានចូលមកបើកប្រតិបត្តិការសឹកបោសសម្អាតកងទ័ពវៀតកុង-វៀតណាមខាងជើង នៅក្នុងទឹកដីកម្ពុជា ពួកគេក៏មានឱកាសសងសឹកធ្វើបាបប្រជាជនកម្ពុជា វិញដែរ ។

នៅខេត្តស្វាយរៀង និងខេត្តព្រៃវែង ពួកគេបានធ្វើសកម្មភាពធក់ប្លន់ទ្រព្យសម្បត្តិ ចាប់ចងធ្វើទារុណកម្ម រំលោភស្ត្រីភេទ និងបាញ់សម្លាប់ប្រជាជនខ្មែរ មួយចំនួនទៀតផង។ នៅពេលពួកគេវាយចូលដល់ភូមិឃុំណាមួយ ប្រជាជនខ្មែរនៅទីនោះ ត្រូវតែនាំកូនចៅរត់គេចទៅកន្លែងផ្សេងទៀត។ គោក្របីរបស់ប្រជាកសិករខ្មែរប្រមាណ ៤០០ក្បាល ក៏ត្រូវពួកនេះដឹកយកទៅប្រទេសគេ ។

ចំណែកទ្រព្យសម្បត្តិផ្សេងៗ ពិសេសសូម្បីតែឆ្នាំងចានរបស់ប្រជាកសិករខ្មែរ ដែលនាំគ្នារត់គេចខ្លួនបាត់ពីផ្ទះ ក៏ពួកគេយកមកដាក់តម្រៀបគ្នា ហើយបើករថក្រោះកិនកម្ទេចចោលដែរ ។

នៅក្នុងវត្តមួយនៅជាយរួមខេត្តស្វាយរៀង ទាហានរដ្ឋការវៀតណាមខាងត្បូងបានបាញ់សម្លាប់ព្រះសង្ឃមួយអង្គ ដោយសារព្រះសង្ឃអង្គនោះចេញមកជួយការពារទ្រព្យសម្បត្តិអ្នកភូមិ។ ព្រះសង្ឃ២អង្គទៀត ត្រូវពួកគេចាប់សម្រាតស្បង់ចីវរ ហើយឱ្យស្លៀកពាក់ធម្មតា នាំយកទៅឱ្យកងទ័ពអាមេរិក ជាមេបញ្ជាការរបស់ពួកគេ ដោយប្រាប់ថា ព្រះសង្ឃទាំង២អង្គនោះជាកម្មាំងបង្កប់របស់ពួកវៀតកុង ។

នៅខេត្តក្រចេះ និងខេត្តកំពង់ចាម ពួកទាហានធីវ-គី ក៏បានធ្វើសកម្មភាពលួចប្លន់ទ្រព្យសម្បត្តិ និងបាញ់សម្លាប់ ធ្វើបាបប្រជាជនខ្មែរ ដូចនៅខេត្តព្រៃវែង តាកែវ កំពង់ស្ពឺ និងខេត្តផ្សេងៗទៀតដែរ ។

តែទោះបីយ៉ាងណា ក៏អន្តរាគមន៍របស់កងទ័ពអាមេរិក និងកងទ័ពរដ្ឋការវៀតណាមខាងត្បូងនេះ ពិតជាមិនអាចខ្វះបានឡើយ ព្រោះទាហានលន់ នល់ ដែលទើបនឹងចូលមកថ្មីៗ មិនទាន់បានហ្វឹកហាត់ក្បួនយុទ្ធសាស្ត្រអ្វីផង ត្រូវគេបញ្ជូនទៅ

សមរភូមិភ្នាមៗ អ្នកខ្លះហៅទាហានប្រភេទនេះថា ទាហាន២៤ម៉ោងនោះ ត្រូវបាក់ទ័ព ស្ទើរគ្រប់សមរភូមិ និងបានដកថយបោះបង់ទីតាំងឈរជើងរបស់ខ្លួនជាបន្តបន្ទាប់ ។

ទាហានលន់ នល់ កាន់តែចុះខ្សោយទៅៗ សូម្បីតែទីរួមខេត្តកំពង់ស្ពឺ នៅមិនឆ្ងាយប៉ុន្មានពីទីក្រុងភ្នំពេញ ក៏កងទ័ពវៀតកុង-វៀតណាមខាងជើង វាយចូលបានដែរ ។ ដើម្បីវាយដណ្ដើមទីរួមខេត្តនេះមកវិញ រដ្ឋាភិបាលលន់ នល់ គ្មានសមត្ថភាពអ្វីក្រៅពីសុំកម្លាំងជំនួយពីកងទ័ពវៀតណាមខាងត្បូង នោះឡើយ ។

នៅពេលជួយវាយដណ្ដើមយកទីរួមខេត្តកំពង់ស្ពឺ បានមកវិញ កងទ័ពវៀតណាមខាងត្បូង ក៏បានប្រមូលយករថយន្តរបស់ប្រជាពលរដ្ឋខ្មែរជាច្រើនគ្រឿង ព្រមទាំងទ្រព្យសម្បត្តិ និងទំនិញផ្សេងៗនៅតាមហាងនានា ដែលម្ចាស់រត់ចោលនោះ ដឹកតាមឧទ្ធម្ភាគចក្រយកទៅប្រទេសគេដែរ។ ប៉ុន្តែបើពួកគេដឹងថា ម្ចាស់ផ្ទះ ឬម្ចាស់ហាងលក់ទំនិញនោះ មានសែស្រឡាយជាជនជាតិវៀតណាម ក៏ពួកគេមិនប៉ះពាល់ដែរ ។

ក្នុងសារទូរលេខសម្ងាត់មួយចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ១៩៧០ តំណាងប្រទេសកម្ពុជាប្រចាំនៅអង្គការសហប្រជាជាតិ បានផ្ញើមកឱ្យឧត្តមសេនីយ៍លន់ នល់ ដឹងថា ប្រធានាធិបតីវៀតណាមខាងត្បូង ង្វៀន វ៉ាន់ ធីវ បាននិយាយប្រាប់អ្នកកាសែតវ៉ាស៊ីនតោនប៉ុស្តិ៍ របស់អាមេរិក ឈ្មោះស្តេនឡី ខារណាវ( Stanley Karnow ) ថា វៀតណាមខាងត្បូង មានបំណងគ្រប់គ្រងប្រជាជនខ្មែរនៅក្នុងប្រទេសកម្ពុជា ដូចការគ្រប់គ្រងខ្មែរកម្ពុជាក្រោម នៅវៀតណាមខាងត្បូងដែរ ។




ទាហានលន់ នល់ នៅអ្នកលឿង



**នាវាដឹកកងទ័ពរដ្ឋការវៀតណាមខាងត្បូង មកឡើងកំពង់ចម្លងអ្នកលឿងត្រើយខាងកើត**

បន្ទាប់មកទៀត ឧត្តមសេនីយ៍ង្វៀន កាវគី អនុប្រធានាធិបតីវៀតណាមខាងត្បូង ក៏បានប្រកាសថា វៀតណាមខាងត្បូង មិនទាមទារយកកោះនានា នៅតាមផ្ទៃសមុទ្ររបស់ប្រទេសកម្ពុជា ដូចកាលមុនឆ្នាំ១៩៧០ទៀតទេ តែគាត់មានបំណងយកតំបន់ចំពុះទា ខេត្តស្វាយរៀង ដែលកងទ័ពគាត់វាយដណ្ដើមបានពីកងទ័ពវៀតកុង-វៀតណាមខាងជើងនោះ ធ្វើជារបស់វៀតណាមខាងត្បូង ។

មិនតែប៉ុណ្ណោះឧត្តមសេនីយ៍វៀតណាមខាងត្បូងម្នាក់ ដែលជាមេបញ្ជាការបើកប្រតិបត្តិការនៅក្នុងទឹកដីកម្ពុជា ក៏បាននិយាយប្រាប់ភ្ញៀវបរទេសរបស់គេថា៖ " ប្រជាជនខ្មែរមានចរិតលក្ខណៈដូចជនជាតិម៉ស់ (Mois) ដែលជាកុលសម្ព័ន្ធនៅតំបន់ខ្ពង់រាបតណ្ឌូចិន ដែរ បើយើងធ្វើកំសាកជាមួយពួកនេះ ច្បាស់ជាពួកនេះកម្ចាត់យើងជាមិនខាន តែបើយើង ត្រួតត្រាពួកគេដោយគ្មានត្រាប្រណីនោះ ពួកគេច្បាស់ជាមកឱបជើងយើងមិនខាន ។

នៅទីប្រជុំជនអ្នកលឿង ត្រើយខាងកើតទន្លេមេគង្គ ក្នុងទឹកដីខេត្តព្រៃវែង កងទ័ពវៀតណាមខាងត្បូង ដែលបោះ ទីតាំងនៅទីនោះ បានលើកទង់ជាតិវៀតណាមខាងត្បូង ជាច្រើន និងលើកខ្ពស់ៗជាងទង់ជាតិខ្មែរទៅទៀត ហើយពួកគេបានហៅទីប្រជុំជនអ្នកលឿងនោះថា សាយហ្គនម៉ឺយ បានន័យថា " ព្រៃនគរថ្មី" របស់ពួកគេទៀតផង ។

ឧត្តមសេនីយ៍ ង្វៀន កាវគី អនុប្រធានាធិបតីវៀតណាមខាងត្បូង បានប្រកាសថា កងទ័ពរបស់ខ្លួនជាអ្នករ៉ាប់រងផ្លូវជាតិសំខាន់ៗ និងផ្លូវទឹកទន្លេមេគង្គរបស់កម្ពុជា ហើយថាខ្លួនមានគម្រោងបង្កើតមូលដ្ឋានកងទ័ពអាកាសមួយនៅទីប្រជុំជនអ្នកលឿងនោះ ទៀតផង។ ប៉ុន្តែ មន្ត្រីយោធា និងមន្ត្រីទូតអាមេរិក នៅវៀតណាមខាងត្បូង ដែលមិនសូវ ពេញចិត្តនឹងអំណួតអួតអាងនេះ បានណែនាំង្វៀន កាវគី ថាកុំនិយាយផ្តេសផ្តាសពាសវាលពាសកាល ហើយត្រូវចេះលាក់ការណ៍ខ្លះផង ។

នៅថ្ងៃទី១១ ខែឧសភា ឆ្នាំ១៩៧០ រដ្ឋាភិបាលលន់ នល់ ក៏បានបង្កើតគណៈកម្មការចម្រុះមួយដើរស្រង់ស្ថិតិផ្ទះសម្បែងរបស់អាណិកជនវៀតណាម ដែលលក់ដូរមិនទាន់ ដោយសារត្រូវបង្ខំឱ្យទៅស្នាក់នៅជំរំប្រមូលផ្តុំ ដើម្បីរៀបចំចេញដំណើរធ្វើមាតុភូមិនិវត្តន៍ទៅរស់នៅប្រទេសវៀតណាមខាងត្បូង វិញនោះដើម្បី ធ្វើការបែងចែកដល់ប្រជាពលរដ្ឋ និងមន្ត្រីរដ្ឋការរបស់ខ្លួន។ ប៉ុន្តែ ២-៣ថ្ងៃក្រោយមក រដ្ឋាភិបាលក្រុងព្រៃនគរ ក៏បានធ្វើការតវ៉ា និងព្រមានយ៉ាងគំរោះគំរើយពីបញ្ហានេះ រហូតដល់រដ្ឋាភិបាលលន់ នល់ បង្ខំចិត្តបោះបង់គម្រោងការបែងចែកផ្ទះជនជាតិវៀតណាមទាំងនោះ ទៅឱ្យប្រជាពលរដ្ឋ និងមន្ត្រីរបស់ខ្លួនចោលវិ ញ។

នៅទីបំផុត រដ្ឋាភិបាលលន់ នល់ ក៏បានប្រគល់ផ្ទះសម្បែងទាំងអស់នោះ ទៅឱ្យជនជាតិវៀតណាមទាំងឡាយណា ដែលមានសិទ្ធិរស់នៅលើទឹកដីកម្ពុជា បន្តទៀត ។

ពេលនោះ រដ្ឋការក្រុងព្រៃនគរ ក៏បានស្រង់ស្ថិតិជនជាតិវៀតណាម ដែលត្រូវពួកទាហានលន់ នល់ សម្លាប់ ក្រោយថ្ងៃរដ្ឋប្រហារទម្លាក់សម្តេចសីហនុ ព្រមទាំងផ្ទះសម្បែងទ្រព្យសម្បត្តិអាណិកជនវៀតណាមទាំងអស់ នៅក្នុងប្រទេសកម្ពុជា ដែលត្រូវ

រងការធក់ប្លន់ និងរឹបអូសយកទាំងប៉ុន្មាន។ តែការស្រង់ស្ថិតិនោះត្រូវបានពួកគេដាក់ពន្ទើសពីការពិតជាក់ស្តែង រាប់រយដងឯណោះ ហើយពួកគេទាមទារឱ្យរដ្ឋាភិបាលលន់ នល់ សងសំណងគិតជាទឹកប្រាក់យ៉ាងច្រើនសន្ធឹកសន្ធាប់ទៅឱ្យអាណិកជនវៀតណាម ជាអ្នករងគ្រោះវិញ ។

អំឡុងពេលកងនាវារដ្ឋការវៀតណាមខាងត្បូងបានចូលចតនៅកំពង់ផែក្រុងភ្នំពេញ ក៏កើតមានជម្លោះបាញ់ប្រហារគ្នាជាមួយទាហានរដ្ឋាភិបាលលន់ នល់ រហូតដល់មានរថក្រោះចេញទៅជួយធ្វើអន្តរាគមន៍ និងបណ្តាលឱ្យអតីតវិមានរដ្ឋាភិបាលនៅខាងកើតរមណីយដ្ឋានវត្តភ្នំ គឺអគារក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) សព្វថ្ងៃនេះ ត្រូវគ្រាប់កាំភ្លើងជាច្រើនកន្លែង ដោយសារកងនាវារដ្ឋការវៀតណាមខាងត្បូង បាញ់រះពីផ្ទៃទន្លេមក ។



មេទាហានលន់ នល់ និងមេទាហានយួនខាងត្បូង ឈ្លោះប្រកែកគ្នា
ផ្អើលពួកកាសែតបរទេស

# ២៨៦
# លន់ នល់ ស្តារទំនាក់ទំនងការទូត ជាមួយវៀតណាមខាងត្បូង ឡើងវិញ



លន់ នល់ ទទួលស្វាគមន៍អនុប្រធានាធិបតីវៀតណាមខាងត្បូង ង្វៀន កាវ់គី

ថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧០ អ្នកធ្វើយធ្វងព័ត៌មានរបស់កាសែតអាអេហ្វប៉េ (AFP) របស់បារាំង និងរ៉យទ័រ (Reuters) របស់អង់គ្លេស បានរាយការណ៍ពីទីក្រុងមូស្គូមកថា ថ្ងៃនេះ សម្តេចសីហនុ ប្រមុខរដ្ឋប្រទេសកម្ពុជា ធ្លាក់ពីតំណែង បានស្នើសុំឱ្យរដ្ឋាភិបាលក្រុងមូស្គូ ទទួលស្គាល់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា របស់ព្រះអង្គ ជាផ្លូវការ ។

ការស្នើសុំរបស់ព្រះអង្គនេះ បានធ្វើឡើងតាមរយៈការផ្ញើសារទូរលេខមួយ ទៅកាន់នាយករដ្ឋមន្ត្រីសហភាពសូវៀត កូស៊ីហ្គីន (Kosigin) ដែលពេលនោះ គាត់គ្រាន់តែបានគាំទ្រសម្តេចសីហនុ ជាលក្ខណៈឯកជនប៉ុណ្ណោះ ប៉ុន្តែជាផ្លូវការ រដ្ឋាភិបាលសហភាពសូវៀត មិនទាន់ទទួលស្គាល់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ដែលព្រះអង្គបង្កើតឡើងនៅក្រុងប៉េកាំង នោះទេ ។

ក្នុងសារទូរលេខនោះ សម្តេចសីហនុ លើកហេតុផលថា សហភាពសូវៀត ជាប្រទេសមួយក្នុងចំណោមបណ្តាប្រទេសទាំងឡាយ ដែលបានទទួលស្គាល់រដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្នវៀតណាមខាងត្បូង ( ពួកវៀតកុង។ ការតស៊ូរបស់ប្រជាជនវៀតណាម និងការតស៊ូរបស់ប្រជាជនកម្ពុជា មិនអាចបំបែកពីគ្នាបានទេ ។

កងទ័ពរណសិរ្សរួបរួមជាតិកម្ពុជា និងប្រជាជនកម្ពុជា កំពុងប្រយុទ្ធតស៊ូប្រឆាំងនឹងការឈ្លានពានយ៉ាងសាហាវឃោរឃៅរបស់ពួកចក្រពត្តិអាមេរិក និងរដ្ឋការក្រុងព្រៃនគរ ដូចរណសិរ្សរំដោះជាតិ និងរដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្នវៀតណាមខាងត្បូង ដែរ ចុះហេតុអ្វី បានជាសហភាពសូវៀត មិនទទួលស្គាល់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ជាផ្លូវការផង? ។

សម្តេចសីហនុ បានលើកហេតុផលបន្តថា សហភាពសូវៀត ធ្លាប់មានប្រពៃណីប្រឆាំងពួកអាណានិគមនិយម និងពួកចក្រពត្តិនិយមគ្រប់ប្រភេទ ហើយក៏មិនធ្លាប់រួញរាក្នុងការគាំទ្រចំពោះប្រជាជន ដែលកំពុងប្រយុទ្ធតស៊ូពីការគាបសង្កត់ជិះជាន់ដើម្បីទាមទារសេរីភាពរបស់ខ្លួនដែរ ដូច្នេះព្រះអង្គទទូចឱ្យរដ្ឋាភិបាលសហភាពសូវៀតទទួលស្គាល់រាជរដ្ឋាភិបាលរបស់ព្រះអង្គជាផ្លូវការ ។

អ្នកឆ្លើយឆ្លងព័ត៌មានកាសែតអាអេហ្វប៉េ និងរ៉យទ័រ ក៏បញ្ជាក់ដែរថា កាលពីសប្តាហ៍មុន នៅក្នុងសន្និសីទកាសែតមួយ កូស៊ីហ្គីន នាយករដ្ឋមន្ត្រីសហភាពសូវៀត បានថ្លែងថា គាត់ចាត់ទុកសម្តេចសីហនុ ជាមេដឹកនាំស្របច្បាប់របស់ប្រទេសកម្ពុជា ។ ប៉ុន្តែពេលអ្នកកាសែតសួរថា តើរដ្ឋាភិបាលកម្ពុជា ណាមួយ ដែលរដ្ឋាភិបាលសហភាពសូវៀត ទទួលស្គាល់? គាត់បែរជានៅស្ងៀម មិនព្រមឆ្លើយទៅវិញ ។

ថ្ងៃទី១៦ ខែឧសភា ឆ្នាំ១៩៧០ ឧត្តមសេនីយ៍លន់ នល់ ក្នុងនាមជានាយករដ្ឋមន្ត្រី បានផ្ញើលិខិតមួយទៅជូនគណៈរដ្ឋមន្ត្រីរបស់គាត់ ស្តីពីផែនការប្រមូលជនជាតិចិនទាំងអស់ យកទៅដាក់ក្នុងជំរំប្រមូលផ្តុំ ដូចជនជាតិវៀតណាម កាលពីខែមុនដែរ ដើម្បីជួយពិចារណា និងផ្តល់យោបល់ ។

នៅក្នុងលិខិតនោះ លន់ នល់ បញ្ជាក់ថា គាត់នឹងធ្វើសេចក្ដីថ្លែងការណ៍មួយពីបញ្ហានេះ ដើម្បីឱ្យគេចាក់ផ្សាយតាមវិទ្យុជាតិផងដែរ។ ប៉ុន្តែ សមាជិកគណៈរដ្ឋមន្ត្រីភាគច្រើន មិនឯកភាពតាមផែនការនេះឡើយ ។

ការពិត រដ្ឋមន្ត្រី និងរដ្ឋលេខាធិការភាគច្រើន ពិសេសគឺ នាយករដ្ឋមន្ត្រីលន់ នល់ ខ្លួនឯងហ្នឹង ក៏ជាប់សែស្រឡាយជាជនជាតិចិនដែរ គ្រាន់តែតិច ឬច្រើនប៉ុណ្ណោះ។ ផែនការនេះ ធ្វើឱ្យជនជាតិចិននៅក្នុងប្រទេសកម្ពុជា ប្រមាណ៣ សែននាក់មានការជ្រួលច្របល់ រហូតដល់មានការប្រឆាំងតវ៉ា ។

ថ្ងៃទី១៨ ខែឧសភា ទ្រង់សិរិមតៈ ឧបនាយករដ្ឋមន្ត្រី បានចេញសារាចរមួយដើម្បីកាត់បន្ថយការភ័យខ្លាចរបស់ជនជាតិចិន ពីបញ្ហាប្រមូលផ្ដុំពួកគេដាក់ក្នុងជំរំនោះ ហើយលន់ នល់ ក៏បានធ្វើការអំពាវនាវដល់ជនជាតិចិនទាំងអស់ កុំឱ្យបារម្ភពីបញ្ហានេះទៀត។ ប៉ុន្តែ ទោះបីយ៉ាងនេះក៏ដោយ ក៏ជនជាតិចិន ជាអ្នកមានភាគច្រើននាំគ្នាបង្វែរប្រាក់បញ្ញើរបស់ពួកគេនៅក្នុងធនាគារក្នុងប្រទេស ទៅដាក់នៅក្នុងធនាគារហុងកុង ឬសិង្ហបុរីវិញ ហើយម្នាក់ៗត្រៀមខ្លួន ចាំតែរត់ចេញទៅក្រៅប្រទេសប៉ុណ្ណោះ។

ថ្ងៃទី១៩ ខែឧសភា រដ្ឋាភិបាលលន់ នល់ បានប្រកាសផ្សារទំនាក់ទំនងការទូតជាមួយប្រទេសវៀតណាមខាងត្បូង និងប្រទេសថៃ ឡើងវិញ ក្រោយពីសម្ដេចសីហនុកាត់ផ្ដាច់ទំនាក់ទំនងការទូតជាមួយប្រទេសទាំងពីរ អស់រយៈពេល ៧ឆ្នាំមក ។

នៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩៧០នោះដែរ មេដឹកនាំក្រុងហាណូយ បានរៀបចំពិធីបុណ្យខួបកំណើតលើកទី៨០ របស់ហូ ជីមិញ ដើម្បីជាការរំលឹកនឹកគុណដល់មេដឹកនាំដ៏ល្បីល្បាញរបស់ពួកគេ ។ ហូ ជីមិញ កើតនៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៨៩០ និងបានទទួលមរណភាពដោយជំងឺគាំងបេះដូង កាលពីថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៦៩។

មេដឹកនាំបក្សកុម្មុយនិស្ដចិន បានផ្ញើសារលិខិតមួយច្បាប់ទៅបក្សពលករវៀតណាម ដើម្បីចូលរួមក្នុងពិធីនោះដែរ។ នៅក្នុងសារលិខិតនោះ មេដឹកនាំចិនក៏បានក្រើនរម្លឹកថា ប្រជាជនវៀតណាម ត្រូវតែរួបរួមជាមួយប្រជាជនកម្ពុជា និងប្រជាជន

លាវ ប្រយុទ្ធតស៊ូរហូតបានជ័យជម្នះទាំងស្រុង ។

នៅថ្ងៃ១៩ ខែឧសភា នោះដែរ សម្តេចសីហនុ ក៏បានធ្វើការបដិសេធជាផ្លូវការ ថា កងទ័ពស្មោះត្រង់ជាមួយព្រះអង្គ ( កងទ័ពវៀតកុង-វៀតណាមខាងជើង? ) មិនបានសម្លាប់សង្ឃកាតូលិក ២អង្គ គឺកូដែល និងរ៉ូឡាំង ដែលត្រូវបាត់បង់ជីវិត នៅក្នុងប្រទេសកម្ពុជា កាលពីប៉ុន្មានថ្ងៃកន្លងមកនេះទេ ហើយព្រះអង្គបានទម្លាក់ ការទទួលខុសត្រូវករណីឃាតកម្មនេះទៅលើពួកអាមេរិក និងទាហានរបស់លន់ នល់ ទៅវិញ ។

ថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧០ ម៉ៅ សេទុង បានប្រកាសសេចក្តីថ្លែងការណ៍ មួយ គាំទ្រពេញទំហឹងចំពោះស្មារតីប្រយុទ្ធតស៊ូរបស់សម្តេចសីហនុ ប្រមុខរដ្ឋនៃ ប្រទេសកម្ពុជា ក្នុងការប្រឆាំងនឹងពួកចក្រពត្តិអាមេរិក និងបរិវារ ព្រមទាំងគាំទ្រយ៉ាង កក់ក្តៅចំពោះសេចក្តីថ្លែងការណ៍រួមរបស់សន្និសីទកំពូលរបស់ប្រជាជនឥណ្ឌូចិន ដែលធ្វើឡើងកាលពី ថ្ងៃទី២៤ និង២៥ ខែមេសា កន្លងទៅថ្មីៗនេះ ។

ក្នុងសេចក្តីថ្លែងការណ៍ដដែលនោះ ម៉ៅ សេទុង ក៏បានសម្តែងការគាំទ្រ យ៉ាងពេញទំហឹងចំពោះការបង្កើតរាជរដ្ឋាភិបាលរួបរួមជាតិ និងទទួលស្គាល់ថាជា រដ្ឋាភិបាលស្របច្បាប់របស់ប្រទេសកម្ពុជា ។

ក្រៅពីប្រទេសចិន កូរ៉េខាងជើង និងវៀតណាមខាងជើង ក៏មានប្រទេស ជាង១០ទៀត បានគាំទ្រ និងទទួលស្គាល់រដ្ឋាភិបាលរួបរួមជាតិដែរ ដូចជាៈ ប្រទេស គុយបា, អាល់បានី, រ៉ូម៉ានី, យូហ្គោស្លាវី, អាល់ហ្សេរី, សាធារណរដ្ឋអារ៉ាប់រួម, អ៊ីរ៉ាក់, យេម៉ែន, ម៉ូរីតានី, កុងហ្គោ, តង់ហ្សានី និងស្រីលង្កា ។

ជាមួយនឹងការគាំទ្រនេះ បើទោះបីសម្តេចសីហនុ ធ្វើការតវ៉ាយ៉ាងណា ក៏ អ៊ូ ថាន់ អគ្គលេខាធិការអង្គការសហប្រជាជាតិ នៅតែប្រគល់អាសនៈកម្ពុជា ប្រចាំនៅក្នុង អង្គការសហប្រជាជាតិ ទៅឱ្យរដ្ឋាភិបាលលន់ នល់ តាមការទាមទាររបស់រដ្ឋាភិបាល ភ្នំពេញ ដែរ ។

នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៧០ កាសែតញូវយ៉កថៃម របស់អាមេរិកបាន ចុះផ្សាយថា សម្តេចសីហនុ អតីតប្រមុខរដ្ឋប្រទេសកម្ពុជា ដែលបានមករស់នៅ ក្នុងប្រទេសចិន តាំងពីថ្ងៃទី ១៩ ខែមីនា នោះ នឹងត្រូវយាងទៅបំពេញទស្សនកិច្ច ជាផ្លូវការនៅសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម (វៀតណាមខាងជើង) ក្នុង ពេលឆាប់ៗខាងមុខនេះ តាមការអញ្ជើញរបស់ប្រធានាធិបតី តុង ឌឹកថាំង ។

ជាមួយគ្នានោះ ក្រសួងការបរទេសវៀតណាមខាងជើង ក៏បានប្រកាសថា រដ្ឋាភិបាលខ្លួនបានបង្កើតគណៈកម្មការមួយ ដើម្បីរៀបចំពិធីទទួលបដិសណ្ឋារកិច្ចយ៉ាងឱឡារិកមួយ ថ្វាយចំពោះសម្តេចសីហនុ ផងដែរ ។

កាសែតដដែលបានបន្តថា នេះជាដំណើរទស្សនកិច្ចលើកដំបូងបង្អស់របស់ សម្តេចសីហនុ តាំងពីថ្ងៃ ដែលព្រះអង្គ មកដល់ទីក្រុងប៉េកាំង ថ្ងៃទី១៩ មីនា គឺបន្ទាប់ពី រដ្ឋសភាកម្ពុជា បានទម្លាក់ព្រះអង្គចេញពីតំណែង ។

នៅក្នុងអំឡុងពេលស្នាក់នៅប្រទេសចិន ព្រះអង្គត្រូវបានចាត់ទុកថា ជាភ្ញៀវ មានកិត្តិយសបំផុត ដោយព្រះអង្គ តែងតែបង្ហាញព្រះភក្ត្រជាមួយម៉ៅ សេទុង ហើយ បានក្លាយទៅជាមិត្តភក្តិដ៏ជិតស្និទ្ធបំផុត របស់នាយករដ្ឋមន្ត្រី ជូ អេនឡាយ ផងដែរ ។

រដ្ឋាភិបាលចិន បានចាក់ផ្សាយនូវសេចក្តីប្រកាសអំពាវនាវរបស់ប្រធានម៉ៅ ដែលស្នើឱ្យចលនាបដិវត្តន៍ពិភពលោក ប្រឆាំងនឹងសហរដ្ឋអាមេរិក និងគាំទ្រសម្តេច សីហនុ ។ មេដឹកនាំចិន បានទាញយកផលប្រយោជន៍យ៉ាងពេញទំហឹងពីវត្តមាន របស់សម្តេចសីហនុ នៅក្រុងប៉េកាំង ដើម្បីបង្ហាញឱ្យពិភពលោកដឹងថា ខ្លួនជាជើង ឯក មានតួនាទីសំខាន់សម្រាប់ប្រជាជនឥណ្ឌូចិន ។ ពេលនោះដែរ សម្តេចសីហនុ បាន ថ្លែងប្រាប់កាសែតស៊ីនហួរ របស់ចិន ថា មេដឹកនាំវៀតណាមខាងជើង និងមេដឹកនាំរដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្នវៀតណាមខាងត្បូង (វៀតកុង) បានប្រកាសទទួល ស្គាល់ និងគោរពព្រំដែនបច្ចុប្បន្នរបស់ប្រទេសកម្ពុជា ហើយថា ពួកគេនឹងមិនឈ្លានពាន កម្ពុជា ឡើយ ។

ជាមួយគ្នានោះ សម្តេចសីហនុ បានអំពាវនាវចំពោះប្រជាជនខ្មែរទាំងឡាយដែលកំពុងគាំទ្ររដ្ឋាភិបាលលន់ នល់ ថា ពួកគេនឹងត្រូវអត់ឱនទោស ប្រសិនបើពួកគេមានការភ្ញាក់រលឹកទាន់ពេលវេលា មកចូលរួមតស៊ូនៅក្រោមការដឹកនាំរបស់រណសិរ្សរួបរួមជាតិកម្ពុជា ។

ថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៧០ សហរដ្ឋអាមេរិក បានផ្តល់ជំនួយជាសម្ភារយោធាដល់រដ្ឋាភិបាលលន់ នល់ គិតជាទឹកប្រាក់ ស្មើនឹងចំនួន ៧,៥លានដុល្លារអាមេរិក ។

នៅព្រឹកថ្ងៃទី២៧ ខែឧសភា ឆ្នាំ១៩៧០ នៅទីក្រុងព្រៃនគរ យ៉ែម សំបូរ ឧបនាយករដ្ឋមន្ត្រីទី២ និងរដ្ឋមន្ត្រីក្រសួងការបរទេស បានធ្វើពិធីចុះហត្ថលេខាជាមួយរដ្ឋមន្ត្រីក្រសួងការបរទេសវៀតណាមខាងត្បូង ដើម្បីផ្សារទំនាក់ទំនងការទូតជាផ្លូវការ រវាងប្រទេសទាំង២ឡើងវិញ ។

ក្រោយពីពិធីចុះហត្ថលេខានោះមក យ៉ែម សំបូរ បានថ្លែងប្រាប់ក្រុមអ្នកកាសែតថា ប្រទេសកម្ពុជា ក៏កំពុងពិនិត្យលទ្ធភាពនៃការផ្សារទំនាក់ទំនងការទូតថ្នាក់ស្ថានបេសកកម្មជាមួយកោះតៃវ៉ាន់ ផងដែរ ។

ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៧០ អនុប្រធានាធិបតីវៀតណាមខាងត្បូង ង្វៀន កាវគី (Nguyen Cao Ky) មកបំពេញទស្សនកិច្ចនៅទីក្រុងភ្នំពេញ។ នាយករដ្ឋមន្ត្រីលន់ នល់ បានទៅទទួលស្វាគមន៍ដល់អាកាសយានដ្ឋានពោធិ៍ចិនតុង ។

ថ្ងៃទី២០ និង២១ ខែមករា ឆ្នាំ១៩៧១ នាយករដ្ឋមន្ត្រីលន់ នល់ បានដឹកនាំគណៈប្រតិភូមួយក្រុម ក្នុងនោះក៏មាន វត្តមានអតីតមេខ្មែរសេរីសឺង ង៉ុកថាញ់ ផងដែរ បានទៅបំពេញទស្សនកិច្ចនៅទីក្រុងព្រៃនគរ( សាយហ្គន ) ប្រទេសវៀតណាមខាងត្បូង ។

ថ្ងៃទី២១ ខែមករា ជាថ្ងៃបញ្ចប់ដំណើរទស្សនកិច្ចរយៈពេលពីរថ្ងៃនៅទីនេះ នាយករដ្ឋមន្ត្រីលន់ នល់ ថ្លែងក្នុងសន្និសីទសារព័ត៌មាន ជាភាសាបារាំង ថា កម្ពុជានឹង

កាត់បន្ថយភាពតានតឹងជាមួយវៀតណាមខាងត្បូង ដើម្បីពង្រីកទំនាក់ទំនងល្អជាមួយគ្នាឡើងវិញ ។

នាយករដ្ឋមន្ត្រីលន់ នល់ ថ្លែងបញ្ជាក់ថា ក្នុងពេលឆាប់ៗនេះ គាត់នឹងបញ្ជូនគណៈប្រតិភូកម្ពុជា មួយក្រុមទៀត ឱ្យមកទីក្រុងព្រៃនគរ( សាយហ្គន ) ដើម្បីចុះហត្ថលេខាលើកិច្ចព្រមព្រៀងទទួលស្គាល់ព្រំដែនរួមគ្នា និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្ដីពីការពង្រីកវិស័យទូរគមនាគមន៍, ការដឹកជញ្ជូន, ទេសចរណ៍ ព្រមទាំងការប្រើប្រាស់ទន្លេមេគង្គ រួមគ្នា ក្នុងនាមជាសម្ព័ន្ធមិត្ត និងជាប្រទេសជិតខាងគ្នាផងដែរ ។

សម្ដេចសីហនុ បានកាត់ផ្ដាច់ទំនាក់ទំនងការទូតជាមួយប្រទេសវៀតណាមខាងត្បូង កាលពីឆ្នាំ១៩៦៤។ តែក្រោយពីធ្វើរដ្ឋប្រហារទម្លាក់សម្ដេចសីហនុ នាថ្ងៃទី១៨ ខែមីនា បានប្រហែល៣ខែប៉ុណ្ណោះ នាយករដ្ឋមន្ត្រីលន់ នល់ ក៏បានស្ដារទំនាក់ទំនងការទូតជាមួយប្រទេសដែលជាគូសត្រូវមួយនេះឡើងវិញ ។

ជាមួយគ្នានោះដែរ នាយករដ្ឋមន្ត្រីលន់ នល់ ក៏បានព្រមព្រៀងជាមួយរដ្ឋាភិបាលវៀតណាមខាងត្បូង ស្ដីពីការបង្កើតគណៈកម្មការចម្រុះមួយ ដើម្បីត្រួតពិនិត្យសកម្មភាពប្រទូសរ៉ាយដោយសារការរើសអើងជាតិសាសន៍ខ្មែរ-វៀតណាម ផងដែរ ។

កិច្ចព្រមព្រៀងស្ដីពីការបង្កើតគណៈកម្មការចម្រុះនេះ កើតចេញពីភាគីវៀតណាមខាងត្បូង បានចោទប្រកាន់ថា ក្រោយរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ទាហាន និងពលរដ្ឋខ្មែរបានធ្វើសកម្មភាពសម្លាប់រង្គាលជនជាតិវៀតណាម នៅក្នុងប្រទេសកម្ពុជា ។

ចំណែក ភាគីរដ្ឋាភិបាលសាធារណរដ្ឋខ្មែរ បានចោទប្រកាន់ថា ទាហានរដ្ឋការវៀតណាមខាងត្បូង បានចាប់រំលោភស្ត្រីភេទ និងប្លន់ទ្រព្យសម្បត្តិរបស់ពលរដ្ឋខ្មែរក្នុងអំឡុងពេលពួកគេចូលមកធ្វើប្រតិបត្តិការសឹកនៅក្នុងប្រទេសកម្ពុជា ។

ដោយឡែកចំពោះបញ្ហាបំណុលហិរញ្ញវត្ថុរវាងប្រទេសទាំងពីរ នាយករដ្ឋមន្ត្រីលន់ នល់ បានថ្លែងថា បញ្ហាខ្វែងគំនិតគ្នាផ្នែកហិរញ្ញវត្ថុរវាងសម្ព័ន្ធមិត្តទាំងពីរ ពេលនេះត្រូវទុកមួយឡែកសិន ដោយទុកឱ្យថ្នាក់រដ្ឋមន្ត្រីជួបគ្នា ដើម្បីធ្វើការដោះស្រាយ

នៅពេលក្រោយ ។

បញ្ហាខ្វែងគំនិតគ្នាផ្នែកហិរញ្ញវត្ថុរវាងសម្ព័ន្ធមិត្តទាំងពីរ បានកើតឡើងដោយសារភាគីវៀតណាមខាងត្បូង ទាមទារឱ្យ ភាគីរដ្ឋាភិបាលសាធារណរដ្ឋខ្មែរ បង់ថ្លៃឈ្នួលឱ្យទាហានរដ្ឋការវៀតណាមខាងត្បូង ដែលចូលមកជួយរដ្ឋាភិបាលសាធារណរដ្ឋខ្មែរ ដើម្បីវាយប្រយុទ្ធទប់ទល់ជាមួយកងទ័ពវៀតកុង-វៀតណាមខាងជើង នៅក្នុងប្រទេសកម្ពុជា។ ទន្ទឹមគ្នានេះ ភាគីវៀតណាមខាងត្បូង ក៏ទាមទារឱ្យភាគីរដ្ឋាភិបាលសាធារណរដ្ឋខ្មែរ សងបំណុលដែលភាគីវៀតណាមខាងត្បូង អះអាងថា ភាគីខ្មែរបានជំពាក់ខ្លួនតាំងពីចុងសម័យអាណានិគមបារាំង គឺតាំងពីឆ្នាំ១៩៥៤ទៀតផង ។

នាយករដ្ឋមន្ត្រីលន់ នល់ បានថ្លែងថា បញ្ហានេះ មានតែថ្នាក់រដ្ឋមន្ត្រីការពារជាតិកម្ពុជា និង វៀតណាមខាងត្បូង ទើបអាចមានលទ្ធភាពដោះស្រាយបាន ។ តែនាយករដ្ឋមន្ត្រីលន់ នល់ បានបញ្ជាក់ហើយបញ្ជាក់ទៀតថា៖ «កម្ពុជា នឹងរក្សាអព្យាក្រឹតភាព» ។

នាយករដ្ឋមន្ត្រីលន់ នល់ បានថ្លែងដែរថា កម្ពុជា បានរៀបចំឱ្យមានការដោះដូរឈ្លើយសឹកវៀតកុង-វៀតណាមខាងជើង ចំនួន១៧នាក់ ជាមួយអ្នកកាសែតចំនួន១៧នាក់ ដែលគេជឿថាត្រូវបានចាប់ខ្លួនដោយកងទ័ពវៀតកុង-វៀតណាមខាងជើង និងពួកខ្មែរម្នាងទៀត។ កន្លងមក កងទ័ពវៀតកុង-វៀតណាមខាងជើង មិនអើពើនឹងសំណើសុំដោះដូរនេះទេ ព្រោះថា បើពួកគេចរចាពិភាក្សាអំពីបញ្ហានេះ មានន័យថា ពួកគេទទួលស្គាល់ថា កងកម្លាំងកុម្មុយនិស្តវៀតណាម កំពុងចូលឈ្លានពានប្រទេសកម្ពុជា ពិតមែន ។

ដោយឡែកចំពោះបញ្ហាជំនួយរបស់សហរដ្ឋអាមេរិក នាយករដ្ឋមន្ត្រីលន់ នល់ បានបញ្ជាក់ប្រាប់ក្រុមអ្នកកាសែតដោយទន់ភ្លន់ថា គាត់នឹងស្នើសុំឧទ្ធម្ភាគចក្រអាមេរិកជាច្រើនគ្រឿងបន្ថែមទៀត។ តែបញ្ហាសុំជំនួយជាកងទ័ពប្រយុទ្ធរបស់សហរដ្ឋអាមេរិក គាត់បានឆ្លើយថា៖ “មិនទាន់មានតម្រូវការចាំបាច់នៅឡើយទេ” ។

ទោះបីយ៉ាងណា ត្រូវបានគេជឿថា នៅរសៀលថ្ងៃទី២១ ខែមករានេះ នាយក

*រដ្ឋមន្ត្រីលន់ នល់ និងជួបពិភាក្សាគ្នាជាមួយឯកអគ្គរដ្ឋទូតអាមេរិក អែលស្វត្ត បាន់ខ័រ (Ellsworth Bunker) និងឧត្តមសេនីយ៍ក្រេកតុន អាប្រាម (Creighton W. Abrams) មេបញ្ជាការកងទ័ពអាមេរិក ប្រចាំនៅវៀតណាម ពីបញ្ហាជំនួយរបស់សហរដ្ឋអាមេរិកនេះ។*

*នាយករដ្ឋមន្ត្រីកម្ពុជា បានលើកដៃសំពះតាមប្រពៃណីព្រះពុទ្ធសាសនា ជារឿយៗ ថ្លែងអំណរគុណចំពោះម្ចាស់ផ្ទះវៀតណាមខាងត្បូងចំពោះ«ការណែនាំ»របស់ពួកគេ ហើយបានកត់សម្គាល់ថា «យើងជាប្រទេសជិតខាងគ្នា ហើយយើងបានយល់ព្រមថាយើងមិនគួរឈ្លោះប្រកែកគ្នាទៀតទេ» ។*



**លន់ នល់ និងសឹង ង៉ុកថាញ់ ពេលទៅបំពេញទស្សនកិច្ចនៅក្រុងព្រៃនគរ**

# ២៨៧
# អតីតខ្មែរវៀតមិញ នៅហាណូយ ត្រលប់មកជួយធ្វើសង្គ្រាមផ្តួលរម្លំរបបលន់ នល់




កែវ មាស កាលសម័យដឹកនាំចលនាតស៊ូមុនឆ្នាំ១៩៥៤

ការបង្កើតរណសិរ្សរួបរួមជាតិកម្ពុជា របស់សម្តេចសីហនុ នៅថ្ងៃទី២៣ ខែមីនា គឺជាការបើកឱកាសឱ្យមេដឹកនាំខ្មែរក្រហម ដែលលាក់ខ្លួនពួននៅតែក្នុងព្រៃ អស់រយៈពេល៧ឆ្នាំមកហើយនោះ ចេញមកដឹកនាំចលនាតស៊ូ ក្រោមការជួយឧបត្ថម្ភគាំទ្ររបស់ពួកវៀតកុង-វៀតណាមខាងជើង ដោយចំហតែម្តង ។

នៅចុងខែមីនា ឆ្នាំ១៩៧០ សាឡុត ស ជាលេខាបក្សកុម្មុយនិស្តកម្ពុជា មិនទាន់ដឹកនាំគណប្រតិភូរបស់គាត់ មកពីប្រទេសចិន វិញនៅឡើយទេ ។

នួន ជា អនុលេខាគណៈកម្មាធិការមជ្ឈិមបក្ស ជាអ្នកទទួលខុសត្រូវជំនួស នៅមន្ទីរមជ្ឈិមបក្ស ក្នុងព្រៃនៃភូមិភាគឦសាននោះ បានជួបពិភាក្សាគ្នាជាមួយឧត្តមសេនីយ៍ មិញ បេសកជនពិសេសរបស់មេដឹកនាំវៀតកុង-វៀតណាមខាងជើង ពីបញ្ហាសហការគ្នាក្នុងការតស៊ូប្រយុទ្ធនឹងពួកចក្រពត្តិអាមេរិក និងផ្ដួលរម្លំរបបអាយ៉ងលន់ នល់ ។

នួន ជា បានព្រមព្រៀងតាមការស្នើសុំមេដឹកនាំវៀតកុង-វៀតណាមខាងជើង ជាសម្ព័ន្ធមិត្តរបស់គាត់ ដែលសុំកាន់កាប់តំបន់មួយចំនួនធំជាបណ្ដោះអាសន្ននៅក្នុងការធ្វើសង្គ្រាមផ្ដួលរម្លំរបបលន់ នល់ ។

នៅក្នុងខែមេសា ឆ្នាំ១៩៧០ សាឡុត ស និងសមាជិកគណៈប្រតិភូទាំងអស់ បានធ្វើដំណើរវិលត្រលប់ពីក្រុងប៉េកាំង មកទីក្រុងហាណូយ វិញ ។ ពេលនោះ ពួកមេដឹកនាំវៀតណាមខាងជើង បានទទួលការស្វាគមន៍ពួកគាត់យ៉ាងកក់ក្ដៅបំផុត ។

ក្នុងពិធីជប់លៀងមួយជូនជាកិត្តិយសដល់សាឡុត ស នាពេលនោះ មេដឹកនាំកុម្មុយនិស្តវៀតណាម បានឡើងថ្លែងសុន្ទរកថាមួយ ដោយគ្មាននិយាយអ្វីក្រៅតែពីការកោតសរសើរការដឹកនាំរបស់មេដឹកនាំបក្សកុម្មុយនិស្តកម្ពុជា តាំងពីដើម រហូតដល់ចប់នោះឡើយ ។

សាឡុត ស បានអះអាងថា ពេលនោះ មេដឹកនាំវៀតណាម បានស្នើគាត់ឱ្យបង្កើតអង្គភាពកងទ័ពចម្រុះគ្នាមួយ ( កម្ពុជា-វៀតណាម) ដូចកាលសម័យតស៊ូខ្មែរឥស្សរៈប្រឆាំងនឹងបារាំង ដែរ។ ប៉ុន្តែ គាត់មានការស្ទាក់ស្ទើរ ព្រោះគាត់មិនចង់ធ្វើខ្លួនឱ្យទៅជាមនុស្សរបស់វៀតណាម ដូចមេដឹកនាំតស៊ូខ្មែរកាលសម័យតស៊ូ ប្រឆាំងបារាំងទៀត។ គាត់យល់ថា បញ្ហាសំខាន់បំផុតរបស់មេដឹកនាំវៀតណាម នៅពេលនោះ គឺពុំមែនបញ្ហារំដោះវៀតណាមខាងត្បូង គឺបញ្ហារំដោះកម្ពុជា ជាបញ្ហាសំខាន់ជាង ។

អំឡុងពេល សាឡុត ស ស្នាក់នៅក្នុងទីក្រុងហាណូយនោះ នួន ជា ក៏បានផ្ញើសារទូរលេខមួយច្បាប់ ដើម្បីរាយការណ៍ទៅសាឡុត ស ឱ្យបានដឹងពីខ្លឹមសារនៃការជួប

ពិភាក្សាគ្នាជាមួយមេដឹកនាំវៀតកុង-វៀតណាមខាងជើង កាលពីចុងខែមីនា នៅភូមិភាគឦសាន នោះផងដែរ ។

នួន ជា បានរាយការណ៍ប្រាប់សាឡុត ស ថា ភាគីទាំង២ បានព្រមព្រៀងថា នឹងសាមគ្គីសហការគ្នាក្នុងការ ប្រឆាំងនឹងពួកចក្រពត្តិអាមេរិក។ ប៉ុន្តែសមាជិកគណៈកម្មាធិការមជ្ឈិមខ្លះ ដូចជា អៀង សារី និង សុន សេន ដែលជា អ្នកទទួលខុសត្រូវនៅភូមិភាគឦសានផ្ទាល់ ហាក់មិនសូវចង់សហការជាមួយពួកវៀតកុង-វៀតណាមខាងជើង ប៉ុន្មានទេ ។

ក្នុងខែឧសភា ឆ្នាំ១៩៧០ សាឡុត ស និងសមមិត្តគាត់មួយចំនួនធ្វើដំណើរត្រលប់មកប្រទេសកម្ពុជា វិញ តាមផ្លូវលំហូ ជីមិញ។ ពេលនោះ សឺង ង៉ុកមិញ និងកែវមាស មិនបានរួមដំណើរមកជាមួយទេ ព្រោះត្រូវសាឡុត ស ចាត់តាំងឱ្យនៅរៀបចំកម្លាំងតស៊ូប្រឆាំងបារាំង ដែលចាកចេញពីប្រទេសក្រោយសន្និសីទក្រុងហ្សឺណែវ មករស់នៅវៀតណាមខាងជើង តាំងពីឆ្នាំ១៩៥៤ ឱ្យវិលត្រលប់ទៅរួមចំណែកតស៊ូវាយរម្ងំពួកក្បត់លន់ នល់ នៅក្នុងប្រទេសវិញ និងនៅរៀបចំស្ថានីយវិទ្យុផ្សាយសំឡេងរបស់រណសិរ្សរួបរួមជាតិកម្ពុជា ផងដែរ ។

នៅតាមផ្លូវលំហូ ជីមិញ សាឡុត ស ឃើញរថយន្តកាំមីញ៉ុងធំៗរបស់កងទ័ពវៀតណាមខាងជើង រាប់រយគ្រឿងដឹកអាវុធយុទ្ធភណ្ឌគ្រាប់រំសេវ និងសម្ភារសឹកផ្សេងៗទៀត កាត់តាមព្រៃភ្នំយ៉ាងគគ្រឹកគគ្រេង។ ជួនកាល គាត់ និងសមមិត្តរួមដំណើរ បាននាំគ្នាឡើងជិះលើរថយន្តកាមីញ៉ុងមួយគ្រឿង ក្នុងចំណោមរថយន្តទាំងអស់នោះទៀតផង។ ជួនកាលពួកគាត់នាំគ្នាដើរដោយថ្មើរជើងរាប់សិបគីឡូម៉ែត្រ កាត់ជ្រោះជ្រងជ្រលងដងអូរ ប្រឈមនឹងជំងឺគ្រុនចាញ់ ដើម្បីបំបាំងខ្លួននៅក្នុងព្រៃភ្នំ កុំឱ្យយន្តហោះអាមេរិក មើលឃើញ អាចពួកវាទម្លាក់គ្រាប់បែកពីលើ។ ពួកគាត់ត្រូវបោះជំរំស្នាក់នៅរាប់សិបកន្លែង ហើយនៅកន្លែងខ្លះ ពួកវៀតណាម បានយកដំរីជាច្រើនក្បាល មកដឹកជញ្ជូនពួកគាត់ទៀតផង ។

នៅពេលធ្វើដំណើរនោះសាឡុត ស ធ្លាក់ខ្លួនមានជំងឺគ្រុនចាញ់ម្តង និងម្តងទៀត គាត់ធ្លាក់ខ្លួនឈឺ ដោយសារការពុលផ្សិតដុះក្នុងព្រៃ ដែលសមមិត្តគាត់ដកយកមកស្ងោឱ្យទទួលទាន ។

នៅក្នុងខែឧសភា នោះដែរ ឧត្តមសេនីយ៍ មិញ បេសកជនពិសេសរបស់វៀតកុង-វៀតណាមខាងជើង បានទៅជួបពិភាក្សាគ្នាជាមួយ អៀង សារី នៅក្នុងព្រៃនៃភូមិភាគឦសាន បន្តទៀត។ ពេលនោះ បេសកជនពិសេសរបស់វៀតកុង-វៀតណាមខាងជើងរូបនេះ បានជំរុញឱ្យមានការបង្កើតមេបញ្ជាការរួមគ្នានៅតាមអង្គភាពនីមួយៗ ដូចកាលសម័យតស៊ូបណ្តេញពួកអាណានិគមបារាំង ដែរ ។

ជាមួយគ្នានេះ ភាគីវៀតណាម សន្យាថា នឹងជួយបង្កើតមន្ទីរពេទ្យមួយ ដែលមានគ្រែអ្នកជំងឺ២០០ ព្រមទាំងបុគ្គលិកពេទ្យ និងសម្ភារបរិក្ខារគ្រប់បែបយ៉ាងទៀតផង ។ អៀង សារី បានយល់ព្រមធ្វើតាមសំណើរបស់វៀតណាម នេះដែរ តែត្រូវរង់ចាំការឯកភាពពីសាឡុត ស សិន។ ប៉ុន្មានថ្ងៃក្រោយមក ឧត្តមសេនីយ៍ មិញ បានធ្វើដំណើរត្រលប់ទៅទីក្រុងហាណូយ វិញ ។

នៅតាមផ្លូវលំហូ ជីមិញ ឧត្តមសេនីយ៍ មិញ ក៏បានជួបសាឡុត ស កំពុងធ្វើដំណើរត្រលប់មកប្រទេសកម្ពុជា វិញដែរ។ ពេលនោះ ឧត្តមសេនីយ៍ មិញ ប្រាប់ទៅសាឡុត ស ថា អៀង សារី បានយល់ព្រមធ្វើតាមសំណើរបស់វៀតណាមហើយ តែត្រូវរង់ចាំតែការឯកភាពពីសមមិត្តប៉ុណ្ណោះ។ ប៉ុន្តែ សាឡុត ស នៅតែមិនឆ្លើយ ព្រោះគាត់មិនចង់ធ្វើរណបរបស់វៀតណាម ដូចមេដឹកនាំតស៊ូសម័យប្រឆាំងបារាំង ទៀត ។

ឧត្តមសេនីយ៍ មិញ ចេះតែទទូចសំណើនោះដដែលៗ រហូតដល់ក្រុមអង្គរក្សវៀតណាមខាងជើង ដែលជាអ្នកអមការពារដំណើរសាឡុត ស ពីក្រុងហាណូយមកនោះ ហាមឃាត់ លែងឱ្យរំខានសាឡុត ស ទៀត ទើបគេនៅស្ងៀម ។

តែទោះបីយ៉ាងនេះក៏ដោយ ពួកគេនៅតែមិនអស់ចិត្ត ក៏បានធ្វើដំណើរត្រលប់មកកម្ពុជាវិញជាមួយ សាឡុត ស ម្តងទៀត ។

បន្ទាប់ពីធ្វើដំណើរចេញពីក្រុងហាណូយ តាមផ្លូវលំហូជីមិញ អស់រយៈពេលប្រមាណ៦សប្ដាហ៍ សាឡុ ស បានមកដល់មន្ទីរមជ្ឈិមបក្ស( មន្ទីរ១០២) នៅក្នុងព្រៃនៃខេត្តរតនគិរី វិញ នៅក្នុងខែមិថុនា ឆ្នាំ១៩៧០ ។ គាត់បានជួបពិភាក្សាជាមួយអៀង សារី ពីបញ្ហាស្នើសុំរបស់មេដឹកនាំវៀតណាម ឱ្យមានការបង្កើតមេបញ្ជាការរួមគ្នានោះ ។

នៅទីបំផុត សាឡុត ស ក៏បានយល់ព្រមទទួលយកការជួយឧបត្ថម្ភគាំទ្រពីពួកមេដឹកនាំវៀតណាម ពិសេសគឺ យល់ព្រមបង្កើតកងឯកភាពចម្រុះគ្នា ( វៀតណាម-កម្ពុជា)និងយល់ព្រមទទួលជំនួយគ្រប់បែបយ៉ាងពីពួកកុម្មុយនិស្តវៀតណាម ព្រោះបើមិនដូច្នេះទេ គាត់គ្មានសមត្ថភាពអាចផ្តួលរម្លំរដ្ឋាភិបាលលន់ នល់ បានឡើយ ។

ក្រោយពីមកដល់មន្ទីរ១០២ ( មន្ទីរមជ្ឈិមបក្ស) មិនបានប៉ុន្មានថ្ងៃផង សាឡុត ស ក៏បានចាត់តាំងឱ្យ អៀង សារី ជាតំណាងគណៈមជ្ឈិមបក្ស ឱ្យទៅគ្រប់គ្រងដឹកនាំស្ថានីយវិទ្យុផ្សាយសំឡេងរបស់រណសិរ្សរួបរួមជាតិកម្ពុជា ដែលទើបបង្កើតថ្មីនៅទីក្រុងហាណូយ ។

នៅក្រុងហាណូយ សឺង ង៉ុកមិញ និងកែវ មាស បានអញ្ជើញអតីតខ្មែរឥស្សរៈទាំងអស់ ដែលបានចាកចេញពីប្រទេស ក្រោយពីមានកិច្ចព្រមព្រៀងក្រុងហ្សឺណែវ ឆ្នាំ១៩៥៤ មកប្រជុំផ្សព្វផ្សាយពីការវិវត្តនយោបាយនៅក្នុងប្រទេសកម្ពុជា និងឱ្យពួកគេរៀបដំណើរវិលត្រលប់ទៅមាតុប្រទេសវិញ ដើម្បីប្រយុទ្ធតស៊ូជាមួយពួកចក្រពត្តិអាមេរិក និងពួកអាយ៉ងលន់ នល់ ក្រោមការដឹកនាំរបស់បក្សកុម្មុយនិស្តនៅក្នុងប្រទេស ។

អតីតខ្មែរឥស្សរៈនៅក្រុងហាណូយ ទាំងអស់នោះ ត្រូវបានបែងចែកជាច្រើនកងអនុសេនាធំ ដោយក្នុងមួយកងៗ មានគ្នាប្រមាណ១០០នាក់ ហើយត្រូវចេញដំណើរម្តងមួយកងៗ តាមផ្លូវលំហូ ជីមិញ ដោយត្រូវរងការយាយីពីជំងឺគ្រុនចាញ់ និងការទម្លាក់គ្រាប់បែករបស់អាមេរិក ។

ទម្រាំធ្វើដំណើរមកដល់មាតុប្រទេសវិញ កងអនុសេនាធំខ្លះ នៅសល់គ្នាតែ៨០ ឬ៩០នាក់ ប៉ុណ្ណោះ ។

ពេលមកដល់មាតុភូមិកំណើត មេដឹកនាំខ្មែរក្រហមនៅក្នុងប្រទេស បានទទួលស្វាគមន៍ និងសម្តែងការកោតសរសើរចំពោះអតីតពួកខ្មែរ-វៀតមិញទាំងនោះថា ជាអ្នកមានការអប់រំ និងមានវិន័យល្អ ហើយថាក្នុងកាលៈទេសៈនេះ ពួកអ្នកតស៊ូនៅក្នុងស្រុក ត្រូវការកម្លាំងពួកអ្នកតស៊ូមកពីវៀតណាមភាគខាងជើង គឺជាការចាំបាច់បំផុត។ ប៉ុន្តែ មានខ្មែរទើបមកពីក្រុងហាណូយ ខ្លះ បាននិយាយថា ពេលមកដល់ដំបូង ពួកមេដឹកនាំមេខ្មែរក្រហមនៅក្នុងប្រទេស បានស្នើឱ្យពួកគេធ្វើលិខិត និងចុះហត្ថលេខាសុំផ្លាស់ប្តូរសមាជិកភាពពីបក្សប្រជាជនបដិវត្តន៍ខ្មែរ ឬបក្សពលករ វៀតណាម មកជាសមាជិកបក្សកុម្មុយនិស្តកម្ពុជា វិញ ។

លាវ កែវមុនី អតីតប្រធានគណៈកម្មាធិការខ្មែរសាងជាតិ (KNLC) របស់ចលនាខ្មែរឥស្សរៈ និងជាបក្ខជនរបស់បក្សកុម្មុយនិស្តឥណ្ឌូចិន តាំងពីទសវត្សរ៍ឆ្នាំ១៩៤០ នោះ ពេលត្រលប់មកតស៊ូនៅក្នុងប្រទេសវិញ ត្រូវបានចាត់តាំងឱ្យធ្វើជាប្រធានគណៈកម្មាធិការស្រុកមួយនៅក្នុងខេត្តសៀមរាប ។ សម័យនោះគេប្រើពាក្យជាផ្លូវការថាប្រធានគណៈកម្មាធិការបម្រើប្រជាជនស្រុក។ ប្រជាជននៅតំបន់នោះ ធ្លាប់ស្គាល់លាវ កែវមុនី តាំងពីសម័យខ្មែរឥស្សរៈប្រឆាំងនឹងបារាំង មកម៉្លេះ ។

លាវ កែវមុនី បានធ្វើដំណើរចូលតំបន់អសន្តិសុខជាច្រើនកន្លែង ដើម្បីឃោសនាពន្យល់ប្រាប់ប្រជាជន ពីការធ្វើបដិវត្តន៍រំដោះទឹកដី និងលុបបំបាត់ការជិះជាន់សង្កត់សង្កិន ហើយថាសម្តេចសីហនុ នឹងត្រលប់មកដឹកនាំមាតុប្រទេសឱ្យសម្បូរធូរធារដូចពីមុនវិញ។ ជាមួយគ្នានោះ គាត់ក៏ឃោសនាបំផុសឱ្យស្រទាប់យុវជនស្ម័គ្រចិត្តចូលបម្រើក្នុងជួរកងទ័ពផងដែរ។ បន្ទាប់ពីការឃោសនារបស់គាត់មក យុវជនជាកូនចៅអ្នកស្រុក ក៏បាននាំគ្នាស្ម័គ្រចិត្តចូលបម្រើជួរកងទ័ពរណសិរ្សរួបរួមជាតិកម្ពុជា កាន់តែច្រើនឡើងៗ ។

មិនថា នៅក្នុងភូមិសាស្ត្រស្រុក ដែលលាវ កែវមុនី ជាអ្នកដឹកនាំគ្រប់គ្រងនោះទេ ទោះបីនៅតាមបណ្ដាស្រុកផ្សេងៗទៀតទូទាំងប្រទេស ប្រជាកសិករភាគច្រើនជឿជាក់លើកងទ័ពរណសិរ្សរួបរួមជាតិកម្ពុជា ព្រោះដឹងថា មានសម្ដេចសីហនុ ជាមេដឹកនាំ និងឃើញកងទ័ពនោះមានសីលធម៌ និងវិន័យល្អបំផុត សូម្បីពេលពួកគេបេះផ្លៃឈើរបស់ប្រជាជនមួយផ្លែ ដែលមិនមានម្ចាស់នៅក្បែរដើមឈើនោះមកទទួលទាន ក៏ពួកគេដាក់លុយនៅនឹងគល់ឈើនោះទុកឱ្យម្ចាស់ដែរ ។

ចំណែកកងទ័ពវៀតកុង-វៀតណាមខាងជើង គឺរឹតតែមានសីលធម៌ និងវិន័យល្អជាងកងទ័ពរណសិរ្សរួបរួមជាតិកម្ពុជា ទៅទៀត។ ពេលពួកគេបោះទីតាំងនៅក្នុងភូមិណាមួយហើយ ពួកគេមិនធ្វើឱ្យអ្នកភូមិទាស់ចិត្តបន្តិចឡើយ។ ពួកគេក្រោកពីព្រឹកបោសសម្អាតទីធ្លាផ្ទះ រែកទឹកដាក់ពាងឱ្យអ្នកភូមិ និងជួយងូតទឹកដុសក្អែលឱ្យក្មេងៗតូចៗ ដែលជាកូនចៅអ្នកភូមិនោះ ទៀតផង ។

ដោយឡែក បើនិយាយពីសមរភូមិប្រយុទ្ធវិញ ពួកវៀតកុង-វៀតណាមខាងជើងតែងតែនាំមុខបើកការវាយប្រហារទៅលើទីតាំងឈរជើងរបស់ទាហានរដ្ឋាភិបាល លន់ នល់ ហើយអាវុធ ដែលវាយដណ្ដើមបានពីពួកទាហាន លន់ នល់ ទាំងប៉ុន្មានពួកគេបានយកមកបំពាក់ឱ្យកងទ័ពរណសិរ្សរួបរួមជាតិកម្ពុជា ទាំងអស់ ។

ពេលណាចាប់បានទាហានលន់ នល់ ពួកគេមិនវាយធ្វើបាបអ្វីទាំងអស់ គឺគ្រាន់តែអប់រំថា ឱ្យឈប់ធ្វើទាហានក្បត់ទៀតទៅ រួចហើយ ពួកវៀតកុង-វៀតណាមខាងជើង ដោះលែងឱ្យវិលត្រលប់ទៅជួបជុំក្រុមគ្រួសារវិញ ។

រ័ត្ន សាមឿន អតីតៈនិស្សិតមកពីប្រទេសបារាំង និងជាអតីតៈមេខ្មែរឥស្សរៈដ៏ល្បីល្បាញម្នាក់ដែរនោះ ពេលត្រលប់មកដល់មាតុប្រទេសវិញ ត្រូវបានចាត់តាំងឱ្យធ្វើជាកម្មាភិបាលទំនាក់ទំនងជាមួយពួកកុម្មុយនិស្តលាវ និងពួកវៀតកុង-វៀតណាមខាងជើង ។

ចំណែក តាំង សារីម ដែលមកពីក្រុងហាណូយ ដែរនោះ ត្រូវបានចាត់តាំងឱ្យ

ធ្វើលេខាបក្សស្រុកមួយនៅក្នុងភូមិភាគឧត្តរ។ គាត់ខិតខំបង្កើតសាខាបក្ស នៅក្នុងជួរកងទ័ព នៅក្នុងជួរមហាជន និងនៅតាមមូលដ្ឋានភូមិ ឃុំ ព្រមទាំងខិតខំឃោសនាអប់រំពីមាគ៌ាបដិវត្តន៍ទៀតផង ។

នៅចុងឆ្នាំ១៩៧០ គាត់ត្រូវបានចាត់តាំងជាសមាជិកគណៈកម្មាធិការបក្សតំបន់៤២ ភូមិភាគឧត្តរ ។

សមមិត្តគាត់២នាក់ទៀត ដែលមកពីក្រុងហាណូយ ជាមួយគ្នាដែរនោះ ក៏ត្រូវបានចាត់តាំងជាកម្មាភិបាលតំបន់ ទទួលខុសត្រូវក្នុងការចាត់តាំងសមាសភាពគណៈកម្មការភូមិនានា ដែលទើបរំដោះបាន និងជាអ្នកបង្ហាត់បង្រៀនកងទ័ពថ្មី នៅស្រុកបារាយណ៍ ។

នៅភូមិភាគបូព៌ា យន់ សឿន អតីតនិស្សិតនៅប្រទេសបារាំងជាមួយសាឡុត ស ដែរនោះ ត្រូវបានចាត់តាំងជាអនុលេខាគណៈកម្មាធិការបក្សតំបន់២២ ។

កម្មាភិបាលមកពីហាណូយ ម្នាក់ទៀតឈ្មោះសូ គុំ ត្រូវបានតែងតាំងជាលេខាគណៈកម្មាធិការបក្សតំបន់២៥ រួមមានស្រុកកៀនស្វាយ ស្រុកលើកដែក ស្រុកស្អាង និងស្រុកកោះធំ ដែលពេលនោះតំបន់២៥ ស្ថិតនៅក្រោមចំណុះភូមិភាគបូព៌ា ។

យស់ ប៉ោ ត្រូវបានចាត់តាំងជាសមាជិកគណៈកម្មាធិការបក្សតំបន់៣៥ (ខេត្តកំពត) ភូមិភាគនិរតី។ ញ៉ែម ស៊ុន អតីតមេបញ្ជាការផ្ទាល់របស់ប៉ែន សុវណ្ណ កាលសម័យតស៊ូខ្មែរឥស្សរៈនៅភូមិភាគនិរតី បានមកបម្រើការងារនៅក្នុងមន្ទីររបស់គណៈកម្មាធិការមជ្ឈិមបក្ស ដែលនៅក្បែរស្ទឹងជីនិត ក្នុងភូមិភាគឧត្តរ ។

ចំណែក ប៉ែន សុវណ្ណ បម្រើការងារនៅស្ថានីយវិទ្យុរណសិរ្សរួបរួមជាតិកម្ពុជា នៅក្រុងហាណូយ។ ប៉ុន្តែ ទោះបីយ៉ាងណា អ្នកតស៊ូមកពីក្រុងហាណូយជាច្រើនទៀត ដែលបានចូលបម្រើនៅក្នុងជួរកងទ័ពរាប់ទាំងក្មួយប្រុស២នាក់របស់សោ ភឹម លេខាបក្សភូមិភាគបូព៌ា ផងដែរ មេដឹកនាំខ្មែរក្រហមនៅក្នុងស្រុក ឱ្យធ្វើត្រឹមតែជាមេបញ្ជាការកងអនុសេនាតូច ឬកងអនុសេនាធំប៉ុណ្ណោះ ។

អៀង លឹម ជាកម្មាភិបាលតស៊ូម្នាក់ ធ្លាប់ជាគ្រូបង្ហាត់ក្បួនយុទ្ធសាស្ត្រនៅវៀតណាមខាងជើង និងអតីតខ្មែរឥស្សរៈមកពីក្រុងហាណូយ ៦នាក់ទៀត ត្រូវបានថ្នាក់លើបញ្ជូនមកឱ្យធ្វើការជាមួយតាំង សារីម នៅតំបន់២២ ភូមិភាគឧត្តរ។ អៀង លឹម ពិនិត្យឃើញថា មេដឹកនាំខ្មែរក្រហម នៅក្នុងប្រទេសមិនទុកចិត្តកងទ័ពវៀតកុង-វៀតណាមខាងជើង និងពួកគាត់ជាអ្នកតស៊ូខ្មែរ ដែលមកពីក្រុងហាណូយទេ។ ប៉ុន្តែ ក្នុងចំណោមពួកគាត់មកពីហាណូយចំនួន៨២២នាក់ មានពាក់កណ្តាលបានក្លាយទៅជាបក្ខជនរបស់បក្សកុម្មុយនិស្តកម្ពុជា នៅក្នុងឆ្នាំ១៩៧០នោះដែរ ហើយជាទូទៅ នៅតាមស្រុកនីមួយៗ យ៉ាងហោចណាស់ ក៏មានពួកគាត់២នាក់ ត្រូវបានចាត់តាំងឱ្យធ្វើជាកម្មាភិបាលដឹកនាំដែរ។ តែអ្វីដែលគួរឱ្យកត់សម្គាល់ផងដែរនោះ គឺអ្នកដែលមានតួនាទីសំខាន់ៗកាលនៅក្នុងសម័យតស៊ូប្រឆាំងបារាំង ដូចជា លាវ កែវមុនី, កែវ មុនី, ម៉ី ផូ, យុន សឿន និងរ័ត្ន សាមឿន ជាដើម ក៏គ្មាននរណាម្នាក់ទទួលបានតួនាទីសំខាន់ៗឡើយ ។

នៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ១៩៧១ អៀង លឹម បានសម្រេចចិត្តរត់មកចុះចូលជាមួយទាហាននៃរបបសាធារណរដ្ឋខ្មែរ និងបានរៀបរាប់ពីមូលហេតុនៃការចុះចូលនោះថា ពួកខ្មែរកុម្មុយនិស្តនៅក្នុងស្រុកបារាយណ៍ តំបន់២២ បានសម្លាប់ប្រជាជនតាមអំពើចិត្ត ដោយសារតែមានកំហុសបន្តិចបន្តួចប៉ុណ្ណោះ ហើយរូបគាត់ផ្ទាល់បានប្រាប់ទៅពួកគេកុំឱ្យសម្លាប់ប្រជាជន ព្រោះតែមានកំហុសបន្តិចបន្តួចដូច្នេះ ។

អៀង លឹម យល់ឃើញថា សង្គ្រាមនៅពេលនោះ បានចំណេញតែនៅខាងបដិវត្តន៍វៀតណាម មិនមែនបានចំណេញមកខាងបដិវត្តន៍កម្ពុជាទេ ដូច្នេះហើយទើបគាត់សម្រេចចិត្តមកចុះចូលជាមួយទាហានរដ្ឋាភិបាលសាធារណរដ្ឋខ្មែរ វិញ ។

ជាមួយគ្នានោះដែរ ក៏មានព័ត៌មានស្តីពីមេដឹកនាំខ្មែរក្រហមបានរៀបចំឱ្យប្រជាជននៅតំបន់រំដោះធ្វើបាតុកម្មប្រឆាំងនឹងកងទ័ពវៀតកុង- វៀតណាមខាងជើង ចំនួន៧កន្លែងក្នុងភូមិភាគឧត្តរ និង៧កន្លែងទៀតនៅក្នុងភូមិភាគបូព៌ា ។

ចំណែកនៅភូមិភាគនិរតី វិញ នៅក្នុងតំបន់១៣ ដែលមាន មាស មុត ឬសមមិត្ត មុត ( កូនប្រសាតាម៉ុក) ជាអនុលេខាបក្សតំបន់នោះ នៅក្នុងឆ្នាំ១៩៧១ ពួកសេអ៊ីអា ក៏បានទទួលព័ត៌មានថា មានការវាយប្រយុទ្ធគ្នារវាងកងទ័ពខ្មែរក្រហម និងវៀតកុង-វៀតណាមខាងជើង ដែរ ។

នៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៧១ ដោយសារឃើញកម្មាភិបាល ដែលមកពីក្រុងហាណូយជាច្រើន ត្រូវបានពួកខ្មែរក្រហមប្រើល្បិចយកទៅសម្លាប់ចោលជាបន្តបន្ទាប់ នោះ អតីតអ្នកតស៊ូខ្មែរឥស្សរៈមកពីក្រុងហាណូយម្នាក់ជាមេបញ្ជាការយោធាស្រុក មួយ នៅក្នុងតំបន់១៣នោះ ក៏បានសម្រេចចិត្តរត់ទៅចុះចូលជាមួយទាហានរបស់រដ្ឋាភិបាលលន់ នល់ ដូចអៀង លឹម នៅតំបន់៤២ ដែរ ។

តាំងពីឆ្នាំចុង១៩៧០ មកម្ល៉េះ ពួកខ្មែរក្រហមបានប្រើល្បិចហៅពួកកម្មាភិបាល ស្រុក, កម្មាភិបាលតំបន់នានា ដែលជាអតីតអ្នកតស៊ូមកពីហាណូយ ឱ្យទៅរៀនសូត្រ រួចយកទៅសម្លាប់ចោលជាបណ្តើរៗ។ ប៉ុន្តែ មានកម្មាភិបាលមួយចំនួនតូចប៉ុណ្ណោះ ដែលដឹងខ្លួនទាន់ពេលវេលា ហើយរត់ទៅចុះចូលជាមួយទាហានរដ្ឋាភិបាល ឬរត់ទៅ នៅអង្គភាពវៀតកុង-វៀតណាមខាងជើង វិញ ។

បើតាមសេនានុព័ន្ធយោធាប្រចាំស្ថានទូតអាមេរិក នៅក្រុងភ្នំពេញ ឈ្មោះ ខេណេត្ហ គ្វីន ( Keneth Quinn ) បានឱ្យដឹងថា នៅឆ្នាំ១៩៧១ នៅក្នុងតំបន់៣៥ នៅ ភូមិភាគនិរតី ពួកមេដឹកនាំខ្មែរក្រហម លែងនិយាយពីការតស៊ូយកសម្តេចសីហនុ មកកាន់អំណាចទៀតហើយ ។

នៅភូមិភាគនិរតី នោះដែរ ពួកខ្មែរក្រហម និយាយតែពីដំណាក់កាលដំបូង នៃ ការធ្វើបដិវត្តប្រជាជាតិប្រជាធិបតេយ្យ ហើយបានបំផុសប្រជាជនឱ្យនាំគ្នាធ្វើបាតុកម្ម បណ្តេញកងទ័ពវៀតកុង-វៀតណាមខាងជើង ឱ្យចាកចេញពីទឹកដីកម្ពុជា ។

នៅចុងខែមីនា ឆ្នាំ១៩៧០ មានសិស្ស និងគ្រូនៅទីក្រុងភ្នំពេញ ជាង៥០នាក់ ដែលស្ម័គ្រចិត្តរត់ចូលព្រៃម៉ាគី ត្រូវបានគេបញ្ជូនទៅដល់ទីរួមខេត្តក្រចេះ ដែលកង

វៀតកុង-វៀតណាមខាងជើង រំដោះបានភ្លាមៗ ក្រោយព្រឹត្តិការណ៍រដ្ឋប្រហារថ្ងៃ១៨ មីនា ។ នៅក្នុងទីរួមខេត្តនេះ គេពុំឃើញមានកងទ័ពខ្មែរក្រហមទេគឺមានតែកងទ័ពវៀតកុង មួយកងវរសេនាធំមានពាក់ព្រះឆាយាលក្ខណ៍សម្តេចសីហនុ ប៉ុណ្ណោះ ។

ពេលនោះពួកវៀតកុង បានចាត់តាំងប្រជាជនខ្មែរ ដែលចេះនិយាយភាសាវៀតណាម ឱ្យកាន់តំណែងផ្សេងៗជាច្រើន តាមសភាពជាក់ស្តែង។ ប្រជាជនខ្មែរក្មេងចាស់ប្រុសស្រី រួមទាំងព្រះសង្ឃផងដែរ មានទឹកចិត្តសប្បាយរីករាយចំពោះវត្តមានកងទ័ពវៀតកុង ដែលមកជួយធ្វើសង្គ្រាមដណ្តើមអំណាចទៅថ្វាយសម្តេចសីហនុ ជាទីគោរពស្រឡាញ់របស់ពួកគេវិញ ហើយពួកគេតែងនាំគ្នាយកបាយសម្ល ទៅឱ្យកងទ័ពវៀតកុងទាំងអស់នោះ ដោយចិត្តរីករាយស្មោះសរ ។

នៅក្នុងក្រុងក្រចេះ ក្រុមសិស្ស និងគ្រូបង្រៀនជាង៥០នាក់ ដែលចេញពីទីក្រុងភ្នំពេញ នោះ ត្រូវបានគេឱ្យស្នាក់នៅក្នុងសណ្ឋាគារមួយ ខណៈដែលជីវភាពរស់នៅរបស់ប្រជាជននៅទីនោះមានសភាពជាធម្មតា ពោលគឺមានផ្សារលក់ដូរ មានភោជនីយដ្ឋាន និងមានសិទ្ធិសេរីភាពដើរហើរ និយាយស្តី ដូចមុនពេលមានរដ្ឋប្រហារដែរ ។

ខេត្តក្រចេះនេះ ត្រូវពួកមេដឹកនាំខ្មែរក្រហមឱ្យឈ្មោះថា តំបន់៥០៥ និងមានអតីតសាស្ត្រាចារ្យម្នាក់ នៅ វិទ្យាល័យអង្គឌួង( ខេត្តព្រៃវែង) ពីឆ្នាំ១៩៦៧-១៩៦៨ ឈ្មោះទីវ អុល ជាអ្នកទទួលខុសត្រូវ ។

ប្រហែល ២ខែក្រោយមក សិស្ស និងគ្រូ ដែលជាអ្នកស្ម័គ្រចិត្តចូលរួមចលនាតស៊ូក្នុងព្រៃម៉ាគី ទាំងជាង៥០នាក់នោះ ត្រូវចេញដំណើរទៅស្នាក់នៅក្នុងតំបន់ព្រៃក្រាស់មួយ ដែលជាប់ព្រំដែនរវាងខេត្តក្រចេះ និងខេត្តកំពង់ធំ ដើម្បីហាត់រៀនក្បួនយុទ្ធសាស្ត្រ ដោយមានកម្មាភិបាលកងទ័ពវៀតកុង ជាអ្នកបង្ហាត់បង្រៀន និងមានការបែងចែកជាក្រុមៗ ដោយក្នុងមួយក្រុមៗមានគ្នា១២នាក់ ។

ក្រៅពីហាត់រៀនក្បួនយុទ្ធសាស្ត្រ ក៏មានការប្រជុំជីវភាពប្រចាំថ្ងៃ និងរៀនភាសាវៀតណាម ហើយពួកវៀតកុង នៅទីនោះ ក៏បានឱ្យពួកគេជួយបង្រៀនភាសាខ្មែរ វិញ

ផងដែរ ។

ក្រោយមក ក្នុងចំណោមសិស្ស និងគ្រូបង្រៀនជាង៥០នាក់នោះ មាន៤០នាក់ត្រូវបានបញ្ជូនឱ្យទៅសមរភូមិតាំងគោក នៅតាមបណ្ដោយផ្លូវជាតិលេខ៦ ក្នុងខេត្តកំពង់ធំ ដើម្បីវាយប្រយុទ្ធគ្នាជាមួយទាហានលន់ នល់ បើកប្រតិបត្តិការសឹកមួយ ឈ្មោះថាចេនឡាទី១ ក្នុងខែកញ្ញា ឆ្នាំ១៩៧០។

ដោយឡែក អតីតមេដឹកនាំកំពូលពួកខ្មែរឥស្សរៈ ដែលស្និទ្ធនឹងពួកវៀតមិញកាលសម័យតស៊ូប្រឆាំងបារាំង ម្នាក់ទៀត ឈ្មោះស៊ីវ ហេង ជាឪពុកមាសាច់ថ្លៃរបស់នួន ជា ដែលបោះបង់ការតស៊ូ ហើយវិលត្រលប់មករស់នៅជួបជុំក្រុមគ្រួសារធ្វើស្រែចម្ការនៅភូមិវត្តគរ ស្រុកសង្កែ ខេត្តបាត់ដំបង តាំងពីឆ្នាំ១៩៥៨ នោះ មិនបានរត់ចូលព្រៃទៅតស៊ូជាមួយសមមិត្តជាអតីតពួកកុម្មុយនិស្តជាមួយគ្នាពីមុនមកទេ។ ផ្ទុយទៅវិញ គាត់បានចូលបម្រើនៅក្នុងជួរទាហានរដ្ឋាភិបាលលន់ នល់ និងទទួលបានឋានន្តរស័ក្តិជាវរសេនីយ៍ត្រី នៅបន្ទាយសឹករង់ស្រុកសិរីសោភ័ណ ។

ចំណែក កោគ ឆាយ ដែលសម្ដេចសីហនុ តែងតាំងឱ្យធ្វើជាអគ្គនាយកក្រុមហ៊ុនសូណាព្រីម( SONAPRIM ) ពីឆ្នាំ១៩៦៦ ហើយក្រោយមក គាត់បានចូលរួមតស៊ូជាកម្លាំងបង្កប់របស់ពួកខ្មែរក្រហម នៅទីក្រុងភ្នំពេញ និងត្រូវតុលាការសឹកផ្ដន្ទាទោសឱ្យជាប់ពន្ធនាគារព្រៃសដែរនោះ ក៏បានរត់ចេញពីក្រុងភ្នំពេញ ទៅចូលរួមតស៊ូបន្តទៀតនៅភូមិភាគនិរតី។ ប៉ុន្មានខែក្រោយមក កោគ ឆាយ ក៏ត្រូវបានចាត់តាំងជាប្រធាននយោបាយរបស់អង្គភាពយោធាភូមិភាគនិរតី ។

---

# ២៨៨
# កាំង ហ្កេចអ៊ាវ រួចពីគុកព្រៃស រត់ទៅតស៊ូបន្តទៀត



កាំង ហ្កេចអ៊ាវ ហៅឌុច

កាំង ហ្កេចអ៊ាវ ដែលជាសាស្ត្រាចារ្យនៅអនុវិទ្យាល័យបល្ល័ង្ក ស្រុកបារាយណ៍ ខេត្តកំពង់ធំ និងជាសកម្មជនរបស់ពួកខ្មែរក្រហម ដែលត្រូវប៉ូលិសរបស់សម្តេចសីហនុ ចាប់យកទៅដាក់ពន្ធនាគារព្រៃស ក្នុងឆ្នាំ១៩៦៧ ហើយត្រូវបានរដ្ឋាភិបាលលន់ នល់ ដោះលែងឱ្យមានសេរីភាពវិញ ក្រោយរដ្ឋប្រហារថ្ងៃទី១៨ ខែមីនានោះ ក៏បានធ្វើដំណើរទៅជួបម្តាយឪពុកបងប្អូននៅស្រុកកំណើត ឯខេត្តកំពង់ធំ មួយរយៈខ្លីក៏រត់ទៅចូលព្រៃតស៊ូធ្វើបដិវត្តន៍បន្តទៀត នៅក្នុងតំបន់ ២៥ ជាទឹកដី ដែលកងទ័ពវៀតកុង-វៀតណាមខាងជើង ជួយវាយរំដោះបានពីពួកទាហានលន់ នល់ ។

កាំង ហ្កេចអ៊ាវ បានរម្លឹកថា ក្រោយពីសម្តេចសីហនុ ប្រកាសបង្កើតរណសិរ្សរួបរួមជាតិកម្ពុជា និងប្រកាសអំពាវនាវឱ្យប្រជារាស្ត្រខ្មែររត់ចូលព្រៃម៉ាគី ដើម្បីរួមគ្នាតស៊ូធ្វើសង្គ្រាមប្រឆាំងនឹងពួកក្បត់លន់ នល់ មក កងទ័ពវៀតកុង-វៀតណាមខាងជើង ដែលកំពុងធ្វើសង្គ្រាមជាមួយពួកទាហានរដ្ឋការវៀតណាមខាងត្បូង នៅក្នុងខេត្តអាងយ៉ាង ( ពួកវៀតកុងហៅថា តំបន់៦២) បានចូលមករំដោះតំបន់២៥នេះ ស្ទើរតែទាំងស្រុងទៅហើយ លើកលែងតែនៅតាម បណ្តោយផ្លូវជាតិលេខ១ ពីក្រុងភ្នំពេញ ទៅ

ទីប្រជុំជនអ្នកលឿង ក្នុងភូមិសាស្រ្តស្រុកកៀនស្វាយ និងស្រុកលើកដែក ពួកទាហាន លន់ នល់ នៅទប់ទល់ការពារកាន់កាប់នៅឡើយ ។

ពេលកងទ័ពវៀតកុង-វៀតណាមខាងជើង ចូលមករំដោះបានតំបន់២៥នេះភ្លាម ពួកគេបានចាត់តាំងរដ្ឋអំណាចមួយដឹកនាំដោយជនជាតិវៀតណាមម្នាក់ឈ្មោះ ហាយ ផាយ តែប្រើឈ្មោះខ្មែរថា ទេព ផាន ។

ប្រជាជនខ្មែរ ដែលស្ម័គ្រចិត្តរត់ចូលព្រៃម៉ាគី ដើម្បីធ្វើកងទ័ពតស៊ូតាមការអំពាវនាវរបស់សម្តេចសីហនុ ទាំងប៉ុន្មាន ក៏ស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋអំណាចវៀតណាម នោះដែរ ។

នៅតាមស្រុកនីមួយៗ មានកងទ័ព ១កងអនុសេនាធំ តែជ័យកណ្តុ ដែលវាយបានពីពួកទាហានលន់ នល់ ទាំងប៉ុន្មាន ត្រូវដឹកយកទៅខេត្តអាងយ៉ាង (វៀតណាមខាងត្បូង) ទាំងអស់។ ពេលនោះដែរ អ្នកតស៊ូដែលចេញពីក្រុងភ្នំពេញ ទាំងអស់ ពួកវៀតណាមនៅទីនោះ មិនចាត់តាំងឱ្យបំពេញការងារអ្វីឡើយ។ មិនតែប៉ុណ្ណោះ ពួកគេបានចាប់អ្នកតស៊ូដែលចេញពីក្រុងភ្នំពេញ ឈ្មោះសែប ឆាន ហៅឆយ ហៅសុវណ្ណ និងចាប់ឈ្មោះហួន គៀ ហៅ សម្បត្តិ យកទៅឃុំឃាំងទៀតផង ។

កាលនោះតំបន់២៥ ស្ថិតនៅក្នុងភូមិភាគបូព៌ា ជាតំបន់សម្បូរធនធានធម្មជាតិ ប្រជាជនមានជីវភាពធូរធារ អាចប្រមូលប្រាក់ពន្ធដារបានច្រើន ដូច្នេះ មេដឹកនាំជាជនជាតិវៀតណាមឈ្មោះទេព ផាន នោះ មិនចង់ប្រគល់រដ្ឋអំណាចមកឲ្យខ្មែរគ្រប់គ្រងទេ។ រហូតដល់ខែធ្នូ ឆ្នាំ១៩៧០ ទើបពួកគេព្រមប្រគល់រដ្ឋអំណាចឲ្យអ្នកតស៊ូខ្មែរ។

តែរដ្ឋអំណាចខ្មែរនៅទីនោះ ក៏មានខ្សែរយៈខុសគ្នាដែរ គឺខ្សែរយៈសុខ ប៊ុតចំរើន និងខ្សែរយៈចេញពីភ្នំពេញ មិនត្រូវគ្នាឡើយ។ ដូច្នេះ គាត់ក៏នៅតែអត់ការងារធ្វើដដែល ។

កាំង ហ្កេចអ៊ាវ បានបន្តថា ក្រោយមក គេបានចាត់តាំងគាត់ឲ្យទៅបង្រៀនឯកសារនយោបាយសង្រ្គាមប្រជាជន, យុទ្ធវិធីសង្រ្គាមឈ្លប និងសីលធម៌ជនបដិវត្ត ព្រមទាំងគោលនយោបាយមួយចំនួនរបស់បក្ស ដល់ពួកកងទ័ពដែលទើបនឹងជ្រើស

រើសបានមកពីតាមស្រុកនានា ។

រហូតដល់ខែឧសភា ឆ្នាំ១៩៧១ គាត់បានទាក់ទងជាមួយប្រធានសេនាធិការកងទ័ពតំបន់២៥ សុំទៅនៅភូមិភាគពិសេស ដែលទើបបង្កើតថ្មី ដើម្បីមករកវន វ៉េត ជាមេដឹកនាំចាស់របស់គាត់កាលតស៊ូនយោបាយនៅភ្នំពេញ ។

ភូមិភាគពិសេស ដែលពួកខ្មែរក្រហមបង្កើតថ្មីនេះ ដឹកនាំដោយវន វ៉េត ក្នុងបំណងបង្កើនការការវាយសម្រុកទៅលើទីក្រុងភ្នំពេញ ឱ្យកាន់តែខ្លាំងក្លាថែមទៀត ។

ភូមិភាគពិសេស ត្រូវបានកាត់យកតំបន់២៥ របស់ភូមិភាគបូព៌ារួមជាមួយ តំបន់៣១ និងតំបន់១៥ របស់ភូមិភាគនិរតី។ តែយ៉ាងណា ក៏មេដឹកនាំភូមិភាគពិសេស និងមេដឹកនាំភូមិភាគនិរតី បានសហការគ្នាយ៉ាងជិតស្និទ្ធខាងផ្នែកសន្តិសុខ និងការវាយប្រហារទៅលើទាហានលន់ នល់ ដែលជាខ្សែក្រវាត់ការពារទីក្រុងភ្នំពេញ ។

ដោយសារកាំង ហ្កេចអ៊ាវ ធ្លាប់ជាប់ពន្ធនាគារពីឆ្នាំ១៩៦៧ ដល់ឆ្នាំ១៩៧០នោះ ក្រោយពីបានជួបវន វ៉េត គាត់ត្រូវបានចាត់តាំងឲ្យធ្វើជាប្រធានមន្ទីរសន្តិសុខ ម.១៣ នៅអមលាំងស្រុកថ្ពង ខេត្តកំពង់ស្ពឺ ។

កាំង ហ្កេចអ៊ាវ បានរម្លឹកថា មុនបង្កើតភូមិភាគពិសេស តាម៉ុក បានបែងចែកវណ្ណៈភាពអ្នកតស៊ូជាមួយគ្នាតឹងតែងណាស់។ គាត់មិនឱ្យពួកអនុជន ដែលចេញពីទីក្រុងភ្នំពេញដឹកនាំកងទ័ព និងដឹកនាំរដ្ឋអំណាចមូលដ្ឋានទេ សូម្បីត្រឹមថ្នាក់ឃុំ ថ្នាក់ស្រុក ក៏មិនឲ្យដឹកនាំដែរ ។

មិនតែប៉ុណ្ណោះ មានអ្នកតស៊ូមានវណ្ណភាពជាអនុជន ( សាស្ត្រាចារ្យ) ៤នាក់គឺ ខែក ប៉ែន( ប៊ុន), កែ គឹមហួត, ជា ហួន និងអ៊ំ ឈឿន ត្រូវតាម៉ុក បណ្តេញចេញពីភូមិភាគនិរតី ក្នុងរយៈពេល២៤ម៉ោង។ តែត្រូវបាន ប៉ុល ពត សម្រួលយកអ្នកទាំង៤នាក់នេះឱ្យទៅនៅខាងភូមិភាគពាយ័ព្យ វិញ ។

អ្នកតស៊ូមានវណ្ណភាពជាអនុជនផ្សេងៗទៀត ត្រូវតាម៉ុក បញ្ឈរជើងចោល អត់ឱ្យធ្វើការអ្វីទាំងអស់ ។

*អនុជនម្នាក់ ឈ្មោះផ្លួន អេង ជាវិស្វករចេញពីទីក្រុងភ្នំពេញ ខឹងតាម៉ុក ខ្លាំងណាស់។ តែមិនហ៊ានតបតអ្វី ក្រៅតែមិននិយាយស្តីអ្វីទាំងអស់។ តាម៉ុក សួរស្អី ក៏មិននិយាយតបវិញ ។ គាត់ថា គាត់គ្រុន។*

*នៅពេលនោះដែរ បើឃើញនរណាអានសៀវភៅ តាម៉ុក តែងនិយាយថា ធ្វើស្រែស៊ីស្រូវ មើលសៀវភៅស៊ីក្រដាស។*

*កាំង ហ្កេចអ៊ាវ បានបញ្ជាក់ថា លេខាភូមិភាគនិរតី ដំបូង ឈ្មោះម៉ា ម៉ង។ តែនៅឆ្នាំ១៩៦៨  ឈ្មោះម៉ា ម៉ង ត្រូវបាត់បង់ជីវិតនៅលើភ្នំឱរ៉ាល់ ដោយសារពេទ្យចាក់ថ្នាំប្រទ្បំ ហើយពេទ្យនោះត្រូវបានគេយកទៅសម្លាប់ចោលដែរ ដោយចោទថា មានបំណងសម្លាប់លេខាភូមិភាគនិរតីឈ្មោះ ម៉ា ម៉ង នោះ ។*

---

# ២៨៩
# សោ ភឹម សហការជាមួយពួកវៀតកុង ធ្វើសង្គ្រាមជាមួយ ទាហានអាមេរិក និងរដ្ឋការក្រុងព្រៃនគរ



សោ ភឹម លេខាគណៈកម្មាធិការបក្សភូមិភាគបូព៌ា

ក្រោយពីមានរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ សោ ភឹម លេខាគណៈកម្មាធិការបក្សភូមិភាគបូព៌ា ក៏បានប្រជុំកម្មាភិបាលតំបន់ និងកម្មាភិបាលស្រុកប្រមាណ ១០០នាក់នៅក្នុងព្រៃ នៃទឹកដីភូមិត្នោត ដែលស្ថិតនៅក្នុងទឹកដី ខេត្តតៃនិញ ប្រទេសវៀតណាមខាងត្បូង ។

នៅក្នុងអង្គប្រជុំនោះ សោ ភឹម បានលើកឡើងពីសភាពការណ៍របស់ប្រទេសជាតិ ពិសេសគឺបញ្ហាធ្វើរដ្ឋប្រហារទម្លាក់សម្តេចសីហនុ និងដាក់ផែនការឱ្យកម្មាភិបាលតំបន់ និងស្រុក ចាប់ផ្តើមប្រយុទ្ធតស៊ូកសាងមូលដ្ឋានបដិវត្តន៍ ។

ដំបូង បើទោះបីកងទ័ពវៀតកុង-វៀតណាមខាងជើង បានស្នើសុំ សោ ភឹម ដើម្បីបើកការវាយប្រហារទៅលើពួកទាហានលន់ នល់ នៅក្នុងភូមិភាគបូព៌ា ក៏ពិតមែន តែ សោ ភឹម គ្រាន់តែចង់បានជំនួយជាគ្រឿងអាវុធយុទ្ធភណ្ឌ តែប៉ុណ្ណោះ។ ប៉ុន្តែ មេដឹកនាំវៀតកុង-វៀតណាមខាងជើង ប្រាប់ថា បើគ្មានជំនួយពីកងទ័ពរបស់ពួកគេទេ កម្ពុជាក៏មិនអាចមានលទ្ធភាពរំដោះប្រទេសពីពួកលន់ នល់ បានឡើយ ។

នៅទីបំផុត កម្លាំងតស៊ូនៅភូមិភាគបូព៌ា ក៏បានសហការគ្នាយ៉ាងជិតស្និទ្ធបំផុតជាមួយពួកវៀតកុង-វៀតណាមខាងជើង ក្នុងការធ្វើសង្គ្រាមជាមួយទាហានរដ្ឋាភិបាល លន់ នល់ និងទាហានរដ្ឋការក្រុងព្រៃនគរ ផងដែរ ។

កងទ័ពបូព៌ា និងកងទ័ពវៀតកុង-វៀតណាមខាងជើង សហការគ្នាវាយដណ្តើមទីតាំងឈរជើងរបស់ពួកទាហានលន់ នល់ ទទួលបានជោគជ័យនៅគ្រប់សមរភូមិ ហើយអាវុធដែលរឹបអូសបានពីពួកទាហានលន់ នល់ ទាំងប៉ុន្មាន ពួកវៀតណាមបានប្រគល់ឱ្យកងទ័ពខ្មែរតស៊ូ ដែលកំពុងតែកើនច្រើនឡើងៗ ។



ពួកខ្មែរក្រហម ឃោសនាឱ្យប្រជាជនចូលរួមក្នុងការតស៊ូធ្វើសង្គ្រាមផ្តួលរម្លំរបបលន់ នល់

ជាមួយនឹងការវាយដណ្តើមទីតាំងឈរជើងរបស់ពួកទាហានលន់ នល់ នោះដែរ កងទ័ពវៀតកុង-វៀតណាម ខាងជើង និងពួកកម្មាភិបាលតស៊ូរបស់ពួកខ្មែរក្រហម បានសហការគ្នាយ៉ាងស្អិតល្មួត ដើម្បីកសាងរដ្ឋអំណាចបដិវត្តន៍នៅតាមមូលដ្ឋានភូមិឃុំនានា ដោយឃោសនាថា ពួកគេជាអ្នកស្មោះត្រង់ជាមួយសម្តេច សីហនុ តស៊ូប្រឆាំងជាមួយពួកចក្រពត្តិអាមេរិក និងពួកអាយ៉ង លន់ នល់ ដើម្បីសម្តេច សីហនុ និងបានបើកសិទ្ធិឱ្យប្រជាជនជ្រើសរើសថ្នាក់ដឹកនាំភូមិ និងថ្នាក់ដឹកនាំឃុំ ដោយខ្លួនឯងតាមតាមបែបប្រជាធិបតេយ្យ។ ប៉ុន្តែ នេះគ្រាន់តែជាសម្បកក្រៅប៉ុណ្ណោះ ។

ប្រសិនបើអ្នកជាប់ឆ្នោតជាគណៈកម្មការភូមិ និងគណៈកម្មាធិការឃុំ ណាម្នាក់ប្រព្រឹត្តអំពើអ្វីមួយដែលផ្ទុយពីមាគ៌ាដឹកនាំបក្សកុម្មុយនិស្តកម្ពុជា ដែលហៅថាអង្គការនោះ នឹងត្រូវគេដកចេញពីតំណែងវិញភ្លាម ។

នៅថ្ងៃទី០១ ខែឧសភា ឆ្នាំ១៩៧០ គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកិច្ចការស៊ីវិល របស់ពួកវៀតកុង បានចេញសេចក្តីណែនាំមួយ ចំពោះពួកកម្មាភិបាលពួកគេ ដែលកំពុងសហការគ្នាជាមួយពួកខ្មែរក្រហមនៅក្នុងប្រទេសកម្ពុជា ថា សកម្មភាពរឹតត្បិតទៅលើប្រជាជនកម្ពុជា ណាមួយ ត្រូវតែធ្វើដោយមានការព្រមព្រៀងរវាងសាខាបក្សរបស់យើង និងសាខាបក្សកម្ពុជា ហើយក្នុងកាលៈទេសៈណាក៏ដោយ កម្មាភិបាលរបស់យើង មិនត្រូវធ្វើកិច្ចការនេះជំនួសកម្ពុជា ឬក៏ធ្វើដោយខ្លួនឯងផ្ទាល់ដែរ ។



យុវជនយុវនារីនៅតំបន់ជនបទ ស្ម័គ្រចិត្តចូលបម្រើកងទ័ពរណសិរ្សរួបរួមជាតិកម្ពុជា

តែទោះបីយ៉ាងណា ក៏ពួកកម្មាភិបាលវៀតណាម បានជួយឱ្យអ្នកតស៊ូដែលមានគំនិតសីហនុនិយមមួយចំនួន បានកាន់តំណែងជាគណៈកម្មការភូមិ និងគណៈកម្មាធិការឃុំ នៅក្នុងតំបន់ ដែលពួកគេរំដោះបាននោះដែរ ព្រោះពួកកម្មាភិបាលវៀតណាម យល់ថាពួកសីហនុនិយមទាំងអស់នោះ នៅតែស្ថិតនៅក្រោមការគ្រប់គ្រងរបស់ពួកខ្មែរក្រហមដដែលជាមិនខាន ។

នៅក្នុងឯកសារមួយ ដែលពួកទាហានលន់ នល់ រឹបអូសបានពីពួកវៀតកុង-វៀតណាមខាងជើង បានសរសេរថា បក្សកម្ពុជា ជាមិត្តរបស់យើងមានបទពិសោធល្អក្នុងការតស៊ូ និងបានសហការយ៉ាងជិតស្និទ្ធបំផុតជាមួយបក្សយើង ក្នុងការកម្ចាត់សត្រូវ។ ប៉ុន្តែប្រជាជនខ្មែរភាគច្រើនគាំទ្រសម្ដេចសីហនុ ហើយពួកសីហនុនិយមទាំងអស់នោះបានហៅខ្លួនឯងថា ខ្មែររំដោះ គឺមិនមែនពួកខ្មែរក្រហមទេ។ ប៉ុន្តែបក្សយើងមានគំនិតផ្សេងទៅវិញ ។

តាមរបាយការណ៍ភ្នាក់ងារស៊ើបការណ៍សម្ងាត់របស់រដ្ឋាភិបាលលន់ នល់ បានឱ្យដឹងថា ពួកសីហនុនិយមជាអ្នកដឹកនាំ ឃុំមួយចំនួន បានឃោសនាប្រាប់ប្រជាជនក្នុងឃុំរបស់ខ្លួនថា ពួកគេធ្វើការតស៊ូដើម្បីនាំយកសម្ដេចសីហនុ មកដឹកនាំប្រទេសវិញ ហើយពួកវៀតកុង-វៀតណាមខាងជើង ក៏បានចែកផ្លាកសញ្ញារូបសម្ដេចសីហនុ តូចៗឱ្យគណៈ កម្មាធិការឃុំទាំងអស់នោះ ពាក់នៅនឹងអាវទៀតផង។ ប៉ុន្តែក្រោយមក ពួកកម្មាភិបាលខ្មែរក្រហម ចូលមកដល់ឃុំនោះ ក៏បានបាញ់សម្លាប់គណៈកម្មាធិការឃុំនោះចោលអស់ ដោយចោទថា សុទ្ធតែជាពួកក្បត់ ។

នេះបង្ហាញឱ្យឃើញពីការចាប់ផ្ដើមពង្រឹងពង្រីករដ្ឋអំណាចបដិវត្តរបស់ពួកខ្មែរក្រហម ហើយរណសិរ្សរួបរួមជាតិ ដែលមានសម្ដេចសីហនុ ជាប្រធាននោះ គឺគ្រាន់តែជាល្បែងនយោបាយមួយប៉ុណ្ណោះ ។

---

**សូមរង់ចាំអានភាគ៧ បន្តទៀត**

**សូមអរគុណ**

# ឯកសារយោង៖

1. Le Cambodge de Sihanouk Espoir, Désillusions et Amertume. par Richard Sola .
2. Le mal Cambodge Histoire D'une société traditionnelle Face à ses Leaders Politiques 1946 – 1987. par Marie Alexandrine Martin .
3. Pol Pot Frère Numéro Un. par Davidp – Chandler.
4.Les Lames du Cambodge L'histoire D'un Auto Genocide. par Elizabeth Becker .
5. Le Cambodge dans la tourmente: Le troisième conflit indochinois, 1978-1991. par Nicolus Regaud .
6. Cambodge : Rêves et Réalités. par Vandy Kaonn.
7. Histoire du Cambodge 1863 – 1992. par Vandy Kaonn .
8. Cambodia: Year Zero by Francois Ponchaud
9. Hun Sen strongman of Cambodia. by Harrish C. Metha Julie B. metha.
10. When the War Was Over by Elizabeth Becker
11. How Pol Pot to come Power. By Ben Kiernan .
12. Wikipedia The free encyclopedia .
13. Wikipedia Org. wiki.
14. DP. Pedia org. page.
15.Wikiwand.
16. U.S. Embassy in Cambodia document.
17. Cold war international history Project.
18. The New York Times newspaper.
19. Times Magazine.
20. The Far Eastern Economic Review Magazine.
21. Le Figaro newspaper.
22. Le Monde newspaper.
23. Les Echos newspaper.
24. Le Parisien newspaper.

25. L′ humanite newspaper.
26. Liberation newspaper.
27. Washington Post newspaper.
28. Pol Pot by Philip Short.
29. The Gate by Francois Bizot.
30. Haing Ngor: A Cambodian Odyssey by Haing S. Ngor with Roger Warner.
31. My War With the CIA by Norodom Sihanouk .
32. War and Hope: The Case for Cambodia by Norodom Sihanouk .
33. Flying Tigers Over Cambodia by Larry Partridge.
34. The United States and Cambodia, 1870-1969 By Kenton Clymer.
35 .L′histoire terrible mais inachevée de Norodom Sihanouk, roi du Cambodge (THEATRE) (French Edition).
36. Souvenir doux et amers  par Norodom Sihanouk.
37. គុកនយោបាយ ដោយ ប៊ុណ្ណ ចន្ទម៉ុល.
38. ឧត្តមគតិ លោកអៀវ កើស ដោយ ង៉ែត ហៀង.
39. លោកព្រឹទ្ធាចារ្យ បណ្ឌិតជួន មុម្ម ដោយបណ្ឌិតពុទ្រី ទត់.
40. ជីវប្រវត្តិសង្ខេប ប៉ែន សុវណ្ណ និងបុព្វហេតុជាតិមាតុភូមិកម្ពុជា ដោយប៉ែន សុវណ្ណ និងនាង សារ៉ុន.
41. Des racines dans lapierre par Sam raingsy
42. ខ្មែរអ្នកជាតិនិយម ដោយឡឹក សំអឿន ហៅផ្កាយព្រឹក
43. The one who was shot

# ជីវប្រវត្តិសង្ខេប



រូបថត ឆ្នាំ១៩៨៥



រូបថត បច្ចុប្បន្ន

១- នាម និងគោត្តនាម ឈឹម សេរីភួន ( Chhim Sereyphuon ) ភេទប្រុស សញ្ជាតិខ្មែរ ។

២- ថ្ងៃ ខែ ឆ្នាំកំណើត ថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩៥៤ ។

៣- ទីកន្លែងកំណើត ភូមិស្រម៉ជ្រំ សង្កាត់សង្ឃ័រ ក្រុងស្វាយរៀង ខេត្តស្វាយរៀង ។

៤- កម្រឹតវប្បធម៌ ថ្នាក់ទីបញ្ចប់ ឆ្នាំសិក្សា១៩៧៤-១៩៧៥ ។

៥- ឪពុកឈ្មោះ ឈឹម ប៉ាវ មានស្រុកកំណើតនៅភូមិព្រៃខ្នុរ ឃុំព្រៃរំដេង ស្រុកមេសាង ខេត្តព្រៃវែង មុខរបរមុនឆ្នាំ១៩៧៥ ជាកម្មករផ្នែកថែសួនច្បារនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ស្លាប់ក្នុងរបបប៉ុល ពត ។

៦- ម្ដាយឈ្មោះ ទេព ឌុន មានស្រុកកំណើតភូមិស្រម៉ជ្រំ សង្កាត់សង្ឃ័រ ក្រុងស្វាយរៀង ខេត្តស្វាយរៀង មុខរបរជាមេផ្ទះ ស្លាប់ក្នុងរបបប៉ុល ពត ។

៧- មានបង៣នាក់( ស្រី១ប្រុស២ ) និងប្អូន៣នាក់( ស្រី២ប្រុស១ ) ស្លាប់ក្នុងរបបប៉ុល ពត ទាំងអស់ ។

៨- ការសិក្សា៖

- ឆ្នាំ១៩៦២-៦៣ ចូលរៀនថ្នាក់ទី១២ សាលាបឋមសិក្សាឯកជនសង្គមមានជ័យ (នៅម៉ុំខាងក្រោយសាលាបច្ចេកទេស ថៃទាំវេជ្ជសាស្ត្រ សព្វថ្ងៃ) ។

- ឆ្នាំ១៩៦៣-១៩៦៩ រៀននៅសាលាបឋមសិក្សាចង្ក្រានតាព្រហ្មមានជ័យ (វត្តស្ទឹងមានជ័យ) ។

- ឆ្នាំ១៩៦៩-១៩៧៤ រៀននៅវិទ្យាល័យឥន្ទ្រទេវី (វិទ្យាល័យទួលគោក) ។

- ឆ្នាំ១៩៧៤-១៩៧៥ រៀនថ្នាក់ទីបញ្ចប់ផ្នែកទស្សនវិជ្ជា នៅវិទ្យាល័យកែវ សង់គីម (វិទ្យាល័យ១៨ មីនា ១៩៧០ ឬ វិទ្យាល័យព្រះយុគន្ធរ) ។

- ក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ត្រូវជម្លៀសជាមួយក្រុមគ្រួសារទៅរស់នៅក្នុងសង្កាត់

ព្រៃរំដេង ស្រុកមេសាង តំបន់២០ ភូមិភាគបូព៌ា ។

- ដើមឆ្នាំ១៩៧៦ ត្រូវជម្លៀសបន្តតែម្នាក់ឯង ទៅរស់នៅក្នុងសង្កាត់តាប្រ៉ុក ស្រុកចម្ការលើ តំបន់៤២ ភូមិភាគឧត្តរ ហើយត្រូវពួកខ្មែរក្រហមបញ្ចូលជាកងចល័តតំបន់៤២ រស់នៅលំបាកវេទនារហូតដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ។

- ក្រោយថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ទើបដឹងថា ឪពុកម្ដាយ និងបងប្អូនបង្កើតទាំង៦នាក់ ព្រមទាំងក្មួយៗប្រមាណ១០នាក់ទៀត ត្រូវពួកខ្មែរក្រហមប៉ុល ពត សម្លាប់ចោលទាំងអស់ កាលក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ នៅរស់តែរូបខ្ញុំបាទម្នាក់ប៉ុណ្ណោះ។

៩- ប្រវត្តិការងារ៖

- ពីឆ្នាំ១៩៧៩-១៩៨៤ ជានាយកអប់រំឃុំព្រៃរំដេង ស្រុកមេសាង ខេត្តព្រៃវែង ។

- ពីឆ្នាំ១៩៨៤-១៩៨៥ ជាអនុប្រធានការិយាល័យអប់រំស្រុកមេសាង ខេត្តព្រៃវែង ។

- ពីឆ្នាំ១៩៨៥-១៩៨៦ ជាប្រធានការិយាល័យឃោសនាការ វប្បធម៌ និងព័ត៌មានស្រុកមេសាង ។

- ពីឆ្នាំ១៩៨៦-១៩៨៧ ជាលេខាបក្សឃុំត្រពាំងស្រែ ស្រុកមេសាង ខេត្តព្រៃវែង ។

- ពីឆ្នាំ១៩៨៧-១៩៩៣ ជាប្រធានមន្ទីរគណៈកម្មាធិការបក្សស្រុកមេសាង និងជាសមាជិកគណៈកម្មាធិការបក្សស្រុកមេសាង ខេត្តព្រៃវែង ។

- ដើមឆ្នាំ១៩៩៣ ជាជំនួយការមន្ត្រីរៀបចំការបោះឆ្នោតអាជ្ញាធរបណ្ដោះអាសន្នរបស់អង្គការសហប្រជាជាតិ(UNTAC) ប្រចាំស្រុកមេសាង ខេត្តព្រៃវែង ។

- ឆ្នាំ១៩៩៤ ជាមន្ត្រីនគរបាលនៅនាយកដ្ឋានជនបរទេស អគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ។

- ពីឆ្នាំ១៩៩៥ ដល់ឆ្នាំ២០២២៖ ជាអ្នកនិពន្ធអត្ថបទវិភាគនយោបាយ វិចារណកថា បទបរិយាយ ឱ្យកាសែតចក្រវាឡ, កាសែតអរិយធម៌, កាសែតសំឡេងនិស្សិត, ទស្សនាវដ្ដី កងរាជអាវុធហត្ថរាជធានីភ្នំពេញ ។

ជានិពន្ធនាយកទស្សនាវដ្ដីអង្គរធំ, ជានិពន្ធនាយកទស្សនាវដ្ដីខេមរា, ជានិពន្ធនាយកទស្សនាវដ្ដីសោភ័ណ, ជានិពន្ធនាយករងទស្សនាវដ្ដីរថយន្ត, ជាទីប្រឹក្សាកាសែតនគរធំ, ជានិពន្ធនាយកគេហទំព័រTVFB, ជានិពន្ធនាយកគេហទំព័រKBN និងជាប្រធានផ្នែកព័ត៌មានជាតិគេហទំព័រSBM News និងជាអ្នកសិក្សាស្រាវជ្រាវឯកសារប្រវត្តិសាស្ត្ររបត់នយោបាយ ។

- ពីឆ្នាំ២០២២ ដល់ឆ្នាំ២០២៣៖ ជាទីប្រឹក្សាក្រសួងមហាផ្ទៃ ឋានៈស្មើអនុរដ្ឋលេខាធិការ ។

- ពីថ្ងៃទី១ ខែមីនា ឆ្នាំ២០២៣ ៖ ជាអនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ ។

UNITED NATIONS
UNITED NATIONS TRANSITIONAL
AUTHORITY IN CAMBODIA
(UNTAC)

NATIONS UNIES
AUTORITE PROVISOIRE DES NATIONS
UNIES AU CAMBODGE
(APRONUC)

CERTIFICATE OF OUTSTANDING SERVICE

This certifies that Mr. Chhim Sery Phuon worked with UNTAC Electoral Component at the District of Mesang for more than eight months at different capacities. Initially, he was recruited as a Registration Team Leader (RTL) for four months. As he extraordinarily completed his contract as RTL, his contract was extended for two more months as Senior Election Assistant (SEA). Finally, after the completion of his contract as SEA, he was re-employed as a Presiding Officer for UNTAC Election in May 1993 in Combodia.

As a RTL, Mr. Chhim worked out Training Manual in Khemer, Trained the Local Staff about Registration Process and was a Team Leader of Eight other Registration Teams. I was really impressed with Mr. Chhim's training capabilities. Because of his fine training skill, we had no complains from the higher authorities regarding registration, despite complex and long procedures. His profound ability to teach others was also reflected during civic education campaign. He trained all the assistants for civic education regarding Paris Peace Agreement, UNTAC Electoral Law, Human Rights etc. so well that 99.3 % people turned over to express their opinion during the Election. He was the best PO in respect of due completion of all the technicalities during the election.

I am very much impressed of his originality, managerial skill and sincerity at work. In brief, he is a multidimensional personality with whom every one would love to work. I give him my highest regards and wish every success in his future assignments.

Sincerely,

H. Prasad

Hari Prasad, DES
Mesang, Prey Veng
COMBODIA

June 7, '93

# លិខិតថ្លែងអំណរគុណ



សៀវភៅ ដែលមានចំណងជើងថា **របត់នយោបាយ** ត្រូវបានបោះពុម្ពជាសៀវភៅ តាំងពីភាគទី១ រហូតដល់ភាគទី៦នេះ ស្របតាមបំណងប្រាថ្នាប្រកបដោយគតិបណ្ឌិត និងមនសិការប្រវត្តិសាស្ត្រជាតិដ៏ខ្ពង់ខ្ពស់របស់ **សម្តេចក្រឡាហោម ស ខេង** ដើម្បីទុកជាឯកសារប្រវត្តិសាស្ត្រដ៏ពិស្តារមួយ ឲ្យយុវជនសម័យបច្ចុប្បន្ននេះ ក៏ដូចជាកូនចៅជំនាន់ក្រោយៗទៀត បានស្រាវជ្រាវសិក្សាត្រិះរិះពិចារណាពីព្រឹត្តិការណ៍នយោបាយសំខាន់ៗ ដែលកើតមានឡើងតាំងពីសម័យអាណានិគមបារាំងមក។

ប្រសិនបើគ្មានការជួយឧបត្ថម្ភគាំទ្រពី **សម្តេចក្រឡាហោម** ទេនោះក៏គ្មានវត្តមានសៀវភៅប្រវត្តិសាស្ត្រដ៏មានសារសំខាន់នេះដែរ។

ខ្ញុំបាទសូមលំឱនកាយគោរពថ្លែងអំណរគុណ និងសូមប្រសិទ្ធពរជ័យជូន **សម្តេចក្រឡាហោម ស ខេង** សូមមានសុខភាពល្អបរិបូរណ៍ អាយុយឺនយូរ បញ្ញាញាណភ្លឺថ្លា ទទួលបានមហាជោគជ័យគ្រប់ភារកិច្ច។

សូម **សម្តេច** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ

**ឈឹម សេរីវុទ្ធ**